វិទ្យាស្ថានជាតិអប់រំ

## ឯកទេស

# សីលធម៌ពលរដ្ឋវិជ្ជា



សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២)

២០២៦

# បុព្វកថា

ទស្សនៈវិស័យអប់រំនាសតវត្សរ៍ទី២១ បានផ្តោតលើការរីកចម្រើនខ្លាំងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងឌីជីថល (Digital) ដែលជាមូលដ្ឋានគ្រឹះរឹងមាំមួយយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសគឺការអភិវឌ្ឍធនធានមនុស្សដើម្បីឆ្ពោះទៅរកគំនិតនវានុវត្តន៍ថ្មីៗ សម្រាប់បម្រើឱ្យសេចក្តីត្រូវការរបស់សង្គមជាតិទាំងមូល។ ដោយសារនិន្នាការពិភពលោក ដែលមានការអភិវឌ្ឍឥតឈប់ឈរ ទើបរាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព។

ឈរលើស្មារតីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ បានដាក់ចេញនូវគោលដៅជាអាទិភាពសម្រាប់ការធ្វើកំណែទម្រង់វិស័យអប់រំដោយផ្អែកលើ សសរស្តម្ភទាំងប្រាំរួមមាន៖ ១. ការអនុវត្តគោលនយោបាយគ្រូបង្រៀន ២.ការវាយតម្លៃ ៣.ការងារអធិការកិច្ច ៤. កម្មវិធីសិក្សា និងបរិស្ថាន ៥.ឧត្តមសិក្សា។ ដោយឡែក កំណែទម្រង់គ្រូបង្រៀន និងកម្មវិធីសិក្សាជានាឱ្យកម្ពុជាមានធនធានមនុស្ស ដែលមានសមត្ថភាពសម្រាប់ដំណើរការអភិវឌ្ឍលើគ្រប់វិស័យ។ ក្រសួងអប់រំ យុវជន និងកីឡាបានកែលម្អកម្មវិធីសិក្សាគ្រប់មុខវិជ្ជា នៅគ្រប់កម្រិតគ្រប់ភូមិសិក្សារហូតដល់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ពលកម្ម ផលប្រយោជន៍របស់អ្នកសិក្សា និងកាន់តែធ្វើឱ្យប្រសើរឡើង នូវគុណភាពអប់រំ ក្នុងគោលបំណងឆ្លើយតបទៅនឹងការវិវឌ្ឍរបស់ពិភពលោក និងគោលដៅយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

សៀវភៅសិក្សាគោលនេះ ត្រូវបានកសាងឡើងដោយគ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ ដើម្បីកសាងឧត្តមភាពគុណវុឌ្ឍគ្រូបង្រៀន ទៅតាមទស្សនៈ និងចក្ខុវិស័យថ្មី ជាមួយនឹងខ្លឹមសារបែបវិទ្យាសាស្ត្រ បែបបញ្ញត្តិសិក្សា និងបញ្ចូលគុណសម្បទាសតវត្សរ៍ទី២១ បន្ថែមទៅលើគុណសម្បទាពលរដ្ឋសកល។

វិទ្យាស្ថានជាតិអប់រំសង្ឃឹមថា គ្រប់ស្ថាប័នអប់រំ ស្ថាប័នពាក់ព័ន្ធ និងអ្នកមានចំណាប់អារម្មណ៍ទាំងអស់ចូលរួមគាំទ្រ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា អនុវត្តលើ កម្មវិធីបណ្តុះបណ្តាលនេះ ដើម្បីពង្រឹងសក្តានុពលរបស់គ្រូបង្រៀននៅគ្រប់កម្រិតសិក្សាទាំងអស់ ដើម្បីអភិវឌ្ឍជំនាញវិជ្ជាជីវៈជាគ្រូបង្រៀនឱ្យកាន់តែល្អប្រសើរឡើង។

វិទ្យាស្ថានជាតិអប់រំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះ គណៈកម្មការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត និងប្រាជ្ញាធ្វើឱ្យស្នាដៃដ៏មានសារៈសំខាន់នេះ សម្រេចបានដើម្បីជាប្រយោជន៍ដល់សង្គមជាតិយើង។

ថ្ងៃ ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៥

**នាយកវិទ្យាស្ថានជាតិអប់រំ**

# អារម្ភកថា

សៀវភៅសិក្សាគោលឯកទេសសីលធម៌ពលរដ្ឋវិជ្ជា ជាកម្រងឯកសារគោលសម្រាប់ផ្ដល់ចំណេះដឹងសំខាន់ៗមានលក្ខណៈវិទ្យាសាស្រ្តសម្រាប់គរុនិស្សិតសិក្សាស្រាវជ្រាវ។ ក្រុមគ្រូឧទ្ទេសសីលធម៌ពលរដ្ឋវិជ្ជានៃវិទ្យាស្ថានជាតិអប់រំបានចងក្រងវណ្ណកម្មនេះយ៉ាងយកចិត្តទុកដាក់សម្រាប់គរុនិស្សិតឯកទេសទសីលធម៌ពលរដ្ឋបរិញ្ញាបត្រ+២ ដើម្បីសិក្សាកាន់តែស៊ីជម្រៅទៅលើជំនាញឯកទេសរបស់ខ្លួន។ ខ្លឹមដែលត្រូវបានសម្រិតសម្រាំងដ៏ពិសិដ្ឋនេះ រួមមាន ពុទ្ធិទូទៅដែលទាក់ទងនឹងទស្សនវិជ្ជា ច្បាប់ សីលធម៌ គុណធម៌ របៀបនៃការអប់រំ ការបង្រៀននិងការរៀន ទ្រឹស្តីនានា ជាពិសេសរបៀបនៃការបង្កើតពុទ្ធិ។ សៀវភៅនេះជាផ្នែកដ៏សំខាន់សម្រាប់អ្នកសិក្សាក្នុងការទទួលបានពុទ្ធិដ៏ទូលំទូលាយ និងមានប្រយោជន៍សម្រាប់សង្គមជាតិក៏ដូចជាពិភពលោកទាំងមូល។

នៅក្នុងសៀវភៅសិក្សាគោលនេះ ត្រូវបានរៀបចំជា៤ជំពូក មាន២៧មេរៀន។ ជំពូកទី១ ស្រាវជ្រាវមជ្ឈមសិក្សាទុតិយភូមិដោយពិភាក្សាអំពីគុណធម៌ ការទទួលខុសត្រូវរបស់មនុស្សនៅក្នុងសង្គមទាំងផ្នែកសីលវិជ្ជា និងផ្នែកច្បាប់, សិទ្ធិសេរីភាព និងយុត្តិធម៌សង្គម។ នៅជំពូកទី២ សិក្សាពីគំនិតសង្គមនយោបាយរបស់ទស្សនវិទូមួយចំនួន។ នៅក្នុងជំពូកនេះក៏និយាយពីគំនិតនៃការគ្រប់គ្រងរដ្ឋ និងការផ្តល់យុត្តិធម៌ សេរីភាព របស់មនុស្សនៅសម័យកាលនីមួយៗ និងពិភាក្សាពីគុណតម្លៃរបស់មេដឹកនាំដើម្បីធ្វើឱ្យសង្គមមានយុត្តិធម៌។ ជំពូកទី៣ រៀបរាប់លម្អិតពីទ្រឹស្តីពុទ្ធិដោយត្រិះរិះថា តើមនុស្សទទួលបានពុទ្ធិដោយរបៀបណា? នៅក្នុងជំពូកទី៤ ពន្យល់លម្អិតអំពីតួនាទីនៃការអប់រំនៅក្នុងសង្គម, តួនាទីគ្រូ និងកម្មវិធីសិក្សារបស់ទ្រឹស្តីនៃការអប់រំធំៗមួយចំនួនដូចជា លោក អូហ្គូស្ទីន, ឌេស៊ីឌេរីអ៊ូស, អេរ៉ាស្មូស, ខូមេនៀស, ស្តីណូហ្សា, ហេហ្គេល និង ម៉ាតទីម័រ អាដល័រ។

យើងខ្ញុំជាអ្នករៀបរៀង សង្ឃឹមយ៉ាងមុតមាំថាគរុនិស្សិតទាំងអស់នឹងបន្តខិតខំឈ្វេងយល់បន្ថែមទៀតទៅលើចំណេះដឹងថ្មីៗ និងប្រកបដោយសច្ចភាព ដើម្បីខ្លួនឯងមានចំណេះដឹងទូលំទូលាយ និងអាចលើកស្ទួយ និងពង្រឹងគុណភាពអប់រំរបស់យើងឱ្យកាន់តែប្រសើរឡើងថែមទៀត។

**ក្រុមគ្រូឧទ្ទេសសីលធម៌ពលរដ្ឋវិជ្ជានៃវិទ្យាស្ថានជាតិអប់រំ**

ចងក្រង និងបោះពុម្ពដោយៈ វិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០២៦
គាំទ្រថវិកាដោយវិទ្យាស្ថានជាតិអប់រំ
© វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៦

## គណៈកម្មការនិពន្ធ

-លោក ប្រាក់ ពៅ
-លោក ផ្លុង គួន
-លោក ឃិន វណ្ណី

## គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

-បណ្ឌិត សោន វណ្ណៈ
-លោក ប៉ូ ប៊ុន្នួន
-លោកស្រី វ៉ា ចំណាន
-លោក ឡុច ចាន់ថន
-លោក បាន កក្កដា

## គណៈកម្មការរចនា

-លោក ប៊ុនលី ម៉ារឌី
-លោកស្រី វ៉ា ចំណាន
-លោកស្រី វីរៈ ខេងឡា
-កញ្ញា ជា សុជាតា
-កញ្ញា កែវ កញ្ញា

## គណៈកម្មការគ្រប់គ្រង

-ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា
-លោក ម៉ៅ សារឿន
-បណ្ឌិត អាន រ៉ូប្រាវ

# មាតិកា


បុព្វកថា ........................................ i

អារម្ភកថា ........................................ ii

**គណៈកម្មការគ្រប់គ្រង** ........................................ iii

មាតិកា ........................................ iv

សេចក្ដីផ្ដើម ........................................ 1

ជំពូកទី១ ស្រាវជ្រាវមេធ្យមសិក្សាទុតិយភូមិ ........................................ 2

មេរៀនទី១ ព្រហ្មវិហារធម៌ និងគុណធម៌ ........................................ 3

១.១ ព្រហ្មវិហារធម៌ ........................................ 3

១.២ គុណធម៌ ........................................ 6

មេរៀនទី២ ទំនួលខុសត្រូវ និងវិបាកវិនិច្ឆ័យ ........................................ 11

២.១ ទំនួលខុសត្រូវ ........................................ 11

២.២ វិបាកវិនិច្ឆ័យ ........................................ 18

មេរៀនទី៣ ឆន្ទៈ ........................................ 23

៣.១ និយមន័យ ........................................ 23

៣.២ វិភាគនៃអំពើឆន្ទៈ ........................................ 23

៣.៣ ធម្មជាតិនៃឆន្ទៈ ........................................ 23

៣.៤ ប្រភពនៃឆន្ទៈ ........................................ 25

៣.៥ ការបណ្ដុះឆន្ទៈ ........................................ 26

មេរៀនទី៤ ល្បិចទូទៅនៃគំនិត ........................................ 27

៤.១ ពុទ្ធិ ........................................ 27

៤.២ ពួកនៃពុទ្ធិ ........................................ 27

៤.៣ ល្បិចនៃពុទ្ធិ ........................................ 28

៤.៤ ទម្រង់នៃពុទ្ធិ ........................................ 29

៤.៥ វិចារ ........................................ 31

៤.៦ ទំនាក់ទំនងរវាងអព្ភន្តរញាណ និងវិចារ ........ 34
មេរៀនទី៥ សេរីភាព ........ 36
៥.១ និយមន័យសេរីភាព ........ 36
៥.២ ទស្សនៈរបស់ទស្សនវិទូមួយចំនួនស្តីពីសេរីភាព ........ 36
៥.៣ រូបភាពនៃការមានសេរីភាព ........ 37
៥.៤ ផលនៃការមានសេរីភាព ........ 38
មេរៀនទី៦ ការសម្តែងមតិ ........ 39
៦.១ សិទ្ធិក្នុងការសម្តែងមតិ ........ 39
៦.២ គោលការណ៍នៃការសម្តែងមតិរបស់សារព័ត៌មាន ........ 39
៦.៣ សារៈសំខាន់នៃសិទ្ធិសេរីភាពក្នុងការសម្តែងមតិ ........ 40
៦.៤ ការទទួលខុសត្រូវក្នុងការសម្តែងមតិ ........ 40
មេរៀនទី៧ សិទ្ធិនិងច្បាប់ ........ 41
៧.១ និយមន័យ ........ 41
៧.២ សីលច្បាប់និងច្បាប់វិជ្ជមាន ........ 41
៧.៤ ច្បាប់និងករណីយកិច្ច ........ 47
មេរៀនទី៨ យុត្តិធម៌ ........ 49
៨.១ យុត្តិធម៌ ........ 49
៨.២ សណ្ឋានបីយ៉ាងនៃយុត្តិធម៌ ........ 49
៨.៣ យុត្តិធម៌ និងសមភាពរវាងបុគ្គល ........ 50
៨.៤ សប្បុរសធម៌ ........ 52
មេរៀនទី៩ ក្រមនីតិវិធីរដ្ឋប្បវេណី ........ 55
៩.១ គោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណី ........ 55
៩.២ សមត្ថកិច្ចសាលាជម្រះក្តី ........ 55
៩.៣ សមត្ថភាពក្នុងការធ្វើបណ្តឹង ........ 56
៩.៤ ប្រាក់ប្រដាប់ក្តី ៖ ........ 57
៩.៥ បណ្តឹងឧទ្ធរណ៍ ........ 57

៩.៦ បណ្ដឹងសាទុក្ខ ........ 58

៩.៧ បណ្ដឹងជំទាស់ ........ 59

មេរៀនទី១០ ក្រមនីតិវិធីព្រហ្មទណ្ឌ ........ 60

១០.១ គោលបំណងនៃក្រមនីតិវិធីព្រហ្មទណ្ឌ ........ 60

១០.២ បណ្ដឹងអាជ្ញា ........ 61

១០.៣ អាជ្ញាយុកាលនៃបទល្មើស ........ 61

១០.៤ អង្គការអយ្យការ ........ 61

១០.៥ ប្រាក់ប្រដាប់ក្ដី ........ 61

១០.៦ ចៅក្រមស៊ើបសួរ ........ 62

១០.៧ នគរបាលយុត្តិធម៌ ........ 62

១០.៨ ការឃាត់ខ្លួន និងការចាប់ខ្លួន ........ 63

ជំពូកទី២ ទស្សនវិជ្ជាសង្គមនយោបាយ ........ 64

មេរៀនទី១ ប្លាតុង ........ 65

១.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ ........ 65

១.២ ទស្សនៈនយោបាយ ........ 65

១.៣ ទស្សនវិជ្ជាមួយចំនួនរបស់ ប្លាតុង ........ 76

មេរៀនទី២ អារីស្តូត ........ 79

២.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ ........ 79

២.២ ទស្សនៈនយោបាយ ........ 79

មេរៀនទី៣ នីកូឡូ ម៉ាគីអាវែល្លី ........ 88

៣.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ ........ 88

៣.២ ទស្សនៈនយោបាយ ........ 88

មេរៀនទី៤ តូម៉ាស ហប្ស ........ 94

៤.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ ........ 94

៤.២ ទស្សនៈនយោបាយ ........ 95

មេរៀនទី៥ ចន ឡុក ........ 107

៥.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ ........ 107
៥.២ ទស្សនៈនយោបាយ ........ 108
មេរៀនទី៦ ម៉ុងតេស្គីយើ ........ 115
៦.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ ........ 115
៦.២ ទស្សនៈនយោបាយ ........ 115
មេរៀនទី៧ ហ្សង់ ហ្សាក់ រូស្សូ ........ 121
៧.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ ........ 121
៧.២ ទស្សនៈនយោបាយ ........ 121
ជំពូកទី៣ ទ្រឹស្តីពុទ្ធិ ........ 131
មេរៀនទី១ លំនាំទូទៅនៃទ្រឹស្តីពុទ្ធិ ........ 132
១.១ តើទ្រឹស្តីពុទ្ធិជាអ្វី? ........ 132
១.២ ស័ព្ទមូលដ្ឋាននៃទ្រឹស្តីពុទ្ធិ ........ 133
១.៣ ប្រភពពុទ្ធិ ........ 133
១.៤ សារៈសំខាន់នៃទ្រឹស្តីពុទ្ធិ ........ 134
មេរៀនទី២ ទ្រឹស្តីពុទ្ធិរបស់ព្រះពុទ្ធ ........ 135
២.១ សេចក្តីផ្តើម ........ 135
២.២ ពុទ្ធប្រវត្តិ ........ 135
២.៣ ទ្រឹស្តីពុទ្ធិរបស់ព្រះពុទ្ធ ........ 136
មេរៀនទី៣ ទ្រឹស្តីពុទ្ធិរបស់លោក ចន ឡក ........ 139
៣.១ ជីវប្រវត្តិ ចន ឡក ........ 139
៣.២ ទ្រឹស្តីពុទ្ធិ ........ 139
មេរៀនទី៤ ទ្រឹស្តីពុទ្ធិរបស់លោក ហ្វ្រីឌ្រិស្ក នីឈេ ........ 142
៤.១ ជីវប្រវត្តិ នីឈេ ........ 142
៤.២ ទ្រឹស្តីពុទ្ធិ ........ 142
៤.៣ សច្ចភាពគឺអ្វីដែលមានប្រសិទ្ធភាព ........ 144
៤.៤ អច្ឆរិយបុគ្គល ឆន្ទៈដើម្បីអំណាច និងភាពច្រំដែលជានិរន្តរ៍ ........ 145

ជំពូកទី៤ ទស្សនវិជ្ជា និងការអប់រំនៅក្នុងសង្គម ........ 147
មេរៀនទី១ ទស្សនវិជ្ជា និងទ្រឹស្តីអប់រំរបស់លោក អូហ្គូស្ទីន ........ 148
១.១ ឥទ្ធិពលរបស់លោក អូហ្គូស្ទីន ........ 148
១.២ ការបង្រៀន ........ 149
មេរៀនទី២ ទស្សនវិជ្ជា និងទ្រឹស្តីអប់រំរបស់លោក ឌេស៊ីឌេរីអ៊ូស អេរ៉ាស្មូស ........ 151
២.១ គោលបំណងនៃការអប់រំ ........ 151
២.២ គ្រូបង្រៀន និងវិធីសាស្ត្របង្រៀន ........ 152
២.៣ ការលើកទឹកចិត្តសម្រាប់ការអភិវឌ្ឍសក្តានុពល ........ 152
មេរៀនទី៣ ទស្សនវិជ្ជា និងទ្រឹស្តីអប់រំរបស់លោក ចន អេមូស ខូមេនៀស ........ 154
៣.១ គោលបំណងនៃការអប់រំ ........ 155
៣.២ ចិត្តវិទ្យានៃការអប់រំ ........ 158
៣.៣ អង្គភាពនៃការអប់រំ ........ 159
៣.៤ កម្មវិធីសិក្សា ........ 161
៣.៥ វិធីសាស្ត្របង្រៀន ........ 162
៣.៦ មុខងារសង្គម ........ 163
មេរៀនទី៤ ទស្សនវិជ្ជា និងទ្រឹស្តីអប់រំរបស់លោក ស្ពីណូហ្សា ........ 164
៤.១ គំនិត និងន័យពង្រីក ........ 164
៤.២ ស្មារតី និងរាងកាយ ........ 165
៤.៣ ពុទ្ធិរបស់មនុស្ស ........ 165
៤.៤ សកម្មភាព អំពើល្អ និងសេរីភាព ........ 166
មេរៀនទី៥ ទស្សនវិជ្ជា និងទ្រឹស្តីអប់រំរបស់លោក ហេហ្គេល ........ 168
៥.១ បញ្ញត្តិបៀលឌុង ........ 168
៥.២ គ្រួសារ សង្គមស៊ីវិល និងរដ្ឋ ........ 170
៥.៣ ការអប់រំគឺជាសិទ្ធិរបស់កុមារ និងការទទួលខុសត្រូវរបស់រដ្ឋ ........ 171
៥.៤ ការអប់រំ និងសីលធម៌ ........ 172
មេរៀនទី៦ ទស្សនវិជ្ជា និងទ្រឹស្តីអប់រំរបស់លោក ម៉តទីម័រ អាដល័រ ........ 174

៦.១ ទស្សនវិជ្ជាអប់រំ ........................................................................................ 175
៦.២ សេរីភាព និងឆន្ទៈសេរី........................................................................................ 176
បណ្ណានុក្រម ........................................................................................................ 177

# សេចក្ដីផ្ដើម

សកលលោកមានការរីកចម្រើន និងការប្រកួតប្រជែងគ្រប់វិនាទី ដើម្បីស្វែងរកឧត្តមភាពនៅលើពិភពលោកក្នុងបរិបទសកលភាវូបនីយកម្ម គឺទាមទារឱ្យប្រទេសនីមួយៗខិតខំបង្កើនគុណភាពផលិតផល និងសេវាកម្មរបស់ខ្លួនឱ្យបានជាអតិបរមា។ ការប្រើប្រាស់ធនធនមនុស្សឱ្យអស់លទ្ធភាពមានសារៈសំខាន់បំផុត ពីព្រោះវាជាកម្លាំងចលករមិនអាចខ្វះបាន ជាពិសេសគុណភាពរបស់គ្រូបង្រៀនដែលបានបញ្ចប់ការសិក្សានៅវិទ្យាស្ថានជាតិអប់រំ។ ដើម្បីធានាគុណភាពអប់រំប្រកបដោយគុណភាពខ្ពស់ និងសមស្របតាមស្តង់ដាថ្នាក់ជាតិ និងអន្តរជាតិ គ្រូឧទ្ទេសសីលធម៌ពលរដ្ឋវិជ្ជានៃវិទ្យាស្ថានជាតិអប់រំបានព្យាយាមសិក្សា និងស្រាវជ្រាវតាមគ្រប់រូបភាព ដើម្បីបង្កើតឱ្យបាននូវខ្លឹមសារមេរៀន និងការបង្រៀនសីលធម៌ពលរដ្ឋវិជ្ជា សម្រាប់បង្រៀនគរុនិស្សិត បរិញ្ញា+២ ឱ្យក្លាយជាគ្រូបង្រៀនកម្រិតឧត្តមដែលប្រកបដោយគុណសម្បត្តិល្អ គ្រប់គ្រាន់ដើម្បីបង្រៀនសិស្សរបស់ខ្លួនប្រកបដោយគុណភាពខ្ពស់។

មុខវិជ្ជាឯកទេសសីលធម៌ពលរដ្ឋវិជ្ជាបង្ហាញខ្លឹមសារនៃការកសាងខ្លួនឯងទៅជាគ្រូបង្រៀនឱ្យមានសមត្ថភាពជំនាញសតវត្សទី២១ដោយផ្ដោតលើចំណេះដឹងវិជ្ជាជីវៈ ជំនាញវិជ្ជាជីវៈ ក្រមសីលធម៌វិជ្ជាជីវៈ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍធនជានមនុស្សឱ្យមានលក្ខណៈសម្បត្តិពេញលេញសម្រាប់កសាងសង្គមពុទ្ធិ និងវិបុលភាព។

មុខវិជ្ជានេះផ្ដល់ឱ្យអ្នកសិក្សានូវសុជីវធម៌ល្អនៅក្នុងការរស់នៅ ចេះដោះស្រាយបញ្ហានៅក្នុងគ្រួសារ និងសហគមន៍ ចេះថែទាំសុខភាពផ្លូវចិត្ត និងចូលរួមថែរក្សាវប្បធម៌ អរិយធម៌ អត្តសញ្ញាណជាតិ ព្រមទាំងមានចំណេះដឹងអំពីច្បាប់សំខាន់ៗរបស់ប្រទេស។ លើសពីនេះទៀត ផ្ដល់ការយល់ដឹងអំពីច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ជាតិ និងអន្តរជាតិ សិទ្ធិមនុស្សសំខាន់ៗ ដូចជាសិទ្ធិ និងករណីយកិច្ចប្រជាពលរដ្ឋ សិទ្ធិសំដែងមតិ សិទ្ធិការពារខ្លួន។ អ្នកសិក្សាឈ្វេងយល់ពីសារៈសំខាន់នៃសុភមង្គគ្រួសារ និងការថែទាំសុខភាពផ្លូវចិត្ត យល់ដឹងពីច្បាប់ជាតិ អន្តរជាតិ និងតួនាទីភារកិច្ចរបស់ខ្លួនក្នុងការអនុវត្តច្បាប់ទៅតាមនិយាមជាតិ និងអន្តរជាតិ ជាពិសេស ច្បាប់ និងសន្ធិសញ្ញាអន្តរជាតិ ច្បាប់អង្គការសហប្រជាជាតិ។ ការចេះគិតពិចារណា និងវិនិច្ឆ័យបានត្រឹមត្រូវចំពោះបញ្ហាដែលកើតមានចំពោះខ្លួនឯង គ្រួសារ ប្រទេសជាតិ វាជាមូលដ្ឋាននៃមុខវិជ្ជាសីលធម៌ពលរដ្ឋក្នុងការបង្ហាញផ្លូវ។

# ជំពូកទី១ ស្រាវជ្រាវមធ្យមសិក្សាទុតិយភូមិ

# មេរៀនទី១ ព្រហ្មវិហារធម៌ និងគុណធម៌

សុខ សន្តិភាព និងសុភមង្គល ជាសេចក្តីប្រាថ្នារបស់មនុស្សគ្រប់រូប។ ដើម្បីមានសន្តិភាព និងសុភមង្គលពេញលេញ មនុស្សម្នាក់ៗត្រូវមានទំនាក់ទំនងល្អជាមួយអ្នកជុំវិញខ្លួន និងសង្គម ។ ការប្រតិបត្តិបានល្អនូវព្រហ្មវិហារធម៌នាំមកសន្តិភាព ភាពសុខសាន្ត ភាពរីករាយ។ ការស្គាល់ខុស ស្គាល់ត្រូវ ស្គាល់គុណ ស្គាល់ទោស ចំពោះអ្នកជុំវិញខ្លួន និងការចេះកែខ្លួនឱ្យក្លាយជាមនុស្សល្អ ជាការរស់នៅចុះសម្រុងរបស់យើងជាមួយអ្នកដទៃ និងជាមូលដ្ឋាននៃការរីកចម្រើនរបស់បុគ្គល គ្រួសារ និងសង្គម។

## ១.១ ព្រហ្មវិហារធម៌

ព្រហ្មវិហារធម៌ ជាធម៌របស់ព្រះព្រហ្មដែលក្រាលចិត្តសន្តោសប្រោសប្រណីចំពោះគ្រប់មនុស្ស សត្វដោយគ្មានការរើសអើង។ ព្រហ្មវិហារធម៌ គឺធម៌ជាទីនៅរបស់ព្រហ្ម ឬជាធម៌ប្រតិបត្តិ ដើម្បីឱ្យមនុស្សរស់នៅបានល្អប្រសើរ ដែលប្រជាជនគ្រប់ស្រទាប់វណ្ណៈ និងត្រូវប្រតិបត្តិដើម្បីសាមគ្គីភាព និងភាពសុខក្សេមក្សាន្តក្នុងគ្រួសារនិងសង្គម។

### ១.១.១ ធាតុនៃព្រហ្មវិហារធម៌

តាមប្រវត្តិសាស្ត្រ ប្រទេសខ្មែរយើងនាសម័យអង្គរជាសម័យកាលមួយដ៏រុងរឿងបំផុត។ បុព្វបុរសខ្មែរបានស្ថាបនាបូជនីយដ្ឋានធំៗជាច្រើនអំពីថ្ម មានកំពូលខ្ពស់ស្កឹមស្កៃ និងមានទំហំ បរិវេណច្រើនគីឡូម៉ែត។

ប្រាសាទអង្គរធំ ជាប្រាសាទដ៏ល្បីល្បាញមួយក្នុងចំណោមប្រាសាទដ៏ល្បីល្បាញជាច្រើន ដែលគេបានកសាងព្រះកេសនៃព្រះព្រហ្មមានព្រះភ័ក្ត្របួនបែរទៅរកទិសទាំងបួន។ ព្រះភ័ក្ត្របួននេះជាតំណាងឱ្យព្រហ្មវិហារធម៌ទាំង៤ គឺ មេត្តា ករុណា មុទិតា និងឧបេក្ខា។

#### ១.១.១.១ មេត្តា

- ការមានចិត្តស្រឡាញ់រាប់អានញាតិមិត្ត និងសាធារណជនក្នុងសង្គមដោយគ្មានការរើសអើងនិងប្រកបដោយសន្តានចិត្តភក្តីទូលាយ ដូចជាមាតាបិតាចង់ឱ្យតែកូនបានសុខ បានចម្រើនជានិច្ចចៀសផុតពីទុក្ខវេទនា ពៀរវេរា និងគ្រោះមហន្តរាយគ្រប់ប្រការ។

- មេត្តាជាថាមពលនៃធម៌ដែលមានអានុភាពបំផុត អាចផ្សព្វផ្សាយដោយគ្មានការរើសអើងទៅកាន់បុគ្គលដែលជាទីស្រឡាញ់របស់យើង ឬទៅកាន់អ្នកដទៃដែលមិនមែនជាក្រុមញាតិមិត្ត ឬ ទៅកាន់បច្ចាមិត្តទៀតផង។

- មេត្តាមានន័យថា ស្និទ្ធស្នាល ការប្រតិបត្តិប្រកបដោយមេត្តា គឺសត្រូវទាំងអស់នឹងត្រឡប់ប្រែក្លាយជាមិត្តមិនអាចស្អប់ និងមិនចងពៀរវេរាចំពោះយើងបានយូរឡើយ។ អ្នកមានមេត្តាគ្មានការភ័យតក់ស្លុតអំពីហេតុការណ៍អាក្រក់កើតឡើងទេ គេអាចដោះស្រាយបានរាល់បញ្ហាទាំងអស់។

ទោសៈជាបដិបក្ខនឹងមេត្តា។ នៅពេលមានទោសៈចូលលុកលុយក្នុងចិត្ត យើងត្រូវយកមេត្តាធម៌មកលាងសំអាតចិត្តរបស់យើង។ ប្រសិនបើមនុស្សគ្រប់រូបសុទ្ធតែមានមេត្តាដូចគ្នា មនុស្សទាំងអស់នៅក្នុងលោកនឹងមិនមានជម្លោះ អំពើហិង្សាជាមួយគ្នាឡើយ។

#### ១.១.១.២ ករុណា

- ករុណា គឺការមានចិត្តអាណិតអាសូរដោយគ្មានច្រណែនឈ្នានីស យកត្រូវតែខ្លួនឯង ទិតៀន រិះគន់កំហុសអ្នកដទៃឡើយ។

- ការអាណិតអាសូរចំពោះមនុស្សទាំងអស់នៅក្នុងសង្គមដែលបានទទួលរងទុក្ខលំបាកផ្សេងៗ ទាំងផ្លូវចិត្ត ទាំងផ្លូវកាយ ដោយចង់ឱ្យពួកគេរួចពីទុក្ខលំបាកនិងរស់នៅបានសុខស្រួលដូចខ្លួនដែរ។

មនុស្សត្រូវចេះជួយសង្គ្រោះនិងធ្វើទានចំពោះជនដែលជួបប្រទះការលំបាកវេទនា។ នៅក្នុងពិភពលោកនេះ គ្មានកន្លែងណា និងគ្មានពេលណាដែលមនុស្សមិនទទួលរងសេចក្ដីទុក្ខនិងការឈឺចាប់នោះទេ តែគ្រាន់តែសេចក្ដីទុក្ខ និងការឈឺចាប់នោះមានប្រភេទខុសៗគ្នាប៉ុណ្ណោះ។ បុព្វហេតុនៃសេចក្ដីទុក្ខនិងការឈឺចាប់ខ្លះបង្កើតឡើងដោយធម្មជាតិដូចជា ខ្យល់ព្យុះ ទឹកជំនន់ ការរាំងស្ងួត ជំងឺរាតត្បាត។ល។ មនុស្សខ្លះត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ដែលកើតឡើងដោយថាហេតុដូចជា ភ្លើងឆេះផ្ទះ ចោរកម្មផ្សេងៗជាដើម។

មនុស្សដែលមានករុណា តែងតែស្ដែងចេញមនោសញ្ចេតនាអាណិតអាសូរតាមរយៈការបរិច្ចាគទាន។ ករុណាដឹកនាំមនុស្សឱ្យដើរតាមផ្លូវ សច្ចៈ យុត្តិធម៌ ចៀសវាងប្រព្រឹត្តសកម្មភាពទាំងឡាយណាដែលធ្វើឱ្យអ្នកដទៃរងការឈឺចាប់ទាំងផ្លូវកាយ ទាំងផ្លូវចិត្តដូចជា ការកាប់សម្លាប់ ការធ្វើទារុណកម្ម ការប្រមាថមាក់ងាយ ការលួចប្លន់ ការកេងប្រវ័ញ្ច បោកប្រាស់ និងអំពើបាបកម្មផ្សេងៗទៀត ព្រោះមនុស្សទាំងអស់សុទ្ធតែស្រឡាញ់អាយុជីវិតរបស់ខ្លួន ចង់រស់នៅដោយសុខសន្តិភាព សុភមង្គល និងសេចក្ដីថ្លៃថ្នូរ។

**១.១.១.៣ មុទិតា**

មុទិតា មានចិត្តទន់ភ្លន់ មានចិត្តរីករាយអបអរសាទរចំពោះសេចក្ដីសុខចម្រើនរបស់អ្នកដទៃ មិនរើសមុខ និងចង់ឱ្យគេស្ថិតនៅក្នុងសេចក្ដីសុខ សុវត្ថិភាពជានិច្ច ដោយគ្មានការច្រណែននិន្ទា ឈ្នានីស។

**១.១.១.៤ ឧបេក្ខា**

ឧបេក្ខា គឺការប្រកាន់ចិត្តជាកណ្ដាល មិនលម្អៀងទៅខាងណា និងមានចិត្តជាអព្យាក្រឹត។

- មិនមានចិត្តត្រេកអរហួសហេតុនិងមិនខឹងសំបារចំពោះអ្នកណាទាំងអស់។ បំណងសំខាន់គឺចង់ឱ្យពួកគេរស់នៅតាមលទ្ធភាព សមត្ថភាព និងសេរីភាពរបស់គេ។
- មិនមានចិត្តលោភលន់ ឬព្រួយកង្វល់ ចំពោះអ្នកជិតខាងដែលមានទ្រព្យសម្បត្តិច្រើនជាងខ្លួន។

មនុស្សតែងតែមានចិត្តជាប់ជំពាក់ទៅលើមនុស្សណាម្នាក់ ឬវត្ថុអ្វីមួយដែលជាទីស្រឡាញ់ពេញចិត្តរបស់ខ្លួន ហើយការជាប់ជំពាក់នេះនាំមនុស្សឱ្យមានចិត្តលម្អៀង ឬអគតិ។

ដូចនេះ មនុស្សត្រូវប្រកាន់ខ្ជាប់ព្រហ្មវិហារធម៌ ព្រោះជាប្រភពនៃសន្តិភាពនិងវឌ្ឍនភាពសង្គម។

**១.១.២ ព្រហ្មវិហារធម៌របស់អ្នកមានគុណ**

ព្រហ្មវិហារធម៌របស់អ្នកមានគុណ ជាព្រហ្មវិហារធម៌របស់បុព្វការីជនដែលបានចិញ្ចឹមបីបាច់ថែរក្សា អាណិតស្រឡាញ់ បង្រៀន និងទំនុកបម្រុងផ្គុងផ្ដើមឱ្យបានសម្រេចផលប្រយោជន៍ផ្សេងៗក្នុងការប្រកបរបរចិញ្ចឹមជីវិត។

- មាតាបិតា ឬអាណាព្យាបាល ជាបុព្វការី និងបុព្វការិនីរបស់បុត្រធីតា
- ព្រះមហាក្សត្រនិងមន្ត្រីរាជការគ្រប់ផ្នែក ជាបុព្វការីរបស់សាធារណជនក្នុងបទេស
- គ្រូអាចារ្យជាបុព្វការីរបស់សិស្សានុសិស្ស
- ព្រះសម្មាសម្ពុទ្ធជាបុព្វការីរបស់ពុទ្ធបរិស័ទ ឬពុទ្ធសាសនិកជន។ ព្រះសម្មាសម្ពុទ្ធទ្រង់ បានចាត់ទុកមាតាបិតាជាព្រះ ជាអ្នកមានគុណ ព្រោះលោកទាំងពីរមានព្រហ្មវិហារធម៌ចំពោះបុត្រធីតា។ ព្រហ្មវិហារធម៌របស់មាតាបិតា ជាធម៌ដ៏ប្រសើរខ្ពង់ខ្ពស់ ព្រោះលោកទាំងពីរប្រកបទៅដោយ៖

**មេត្តា៖** ការស្រឡាញ់ ប្រាថ្នាឱ្យកូនបានសុខ ពិសេស ស្រឡាញ់តាំងពីដឹងថាខ្លួនមានផ្ទៃពោះ គឺធ្វើយ៉ាងណាមិនឱ្យខូចសុខភាពដល់កូនក្នុងផ្ទៃឡើយ ដូចជាមិនហ៊ានហូបអាហារដែលមានជាតិហឹរជាដើម។

**ករុណា៖** សេចក្ដីអាណិតអាសូរគិតចង់ឱ្យកូនបានរួចពីទុក្ខ ចាប់តាំងពីប្រសូត្រមក ប្រុសក្ដី ស្រីក្ដី ល្អ អាក្រក់យ៉ាងណាក៏ដោយ ក៏មាតាបិតាខំចិញ្ចឹមកូនឱ្យរស់រានដែរ។

**មុទិតា៖** សេចក្តីត្រេកអរក្នុងវេលាដែលកូនបានសុខ ត្រេកអរតាំងពីកូនរៀននិយាយ ចេះសើច ហើយតែងតែសរសើរកូនគ្រប់ពេល។

**ឧបេក្ខា៖** តាំងចិត្តជាកណ្តាល ព្រោះឪពុកម្តាយស្រឡាញ់កូនស្មើៗគ្នា។ មាតាបិតាតែងតែប្រស់ព្រំមកលើបុត្តធីតាជានិច្ច។

ដោយអំណាចព្រហ្មវិហារធម៌នេះ៖ លោកជាមាតាបិតាខិតខំព្យាយាមស្វែងរកទ្រព្យសម្បត្តិ សម្រាប់ជួយឧបត្ថម្ភដល់បុត្រធីតា ទោះបីជាលោកបានជួបប្រទះនឹងសេចក្តីកលំបាកវេទនាយ៉ាងណាក៏ដោយ ក៏លោកនៅតែព្យាយាម ប្រឹងប្រែងជួយឧបត្ថម្ភបុត្រធីតារបស់ខ្លួនតាមលទ្ធភាពដែរ។ មិនតែប៉ុណ្ណោះ ពេលបុត្រធីតាបានចម្រើនវ័យពេញរូបរាង មាតាបិតាទាំងឡាយតែងព្យាយាមរំពៃរកមើល ជ្រើសរើសគូស្រករដ៏សមរម្យ ដើម្បីរៀបចំផ្សំផ្គុំជាគូស្វាមីភរិយា និងចែកទ្រព្យសម្បត្តិឱ្យបុត្រធីតាទុកប្រកបរបរចិញ្ចឹមជីវិតទៀតផង។

### ១.១.៣ កតញ្ញុតាធម៌ និងកតវេទិតាធម៌

កតញ្ញុតាធម៌និងកតវេទីតាធម៌ ជាធម៌ដែលបុគ្គលគ្រប់រូបត្រូវយល់ដឹងនិងអនុវត្តជាប់ជានិច្ច ដើម្បីជៀសវាងការប្រមាថមាក់ងាយពីអ្នកដទៃដែលនាំឱ្យអាប់ឱនសិរីសួស្តី។ ការយល់ដឹង និងការអនុវត្តបានល្អនូវធម៌ទាំងពីរនេះនឹងដឹកនាំឱ្យបុគ្គលនោះក្លាយជាមនុស្សមានភាពថ្លៃថ្នូរក្នុងសង្គមប្រកបដោយសិរីសួស្តីនិងសុភមង្គល។

ការដឹងគុណគឺការទទួលស្គាល់គុណបំណាច់ដ៏ធំធេងរបស់បុព្វការីជន មានមាតាបិតាជាដើម ដែលលោកបានធ្វើចំពោះយើង គេហៅថា កតញ្ញុតាធម៌ ។ ឯការតបស្នងចំពោះលោកអ្នកមានគុណ គេហៅថា កតវេទីតាធម៌ ។

ពាក្យកតញ្ញុតាធម៌និងកតវេទីតាធម៌មានន័យផ្សេងគ្នា តែគេច្រើនប្រើពាក្យនេះបញ្ចូលគ្នាគឺកតញ្ញុកតវេទីដែលមានន័យថា ជាការដឹងគុណផងនិងជាការតបគុណផង។ បុត្រធីតាគ្រប់រូបត្រូវ កតញ្ញុកតវេទី អប់រំខ្លួនឱ្យក្លាយជាមនុស្សដឹងគុណមាតាបិតានិងការខិតខំតបគុណលោកទាំងពីរវិញ ដោយគោរព ស្តាប់ដំបូន្មាន និងចិញ្ចឹមបីបាច់ថែរក្សាលោកជាប្រចាំតាមលទ្ធភាពនិងសមត្ថភាពរបស់ខ្លួន និងមានស្មារតីទទួលខុសត្រូវចំពោះជីវភាព សុខភាព និងសុវត្ថិភាពរបស់លោកគ្រប់កាលៈទេសៈ មិនធុញទ្រាន់ ទោះជាពេលវេលាដែលជួបការលំបាកស្មុគស្មាញក្នុងជីវភាព ឬហេតុការណ៍អ្វីផ្សេងក៏ដោយ។ ទាំងអស់នេះមានឈ្មោះថាជា កូនកតញ្ញុកតវេទី ឬកូនប្រកបដោយកតញ្ញុកតវេទីតាធម៌។ ផ្ទុយមក វិញកូនចៅដែលមិនដឹងគុណ មិនបានតបគុណមាតាបិតា មិនស្តាប់ដំបូន្មាន មិនប្រព្រឹត្តអំពើល្អ ធ្វើឱ្យវង្សត្រកូលខូចកិត្តិយស និងមិនយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សាមាតាបិតាតាមលទ្ធភាពរបស់ខ្លួន ទោះបីខ្លួនមានទ្រព្យសម្បត្តិគ្រប់គ្រាន់ ក៏មិនរវល់អើពើនឹងលោកទាំងពីរទាល់តែសោះ គិតតែពីជីវិតខ្លួនប្រពន្ធកូនខ្លួន ទុកបណ្តោយឱ្យលោកទទួលរងទុក្ខលំបាកតាមយថាកម្ម ទាំងនេះមានឈ្មោះថាជា កូនអកតញ្ញុ អកតវេទី ឬកូនរមិលគុណ។

ចំពោះសិស្សានុសិស្សនៅពេលមានចំណេះដឹងច្រើន មានបុណ្យសក្តិខ្ពស់ និងមានទ្រព្យសម្បត្តិ គ្រប់គ្រាន់ ពេលឃើញគូរបស់ខ្លួនចាស់ជរា ឬមានទុក្ខធុរៈផ្សេងៗ ត្រូវយកចិត្តទុកដាក់ជួយសង្គ្រោះលោកតាមកាលៈទេសៈនិងតាមលទ្ធភាព ទើបមានឈ្មោះថា សិស្សកតញ្ញុកតវេទី។

រីឯប្រជារាស្ត្រក៏ដូចគ្នាដែរ គឺមានភារៈជួយទំនុកបំរុងប្រទេសជាតិរបស់ខ្លួនតាមលទ្ធភាពដូចជា បង់ពន្ធជូនរដ្ឋតាមច្បាប់កំណត់មិនគេចវេះ ចង់មានចង់បានហួសហេតុ ភ្លេចគិតដល់ការអភិវឌ្ឍប្រទេស ជាតិនិងគោរពច្បាប់សង្គម មិនពុករលួយ មិនបង្កឱ្យមានបញ្ហាផ្សេងៗដល់ការរក្សាសុខសន្តិភាពនិង សុវត្ថិភាពសង្គម ទើបមានឈ្មោះថាជាជនដែលមានកតញ្ញុកតវេទីចំពោះប្រទេសជាតិរបស់ខ្លួន ។

ព្រះម្ចាសម្ពុទ្ធទ្រង់មានព្រះមហាករុណា ព្រះអង្គបានប្រោសប្រទានព្រះធម៌ ព្រះវិន័យ និង ព្រះឱវាទទាំងឡាយដល់មនុស្សលោក ដើម្បីទុកជាផ្លូវប្រតិបត្តិប្រកបដោយផលល្អ សិរីមង្គល សម្រាប់កសាងជីវភាពរស់នៅរបស់ខ្លួនទោះក្នុងបច្ចុប្បន្ន ឬបរលោក ពុទ្ធបរិស័ទគ្រប់ស្រទាប់វណ្ណៈទាំងបព្វជិត ទាំងគ្រហស្ថ តែងគោរពបូជាតាមធម៌ព្រះអង្គដោយគ្រឿងសក្ការៈទាំងឡាយមានម្ហូបអាហារ នំចំណី និងផលានុផលជាដើមទៅតាមលទ្ធភាពនិងកាលៈទេសៈ ។

### ១.១.៤ គោលការណ៍ និងសារៈសំខាន់នៃសីលវិជ្ជាផ្ទាល់ខ្លួន

ដើម្បីបញ្ជាក់គោលការណ៍នៃសីលជីវិត គេតែងយកមនុស្សមកធ្វើជាគោល ព្រោះមនុស្សជាតម្លៃធំបំផុត។ ដូចនេះមនុស្សជាវត្ថុផងនិងជាតម្លៃផង។ ក្នុងសភាពជាវត្ថុមនុស្សគឺជាប្រធាន។ តែក្នុងសភាពជាតម្លៃមនុស្សគឺជាឧត្តមគតិដែលគេចង់បានដែលគេត្រូវធ្វើឱ្យបានសម្រេច។ គឺមកពីដូចនេះហើយបានជាម្នាក់ៗត្រូវមានករណីយកិច្ចចំពោះខ្លួនឯងដើម្បីធ្វើឱ្យសម្រេចជារូបរាងឡើងនូវតម្លៃនោះដែលមានជាអទត្តពលភាព(virtuellement)នៅក្នុងខ្លួនយើងតាំងពីយូរមកហើយនិងដើម្បីឱ្យទៅដល់ឋានៈជាមនុស្សមែនទែនពោលគឺឱ្យមានបុគ្គលិកលក្ខណៈមែនទែន។ គឺគំនិតនេះហើយដែលជាគោលការណ៍នៃសីលវិជ្ជាមនុស្ស។ តែតាមពួកអ្នកសង្គមវិទ្យាដូចជា ដួខិម (Durkheim) "សីលវិជ្ជានឹងចាប់ផ្ដើមមានឡើង កាលណាការរស់នៅជាក្រុមចាប់មានឡើង"។ តាមពិតបុគ្គលិកលក្ខណៈដុះដាលឡើងនិងសម្រេចឡើងបានតែនៅក្នុងការរស់នៅជាសង្គម ឬ ដោយសារតែការរស់នៅរបៀបនេះ។ គឺដូចនេះហើយបានជាវិញ្ញូ ឬអ្នកបួស(le religieux)ដែលចេញពីសង្គមទៅនៅក្នុងព្រៃដើម្បីធ្វើសមាធិ ឬដើម្បីធ្វើការចម្រើនភាវនា គឺនៅតែប្រើប្រព័ន្ធជំនឿ ឬទំនៀមផ្លូវចិត្តដែលគេបានទទួលពីសង្គមមកហើយ។ ដោយបុគ្គលសម្រេចនូវបុគ្គលិកលក្ខណៈខ្លួនដោយប្រើមធ្យោបាយដែលបានមកពីសង្គម ម្ល៉ោះហើយសង្គមមានតម្លៃក៏ដោយសារតែសង្គមនេះជាឧបករណ៍សម្រាប់បណ្ដុះពង្រីកចិត្តមនុស្ស។ គឺមកពីបុគ្គលម្នាក់ៗខំសាងបុគ្គលិកលក្ខណៈខ្លួនហើយបានជាកិច្ចការសង្គមដែលពីដើមត្រូវធ្លាក់ទៅលើក្រុមនីមួយៗ ឥឡូវត្រូវធ្លាក់លើបុគ្គលម្នាក់ៗទៅវិញ។ ពីដើមគេផ្សំផ្គុំកូនដោយបង្ខំដោយប្រើអំណាចជាពិសេសចំពោះកូនស្រី។ សព្វថ្ងៃកូនប្រុសក្ដី ស្រីក្ដីមានសេរីភាពនឹងរើសគូស្រករខ្លួនឯង។ គឺមកពីដូចនេះហើយបានជាកូនត្រូវមានទំនួលខុសត្រូវដែលខ្លួនពុំត្រូវទទួលបើនិយាយតាមពីដើមនោះ។ បានជាមានទំនួលខុសត្រូវ មកពីការរើសគូស្រករ និងការបង្កើតគ្រួសារនីមួយៗជាបញ្ហាពិបាកណាស់ ហើយអាចមានវិបាក(conséquences)ជាយថាហេតុច្រើនយ៉ាង។

ពីដើមមុខរបរច្រើនតែតពីឪទៅកូនហើយកូនច្រើនតែត្រូវបន្តការងាររបស់ឪពុកសឹងតែជាចាំបាច់។ សព្វថ្ងៃនេះពុំដូចនោះទេម្នាក់ៗត្រូវរើសការងារខ្លួនឯង ព្រោះបើតាមប៉ាស្កាល់(Pascal)ការរើសការងារគឺជាការមួយសំខាន់ជាងគេបំផុតចំពោះជីវិតយើង។

ពីដើមទម្រង់នយោបាយមានសភាពផ្ដាច់ការ។ សព្វថ្ងៃរដ្ឋប្រជាធិបតេយ្យពុំប្រើលទ្ធិផ្ដាច់ការទេហើយតែងប្រើការបោះឆ្នោតជាសកល។ ម្ល៉ោះហើយបុគ្គលម្នាក់ៗត្រូវមានទំនួលខុសត្រូវថ្មីមួយទៀតគឺទំនួលខុសត្រូវលើការជ្រើសរើសតំណាងរបស់ខ្លួន។ គឺមកពីដូចនេះហើយបានជាសីលជីវិត(vie morale)នៃបុគ្គលិកលក្ខណៈម្នាក់ៗទៅជាមានសារៈសំខាន់ជាងពីដើមទុកជាចំពោះផ្នែកសង្គមក៏ដោយ។ "ពលរដ្ឋល្អនៃបុរីទំនើប ជាបឋមត្រូវតែជាមនុស្សមួយមែនទែន ព្រោះតម្លៃដែលធ្វើឱ្យវិចារណញ្ញាណមាំមួន ឬធ្វើឱ្យចិត្តរីកដុះដាល ឬធ្វើឱ្យឆន្ទៈរឹងមាំនោះ ក៏សុទ្ធតែជាកត្តាមួយដែលធ្វើឱ្យមានវឌ្ឍនភាពដល់បុរីដែរ"។ គេអាចនិយាយម្យ៉ាងទៀតថា ពលរដ្ឋល្អដោយខំកសាងនូវតម្លៃខ្លួនក៏អាចកសាងនៅពេលជាមួយគ្នានោះនូវតម្លៃបុរីដែរ។ តែតម្លៃទាំងនោះគឺជាសីលតម្លៃ។ តើសីលតម្លៃរបស់យើងម្នាក់ៗអាចទៅគុណធម៌បានឬទេ?

## ១.២ គុណធម៌

សីលតម្លៃនៃបុគ្គលកាលណាមានភាពជាទម្លាប់ហើយជាក់ច្បាស់អាចហៅថាគុណធម៌បាន។

### ១.២.១ សញ្ញាណទូទៅនៃគុណធម៌

តាមឫសគល់នៃពាក្យ"គុណធម៌" មានន័យថា"កម្លាំង"។ តែដូចពុំនោលរបស់រ៉ឺនូវៀ(Renouvier)គុណធម៌គឺជាកម្លាំងដែលមានការគិតពិចារណា ការជជែកផ្ទផ្ទង់ សេរីភាព ភាពជាម្ចាស់នៃខ្លួនឯង និងដំណឹកនាំ ឬចំណាត់ចំណែងដោយខ្លួនឯង។ កម្លាំងពុំមែនមានតែនៅក្នុងការប្រឆាំងនឹងលំងប់(passion) និងសភាវគតិនោះទេ តែមាននៅក្នុងការរាតត្បាត ក្នុងការគ្រប់គ្រងលើរបស់ខាងក្រៅខ្លួនយើង ឬក្នុងធម្មជាតិទៀតដែរ។ ដូចនេះគុណធម៌តែងតែ

មាននៅក្នុងឆន្ទៈយើងដែលពុំអាចបង្អាក់បានទោះជាមានឧបសគ្គអ្វីក៏ដោយ ព្រមទាំងនៅក្នុងការគ្រប់សង្កត់ចិត្តខ្លួនឯង និងនៅក្នុងភាពសុខដុមខាងក្នុងខ្លួនយើងថែមទៀត។ ដូចនេះ គុណធម៌មែនទែនតែងជាដើមហេតុ ជាកត្តាដើម ជាកម្លាំងជម្រុញឱ្យយើងធ្វើនេះឬធ្វើនោះ តាមឡឺសែន(Le Senne) គុណធម៌មែនទែនគឺសេចក្តីក្លាហានក្នុងការស្វែងរកកុសល។

ក៏ប៉ុន្តែ កម្លាំងដែលជាដើមហេតុ នេះតែងមានជាលំដាប់។ គុណធម៌តែងតែលំឱនទៅតាមលំដាប់នៃតម្លៃ។ ការលំឱនទៅតាមលំដាប់ ឬការស្រឡាញ់ លំដាប់នេះមិនមែនត្រឹមតែជាសីលគុណធម៌សំខាន់បំផុតនោះទេ តែជាគុណធម៌ដែលមានតែមួយគត់គឺគុណធម៌ដើម ចម្បង សកល។ ឯលំដាប់ក្នុងការណ៍នេះមានន័យថាលំដាប់ថ្នាក់នៃសុក្រឹតភាព។ ឯអំពើប្រកបដោយគុណធម៌ក៏ឋិតនៅត្រង់អំពើនោះលំឱនទៅតាមលំដាប់ថ្នាក់នោះឯង។

ក៏ប៉ុន្តែគុណធម៌អាចខ្លាំងជាងនេះទៅទៀត គឺគុណធម៌អាចទៅជាចិត្តបុណ្យ។ ហើយចិត្តបុណ្យនេះ ដូចដែលលោក ដេកាត(Descartes)បាននិយាយនៅក្នុងស្នាដៃរបស់គាត់ឈ្មោះ «កម្រងនៃលំងប់» ថាវាគឺជាកូនសោនៃគុណធម៌ផ្សេងៗទាំងអស់។

ជាពិសេសទៅទៀត គុណធម៌គឺសេចក្តីខ្ជាប់ខ្ជួន សេចក្តីព្យាយាម។ ក្នុងន័យនេះ គុណធម៌គឺជាទម្លាប់នៃកុសល។ អំពើពិសេសទុកជាមានវីរភាពយ៉ាងណាក៏ដោយទុកជាគួរកោតសរសើរយ៉ាងណាក៏ដោយ ក៏ពុំមានលក្ខណៈគ្រប់គ្រាន់នឹងទៅជាគុណធម៌បានដែរ។ ដើម្បីបញ្ជាក់គំនិតខាងលើនេះ អារីស្តូត និយាយថា "សត្វត្រចៀកកាំមួយពុំអាចបង្កើតនិទាឃរដូវបានទេ"។ គុណធម៌ គឺជាលំដាប់អចិន្ត្រៃយ៍ ហើយច្រើនតែបានមកដោយប្រឹង។ គុណធម៌គឺជាឆន្ទៈច្បាស់លាស់នៅក្នុងសីលចរិយា។

ប៉ុន្តែ «គុណធម៌ ឬគុណធម៌ទូទៅប្លែកពី «គុណធម៌ផ្សេងៗ»។

### ១.២.២ ភាពប្លែកគ្នារវាងគុណធម៌និងគុណធម៌ផ្សេងៗ

កាលណាគេនិយាយពីគុណធម៌ទាំងឡាយ ឬ គុណធម៌នីមួយៗ គេតែងចាត់ទុកជាពិសេសនូវកុសលដែលបានសម្រេចមែនទែនហើយ។ឧទាហរណ៍៖ អាការទៀងពេល ការចេះប្រមាណមិនឱ្យហួស ភក្តីភាព ភាពខ្ជាប់ខ្ជួន ការគួរសម។ ផ្ទុយទៅវិញ គុណធម៌ ឬគុណធម៌ទូទៅ សំដៅថាមពលឆន្ទៈទៅរកកុសល។

គុណធម៌ពិសេសៗ ឬមួយៗអាចមានមកពីកំណើត ឧទាហរណ៍ ចិត្តល្អ ភាពមិនរឹងរូស។ ផ្ទុយទៅវិញគុណធម៌ទូទៅតម្រូវឱ្យមានការប្រឆាំងនឹងទំនោរជាន់ទាប។

### ១.២.៣ ចំណែកថ្នាក់គុណធម៌

អារីស្តូត បានចែកគុណធម៌ជាពីរក្រុមគឺគុណធម៌បញ្ញា និងសីលគុណធម៌។ តើគុណធម៌ទាំងពីរក្រុមនេះមានលំនាំយ៉ាងណាទៅតាមគំនិតអារីស្តូតនោះ?

(១). គុណធម៌បញ្ញា គឺជាគុណធម៌ដែលធ្វើឱ្យបញ្ញារិះគិតកាន់តែល្អឡើងដើម្បីសាងពុទ្ធិខាងសច្ចៈ។ ក្នុងចំណោមគុណធម៌បញ្ញានេះគេអាចរៀបរាប់ដូចតទៅ៖ សិល្បៈ ស្បង់ ការប្រុងប្រយ័ត្ន គតិវិញ្ញូ និងបញ្ញា។

(២). សីលគុណធម៌ គឺជាគុណធម៌ដែលមាននៅក្នុងទម្លាប់គ្រប់សង្កត់លើសំទុះរុញនៃវិចារណញ្ញាណ និងក្នុងទម្លាប់ប្រព្រឹត្តឱ្យសមរម្យត្រឹមត្រូវ ទោះជានៅក្នុងស្ថានភាពណាក៏ដោយ។ សីលគុណធម៌ដែលសំខាន់ជាងគេ គឺសេចក្តីក្លាហាន ការចេះប្រមាណ យុត្តិធម៌ និងគតិវិញ្ញូ។

ការបំបែកគុណធម៌ជាពីរបែបតាម អារីស្តូត នេះគ្មានបំណងអ្វីក្រៅពីចង់បង្ហាញបំណងរកកុសលនិងការរៀបចំឱ្យសមតាមវិចារណញ្ញាណនៅក្នុងជីវិតលោកិយយើងនេះឡើយ។ លោក ថូម៉ាស(Saint Thomas)បានគាំទ្រគំនិតអារីស្តូតនេះដោយសុទ្ធចិត្ត។ តែលោក តូម៉ាស បានបន្ថែមគុណធម៌មួយបែបទៀត គឺទៅគុណធម៌ទេវកម្មវត្ថុ។ ក្នុងចំណោមគុណធម៌ទេវកម្មវត្ថុនេះគេអាចរៀបរាប់ដូចតទៅ៖ ជំនឿចំពោះសាសនា ការសង្ឃឹម និងសេចក្តីសប្បុរស។ គុណធម៌ទេវកម្មវត្ថុទាំងបីនេះដឹកនាំយើងឱ្យអាចឃើញអាទិទេពដោយអព្ភន្តរញាណ។ ប៉ុន្តែគំហើញអាទិទេពនេះ

ហួសលទ្ធភាពនៃធម្មជាតិយើងទាំងស្រុងព្រោះបើយើងគិតឱ្យមែនទែនមនុស្សយើងពុំអាចមានសមត្ថភាពមើលឃើញអាទិទេពទេ។ ប៉ុន្តែ អារីស្តូត និយាយថាមានគុណធម៌ដែលអាចដឹកនាំយើងឱ្យមើលឃើញអាទិទេព ហើយគុណធម៌នោះ មនុស្សយើងពុំអាចរកបានដោយចលនាដោយពិសោធន៍ ដោយការខំប្រឹង ដោយការខំប្រឹង ដោយការហាត់រៀនទេ។ តាម អារីស្តូត គុណធម៌នោះគឺជាអំណោយឯកឯងរបស់អាទិទេព។

(៣). សញ្ញាណស្រដៀងនិងគុណធម៌គឺ សុក្រឹតភាព និង គុណូបការៈ។

(ក). សុក្រឹតភាព

តាមឫសគល់នៃពាក្យ អ្វីសុក្រឹត(parfait)គឺអ្វីដែលគេបានធ្វើដោយសព្វគ្រប់ ឬអ្វីដែលគេពុំអាចបន្ថែមអ្វីទៅទៀតបាន។ ដូចនេះ សុក្រឹតភាពគឺជាលក្ខណៈនៃអ្វីដែលប្រជុំគ្រប់គុណសម្បត្តិដោយពុំលាយឡំនឹងគុណវិបត្តិ។ ក្នុងន័យនេះសុក្រឹតភាពប្រើតែឯកវចនៈហើយជាសទិសន័យ និងគុណសម្បត្តិនឹងគុណធម៌។ ចុះគុណូបការៈវិញ តើមានន័យយ៉ាងណាដែរ?

(ខ). គុណូបការៈ

តាមន័យទូលាយ «គុណូបការៈ» បានសេចក្តីថា តម្លៃហើយជាពិសេស តម្លៃវិជ្ជាជីវៈនៃបុគ្គលនីមួយៗ ឬតម្លៃនៃស្នាដៃនីមួយៗ។

តាមន័យក្នុងសីលវិជ្ជាឬន័យចង្អៀតវិញ គុណូបការៈសំដៅលើតែអ្វីដែលជាសីលតម្លៃ។ ក្នុងករណីនេះ គុណូបការៈប្រើក្នុងន័យអរូបី ប្រើជាឯកវចនៈហើយបានសេចក្តីថាគុណធម៌ដែរ។ ក្នុងន័យទីពីរនេះគុណូបការៈនឹងទទួលនិយមន័យថា«សីលតម្លៃ» តម្លៃដែលប្រកបដោយទំហំប្រឹង ដើម្បីពុះពារនូវការពិបាក ហើយជាពិសេស ដើម្បីពុះពារឧបសគ្គខាងក្នុង ដែលប្រឆាំងនឹងសីលចរិយា។ គឺមកពីមាននិយមន័យបែបនេះហើយ បានជាគេថ្លឹងតម្លៃគុណូបការៈទៅតាមការពិបាកដែលគេបានពុះពារឈ្នះហើយ។

អំពើមួយមានគុណូបការៈច្រើន កាលណាអំពើនោះបានតម្រូវនូវកំហំប្រឹងច្រើន ឬ គុណធម៌ធំៗ។

ប៉ុន្តែពាក្យ«គុណូបការៈ»នេះមានប្រើតែក្នុងន័យអរូបី និងជាពហុវចនៈដែរគឺមាននៅក្នុងសីលទេវវិជ្ជានេះឯង។ ឧទាហរណ៍៖ គេនិយាយពីគុណូបការៈទាំងឡាយនៃព្រះយេស៊ូ នៃម្តាយព្រះយេស៊ូ នៃពួកសន្តបុគ្គល។ នៅក្នុងករណីនេះ គុណូបការៈបានសេចក្តីថាសុក្រឹត្យភាពនៃស្នាដៃ និងសេចក្តីថ្លៃថ្នូរនៃភ្នាក់ងារ។ គឺនៅក្នុងនិយមន័យនេះហើយ ដែលគេនិយាយថាគុណូបការៈនៃព្រះយេស៊ូគ្មានព្រំដែនគ្មានទីបញ្ចប់ទេ ព្រោះព្រះយេស៊ូជាអាទិទេព។ ដោយសារមាន គុណូបការៈ ឬតម្លៃ ច្រើនដូចនេះហើយ បានជាមនុស្សមានតម្លៃ ឬគុណូបការៈប្លែកៗគ្នាទៅតាមកម្រិតនិងសណ្ឋាននៃគុណធម៌ផ្សេងៗ។

(៤). តួយ៉ាង «ជនឧត្តម» ខ្លះៗ

លោក ម៉ាក្ស សែលែ(Max Scheler) បាននិយាយថា«មនុស្សប្រកបដោយតម្លៃ» អាចមានជាតួយ៉ាងពីរ ឬបីនាក់ដែរ។ ឯមនុស្សនោះ គឺជាអ្នកដែលមានកម្រិតគុណធម៌ ឬកម្រិត គុណូបការៈខ្ពស់។ ក្នុងចំណោមមនុស្សនេះ គេអាចរៀបរាប់អ្នកដែលសំខាន់ជាងគេដូចតទៅ៖

(ក). វិញ្ញូ (le sage)

ពាក្យវិញ្ញូនេះមានឫសគល់វែងបន្តិច។ ដំបូងនៅក្នុងអរិយធម៌ឡាតាំង វិញ្ញូបើចំពោះវត្ថុគឺសំដៅអ្វីដែលមានរសបើចំពោះមនុស្ស គឺសំដៅអ្នកដែលចេះច្បាស់នូវអ្វីមួយ។ ពាក្យវិញ្ញូរបស់អរិយធម៌ឡាតាំងនេះមានន័យថាអ្នកប្រាជ្ញផងថាជាវិញ្ញូផង។

កាលពីដើមគតិវិញ្ញូសំដៅគុណធម៌បញ្ញា។ សព្វថ្ងៃគតិវិញ្ញូសំដៅលើសីលគុណធម៌។

គតិវិញ្ញូតម្រូវឱ្យមានស្បង់មួយ ប៉ុន្តែជាស្បង់ដែលមានកម្មវត្ថុជាមនុស្ស ពុំមែនមានកម្មវត្ថុជារបស់ទេ ហើយជាស្បង់ដែលចេញមកពីការគិតពិចារណាយ៉ាងយូរ លើពិសោធន៍ធម្មតាពុំមែនជាស្បង់ដែលចេញមកពីការសិក្សានោះទេគតិវិញ្ញូនេះមានភាពឈ្លាសវៃទាំងផ្លូវបញ្ញាយ៉ាងធំ។ ប៉ុន្តែវិញ្ញូប្រព្រឹត្តដោយអព្ភន្តរញ្ញាណសំយោគ ពុំមែនដោយវិធីវិចារ និងវិភាគរបស់គំនិតវិចារណញ្ញាណនោះទេ។ ជាពិសេសទៅទៀតវិញ្ញូពុំសម្រាំងស្មារតីលើអ្វីៗដែលមានភ្លាមៗនោះទេហើយវិនិច្ឆ័យលើអ្វីៗដោយយោងទៅតាមគោលការណ៍ធំៗនិងទៅតាមបញ្ញត្តិកម្មទូទៅនៃជីវិត។

និយាយឱ្យខ្លី វិញ្ញូ មើលឆ្ងាយហើយជាពិសេសវិញ្ញូរស់នៅដោយមានសណ្ដាប់ធ្នាប់ណាស់។ «គំនិតប្រកបដោយគតិវិញ្ញូនីមួយៗ» តាមសម្ដី ស៊ូប៊ែ(Joubert) ជាចំណងចងមនុស្សឱ្យជាប់នៅនឹងកន្លែងខ្លួនក្នុងសកលលោកហើយធ្វើឱ្យមនុស្សនោះមានសញ្ចេតនាដឹងកន្លែងខ្លួននិងធ្វើឱ្យមនុស្សស្រឡាញ់កន្លែងខ្លួនដូចជាស្រឡាញ់កន្លែងកំណើត កន្លែងស្រួល កន្លែងធ្លាប់។

វិញ្ញូគឺមនុស្សប្រកបដោយទម្លាប់ទៀងទាត់ ព្រោះទំនៀងទំនាត់អាចធ្វើឱ្យវិញ្ញូចៀសរួចពីការយកមកជជែកផ្ទួរផ្ទងឡើងវិញនូវការជ្រើសរើសមិនសំខាន់ និងឱ្យរួចពីការធ្លាក់ទៅក្នុងកង្វះប្រមាណ។ វិញ្ញូអាចមានលក្ខណៈសម្បត្តិជួនកាលឡើងរហូតដល់គុណធម៌ហើយប្រហែលជាអាចរហូតទៅដល់វីរភាពថែមទៀតផង។ ប៉ុន្តែមានតែសុក្រឹតភាពនៃជីវិតឥតពន្លឺមួយទេដែលស្របទៅតាមសេចក្ដីប្រាថ្នារបស់វិញ្ញូមែនទែន។

(ខ). វីរបុរស (Héros)

នៅពេលដែលគតិវិញ្ញូមានជានិច្ចនូវការចេះប្រមាណ(mesure) វីរភាពតែងមានផ្ទុយទៅវិញនូវអ្វីដែលហួសហេតុ(démesuré) ហួសពីខ្នាតសមត្ថភាពមនុស្ស។

ពីដើមវីរបុរសគឺជាមនុស្សពាក់កណ្ដាលអាទិទេពពាក់កណ្ដាល(demidieu) ឬជាមនុស្សដែលមានគេលើកជាអាទិទេព ឬក៏ជាភាវៈអាថ៌កំបាំងដែលនៅក្រៅធម្មជាតិ។

សព្វថ្ងៃនេះ គេហៅថាវីរបុរសតែអ្នកណាដែលបង្កើតអំពើដែលនឹងអាចសម្រេចទៅបានដោយសារកម្លាំងឬសេចក្ដីក្លាហានសឹងតែផុតវិស័យមនុស្ស។ វីរភាពអាចមើល ឬសង្កេតឃើញបាន កាលណាវីរភាពនោះចូលទៅបម្រើព្រឹត្តិការណ៍ធំៗ ជាពិសេសនៅក្នុងចម្បាំង ដែលគេត្រូវពុះពារសេចក្ដីស្លាប់ និងការឈឺចាប់ខ្លាំងបំផុតទាំងខាងផ្លូវចិត្តទាំងខាងផ្លូវកាយ។

(គ). សន្តបុគ្គល

សន្តភាព(sainteté) មានគតិវិញ្ញូនិងវីរភាពដែលមានទំហំឬខ្នាតប្លែកៗគ្នា ផ្សេងៗគ្នា។ តែសន្តបុគ្គលប្លែកពីវិញ្ញូនិងពីវីរបុរស ត្រង់សន្តបុគ្គលរស់នៅដោយយកអាទិទេពមកធ្វើជាធំ ជាគោល ជាវត្ថុបំណង។

តាមឫសគល់នៃពាក្យអ្វីដែលសន្តៈ(saint)គឺអ្វីដែលគេធ្វើឱ្យពិសិដ្ឋ(sacré) ពោលគឺអ្វីដែលគេលើកទៅដល់ភាពថ្លៃថ្នូរ(dignité)ដែលញែកចេញឱ្យដាច់ស្រឡះពីគ្នានូវវត្ថុនោះនិងវត្ថុសាមញ្ញ ហើយដែលធ្វើឱ្យមនុស្សសាមញ្ញ(le vulgaire)ពុំអាចរំលោភបានឬប៉ះពាល់បាន។ គឺក្នុងន័យនេះហើយដែលជើងសម្រាប់បូជា ឬសន្តភាជន៍(vase saint) មិនអាចអ្នកណាប៉ះពាល់បានក្រៅពីបុព្វជិត(prêtre) បើតាមគោលការណ៍។ ឯសន្តបុគ្គលមែនទែនតាមធម្មតានៅឋានសួគ៌ឯណោះទេ។

ដូចនេះ គេត្រូវចាំមនុស្សនោះស្លាប់សិន ទើបគេអាចនិយាយថាមនុស្សនោះមានសន្តភាព។ ឯបុគ្គលដែលយើងនាំគ្នាសន្មត់នៅក្នុងលោកយើងនេះ អាចឫសមនឹងទទួលងារឬក៏ឈ្មោះថាសន្តបុគ្គលបាន ដោយសារតែការប្រៀបប្រដូច ឬដោយសារតែការស្មានទុកជាមុននូវអនាគតភាវៈរបស់អ្នកនោះឯងដែលយើងដឹងតាំងពីឥឡូវថានឹងដូចនោះឯង។

តួយ៉ាងនៃសីលជីវិតទាំងបីដែលយើងបាននិយាយមកនេះ គេអាចប្រៀបធៀបគ្នាទៅតាមចំណុចលក្ខណៈមួយម្ដងៗ ហើយយើងអាចធ្វើការប្រៀបធៀបគ្នានេះដោយប្រើតារាងរួមមួយដែលយើងជូនជាប់មកនេះ(សូមពិនិត្យតារាង

រួមនៅទំព័រក្រោយ)។ មានតែការប្រើតារាងរួមរបៀបនេះទេ ដែលអាចធ្វើឱ្យការប្រៀបធៀបនេះស្រួលមើល ហើយងាយយល់។ សូមពិនិត្យតារាងរួម៖

| | បំណក់ទាញ (inspiration) | របៀបជីវិត (style) | ឥរិយាបថចំពោះធម្មជាតិ (attitude envers la nature) | ឥរិយាបថចំពោះគ្រឿងស្រើបភាព (attitude envers la ) | ឥរិយាបថចំពោះអ្នកដទៃ (attitude envers la autrui) | ការមិនគិតប្រយោជន៍ផ្ទាល់ខ្លួន (désintéres sement) |
|---|---|---|---|---|---|---|
| វិញ្ញូ | បញ្ញានិយម | លំនឹង | ធ្វើតាម ធម្មជាតិ | មិនរំភើប | បុគ្គលនិយម | គុណធម៌ជារង្វាន់ផ្ទាល់ខ្លួន |
| វីរបុរស | សន្ទុះដោយសភាវគតិ | ភាពក្លៀវក្លា ហួសហេតុ | ការហួសការលើសឈ្នះ ធម្មជាតិ | លំងប់ | បុគ្គលនិយម ហួសហេតុ | ចិត្តបុណ្យ |
| សន្តបុគ្គល | ជំនឿលើសាសនា ស្យង់ខាងកាន់សាសនាតឹងរឹង | ការមិនស្កប់ស្កល់ក្នុងការស្វែងរកសុក្រឹតភាពដែលគ្មានព្រំដែន | អតិសេដ្ឋភាព ហួសធម្មជាតិ | តបៈ | ការត្រូវគំនិតគ្នា | បារម្ភតែលើសុគតិភព |

បើយើងពិនិត្យមើលតារាងនេះឱ្យមែនទែន យើងនឹងឃើញយ៉ាងច្បាស់ ក្រឡែតនូវលក្ខណៈដូចគ្នាខ្លះ។ ថ្វីត្បិតតែតួយ៉ាងជីវិតទាំងបីប្រើមធ្យោបាយប្លែកគ្នា ដាច់គ្នាស្រឡះក៏ដោយ ក៏នៅមានសភាពដូចគ្នាត្រូវគ្នាមួយដែរ។ ឯសភាពត្រូវគ្នានេះ គឺគោលដៅធំដែលគេប៉ងប្រាថ្នា គឺវត្ថុបំណង។ បុគ្គលទាំងបីប្រាថ្នារបស់តែមួយដូចគ្នា គឺសេចក្ដីល្អ ទោះបីសេចក្ដីល្អនោះជាគុណធម៌ក៏ដោយ ជាចិត្តបុណ្យក៏ដោយ ជាគំនិតសុគតិភពក៏ដោយ។ ព្រោះតែអ្នកទាំងបីប្រាថ្នាគោលដៅដូចគ្នា គឺគោលដៅដែលមនុស្សគ្រប់រូបប្រាថ្នាដែរនោះហើយ បានជាឧត្តមគតិនៃអ្នកទាំងបីនេះនៅតែមានតម្លៃជានិច្ច ហើយមានប្រយោជន៍យ៉ាងសម្បើមចំពោះយើង ព្រោះឧត្តមគតិនេះនឹងទៅជាផ្លូវមួយសម្រាប់ឱ្យយើងដើរតាមនឹងជាស្នូរជួងមួយសម្រាប់រំលឹកដាក់តឿនយើងឱ្យខិតខំសម្រេចសីលគោលការណ៍ផ្ទាល់របស់យើងផង។ ឯសីលគោលការណ៍ផ្ទាល់ខ្លួនយើងនោះ គឺការកសាងនូវបុគ្គលិកលក្ខណៈយើង។ ដូចនេះឧត្តមគតិនៃមនុស្សជាតួយ៉ាងទាំងបីខាងលើនេះ ជាកត្តាមួយដែលនាំយើងឱ្យស្ថាបនាបុគ្គលិកលក្ខណៈទៅរកផ្លូវល្អ៕

# មេរៀនទី២ ទំនួលខុសត្រូវ និងវិបាកវិនិច្ឆ័យ

## ២.១ ទំនួលខុសត្រូវ

### ២.១.១ និយមន័យ

ទំនួលខុសត្រូវមាននិយមន័យថាជាកាតព្វកិច្ចដែលត្រូវ «រ៉ាប់រង» អំពីអំពើរបស់ខ្លួនឬជានាអំពីអ្វីមួយនៅចំពោះមុខអំណាចជាន់ខ្ពស់ណាមួយ។ ដូចនេះ ទទួលខុសត្រូវអំពីអំពើមួយគឺៈ

ក- សារភាពថាខ្លួនជាអ្នកប្រព្រឹត្ត

ខ- ហ៊ានទទួលវិបាកនៃអំពើនោះ ទោះជាខាងផ្នែកសីលវិជ្ជាក្តី ខាងផ្នែកសង្គមក្តី ពោលគឺហ៊ានទទួលវិបាកវិនិច្ឆ័យ។ ឧទាហរណ៍ៈតាមរបបសភានិយម «ទំនួលខុសត្រូវនៃរដ្ឋមន្ត្រី» បង្ហាញនូវការដែលរដ្ឋមន្ត្រីទាំងអស់មានកាតព្វកិច្ចនឹងទៅឆ្លើយដោះសាចំពោះការចោទប្រកាន់ទាំងឡាយនិងត្រូវរ៉ាប់រងអំពីនយោបាយនៃរដ្ឋាភិបាលចំពោះរដ្ឋសភា។ រដ្ឋមន្ត្រីទាំងនោះត្រូវឆ្លើយនឹង«សំណួរដេញដោល»នៃអ្នកតំណាងរាស្ត្រ។

គេអាចសម្គាល់ឃើញថាមានទំនួលខុសត្រូវពីរបែងយ៉ាងសំខាន់ អាស្រ័យទៅតាមធម្មជាតិនៃអំណាចដែលវិនិច្ឆ័យនូវអំពើរបស់យើង។

- យើងអាចនិយាយអំពីទំនួលខុសត្រូវផ្នែកសង្គម ( responsabilité sociale ) នៅពេលដែលយើងត្រូវឆ្លើយរ៉ាប់រងនៅចំពោះមុខតុលាការ ពោលគឺនៅចំពោះអំណាចនៃសង្គម។

- ម្យ៉ាងទៀតយើងអាចនិយាយអំពីទំនួលខុសត្រូវផ្នែកសីលវិជ្ជា ( responsabilité morale ) នៅពេលដែលញាណរបស់យើងទទួលស្គាល់ថា យើងជាអ្នកប្រព្រឹត្ត ហើយតម្រូវឱ្យយើងទទួលរ៉ាប់រងអំពីអំពើរបស់យើងនៅចំពោះមុខ «តុលាការនៃញាណ» ពោលគឺចំពោះមុខ «សីលញាណ»។ យើងនឹងបញ្ជាក់ឱ្យច្បាស់លាស់ថែមទៀតនូវសញ្ញាណនៃទំនួលខុសត្រូវទាំងពីផ្នែកខាងលើនេះ។

### ២.១.២ ទំនួលខុសត្រូវផ្នែកសីលវិជ្ជា

បើយើងពិចារណាលើសញ្ចេតនាដែលយើងមាន នៅពេលដែលញាណយើងវិនិច្ឆ័យថាយើងទទួលខុសត្រូវអំពីអំពើមួយ នោះយើងនឹងឃើញភ្លាមថា ការវិនិច្ឆ័យបែបនេះតម្រូវឱ្យមានល័ក្ខខ័ណ្ឌពីរៈ

ក. ដើម្បីនឹងទទួលខុសត្រូវ គេត្រូវមានញាណគ្រប់គ្រាន់ ហើយគេត្រូវតែមានសមត្ថភាពនឹងស្គាល់កុសលនិងអកុសល ពោលគឺគេត្រូវស្គាល់ជាក់ច្បាស់អំពីសីលតម្លៃទាំងឡាយ។ ឧទាហរណ៍ ដូចជាក្មេងម្នាក់អាយុដប់ឆ្នាំបាននិយាយប្រាប់អ្នកដទៃនូវសំដីដែលឪពុកម្តាយវាបាននិយាយចំពោះមុខវា វាអាចនឹងកើតមានពីការមិនចេះលាក់អាថ៌កំបាំងនេះនូវវិបាកធ្ងន់ធ្ងរបាន។ ប៉ុន្តែ ក្មេងនេះបាននិយាយ«ដោយគ្មានបំណងអាក្រក់» ទេ។ គ្មាននរណាមានការប្រុងប្រយ័ត្ននឹងហាមប្រាមវាមិនឱ្យនិយាយពាក្យទាំងនោះឡើយ ហើយវាខ្លួនឯងក៏គ្មានការសង្ស័យថានឹងមានវិបាក ដែលអាចកើតមានឡើងពីការនិយាយច្រើនរបស់វាដែរ។ ហើយគេក៏មិនអាចឱ្យក្មេងនេះទទួលខុសត្រូវផ្នែកសីលវិជ្ជាអំពីអកុសលដែលវាអាចនឹងធ្វើនោះឡើយ។

ខ. យើងអាចនឹងទទួលស្គាល់ថា យើងជាអ្នកប្រព្រឹត្តអំពើនិងទទួលរ៉ាប់រងអំពើនោះចំពោះសីលញាណរបស់យើង ក៏លុះត្រាតែយើងមានសេរីភាពពេញលេញដែរ។ ប្រសិនបើយើងត្រូវគេបង្ខិតបង្ខំដោយការគំរាមកំហែងឱ្យបំពេញអំពើមួយដែលញាណរបស់យើងបដិសេធមិនទទួលស្គាល់ ប្រសិនបើយើងប្រព្រឹត្តនៅក្នុងភាពនៃការមេមើ ឬនៅក្រោមឥទ្ធិពលនៃការឡប់សតិ ( désordre mental ) ដែលធ្វើឱ្យយើងអស់សមត្ថភាពនឹងធ្វើការជ្រើសរើស យើងក៏គ្មានទំនួលខុសត្រូវផ្នែកសីលវិជ្ជាដែរ។

ដូចនេះទំនួលខុសត្រូវផ្នែកសីលវិជ្ជាតម្រូវឱ្យមានពុទ្ធិនៃតម្លៃផង និងសេរីភាពផង។

### ២.១.៣ ទំនួលខុសត្រូវផ្នែកសង្គម

ទំនួលខុសត្រូវផ្នែកសង្គមមានលក្ខណៈច្បាស់លាស់ គឺជាទំនួលខុសត្រូវដែលនាំឱ្យយើងត្រូវទៅទទួលការកាត់សេចក្ដីចំពោះមុខតុលាការ ប្រសិនបើអំពើរបស់យើងមានលក្ខណៈផ្ទុយនឹងច្បាប់ដែលមានជាធរមាន។

ប៉ុន្តែ នៅទីនេះយើងត្រូវចែកឱ្យច្បាស់នូវទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងទំនួលខុសត្រូវផ្នែករដ្ឋប្បវេណី។

ក. មនុស្សម្នាក់ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ នៅពេលដែលខ្លួនបានប្រព្រឹត្តទោសកម្មបទមជ្ឈិមឬបទឧក្រិដ្ឋ ហើយក្នុងលក្ខណៈនេះមនុស្សនោះត្រូវគេប្ដឹងឱ្យតុលាការជំនុំជំរះនៅសាលាលហុ ឬសាលាឧក្រិដ្ឋ។

ខ. មនុស្សម្នាក់ទទួលខុសត្រូវផ្នែករដ្ឋប្បវេណី នៅពេលដែលច្បាប់បង្ខិតបង្ខំខ្លួនឱ្យជួសជុលកំហុចខាតដែលខ្លួន ឬ អ្នកដែលនៅក្រោមអាណាព្យាបាលរបស់ខ្លួនបានធ្វើដល់អ្នកដទៃ។ ក្រមរដ្ឋប្បវេណី «គេត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណីមិនត្រឹមតែអំពីកំហុចខាតដែលគេបានធ្វើដោយអំពើរបស់គេផ្ទាល់ប៉ុណ្ណោះទេ តែអំពីកំហុចខាតដែលបានធ្វើឡើងដោយមនុស្សដែលគេត្រូវធានាទៀតដែរ»(បារព្រាវ កូនដែលអាយុពុំទាន់ពេញវ័យច្បាប់ឬក៏«អំពីវត្ថុដែលនៅក្នុងបន្ទុករបស់គេ»)។ ដូចនេះមេគ្រួសារត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណីពីកំហុចខាត ដែលកូនមិនទាន់ពេញវ័យច្បាប់បានបង្កបង្កើតឡើងទោះបីកូននោះជាកូនមិនលុះដោយដំបូន្មានរបស់ម៉ែឪក៏ដោយ។

ប្រសិនបើគេលួចរថយន្តរបស់យើងហើយចោរដែលលួចនោះបរទៅកិនថ្មើរជើងម្នាក់យើងជាម្ចាស់រថយន្តត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី(បើពុំនោះសោតគឺក្រុមហ៊ុនធានារ៉ាប់រងរថយន្តរបស់យើងដែលនឹងត្រូវសង)នៅពេលណាដែលយើងមិនទាន់បានប្ដឹងអំពីបទលួចរថយន្តនេះនៅស្នងការដ្ឋាននគរបាល។

យើងលើកយកឧទាហរណ៍មួយយ៉ាងងាយបំផុតដែលនាំឱ្យយើងអាចសម្គាល់បាននូវទំនួលខុសត្រូវផ្នែករដ្ឋប្បវេណីនិងទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌមកអធិប្បាយដូចតទៅនេះ អ្នកបើករថយន្តផ្ទុកមនុស្សម្នាក់ស្រវឹងស្រាបានធ្វើឱ្យមានគ្រោះថ្នាក់។ អ្នកជិះខ្លះត្រូវរបួស។ ពិតមែនហើយដែលថាអ្នកបើករថយន្តនេះទទួលខុសត្រូវតាមច្បាប់ព្រហ្មទណ្ឌ ប៉ុន្តែគឺក្រុមហ៊ុនដឹកនាំទេ ដែលទទួលខុសត្រូវតាមច្បាប់រដ្ឋប្បវេណី។ គួរកត់សម្គាល់ថាចំពោះរឿងនេះ «នីតិបុគ្គល» សមាគមមួយ ក្រុមហ៊ុនអនាមិកមួយអាចនឹងទទួលខុសត្រូវផ្នែករដ្ឋប្បវេណីដែរ។

បើយើងងាកចេញពីច្បាប់ឯកជន ទៅមើលច្បាប់សាធារណៈវិញ យើងគួររំលឹកឡើងវិញថារដ្ឋខ្លួនឯងក៏អាចទទួលខុសត្រូវផ្នែករដ្ឋប្បវេណីដែរ។ ប្រសិនបើថ្មើរជើងម្នាក់ត្រូវរថយន្តទាហាន ឬក៏ត្រូវរថយន្តក្រុមហ៊ុនឯកជនមួយកិន នៅក្នុងករណីទាំងពីរនេះ អ្នកនោះមានសិទ្ធិនឹងទាមទារសំណងបានដូចគ្នា។ នៅក្នុងឧទាហរណ៍នេះ គេឃើញថាទំនួលខុសត្រូវផ្នែករដ្ឋប្បវេណីហាក់ដូចជាឋិតនៅក្រោមការយកចិត្តទុកដាក់ទៅលើអ្វីផ្សេងពីទំនួលខុសត្រូវផ្នែកសីលវិជ្ជា។ ការសំខាន់មិនមែនឋិតនៅលើគោលបំណងរបស់ «អ្នកទទួលខុសត្រូវ»នោះទេ ដោយអ្នកទទួលខុសត្រូវនោះមិនចាំបាច់តែជាបុគ្គល «ដែលមានរូបរាង» នោះទេ គឺជាកំហុចខាតដែលបានធ្វើទៅហើយ ហើយអ្នកទទួលខុសត្រូវគឺអ្នកណាដែលអាចសងនូវកំហុចខាតនោះបាន។ ម្យ៉ាងទៀតស្ថាប័ននៃទំនួលខុសត្រូវផ្នែករដ្ឋប្បវេណី ក៏កំណត់ឱ្យមាន ការពឹងផ្អែកទៅលើក្រុមហ៊ុនធានារ៉ាប់រងដែលទទួលបន្ទុកខាងគ្រោះថ្នាក់ដែរ។ តាមពិត ស្ថាប័ននេះមានលក្ខណៈដូចជាប្រព័ន្ធរួមមួយយ៉ាងទូលាយនៃកិច្ចការពារនិងការធានាទៅវិញទៅមក។

### ២.១.៤ ទំនាក់ទំនងនៃទំនួលខុសត្រូវផ្នែកសង្គមនិងទំនួលខុសត្រូវផ្នែកសីលវិជ្ជា

គួរកត់សម្គាល់ថា នៅក្នុងទំនៀមទម្លាប់និងនៅក្នុងការតែងច្បាប់របស់យើង សព្វថ្ងៃ ទំនួលខុសត្រូវផ្នែកសង្គមនិងទំនួលខុសត្រូវផ្នែកសីលវិជ្ជាមិនមែនឋិតនៅដាច់ពីគ្នាស្រឡះទេ។ តាមពិតទោះជាតិចឬច្រើន ទំនួលខុសត្រូវផ្នែកសីលវិជ្ជាជាមូលដ្ឋាននៃទំនួលខុសត្រូវផ្នែកសង្គម។

**ក. ទំនាក់ទំនងរវាងទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌនិងទំនួលខុសត្រូវផ្នែកសីលវិជ្ជា**

ទំនាក់ទំនងប្រភេទនេះមានលក្ខណៈច្បាស់លាស់ណាស់។ ចំពោះទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គេមិនត្រឹមតែធ្វើវិបាកវិនិច្ឆ័យទៅលើទម្ងន់ «ពិតប្រាកដ» នៃកំហុសមួយ ឬទៅលើសារៈសំខាន់នៃកំហូចខាតឡើយ។ គេគិតជាពិសេសទៅលើពិរុទ្ធភាពនៃអ្នកប្រព្រឹត្តទោសកម្ម ពោលគឺទៅលើឆន្ទៈផ្ទាល់ខ្លួនរបស់អ្នកនោះ។ គឺដោយសារហេតុនេះហើយ បានជាមនុស្សឃាតដោយឆន្ទៈត្រូវមានទោសធ្ងន់ជាងមនុស្សឃាតធ្វេសប្រហែស «ទោះជាកំហូចខាតវត្ថុវិស័យដូចគ្នាក៏ដោយ»ហើយមនុស្ស ឃាតដោយឆន្ទៈរឹតតែមានទោសធ្ងន់ណាស់ទៅទៀត ប្រសិនបើអំពើនោះត្រូវបានគិតទុកជាមុន។ តាមគោលការណ៍ទោះជា «គ្មាននរណាម្នាក់អាចសន្មតថាមិនស្គាល់ច្បាប់ឡើយ» ក៏ដោយក៏អ្នកជាប់ពិរុទ្ធដែលជាមនុស្សល្ងីល្ងើត្រូវគេទទួលស្គាល់ថាគ្មានទំនួលខុសត្រូវដែរ ឬក៏គេអាចឱ្យមនុស្សនោះទទួលខុសត្រូវយ៉ាងស្រាលបំផុត។ ហើយអ្វីដែលបំផ្លាញឬបន្ថយសេរីភាពក្នុងការជ្រើសរើសក៏បន្ថយកម្រិតនៃទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែរ។

មេធាវីតែងតែខំប្រឹងប្រែងបង្ហាញឱ្យឃើញអំពីតំណពូជអាក្រក់ ការអប់រំមិនជិតដល់លក្ខខណ្ឌដ៏អាស្រូវនៃជីវិតរបស់ឧក្រិដ្ឋជនដែលជាកូនក្តីរបស់ខ្លួន។ អាស្រ័យហេតុនេះ មេធាវីតែងសុំបានជាញឹកញយនូវការអនុគ្រោះពីក្រុមប្រឹក្សាតុលាការឱ្យមាន«ស្ថានភាពសម្រាលទោស» ពោលគឺធ្វើឱ្យការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌស្រាលជាងក្នុងស្ថានភាពធម្មតា។ ឧទាហរណ៍ ដូចជាអ្នកជាប់ពិរុទ្ធម្នាក់បានសម្លាប់ម្តាយរបស់ខ្លួនដោយឃោរឃៅព្រៃផ្សៃ។ អំពើនេះធ្វើឱ្យគេរន្ធត់យ៉ាងខ្លាំងប៉ុន្តែអ្នកជំនាញចិត្តវេជ្ជវិទ្យាបានពិនិត្យអ្នកជាប់ចោទ ដោយវង្វាស់លលកខួក្បាលដោយអគ្គីសនីទៅឃើញថាលលកខួក្បាល «អាល់ផា» របស់សាមីជនមិនស្មើដូចលលកខួរក្បាលរបស់មនុស្សធម្មតាឡើយ តែបែរជាមាន«ចុងស្រួច»និងស្នាមប្រេះ។ ពេលនោះ គេក៏ចាប់ធ្វើរោគវិនិច្ឆ័យនៃជំងឺឆ្កួតជ្រូក។ គេក៏ឃើញថាមនុស្សនេះបានប្រព្រឹត្តបទឧក្រិដ្ឋនៅពេលដែលមាន «អវត្តមានលំនឹក» នៃជំងឺឆ្កួតជ្រូក ។ នៅពេលនោះជននេះមិនដឹងខ្លួនព្រមទាំងគ្មានសេរីភាពផង។ មនុស្សនេះនឹងត្រូវរួចពីឱវាទនៃក្រសួងយុត្តិធម៌ ហើយត្រូវគេនាំទៅព្យាបាលនៅមន្ទីពេទ្យខាងវិកលចរិតវិញ។

ប៉ុន្តែ បើយើងពិចារណាលើឧទាហរណ៍នេះ យើងនឹងឃើញថា ការតម្រូវឱ្យមានទំនួលខុសត្រូវមានការពិបាកនឹងកំណត់ឱ្យបានត្រឹមត្រូវ ទៀងទាត់ពន់ពេកណាស់។ គឺគេអាចធ្វើយ៉ាងណា ដើម្បីនឹងធ្វើវិនិច្ឆ័យដាច់ខាតមួយទៅលើពិរុទ្ធភាពនៃជនជាប់ចោទដោយប្រើតិចនិចនៃចិត្តវេជ្ជវិទ្យា បើតិចនិចនេះមិនទាន់មានលក្ខណៈត្រឹមត្រូវឥតខ្ចោះហើយនៅតែប្រែប្រួលទៅតាមសម័យនិងកាលៈទេសៈនៅឡើយ? ប្រហែលជាហាសិបឆ្នាំមុនឧក្រិដ្ឋជនឆ្កួតជ្រូកដែលយើងលើកយកមកនិយាយនេះ(បើពីមុនមក គ្មានប្រកាច់«ឆ្កួតជ្រូកធ្ងន់» ហើយមានត្រឹមតែ«អវត្តមានលំនឹក» ដែលអ្នកជិតខាងមើលមិនឃើញ)មុនជានឹងត្រូវគេយល់ថាមានទោសមិនខាន។ ប៉ុន្តែបើ «អ្នកមានពិរុទ្ធ» ពីមុនបានត្រូវគេយល់ថាជាមនុស្សឈឺនៅបច្ចុប្បន្នតើថ្ងៃក្រោយទៅអ្នក «ជាប់ពិរុទ្ធ» បច្ចុប្បន្ននឹងទៅជាយ៉ាងណាដែរ?

ជាពិសេសទៅទៀត សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាតុលាការនៃសាលាឧក្រិដ្ឋ ដែលយោលទៅតាមតែការប៉ិនប្រសប់ ឬការមិនប៉ិនប្រសប់របស់មេធាវីហាក់ដូចជាមិនសូវមានការធានាឱ្យកក់ក្តៅសោះ។ នៅពេលមុន គេយល់ថាការពន្លូតកូនត្រូវទុកជា «បទឧក្រិដ្ឋ» តាមផ្លូវច្បាប់ដូចនេះ វាត្រូវឋិតនៅក្រោមឱវាទនៃសាលាឧក្រិដ្ឋ និងក្រោមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាតុលាការ តែស្ត្រីជាប់ចោទច្រើនតែរួចខ្លួនញឹកញយ(ទូទៅស្ត្រីនោះដាច់ចិត្តនឹងសម្រេចអំពើមនុស្សឃាតរបស់ខ្លួនលុះត្រាតែខ្លួនឋិតនៅក្នុងភាពក្រីក្រ ឬក៏ត្រូវគេបោះបង់ចោលក្នុងស្ថានភាពមួយគួរឱ្យរន្ធត់រហូតដល់ក្រុមប្រឹក្សាតុលាការរារែកចិត្តនឹងដាក់ទោសដល់នាង)។ ដូចនេះ អំណាចសាធារណៈដែលចង់ដាក់ទណ្ឌកម្មយ៉ាងធ្ងន់ដល់ការពន្លូតកូន បានលទ្ធផលផ្ទុយទៅវិញ ដោយត្រូវគេចាត់ទុកអំពើនេះថាត្រឹមត្រូវតែជាទោសកម្មធម្មតាដែលឋិតនៅក្រោមឱវាទនៃតុលាការបទមជ្ឈិម ពោលគឺនៅក្រោមការកាត់សេចក្តីរបស់ចៅក្រមទៅវិញ។

ប៉ុន្តែ ទោះជាល័ក្ខខ័ណ្ឌនៃទំនួលខុសត្រូវឋិតនៅលើសេរីភាព និងលើពុទ្ធិនៃសីលតម្លៃក៏ដោយក៏ល័ក្ខខ័ណ្ឌទាំងនេះ ហាក់ដូចជាទាក់ទងនៅនឹងពិសោធន៍ផ្ទាល់ខ្លួនរបស់ជនម្នាក់ៗទៅវិញ។ ដូចនេះយើងឃើញថាការវាយ

តម្លៃទំនួលខុសត្រូវរបស់អ្នកដទៃមានការពិបាកពន់ពេកណាស់។ គេច្រើនតែពិចារណាតាមភាពស្រដៀងគ្នាដោយដាក់ជា«ប៉ូស្ទុយឡា» យ៉ាងធ្វេសប្រហែសថាអ្នកម្នាក់ទៀតក៏ឋិតនៅក្នុងល័ក្ខខ័ណ្ឌដូចខ្លួនឯងដែរ។

ដោយហេតុនេះហើយ បានជាយើងតែងតែវិនិច្ឆ័យឃាតកម្មលើឪពុកម្ដាយយ៉ាងតឹងរ៉ឹងបំផុត(ពីព្រោះអំពើនេះនាំឱ្យយើងរន្ធត់យ៉ាងខ្លាំងនាំឱ្យយើងយើញថា អាក្រក់គួរឱ្យខ្លាចព្រោះវាផ្ទុយនឹងបញ្ញត្តិកម្មផ្ទាល់របស់យើងអំពីកុសល)។ ផ្ទុយទៅវិញ យើងមនុស្សភាគច្រើនប្រាកដជាប្រុងប្រៀបជាស្រេចនឹងអនុញ្ញាតឱ្យមានស្ថានភាពសម្រាលទោសដល់មនុស្សដែលជាឃាតកនៃសហាយរបស់ប្រពន្ធខ្លួន ព្រោះគេអាចយល់បានយ៉ាងងាយនូវសញ្ចេតនារបស់ឃាតកប្រភេទនេះ។ គួរកត់សម្គាល់ថា សេចក្ដីប្រច័ណ្ឌជា សញ្ចេតនាទូទៅក៏ពិតមែន តែភាពសាមញ្ញរបស់វាមិនធ្វើឱ្យសញ្ចេតនានេះមានលក្ខណៈថ្លៃថ្នូរតាមសីលវិជ្ជាបានឡើយ។

**ខ. ទំនាក់ទំនងរវាងទំនួលខុសត្រូវផ្នែករដ្ឋប្បវេណី និងទំនួលខុសត្រូវផ្នែកសីលវិជ្ជា**

ទោះជាទំនាក់ទំនងប្រភេទនេះមិនសូវប្រត្យក្ស ដូចទំនាក់ទំនងរវាងទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងទំនួលខុសត្រូវផ្នែកសីលវិជ្ជាក៏ដោយ ក៏អ្នកតែងច្បាប់ត្រូវគិតដល់ទំនាក់ទំនងប្រភេទនេះដែរ។ ដំបូងយើងគួរកត់សម្គាល់ថា មនុស្សវិកលចរិត មិនអាចនឹងទទួលខុសត្រូវឡើយទោះជានៅផ្នែករដ្ឋប្បវេណីក៏ដោយ។ ក្នុងករណីដែលមានគ្រោះថ្នាក់ការងារដល់កម្មករម្នាក់ និយោជកក៏អាចរួចខ្លួនពីទំនួលខុសត្រូវផ្នែករប្បវេណីដែរ ប្រសិនបើខ្លួនអាចផ្ដល់ភស្តុតាងគ្រប់គ្រាន់នៃកំហុសធ្ងន់ ដែលអ្នករងគ្រោះបានធ្វើ។

អ្នកយុទ្ធសាស្ត្របានតាក់តែងទ្រឹស្ដីនានាដើម្បីបង្វិតគោលការណ៍នៃទំនួលខុសត្រូវផ្នែករដ្ឋប្បវេណីឱ្យទៅជិតគោលការណ៍នៃទំនួលខុសត្រូវផ្នែកសីលវិជ្ជា។ មុនដំបូងគឺជាទ្រឹស្ដីនៃកំហុស(គោលការណ៍នៃទំនួលខុសត្រូវផ្នែករដ្ឋប្បវេណី សំដៅទៅលើការបង្ហាញជាទូទៅនូវកំហុស ដែលអ្នកទទួលខុសត្រូវបានប្រព្រឹត្តយ៉ាងហោចណាស់ ក៏សំដៅទៅលើការធ្វេសប្រហែសក្នុងកិច្ចការដែរ។ ទ្រឹស្ដីនៃគ្រោះថ្នាក់មានលក្ខណៈថ្មីជាងនេះទៅទៀត។ បើយើងបង្កើតកូនឬយើងទិញរថយន្តមួយ បើយើងមានចិញ្ចឹមសត្វ យើងបានបញ្ចូលដោយឆន្ទៈទៅក្នុងសហាគមន៍នូវ«គ្រោះថ្នាក់» ដែលជាប្រភពនៃកំហូចខាតដែលនឹងអាចកើតមានឡើង។ ដូចនេះការដែលយើងត្រូវទទួលវិបាកជាការមួយត្រឹមត្រូវតាមលក្ខណៈច្បាប់។

## ២.១.៥ ទ្រឹស្ដីផ្សេងៗពីទំនួលខុសត្រូវ

សញ្ញាណនៃទំនួលខុសត្រូវផ្នែកសីលវិជ្ជាដែលទាក់ទងទៅនិងការស្គាល់កុសលនិងអកុសល ហើយការមានសេរីភាពក្នុងការជ្រើសរើស បានចោទជាបញ្ហាមួយផ្នែកអស្តិរូបវិជ្ជា ពីព្រោះគេត្រូវតែដឹងថា តើមនុស្សមានសេរីភាពពិតប្រាកដឬទេ? ហើយពិសេសទៀត តើសេរីភាពនេះឋិតនៅលើអ្វី? តាមបញ្ញត្តិកម្មអស្តិរូបវិជ្ជាដែលបានអនុម័តហើយ គំនិតដែលគេមានពីទំនួលខុសត្រូវ ខុសគ្នាឆ្ងាយពីគំនិតដែលមាននៅក្នុងទ្រឹស្ដីវិចារណញ្ញាណនិយម។

**ក. ទ្រឹស្ដីប្រពៃណីនិយម**

ទស្សនវិស័យប្រពៃណីនិយម គេចាត់ទុកមនុស្សម្នាក់ថា បានប្រព្រឹត្តអំពើមួយប្រកបដោយសេរីភាព កាលណាមនុស្សនោះធ្វើអំពើមួយដែលគេអាចមិនធ្វើក៏បានដែរ។ ខ្ញុំនឹងត្រូវគេចាត់ទុកថាមានទោស កាលណាខ្ញុំដឹងនិងស្គាល់ច្បាស់អំពីសីលតម្លៃ ហើយខ្ញុំមានកម្លាំងគ្រប់គ្រាន់អាចនឹងប្រព្រឹត្តទៅតាមគន្លងសីលតម្លៃនោះបាន តែខ្ញុំបែរជាងាកចេញអំពីសីលតម្លៃទាំងនោះ ហើយទៅប្រព្រឹត្តអាក្រក់ដោយគ្មានអ្នកណាបង្ខំទៅវិញ។ ហេតុនេះ មូលហេតុទាំងឡាយដែលនាំខ្ញុំទៅកាន់សេចក្ដីអាក្រក់ មិនមែនជាមូលហេតុដែលខ្ញុំមិនអាចជៀសវាងបានទេ។ គឺខ្លួនខ្ញុំផ្ទាល់តែម្តងដែលជាអ្នកជ្រើសរើសថាត្រូវគោរពទៅតាមមូលហេតុទាំងនោះ។ ដូចនេះ នៅក្នុងប្រភពដើមនៃទំនួលខុសត្រូវរបស់ខ្ញុំ ហាក់ដូចជាមានសេរីអាជ្ញាសុទ្ធសាធមួយដែលជា ការសម្រេចចិត្តប្រកបដោយលក្ខណៈអាថ៌កំបាំងនិងអវិចារណញ្ញាណ ព្រោះវាជាការសម្រេចចិត្តមួយដែលនៅពីលើ និងគ្របដណ្តប់ទៅលើមូលហេតុទាំងអស់។

ប្លាតុង បានបញ្ចេញមតិនេះនៅក្នុងសៀវភៅរបស់គាត់ឈ្មោះ «សាធារណរដ្ឋ»ដែលមានលក្ខណៈជាទេវកថាមួយ។ ទាហានម្នាក់ឈ្មោះអ៊ែ (Er) ដែលស្លាប់នៅក្នុងសមរភូមិ បានរស់ឡើងវិញយ៉ាងចម្លែកអស្ចារ្យ ហើយបាននិទានប្រាប់មិត្តភ័ក្តិខ្លួននូវហេតុភេទដែលខ្លួនបានឃើញនៅឋាននរក។ ខ្មោចទាំងអស់ត្រូវគេហៅទៅឱ្យជ្រើសរើសយកវាសនាថ្មីមួយដោយសេរី ដើម្បីនឹងចាប់បដិសន្ធិជាថ្មី។ នៅពេលដែលជ្រើសរើសហើយ ខ្មោចទាំងនោះត្រូវទៅផឹកទឹកនៅក្នុងទន្លេនៃការភ្លេច ទើបឡើងមកចាប់ជាតិនៅលើដីបាន។ អ្នកទាំងអស់នោះក៏ភ្លេចថាគឺខ្លួនឯងតែម្តងដែលបានជ្រើសរើសវាសនារបស់ខ្លួន ហើយបែរជាទៅចោទប្រកាន់ជោគវាសនាទៅវិញ។ «អាទិទេពគ្មានកំហុសទេ» ក្នុងបំណែងជោគវាសនានេះគឺពួកអ្នកទាំងនោះទេ ដែលទទួលខុសត្រូវក្នុងការនេះ។ ខាន់ (Kant) ក៏យល់ដូចនេះដែរ ព្រោះគាត់ពោលថា មនុស្សអាចបានជ្រើសរើសយកចរិតកាចរបស់ខ្លួនតាមអំពើនៃសេរីអាជ្ញាមួយដែលគ្មានទាក់ទងនឹងកាលវេលាឡើយ។ មនុស្សនេះត្រូវមានកំហុសនិងត្រូវទទួលខុសត្រូវ។

### ខ. ការពិភាក្សាលើទ្រឹស្តីនេះ

ទ្រឹស្តីនៃសេរីអាជ្ញា ពិបាកយល់ណាស់។ ដំបូងទ្រឹស្តីនេះពុំបានឱ្យមូលដ្ឋានពិតប្រាកដទៅលើទំនួលខុសត្រូវរបស់យើងឡើយ។ ដូចនេះ ឡាសឺល្យេ(Lachelier)និយាយថា «អំពើដែលកើតឡើងដោយសេរីភាពសុទ្ធសាធ គឺជាអំពើដែលគ្មានទាក់ទងនឹងមតិ ឬការដឹងរបស់យើងទេ ទោះជាមានពីកំណើត ឬជាបំណានក៏ដោយ។ ដូចនេះអំពើនោះច្បាស់ជាគ្មានទាក់ទងបន្តិចបន្តួចសោះឡើយទៅនឹងអ្វីទាំងអស់ដែលបង្កបង្កើតចរិតផ្ទាល់របស់យើងហើយយើងក៏មិនអាចនឹងយល់បានថាតើយើងជាអ្នកប្រព្រឹត្តឬក៏យើងជាអ្នកទទួលខុសត្រូវឡើយ»។ ទំនួលខុសត្រូវដែលចេញពីសេរីអាជ្ញានេះ គឺជាទំនួលខុសត្រូវរបស់អង្គភាពមួយដែលមិនអាចចាប់បាន មិនមែនជាទំនួលខុសត្រូវរបស់មនុស្សក្នុងតថភាពឡើយ។

ម្យ៉ាងទៀត ទ្រឹស្តីសេរីអាជ្ញាមានសំអាងថា ក្នុងការប្រព្រឹត្តអំពើមួយ យើងអាចនឹងមិនប្រព្រឹត្តអំពើនោះ ហើយប្រព្រឹត្តផ្សេងទៅវិញបាន។ សំអាងនេះមិនអាចឱ្យគេយល់ព្រមបានឡើយ ព្រោះមុននឹងប្រព្រឹត្ត យើងគ្មានពិសោធន៍អំពើកំហុសនៃអំពើនោះឡើយ។ ហើយអំពើណាមួយក៏ដោយ បើយើងពិចារណាឱ្យជិតដល់ទៅ យើងនឹងឃើញថាសុទ្ធតែមានហេតុទាំងអស់។ នៅក្នុងទេវកថានៃទាហានឈ្មោះអ៊ែ (Er) ប្លាតុង ខ្លួនឯងក៏បានទទួលស្គាល់ដែរថាព្រលឹងបានជ្រើសរើសវាសនារបស់ខ្លួនអាស្រ័យទៅតាមចរិតរបស់ខ្លួន និងតាមពិសោធន៍នៅក្នុងកម្រិតពីជាតិមុនរបស់ខ្លួន។ គាត់បានកត់សម្គាល់ដោយវាងវៃថា មនុស្សដែលទៀងត្រង់ជាងគេ ច្រើនតែឆោតហើយក៏បណ្តោយខ្លួនដោយ សេចក្តីឆោតនេះឱ្យទោរទន់ទៅតាមទំនាញខាងក្រៅ រហូតដល់ទៅជ្រើសរើសយកវាសនារបស់អ្នកមានអំណាចឬរបស់អ្នកប្រើលទ្ធិផ្តាច់ការដែលជាវាសនាមិនគួរឱ្យចង់បានឡើយ។ ព្រលឹងនៃអ៊ុយលិស(ulysse)ដែលមានការប្រុងប្រយ័ត្នជានិច្ចកាល ដោយសារមានការចេះដឹងច្រើន និងដោយសារការផ្សងព្រេងរបស់ខ្លួនដែលធ្លាប់មានមកហើយក៏ជ្រើសយកវាសនានៃមនុស្សសាមញ្ញដែលរស់នៅដោយសុខសាន្ត។

### គ. ទ្រឹស្តីវិចារណញ្ញាណនិយមនៃទំនួលខុសត្រូវ

បើតាមកំណត់សម្គាល់ទាំងនេះ តើគេត្រូវសន្និដ្ឋានថា សេរីភាពគ្រាន់តែជាការភាន់ (illusion) ឬយ៉ាងណា? ដើម្បីឆ្លើយនឹងសំណួរនេះបាន គេត្រូវយល់ឱ្យច្បាស់នូវន័យនៃសេរីភាពសិន។

សេរីភាពមិនមែនជាសេរីអាជ្ញាគ្មានហេតុផលទេ ពោលគឺសេរីភាពមិនមែនជាអំណាចជ្រើសរើសប្រកបដោយលក្ខណៈអាថ៌កំបាំង ហើយគ្មានទាក់ទងទៅនឹងមូលហេតុនោះទេ។ មានសេរីភាពគឺរួចពីចំណង។ មនុស្សដែលមានសេរីភាព គឺជាមនុស្សដែលរួចពីចំណងទាសករនៃបុរេនិច្ច័យនិងលំងប់នានា ហើយសកម្មភាពទាំងអស់របស់គេសុទ្ធតែបិតនៅក្រោមពន្លឺដ៏ត្រចះនៃសច្ចភាពនិងតម្លៃ។

មនុស្សដែលប្រកបដោយសេរីភាពពេញលេញនោះ ត្រូវទទួលខុសត្រូវពេញទី។

ដោយមានការឈ្លាសវៃបរិបូរ (lucide) អ្នកនោះបានពិចារណាជាស្រេចមុននឹងប្រព្រឹត្ត។ គ្មានលំដាប់ណាមួយ គ្មានលំអក់ណាមួយជាមោហ៍បាំងសេចក្តីសម្រេចចិត្តរបស់គេឡើយ អ្នកនោះនឹងគ្មានវិប្បដិសារៈចំពោះអំពើរបស់គេទេ ពីព្រោះគេបានស្គាល់ខ្លួនគេយ៉ាងច្បាស់ដូចជាឆ្លុះកញ្ចក់យ៉ាងនោះដែរ។ ប៉ុន្តែ ការដែលអះអាងថាមនុស្សនេះអាចប្រព្រឹត្តផ្សេងទៅវិញនោះ មិនអាចចោទជាបញ្ហាបានឡើយ។ គេអាចប្រព្រឹត្តផ្សេង លុះត្រាតែគេជាទាសករនៃលំងប់មួយ នៃកម្លាំងជំរុញចិត្តឱ្យធ្វើដោយងងឹតងងល់មួយ ឬជាអ្នករងគ្រោះដោយអវិជ្ជាណាមួយ។ គេនឹងលែងមានសេរីភាពទៀតហើយ ប្រសិនបើគេប្រព្រឹត្តអាក្រក់។ ប្រសិនបើយើងមានសេរីភាពពិតមែន ប្រសិនបើភាពឈ្លាសវៃនៃប្រាជ្ញារបស់យើង ហើយនិងសមត្ថភាពនៃអំពើរបស់យើងមិនត្រូវឱនថយដោយសារលំងប់ដ៏ចង្រៃណាមួយទេនោះ យើងច្បាស់ជានឹងប្រព្រឹត្តតែអំពើជាកុសលមិនខាន។ បើយើងប្រព្រឹត្តអំពើអកុសល គឺមកតែពីយើងមិនដឹងខុសត្រូវ មិនចេះពិចារណា ពោលឱ្យខ្លីគឺយើងគ្មានសេរីភាព។ សេចក្តីនេះដូចគ្នានឹងន័យនៅក្នុងរូបមន្តដ៏ល្បីល្បាញរបស់ សូក្រាត ដែលចែងថា «គ្មាននរណាម្នាក់ប្រព្រឹត្តអាក្រក់ដោយឆន្ទៈឡើយ»។

តាមពិតអំពើទាំងអស់ ទោះជាល្អឬអាក្រក់ សុទ្ធតែមានហេតុផល ហើយហេតុទាំងអស់សុទ្ធតែលេចឡើងក្នុងឋានៈជាតម្លៃមួយចំពោះញាណនៃអ្នកប្រព្រឹត្ត។ ឧទាហរណ៍ មនុស្សអនាថាម្នាក់បានសម្លាប់អ្នកដើរតាមផ្លូវម្នាក់ដោយឃោរឃៅបំផុត ដើម្បីនឹងប្លន់យកប្រាក់។ បើតាមទ្រឹស្តីប្រពៃណីនិយម មនុស្សនេះប្រហែលជា«មានទោស» ពីព្រោះមនុស្សនេះស្គាល់សីលតម្លៃដ៏ឧត្តមនៃការគោរពជីវិតមនុស្ស ហើយបែរជាងាកចេញពីតម្លៃនេះ ប៉ុន្តែ វិភាគតាម «អស្តិរូបវិជ្ជា» នេះមិនត្រូវជាមួយនឹងពិសោធន៍នៃចិត្តវិទ្យាពិតប្រាកដទេ។ បើមនុស្សនេះបានសម្លាប់ គឺមកតែពីកាលដែលខ្លួនបានប្រព្រឹត្តបទឧក្រិដ្ឋនោះ ទំនាញនៃប្រាក់មានតម្លៃចំពោះគេជាងការគោរពជីវិត។ តម្លៃនៃការគោរពជីវិត ជាតម្លៃមួយដែលជនកំសត់នេះគ្រាន់តែបានស្គាល់ក្នុងឋានៈជាទ្រឹស្តីអរូបីប៉ុណ្ណោះ ព្រោះក្នុងការរស់នៅរាល់ថ្ងៃរបស់គ្នា ជីវិតមិនមានតម្លៃទេគឺប្រាក់ទេតើដែលមានតម្លៃលើសលុប។ ឧទាហរណ៍មួយទៀត ដូចជាប្តីដែលក្បត់ប្រពន្ធរបស់ខ្លួន។ មនុស្សនេះបណ្តោយខ្លួនទៅតាមទំនាញនៃការផ្សងព្រេងទៅតាមសេចក្តីសង្ឃឹមនៃសេចក្តីត្រេកត្រអាល។ នៅពេលនោះ ទំនាញទាំងអស់នេះមានតម្លៃសម្រាប់គេជាងករណីយកិច្ចនៃស្វាមីភក្តិ។ តម្លៃចុងក្រោយនេះ ពោលគឺសុភមង្គលនៃគ្រួសាររបស់គេ និងអនាគតនៃកូនរបស់គេ បានត្រូវលុបអស់ចំពោះគេ។ ដើម្បីយល់ឧទាហរណ៍ទាំងនោះបានគេគួរកត់សម្គាល់ថា នៅក្នុងពិសោធន៍នៃសីលវិជ្ជារូបី គ្មានកុសលដាច់ខាតទេ ប៉ុន្តែមានលំដាប់ថ្នាក់មួយនៃតម្លៃទាំងឡាយ។ សេចក្តីរីករាយដែលប្រាក់កាសបានផ្តល់ឱ្យក៏ជាតម្លៃមួយ។ សេចក្តីត្រេកត្រអាលក្នុងកាមគុណក៏ជាតម្លៃមួយដែរ។ ពិតប្រាកដហើយដែលថា មនុស្សប្រកបដោយគុណធម៌ មនុស្សមានសេរីភាព(រួចចាកពីលំងប់)មុខជាស្គាល់ច្បាស់ថា មានតម្លៃឧត្តម ពោលគឺការគោរពជីវិតនិងភក្តីភាព។ បើអ្នកខ្លះប្រព្រឹត្តអាក្រក់ ពោលគឺចោលតម្លៃឧត្តមដើម្បីប្រកាន់យកតម្លៃទាបទៅវិញ ចោលកុសលពិតប្រាកដ ទៅយកកុសលតាមការយល់ឃើញរបស់ខ្លួនទៅវិញ នោះគឺមកពីតែពីទំនាញដ៏ខ្លាំងក្លានៃតម្លៃទាប (សេចក្តីត្រេកត្រអាល ប្រាក់កាស អំណាច)ដែលបានបន្លប់អស់នូវការតម្រូវនៃតម្លៃឧត្តមក្នុងមួយរយៈពេលដែរ។ សន្តបុគ្គល តូម៉ាស (Saint Thomas) ពោលថា"អកុសលជាកុសលមួយបែបដែរ" មតិរបស់គាត់បានត្រូវបព្វជិតកាតូលិចឈ្មោះ ស៊ែទីយ៉ង់ (Révérend Père Sertillanges) យកមកធ្វើអត្ថាធិប្បាយយ៉ាងច្បាស់លាស់ថា "បើគេជ្រើសរើសនិងបំពេញអំពើអកុសល ក៏គឺនៅក្នុងគោលបំណងចង់បានកុសលដែរ ហើយបើទោះជាមានពេលខ្លះ កុសលនេះគ្រាន់តែជាអាការខាងក្រៅក៏ដោយ ក៏គេត្រូវគិតថា អាការខាងក្រៅគឺជាការពិតមួយសម្រាប់មនុស្សដែលមើលឃើញតែខាងក្រៅនោះដែរ"។

ប៉ុន្តែច្បាស់ជាមានមតិខ្លះប្រឆាំងវិញថា វិភាគនេះមិនសុទ្ធត្រូវគ្រប់ករណីទេ។ ពិតមែនហើយអ្នកមានពិរុទ្ធខ្លះប្រព្រឹត្តអំពើអកុសល ដើម្បីឱ្យបានកុសល ហើយធ្វើកំហុសនៅក្នុងភាពកញ្ឆាតនៅក្នុងនាមនៃលំដាប់ថ្នាក់មួយនៃតម្លៃនានា យោលទៅតាមលំងប់ ដែលមិនមែនជាលំដាប់ថ្នាក់នៃតម្លៃពិតប្រាកដ។ ក៏ប៉ុន្តែ តើអ្នកខ្លះមិនប្រព្រឹត្តអកុសលនៅពេលដែលខ្លួនស្គាល់ហេតុផលជាក់លាក់និងស្គាល់យ៉ាងច្បាស់នូវលំដាប់ ថ្នាក់ពិតប្រាកដនៃតម្លៃទេឬ?

អូវីត(Ovide)បានធ្វើឱ្យតួអង្គរបស់គាត់ឈ្មោះ មេដេ(Médée)និយាយថា "ខ្ញុំមើលឃើញអំពើដែលល្អ ហើយខ្ញុំទទួលស្គាល់អំពើនោះដែរ ក៏ប៉ុន្តែខ្ញុំបែរជាប្រព្រឹត្តអំពើអាក្រក់ទៅវិញ" ឯសន្តបុគ្គល ប៉ូល (Saint Paul) បានកត់សម្គាល់ថា "ខ្ញុំមិនប្រព្រឹត្តអំពើជាកុសលដែលខ្ញុំចង់ទេ តែខ្ញុំបែរជាប្រព្រឹត្តអំពើអកុសលដែលខ្ញុំមិនចង់ទៅវិញ"។ ឧទាហរណ៍ ដូចជាអ្នកជំនួញម្នាក់ដែលតម្លើងថ្លៃទំនិញហួសហេតុ ស្ត្រីម្នាក់ដែលនិយាយដើមគេដោយមិនស្មោះនៅក្នុងការសន្ទនារបស់ខ្លួន ឪពុកម្នាក់ដែលខ្ជិលមិនរវល់នឹងកូនរបស់ខ្លួន ប្រហែលជាដឹងដែរថា អាកប្បកិរិយារបស់គេផ្ទុយនឹងការតម្រូវរបស់សីលវិជ្ជា។ យើងទទួលស្គាល់ទៅចុះថា អ្នកទាំងនោះស្គាល់ច្បាស់មែនពីឧត្តមភាពនៃតម្លៃដែលខ្លួនរំលោភ តែយើងមិនអាចទទួលស្គាល់ថា អ្នកទាំងនោះមានសេរីភាពពេញលេញបានទេ។ ប្រព្រឹត្តផ្ទុយនឹងតម្លៃផ្ទាល់របស់ខ្លួន គឺពិតជាដាក់ខ្លួនទៅក្នុងភាពជាទាសករ គឺជាទាសករនៃមូលហេតុដែលញ៉ាំងយើងឱ្យធ្វើ ទោះជាពេលនោះយើងយល់ថាមូលហេតុទាំងនោះអាក្រក់ក៏ដោយ។

ដូចនេះ ទ្រឹស្តីវិចារណញ្ញាណនិយមហាក់ដូចជាប្រកាន់យកទ្វេបទ (dilemme) របស់ខ្លួនថាៈ ឬមួយគេមានសេរីភាពក្នុងន័យពិតប្រាកដនៃពាក្យ ហើយពេលនោះ គេប្រព្រឹត្តតែអំពើជាកុសល ឬមួយគេប្រព្រឹត្តអំពើអកុសល ហើយពេលនោះ គេគ្មានសេរីភាព។

តើទ្រឹស្តីវិចារណញ្ញាណនិយមនេះ អាចនាំផលអាក្រក់មកឱ្យសីលវិជ្ជាឬទេ? ជនភាគច្រើនណាស់ដែលអះអាងអំពីផលអាក្រក់នៃទ្រឹស្តីវិចារណញ្ញាណនិយមទៅលើសីលវិជ្ជា ព្រោះគេអាងថា បើយើងមិនដាក់កំហុសទៅលើអ្នកប្រព្រឹត្តអាក្រក់ទេ ច្បាស់ជាមនុស្សទាំងអស់នឹងនាំគ្នារត់ទៅរកអំពើជាអកុសល ដោយគ្មានញញើត ហើយដោយដេកលក់ស្រួលទៀតជាមិនខាន។ បើយើងទទួលស្គាល់គំនិតរបស់ជនខាងលើនេះ យើងក៏ត្រូវទទួលស្គាល់ដែរថា សីលជីវិត (vie morale) ជាជីវិតបំភាន់ ព្រោះមនុស្សដែលខំធ្វើល្អទៅតាមសីលវិជ្ជា មិនមែនស្រលាញ់កុសលទេ គេខំប្រព្រឹត្តល្អដោយសារតែគេខ្លាចសង្គមតែប៉ុណ្ណោះ បើគេអាចធ្វើអកុសលបានដោយគ្មានទទួលទណ្ឌកម្ម គេច្បាស់ជានាំគ្នាងាកទៅរកអំពើជាអកុសលមិនខានឡើយ។ នេះជាគំនិតដែលផ្ទុយស្រលះពីសីលវិជ្ជា។ បើសីលតម្លៃមានពិតប្រាកដមែន ហើយបើញាណទទួលស្គាល់នូវសីលតម្លៃនោះហើយ មិនមែនការអះអាងអំពីការគ្មានទទួលខុសត្រូវនៃអ្នកជាប់ពិរុទ្ធ អាចនាំឱ្យមនុស្សងាកចេញអំពីតម្លៃជាក់លាក់បានឡើយ។ គ្មានអ្នកណាម្នាក់ចង់មានឈ្មោះជាទាសករ ជាមនុស្សល្ងង់ឬជាអ្នកទទួលរងគ្រោះឡើយ។

ក៏ប៉ុន្តែ គេអាចនឹងបង្ហាញបានដោយងាយថា ទ្រឹស្តីវិចារណញ្ញាណនិយមបើកផ្លូវឱ្យសីលវិជ្ជា ច្រើនជាងឱ្យទ្រឹស្តីនៃសេរីអាជ្ញា។ ទ្រឹស្តីខាងក្រោយនេះជាទ្រឹស្តីអស់សង្ឃឹម ព្រោះបើយល់ថា ការប្រព្រឹត្តអំពើអាក្រក់ជាវិបាកនៃសេរីអាជ្ញាមួយគ្មានហេតុ គ្មានផលនោះគ្មានឱសថណាមួយអាចទប់ទល់នឹងអំពើអាក្រក់បានឡើយ។ ទ្រឹស្តីនេះគ្រាន់តែបង្ហាញឱ្យឃើញអំពីអកុសល បង្ហាញនូវភាពអាក្រក់ក្រៃលែងដែលគ្មានកំណែទម្រង់ពីខាងក្រៅណាមួយអាចនឹងមានជ័យជម្នះលើបានឡើយ។ ផ្ទុយទៅវិញ បើកំហុស បើបទឧក្រិដ្ឋនានាមានមូលហេតុដែលបណ្តាលឱ្យគេប្រព្រឹត្តអំពើទាំងនោះ គេអាចនឹងបន្ថយកំហុស ឬបទឧក្រិដ្ឋបានដោយលុបបំបាត់ចោលនូវមូលហេតុទាំងនោះ។ ករណីនេះក៏ដូចជាករណីឯទៀតៗដែរ ពិរុទ្ធកំណត់និយមគឺជាល័ក្ខខ័ណ្ឌដែលបណ្តាលឱ្យមានតិចនិចរំដោះ។ ម្យ៉ាងទៀត មានស្បង់មួយឈ្មោះឧក្រិដ្ឋវិទ្យាដែលមានបំណងនឹងរកឱ្យឃើញនូវកំណត់និយមមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ឡូប្រូសូ (Losbroso) បានពិនិត្យយ៉ាងច្បាស់លាស់រួចមកហើយនូវគោលការណ៍នៃកំណត់និយមនេះ។ ក៏ប៉ុន្តែទ្រឹស្តីរបស់គាត់ដែលបញ្ជាក់ថាមានឧក្រិដ្ឋជនពីកំណើត ហើយពន្យល់បទឧក្រិដ្ឋដោយវិកលកាយ ឬពីជីវចរិតមានលក្ខណៈសង្ខេបពេក។ ចំណែក ភែរី (Ferri) គាត់បែរជាពន្យល់ការប្រព្រឹត្តឧក្រិដ្ឋកម្មចេញពីការអប់រំនិងពីមជ្ឈដ្ឋានដែលឧក្រិដ្ឋជនរស់នៅវិញ។ គាត់បានផ្សព្វផ្សាយនូវការស្រាវជ្រាវនានា ដែលផ្តល់នូវលទ្ធផលល្អៗក្នុងឧក្រិដ្ឋវិទ្យាសហសម័យ។ ឧទាហរណ៍ៈ បើយើងពិនិត្យមើលផែនទីនៃឧក្រិដ្ឋភាពនៃទីក្រុងប៉ារីស យើងនឹងឃើញថានៅក្នុងផ្នែក

ខាងកើតនៃរដ្ឋជានីឃាតកម្ម ការលួចស្មន្ទលើកូនចៅឯង ការលួចប្លន់មានច្រើនជាងនូវផ្នែកខាងលិច។ អ្នកសង្គ្រាម ប៉ាកកាបារាំងម្នាក់បាននិយាយថាការនេះបញ្ជាក់ឱ្យឃើញថា៖ "នៅក្នុងគុករបស់យើងមានជនខ្លះទទួលទណ្ឌកម្មពី បទឧក្រិដ្ឋ ដោយគ្រាន់តែជននោះ មិនបានកើតក្នុងតំបន់ទី១៦ ឬ១៨ នៃទីក្រុងបារីសតែប៉ុណ្ណោះ"។ តែដើមហេតុ នៃបទឧក្រិដ្ឋមិនមែនសុទ្ធតែឋិតនៅលើបុព្វហេតុសេដ្ឋកិច្ចឬសង្គមនោះទេ។ ចិត្តវិភាគបានរកឃើញកំណត់និយមខ្លះ ទៀតដែលមានលក្ខណៈល្អិតល្អន់ជាងនេះទៅទៀត។ ទោះជាយ៉ាងណាក៏ដោយ ក៏ទ្រឹស្តីកំណត់និយម បានបើកឱ្យ សីលវិជ្ជាមានលទ្ធភាពនឹងសម្រេចអំពើជាតថៈដែលទ្រឹស្តីនៃអំណាចសម្រេចចិត្តមិនបានបើកឱ្យដល់ខ្លួនឯងដែរ។ បាយែ ( M Bayer ) បានសរសេរថា"នៅពេលដែលគេដាក់សម្មតិកម្មថាឧក្រិដ្ឋភាពគឺជាការមួយដែលអាចកំណត់ បាននៅពេលនោះគេអាចស្អប់ខ្ពើមឧក្រិដ្ឋកម្ម តែគេមិនអាចស្អប់ឧក្រិដ្ឋជនបានទៀតឡើយ គេបែរជាអាណិតជន នេះទៅវិញ ដោយវាជាអ្នករងគ្រោះព្រោះអំពើអកុសលដែលវាបានប្រព្រឹត្តមុនគេ...។ បើយើងពង្រីកការស្រាវជ្រាវ ផ្នែកស្បង់តទៅទៀតការស្រាវជ្រាវនេះនឹងនាំមកឱ្យយើងនូវមធ្យោបាយសម្រាប់ការពារ ព្រមទាំងធ្វើឱ្យសីលវិជ្ជាមាន ជ័យជម្នះផង.... ការស្រាវជ្រាវនេះច្បាស់ជានាំមធ្យោបាយទាំងនេះមកឱ្យយើង នៅពេលដែលយើងលះបង់ចោល សម្មតិកម្មដ៏ខ្ចិលច្រអូសនៃសេរីអាជ្ញា ដែលគ្រាន់តែដាក់ឱ្យអ្នកជំងឺមានទំនួលខុសត្រូវចំពោះអំពើអកុសល ដែលខ្លួន បានប្រព្រឹត្ត ហើយមិនអាចនឹងឱ្យយើងជួយមនុស្សនោះបានឡើយ។

អាស្រ័យហេតុនេះ នៅក្នុងក្របខ័ណ្ឌនៃទ្រឹស្តីវិចារណញ្ញាណនិយម គំនិតប្រពៃណីនិយមនៃវិបាកវិនិច្ឆ័យត្រូវ យកមកពិនិត្យសារជាថ្មីឡើងវិញ។ យើងនិងសិក្សាឱ្យបានម៉ត់ចត់បន្តិចអំពីបញ្ញត្តិកម្មនៃវិបាកវិនិច្ឆ័យនេះ។

## ២.២ វិបាកវិនិច្ឆ័យ

### ២.២.១ និយមន័យ

វិបាកវិនិច្ឆ័យគឺជាវិបាកដែលកើតឡើងពីភាពស្របគ្នា ឬភាពមិនស្របគ្នារវាងអំពើនិងតម្លៃដែលមាននិយាម ជាតំណាង។ ក្នុងផ្នែកសីលវិជ្ជា វិបាកវិនិច្ឆ័យសំដៅទៅលើរង្វាន់ឬទណ្ឌកម្មដែលអនុវត្តទៅលើអ្នកប្រតិបត្តិសីលវិជ្ជា។

### ២.២.២ បែបផ្សេងៗនៃវិបាកវិនិច្ឆ័យ

ដូចទំនួលខុសត្រូវដែរ វិបាកវិនិច្ឆ័យអាចមានបែបផ្សេងៗគ្នា។ ទំនួលខុសត្រូវចំពោះអំណាចខាងក្នុងស្របទៅ នឹងវិបាកវិនិច្ឆ័យផ្នែកសីលវិជ្ជាដូចជាសេចក្តីរីករាយដោយបានបំពេញករណីយកិច្ច ឬបានធ្វើពលិកម្ម ឬផ្ទុយទៅវិញ ការខ្មាសអៀនដោយបានប្រព្រឹត្តកំហុសពោលគឺវិប្បដិសារៈ ឬការស្តាយក្រោយ។ ប៉ុន្តែ វិបាកវិនិច្ឆ័យប្រភេទនេះមាន នៅតែនឹងមនុស្សដែលស្គាល់និយាមនិងតម្លៃដែលមាននិយាមជាតំណាង។ ដោយសារហេតុនេះហើយ បានជាមាន ភាពផ្ទុយគ្នាស្រលះរវាងការស្តាយធម្មតា ដែលតែងមានក្រោយការមិនបានសម្រេចអ្វីមួយដែលឋិតនៅតែក្នុងវិស័យ នៃការត្រិះរិះសាមញ្ញ( ឧក្រិដ្ឋជនម្នាក់អាចនឹងស្តាយដោយមិនបានសម្លាប់ចោលនូវសាក្សីម្នាក់ដែលរំខានដល់គេ) និងម្ខាងទៀតវិប្បដិសារៈដែលដាក់ទណ្ឌកម្មដល់កំហុសរបស់យើង ហើយឋិតនៅក្នុងវិស័យសីលវិជ្ជាសុទ្ធសាធ។

ចំណែកឯទំនួលខុសត្រូវវត្ថុវិស័យតែងតែស្របទៅនឹងវិបាកវិនិច្ឆ័យផ្នែកសង្គម។

សង្គមតែងតែធ្វើវិបាកវិនិច្ឆ័យទៅលើអំពើ ដែលសង្គមតម្រូវឱ្យយើងទទួលខុសត្រូវ (យើងអាចនឹងទទួលការ ពិន័យ ឬទោសត្រូវជាប់គុក បើយើងមិនគោរពច្បាប់ក៏ដូចជាយើងអាចទទួលគ្រឿងឥស្សរិយយសឬគុណូបការៈផ្នែក កសិកម្មប្រសិនបើយើងបានបម្រើសង្គមដោយម៉ត់ចត់។

### ២.២.៣ ទ្រឹស្តីនៃវិបាកវិនិច្ឆ័យ

តាមគំនិតប្រពៃណីនិយម គឺសេរីអាជ្ញារបស់អ្នកមានពិរុទ្ធទេដែលធ្វើឱ្យការដាក់ទណ្ឌកម្មមានលក្ខណៈត្រឹមត្រូវ។ មកពីមនុស្សនេះបាន «សម្រេច» ថានឹងប្រព្រឹត្តអំពើអកុសល ដោយស្គាល់ហេតុផលច្បាស់សាល់ ទើបមនុស្សនេះ ត្រូវតែទទួលទោស។ បើគេធ្វើការពិចារណាទៅ សំអាងនេះគ្មានអ្វីច្បាស់លាស់សោះ។ ទណ្ឌកម្ម( ពិន័យគុក) ធ្វើ

ទោសឥន្ទ្រិយភាព តែសេរីអាជ្ញាទេដែលជាអ្នកទទួលខុសត្រូវ។ គេមិនយល់ថា ហេតុអ្វីបានជាទុក្ខវេទនាដែលឥន្ទ្រិយភាពជាអ្នកទទួល បែរជាធ្វើឱ្យសេរីអាជ្ញាខ្មាសអៀនទៅវិញ។

តាមពិត វិបាកវិនិច្ឆ័យរៀបចំនៅក្នុងសង្គម មិនមែនមានប្រភពផ្នែកអស្តិរូបវិជ្ជាទេ។ គេក៏មិនអាចពន្យល់អំពីវិបាកវិនិច្ឆ័យដោយមានសំអាងលើអស្តិរូបវិជ្ជាដែរ។ អត្ថិភាពនៃវិបាកវិនិច្ឆ័យមានប្រភពផ្អែកទៅលើសង្គមចិត្តវិទ្យាសុំញ៉ាំដែល ផូកូនេ(Fauconnet)ធ្វើការបំភ្លឺយ៉ាងច្បាស់។ ទោះជាមានចំណាស់ជាងពាក់កណ្ដាលសតវត្សហើយក៏ដោយ ក៏មានវគ្គខ្លះនៃស្នាដៃរបស់គាត់បានត្រួសត្រាយនូវកិច្ចការនៃអ្នកចិត្តវិភាគ និងអ្នកសង្គមវិទ្យាសម័យថ្មីដែរ។

ប្រវត្តិវិទ្យាជាតិពន្ធពណ៌នា(ethnographie)បានធ្វើឱ្យដឹងថា វត្ថុឬសត្វ(មិនមែនត្រឹមតែមនុស្សទេ)ដែលអាចទទួលវិបាកវិនិច្ឆ័យនឹងត្រូវគេយល់ថាអាចទទួលខុសត្រូវបាន។ នៅក្នុងសង្គមជំនាន់ដើម គេដាក់ទណ្ឌកម្មដល់ព្រនង់ប្រឡាក់ឈាមដែលគេរកឃើញក្បែរអ្នករងគ្រោះ។ ក្នុងរឿងរបស់ រ៉ាស៊ីន(Racine)ឈ្មោះ«គូក្កី» គេវិនិច្ឆ័យទោសឆ្កែមួយ(ការនេះស្របទៅនឹងទំនៀមទម្លាប់ពិតប្រាកដនៃជំនាន់ដើម) នៅសតវត្សទី១៧ គេនៅតែធ្វើវិបាកវិនិច្ឆ័យក្រោយមរណភាពទៅលើសាកសពទៀត(ដូចជាគេកាត់សពជាកង់ៗជាដើម)។ រហូតដល់សតវត្សទី១៨ ចំពោះបទឧក្រិដ្ឋនៃការក្បត់ នៃការប្រមាថព្រះចេស្ដា គេដាក់ទណ្ឌកម្មសាច់ញាតិសាលោហិតនិងកូនរបស់អ្នកជាប់ពិរុទ្ធ។

តាម ផូកូនេ ការណ៍អាថ៌កំបាំងទាំងនេះអាចពន្យល់បានដោយងាយ ព្រោះជាការណ៍ដែលលាតត្រដាងបង្ហាញអំពីទម្លាប់ប្រព្រឹត្តផ្ទាល់របស់យើង។ ដោយហេតុថា បទឧក្រិដ្ឋនាំឱ្យមានការរំភើបរួមយ៉ាងខ្លាំង តម្លៃពិសិដ្ឋបំផុតរបស់សង្គមក៏ត្រូវបានគេប្រមាថ។ ការរំភើបរួមនេះចង់បន្ធូរចេញមកក្រៅ ដូចនេះត្រូវតែរកច្រកដើម្បីនឹងអាចសំដែងចេញមកដោយសេរី និងដើម្បីឱ្យបានស្រាកកំហឹង។ ពិតមែនហើយថា ការរំភើបរួមអាចនឹងបាត់ កាលបើគេអាចធ្វើឱ្យបទឧក្រិដ្ឋដែលបានប្រព្រឹត្តទៅហើយត្រឡប់ជាគ្មានទៅវិញ។ ក៏ប៉ុន្តែ អ្វីដែលកើតមានឡើងហើយ គឺជាការរួចស្រេចទៅហើយគ្មានតិចនិចណាមួយអាចនឹងលុបបំបាត់បទឧក្រិដ្ឋដែលបានប្រព្រឹត្តហើយនោះបានទេ។ នៅពេលនោះដោយមិនអាចបំបាត់ចោលមែនទែននូវបទឧក្រិដ្ឋដែលទើបនឹងប្រព្រឹត្តរួចហើយនោះបានសង្គមក៏សាកល្បងលុបបំបាត់ចោលនូវបទឧក្រិដ្ឋនោះ តាមមន្តអាគមទៅវិញ ពោលគឺខិតខំបំផ្លាញចោលនូវនិមិត្តរូបនៃបទឧក្រិដ្ឋដែលគេទុកជា«អ្នករងកំហុស»។ អ្នករងកំហុសគឺជាវត្ថុណាមួយក៏ដោយដែលមានជាប់ទាក់ទងទៅនឹងឧក្រិដ្ឋកម្មតាមគំនិតរបស់យើងដោយសារទំនាក់ទំនងនៃភាពដូចគ្នា ឬក៏គ្រាន់តែនៅជិតខាងគ្នាប៉ុណ្ណោះ។ ឧទាហរណ៍ដូចជាដោយមិនអាចនឹងបំបាត់បទឧក្រិដ្ឋបាន គេក៏តាំងនាំគ្នាដុតចោល នៅក្នុងការហែក្បួនយ៉ាងអឹកធឹកនូវព្រនង់ប្រឡាក់ឈាមដែលគេឃើញនៅក្បែរអ្នករងគ្រោះ។ ដូចនេះការដាក់ទោសជំនាន់ដើមមានលក្ខណៈទាក់ទងនឹងមន្តអាគមទៅវិញ។ វិបាកវិនិច្ឆ័យរបស់យើងឥឡូវនេះក៏មិនមានលក្ខណៈតាមរបៀបនេះដែរ ក៏ប៉ុន្តែការជឿនលឿននៃគំនិតរិះគិតគ្រាន់តែបានបង្រួបបង្រួមដែនអនុវត្តន៍ប៉ុណ្ណោះ។

យើងលែងផ្ដន្ទាទោសវត្ថុ សាកសព ឬគ្រួសាររបស់អ្នកជាប់ពិរុទ្ធទៀតហើយ ពីព្រោះភាពឥតន័យនៃការអនុវត្តន៍បែបនេះ ត្រូវបានគេទទួលស្គាល់គ្រប់គ្នា។ ហើយបើឧក្រិដ្ឋជន នៅតែត្រូវគេ«ផ្ដន្ទាទោស»ជាញឹកញាប់ ព្រោះតែឧក្រិដ្ឋកម្មរបស់ខ្លួន ក៏មិនមែនមកពីទំនាក់ទំនងបែបអស្តិរូបវិជ្ជារវាងសេរីអាជ្ញាមួយនិងអំពើមួយនោះទេ គឺមកតែពីគំនិតរបស់យើងតែងតែទាញប្រដូចឧក្រិដ្ឋកម្មទៅឧក្រិដ្ឋជន។ ហើយទោះជាតម្រូវទៅលើបុគ្គលម្នាក់ៗហើយក៏ដោយ ក៏ដំបូង វិបាកវិនិច្ឆ័យមានលក្ខណៈទាបនៅឡើយ ដូចជាគេអនុវត្តច្បាប់របស់ តាល្យុង (Loi de Talion) «យកភ្នែកទៅសងភ្នែក ធ្មេញទៅសងធ្មេញ»។ ក្រោយមក គេក៏យកការពិន័យមកជំនួសច្បាប់របស់ តាល្យុង វិញ ប៉ុន្តែចំនួនប្រាក់ដែលត្រូវបង់មិនមែនសមទៅតាមកំហុចខាតដែលបានធ្វើហើយនោះទេតែសមទៅតាមឋានៈនៅក្នុងសង្គមនៃបុគ្គលដែលត្រូវគេប៉ះពាល់ដល់សិទ្ធិទៅវិញ។ នៅទីបំផុតច្បាប់ព្រហ្មទណ្ឌជំនាន់ដើមច្រើនតែមានភាពឃោរឃៅ ហើយនៅពេលខ្លះទណ្ឌកម្មតម្រូវទៅលើរូបរាងកាយនៃអ្នកប្រព្រឹត្តបទល្មើសតែម្ដង ដូចជាការវាយដំទៅលើរាងកាយ ការចងនឹងសសរ។ល។

បញ្ហាមួយបានចោទឡើងចំពោះវិបាកវិនិច្ឆ័យគឺករណីនៃទោសប្រហារជីវិត។ ដោយគេមិនអាចបំបាត់ឧក្រិដ្ឋកម្មបាន គេក៏បំបាត់ឧក្រិដ្ឋជនតែម្ដង។ ការដាក់ទោសប្រហារជីវិតឃាតកជាបរាជ័យមួយធំណាស់ បើយើងពិចារណាឱ្យដល់ ព្រោះនៅក្នុងករណីនេះ មិនមែនមានតែមនុស្សម្នាក់ស្លាប់ទេ បែរជាមានអ្នកស្លាប់ដល់ទៅពីរវិញ។ ឃើញថា តុលាការដែលមានគំនិតប្រឆាំងនឹងឃាតកបែរជាធ្វើត្រាប់តាមឃាតកទៅវិញ ខុសគ្នាតែត្រង់ឃាតកសម្លាប់ក្រោមឥទ្ធិពលនៃតណ្ហា រីឯតុលាការសម្លាប់ដោយមានរបៀបរៀបរយ (méthodiquement) និងក្រោយពីការជជែកផ្ទុផ្ទងគ្នាយ៉ាងយូរតែប៉ុណ្ណឹង។

តែទោះជាយ៉ាងណាក៏ដោយ ក៏យើងមិនអាចសន្និដ្ឋានថា វិបាកវិនិច្ឆ័យសុទ្ធតែមិនសមហេតុផលទាំងអស់បានទេ។ តាមពិត វិបាកវិនិច្ឆ័យសុទ្ធតែមានសំអាងជាក់លាក់ ហើយក្នុងករណីខ្លះវាអាចមានលក្ខណៈចាំបាច់ផង។ វិបាកវិនិច្ឆ័យពិតមែនតែមានលក្ខណៈផ្អែកទៅលើមន្តអាគមច្រើន តែវាអាចមានលក្ខណៈប្រកបទៅដោយវិចារណញ្ញាណដែរ។ គឺអាស្រ័យដោយលក្ខណៈខាងក្រោយនេះហើយ ទើបគេអាចពន្យល់តាមទ្រឹស្តីកំណត់និយមបានអំពីវិបាកវិនិច្ឆ័យបំបាត់ចោល និងវិបាកវិនិច្ឆ័យបំភ័យ។

នៅកន្លែងនេះគឺមិនមែនក្នុងនាមនៃអស្តិរូបវិជ្ជាទៀតទេ ដែលគេឱ្យអ្នកជាប់ពិរុទ្ធ «លុបលាងកំហុសដោយទទួលទណ្ឌកម្ម» ចំពោះអំពើដែលបានធ្វើរួចស្រេចទៅហើយ ហើយមិនអាចនឹងកែវិញបាន ប៉ុន្តែគឺក្នុងនាមនៃផលប្រយោជន៍សង្គមដែលតម្រូវឱ្យចៀសវាងទោសកម្មទៅអនាគតនិងឧក្រិដ្ឋកម្មនានា។ ស្ពីណូសា ទោះជាជឿកំណត់និយមនៃអំពើរបស់យើងយ៉ាងច្បាស់លាស់ក៏ដោយ ក៏នៅតែគិតថា អ្នកជាប់ពិរុទ្ធត្រូវតែទទួលទណ្ឌកម្មព្រោះ«មនុស្សដែលមានធម្មជាតិអាក្រក់តែងនាំឱ្យគេខ្លាច និងចង្រៃមិនតិចជាងសត្វពស់ឡើយ។ គេត្រូវតែមានច្បាប់សម្រាប់ឱ្យធ្វើពួកនេះបិតនៅក្នុងភាពលែងបង្កទោសបាន ដូចជាគេប្រល័យសត្វពស់ដែលមានពិសនោះដែរ»។ នៅក្នុងន័យនេះ ដោយមានគំនិតចេញមកពីភាពចាំបាច់នៃកិច្ចការពារសង្គម វិបាកវិនិច្ឆ័យត្រូវតែមានមុខងារជាអ្នកបំបាត់ចោល។

ប៉ុន្តែ សម្រាប់ពួកអ្នកទ្រឹស្តីជាច្រើនវិបាកវិនិច្ឆ័យត្រូវតែមានមុខងារបំភ័យមុនអ្វីទាំងអស់។ គេត្រូវតែធ្វើឱ្យឃើញជាឧទាហរណ៍ ធ្វើឱ្យនឿយណាយដល់អ្នកចង់ត្រាប់ជាយថាហេតុនូវឧក្រិដ្ឋកម្មដែលបានធ្វើមកហើយដោយចង្អុលប្រាប់អ្នកទាំងនោះថា តើគេអាចនឹងរងគ្រោះថ្នាក់យ៉ាងណាខ្លះ? ដូចនេះការខ្លាចទណ្ឌកម្មនឹងចូលរួមតែម្ដងទៅក្នុងកំណត់និយមនៃអំពើ ហើយនិងក្លាយទៅជាមូលហេតុដ៏ខ្លាំងក្លាមួយ ដែលអាចធ្វើឱ្យមនុស្សបែរចេញពីអំពើអកុសលបាន។ នេះគឺជាសំអាងដែលពួកអ្នកនិយមឱ្យមានទោសប្រហារជីវិតតែងលើកយកមកនិយាយជាញឹកញយៈ «សង្គមលើកក្បាលអ្នកស្លាប់ដោយទោសប្រហារជីវិតគ្រាន់ដើម្បីឱ្យពួកបេក្ខជនឃាតកម្មមើលឃើញអនាគតរបស់ខ្លួនហើយថយក្រោយវិញ»។

អស់អំឡុងពេលដ៏យូរ ការប្រហារជីវិតមនុស្សទោសបានធ្វើឡើងជាសាធារណៈ។ នៅប្រទេសអង់គ្លេស នាពាក់កណ្ដាលសតវត្សទី១៩ ថ្ងៃដែលគេព្យួកមនុស្សទោសបានត្រូវគេឱ្យឈប់សំរាកដើម្បីឱ្យអ្នកទាំងអស់អាចនឹងមកប្រជុំគ្នាមើលទស្សនីយភាពការធ្វើទោសជាសាធារណៈមានគោលបំណងពីរ គោលបំណងមួយដែលគេសារភាពគឺចង់បន្លាចដោយឱ្យឃើញជាឧទាហរណ៍ គោលបំណងអាថ៌កំបាំងមួយទៀត គឺអនុញ្ញាតឱ្យអ្នកធ្វើត្រាប់ជាយថាហេតុ «បន្ធូរ» កម្លាំងជំរុញចិត្តឈ្លានពានរបស់គេ ដោយទៅសប្បាយនឹងទស្សនីយភាពនៃការប្រហារជីវិត។ កេសលែ (Kestler) បាននិទានថានៅឆ្នាំ1807 ការព្យួរកឧក្រិដ្ឋជនពីរនាក់បានទាក់ទាញទស្សនិកជនយ៉ាងហោចណាស់បួនម៉ឺននាក់ ហើយហ្វូងមនុស្សដែលរំភើបក្រៃលែងជ្រួលចុះជ្រួលឡើងដល់ទីបំផុតមានទុកសាកសពមួយរយនៅលើទីលាន!

តាមពិត វិបាកវិនិច្ឆ័យបំបាត់ចោលនិងវិបាកវិនិច្ឆ័យបំភ័យមិនជាទីពេញចិត្តណាស់ណាទេ ខាងផ្នែកសីលវិជ្ជា។ ដំបូង អ្នកជាប់ពិរុទ្ធត្រូវគេទុកដូចជាវត្ថុសាមញ្ញមួយ ទុកជាឱកាសនិងធ្វើឱ្យឃើញជា «ឧទាហរណ៍»។ ចំណែកឯសីលវិជ្ជាវិញតម្រូវ (ដូចខាន់ (Kant) បានយល់ឃើញរួចមកហើយ) ឱ្យទុកមនុស្សទាំងអស់ជាគោលបំណងមិន

មែនទុកជាមធ្យោបាយទេ។ នៅស្រុកបារាំង ចាប់តាំងពីឆ្នាំ1937 ក្រោយពីមានការប្រហារជីវិតឧក្រិដ្ឋជនម្នាក់ឈ្មោះ វេតម៉ាន់ (Weidmann) ដែលបានទាក់ទាញអ្នកកាសែតនិងអ្នកថតរូបមួយហ្វូងមក និងដោយសារអ្នកទាំងនេះបានទិតៀនរឿងនេះយ៉ាងខ្លាំងនៅក្នុងការយកព័ត៌មានកាសែតរបស់ខ្លួន អំណាចសាធារណៈក៏សម្រេចលែងឱ្យមានការប្រហារជីវិតជាសាធារណៈទៀត។ អ្នកជាប់ទោសប្រហារជីវិតត្រូវគេសម្លាប់យ៉ាងស្ងាត់ៗ នៅក្នុងទីធ្លានៃពន្ធនាគារ។ ការដែលនៅតែទុកទោសប្រហារជីវិតជាឧទាហរណ៍ ប៉ុន្តែគ្រាន់តែបន្ថយការផ្សាយហាក់ដូចជាមិនត្រូវទៅតាមវិចារណញ្ញាណសោះ។ ហើយម្យ៉ាងទៀតតើទោសប្រហារជីវិតជាឧទាហរណ៍ស័ក្តិសិទ្ធិឬទេ ?ទោះជាយ៉ាងណាក៏ដោយក៏ អាល់ប៊ែកាមុស (Albert Camus) ធ្វើការកត់សម្គាល់ថា "នៅក្នុងចំណោមប្រជាជាតិទាំងសាមសិបពីរដែលបានបំបាត់ចោល ឬក៏លែងប្រើតទៅទៀតនូវទោសប្រហារជីវិត ចំនួនឧក្រិដ្ឋកម្មក៏មិនបានកើនតទៅទៀតដែរ។ ហើយតាមការសង្កេតមកហើយ វិបាកវិនិច្ឆ័យដែលមានន័យកំញើញបំភ័យមិនបានហុចលទ្ធផលដូចដែលគេបានសង្ឃឹមទុកនោះឡើយ។ ការសិក្សាវិភាគផ្នែកចិត្តវិទ្យាទៅលើពពួកអ្នកប្រព្រឹត្តបទល្មើសបានបង្ហាញឱ្យឃើញថា ការដាក់ទណ្ឌកម្មធ្ងន់ហួសកម្រិតដល់ឧក្រិដ្ឋជនមិនគ្រាន់តែមិនបានធ្វើឱ្យធ្លាក់ទឹកចិត្តដល់អ្នកប្រព្រឹត្តបទល្មើសប៉ុណ្ណោះទេ តែថែមទាំងលើកទឹកចិត្ត ពន្យុះអ្នកទាំងនោះឱ្យស្រឡាញ់ចូលចិត្តប្រព្រឹត្តបទល្មើស កាន់តែខ្លាំងទៅវិញ។ ឧក្រិដ្ឋជនទាំងនេះបែរជារកឃើញនៅក្នុងបទឧក្រិដ្ឋនូវកិត្តិយសដ៏រុងរឿងរបស់ខ្លួនរបស់ខ្លួននៅក្នុងមន្ទីរឃុំឃាំង អ្នកទោសប្រហារជីវិតទាំងឡាយត្រូវបានគេគោរពយកចិត្តទុកដាក់ផ្តល់កិត្តិយសដូចវីរបុរស។ ម្យ៉ាងវិញទៀតការដាក់ទណ្ឌកម្មធ្ងន់ហួសកំហុសដែលធ្វើបានជំរុញចិត្តមនុស្សឱ្យធ្វើការប្រឆាំងតបវិញ ជាជាងមានការស្តាយក្រោយចំពោះអំពើរបស់ខ្លួន។ ហេតុដូចនេះហើយបានជាគេតែងនិយាយថា "កន្លែងអប់រំគឺជាកន្លែងនៃអំពើពុករលួយគ្រប់យ៉ាង"។

វិបាកវិនិច្ឆ័យអាចជាទីពេញចិត្តពិតប្រាកដបាន លុះត្រាតែមានមុខងារអប់រំសាជាថ្មីឡើងវិញ។ ប្លាតុង ក៏បានធ្វើការកត់សម្គាល់រួចមកហើយដែរថា អ្នកជាប់ពិរុទ្ធខ្លួនឯងត្រូវទាមទាររកចៅក្រមដូចជាអ្នកជំងឺទាមទាររកគ្រូពេទ្យដែរ។ នេះប្រហែលជាមកពីគាត់គិតទៅដល់គុណធម៌នៃការលាងកំហុសដោយទទួលទណ្ឌកម្មនៅក្នុងទស្សនវិស័យនៃអស្តិរូបវិជ្ជាហើយមើលទៅ។ ប៉ុន្តែ វិបាកវិនិច្ឆ័យអាចមានលក្ខណៈជាវិធីព្យាបាលជំងឺនៅក្នុងន័យពិតប្រាកដជាងមុន។ បើអ្នកជាប់ពិរុទ្ធជាមនុស្សឈឺ គេត្រូវតែព្យាបាលអ្នកនោះ។ នៅក្នុងរឿងនេះចិត្តវេជ្ជវិទ្យា ចិត្តវិភាគមានដែនអនុវត្តន៍ដែលសារៈសំខាន់តែងលេចយ៉ាងច្បាស់ឡើងរាល់ៗថ្ងៃ។ មុនអ្វីៗទាំងអស់គេត្រូវតែអប់រំមនុស្សទោសឱ្យស្របនឹងជីវិតក្នុងសង្គមសាជាថ្មីឡើងវិញ។ គួរតែបង្រៀនមនុស្សនេះឱ្យចេះមុខរបរអ្វីមួយ បង្រៀនគេឱ្យស្គាល់តម្លៃនៃសាមគ្គីភាព និងរៀបចំការចូលមករស់នៅក្នុងសង្គមសាជាថ្មីឡើងវិញរបស់គេ (កំណែទម្រង់ផ្នែកតុលាការនៅឆ្នាំ1945 ក៏មានគំនិតចេញមកពីគោលការណ៍នេះដែរ)។

ប៉ុន្តែជាការប្រសើរ ត្រូវតែការពារជាមុនកុំឱ្យមានទោសកម្មនិងឧក្រិដ្ឋកម្ម ដើម្បីចៀសវាងការធ្វើទោសដល់អំពើទាំងនោះ។ ដោយពិតទោសកម្មអាចនឹងឱ្យគេយល់បានពីព្រោះកង្វះខាតដែលមាននៅក្នុងជីវិតបង្កើតឱ្យមានប្រតិកម្មឈ្លានពាននៃបទឧក្រិដ្ឋ។ ចំណែកឯសង្គមវិញ ដោយត្រូវគេរំលោភលើតម្លៃរបស់ខ្លួន បានបញ្ចេញការឃោរឃៅចំពោះអ្នកមានពិរុទ្ធដែរ។ បើកង្វះខាតដែលបង្កើតបទឧក្រិដ្ឋកាន់តែមានខ្លាំងឡើង ពេលនោះវិបាកវិនិច្ឆ័យនៃសង្គម (ដែលធ្វើឱ្យមានលំនឹងជាមួយនឹងកង្វះខាតនោះ) ក៏កាន់តែធ្ងន់ឡើងៗដែរ។ ពីដើមមនុស្សលួចនំប៉័ងអាចនឹងជាប់គុកពីបទឧក្រិដ្ឋ។ ឥឡូវនេះទោសកម្មដ៏ស្តួចស្តើងនេះបើសន្មតថាត្រូវគេប្តឹងគ្រាន់តែបណ្តាលឱ្យមានការពិន័យប៉ុណ្ណោះ។ ការលួចសំខាន់ជាងនេះទៅទៀតត្រូវដាក់ទណ្ឌកម្មដល់ទោសជាប់គុកដោយមានការព្យួរទោស (កុំឱ្យតែមានការប្រព្រឹត្តិខុសម្តងទៀត។ គេអាចនឹងពន្យល់ការអត់ឱនទោសនេះបាន៖ ការជឿនលឿននៃសេដ្ឋកិច្ចបន្ថយទំនោរទៅរកទោសកម្មប្រាក់បំណាច់នៃការងារក្នុងមួយម៉ោងទោះជាគេឱ្យតិចយ៉ាងណាក៏ដោយ ក៏អាចគ្រប់គ្រាន់សម្រាប់ទិញនំប៉័ងមួយដែរ។ ដើម្បីប្រយុទ្ធតទល់នឹងអំពើប្រឆាំងសង្គមគេត្រូវប្រយុទ្ធទល់នឹងមហាភ័យទាំងឡាយនៃសង្គមមានដូចជាលំនៅស្មោគគ្រោគ ការសេពសុរា និងខិតខំធ្វើឱ្យជីវភាពនៃជនទាំងអស់មានកម្រិត

ខ្ពស់ជាងមុន។ អំពើប្រឆាំងសង្គមទាំងនេះមិនមែនមានប្រភពចេញមកតែអំពីបញ្ហាសេដ្ឋកិច្ចប៉ុណ្ណោះទេ តែវាអាចកើតមានឡើងដោយកង្វះការអប់រំដែរ ឧទាហរណ៍ដូចជាបទល្មើសនៃពួកក្មេងដែលគេជួបប្រទះនៅក្នុងសម័យយើងនេះ។ ដូចនេះដើម្បីដោះស្រាយបញ្ហានៃបទល្មើសប្រភេទក្រោយនេះគេត្រូវការជាចាំបាច់នូវការអប់រំ។ ប៉ុន្តែនៅក្នុងន័យជាទូទៅគឺការជឿនលឿននៃសង្គមទាំងអស់ ដែលធ្វើឱ្យបរាជ័យដល់កម្លាំងជំរុញចិត្តឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ហើយបន្ថយវិបាកវិនិច្ឆ័យដាក់ទណ្ឌកម្មឱ្យមានចំនួនយ៉ាងតិចបំផុត៕

# មេរៀនទី៣ ឆន្ទៈ

## ៣.១ និយមន័យ

ឆន្ទៈគឺជាកម្លាំងចិត្តដែលជំរុញឱ្យមនុស្សយើងធ្វើសកម្មភាពប្រកបដោយការរិះគិត។

អំពើឆន្ទៈ គឺជាអំពើប្រកបដោយបំណង ពោលគឺអំពើកើតឡើងដោយសេចក្តីព្រាង ឬសេចក្តីប្រាថ្នាជាមុន។ ដូចនេះ អំពើឆន្ទៈគឺជាអំពើប្រកបដោយការរិះគិត។

## ៣.២ វិភាគនៃអំពើឆន្ទៈ

តាមវិភាគធម្មតា អំពើឆន្ទៈមានបួនដំណាក់កាលៈ

### ៣.២.១ បញ្ញត្តិកម្ម

នៅដំណាក់ទី១នេះ យើងពិនិត្យក្នុងចិត្តនូវអំពើដែលបម្រុងនឹងធ្វើ។ ឧទាហរណ៍ៈ ទិញឡាន ធ្វើវិស្វករ។

### ៣.២.២ ការជជែកផ្ទួផ្ទង

នៅដំណាក់ទី២នេះ យើងពិនិត្យនូវហេតុ មូលហេតុ អត្ថប្រយោជន៍ អត្ថទោស ឬផលអាក្រក់នៃអំពើដែលយើងបានព្រាងហើយ។ យើងថ្លឹងមើលគុណ និងទោសដោយម៉ឺងម៉ាត់។

### ៣.២.៣ សេចក្តីសម្រេច

នៅដំណាក់ទី៣នេះ បន្ទាប់ពីបានគិត និងថ្លឹងមើលហេតុផលសព្វគ្រប់ហើយ យើងធ្វើសេចក្តីសម្រេចក្នុងចិត្ត គឺយើងសម្រេចថាធ្វើ ឬមិនធ្វើ។ ការសម្រេចជាដំណាក់សំខាន់បំផុតនៃឆន្ទៈ។ មនុស្សដែលគ្មានឆន្ទៈមែនទែន តែងគិតចុះគិតឡើងពុំចេះដាច់ស្រេច ហើយទីបញ្ចប់ពុំហ៊ានសម្រេចអ្វីមួយសោះ។ ខ្វះការសម្រេចគឺខ្វះឆន្ទៈ។

### ៣.២.៤ ការប្រតិបត្តិ

ប្រសិនបើការសម្រេចនោះមានភាពជាវិជ្ជមាននៅដំណាក់ទី៤នេះ គេចាប់ប្រត្តិបត្តិការ ដើម្បីសម្រេចកិច្ចដែលគេបានប្តេជ្ញាថានឹងធ្វើដោយប្រើមធ្យោបាយត្រឹមត្រូវឱ្យស្របនឹងកិច្ចនោះ។ អនុវត្តន៍ ឬការប្រតិបត្តិនេះជាដំណាក់ចុងក្រោយនៃឆន្ទៈ ហើយជាសក្ខីភាព ឬជាភស្តុតាងនៃឆន្ទៈ។ បើគ្មានដំណាក់ទី៤នេះទេ ឆន្ទៈក៏ពុំអាចមានរូបរាងកើតដែរហើយយើងក៏ពុំអាចមានឈ្មោះថាមានឆន្ទៈដែរ តែមានឈ្មោះថា មាន «ឆន្ទៈស្ទើរ» (velléité)គឺការគ្រាន់តែចង់នោះឯង។

## ៣.៣ ធម្មជាតិនៃឆន្ទៈ

ធម្មជាតិនៃឆន្ទៈនេះ ត្រូវបានទ្រឹស្តីខ្លះយកមកបកស្រាយប្លែកៗគ្នាទៅតាមទស្សនៈនៃទ្រឹស្តីនីមួយៗនោះ។

### ៣.៣.១ ទ្រឹស្តីបញ្ញានិយម

បើតាមពួកបញ្ញានិយមដូចជា ស្ពីណូសា ឆន្ទៈនិងបញ្ញាគឺជាវត្ថុតែមួយគត់ ពោលគឺវត្ថុដែលមានលក្ខណៈដូចគ្នាទាំងអស់។ ឆន្ទៈគឺបញ្ញានេះឯង។ ការសម្រេចនៃឆន្ទៈចេញមកពីស្វ័យប្រវត្តិនៃបញ្ញា ពោលគឺបញ្ញាយើងសម្រេចដោយស្វ័យប្រវត្តិនូវអ្វីៗដែលយើងប្រាថ្នា។ មានន័យថា ការសម្រេចនៃឆន្ទៈជាលទ្ធផលនៃស្វ័យប្រវត្តិរបស់បញ្ញា។

ការនិយមថា ឆន្ទៈគឺជាបញ្ញាបែបនេះ ដូចជាច្របូកច្របល់បន្តិច ព្រោះបើជាឆន្ទៈក៏ជាបញ្ញាដែរ នោះយើងមុខជានឹងអស់ផ្លូវរែកញែកចែកចេញឱ្យដាច់ពីគ្នានូវអ្វីជា ឆន្ទៈ អ្វីជាបញ្ញាហើយ។ តែយើងមិនមែនពុំទទួលស្គាល់ថាឆន្ទៈតែងប្រើបញ្ញាខ្លះដែរនោះទេ ព្រោះកាលណាយើងប្រឌិតហើយពិចារណាត្រិះរិះមុននឹងសម្រេច យើងតែងតែប្រើបញ្ញាដែរ។ ហេតុនេះ បើនិយាយថានៅក្នុងឆន្ទៈមានបញ្ញាដែរ ដូចជាសមជាងថា ឆន្ទៈគឺជាបញ្ញា ព្រោះថាការនិយាយបែបនេះមានន័យប្លែកគ្នា ហើយទទួលស្គាល់ភាពពីរប្លែកគ្នាតែមានទំនាក់ទំនងគ្នាដែរ។

តាមពួកបញ្ញានិយមនេះ កូនសោនៃឆន្ទៈឋិតនៅលើដំណាក់ទី១និងទី២។ បើមើលមួយភ្លែតយើងមុខជាជឿដែរ ព្រោះដំណាក់ទី១និងទី២ជាកត្តាដើមនៃកំណើតរបស់ឆន្ទៈ។ តែបើយើងគិតឱ្យមែនទែនទៅ យើងពុំអាចជឿទេ ព្រោះបើគ្មានដំណាក់ទី៣ និងទី៤ទេនោះ ឆន្ទៈក៏ពុំអាចកើតមានបានដែរ ហើយបើនៅត្រឹមតែដំណាក់ទី១ និង ទី២វិញ ឆន្ទៈនឹងក្លាយទៅជាចំណង់វិញ។

តាម គូហ៊ីយេ (Gouhier) កូនសោនៃឆន្ទៈឋិតនៅលើដំណាក់ទី៤វិញ គឺការប្រតិបត្តិព្រោះសេចក្តីសម្រេចនឹងអាចមានរូបរាងបាន លុះត្រាតែមានការប្រតិបត្តិ។

### ៣.៣.២ ទ្រឹស្តីពិសោធនិយម

តាមអ្នកនិយមទ្រឹស្តីនេះដូចជា កុងឌីយ៉ាក់(Condillac) ឆន្ទៈគឺចំណង់។ ឆន្ទៈគឺចំណង់ដាច់ខាត ការនិយមបែបនេះក៏ពុំសូវសមដែរ ព្រោះនាំឱ្យមានភាពច្របូកច្របល់រវាងឆន្ទៈនិងចំណង់។ ទុកជាថាឆន្ទៈគឺចំណង់ខ្លាំងដាច់ខាតក៏ដោយ ក៏នៅតែពុំសូវសមដែរ ព្រោះឆន្ទៈមានធម្មជាតិសកម្ម រីឯចំណង់វិញមានធម្មជាតិអកម្ម។ ឆន្ទៈតែងតែចេញជាអំពើ ឯចំណង់វិញតែងតែឋិតនៅត្រឹមតែក្នុងចិត្តក្នុងការព្រាង។ ជាពិសេស ចំណង់ខ្លាំងដាច់ខាត់ គឺលំងប់ទៅវិញទេ។ ដូចនេះ ក្នុងករណីណាក៏ដោយក៏ឆន្ទៈពុំអាចច្រឡំនឹងចំណង់បានឡើយ។

### ៣.៣.៣ ភាពប្លែកគ្នារវាងឆន្ទៈនិងចំណង់

នៅក្នុងភាសាយើងសព្វថ្ងៃ ពាក្យ «ចំណង់» ត្រូវគេនាំគ្នាប្រើជាទូទៅដើម្បីសម្គាល់សេចក្តីប្រាថ្នា ទុកជាសេចក្តីប្រាថ្នានេះមិនអាចសម្រេចបានក៏ដោយ។ ចំណង់នេះមិនមែនជាអំពើទេ តែជាការយល់សប្តិ ឬជាបំណន់។ ពីចំណង់នេះទៅឆន្ទៈ ការប្លែកគ្នាឋិតនៅត្រង់ការងារ។ លោក អាឡាំង (Alain) បានផ្ទុយពិភពនៃចំណង់ ឬពិភពកូនក្មេងទៅនឹងពិភពនៃឆន្ទៈនិងការងារ ឬពិភពនៃមនុស្សចាស់។ តាម ហ៊ីស្មាន់ (Heisman) គេអាចប៉ងធ្វើអ្វីក៏បានដែរ ប៉ងប៉ុន្មានក៏បានដែរ តែគេអាចមានឆន្ទៈតែទៅលើរបស់មួយគត់។ ឆន្ទៈសម្រាប់តែអំពើភ្លាមៗ។ គឺដោយហេតុនេះហើយ បានជាឆន្ទៈឋិតនៅលើការប្រតិបត្តិ។ តាមសម្តី ហ៊ីស្មាន់ ចំណង់សម្រាប់តែអនាគតកាល។ ចំណែកឯអំពើឆន្ទៈវិញ មាននៅតែក្នុងបច្ចុប្បន្នកាលប៉ុណ្ណោះ។

ពិតមែនហើយកិរិយាសព្ទ«មានឆន្ទៈ» ប្រើក្នុងន័យជាមួយគ្នានឹងកិរិយាសព្ទ«ចង់»។ ការប្លែកគ្នាឋិតនៅត្រង់ថាឆន្ទៈតែងប្រកបដោយវិចារណញ្ញាណនិងសកម្មភាព។ ឯចំណង់គ្មានវិចារណញ្ញាណទេ ហើយអកម្មថែមទៀត។

លោក កុងឌីយ៉ាក់ ពិតជាច្រឡំហើយ ព្រោះចំណង់ខ្លាំងដាច់ខាតមិនមែនជាឆន្ទៈទេ តែជាលំងប់វិញ។ មនុស្សដែលជាចំណីនៃចំណង់ខ្លាំងគឺជាមនុស្សដែលជក់នឹងអ្វីមួយមិនមែនជាមនុស្សដែលប្រកបដោយឆន្ទៈទេ ព្រោះមនុស្សប្រភេទក្រោយនេះ តែងតែចេះទប់ទល់នឹងចំណង់។

បើតាម រ៉ឺនូវៀ (Renouvier)មានឆន្ទៈមែនទែនគឺមានឆន្ទៈលើអ្វីដែលយើងមិនចង់បាន។ នេះបានសេចក្តីថាកម្មវត្ថុនៃឆន្ទៈ ពុំមែនជាកម្មវត្ថុនៃចំណង់ទេ។ ចំណែក លោក រីលៀម ដេម អះអាងថានៅក្នុងឆន្ទៈតែងមានអំណាចដើម្បីគ្របសង្កត់ចិត្តយើងប្រឆាំងនឹងសំទុះជំរុញនេះ ឬចិត្តសាវានោះ។ ដូចនេះតាមគំនិតរបស់លោក រីលៀម ដេម ឆន្ទៈមិនមែនជាចំណង់ទេ តែហាក់ដូចជាចិត្តជាប់នឹងការខំប្រឹង។ តើឆន្ទៈពិតជាទាក់ទងនឹងការខំប្រឹងមែនឬ?

### ៣.៣.៤ ទ្រឹស្តីការខំប្រឹង

បើតាម ម៉ែន ដឺ ប៊ីរ៉ង់ (Maine de Biran) គឺពិសោធន៍និងការខំប្រឹងជាពិសេសការខំប្រឹងខាងសាច់ដុំដែលធ្វើឱ្យយើងឃើញច្បាស់ល្អជាងគេនូវឆន្ទៈរបស់យើង។ ឧទាហរណ៍ ខ្ញុំលើកទ្រកៅអីមួយដោយលាតដៃសន្ធឹង។ ប៉ុន្តែមួយភ្លែត ខ្ញុំក៏ចាប់ឈឺដៃ។ ប៉ុន្តែបើខ្ញុំមានឆន្ទៈ ខ្ញុំក៏អាចបន្តការខំប្រឹងរបស់ខ្ញុំទៅទៀត។ ដូចនេះ ឆន្ទៈមានន័យថាអំណាចចិត្តអតិសេដ្ឋ គឺអំណាចដែលអាចថាព្រម ឬមិនព្រម ធ្វើឬមិនធ្វើ។ ឆន្ទៈជាការសម្រេចប្រកបដោយសេរីភាពពេញទីដែលពួកអស្តិរូបវិជ្ជាហៅថា សេរីអាជ្ញា។ ទ្រឹស្តីការខំប្រឹងនេះអាចឱ្យយើងឃើញសភាពនៃឆន្ទៈមែន តែពុំមែនធ្វើឱ្យយើងយល់ថាឆន្ទៈគឺការខំប្រឹងនោះទេ។ ឆន្ទៈនិងការខំប្រឹងជាលក្ខណៈពីរដោយឡែកពីគ្នា។ ឆន្ទៈសំដៅទៅ

លើអំណាចចិត្តដែលសម្រេចឱ្យយើងធ្វើ ឬមិនធ្វើ ឯការខំប្រឹងវិញជាសកម្មភាពកម្លាំងកាយដឹកនាំដោយកម្លាំងចិត្ត។ ឆន្ទៈឋិតនៅក្នុងវិស័យផ្លូវចិត្ត ការខំប្រឹងឋិតនៅក្នុងវិស័យផ្លូវកាយ។

## ៣.៤ ប្រភពនៃឆន្ទៈ

ប្រភពឬបុព្វហេតុនៃឆន្ទៈត្រូវបានទ្រឹស្តីខ្លះយកមកសិក្សាវែកញែកប្លែកៗគ្នាដូចតទៅ៖

### ៣.៤.១ សេរីអាជ្ញា

ចិត្តវិទ្យាដែលពឹងផ្អែកទៅលើស្បង់បានសិក្សាអំពីឆន្ទៈនេះ ហើយបានប្រកែកពុំព្រមទទួលស្គាល់ឆន្ទៈអរូបីអតិសេដ្ឋដែលដាច់ចេញស្រលះគ្មានទំនាក់ទំនងនឹងទំនោរនោះឡើយ។ បើនិយាយម្យ៉ាងទៀត ចិត្តវិទ្យាដែលប្រើវិធីវិទ្យាសាស្ត្រ ពុំព្រមទទួលស្គាល់ថាមានឆន្ទៈដែលផ្អែកលើសេរីអាជ្ញានោះទេ។ ដូចនេះចិត្តវិទ្យាបែបនេះទទួលស្គាល់តែឆន្ទៈដែលទាក់ទងនឹងទំនោរផ្សេងៗរបស់យើងដែលចេញពីទំនោរនោះ។ ការយល់បែបនេះក៏សមម្យ៉ាងដែរ ព្រោះទំនោរជាប្រភពនៃសកម្មភាពផ្លូវចិត្តរបស់យើងមែន។ ប៉ុន្តែត្រង់ថាឆន្ទៈពុំអាចឋិតលើសេរីអាជ្ញាវិញ ហាក់ដូចជាពុំសូវសម ព្រោះឆន្ទៈរបស់យើងអាចមានសេរីភាពពេញលេញ។ ម្ល៉ោះហើយឆន្ទៈរបស់យើងអាចប្រព្រឹត្តទៅដោយគ្មានអ្វីបង្ខិតបង្ខំ រារាំង ជ្រៀតជ្រែក។ ក្នុងករណីនេះឆន្ទៈយើងអាចមានទម្រង់ជាសេរីអាជ្ញាដែរ។

### ៣.៤.២ ទ្រឹស្តីកំណត់និយម

តាមទ្រឹស្តីនេះតែមានហេតុគឺមានផលហើយបើមានផលច្បាស់ជាមានហេតុ។ តាមទ្រឹស្តីនេះកិរិយាមាយាទមនុស្សចេញមកតែពីភាវៈសរីរាង្គ ពីចំណេះវិជ្ជាគឺការអប់រំរបស់យើង។ ដូចនេះអំពើប្រកបដោយឆន្ទៈសម្រេចមកតែពីកត្តាសរីរាង្គ បញ្ញា ចិត្ត និងសង្គម។ ម្យ៉ាងទៀត ឆន្ទៈមិនអាចឃ្លាតពីសំយោគត្រិះរិះនៃទំនោរផ្សេងៗទេ។ អ្នកខ្លះហ៊ាននិយាយថាចរិតរបស់មនុស្សអាចតពូជថែមទៀត។ ជំនឿលើហេតុផលធម្មជាតិក៏សមម្យ៉ាងដែរ ព្រោះវាស្របនឹងឧទាហរណ៍ខ្លះៗដែលយើងបានជួបប្រទះនៅក្នុងសង្គមមនុស្សមែនៗ តែជំនឿបែបនេះអាចបង្ហាញឱ្យដឹងថាគេពុំអាចគិតដល់ឥទ្ធិពលនៃការអប់រំទេ។ តាមពិតដោយផ្អែកលើអរិយធម៌នៃប្រទេសនីមួយៗការអប់រំមានសារៈសំខាន់ណាស់ប្រសិនបើអប់រំត្រូវ ព្រោះគេអាចច្នៃ ឬឆ្លាក់មនុស្សបានដោយការអប់រំនេះ។ គេអាចអប់រំច្នៃបានទាំងកាយទាំងចិត្ត ទាំងគំនិតមនុស្ស។ ក្នុងគ្រួសារខ្លះ ឪពុកជាចោរ តែកូនអាចទៅជាអាចារ្យ ប្រសិនបើកើតឡើងហើយ និងបានទទួលការអប់រំល្អគ្រប់គ្រាន់ដល់កម្រិតនិងទាន់ពេលវេលា។ ហេតុនេះ ឆន្ទៈមនុស្សអាចជាលទ្ធផលនៃការអប់រំមែនហើយស្របទៅតាមទ្រឹស្តីកំណត់និយមពិតផង។

### ៣.៤.៣ ទ្រឹស្តីវាសនានិយម

ទ្រឹស្តីវាសនានិយម គឺជាទ្រឹស្តីដែលយល់ថា វាសនាគឺជាប្រភពនៃអ្វីៗទាំងអស់។ តាមទ្រឹស្តីនេះ តែវាសនាចែងមកយ៉ាងណា គ្មានអ្វីអាចមករារាំងជំទាស់បានឡើយ។ ការអប់រំពុំមានឥទ្ធិពលអាចកែប្រែវាសនាបានទេ។ ហេតុនិងបុព្វហេតុត្រូវកម្រិតដោយវាសនាជាស្រេច។ មនុស្សមិនមែនជាម្ចាស់នៃអំពើខ្លួនឡើយ។ គឺវាសនាវិញទេដែលជាម្ចាស់នៃអំពើរបស់មនុស្សនោះឯង។ អ្នកទស្សនវិជ្ជាបារាំងឈ្មោះ ប៊ែសុន( Bergson ) ពុំបាននិយាយពីវាសនានិយមទេ តែបានអធិប្បាយថា"មនុស្សមិនមែនជាម្ចាស់នៃអំពើរបស់ខ្លួនឡើយ។ គឺសំទុះជីវិតវិញទេដែលជាម្ចាស់នៃអំពើរបស់មនុស្ស"។ យើងអាចសន្និដ្ឋានបានថា តាមគំនិត ប៊ែសុន ឆន្ទៈត្រូវបានសំទុះជីវិតគ្របសង្កត់លេបបាត់។ ដូចនេះ ក្នុងទ្រឹស្តីវាសនានិយមនិងទ្រឹស្តីសំទុះជីវិតរបស់ ប៊ែសុន មនុស្សយើងពុំមានឆន្ទៈទេ ព្រោះអំពើប្រកបដោយឆន្ទៈតែងតែមានការត្រិះរិះ និងការរើសយកនូវអ្វីមួយក្នុងចំណោមអ្វីទាំងឡាយដែលយើងមានលទ្ធភាពនឹងធ្វើបាន។ ប្រសិនបើយើងជឿវាសនា ឬជឿសំទុះជីវិតរបស់ ប៊ែសុន តើយើងមានប្រយោជន៍អ្វីនឹងបង្កបង្កើតស្បង់និងការអប់រំ ? តើស្បង់និងការអប់រំមានន័យតទៅទៀតឬទេ ? តាមពិតគឺឥទ្ធិពលនៃស្បង់នេះហើយ ដែលធ្វើឱ្យយើងអស់ជំនឿទៅលើវាសនា។ យើងអាចជឿថា មានសំទុះជីវិតមែន តែយើងជឿថា ការអប់រំរបស់សង្គមអាចធ្វើឱ្យយើងទៅជាម្ចាស់នៃសំទុះជីវិត វាធ្វើឱ្យយើងមានឆន្ទៈក្នុងការធ្វើអ្វីនីមួយៗ ពុំមែនធ្វើអ្វីៗទៅតាមសំទុះជីវិតនោះទេ។

## ៣.៥ ការបណ្តុះឆន្ទៈ

ការបណ្តុះឆន្ទៈគឺជាការដែលត្រូវប្រើពេលយូរព្រោះអំពើប្រកបដោយឆន្ទៈ តែងផ្អែកទៅលើកត្តាច្រើនយ៉ាងៈ

### ៣.៥.១ កត្តាសរីរាង្គ

យើងត្រូវថែសារពាង្គកាយឱ្យបានម៉ត់ចត់ដោយអនុវត្តតាមអនាម័យបានទៀតទាត់ ធ្វើចលនាឱ្យសមល្មម ដើម្បីឱ្យសារពាង្គកាយឋិតនៅក្នុងសភាពធម្មតាហើយសុខដុមដែលជាមូលហេតុនៃឆន្ទៈប្រកបដោយលំនឹង។ មនុស្សភាគច្រើនពុំបាននឹកនាថាឆន្ទៈតែងតែទាក់ទងនឹងសារពាង្គកាយទេ ព្រោះគេច្រើនយល់ថា ឆន្ទៈឋិតតែនៅលើចិត្តប៉ុណ្ណោះ។ ការយល់បែបនេះក៏សមម្យ៉ាងដែរ ព្រោះជួនកាលគេឃើញមនុស្សមាឌតូចស្គម ឈឺញឹកញាប់ តែមានចិត្តអង់អាចហ៊ានតស៊ូពុំខ្លាចស្លាប់។ តែក្នុងករណីនេះ ឆន្ទៈរបស់មនុស្សនោះច្បាស់ជាកើតឡើងដោយកត្តាផ្សេងពីកត្តាសរីរាង្គ។ គេច្រើនតែឃើញមនុស្សបែបនេះមានការអប់រំគ្រប់គ្រាន់។ ដូចនេះ ការបណ្តុះសញ្ចេតនាឱ្យបានគ្រប់គ្រាន់អាចជាកត្តាជំរុញមនុស្សឱ្យមានឆន្ទៈបានដែរ។ ផ្ទុយទៅវិញ នៅពេលខ្លះ គេឃើញមនុស្សមាឌធំ តែពុំមានចិត្តអង់អាចក្លាហានទេ។ កង្វះឆន្ទៈនេះប្រហែលមកពីមនុស្សនោះបានតែមាឌ ហើយខ្វះកម្លាំង ឬខ្វះការអប់រំខាងសញ្ចេតនានេះឯង។ តាមធម្មតា គេតែងសង្កេតឃើញមនុស្សដែលមាឌតូចក្តី ធំក្តី តែមានសុខភាពប្រសើរមានការអប់រំខាងសញ្ចេតនាថ្លៃថ្លាច្រើនជាមនុស្សប្រកបដោយឆន្ទៈជាមនុស្សពុំខ្លាចនឿយហត់ ពុំសូវញញើតគ្រោះថ្នាក់ ពុំចេះស្លន់ស្លោ ចូលចិត្តគិតមុនប្រព្រឹត្ត ស្រឡាញ់ការប្រឹងប្រែងនឹងការងារ។ មនុស្សដែលស្គាល់កម្លាំងខ្លួនច្បាស់ តែមានការទុកចិត្តលើខ្លួនហើយមិនសូវខ្វះឆន្ទៈទេ។

### ៣.៥.២ កត្តាបញ្ញា

កត្តាបញ្ញាមានសារៈសំខាន់ណាស់។ ដើម្បីឱ្យឆន្ទៈបានសម្រេចជោគជ័យគ្រប់ពេលយើងត្រូវទម្លាប់គិតមើលឱ្យច្បាស់នូវគោលបំណងយើង ហើយត្រូវគិតទៅរកមធ្យោបាយឱ្យស្របនឹងគោលបំណងនោះផង។ កំសោយឆន្ទៈច្រើនជាលទ្ធផលនៃចិត្តច្របូកច្របល់គ្មានសណ្តាប់ធ្នាប់។ ដើម្បីឱ្យឆន្ទៈយើងខ្លាំង យើងត្រូវធ្វើចិត្ត ឬបញ្ញាយើងឱ្យខ្លាំង ដោយត្រូវចេះផ្ចង់ស្មារតីឱ្យខ្លាំង។ ទម្លាប់ចាប់ផ្ចង់ស្មារតីឱ្យខ្លាំងក៏ពុំទាន់គ្រប់គ្រាន់ដែរគឺយើងត្រូវទម្លាប់ចៀសវាងរវើរវាយដែលជាប្រភពនៃឧបសគ្គដល់ឆន្ទៈ។ ដូចនេះ ឆន្ទៈពុំអាចចោលបញ្ញាបានទេ នៅក្នុងឆន្ទៈមានកត្តាបញ្ញាមួយ ដើម្បីជាពន្លឺជួយឱ្យឆន្ទៈបានសម្រេចការអ្វីនីមួយៗ រីឯបញ្ញានេះក៏ទាក់ទងនឹងការផ្ចង់ស្មារតីដែរ។ ឯការផ្ចង់ស្មារតីនេះខ្លាំងឬខ្សោយ យូរឬឆាប់ក៏អាស្រ័យទៅលើសុខភាព ឬកម្លាំងរបស់យើងមួយផ្នែកដែរ។ ដូចនេះ កត្តាបញ្ញាក៏ត្រូវមានទំនាក់ទំនងនឹងកត្តាសរីរាង្គដែរ ដើម្បីឱ្យឆន្ទៈមានសកម្មភាពល្អ។

### ៣.៥.៣ កត្តាសញ្ចេតនា

សញ្ចេតនាជាចលករដែលមានកម្លាំងខ្លាំងបំផុតក្នុងចំណោមចលករទាំងឡាយរបស់ឆន្ទៈ។ ដូចនេះ ម្នាក់ៗត្រូវបណ្តុះនៅក្នុងខ្លួននូវសញ្ចេតនាថ្លៃថ្នូរ ដើម្បីឱ្យយើងបានជាម្ចាស់ខ្លួនយើងមែនទែន និងដើម្បីចៀសវាងគុណវិបត្តិផ្សេងៗដូចជា កង្វះឆន្ទៈ សំទុះជំរុញ និងចំណង់ខ្លាំង ព្រោះគុណវិបត្តិទាំងនេះតែងជាឧបសគ្គដល់កំណើតនៃឆន្ទៈ។

### ៣.៥.៤ កត្តាឧត្តមគតិសង្គម ( idéal social )

អំពើប្រកបដោយឆន្ទៈត្រូវតែឆ្លើយឱ្យស្របទៅនឹងបទបញ្ញាសង្គមព្រោះបើឆន្ទៈយើងមិនស្របនឹងឧត្តមគតិសង្គមទេ នោះឆន្ទៈយើងនឹងត្រូវសង្គមកែតម្រូវពុំខាន ឬនឹងត្រូវកម្លាំងសង្គមរារាំងមិនឱ្យប្រព្រឹត្តទៅបានក៏មាន។ ដូចនេះ ដើម្បីឱ្យឆន្ទៈយើងបានទៅជាឆន្ទៈមែនទែន គួរយើងបណ្តុះឱ្យជាប់នៅក្នុងខ្លួនយើងនូវឧត្តមគតិសង្គម ឬឧត្តមគតិមនុស្សជាតិដែលសង្គមមនុស្សតែងតែខិតខំបណ្តុះបណ្តាលដើម្បីជាប្រយោជន៍ដល់សង្គម៕

# មេរៀនទី៤ ល្បិចទូទៅនៃគំនិត

## ៤.១ ពុទ្ធិ

ពុទ្ធិ សំដៅយកចំណេះដឹងទូទៅរបស់មនុស្ស ទោះក្នុងខ្លួនយើងក្តី ខ្លួនអ្នកដទៃក្តី ឬនៅលើធម្មជាតិក្រៅខ្លួនយើងក្តី។ ប៉ុន្តែពុទ្ធិពុំមែនត្រឹមតែជាចំណេះដឹងស្រពេចស្រពិលឬមានប្រព័ន្ធច្បាស់លាស់ដែលមនុស្សបង្កើតប៉ុណ្ណោះទេ តែពុទ្ធិជារបៀបដែលញ៉ាំងឱ្យចំណេះទាំងនោះកើតឡើងថែមទៀតផង។

គេចែកពុទ្ធិជាបីសណ្ឋានតាម៖

- **ពួកនៃពុទ្ធិ៖** ពុទ្ធិសាមញ្ញ ពុទ្ធិស្សង់ ពុទ្ធិទស្សនវិជ្ជា
- **ល្បិចនៃពុទ្ធិ៖** វិភាគ ឬសំយោគ
- **ទម្រង់នៃពុទ្ធិ៖** អព្ភន្តរញាណ ឬវិចារ

## ៤.២ ពួកនៃពុទ្ធិ

### ៤.២.១ ពុទ្ធិសាមញ្ញ

ជាពុទ្ធិធម្មតាដែលអ្នកផងមានគ្រប់ៗគ្នា។ ពុទ្ធិដែលកើតពីការដែលពួតៗគ្នាស្រពេចស្រពិលមិនច្បាស់លាស់ ឬដែលកើតពីគំហើញវត្ថុនានាដោយផ្ទាល់ ឬកិច្ចសន្ទនាជាមួយអ្នកដទៃ ពីព័ត៌មានកាសែត កុន ល្ខោន វិទ្យុ។ល។ ចំណេះដឹងដោយការផ្សាយទាំងនេះ យើងធាប់ជឿ ធាប់ទទួលយកណាស់ ព្រោះវាឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការរស់នៅរបស់យើង។ ជួនកាលយើងជឿដោយមិនបាច់គិតផងក៏សឹងមាន ហើយពុទ្ធិដែលចេញពីជំនឿនេះតែងតែមានខុស ឬច្រឡំឬក៏ល្អៀងញយៗណាស់។

ពុទ្ធិសាមញ្ញមានលក្ខណៈដូចតទៅនេះ៖ គ្មានលំដាប់ គ្មានទំនាក់ទំនងជិតស្និទ្ធ និងគ្មានការត្រួតពិនិត្យម៉ត់ចត់។ ពុទ្ធិសាមញ្ញច្រើនច្រឡំ «ភាគច្រើន» និង«ទូទៅ»។ ឧទាហរណ៍៖ ថ្មលិចក្នុងទឹក ផ្សែងហុយឡើងលើ ឈើ«ឆេះ»។ គេឥតបានគិតដល់ទេថា ថ្មខ្លះឥតលិចក្នុងទឹក ផ្សែងខ្លះឥតហុយឡើងលើ ឬក៏ឈើខ្លះ «មិនឆេះ» ថ្វីត្បិតតែមានភាគតិចក៏ដោយ។

ប៉ុន្តែ ថ្វីបើមានលក្ខណៈបែបនេះ មនុស្សយើងតែងតែត្រូវការពុទ្ធិសាមញ្ញជាចាំបាច់ក្នុងការរស់នៅ។ ដូចជាដើម្បីទិញបាយបរិភោគ អ្នកជាក់ស៊ីក្លូ ត្រូវតែដឹងជាចាំបាច់នូវកន្លែងលក់បាយនិងម្ហូបអាហារ ព្រមទាំងពេលវេលាបើកលក់ ដោយមិនបាច់ពិចារណាវែកញែករកហេតុផលតាមរបៀបស្សង់ ឬតាមរបៀបទស្សនវិជ្ជាទេ ប្រសិនបើគេមិនចង់អត់បាយបរិភោគ។

### ៤.២.២ ពុទ្ធិស្សង់

ពុទ្ធិនេះមានលក្ខណៈដូចតទៅ៖

- ភាពជាក់លាក់ ឧទាហរណ៍៖ ខ្លួនខ្ញុំមានកំដៅ 40oC (អង្សារ)
- ភាពទូទៅ មិនរើសទីកន្លែង ឬពេល
- ឈរជានិច្ចលើវិចារណញ្ញាណ ហើយថែមទាំងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធក្នុងប្រព័ន្ធមួយៗទៀតផង។

ពុទ្ធិស្សង់កើតពីការត្រិះរិះពិចារណាយ៉ាងល្អិតល្អន់នៃបញ្ហា ហើយត្រួតពិនិត្យយ៉ាងម៉ត់ ចត់ដោយវិចារស្សង់ របៀបគណិតវិទ្យា ឬដោយពិសោធន៍បញ្ជាក់សម្មតិកម្មនៃស្សង់ពិសោធផង។ ពុទ្ធិបែបនេះល្បងគាស់កកាយយកទំនាក់ទំនងអរូបី ដែលកប់នៅក្នុងបាតុភូតមកជំនួសស្រមោលតថភាពដែលគ្រាន់តែបន្លំឬបញ្ឆោតឥន្ទ្រិយរបស់យើងប៉ុណ្ណោះ។ ជំនួសការប្រើពាក្យសាំញ៉ាំមិនច្បាស់លាស់ ស្សង់ត្រូវការជាចាំបាច់នូវភាពជាក់លាក់ដោយប្រើចំនួនទោះក្នុងរង្វាស់ក្តីក្នុងទំនាក់ទំនងស្ថិតិក្តី ឬក្នុងច្បាប់ពិជគណិតក្តី។

### ៤.២.៣ ពុទ្ធិទស្សនវិជ្ជា

ពុទ្ធិទស្សនវិជ្ជាមានភាពទូទៅជ្រៅល្អិតល្អន់ជាងពុទ្ធិសាមញ្ញឬស្យង់ព្រោះពុទ្ធិនេះកើតពីការត្រិះរិះពិចារណាលើគ្រប់បញ្ហា លើបញ្ហាធម្មតាក៏ដូចជាលើបញ្ហាស្យង់ដែរ។ ដោយពិតទៅ ទស្សនវិជ្ជាគឺជាការពិចារណារិះគន់លើជីវិត លើភារៈទាំងឡាយនិងលើពិភពលោក។ ក្នុងន័យនេះ ប្រ៊ុនវិច ពោលបញ្ជាក់ថា "នៅបច្ចុប្បន្ននេះទស្សនវិជ្ជាឈប់ល្បងបង្កើនបរិមាណចំណេះទៀតហើយ ប៉ុន្តែ វាជាការត្រិះរិះពិចារណាលើគុណភាពនៃចំណេះទាំងនោះ"។ អស្តិរូបវិជ្ជាខិតខំរាវរកមូលធម៌នៃបញ្ញត្តិនានាដែលមានភាពទូទៅបំផុត។ រីឯអគ្គវិជ្ជា(axiologie)ខិតខំរកនិយាមនៃតម្លៃទាំងពួងដូចជាសច្ចៈ កុសល សោភ័ណជាដើម។

## ៤.៣ ល្បិចនៃពុទ្ធិ

### ៤.៣.១ វិភាគ

(1). និយមន័យ៖ វិភាគគឺការបំបែកអង្គធាតុមួយឱ្យទៅជាធាតុផ្សំផ្សេងៗ ឬការបំបែកអ្វីមួយដែលសាំញ៉ាំឱ្យទៅជាងាយស្រួល។

(2). ទម្រង់ផ្សេងៗនៃវិភាគ៖ វិភាគចែកចេញជាពីរយ៉ាងគឺវិភាគពិត និងវិភាគក្នុងគំនិត។

វិភាគពិតគឺវិភាគដែលធ្វើលើវត្ថុដែលមានអត្ថិភាពផ្នែករូបធាតុពិតប្រាកដមែន។ វិភាគម៉ាស៊ីនមួយគឺដោះម៉ាស៊ីននោះទុកខ្ចៅនិងគ្រឿងផ្សេងៗដោយឡែកពីគ្នា។ ពេលដាំទឹកពុះគេសង្កេតមានចំហាយទឹកហុយឡើងលើ។ តាមពិសោធន៍ស្យង់ ចំហាយនេះគឺជា $O_2$ និង $H_2$ ដែលភាយឡើង។ ក្នុងករណីជំងឺសរសៃប្រសាទវេជ្ជបណ្ឌិតអាចវះកាត់យកសរសៃប្រសាទណាមួយ ដើម្បីព្យាបាលជំងឺប្រភេទនេះ។ វិភាគទាំងបីខាងលើនេះ ជាវិភាគពិត។

វិភាគក្នុងគំនិត គឺធ្វើតែក្នុងគំនិតសុទ្ធសាធ ឯវត្ថុវិភាគឥតមានអត្ថិភាពផ្នែករូបធាតុទេ។ ឧទាហរណ៍៖ វិភាគគុណនិងទោសនៃការងារផ្សេងៗដែលយើងជ្រើសរើសយកទៅអនាគត។

### ៤.៣.២ សំយោគ

(1). និយមន័យ៖ ផ្ទុយពីវិភាគ សំយោគគឺជាការរៀបចំវត្ថុមួយដោយយកធាតុផ្សេងៗ មកផ្សំបង្កបង្កើតឱ្យចេញជាវត្ថុនោះឡើង។

(2). ទម្រង់ផ្សេងៗនៃសំយោគ៖ ក្នុងសំយោគពិត វត្ថុសំយោគមានអត្ថិភាពពិតប្រាកដក្នុងធម្មជាតិ។ ឧទាហរណ៍៖ ការតម្លើងម៉ូទ័រមួយ ឬសំយោគទឹកក្នុងអីដ្យូម៉ែត $(1/2)_2 + H_2 \rightarrow H_2O$។ ម្យ៉ាងទៀតការសូត្រមេរៀនដោយទន្ទេញចាំស្ទាត់ ក៏អាចចាត់ជាសំយោគពិតបានដែរ។

ក្នុងសំយោគក្នុងគំនិតវត្ថុសំយោគគ្មានអត្ថិភាពផ្នែករូបធាតុទេ។ សំយោគក្នុងគំនិតមានបីយ៉ាង គឺសំយោគបញ្ញត្តិ សំយោគគណិតវិទ្យា និងសំយោគ បដិសំយោគ។ សំយោគបញ្ញត្តិផ្តុំគោល គំនិតធំៗដូចដែលគេបានធ្វើនៅក្នុងសុន្ទរកថា។ សំយោគនៃប្រវត្តិវិទ្យា ទស្សនវិជ្ជា ឬមនុស្សវិទ្យា មិនមែនត្រឹមតែជាសេចក្តីដែលគេតែងងាយស្រួលនោះទេ ប៉ុន្តែជាកិច្ចការមួយដ៏ពិបាកខាងមូលវិចារ ការជ្រើសរើសនិងការឱ្យតម្លៃលើគោលគំនិតធំៗដែលគួរយកមកដាក់បញ្ចូលឱ្យបានសមរម្យ។

សំយោគគណិតវិទ្យាចាប់ផ្តើមពីអ្វីដែលងាយទៅអ្វីដែលសាំញ៉ាំ។ រីឯសំយោគ បដិសំយោគកើតពីបដិក្ខភាពរវាងមតិនិងបដិមតិ។ មតិយល់ស្របតាម ឯបដិមតិប្រឆាំងមិនស្របតាម។ រីឯសំយោគភ្ជាប់មតិនិងបដិមតិ ដើម្បីបង្កើតច្រកថ្មីមួយនោះ អេគែល (Hegel) ឱ្យឈ្មោះថា "dépassement" ឬសំយោគនេះឯង។

### ៤.៣.៣ ទំនាក់ទំនងរវាងវិភាគ និងសំយោគ

ក្នុងទម្រង់នៃពុទ្ធិទាំងអស់(អព្ភន្តរញ្ញាណ វិចារក្តី)សំយោគនិងវិភាគតែងតែត្រូវការគ្នាទៅវិញទៅមកជានិច្ច។ ឧទាហរណ៍៖ ក្នុងគំហើញទេសភាពអ្វីមួយ ធាតុនីមួយនៃទេសភាពនោះហាក់នៅជាប់ៗគ្នា(ពណ៌ កម្ពស់ ទំហំ...) ប៉ុន្តែតាមពិត ធាតុទាំងអស់នោះឋិតក្នុងដុំទេសភាពទាំងមូលបង្កើតបានជាន័យប្លែកៗដល់ធាតុនីមួយៗតាមទ្រឹស្តី កេស្តាល់។

រ៉ើណង់ (Renan) និយាយថា គ្រប់ពុទ្ធិទាំងអស់របស់មនុស្សជា «វិភាគកណ្តាលសំយោគពីរ» ព្រោះថានៅចំពោះមុខតថៈយើងចាប់ផ្តើមឃើញអ្វីមួយទាំងដុលមិនសូវច្បាស់លាស់ តមកយើងធ្វើវិភាគត្រិះរិះលើជាតុនីមួយៗ ហើយជាបញ្ចប់ ទើបឃើញបានសំយោគពិត ប្រាកដនិងច្បាស់លាស់។ នេះគឺ «ចង្វាក់បី»នៃពុទ្ធិទូទៅ។

នៅក្នុងទស្សនៈបដិសំយោគនៃពិភពតថៈរបស់អេគែល ឬកាល់ម៉ាក្សវិភាគ និងសំយោគតែងតែនៅជាមួយគ្នាជានិច្ច។ គេមិនអាចនិយាយថាឯក ក្លាយទៅជា ពហុ (តាមវិភាគ) ឬក៏ថា ពហុក្លាយមកជាឯក (តាមសំយោគ) បានទេ ក៏ប៉ុន្តែគេត្រូវនិយាយថា ឯកគឺជាពហុ រីឯពហុគឺជាឯក ក្នុងពិភពមួយដែលរស់រវើក។ ក្នុងន័យនេះ វិភាគនិងសំយោគមានន័យច្រឡំគ្នាតែម្តង។

### ៤.៣.៤ តម្លៃវិភាគ និងសំយោគ

គេតែងនិយាយថា តម្លៃវិភាគមិនឋិតលើការស្រាវជ្រាវ រីឯសំយោគមានមុខងាររបាយការណ៍ ឬក៏ថា សំយោគសម្រាប់ប្រើជាវិធី បង្រៀនសិស្សក៏ថាបាន។ ក៏ប៉ុន្តែ បើគិតឲ្យសព្វគ្រប់ទៅចែកមុខងារដាច់ដោយឡែកពីគ្នាបែបនេះជាការងាយពេកហើយ។ ជាញឹកញាប់ណាស់វិភាគនិងសំយោគមានមុខងារដូចគ្នាគឺថាជួនកាលសំយោគអាចជាការស្រាវជ្រាវ រីឯវិភាគជួនកាលក៏អាចចាត់ជារបាយការណ៍ឬវិធីបង្រៀនដ៏ល្អបានដែរ។

## ៤.៤ ទម្រង់នៃពុទ្ធិ

### ៤.៤.១ អព្ភន្តរញ្ញាណ

អព្ភន្តរញ្ញាណ ជាពុទ្ធិដែលបានមកពីចំណាប់ផ្ទាល់និងភ្លាមៗដោយឥតប្រើវិចារ។ គេច្រើនប្រៀបធៀបអព្ភន្តរញ្ញាណទៅនឹងបន្សាយភ្លាមនៃប្រត្យក្សកម្មចក្ខុ។ អព្ភន្តរញ្ញាណមានលក្ខណៈដូចតទៅ៖

- ជាចំណេះដឹងផ្ទាល់និងភ្លាមៗហើយ «គ្មានបញ្ញត្តិ»
- ជាអវិចារណភាព (irrationlité)
- ជាប្រធានវិស័យភាព ដែលទាក់ទងផ្ទាល់ទៅនឹងប្រធានម្នាក់ៗហើយផ្លាស់ប្តូរតាមប្រធានដែលជាចេះឬដឹងផង។ វត្ថុមួយអាចក្រលេកមួយភ្លែតទៅឃើញល្អឬត្រូវពិតសម្រាប់អ្នកមួយ ឬក៏អាក្រក់ខុសស្រឡះសម្រាប់អ្នកមួយទៀតតាមចំណូលចិត្តម្នាក់ៗ។

ជាពុទ្ធិដែលមិនអាចពន្យល់បាន ។ វាលេចចេញតែម្តង ប៉ុន្តែគេមិនអាចពិពណ៌នាបានឡើយ។ លក្ខណៈនេះហើយដែលញ៉ាំងឱ្យទស្សនវិជ្ជាពិបាកយល់ ពិបាកសិក្សា ដោយហេតុថា ពុទ្ធិបែបទស្សនវិជ្ជានេះច្រើនចេញមកពីអព្ភន្តរញ្ញាណនេះឯង។

ជាពុទ្ធិដែលកើតមុនគេបំផុត ផ្ទុយពីវិចារដែលកើតពីការដាក់ជាទំនាក់ទំនងទំនាក់ទំនងរវាងបញ្ញត្តិផ្សេងៗក្នុងវិនិច្ឆ័យឬទំនាក់ទំនងរវាងវិនិច្ឆ័យផ្សេងៗក្នុងវិចារ។

សរុបសេចក្តីទៅ អព្ភន្តរញ្ញាណជាពុទ្ធិគ្មានតិចនិច គ្មានវិធី គ្មានកណ្តាល ជាពុទ្ធិដែលប្រកបទៅដោយអាថ៌កំបាំង។

### ៤.៤.២ ពួកផ្សេងៗនៃអព្ភន្តរញ្ញាណ

គេចែកអព្ភន្តរញ្ញាណជាបួនពួក៖

(1). អព្ភន្តរញ្ញាណចិត្តវិទ្យា (intuition psychologique)៖ ចិត្តយើងក្តី សភាពទាំងឡាយនៃញាណយើងក្តី ជាតថៈមួយ ដែលយើងអាចស្គាល់ដោយផ្ទាល់ ដោយមិនបាច់ធ្វើបំណកស្រាយ ឬបង្កើតអ្វីទេ។ ឥន្ទ្រិយារម្មណ៍ឈឺចាប់មួយ សញ្ចេតនាព្រួយមួយ ដែលកើតឡើងក្នុងញាណរបស់ខ្ញុំ ត្រូវបានចិត្តខ្ញុំដឹងឮផ្ទាល់ភ្លាមៗ។ ហេតុនេះ គេអាចនិយាយថា អព្ភន្តរញ្ញាណចិត្តវិទ្យា ជាអព្ភន្តរញ្ញាណមួយពិតៗ។ នៅក្នុង អព្ភន្តរញ្ញាណនេះមាន «គំហើញផ្ទាល់របស់ចិត្តដោយចិត្ត» គំហើញដែលខុសតិចតួចណាស់ពីវត្ថុដែលឃើញ ហើយជាពុទ្ធិដែលកើតដោយការប៉ះផ្ទាល់ ឬដោយត្រួតស៊ីគ្នា។ ប៉ុន្តែយើងត្រូវតែចែកអ្វីដែលយើងស្គាល់ដោយអព្ភន្តរញ្ញាណចិត្តវិទ្យា ឱ្យដាច់ពីអ្វីដែលចិត្តយើងបន្ថែមពន្លើស ព្រោះស្ទើរតែគ្រប់ពេលទាំងអស់ យើងតែងតែបកស្រាយបំផ្លើសការឈឺចាប់ឬការព្រួយរបស់យើង។

អព្តន្តរញាណចិត្តវិទ្យានេះសម្រាប់ឱ្យយើងទទួលនូវឥន្ទ្រិយារម្មណ៍មួយនូវសញ្ចេតនាមួយដែលផុសឡើងក្នុងចិត្តរបស់យើង តែមិនមែនសម្រាប់ឱ្យយើងស្គាល់ ចេះដឹងពីឥន្ទ្រិយារម្មណ៍នោះ ឬសញ្ចេតនានោះទេ ដោយហេតុថាការស្គាល់ ចេះដឹងពីអ្វីមួយត្រូវការជាចាំបាច់នូវលក្ខខណ្ឌពីរ។ លក្ខខណ្ឌទីមួយទាក់ទងទៅនឹងប្រធាន ឯលក្ខខណ្ឌទីពីរទាក់ទងទៅនឹងវត្ថុ។ ប្រធានដែលមានការស្គាល់ ចេះដឹងត្រូវដាច់ពីវត្ថុដែលខ្លួនស្គាល់ចេះដឹងនោះ។

ចំណែកឯវត្ថុវិញត្រូវមានលក្ខណៈនឹងនរហើយជាក់ច្បាស់។ អព្តន្តរញាណចិត្តវិទ្យាពុំបានបំពេញលក្ខខណ្ឌទាំងពីរខាងលើនេះទេ។ ហេតុនេះគេអាចសន្និដ្ឋានបានថា អព្តន្តរញាណប្រភេទនេះពុំមែនជាពុទ្ធិទេ។

(2). អព្តន្តរញាណឥន្ទ្រិយ(intuition sensible)៖ បញ្ហាចោទឡើងថា តើឥន្ទ្រិយទាំងអស់របស់យើងអាចផ្តល់ឱ្យយើងនូវអព្តន្តរញាណដើម្បីចាប់យកតថភាពទាំងឡាយដែលនៅក្រៅខ្លួនយើងបានឬទេ? តាមយោបល់សាមញ្ញ ឥន្ទ្រិយទាំងឡាយជាអព្តន្តរញាណ ដែលធ្វើឱ្យយើងស្គាល់នូវវត្ថុទាំងឡាយណាដែលឋិតនៅក្រៅញាណ។ តែបើយើងពិចារណាបន្តិចទៅ យើងនឹងឃើញថា អព្តន្តរញាណឥន្ទ្រិយគឺជាអព្តន្តរញាណចិត្តវិទ្យា។ លក្ខណៈដែលខ្ញុំឱ្យទៅវត្ថុខាងក្រៅមួយសុទ្ធតែជាឥន្ទ្រិយារម្មណ៍ដែលខ្ញុំបានទទួល។ ឥន្ទ្រិយារម្មណ៍ទាំងអស់ សុទ្ធតែជាបំណកស្រាយនៃញាណរបស់ខ្ញុំ។ ហេតុនេះ គេអាចនិយាយបានថា ការស្គាល់វត្ថុទាំងឡាយ ដែលនៅក្រៅខ្លួនខ្ញុំសុទ្ធតែជាពុទ្ធិប្រយោលគឺថាខ្ញុំស្គាល់វត្ថុទាំងនោះដោយសារការរំភើបដែលវត្ថុទាំងនោះមានមកលើញាណរបស់ខ្ញុំ ហើយទៅលើការរំភើបនេះ ចិត្តខ្ញុំបន្ថែមនូវលក្ខណៈឯទៀតនៃវត្ថុនោះដែលខ្ញុំបានស្គាល់ដោយពិសោធន៍មុនៗរបស់ខ្ញុំ។ ឧទាហរណ៍ ដូចជាខ្ញុំអាចដឹងថាផ្លែឈើមួយទុំ ដោយសារខ្ញុំធ្វើបំណកស្រាយហេតុទាំងអស់ដែលខ្ញុំឃើញ បើពេលឱ្យខ្លី គឺខ្ញុំធ្វើវិនិច្ឆ័យ។ ខ្ញុំថា ផ្លែឈើនេះទុំដោយសារមានសម្បុរក្រហមជាដើម។ ដូចនេះ នៅក្នុងឥន្ទ្រិយារម្មណ៍សុទ្ធតែមានវិនិច្ឆ័យចូលទៅលាយឡំជាមួយដែរ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏អព្តន្តរញាណឥន្ទ្រិយជាសសរទ្រទ្រង់ពុទ្ធិរបស់យើងទាំងអស់ទៅលើពិភពខាងក្រៅ។ នៅក្នុងស្បង់ពិសោធអព្តន្តរញាណឥន្ទ្រិយជាឫសគល់នៃពិសោធន៍។ អារីស្តូត បានពោលថា"ឥន្ទ្រិយារម្មណ៍ក៏មិនអាចមានពុទ្ធិបានដែរ"។

(3). អព្តន្តរញាណបញ្ញា៖ អព្តន្តរញាណនេះមានលក្ខណៈខុសស្រឡះពីអព្តន្តរញាណខាងលើ។

អព្តន្តរញាណនេះអាចឱ្យយើងចាប់បាននិងយល់បាននូវទំនាក់ទំនង។ គេចែកអព្តន្តរញាណបញ្ញាជាពីរបែប៖

អព្តន្តរញាណខាងការបង្កើតថ្មី៖ អព្តន្តរញាណនេះមានភាពដូចជាពន្លឺមួយភ្លែតដែលចាំងចូលទៅក្នុងញាណរបស់អ្នកប្រាជ្ញ ធ្វើឱ្យគេដឹងខ្លួនថាបានរកឃើញចម្លើយនៃចំណោទដែលគេកំពុងគិត។ អព្តន្តរញាណនេះបានទទួលភ្លាមនូវពុទ្ធិជាក់ច្បាស់មួយ គឺជាការដឹងមុននូវទំនាក់ទំនង។ ប៉ុន្តែ អព្តន្តរញាណខាងការបង្កើតថ្មីតែងតែឱ្យគេច្រឡំជាញឹកញាប់ទោះបីគេមានសញ្ចេតនាភ្លឺស្វាងយ៉ាងណាក៏ដោយ។

អព្តន្តរញាណខាងបច្ចក្ខភាព៖ អព្តន្តរញាណនេះអាចឱ្យយើងចាប់បាននូវពន្លឺយ៉ាងច្បាស់នៃគំនិតមួយ អាចឱ្យយើងចាប់បាននូវសច្ចភាពមួយឬក៏ភាពចាំបាច់នៃអាក់ស្យូមគណិតវិទ្យាមួយ។ គឺជាអព្តន្តរញាណដែលឱ្យយើងចាប់បាននូវទំនាក់ទំនងសមហេតុផលនៃតំណាផ្សេងៗរបស់វិចារណាមួយ។ អព្តន្តរញាណបែបនេះ ដេកាតឱ្យឈ្មោះថា អព្តន្តរញាណសង្ខេប។

(4). អព្តន្តរញាណអស្តិរូបវិជ្ជា៖ អ្នកទស្សនវិជ្ជាខ្លះអះអាងថា មានអព្តន្តរញាណមួយបែបទៀតគឺអព្តន្តរញាណអស្តិរូបវិជ្ជាដែលអាចឱ្យយើងចាប់បាននូវតថភាពមួយដែលជា៖

- អត្ថិភាព(existence)ចំពោះដេកាត (cogito ergo sum)។

- សារជាតិ(essence)ចំពោះហ៊ុសស៊ែល (អព្តន្តរញាណខាងសារជាតិ) ឬអព្តន្តរញាណខាងតម្លៃ ចំពោះម៉ាក្ស សែលែ(Max Scheler)។

- តថភាពមួយ ដែលជាអត្ថិភាពផង ចំពោះប៉ៃសុន។

### ៤.៤.៣ មុខងារ និងតម្លៃនៃអព្ភន្តរញ្ញាណ

អព្ភន្តរញ្ញាណជាសតិមួយក្នុងចំណោមសតិទាំងឡាយនៃបញ្ញា។ វាមានមុខងារច្រើនណាស់។ អព្ភន្តរញ្ញាណអាចឱ្យយើងចាប់បាននូវពុទ្ធិប្រភេទខ្លះដែលវិចារមិនអាចធ្វើបាន។ វាជាអ្នកផ្តល់គោលការណ៍ដំបូងឱ្យវិចារ ព្រោះពុទ្ធិដំបូងដែលវិចារត្រូវការសុទ្ធតែជាពុទ្ធិដែលបានមកពីអព្ភន្តរញ្ញាណទាំងអស់។ ម្យ៉ាងទៀតនៅក្នុងពុទ្ធិទាំងអស់ អព្ភន្តរញ្ញាណតែងតែនៅមុខវិចារជានិច្ច ហើយថែមទាំងបង្រួមឡើងវិញនូវវិចារមួយទៀតផង។

មានអ្នកទស្សនវិជ្ជាច្រើនណាស់ដែលឱ្យតម្លៃទៅអព្ភន្តរញ្ញាណខ្លាំងជាងវិចារ។ គេថាវាជាវិធីផ្ទាល់ប្រសើរ និងសុក្រឹតជាងវិចារដែលជាវិធីប្រយោល។ គេថាវាជាមធ្យោបាយតែមួយគត់ ដើម្បីចាប់ «តថៈ» បាន។ ជាពិសេស គេថាវាមិនអាចឱ្យច្រឡំបានទៀតផង។

### ៤.៤.៤ ពិភាក្សាការរិះគន់

អព្ភន្តរញ្ញាណគ្រាន់តែជារូបរាងមួយនៃពុទ្ធិប៉ុណ្ណោះ។ វាអាចមានគុណសម្បត្តិ និងគុណវិបត្តិដូចវិចារដែរ។

(1). គុណសម្បត្តិ៖ ជាការពិតហើយ ដោយហេតុថា វាគ្មានអ្នកកណ្តាល។អព្ភន្តរញាណតែងតែប្រព្រឹត្តទៅបានលឿនជាងវិចារដែលជាពុទ្ធិប្រយោល។ គឺជាល្បិចមួយនៃគំនិតដែលពុំផ្តល់ការនឿយហត់ឱ្យអ្នកប្រព្រឹត្តឡើយ។ ភាពលឿនរហ័សនៃអព្ភន្តរញ្ញាណអាចឱ្យយើងចៀសផុតពីកំហុសបានច្រើនមានកំហុសដែលកើតឡើងដោយការអន់ថយនៃលំនឹកជាដើម។

(2). គុណវិបត្តិ៖ ក៏ប៉ុន្តែជួនកាលវាក៏មានការភ្លាំងភ្លាត់ដែរ។ សក្ខីកម្មរបស់អ្នកគិតធំៗជាច្រើនបញ្ជាក់ប្រាប់យើងយ៉ាងច្បាស់ពីអន្ទាក់នៃអព្ភន្តរញ្ញាណដែលតែងតែនាំឱ្យយើងភាន់ច្រឡំញយណាស់។ ញយជាងគេគឺអន្ទាក់នៃអព្ភន្តរញ្ញាណឥន្ទ្រិយនេះឯង(ឧទាហរណ៍៖ ប៉មជ្រុង ឃើញពីចម្ងាយថាជាមូល។ ដំបងដាក់បញ្ឆៀងក្នុងទឹក យើងឃើញថាវាបាក់....)។ រីឯអន្ទាក់នៃអព្ភន្តរញ្ញាណបញ្ញាក៏មានមិនតិចតួចដែរ។ ជាបញ្ចប់អព្ភន្តរញ្ញាណផ្តេសផ្តាសក៏មានក្រាស់ក្រែលដែរ ការត្រាស់ដឹងផ្តេសផ្តាស់ខ្លះ ការប្រមើល «ខុស»ខ្លះ។ល។ ហេតុនេះយើងមិនត្រូវទុកចិត្តលើអព្ភន្តរញ្ញាណទាំងស្រុងទេ ព្រោះវាមិនមែនគ្មានកំហុសជានិច្ចនោះឡើយ។

## ៤.៥ វិចារ

### ៤.៥.១ និយមន័យ

វិចារមានទម្រង់ផ្ទុយស្រឡះពីអព្ភន្តរញ្ញាណ។ វាជាតំណជាប់តៗគ្នាជាច់នៃគំនិតជាច្រើនដើម្បីឆ្ពោះទៅរកសន្និដ្ឋានមួយ។ នៅក្នុងតំណជាប់គ្នានេះគំនិតត្រូវគោរពច្បាប់ខ្លះ ដែលគេអាចឱ្យឈ្មោះថាជាច្បាប់ឯកតា ដូចជាច្បាប់ថា «គំនិតទីពីរមិនត្រូវប្រឆាំងនឹងគំនិតទីមួយដែលឋិតនៅក្នុងវិចារតែមួយ» ជាដើម។ ឧទាហរណ៍៖ ក្រដាសសម្រាប់សរសេរ តែគេមិនអាចសរសេរលើក្រដាសបានទេ។

វិចាររបៀបនេះមិនត្រឹមត្រូវទេព្រោះវិចារនេះមិនបាននាំទៅដល់សន្និដ្ឋានណាមួយឡើយ។

### ៤.៥.២ អំពើទាំងបីនៃគំនិត

(1). បញ្ញត្តិ(concept)៖ បញ្ញត្តិជាន័យរបស់ពាក្យមួយ ជាអ្វីដែលគេនឹកដល់កាលណាគេប្រើពាក្យមួយ។ បញ្ញត្តិសុទ្ធតែអរូបីទាំងអស់។ បញ្ញត្តិដែលទាក់ទងនឹងវត្ថុរូបីក៏អរូបីដែរព្រោះដើម្បីឱ្យកើតជាបញ្ញត្តិបាន គេរក្សាទុកពីវត្ថុនោះនូវអ្វីដែលមានតែលក្ខណៈទូទៅប៉ុណ្ណោះ។ ហេតុនេះហើយបានជាគេនិយាយថា គំនិតទាំងអស់ ទោះបីគំនិតនោះងាយស្រួលឬធម្មតាយ៉ាងណាក៏ដោយ ក៏សុទ្ធតែជាគំនិតអរូបីទាំងអស់។

ឧទាហរណ៍៖ បញ្ញត្តិ «តុ» ឬ «មនុស្ស» មិនសំដៅតុណាមួយ ឬមនុស្សណាម្នាក់ទេ ប៉ុន្តែសំដៅតុទូទៅ មនុស្សទូទៅ។

(2). វិនិច្ឆ័យ៖ វិនិច្ឆ័យជាអំពើមួយរបស់គំនិតដែលឱ្យលក្ខណៈទៅបញ្ញត្តិមួយ ឬក៏ជាចំណងដែលចងបញ្ញត្តិពីរឬបញ្ញត្តិច្រើនឱ្យជាប់គ្នា។ ឧទា៖ តុរាងមូល, ផ្កាពណ៌ក្រហម, តុខ្ពស់ជាងកៅអី, ក្មេងប្រុសខ្លាំងជាងក្មេងស្រី។

(3). វិចារ (raisonnement)៖ វិចារជាការប្រមូលផ្តុំនូវវិនិច្ឆ័យពីរឬច្រើន។ ឧទាហរណ៍ ចាស់ជាងគេរបស់វិចារ គឺតក្ករូប(syllogisme) ដែលជាការផ្តុំនូវវិច្ឆ័យបី។ ឧទាហរណ៍៖ ជនណាមិនសូវមានប្រាក់ជននោះមិនសូវមានបាយបរិភោគ អ្ហ! សុខមិនសូវមានប្រាក់ ដូចនេះ សុខក៏មិនសូវមានបាយបរិភោគដែរ។

### ៤.៥.៣ បែបផ្សេងៗនៃវិចារ

(1). វិចារតូចតាច៖ ក្នុងការសិក្សាពីបញ្ញាសត្វ យើងបានឃើញរួចមកហើយ(សូមអានមេរៀន«បញ្ញា») ថាក្នុងការរកចម្លើយក្នុងដំណោះស្រាយបញ្ហាខ្លះ (បញ្ហាពង្វាង បញ្ហាចំណាប់ បញ្ហាប្រើប្រាស់ឧទាហរណ៍របស់ពួកស្វាឌី) គេមិនអាចបដិសេធវត្តមាននៃបញ្ញាសត្វនោះឡើយ ថ្វីបើវាមានតិចតួចក៏ ដោយ។ គ្រាន់បើជាងបញ្ញាសត្វបន្តិចបញ្ញាក្មេងអាចធ្វើវិចារខ្លះៗ ដោយការប្រៀបធៀបវត្ថុរូបីនានាក្នុងពិសោធន៍របស់វា។ ឧទាហរណ៍៖ កុមារសៅនិយាយថា "ដើមឈើងាប់ព្រោះវាដើរមិនកើត"...។ គឺជាវិចារមួយដែរ ប៉ុន្តែវិចារនេះមានលក្ខណៈដូចតទៅ៖ គ្មានទំនាក់ទំនងជិតស្និទ្ធ មានទំនាស់។ វិចារនេះធ្វើពីពិសេសទៅពិសេស មិនដូចវិចារអនុមានញែកដែលចេញពីទូទៅទៅពិសេស ឬវិចារអនុមានរួម ដែលឡើងពីពិសេសទៅទូទៅឡើយ។ ចំពោះវិចាររបស់ក្មេងនេះ ស្ទែន(Stern)អ្នកចិត្តវិទ្យាអាមេរិកឱ្យឈ្មោះថា raisonnemts traductif ។

(2). វិចារតាមដំណូច៖ គឺជាវិចារដែលសន្និដ្ឋានកើតពីគំហើញដំណូចខ្លះដែលគេសម្គាល់ឃើញ ទៅដំណូចខ្លះទៀតដែលគេសម្គាល់មិនបាន។ ឧទាហរណ៍៖ ផែនដីអាចឱ្យសត្វរស់នៅបានព្រោះវាមានបរិយាកាស អ្ហ! ភពអង្គារ ក៏មានបរិយាកាសដែរដូចនេះភពអង្គារក៏អាចឱ្យសត្វរស់នៅបានដែរ។ គួរកត់សម្គាល់ថា វិចារតាមដំណូចខ្វះតម្លៃសមហេតុផល។ ប៉ុន្តែវាមានតម្លៃមហិមាក្នុងឋានៈជាប្រភពសម្មតិកម្មក្នុងការពិនិត្យបញ្ជាក់សច្ចភាពអ្វីមួយ។ លក្ខណៈនេះបានញាំងឱ្យវិចារតាមដំណូចជាវិចារ«សាយ»។ ជាពិសេសវាមានតម្លៃខាងការរុករកឥតគណនាសម្រាប់ស្បង់ពិសោធ។

(3). អនុមានញែក

និយមន័យ ៖ គឺវិចារដែលត្រឹមត្រូវជាងគេ ហើយដែលអ្នកតក្កវិជ្ជាបានសិក្សាយូរយារណាស់មកហើយ។ គេអាចឱ្យនិយមន័យអនុមានញែកថា ជាវិចារដែលចេញពីគោលការណ៍ទៅវិបាក។

បែបផ្សេងៗនៃអនុមានញែក៖ គេចែកអនុមានញែកជាពីរបែប អនុមានញែកសាររួម និងអនុមានញែកគណិតវិទ្យា។

- អនុមានញែកសាររូប៖ គឺអនុមានញែកដែលឱ្យតម្លៃតែទៅលើទម្រង់ប៉ុណ្ណោះឥតគិតពីន័យខុសឬត្រូវទេ។ គេអាចហៅអនុមានញែកសាររូបនេះថាជាអនុមានញែកវិភាគក៏បានដែរ។ នៅក្នុងអនុមានញែកសាររូបនេះវិបាកបិតនៅក្នុងគោលការណ៍តែម្តង។ អនុមានញែកដែលសំខាន់ជាងគេហើយដែលមានចំណាស់ជាងគេគឺតក្ករូប។ គឺជាវិចារដែលមានសំណើ(propositions)បីគឺមូលបដិញ្ញាពីរ(deux prémisses)និងនិដ្ឋានបដិញ្ញា(conclusion)។

ឧទាហរណ៍៖

| | | |
|---|---|---|
| មនុស្សទាំងឡាយសុទ្ធតែត្រូវស្លាប់ | => មូលបដិញ្ញាធំ (majeure) | Pré- |
| សូក្រាតជាមនុស្សម្នាក់ | => មូលបដិញ្ញាតូច (mineure) | mis- |
| ដូចនេះ សូក្រាតត្រូវស្លាប់ដែរ | => និដ្ឋានបដិបញ្ញា (conclusion) | ses |

អារីស្តូតដែលបានបង្កើតតក្ករូបនេះឡើង។ គាត់បានបង្ហាញគោលការណ៍ទាំងឡាយដែលវិចារត្រូវគោរពដើម្បីឱ្យមានលក្ខណៈត្រឹមត្រូវ។ តក្ករូបត្រូវបំពេញលក្ខខណ្ឌពីរ៖

- មូលបដិញ្ញានីមួយៗមិនត្រូវមានន័យ (contenu) ខុសទេ (លក្ខខណ្ឌន័យ)

- តក្ករូបត្រូវប្រព្រឹត្តទៅតាមនិយាមទាំងឡាយនៃតក្កវិជ្ជាសាររូប(logique formelle)។

- អនុមានញែកគណិតវិទ្យា៖ គេអាចហៅអនុមានញែកសំយោគក៏បាន។ ផ្ទុយពីអនុមានញែកវិភាគ អនុមានញែកសំយោគជាអនុមានញែកសំណង់ ព្រោះវិបាកជាសំណើមួយថ្មីដែលកើតឡើងពីគោលការណ៍។ ដូចជានៅក្នុងទ្រឹស្តីបទនៃធរណីមាត្រ សន្និដ្ឋានមិនមែននៅក្នុងសម្មតិកម្មទេ ក៏ប៉ុន្តែវាត្រូវសម្រាយបញ្ជាក់សង់ឡើងជាមួយនឹងសម្មតិកម្ម។

អនុមានញែកគណិតវិទ្យា ខុសពីអនុមានញែកសាររូបដោយសារមានភាពរីកចម្រើន ភាព «សាយ» ។ រីឯសន្និដ្ឋាន ជាសំណើថ្មីខុសប្លែកពីមូលបដិញ្ញាស្រឡះ(ផ្ទុយពីអនុមានញែកសាររូបដែលមិនរីកចម្រើន ហើយដែលសន្និដ្ឋានគ្រាន់តែថាឡើងវិញតាមមូលបដិញ្ញាដើមប៉ុណ្ណោះ)។

ភាពរីកចម្រើននៃអនុមានញែកគណិតវិទ្យា មានទំនាក់ទំនងទៅនឹងធម្មជាតិរបស់គណិតវិទ្យាដែលជាស្បង់កើតចេញពីគំនិតមនុស្សសុទ្ធសាធ។ គេអាចពោលបានថា គណិត វិទ្យាជាសំណង់នៃគំនិត។

មុខងារ និងតម្លៃនៃអនុមានញែក៖ អនុមានញែកជាវិចារមួយដែលគេនិយមប្រើច្រើនជាងគេនៅក្នុងគណិតវិទ្យា ព្រោះវាជាវិចារគំរូដែលមានភាពត្រូវល្អិតល្អន់ជាងគេ។ ដោយហេតុថា គណិតវិទ្យាជាស្បង់ដែលត្រូវការភាពល្អិតល្អន់នេះ អនុមានញែកតែងតែនៅជាប់នឹងគណិតវិទ្យាជានិច្ច។

នៅក្នុងស្បង់ពិសោធ គេនិយមប្រើវាខ្លះដែរ ហើយវាមានមុខងារខាងទាយ លទ្ធផលច្បាប់មួយឬច្បាប់មួយពួកនៅក្នុងកាលៈទេសៈមួយ។ ហើយក្នុងអនុវត្តន៍ច្បាប់មួយក្នុងស្បង់ពិសោធ គេត្រូវការជាចាំបាច់នូវអនុមានញែក។ ឧទាហរណ៍៖ កាលណាគេស្គាល់ច្បាប់ទំនាក់ទំនងមេកានិចនៃតារា អនុមានញែកអាចឱ្យគេទាយពេលណាមានចន្ទ្រគ្រាស ឬសូរ្យគ្រាសបាន។

ប៉ុន្តែគួរកត់សម្គាល់ថា ដើម្បីឱ្យបានសន្និដ្ឋានត្រឹមត្រូវ អនុមានញែកត្រូវចេញពីគោលការណ៍ដែលត្រឹមត្រូវជាចាំបាច់ដែរ។

(4). អនុមានរួម

និយមន័យ ៖ អនុមានរួមជាវិចារមួយដែលចេញដំណើរពីសំណើពិសេសៗទៅសំណើទូទៅមួយឬច្រើន។ គេអាចនិយាយម្យ៉ាងទៀតបានថា អនុមានរួមចេញដំណើរពីការណ៍ពិសេសៗទៅច្បាប់ទូទៅមួយ។

បែបផ្សេងៗនៃអនុមានរួម៖ គេចែកអនុមានរួមជាពីរបែបដែរគឺ៖ អនុមានរួមសាររូប(induction formelle) និងអនុមានរួមពង្រីក(induction amplifiante)។

អនុមានរួមសាររូប ៖ បង្កើតឡើងដោយ អារីស្តូត អនុមានរួមសារមានមុខងារត្រង់អះអាងភាពទូទៅមួយ ពីការណ៍ពិសេសច្រើនដែលគេស្គាល់រួចអស់ហើយ។ ឧទាហរណ៍៖ ក្នុងថ្នាក់ទី១២ក ក្រោយពីបានសួរអាយុសិស្សម្នាក់ៗរួចហើយ ខ្ញុំដឹងថាម្នាក់ៗមានអាយុច្រើនជាង16ឆ្នាំ។ ដូចនេះខ្ញុំអាចសន្និដ្ឋានបានថា សិស្សទាំងអស់ក្នុងថ្នាក់នេះមានអាយុលើសពី 16 ឆ្នាំ។

គួរកត់សម្គាល់ថា សន្និដ្ឋានរបស់វាមានភាពត្រឹមត្រូវល្អិតល្អន់ណាស់។ ក៏ប៉ុន្តែឥតបានបង្កើតអ្វីប្លែកសោះទេ។ ដូចនេះ អនុមានរួមសាររូបគឺជាវិចារ«អា»(infécond)។

- អនុមានរួមពង្រីក៖ គឺជាវិចារពិសោធដែលគេនិយមប្រើក្នុងរូបវិទ្យា។ គឺជាវិចារមួយដែលអនុញ្ញាតឱ្យចេញពីការណ៍ខ្លះៗ ដែលគេស្គាល់ទៅច្បាប់ទូទៅដើម្បីពន្យល់ការណ៍ទាំងនេះ។

ឧទាហរណ៍៖ ខ្ញុំសង្កេតឃើញថា៖

- មនុស្សឈ្មោះសុខស្លាប់

- មនុស្សឈ្មោះសៅស្លាប់

- មនុស្សឈ្មោះដាក៏ស្លាប់ទៀត

ខ្ញុំអាចសន្និដ្ឋានថា៖ មនុស្សទាំងអស់សុទ្ធតែត្រូវស្លាប់។

គួរកត់សម្គាល់ថា អនុមានរួមពង្រីកគ្មានភាពត្រឹមត្រូវល្អិតល្អន់ទេ។ ជួនកាលសន្និដ្ឋានជាទង្វើទូទៅផ្ដេសផ្ដាស ។ ដូចនេះ នៅក្នុងស្យង់ពិសោធ អនុមានរួមពង្រីកមិនត្រូវធ្វើដោយខ្វះការត្រួតពិនិត្យតឹងរ៉ឹងនោះឡើយ។

មុខងារនិងតម្លៃនៃអនុមានរួម៖ អនុមានរួមជាវិចារសម្រាប់ស្យង់ពិសោធតែប៉ុណ្ណោះ។ គេមិនសូវនិយមយកវាទៅប្រើក្នុងគណិតវិទ្យាទេ។ ប៉ុន្តែនៅក្នុងការរស់នៅធម្មតាអនុមានរួមតែងធ្វើឡើងដោយស្វ័យប្រវត្តិដូចជាយើងមានទម្លាប់នឹងទាញច្បាប់ទូទៅ ចេញពីពិសោធន៍របស់យើងក្នុងជីវិតជាដើម។ អនុមានរួមសាររូប ត្រឹមត្រូវ សុក្រឹត មិនដែលប្រឡំ ប៉ុន្តែមិនបានការ។ រីឯអនុមានរួមពង្រីក មិនត្រឹមត្រូវល្អិតល្អន់ មិនសុក្រឹត អាចប្រឡំញឹកញាប់ ក៏ប៉ុន្តែមានប្រយោជន៍សំខាន់ណាស់ក្នុង ស្យង់ពិសោធ ប្រសិនបើគេចេះយកតិចនិចត្រឹមត្រូវមកត្រួតពិនិត្យ។

(5). ទំនាក់ទំនងរវាងអនុមានញែកនិងអនុមានរួម៖ គឺជាចលនាពីររបស់គំនិតដែលមានដំណើរផ្ទុយគ្នា ប៉ុន្តែដែលជួយបំពេញកង្វះខាតគ្នាទៅវិញទៅមក។ អនុមានរួមផ្ដល់ឫសគល់ឱ្យអនុមានញែក ព្រោះអនុមានរួមជាអ្នកស្វែងរកច្បាប់ទូទៅក្នុងស្យង់ពិសោធ និងរកគោលការណ៍ឱ្យគណិតវិទ្យា។ គឺច្បាប់ទូទៅ និងគោលការណ៍នេះហើយដែលជាទីដើមសម្រាប់អនុមានញែកចេញដំណើរ។ អនុមានញែកដែលមាន លក្ខណៈត្រឹមត្រូវល្អិតល្អន់ជាអ្នកដឹកនាំអនុមានរួម។ គេតែងតែត្រូវការអនុមានញែកជាចាំបាច់ពេលណាគេចង់យកច្បាប់ទូទៅមួយដែលគេរកឃើញទៅអនុវត្ត។

(6). តម្លៃ និងព្រំដែននៃវិចារ៖ ចំពោះអ្នកតក្កវិជ្ជាភាគច្រើនគេតែងតែយល់ថា បណ្ដាវិចារទាំងអស់មានតែអនុមានញែកមួយប៉ុណ្ណោះទេដែលអាចឱ្យគេចាត់បានថាជាវិចារពិតប្រាកដ។ អនុមានរួមក្ដី វិចារតាមដំណូចក្ដី មិនអាចចាត់បានថាជាវិចារពេញលក្ខណៈទេ។ ក៏ប៉ុន្តែ ចំពោះយើងយល់ឃើញថា វិចារមួយៗនេះទោះពេញ លក្ខណៈឬមិនពេញក្ដីក៏នៅតែមានតម្លៃរបស់វាប្លែកគ្នាដែរ។

អនុមានញែកមានតម្លៃត្រង់មានភាពត្រឹមត្រូវជាក់លាក់។ អនុមានញែកសំណាង់អាចបញ្ចេញសន្និដ្ឋានទូលំទូលាយនិងថ្មីៗទៀតផង។

អនុមានរួមពង្រីកមានតម្លៃខាងរាវរកឥតប្រៀបបានទេនៅក្នុងស្យង់ពិសោធ។

រីឯវិចារតាមសដំណូច ថ្វីបើមិនសូវមានតម្លៃសមហេតុផលដូចគេឯងក៏ដោយ ក៏វាមានតម្លៃខាងរាវរកដែរតាមរយៈការណែនាំក្នុងការបង្កើតសម្មតិកម្មផ្សេងៗក្នុងវិចារពិសោធ។

ប៉ុន្តែ ប្រសិនបើវិចារជាឧបករណ៍មួយយ៉ាងសំខាន់ក្នុងរបកគំហើញ និងសម្រាយបញ្ជាក់សច្ចភាព វាក៏ត្រូវតែមានព្រំដែនដែរ។ ម្យ៉ាង វិចារមិនមែនជាវិធីមួយដែលគ្រប់គ្រាន់ខ្លួនឯងក្នុងការរំកិលទៅជិតសច្ចៈទេ គឺអព្ភន្តរញាណទេដែលមានលទ្ធភាពធ្វើដូចនេះបាន។ ម្យ៉ាងទៀត នៅក្នុងគ្រប់វិចារតែងតែមានជាតុខ្លះដែលគេមិនអាចស្រាយបញ្ជាក់បានជាដាច់ខាត (ឧទាហរណ៍៖ អាក់ស្យូម...)។ ជាបញ្ចប់ដោយពិតទៅមានសច្ចភាពច្រើនណាស់ដែលគេ «ចាប់» បានដោយប្រើវិធីផ្សេងពីវិចារដូចជាពុទ្ធិដែលកើតពីកត្តាវេទនាដូចជាជំនឿសាសនាឬជំនឿជាក់ច្បាស់តាមផ្លូវទស្សនវិជ្ជា។

## ៤.៦ ទំនាក់ទំនងរវាងអព្ភន្តរញាណ និងវិចារ

អព្ភន្តរញាណ និងវិចារជាទម្រង់នៃពុទ្ធិដែលតែងតែត្រូវការគ្នាទៅវិញទៅមក បំពេញ កង្វះខាតដល់គ្នាតាមបែបផែនផ្សេងៗ ក្នុងមែកធាងនានានៃពុទ្ធិ៖ អព្ភន្តរញាណ ជាអ្នកផ្ដល់ សម្ភារៈសំណាង់ រីឯវិចារជាអ្នកចម្រាញ់ ការប្រើប្រាស់សម្ភារនេះ។ គេអាចនិយាយបានថា អព្ភន្តរញាណរកឃើញទំនាក់ទំនង រីឯវិចារបង្ហាញ ភស្តុតាងទំនាក់ទំនងនេះ។ អព្ភន្តរញាណមានភាពរហ័សពេកណាស់ ប៉ុន្តែខ្វះហេតុផល ដូចនេះវាត្រូវការវិចារដែលមានភាពយឺតៗ ប៉ុន្តែមាំទាំ កម្រក្លាំងក្លាត់ និងចាំបាច់ខានមិនបាន៕

# មេរៀនទី៥ សេរីភាព

មនុស្សម្នាក់ៗដែលរស់នៅក្នុងសង្គមតែងមានតម្រូវការជាប់ជានិច្ច ដើម្បីរស់រានមានជីវិត និងការរីកចម្រើន នៅពេលដែលតម្រូវការរបស់មនុស្សត្រូវបានគេគោរព នាំឱ្យគេមានសេរីភាពក្នុងការបញ្ចេញសមត្ថភាពរបស់គេ ប្រកបដោយគំនិតច្នៃប្រឌិតនិងធ្វើឱ្យសមត្ថភាពរបស់គេកាន់តែរីកចម្រើន។

## ៥.១ និយមន័យសេរីភាព

សេរីភាព ជាអ្វីដែលមនុស្សគ្រប់រូបប្រាថ្នាចង់បាន មនុស្សមានសេរីភាពត្រូវមានការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។ ហេតុអ្វីបានជាមនុស្សរស់នៅចាំបាច់មានសេរីភាព? សេចក្តីប្រកាសអំពីសិទ្ធិមនុស្សនៅឆ្នាំ១៧៨៩ របស់ប្រទេសបារាំងបានឱ្យនិយមន័យសេរីភាពថា ជាអំណាច ឬសិទ្ធិក្នុងការបំពេញសកម្មភាពអ្វីមួយដែលមិនធ្វើឱ្យខូចខាតដល់ប្រយោជន៍អ្នកដទៃ។ បើតាមវចនានុក្រមខ្មែរ សេរីភាពមានន័យថាអំណាចដែលអាចធ្វើអ្វីបានតាមអំពើចិត្ត ប៉ុន្តែស្ថិតក្រោមច្បាប់។ លោក កាល់ ម៉ាក្ស ពោលថា សេរីភាព គឺជាការទទួលស្គាល់ ការគោរព និងការបំពេញដោយហ្មត់ចត់នូវតួនាទី និងភារកិច្ចរបស់ខ្លួន។

សេរីភាព តាមន័យទូទៅ គេឲ្យនិយមន័យថា ជាការប្រើប្រាស់សិទ្ធិ ដោយគ្មានការហាមឃាត់ ដោយស្រប តាមច្បាប់សង្គម។ មនុស្សអាចដើរគ្រប់ទីកន្លែង អាចប្រកបមុខរបរគ្រប់ប្រភេទ អាចនិយាយអ្វីក៏បាន អាចមើលអ្វីក៏បាន អាចស្តាប់អ្វីក៏បាន និងធ្វើអ្វីៗដែលមនុស្សចង់ធ្វើ ឲ្យតែស្របតាមច្បាប់។ ទាំងនេះ គឺជាសេរីភាព។

ហេតុដូច្នេះ សេរីភាព គឺជាអំណាចក្នុងការធ្វើអ្វីបាន កុំឱ្យតែប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃ។ តាមន័យនេះ សេរីភាពសម្គាល់បាននូវភាពធ្វើអ្វីៗបានតាមចិត្តដោយគ្មានការបង្ខិតបង្ខំ ទោះបីក្នុងផ្លូវគំនិតក្តី ជំនឿក្តី និងសកម្មភាពសព្វបែបយ៉ាងក្តី អាចធ្វើបានតាមចិត្ត ឱ្យតែស្ថិតក្នុងក្របខ័ណ្ឌច្បាប់កំណត់។

## ៥.២ ទស្សនៈរបស់ទស្សនវិទូមួយចំនួនស្តីពីសេរីភាព

ទស្សនៈរបស់ទស្សនវិទូជាច្រើនបានបកស្រាយអំពីសេរីភាពដូចខាងក្រោម៖

- ហ្សង់ ហ្សាក់ រូស្សូ (Jean Jacque Rousseau) និយាយថា មនុស្សខុសពីសត្វត្រង់មនុស្សមានសមត្ថភាពក្នុងការជ្រើសរើសយកសកម្មភាពទាំងឡាយណាដែលគេអាចធ្វើបានមកអនុវត្ត។
- ដេកាត (Descartes) សេរីភាពគឺស្ថិតនៅត្រង់ការទទួលស្គាល់ការពិត ព្រោះជនគ្មានសេរីភាព ពុំហ៊ានទទួលស្គាល់ការពិតទេ ឃើញអាក្រក់ថា ល្អ ឃើញស ថាខ្មៅ ឃើញបាបថាបុណ្យ។
- បូ ស៊ុយអេ (Bossuet, Jacques Bénigne) សេរីភាពជាសិទ្ធិធ្វើអ្វីៗ ដែលច្បាប់អនុញ្ញាតឱ្យធ្វើ ។
- អាល់ប៊ែ កាមុស (Albert Camus) យល់ថាសេរីភាពគឺជាការភ្ញាក់ខ្លួន ដោយដឹងថាជីវិតរបស់យើងទាំងអស់គ្នាសព្វថ្ងៃគឺជាជីវិតឥតន័យ ហេតុនេះយើងត្រូវធ្វើខ្លួនដើម្បីរកន័យពិតឱ្យជីវិតមានន័យ។
- ហ្សង់ ប៉ូល សាត្រ (Jean Paul Sartre) សេរីភាព គឺភាពធ្វើអ្វីៗដោយគ្មានលក្ខខណ្ឌ។ នៅក្នុងន័យនេះ លោកឱ្យមនុស្សមានសេរីភាពស្មើគ្នាដោយមិនគិតពីវណ្ណៈ ឬមុខងាររបស់អ្នកតូច ឬអ្នកធំ អ្នកមានបុណ្យសក្តិ អ្នកក្រ ឬ អ្នកមានឡើយ។ បើអ្នកចង់ប្រកបមុខរបរណាមួយដែលអ្នកយល់ថានឹងបានធ្វើឱ្យជីវិតរបស់អ្នកមានសេចក្តីសុខ ក៏ស្រេចតែរូបអ្នក ហើយអ្នកចង់គោរព ឬមានជំនឿលើសាសនា ក៏គ្មាននរណាម្នាក់ហាមឃាត់ដែរ ព្រោះនេះជាសិទ្ធិសេរីភាពរបស់អ្នក ប៉ុន្តែសេរីភាពទាំងអស់នេះត្រូវសមស្របទៅតាមច្បាប់សង្គម។

មនុស្សមានសេរីភាពគ្រប់បែបយ៉ាង និងត្រូវមានសេចក្តីក្លាហានក្នុងការទទួលខុសត្រូវ។ មនុស្សដែលរស់នៅក្នុងសង្គម ត្រូវមានសេរីភាពក្នុងផ្លូវគំនិត និងសេរីភាពក្នុងការងារសម្រេចសេចក្តីប្រាថ្នារបស់គេ។ មនុស្សត្រូវតែមានសេរីភាព និងជ្រើសរើសផ្លូវមួយសម្រាប់ខ្លួន ដោយគ្មានអ្នកណា បង្ខិតបង្ខំឡើយ ។

## ៥.៣ រូបភាពនៃការមានសេរីភាព

មនុស្សមានសេរីភាពគ្រប់គ្រាន់ លុះត្រាតែមនុស្សនោះរស់នៅក្នុងសង្គមប្រកបដោយភាពយុត្តិធម៌ ព្រោះក្នុងសង្គមអយុត្តិធម៌ គេប្រើគ្រប់មធ្យោបាយក្នុងការបំបិទសេរីភាព ដើម្បីការពារផលប្រយោជន៍របស់ពួកគេ។ ក្នុងសង្គមយុត្តិធម៌ គេបានផ្តល់សេរីភាពដល់ពលរដ្ឋគ្រប់រូបក្នុងក្របខ័ណ្ឌច្បាប់ ក្នុងការកសាងជីវភាពរស់នៅរបស់ខ្លួន ។

### ៥.៣.១ រូបភាពនៃការមានសេរីភាព

**សេរីភាពនៃការបញ្ចេញមតិ៖** មនុស្សម្នាក់ៗមានតម្លៃដូចគ្នាក្នុងការរស់នៅក្នុងសង្គម ដូចនេះ មតិយោបល់របស់បុគ្គលម្នាក់ៗក៏មានតម្លៃដូចគ្នាដែរ សេរីភាពនៃការបញ្ចេញមតិ តម្រូវការចាំបាច់មួយក្នុងការចូលរួមសម្រេចចិត្ត ។ សង្គមមានសកម្មភាពរស់រវើកនិងកាន់តែរឹងមាំ នៅពេលដែលសមាជិកនៅក្នុងសង្គមបានចូលរួមផ្តល់គំនិត និងទស្សនៈផ្សេងៗ សេរីភាពនៃការបញ្ចេញមតិមិនត្រឹមតែជាការចែកផ្សាយព័ត៌មាន ឬគំនិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការស្វែងរក និងទទួលព័ត៌មានដោយឥតព្រំដែន ទោះបីតាមរយៈប្រព័ន្ធផ្សព្វផ្សាយអ្វីក៏ដោយ នៅក្នុងសង្គមប្រជាធិបតេយ្យ ប្រជាពលរដ្ឋបានប្រើប្រាស់សេរីភាពក្នុងការបញ្ចេញមតិមានដូចជា ការសរសេរជាអត្ថបទ ការពិភាក្សាជាមួយមិត្តភក្តិ ការផ្សព្វផ្សាយរូបភាព ឬតាមវិធីផ្សេងៗទៀតជាច្រើន ។

**សេរីភាពនៃការជួបប្រជុំ៖** ការជួបប្រជុំជាសេរីភាពមួយនៃសេរីភាពបញ្ចេញមតិដែលមានអំណាច និងមានប្រសិទ្ធភាពជាងគេ ព្រោះគេបានពិភាក្សាផ្លាស់ប្តូរគំនិត និងផ្សព្វផ្សាយគំនិតរបស់គបានភ្លាមៗដោយគេបានប្រាស្រ័យទាក់ទងរវាងមនុស្សម្នាក់ជាមួយនឹងអ្នកដទៃទៀត។ សេរីភាពខាងការជួបប្រជុំមានគោលបំណងធ្វើឱ្យប្រជាពលរដ្ឋលែងនៅឯកោ ដោយផ្តល់ឱ្យពួកគេមានអារម្មណ៍ក្នុងការរស់នៅជាសហគមន៍និងការផ្តល់កម្លាំងចិត្តនៅក្នុងការបញ្ចេញមតិពីបញ្ហាផ្សេងៗ។

**សេរីភាពនៃការបង្កើតសមាគម៖** ការធ្វើការងារជាក្រុមដែលរៀបចំបានល្អ ធ្វើឱ្យសមាជិកក្រុមម្នាក់ៗមានកម្លាំងកាន់តែខ្លាំងក្លា មានបទពិសោធន៍ មានការគាំទ្រ អាចទទួលបានអត្ថប្រយោជន៍ និងការការពារដល់ខ្លួនគេទៀតផង។

ការបង្កើតក្រុម ជាមធ្យោបាយមួយដ៏មានឥទ្ធិពលបំផុតសម្រាប់អ្នកចូលរួមទាំងអស់ ដើម្បីការពារផលប្រយោជន៍របស់ពួកគេម្នាក់ៗ ពិសេសការរួមគ្នាដោះស្រាយបញ្ហាផ្សេងៗដូចជា សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ នយោបាយ ដើម្បីការពារសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ នៅក្នុងការបង្កើតសមាគមណាមួយ ច្បាប់បានធានាសិទ្ធិជាមូលដ្ឋានសម្រាប់សេរីភាពក្នុងការបង្កើតសមាគមរបស់ប្រជាពលរដ្ឋ។ លទ្ធផលនៃសេរីភាពក្នុងការបង្កើតសមាគមបានជំរុញឱ្យប្រជាពលរដ្ឋធ្វើសកម្មភាពក្នុងភាពរឹងមាំ និងមានចរិតឯករាជ្យ។

### ៥.៣.២ ប្រភេទសេរីភាព

តាមទស្សនៈមួយចំនួនស្តីពីសេរីភាព គេបានបែងចែកសេរីភាពតាមប្រភេទដូចខាងក្រោម៖

**សេរីភាពធម្មជាតិគឺ**

- គ្មានការគំរាមកំហែង និងការបង្ខិតបង្ខំពីអ្នកដទ
- អាចធ្វើអ្វីៗតាមធម្មជាតិ ឬតាមឆន្ទៈរបស់មនុស្សម្នាក់ៗ
- គ្មានឧបសគ្គមករារាំងមនសិការរបស់គេម្នាក់ៗ និងធ្វើកិច្ចការដោយសេរី។

**សេរីភាពពលរដ្ឋ៖** ប្រជាពលរដ្ឋម្នាក់ៗមានសេរីភាពធ្វើអ្វីៗបានគ្រប់យ៉ាងតាមចិត្តប្រាថ្នារបស់ខ្លួន ដោយច្បាប់អនុញ្ញាត។ ការអនុវត្តច្បាប់ ត្រូវមានភាពយុត្តិធម៌ និងប្រជាធិបតេយ្យ។

**សេរីភាពនយោបាយ៖** ពលរដ្ឋម្នាក់ៗមានសេរីភាពក្នុងការធ្វើនយោបាយ ឱ្យតែនយោបាយនោះអាចធ្វើឱ្យពលរដ្ឋបានសេចក្តីសុខចម្រើន សម្បូរសប្បាយក្នុងស្ថានភាពប្រសើរ។ សេរីភាពនយោបាយឋិតនៅលើការអនុញ្ញាតឱ្យប្រជាពលរដ្ឋបានជួបប្រជុំគ្នា អាចបង្កើតសមាគម មានសិទ្ធិបញ្ចេញមតិយោបល់ និងសិទ្ធិសរសេរអត្ថបទ។ល។

**សេរីភាពសេដ្ឋកិច្ច៖** ពលរដ្ឋម្នាក់ៗមានសេរីភាពប្រកបវិជ្ជាជីវៈ បានតាមចំណូលចិត្តរបស់ខ្លួន។ ប្រជាពលរដ្ឋគ្រប់រូបមានសេរីភាពគ្រប់បែបយ៉ាង ប៉ុន្តែស្ថិតនៅក្នុងរង្វង់ច្បាប់ ប្រសិនបើគេប្រើសេរីភាពហួសព្រំដែនច្បាប់កំណត់នោះនឹងមានឈ្មោះ៖ ជាអ្នករំលោភច្បាប់ រំលោភលើសិទ្ធិ និងភារកិច្ចតួនាទីរបស់អ្នកដទៃ នឹងនាំឱ្យកើតមានភាពអនាធិបតេយ្យ បក្សពួកនិយម អំណាចផ្តាច់ការ និងធ្វើឱ្យសង្គមគ្មានសន្តិសុខនិងអស្ថិរភាព ។

## ៥.៤ ផលនៃការមានសេរីភាព

លោក ចន ស្ទូអារច៍ មៀល( John Stuart Mill ) បានអះអាងថា សេរីភាពមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យមានសច្ចធម៌ និងទទួលបានជោគជ័យ ។

គំនិតរបស់មនុស្សម្នាក់ៗ ឬក្រុមមួយតែងតែមានការខ្វះចន្លោះ ឬការភាន់ច្រឡំ។ ដូច្នេះ សេរីភាពក្នុងការបញ្ចេញមតិជាការឆ្លើយតបទៅនឹងអ្វីដែលមិនត្រឹមត្រូវ ឬខ្វះចន្លោះ។

នៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ សេរីភាពខាងសារព័ត៌មានសេរីភាពក្នុងការបង្កើត សមាគម... ជាឧបករណ៍ដ៏សំខាន់មួយក្នុងការប្រឆាំងនឹងការរំលោភសិទ្ធិប្រជាជនពីសំណាក់អ្នកមានប្រាក់ និងមានអំណាច។ ជាការពិតណាស់ដែលថា ទីណាគ្មានសេរីភាពក្នុងការបញ្ចេញមតិទិតៀន ទីនោះត្រូវតែទទួលរងនូវការគាបសង្កត់ កេងប្រវ័ញ្ច អយុត្តិធម៌ អំពើពុករលួយ បក្សពួកនិយម និងអំណាចផ្តាច់ការ ផ្ទុយមកវិញ សង្គមមានសេរីភាព មានយុត្តិធម៌ សង្គមនោះពិតជាសង្គមមានសន្តិភាព និងមានស្ថិរភាពយូរអង្វែង៕

# មេរៀនទី៦ ការសម្តែងមតិ

មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិតវ៉ាចំពោះអ្វីដែលខ្លួនពុំពេញចិត្ត ឬគិតថាបាត់បង់ផលប្រយោជន៍របស់ខ្លួន។ សេរីភាពបញ្ចេញមតិត្រូវបានប្រើប្រាស់ក្រោមការកំណត់របស់ច្បាប់។ ការសម្តែងមតិមិនត្រូវប៉ះពាល់សិទ្ធិ កិត្តិយស សេចក្តីថ្លៃថ្នូរអ្នកដទៃឡើយ។ ក្នុងសង្គមប្រជាធិបតេយ្យ ការសម្តែងមតិជាចំណុចសំខាន់ក្នុងការចូលរួមកែលម្អក្នុងន័យវិជ្ជមាន ដើម្បីឱ្យប្រទេសជាតិមានការអភិវឌ្ឍ។

## ៦.១ សិទ្ធិក្នុងការសម្តែងមតិ

នៅប្រទេសកម្ពុជាច្បាប់បានផ្តល់សិទ្ធិសេរីភាពឱ្យប្រជាពលរដ្ឋសម្តែងមតិដោយសេរីចំពោះបុគ្គលសាធារណៈ ឬប្រឆាំងតវ៉ាចំពោះនិយោជក ប្រសិនបើពួកគេរងការគាបសង្កត់ដោយមធ្យោបាយណាមួយ ឬសកម្មភាពដែលខុសច្បាប់បញ្ញត្តិបានចែង។ ប្រព័ន្ធផ្សព្វផ្សាយជាច្រើនបានបើកទូលាយ ដូចជា សារព័ត៌មាន ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ ដែលជាឧបករណ៍ដើម្បីសម្តែងមតិជាសាធារណៈ។

ប្រជាពលរដ្ឋមានសិទ្ធិតវ៉ាគ្រប់យ៉ាងតាមរយៈការសុំច្បាប់ធ្វើកូដកម្ម បាតុកម្ម ឬតវ៉ារាល់បញ្ហាអ្វី ដែលខ្លួនគិតថា ជាការរំលោភសិទ្ធិរបស់ខ្លួន ប៉ុន្តែការសម្តែងមតិធ្វើបាតុកម្មពុំត្រូវធ្វើឱ្យបាត់បង់សណ្តាប់ធ្នាប់សង្គម និងទ្រព្យសម្បត្តិសាធារណៈឡើយ។

ម្យ៉ាងទៀត ការសម្តែងមតិត្រូវមានភាពប្រាកដនិយម មិនត្រូវយកការសម្តែងមតិជាឧបករណ៍ទាញចំណេញពីអ្នកដទៃ ឬធ្វើជាឧបករណ៍នយោបាយឡើយ។ បច្ចុប្បន្នមនុស្សម្នាក់ៗមានសិទ្ធិសេរីភាពក្នុងការសម្តែងមតិយោបល់ ចូលរួមកែលម្អគម្រោងអភិវឌ្ឍន៍ផ្សេងៗក្នុងសហគមន៍របស់ខ្លួន និងអាចជំទាស់គម្រោងផែនការណាដែលពុំផ្តល់ផលប្រយោជន៍ដល់សហគមន៍ខ្លួន ឬផ្តល់ប្រយោជន៍ដល់តែជនមួយក្តាប់តូច។

ដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋម្នាក់ៗក្នុងការសម្តែងមតិ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សត្រង់មាត្រាទី១៩ បានចែងថា "មនុស្សគ្រប់រូបមានសិទ្ធិនិងសេរីភាពក្នុងការប្រកាន់មតិ និងក្នុងការសម្តែងគំនិត។ សិទ្ធិនេះរួមមាន សេរីភាពក្នុងការប្រកាន់ និងបញ្ចេញមតិដោយគ្មានការជ្រៀតជ្រែក គ្មានការបារម្ភភិតភ័យដោយសារមតិរបស់ខ្លួន និងសេរីភាពក្នុងការស្វែងរកការទទួល និងការផ្សព្វផ្សាយទូទៅដោយពុំគិតព្រំដែនអ្វីឡើយនូវព័ត៌មានព្រមទាំងគំនិតអ្វីផ្សេងៗតាមមធ្យោបាយណាក៏ដោយ" ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានគាំទ្រសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សដែលបានប្រកាសឡើងដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ជាកម្រិតនៃការសម្រេចជោគជ័យរួមគ្នារបស់ប្រជាជនទាំងអស់គ្រប់សញ្ជាតិ។

## ៦.២ គោលការណ៍នៃការសម្តែងមតិរបស់សារព័ត៌មាន

អ្នកសារព័ត៌មាន ជាអ្នកនាំពាក្យពីប្រជាជនទៅរាជរដ្ឋាភិបាល ឬពីរាជរដ្ឋាភិបាលទៅប្រជាជន តាមរយៈសារព័ត៌មាន វិទ្យុ ទូរទស្សន៍ ...។ អ្នកសារព័ត៌មានប្រាប់ព័ត៌មាន ហេតុការណ៍ផ្សេងៗដែលកើតមានក្នុងសង្គមឱ្យប្រជាជន និងរាជរដ្ឋាភិបាលបានដឹងនិងរកដំណោះស្រាយ ធ្វើអន្តរាគមន៍ទាន់ពេលវេលា។

ដើម្បីឱ្យព័ត៌មាន មានលក្ខណៈប្រាកដនិយម អ្នកសារព័ត៌មានត្រូវគោរពក្រមសីលធម៌ និងគោរពគោលការណ៍ដូចខាងក្រោម៖

- ត្រូវផ្សាយដំណឹងដោយសុចរិតព្រមទាំងធ្វើអត្ថាធិប្បាយ ឬរិះគន់ឱ្យត្រឹមត្រូវនិងសមស្របតាមច្បាប់ ។

• ត្រូវរាយការណ៍ពីហេតុការណ៍ដែលខ្លួនដឹងពីប្រភពដើមប៉ុណ្ណោះ។ អ្នកសារព័ត៌មានមិនត្រូវបំបាត់ចោលព័ត៌មានសំខាន់ៗ ឬកបន្លំឯកសារផ្សេងៗឡើយ។

• គោរពសច្ចធម៌ និងគោរពសិទ្ធិយល់ដឹងសច្ចធម៌របស់សាធារណជន។

• ត្រូវកែតម្រូវព័ត៌មានណាដែលចេញរួចហើយមានលក្ខណៈមិនជាក់លាក់ និងនាំឱ្យមានការយល់ច្រឡំ។

• ត្រូវចៀសវាងការផ្សាយព័ត៌មានដែលញុះញង់ឱ្យមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភាសា ជំនឿ សាសនា មតិ ឬស្ថានភាពដទៃទៀត។

• ត្រូវគោរពសិទ្ធិ និងសេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល។ ត្រូវគោរពឱ្យបានហ្មត់ចត់តាមក្បួនវេយ្យាករណ៍ខ្មែរក្នុងការសរសេរអត្ថបទ។

• ហាមបោះពុម្ពផ្សាយអត្ថបទ ឬរូបភាពអាសអាភាសនិងរូបភាពអំពើហិង្សា។

• ហាមរំលោភលើសិទ្ធិដើម្បីមានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់បុគ្គលម្នាក់ៗដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ការរំលោភដ៏ធ្ងន់ធ្ងរខាងផ្នែកវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន មានៈ

- ការលួចចម្លងគំនិត ឬស្នាដៃរបស់អ្នកដទៃមកដាក់ជារបស់ខ្លួន

- ការបន្លំឱ្យគេយល់ខុសដូចជាការសរសេរបញ្ឆិតបញ្ឆៀង ដើម្បីឱ្យអ្នកអានមានការសង្ស័យដោយអយុត្តិធម៌លើបុគ្គលណាម្នាក់ ក្រុម បក្សណាមួយ

- ការមួលបង្កាច់ បរិហារកេរ្តិ៍ និងការជេរប្រមាថ

- ការទទួលសំណូកក្នុងបែបបទណាមួយ ឬការជីវិតយកប្រាក់ ដើម្បីជាថ្នូរនឹងការបោះពុម្ពផ្សាយ ឬមិនបោះពុម្ពផ្សាយព័ត៌មានណាមួយ។

## ៦.៣ សារៈសំខាន់នៃសិទ្ធិសេរីភាពក្នុងការសម្តែងមតិ

ការសម្តែងមតិ ជាមធ្យោបាយមួយសម្រាប់ប្រាប់ហេតុការណ៍ពិតដែលកើតឡើងដល់រដ្ឋាភិបាលឱ្យបានដឹង និងរកវិធីដោះស្រាយទាន់ពេលវេលា។ ប្រជាជនមានសិទ្ធិសម្តែងមតិ ប្រាប់ពីគោលបំណង និងតម្រូវការរបស់ក្រុមខ្លួនដល់អ្នកដឹកនាំពីព័ត៌មានសំខាន់ៗសម្រាប់វិភាគពិចារណាគ្រប់ជ្រុងជ្រោយ មុននឹងដោះស្រាយបញ្ហាណាមួយ។ រដ្ឋាភិបាលមានឱកាសដឹងរឿងរ៉ាវដែលកើតឡើងនៅមូលដ្ឋាន និងធ្វើសកម្មភាពជួយដោះស្រាយបញ្ហាជនរងគ្រោះតាមលក្ខណៈច្បាប់។

សេរីភាពសម្តែងមតិ ជាការបញ្ចេញសំឡេងអ្វីមួយដែលខ្លួនពុំយល់ព្រមចំពោះបុគ្គលសាធារណៈ ឬក្រុមហ៊ុនដែលដាក់ការគាបសង្កត់មកលើខ្លួន ធ្វើឱ្យបាត់បង់ផលប្រយោជន៍ និងចង់ឱ្យបុគ្គល ឬក្រុមហ៊ុនដោះស្រាយលើបញ្ហារបស់ខ្លួន។

## ៦.៤ ការទទួលខុសត្រូវក្នុងការសម្តែងមតិ

ការបញ្ចេញមតិ ជាសេរីភាពរបស់មនុស្សគ្រប់រូប ប៉ុន្តែមិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិបុគ្គល កិត្តិយស កេរ្តិ៍ឈ្មោះ មាក់ងាយ បង្កភាពញុះញង់ គ្មានសីលធម៌ ដែលធ្វើឱ្យបាត់បង់ស្ថិរភាពសង្គម និងខុសច្បាប់។ ការប្រើប្រាស់សិទ្ធិបញ្ចេញមតិត្រូវមានការទទួលខុសត្រូវ ដើម្បីជៀសវាងកុំឱ្យប៉ះទង្គិចសិទ្ធិអ្នកដទៃ បង្កវិទ្ធង្សនាដល់សន្តិសុខជាតិ។ ដូចនេះ អ្នកបញ្ចេញមតិត្រូវធានាលើមតិរបស់ខ្លួនថា ពិតនិងមានក្រមសីលធម៌ស្របតាមច្បាប់បានកំណត់៕

# មេរៀនទី៧ សិទ្ធិនិងច្បាប់

## ៧.១ និយមន័យ

តាមឡឺបនិច(Leibniz)ច្បាប់មាននិយមន័យថាជា«សីលអំណាចមួយ»។

ក. ច្បាប់ដែលជាអំណាចមួយ មានន័យផ្ទុយពីករណីយកិច្ច ព្រោះថាករណីយកិច្ចកម្រិតព្រំដែននៃអំពើរបស់យើងក្នុងឋានៈជាកាតព្វកិច្ច។ ចំណែកឯច្បាប់វិញបើកសិទ្ធិឱ្យយើងអាចធ្វើនេះធ្វើនោះបាន។

ខ. អំណាចដែលច្បាប់ឱ្យមកយើង ពុំមែនជាអំណាចធម្មតាឡើយ តែជាសីលអំណាចមួយ។ សីលអំណាចមានន័យផ្ទុយពីអំណាចរូប ពោលគឺសីលអំណាចនេះ ពុំមែនជាអំណាចមួយផ្នែកសម្ភារទេ។ តាមផ្លូវសម្ភារខ្ញុំ «អាច» ធ្វើអំពើជាច្រើនដែលតាមច្បាប់ ខ្ញុំគ្មានសិទ្ធិនឹងធ្វើ។ ក្នុងន័យនេះ សីលអំណាចគឺជាអំណាចមួយខាងផ្លូវគំនិតដែលឋិតនៅបរិសុទ្ធជានិច្ច ទោះជាគេមិនទទួលស្គាល់ ឬក៏គេជាន់ឈ្លីអំណាចទោះយ៉ាងណាក៏ដោយ។

## ៧.២ សីលច្បាប់និងច្បាប់វិជ្ជមាន

និយមន័យដែលយើងពោលមកខាងលើ ស្របជាពិសេសនឹងសីលច្បាប់ដែលមាននៅក្នុងវិចារណញ្ញាណ និងនៅក្នុងសីលញាណរបស់យើង។ ប៉ុន្តែ ច្បាប់ដែលជា«សីលអំណាច»នេះដូចជាសីលញាណឯទៀតៗដែរ ត្រូវមានរូបរាងនិងកំណត់ឡើងនៅក្នុងការរស់នៅក្នុងសង្គមរបស់មនុស្ស។ ក្នុងករណីនេះ សីលច្បាប់ក្លាយទៅជាច្បាប់ក្នុងន័យតិចនិចនៃពាក្យ ដែលគេហៅថាច្បាប់វិជ្ជមាន។ នៅក្នុងសង្គមដែលមិនសូវមានការជឿនលឿន ច្បាប់វិជ្ជមានមានទ្រង់ទ្រាយស្ទើរតែទាំងអស់ជាប្រពៃណី និងជាទំនៀមទម្លាប់ ដែលមានលក្ខណៈសាសនាផង។ ប៉ុន្តែ ច្បាប់ប្រពៃណី បានផ្លាស់បន្តិចម្តងៗទៅជាច្បាប់លាយលក្ខណ៍អក្សរ។ ដូចនេះ ច្បាប់វិជ្ជមានទោះជានៅប្រទេសណាក៏ដោយ ក៏ពុំមែនជាការបង្កើតរបស់វិចារណញ្ញាណសុទ្ធសាធ ដោយគ្មានពឹងទៅលើអ្វីពីមុនមកសោះទេ។ គឺជាផលសាំញ៉ាំនៃប្រវត្តិសាស្ត្រ។ ដំបូងជាច្បាប់ប្រពៃណី រួចមកជាច្បាប់លាយលក្ខណ៍អក្សរ ច្បាប់វិជ្ជមានបានវិវត្តទៅតាមឧប្បត្តិហេតុនានាក្នុងប្រវត្តិសាស្ត្រ ច្បាប់វិជ្ជមានបានផ្លាស់ប្តូរជានឹងចំបាំងរាំងជល ជាមួយនឹងសង្គ្រាមបដិវត្តជាមួយនឹងបម្រែបម្រួលទាំងឡាយនៅក្នុងប្រវត្តិសាស្ត្រ។

## ៧.៣ មតិផ្សេងៗអំពីច្បាប់

### ៧.៣.១ ទ្រឹស្តីនៃច្បាប់ធម្មជាតិ

អ្នកទ្រឹស្តីវិចារណញ្ញាណនិយមបានចាត់ទុកច្បាប់ជាកេតនភណ្ឌ ពិសេសរបស់មនុស្សដោយមនុស្សមានធម្មជាតិជាភាវៈប្រកបដោយ«វិចារណញ្ញាណ»។ ធម្មជាតិជាភាវៈប្រកបដោយវិចារណញ្ញាណនេះ បានផ្តល់ដល់មនុស្សនូវសេចក្តីថ្លៃថ្នូរមួយដ៏ឧត្តមដែលមិនអាចប្រៀបធៀបបានជាមួយនឹងធម្មជាតិនៃភាវៈដែលមានរូបរាងសត្វឬវត្ថុ។

ប្រកបដោយលក្ខណៈសកលនិងមិនចេះប្រែប្រួល ច្បាប់ធម្មជាតិនេះមិនគឺក្រៅពីវិចារណញ្ញាណសាមញ្ញរបស់មនុស្សទូទៅដែលគ្រប់គ្រងឥរិយាបថរបស់មនុស្សនោះឡើយ។ គឺជាច្បាប់ធម្មជាតិនេះហើយ ដែលបង្កើតឱ្យមានទ្រង់ទ្រាយ ផ្សេងៗនៃច្បាប់វិជ្ជមាន។ ទស្សនៈ ស៊ីសេរ៉ុង(Cicéron)បានលើកយកមកបរិយាយរួចម្តងហើយនៅពេលដែលគាត់ឱ្យនិយមន័យទៅច្បាប់ថា «និយាមឧត្តមបំផុត» ដែលមានចរិតនៅក្នុងធម្មជាតិ ហើយត្រូវបានក្រូស្យុស(Grotius)លើកយកមកធ្វើអត្ថាធិប្បាយម្តងទៀតដោយឱ្យនិយមន័យច្បាប់ធម្មជាតិថា "គឺជានិយាមមួយដែលមានគំនិតចេញមកពីវិចារណញ្ញាណត្រឹមត្រូវ ហើយតាមនិយាមនោះយើងវិនិច្ឆ័យថាអំពើមួយប្រកបដោយសីលលក្ខណៈ ឬអយុត្តិធម៌អាស្រ័យទៅតាមភាពស្របឬពុំស្របនៃអំពើនោះទៅនឹងធម្មជាតិប្រកបដោយវិចារណញ្ញាណ"។ នៅសតវត្សទី១៨ ខាន់ បានពន្យល់ថាច្បាប់ពុំមែនជាការពិសោធមួយទេ ប៉ុន្តែគឺជាគំនិតមួយ

«ខ្ពស់ជាងនឹងកើតមុនការណ៍» ដែលមានមូលដ្ឋានជាវិចារណញ្ញាណកើតមុនពិសោធន៍នៅក្នុងសេរីភាពរបស់មនុស្ស ដូចនោះច្បាប់គឺជា «លក្ខខណ្ឌទាំងអស់ដែលនៅក្នុងនោះឆន្ទៈរបស់ជនម្នាក់ៗអាចភ្ជាប់ទៅនឹងឆន្ទៈរបស់អ្នកដទៃតាមច្បាប់ទូទៅមួយនៃសេរីភាព»។ ច្បាប់ធម្មជាតិជាសកលនិងមានជាប់នឹងធម្មជាតិរបស់មនុស្សនេះហើយ ដែលជាមូលដ្ឋាននៃការប្រកាសសិទ្ធិមនុស្សនៅឆ្នាំ1789 និងការប្រកាសជាសកលនៃសិទ្ធិមនុស្សនៅឆ្នាំ1948។

### ៧.៣.២ ច្បាប់និងកម្លាំង

ដោយគិតដល់ភាពប្រាកដនិយម អ្នកទ្រឹស្តីខ្លះបានប្រកាសយកជំហរផ្ទុយពីមតិមុនហើយចង់ទាញច្បាប់ជាសីលអំណាចឱ្យទៅជាអំណាចរូប ពោលគឺឱ្យទៅជាកម្លាំងទៅវិញ។ បើតាមអ្នកទ្រឹស្តីទាំងនោះ«ច្បាប់គ្រាន់តែជាការសម្តែងចេញនៃកម្លាំងប៉ុណ្ណោះ»។ នីត (Nietzsche 1844-1900) បានលើកតម្កើង «ឆន្ទៈស្វែងអំណាច» រំលោភទាំងបំពារបំពានទៅលើអ្នកទន់ខ្សោយ។ នៅក្នុងវិស័យពិសោធន៍ អ្នកវិវត្តនិយមខ្លះយកគំនិតនៃ «ការតស៊ូដើម្បីជីវិត» មកជាសំអាង ដើម្បីពន្យល់«ច្បាប់នៃអ្នកខ្លាំងជាងគេ»។ នៅក្នុងវិស័យអស្តិរូបវិជ្ជា លទ្ធិសព្វទេវនិយមតែងតែមានទំនោរចង់ប្រដូចច្បាប់ទៅនឹងកម្លាំង ឬបើពុំនោះក៏ចង់ចាត់ទុកកម្លាំងជាការសម្តែងចេញមកពិតប្រាកដរបស់ច្បាប់ដែរ។ ហេតុដូចនេះហើយបានជា ស្ពីណូសា(Spinoza)ក្នុងការលើកតម្កើងសារជាតុសកលជាអាទិទេពបានថ្លែងថា«ដោយ ហេតុថាព្រះអាទិទេពបែងភាគនៅក្នុងធម្មជាតិ កម្លាំងធម្មជាតិទាំងឡាយគ្រាន់ តែជាផ្នែកមួយនៃអំណាចរបស់អាទិទេពប៉ុណ្ណោះ» ហើយគាត់ហ៊ានរហូតទៅដល់និយាយថា៖ «បុគ្គលម្នាក់ៗមានសិទ្ធិស្មើនឹងអំណាចដែលខ្លួនមាន»៖ សត្វត្រីមានសិទ្ធិនឹងហែលនៅក្នុងទឹកហើយត្រីធំៗមានសិទ្ធនឹងស៊ីត្រីតូចៗ។ តាមគំនិតគាត់ «អ្វីដែលគេអាចធ្វើបាន គេមានសិទ្ធិនឹងធ្វើ»។ ចំណែក ម៉ាក្ស ស្ទៀន័រ (Marx Stirner) ក៏យល់ដូចនេះដែរ។ គាត់បានថ្លែងថា«អ្នកណាមានកម្លាំង អ្នកនោះមានច្បាប់៖ សត្វខ្លាដែលប្រហារយើងបានធ្វើត្រូវ (ព្រោះសត្វខ្លាខ្លាំងជាងយើង)ចំណែកយើង បើយើងសម្លាប់ខ្លាបានវិញ យើងធ្វើត្រូវដែរ(ព្រោះយើងខ្លាំងជាងខ្លា)»។

នៅក្នុងទ្រឹស្តីរបស់ អេគែល (Hegel)និង ម៉ាក្ស (Marx) គំនិតយកកម្លាំងធ្វើជាច្បាប់បានត្រូវលើកយកមកវែកញែកអធិប្បាយម្តងទៀតយ៉ាងពិស្តារ។ ចំពោះ អេគែល គំនិតឬចិត្តគឺអ្វីដែលសម្រេចបាន ជាការពិតជាក់ស្តែងឡើងនៅក្នុងដំណើរការនៃប្រវត្តិសាស្ត្រ៖ ប្រជាជាតិមួយ អរិយធម៌មួយ ដែលបានទទួលជោគជ័យនៅពេលមួយនៃប្រវត្តិសាស្ត្រ តាងនូវដំណាក់ការមួយក្នុងដំណើរទៅមុខនៃគំនិត។ កម្លាំងពិតប្រាកដជាក់ស្តែងជាខ្នាតតែមួយគត់នៃច្បាប់។ សម្រាប់ ម៉ាក្ស វិញច្បាប់បកស្រាយឬតាងនូវកម្លាំងព្រោះតាមការពិតច្បាប់គឺគ្មានអ្វីក្រៅពីបំណកស្រាយអានុភាពរបស់វណ្ណៈសង្គមមួយដែលមានអំណាចឡើយ៖ ច្បាប់គឺឆន្ទៈរបស់វណ្ណៈសង្គមដែលកាន់អំណាច។ គឺនៅក្នុងន័យនេះហើយ ដែលសិទ្ធិទាំងឡាយរបស់មនុស្ស បានត្រូវគេប្រកាសកាលពី ឆ្នាំ1789 គឺគ្មានអ្វីក្រៅពីសេចក្តីត្រូវការរបស់វណ្ណៈគហបតី ដែលតែកំពង់តែរីកចម្រើននោះឡើយ។ គំនិតសមភាពទៀត តាមពិតគឺគ្រាន់តែបំណកស្រាយមហិច្ឆិតារបស់វណ្ណៈនេះ ដែលស្គាល់ច្បាស់នៅឥទ្ធិពលសេដ្ឋកិច្ចរីកសាយរបស់ វណ្ណៈខ្លួន ហើយដែលមានបំណងចង់ទទួលឯកសិទ្ធិនានាដូចជាវណ្ណៈអភិជនដែរតែប៉ុណ្ណោះ។ ជាពិសេសគំនិតសេរីភាពក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងប្រយោជន៍របស់វណ្ណៈគហបតីដែរ។ ដូចនេះហើយ បានជានៅក្នុងឆ្នាំ1791 ក្នុងនាមនៃសេរីភាពច្បាប់ឡឺសាប៉ីល្យេ(loi Chapellier)បានលុបបំបាត់លែងឱ្យមានសមាគមផ្សេងៗនៃមុខរបរ។ ការលុបបំបាត់នេះមានន័យថា ម្ចាស់សហគ្រាសទាំងឡាយមានបំណងចង់ឱ្យនិយោជិតរបស់ខ្លួន«មានសេរីភាព» រួចចាកផុតពីអង្គការសហជីពមានសមាគមមុខរបរនេះជាដើម។ កាលបើសមាគមខ្លួនត្រូវគេរំលាយហើយ កម្មករទាំងឡាយក៏ត្រូវនៅរាយប៉ាយ បែកខ្ញែកគ្នា ខ្សោយកម្លាំង ឥតមានអ្វីការពារខ្លួនឡើយនៅចំពោះមុខគហបតីជាចៅហ្វាយរបស់ខ្លួន។

និយាយដូចនេះ ពុំមែនបានសេចក្តីថា ម៉ាក្សខឹងសម្បារឬមួយក៏មានការទោមនស្សចំពោះស្ថានការណ៍ដូចបានពោលមកខាងលើក៏ទេដែរ។ ម៉ាក្ស ពុំដែលបានតាំងខ្លួនជាអ្នកការពារឬមួយក៏ជាអ្នកផ្សព្វផ្សាយនូវ «យុត្តិធម៌មួយដាច់ខាត» ឥតមានទំនាក់ទំនងអ្វីសោះនឹងឥទ្ធិពលផ្សេងៗនៃប្រវត្តិសាស្ត្រនេះម្តងណាឡើយ។អំពើទាំងឡាយ

របស់ពពួកគហបតីនៃឆ្នាំ1789 សុទ្ធជាអំពើត្រឹមត្រូវទាំងអស់ ព្រោះពួកគហបតីទាំងនេះតាងនូវកម្លាំងដែលទៅស្មុះខាងមុខនៃប្រវត្តិសាស្ត្រ។ ម៉ាក្ស បានទាំងពោលសរសើរយ៉ាងច្រើនដល់របប មូលធននិយម ដែលបានជួយកែប្រែមុខមាត់សង្គមកសិកម្មចាស់ឱ្យមានលក្ខណៈទាន់សម័យនិយម ដោយការប្រើប្រាស់នូវគ្រឿងយន្តទំនើបៗថែមទៀតផង។ ប៉ុន្តែចំពោះ ម៉ាក្ស ប្រសិនបើច្បាប់ទាំងឡាយរបស់ពួកគហបតីដែលមានលក្ខណៈត្រឹមត្រូវក្នុងពេលមុន បានប្រែក្លាយជាច្បាប់ឥតន័យ អស់តម្លៃក្នុងពេលនោះ ក៏ព្រោះតែច្បាប់អស់នេះជាបំណាកស្រាយអត្តទត្ថភាពរបស់វណ្ណៈសង្គមមួយដែលចុះដុនដាបទៅរកការរលត់រលាយ ហើយដែលតទៅអនាគតនឹងត្រូវបាត់បង់អស់នូវកម្លាំងរបស់ខ្លួន។ មែនទែនទៅច្បាប់ពិតប្រាកដត្រូវកប់ទុកក្នុងផលប្រយោជន៍របស់វណ្ណៈកម្មករ ព្រោះវណ្ណៈនេះជាវណ្ណៈដែលឋិតនៅ «ក្នុងទិសដៅនៃប្រវត្តិសាស្ត្រ»។ និយាយម៉្យាងទៀតថា នៅក្នុងវិវត្តន៍ដ៏ចាំបាច់នៃពិភពលោក វណ្ណៈកម្មករនឹងត្រូវបានឡើងកាន់អំណាចទៅថ្ងៃក្រោយ។

**សិក្សារិះគន់**

ទ្រឹស្តីខាងលើមិនអាចនឹងយកជាការបានឡើយ។

ជាបឋមយើងគួរកត់សម្គាល់ឃើញថាក្នុងការពិតទ្រឹស្តីនេះផ្ទុយនឹងធម្មជាតិហើយនិងប្រវត្តិសាស្ត្រនៃច្បាប់នោះតែម្តង ទោះជាទ្រឹស្តីនេះខំលើកយកភាពប្រាកដនិយមមកធ្វើជាលេសយ៉ាងណាក្តី។ ទោះជានៅក្នុងសង្គមជាន់ដើមក៏ដោយ ក៏ការលើកយកកម្លាំងតែម្យ៉ាងមកធ្វើច្បាប់នោះគ្មានលក្ខណៈត្រឹមត្រូវឡើយ។ តាមពិតនៅក្នុងសង្គមទាំងនោះគេឃើញមានជំនឿមួយចំនួនទំនៀមទម្លាប់ជាច្រើន និងជាពិសេសការហាមឃាត់ផ្សេងៗដែលរួមប្រមូលទៅបានជារបបមួយដែលមានលក្ខណៈសង្គម និងមនុស្សជាតិពិតប្រាកដត្រួតភ្ជាប់នឹងរបបទំនាក់ទំនងរវាងកម្លាំងនិងកម្លាំង។ ដូចជា នៅប្រទេសណូវែលហ្សេឡង់(Nouvelle Zélande) គេជំណាលថា បើអ្នកស្រុក ម៉ៅរី (Maori) ម្នាក់មិនចង់នៅផ្ទះ គាត់គ្រាន់តែចងសរសៃធ្មៃនៅមាត់ទ្វារគាត់ជាការស្រេច។ អំណោះតទៅទ្វារផ្ទះនឹងទៅជា «តាប៊ូ» (Tabou) ហើយគ្មាននរណាម្នាក់ហ៊ានលូកដៃទៅប៉ះពាល់ទ្វារនោះឡើយ។

តើជំនឿនេះជាសញ្ញានៃកម្លាំងដែរឬទេ? ជាការពិត ដែលនៅក្នុងប្រវត្តិសាស្ត្រ តែងតែមានអំពើឃោរឃៅមានការជេណ្តើមរំលោភជាច្រើន ហើយគេត្រូវតែសារភាពថា អំពើកំរោលប្រើកម្លាំងបាយទាំងនេះ ជួនកាលនៅទីបំផុតអាចឱ្យគេសម្គាល់ទុកដូចជា «ច្បាប់» ដែរ។ ដូចនេះបានជាលោក ប៉ាស្កាល់(Pascal)សរសេរថា«ដោយមិនអាចធ្វើអ្វីដែលត្រូវទៅតាមលក្ខណៈច្បាប់ឱ្យទៅជាខ្លាំងបានគេក៏ធ្វើអ្វីដែលខ្លាំងឱ្យទៅជាត្រូវតាមលក្ខណៈច្បាប់វិញ»។ ប៉ុន្តែគេអាចកត់សម្គាល់ថាបំលាស់ប្តូរទាំងនេះមិនអាចនឹងធ្វើទៅបានដោយគ្មានការឱ្យតម្លៃ ទៅកម្លាំងឡើយ។ គ្មានអំណាចណាមួយដែលប្រកាសថា "ចូរអ្នកស្តាប់បង្គាប់ខ្ញុំ ព្រោះខ្ញុំជាអ្នកខ្លាំងពូកែ" យ៉ាងខ្លី ហើយចប់តែប៉ុណ្ណោះទេ។ គេតែងមានសំអាងជានិច្ចទៅលើការបង្ហាញភស្តុតាង ឬយ៉ាងហោចណាស់ទៅលើលេសផ្សេងៗដែលទោះជាត្រូវច្បាប់ឬមិនត្រូវច្បាប់ក្តី ស្មោះត្រង់ ឬលាក់ពុតក្តីក៏ជាការឱ្យតម្លៃ និងជាការលើកតម្កើងដែលកម្លាំងបានធ្វើចំពោះច្បាប់ដែរ។

គេបានសង្កេតឃើញថា ទោះជាជនណាម្នាក់ឈ្នះគេដោយអយុត្តិធម៌និងទាំងកំរោលក៏ដោយក៏ជននោះខំនិយាយរកច្បាប់ជាងជនណាៗទាំងអស់ដែរ។ ហ៊ីត្លែរ(Hitler) និងពួក ណាស៊ី (Nazis) ដែលជាអ្នកសម្លាប់រង្គាលមិនអះអាងថាគេជា«អ្នកការពារច្បាប់និងអរិយធម៌» ទេឬ? ការឃោសនាដោយលាក់ពុតរបស់គេកាន់តែបញ្ជាក់ឱ្យឃើញច្បាស់ណាស់ថា កម្លាំងព្រៃផ្សៃតែងតែត្រូវការយកលេសប្រកបដោយកិត្តិយសមកបិទបាំងជានិច្ច ពីព្រោះច្បាប់ព្រៃផ្សៃតែឯកងងពុំមានឥទ្ធិពលស័ក្តិសិទ្ធិទៅលើញាណរបស់មនុស្សឡើយ។ ប៉ាស្កាល់បានកត់សម្គាល់ថា «មតិមានឥទ្ធិពលទៅលើចិត្តគំនិតរបស់មនុស្សខ្លាំងណាស់ ប៉ុន្តែកម្លាំងពុំអាចបង្ក្រាបមនុស្សឱ្យចុះញ៉មបានឡើយ»។ កម្លាំងត្រូវធ្វើខ្លួនឱ្យទៅតាមច្បាប់សិន ដើម្បីឱ្យខ្លួនអាចមានស្ថិរភាពបាន។ យ៉ាងណាមិញ គេមិនអាចកែនប្រជាជាតិមួយឱ្យទៅធ្វើសង្គ្រាមមួយដែលគេសារភាពប្រាប់តាមត្រង់ថា ជាសង្គ្រាមអយុត្តិធម៌ផ្ទុយពីសីលវិជ្ជានោះបានឡើយ!

ក្នុងន័យនេះតើយើងត្រូវសន្និដ្ឋានថាកម្លាំង និងច្បាប់ជាញាណពីរដាច់គ្នា ឌុសគ្នាស្រឡះឬអ្វី? តើយើងត្រូវគិតថាយើងគ្រាន់ដឹងថាខ្លួនមានសិទ្ធិត្រឹមត្រូវសព្វគ្រប់ជាការស្រេចហើយក្នុងករណីនេះ ឈ្នះឬចាញ់ពុំមែនជាកត្តាសំខាន់ទេឬអ្វី? ប៉ុន្តែសិទ្ធិមួយដែលបិតនៅក្នុងគំនិតដោយឥតខំធ្វើខ្លួនឱ្យក្លាយទៅការពិតជាក់ស្តែងសោះ មិនគឺអ្វីក្រៅពីការយល់សប្តិនោះឡើយ។

ពិតហើយ ការគិតថា សិទ្ធិគឺជាកម្លាំងដែលឈ្នះគេ ជាគំនិតដែលប្រកាន់យកសីលវិជ្ជានៃអំពើឃោរឃៅមួយដែលគ្មានសីលលក្ខណៈអ្វីទាល់តែសោះ។ ប៉ុន្តែផ្ទុយទៅវិញបើការប្រកាន់យកទ្រឹស្តីមួយ ដែលជាឧត្តមគតិសុទ្ធសាធគឺពិតជាធ្វើឱ្យតម្លៃលត់លោយទៅក្នុងការយល់សប្តិប្រាកដណាស់។ គ្រប់សិទ្ធិទាំងអស់ខិតខំធ្វើយ៉ាងណាឱ្យមានជាប់នឹងខ្លួននូវ «កម្លាំងខាងផ្លូវច្បាប់»។ ចំពោះតថភាពសីលវិជ្ជាមិនត្រូវនៅត្រឹមតែការរវើរវាយមួយគ្មានរូបរាងពិតប្រាកដឡើយ ប៉ុន្តែសីលវិជ្ជាត្រូវនៅជាតំណាងពិតប្រាកដនៃតម្លៃដែលមាននៅក្នុងតថភាព។

ការនិយាយរបៀបនេះបង្កើតជាបញ្ហាមួយដែលមានភាពស្មុគស្មាញពន់ ប្រមាណ។ ប្រសិនបើសិទ្ធិត្រឹមត្រូវពិតប្រាកដត្រូវមានរូបរាងឡើងជាអំពើ តើយើងត្រូវទទួលយល់ព្រមឱ្យមានការប្រយុទ្ធប្រឆាំងនឹងអំពើអយុត្តិធម៌និងឃោរឃៅដែរឬអ្វី? យើងគួរកត់សម្គាល់ថាឧត្តមគតិនៃអហិង្សាសុទ្ធសាធប្រហែលជាការស្រមៃរវើរវាយប៉ុណ្ណោះ។ ឧត្តមគតិនេះពុំអាចនឹងមានរូបរាងឡើងដោយគ្មានទំនាស់ឡើយ៖ ជាការពិតណាស់ ចំពោះខ្លួនយើងផ្ទាល់ យើងមានសិទ្ធិនឹងបណ្តោយបច្ចាមិត្តអយុត្តិធម៌សម្លាប់ដោយគ្មានតដៃបន្តិចបន្តួចសោះ។ ប៉ុន្តែបើយើងមិនចូលទៅជួយមិត្តរបស់យើងដែលត្រូវគេធ្វើបាប យើងនឹងមានឈ្មោះថាជាសមគំនិតជាមួយអ្នកធ្វើបាបមិត្តយើង។ បើយើងប្រកាន់យកអហិង្សានៅក្នុងពិភពមួយដែលអំពើឃោរឃៅមានរូបរាងជាការពិតជាក់ស្តែង យើងនឹងទៅជាអ្នកសមគំនិត ដោយដឹងខ្លួនក្តីឬដោយមិនដឹងខ្លួនក្តី ជាមួយមនុស្សកំរោលកាចសាហាវ ដែលរស់សប្បាយក្នុងអំពើឃោរឃៅរបស់ខ្លួន។

ជាពិតហើយ ការធ្វើឱ្យអំពើកំរោលប្រើកម្លាំងបាយ មានលក្ខណៈត្រឹមត្រូវតាមច្បាប់អាចធ្វើទៅបានតែនៅក្នុងករណីមួយពិសេសណាស់ ព្រោះគេពុំអាចដោះសាពន្យល់អំពីភាពត្រឹមត្រូវនៃការធ្វើឱ្យបានសម្រេចនូវសីលគោលបំណងមួយតាមមធ្យោបាយផ្ទុយនឹងសីលវិជ្ជាបានឡើយ។ ពិតមែនហើយថា ម៉ាក្យាវែល (Machiavel) បានគិតថានៅក្នុងវិស័យនយោបាយ(ដែលអំពើតែងតែប៉ះពាល់ដល់ផលប្រយោជន៍សំខាន់ៗនៃប្រជាជាតិទាំងមូល) គោលបំណងដែលស្របទៅតាមសិទ្ធិត្រឹមត្រូវអាចធ្វើឱ្យមធ្យោបាយអាក្រក់យ៉ាងណាក៏ដោយ ដែលគេប្រើដើម្បីសម្រេចគោលបំណងនោះ មានភាពត្រឹមត្រូវសមរម្យជានិច្ច។ ប៉ុន្តែមតិរបស់ ម៉ាក្យាវែល ផ្អែកលើ ប៉ូស្ទុយឡា (postulat) ដែលថា «មនុស្សសុទ្ធតែអាក្រក់ទាំងអស់» «កាចផង» «រមិលគុណផង» «ប្រែប្រួល» «លាក់ពុត» «លោភលន់គ្មានទីបញ្ចប់»។ ក្នុងករណីនេះជាការត្រឹមត្រូវណាស់ដែលអំពើឃោរឃៅនៃអ្នកនយោបាយត្រូវមានជាចាំបាច់ «ពីព្រោះមនុស្សសុទ្ធតែអាក្រក់ទាំងអស់»។ អ្នកកាន់អំណាចដែលមិនព្រមប្រើអំណាចផ្តាច់ការមិនអាចចៀសវាងរួចពីមហន្តរាយផ្ទាល់ខ្លួន និងពីមហន្តរាយរបស់ប្រទេសខ្លួនបានឡើយ «ពីព្រោះអ្នកណាដែលតាំងខ្លួនជាមនុស្សប្រកបដោយគុណធម៌សុទ្ធសាធនៅក្នុងចំណោមអ្នកឯទៀតដែលពុំមែនជាមនុស្សល្អពុំអាចចៀសរួចពីមហន្តរាយផ្ទាល់ខ្លួនជាដាច់ខាត»។

ទស្សនបែបនេះមានគ្រោះថ្នាក់ពន់ពេកណាស់។ អំពើឃោរឃៅនឹងក្លាយទៅជាមធ្យោបាយស្រួល ហើយងាយជាទីបំផុត តែអាចអនុញ្ញាតឱ្យប្រើអំពើនេះបានតែក្នុងករណីណាដែលគេមានភស្តុតាងច្បាស់ថា «មធ្យោបាយឯទៀតៗ ដែលមានលក្ខណៈផ្ទុយនឹងសីលវិជ្ជាតិចជាងអំពើនេះ ពុំអាចមានប្រសិទ្ធិភាពបានឡើយ។ ហើយជាពិសេសទៅទៀតសូមយើងកុំភ្លេចថា លក្ខណៈផ្ទុយនឹងសីលវិជ្ជានៃមធ្យោបាយនឹងជិះឥទ្ធិពលជាចាំបាច់ទៅលើគោលដៅតែម្តង ពីព្រោះសីលអំពើមិនអាចនឹងបែងចែកបានឡើយ។ ការប្រើនូវអំពើឃោរឃៅ ទោះជាក្នុងករណី

ណាក៏ដោយ ក៏គឺជាការប្រកាសនូវកង្វះសមត្ថភាពរបស់អ្នកប្រតិបត្តិសីលវិជ្ជាក្នុងការធ្វើឱ្យបានការសម្រេចពិតប្រាកដនូវតម្លៃនានាដែរ។

សរុបសេចក្ដីទៅ ទ្រឹស្ដីដែលយល់ថាច្បាប់បិតនៅលើកម្លាំង គឺជាទ្រឹស្ដីដែលបដិសេធច្បាប់តែម្ដង។ ដូចយើងបានឃើញរួចមកហើយថា ធាតុពិតនៃច្បាប់គឺជាសីលអំណាចមួយ គោលគឺអំណាចខាងផ្នែកគំនិត។ ការទាញច្បាប់ឱ្យធ្លាក់មកនៅត្រឹមតែជាអំណាចរួម គឺជាការប្រកែកមិនព្រមទទួលស្គាល់ថា នៅពីលើទំនាក់ទំនងនៃកម្លាំងនេះមានរបបឧត្តមគតិមួយដែលមានកម្រិតខ្ពស់ជាងទំនាក់ទំនងទាំងនោះ ដូចនេះ គឺបដិសេធច្បាប់តែម្ដង។

### ៧.៣.៣ ច្បាប់និងសេចក្ដីត្រូវការ

អ្នកនិពន្ធខ្លះទៀតយល់ថា សេចក្ដីត្រូវការជាមូលដ្ឋាននៃច្បាប់។ នេះគឺជាអ្នកទ្រឹស្ដីរបស់អ្នកទស្សនវិជ្ជាជាតិអង់គ្លេសឈ្មោះ ហុប( Hobbes: 1588-1679 )។ តាម ហុប មនុស្សនៅក្នុងសភាពធម្មជាតិបណ្ដោយឱ្យតែសភាវគតិរក្សាជីវិតដឹកនាំ ហើយមនុស្សមានសិទ្ធិនឹងធ្វើអ្វីទាំងអស់ ដើម្បីបំពេញសេចក្ដីត្រូវការរក្សាជីវិតខ្លួនឱ្យគង់វង់នេះ។ សិទ្ធិនេះគ្មានព្រំដែនហើយដាច់ខាត។ ប៉ុន្តែ នៅក្នុងការពិតជាក់ស្ដែង មនុស្សពុំអាចប្រើសិទ្ធិនេះបានឡើយ ពីព្រោះកាលបើសិទ្ធិរបស់ខ្លួនទូលំទូលាយគ្មានព្រំដែនដូចនេះទៅមនុស្សទាំងអស់ ដោយមានសេចក្ដីត្រូវការដូចគ្នាក៏ក្លាយទៅជាសត្រូវចំពោះគ្នាទៅវិញទៅមក «មនុស្សជាឆ្កែចចកចំពោះមនុស្សដូចគ្នា»ហើយសភាពធម្មជាតិគឺសភាពនៃ «ចំបាំងរវាងគ្នាទៅវិញទៅមក» មិនចេះចប់។ វិចារណញ្ញាណបាននាំមនុស្សឱ្យលះបង់សិទ្ធិធម្មជាតិរបស់ខ្លួនទៅក្នុងកណ្ដាប់ដៃនៃព្រះមហាក្សត្រមួយអង្គ។ ដើម្បីរក្សាអំណាចរបស់ព្រះអង្គ មហាក្សត្រត្រូវរៀបចំឱ្យមានសន្តិភាពដោយតែងតាំងជាច្បាប់ឡើង។

ទ្រឹស្ដីអាល្លឺម៉ង់អំពី «ទីកន្លែងរស់នៅ»ក៏មានមូលដ្ឋានផ្អែកលើសញ្ញាណនៃសេចក្ដីត្រូវការនេះដែរ៖ ប្រជាជាតិមួយមានសិទ្ធិអាចពង្រីកទឹកដីរបស់ខ្លួនរស់នៅទៅតាមសេចក្ដីត្រូវការចាំបាច់របស់ខ្លួន។ អ្នកទ្រឹស្ដីខាងសង្គមខ្លះទៀតបានប្រកាន់យកទុកជាគោលការណ៍នៃការបែងចែកទ្រព្យសម្បត្តិនូវរូបមន្តៈ «ម្នាក់ៗមានសិទ្ធិត្រូវបានទៅតាមសេចក្ដីត្រូវការរបស់ខ្លួន»។

### សិក្សារិះគន់

បើមើលមួយភ្លែត មតិនេះហាក់មានភាពទន់ភ្លន់ និងទិដ្ឋភាពពិតច្រើនជាងមុន។ ឧទាហរណ៍ ដូចជាការឱ្យឈ្នួលការងារដោយគិតទៅតាមសេចក្ដីត្រូវការពិតប្រាកដនៃកម្មករតាមអ្នកនោះនៅលីវឬមានគ្រួសារ គ្មានកូនឬជាមេគ្រួសារដែលមានកូនច្រើន។ គេបានធ្វើឱ្យសម្រេចភាគខ្លះទៅហើយមានការឱ្យប្រាក់បំណាច់សម្រាប់បន្ទុកគ្រួសារ ហើយនិងការបង្កើតឱ្យមានបេឡាសម្រាប់ជួសជុលសោហ៊ុយជាដើម។ ប៉ុន្តែទាំងនេះពុំទាន់មានលក្ខណៈ គ្រប់គ្រាន់ និងដាក់សេចក្ដីត្រូវការឱ្យទៅជាមូលដ្ឋាននៃច្បាប់បាននៅឡើយ។

ដំបូងយើងអាចសម្គាល់បានថា សេចក្ដីត្រូវការ តាមពិតគ្រាន់តែជាការណ៍សាមញ្ញមួយដូចជាកម្លាំងដែរ។ ដូចនេះ សេចក្ដីត្រូវការមិនអាចនឹងលើកឱ្យទៅជាតម្លៃបានឡើយ។

ម្យ៉ាងទៀត សេចក្ដីត្រូវការប្រែប្រួលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ហើយគ្មានលក្ខណៈទៀងទាត់សោះ។ និយាយម្យ៉ាងទៀតថា មនុស្សទាំងអស់ពុំមានសេចក្ដីត្រូវការដូចគ្នាឡើយ។ បុគ្គលម្នាក់ ប្រជាជាតិមួយ អាចនឹងមានសេចក្ដីត្រូវការផ្សេងៗហួសប្រមាណហួសហេតុ។ ក្នុងន័យនេះ យើងអាចចែកសេចក្ដីត្រូវការនេះជាពីរប្រភេទ គឺសេចក្ដីត្រូវការស្របច្បាប់ និងសេចក្ដីត្រូវការមិនស្របច្បាប់នេះជាភ័ស្តុតាងជាក់ស្ដែងដែលបង្ហាញថា សេចក្ដីត្រូវការពុំមានដោយខ្លួនឯងនូវគោលការណ៍នៃការឱ្យតម្លៃដល់ខ្លួនឡើយ។

សរុបសេចក្ដីទៅសេចក្ដីត្រូវរបស់បុគ្គលក៏ដូចជាសេចក្ដីត្រូវរបស់សហគមន៍ដែរ ពុំមែនសុទ្ធចុះសម្រុងគ្នាជាដរាបនោះទេ។ ហើយកាលបើសេចក្ដីត្រូវការទាំងនោះប្រឆាំងគ្នាទៅវិញទៅមកនោះ វាច្បាស់ណាស់ថា (ព្រោះគេ

មិនទទួលស្គាល់ថាមាននិយាមណាមួយប្រសើរឧត្តមជាងសេចក្តីត្រូវការអស់នោះឡើយ) មានតែកម្លាំងមួយមុខប៉ុណ្ណោះ ដែលអាចនឹងសម្រេចបាន។

ដូចនេះ គេធ្លាក់ចូលទៅក្នុងទ្រឹស្តីមុនដដែល ហើយការពិតនោះគឺលទ្ធិរបស់ហុបនាំទៅរកអំណាចផ្តាច់ការទ្រឹស្តីអំពើ «ទីកន្លែងរស់នៅ» ទៅរកចំបាំង រូបមន្ត «ម្នាក់ៗមានសិទ្ធិត្រូវបានទៅតាមសេចក្តីត្រូវការរបស់ខ្លួន» ទៅរករបប«សង្គមគ្មានច្បាប់ រស់នៅលួចឆក់គ្នាតាមចិត្ត»។

**៧.៣.៤ ច្បាប់និងប្រយោជន៍**

អ្នកទស្សនវិជ្ជាខ្លះទៀតបានយកប្រយោជន៍ធ្វើជាមូលដ្ឋាននៃច្បាប់។ ស្តាតមីល បានសរសេរថា៖ «មានសិទ្ធិគឺមានអ្វីមួយដែលសង្គមត្រូវធានារ៉ាប់រងនូវការកាន់កាប់ចំពោះយើង»។ ប្រសិនបើគេសួរថា៖ «ហេតុអ្វីបានជាសង្គមត្រូវធានារ៉ាប់រងនូវការកាន់កាប់អ្វីមួយចំពោះយើង?» យើងអាចឆ្លើយយ៉ាងខ្លីថា៖ "ព្រោះប្រយោជន៍រួម"។ អ្នកតំណាងទ្រឹស្តីប្រយោជន៍និយមសំខាន់ជាងគេគឺ រ.វ៉ុនសេរិង(R.Von Jhéring)។ រ.វ.សេរិង យល់ថាច្បាប់គឺជាបំណកស្រាយអត្តទត្ថភាពរួមនៃប្រជាជាតិមួយ។ ដូចប្រវត្តិសាស្ត្រនៃច្បាប់រ៉ូម៉ាំងបានបង្ហាញស្រាប់៖ គឺបុគ្គលអ្នកដឹកនាំរដ្ឋអ្នកដឹកនាំប្រជាជាតិដែលជាអ្នកបង្កើតច្បាប់មែនទែន។ អ្នកដឹកនាំទាំងនេះស្គាល់ច្បាស់ជាងអ្នកណាទាំងអស់នូវការចាំបាច់ចម្បងនៃប្រយោជន៍រួម ហើយស្របទៅតាម ឆន្ទៈដ៏ឈ្លាសវៃរបស់គេបានធ្វើពលិកម្មនៅអ្វីៗទាំងអស់ដើម្បីច្បាប់ដ៏ឧត្តមបំផុតនេះ។

**សិក្សារិះគន់**

មតិនេះបានលើកឡើងនូវបញ្ហាដូចគ្នានឹងមតិមុន ដែលអះអាងចង់យកសេចក្តីត្រូវការធ្វើជាមូលដ្ឋាននៃច្បាប់ដែរ។ ពិតប្រាកដហើយមតិនេះមានទំនងហាក់ដូចជាពិតច្រើនដូចមតិមុនដែរ។គេអាចអះអាងបានថាបើគេលាតវិសាលភាពនៃប្រយោជន៍ឱ្យកាន់តែធំឡើងៗនោះ ប្រយោជន៍ដែលរីកសាយនេះក៏ខិតទៅជិតច្បាប់ជិតឡើងៗស្របគ្នាទៅតាមនោះដែរជាការប្រាកដណាស់ ច្បាប់មិនអាចច្រឡំគ្នាបានជាមួយនឹងប្រយោជន៍ផ្ទាល់របស់បុគ្គលម្នាក់ៗឡើយ។ ប៉ុន្តែនៅទីបំផុតទៅ តើច្បាប់អាចនឹងច្រឡំគ្នាបានជាមួយនឹងប្រយោជន៍រួមដែរឬយ៉ាងណា? មកដល់កន្លែងនេះ យើងជួបនូវភាពមិនច្បាស់លាស់មួយ ដែលអាចយើងមានការយល់ច្រឡំហើយដែល ស៊ីសេរ៉ុង (Cicéron) បានលើកមកវែកញែកទាញអារម្មណ៍ដូចតទៅ៖ «ពិតមែនហើយគ្មានអ្វីដែលមានប្រយោជន៍ ហើយពុំមានលក្ខណៈល្អតាមសីលវិជ្ជាផងដែរនោះទេ។ ប៉ុន្តែពុំមែនមកពីវត្ថុមួយមានប្រយោជន៍ ទើបវត្ថុនោះល្អនោះទេ គឺពិតជាផ្ទុយទៅវិញ មកពីវត្ថុនោះមានលក្ខណៈល្អតាមសីលវិជ្ជាទើបបានជាវត្ថុនោះមានប្រយោជន៍»។ តាមការពិត ប្រយោជន៍ ក៏ដូចជាសេចក្តីត្រូវការដែរគឺគ្រាន់តែជាសញ្ញាណមួយយ៉ាងសាមញ្ញដែលមិនអាចនឹងបង្កើតនូវតម្លៃបានឡើយ។ កាលណាខ្ញុំនិយាយថា៖ «គឺជាសិទ្ធិរបស់ខ្ញុំ» ខ្ញុំពិតជាចង់និយាយអំពីអ្វីដែលពុំមានន័យថា៖ «គឺជាប្រយោជន៍របស់ខ្ញុំ» នោះឡើយ។ ហើយទោះជាន័យនៃឃ្លាទាំងពីដូចគ្នាក៏ដោយ(យើងត្រូវទទួលស្គាល់ថាគឺនៅក្នុងករណីនេះឯងតែម្តងដែលយើងច្រើនតែទាមទាររកសិទ្ធិរបស់យើង)ក៏នៅពេលនោះយើងមានសញ្ចេតនាចង់លើកយកមកជាសំអាងនូវនិយាមដែលមានកម្រិតខ្ពស់លើសយើង ហើយដែលពុំអាចបន្ថយតម្លៃខ្លួន មកត្រឹមតែការគិតគូរសុទ្ធសាធអំពីប្រយោជន៍ខាងផ្នែកសម្ភារឡើយ។ ពិសោធន៍រាល់ថ្ងៃបានបង្ហាញឱ្យយើងឃើញយ៉ាងច្បាស់នូវទំនាស់ ដែលអាចកើតមានឡើងបានរវាងប្រយោជន៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ និងប្រយោជន៍រួម និងរវាងប្រយោជន៍ទៅវិញទៅមកនៃក្រុមផ្សេងៗ។ល។នៅក្នុងករណីដែលមានទំនាស់ យើងចោទឡើងវិញនូវសំណួរដែលយើងធ្លាប់បានចោទចំពោះសេចក្តីត្រូវការថាតើនរណាទៅជាអ្នកសម្រេច? បើគេបដិសេធមិនព្រមពឹងផ្អែកទៅលើកម្លាំងសុទ្ធសាធនោះជាដាច់ខាតគេត្រូវឱ្យតម្លៃដល់ប្រយោជន៍ខ្លះ ក្នុងបណ្តាប្រយោជន៍ទាំងនោះ ក្នុងនាមនៃគោលការណ៍មួយដែលឧត្តមជាងប្រយោជន៍ទាំងនោះ។ ឧទាហរណ៍៖ ប្រសិនបើមានទំនាស់រវាងប្រយោជន៍វណ្ណៈនិងប្រយោជន៍ជាតិ យើងតែងទុកប្រយោជន៍ជាតិធំជាងប្រយោជន៍វណ្ណៈ នេះគឺមកពីយើងឱ្យទៅជាតិនូវតម្លៃមួយឧត្តមជាងតម្លៃនៃវណ្ណៈនេះឯង។

ដូចនេះ ច្បាប់ដែលជាសីលម្លៃមួយ មិនអាចប្រទ្បាំជាមួយនឹងប្រយោជន៍សាមញ្ញបានឡើយ។

### ៧.៣.៥ ទស្សនៈសង្គមវិទ្យានិយមនៃច្បាប់

អ្នកសង្គមវិទ្យានិយមតាមទ្រឹស្តី ដួខិម បានយល់ឃើញថា ច្បាប់ក៏ដូចជាសីលតម្លៃឯទៀតដែរ គឺជា «ផល» បានមកពីសង្គម។ ការសិក្សាជាក់លាក់ពីវិវត្តន៍នៃច្បាប់ បានបង្ហាញឱ្យឃើញថា ច្បាប់ឋិតនៅក្នុងដំណាក់ការដំបូង យ៉ាងច្របូកច្របល់លាយឡំជាមួយនឹងសង្គមផ្សេងៗជាមួយនឹងរីតសាសនា។ល។ បន្ទាប់មកច្បាប់នេះមានលក្ខណៈច្បាស់ឡើងៗ។ ជាទម្លាប់ប្រពៃណីបែបនីតិវិធីរួចក្លាយខ្លួនទៅជាច្បាប់លាយល័ក្ខអក្សរ។ បន្តិចម្តងៗ ច្បាប់ដែលពីដើមអនុវត្តតែទៅលើមនុស្សមួយក្រុមៗ ក៏មានលក្ខណៈទាក់ទងជិតស្និទ្ធខ្លាំងឡើងៗទៅនឹងបុគ្គលទៅវិញ ហើយរូបមន្តនីតិវិធីដែលពីដើមជារូបមន្តមានលក្ខណៈអច្ឆរិយៈ ក៏បានយកចិត្តទុកដាក់ខ្លាំងឡើងៗទៅលើឆន្ទៈនិងការប្រព្រឹត្តផ្សេងៗរបស់បុគ្គលម្នាក់ៗដែរ។ គឺដោយ «យកញាណរបស់បុគ្គលម្នាក់ៗធ្វើជាព្រះវិហារ» នេះហើយដែលច្បាប់បានទទួលនូវលក្ខណៈសីលវិជ្ជាពេញលេញ។ ដូចនោះឃើញថាសង្គមដែលជាប្រភពនៃតម្លៃគ្រប់បែបយ៉ាងគឺពិតជាប្រភពនៃច្បាប់នៃកម្រងតម្លៃទាំងឡាយដែលគេទទួលស្គាល់ និងចាត់ទុកជាទីសក្ការៈជាឧត្តមគតិតែម្តង។

តាមពិត ទ្រឹស្តីសង្គមវិទ្យានិយមបានសម្រេចសម្រួលឱ្យចុះសម្រុងនូវតថភាពនិយម និងឧត្តមគតិនិយមនៃច្បាប់៖ «ឧត្តមគតិនៃច្បាប់យល់ថា តម្លៃទាំងឡាយមានមកជាមួយនឹងកំណើតមនុស្សគឺធម្មជាតិរបស់មនុស្ស។ ចំណែកឯទ្រឹស្តីសង្គមវិទ្យានៃច្បាប់យល់ផ្ទុយទៅវិញថាតម្លៃទាំងឡាយពុំមែនជាធម្មជាតិរបស់មនុស្សទេតែគឺជាបំណានដែលមនុស្សបានមកបន្តិចម្តងៗក្នុងដំណើរទៅមុខដ៏វែងឆ្ងាយនៃប្រវត្តិសាស្ត្រ ដែលមានឈ្មោះច្បាស់ថា «អរិយធម៌» នោះឯង... សិទ្ធិរបស់បុគ្គល ការមិនអាចរំលោភបានយុត្តិធម៌ ការគោរពចំពោះកិច្ចសន្យា ទាំងនេះគឺពិតជារង្វាយដណ្តើមដ៏លំបាកនិងយូរលង់របស់មនុស្សជាតិទៅលើខ្លួនឯងប្រាកដណាស់»(ស.ដាវី G.Davy)។

**សិក្សារិះគន់**

មតិនេះអាចនឹងពន្យល់លក្ខណៈខ្លះរបស់ច្បាប់ ហើយជាពិសេសវិវត្តន៍របស់ច្បាប់តែម្តង។ប៉ុន្តែ ដួខិម ខ្លួនឯងក៏បានថ្លែងដែរថាសង្គមពិតប្រាកដតែង «ពេញទៅដោយគុណវិបត្តិនិងអសុក្រឹតភាព»។ ដូចនោះ ប្រភពនៃតម្លៃគឺសង្គមឧត្តមគតិដែលដួខិមបានឱ្យតម្លៃ និងលើកតម្កើងស្មើនឹងអាទិទេពដោយទុកសង្គមជាប្រភពនៃតម្លៃទាំងអស់។ រីឯសង្គមមែនទែនគឺពិតជាឧបករណ៍នៃការកំណត់តម្លៃជាជាងប្រភពនៃតម្លៃ។

### ៧.៣.៦ មូលដ្ឋាននៃច្បាប់

តើមូលដ្ឋាននៃច្បាប់ឋិតលើអ្វី?

ដំណោះស្រាយនៃបញ្ហានេះត្រូវតែស្វែងក្នុងបញ្ញត្តិកម្មវិចារណញ្ញាណនិយម។ វិចារណញ្ញាណក្នុងឋានៈខ្លួនជាអំណាចបង្កើតនូវរបៀប និងជាអំណាចបង្កើតនិយាម គឺជាប្រភពពិតប្រាកដនៃតម្លៃ។ ដូចនេះ វិចារណញ្ញាណក៏ជាប្រភពនិងជាមូលដ្ឋានរបស់ច្បាប់ដែរ ប៉ុន្តែបើករណីយកិច្ចគ្មានអ្វីក្រៅពីតម្លៃដែលជាកាតព្វកិច្ចរបស់យើង បើកុសលជាតម្លៃដែលទាក់ទាញយើង ច្បាប់គឺជាតម្លៃដែលបើកអំណាចឱ្យដែលធ្វើឱ្យអំពើរបស់យើងមានលក្ខណៈត្រឹមត្រូវតាមច្បាប់និងធ្វើឱ្យលក្ខខណ្ឌ នៃអំពើនោះអាចឆ្លើយស្របទៅតាមសីលវិជ្ជាបាន។ ក្នុងន័យនេះគ្មានអ្វីជាការចម្លែកទេដែលវិវត្តន៍របស់ច្បាប់បានត្រូវធ្វើឡើងក្នុងន័យនៃការទទួលស្គាល់សេចក្តីថ្លៃថ្នូររបស់មនុស្ស តម្លៃខ្ពស់បំផុតក្នុងបណ្តាតម្លៃឯទៀតៗ។

## ៧.៤ ច្បាប់និងករណីយកិច្ច

ច្បាប់និងករណីយកិច្ច តាងនូវទិដ្ឋភាពពីរនៃតម្លៃដែលបង្គ្រប់គ្នាទៅវិញទៅមក។ គេអាចកត់សម្គាល់ថាភាពទាក់ទងគ្នាទៅវិញទៅមករវាងច្បាប់និងករណីយកិច្ចនេះមានលក្ខណៈជិតស្និទ្ធចាំបាច់ណាស់។ កាតព្វកិច្ចរបស់អ្នកដទៃចំពោះខ្ញុំគឺជាចម្លើយចំពោះសិទ្ធិរបស់ខ្ញុំ ផ្ទុយទៅវិញកាតព្វកិច្ចរបស់ខ្ញុំចំពោះអ្នកដទៃគឺចម្លើយតបនឹងសិទ្ធិរបស់អ្នកដទៃវិញ។ កម្មករមានសិទ្ធិនឹងទាមទារអំពីនិយោជិករបស់ខ្លួននូវ«ប្រាក់ខែអប្បបរមាអន្តរវិជ្ជាជីវៈដែលត្រូវបាន

ជានា» ហើយនិងវិស្សមកាលបីសប្តាហ៍។ និយោជកមានករណីយកិច្ចនឹងបើកប្រាក់ខែ និងអនុញ្ញាតវិស្សមកាលនោះដល់កម្មករ។ ប៉ុន្តែនិយោជកនោះមានសិទ្ធិនឹងតម្រូវឱ្យកម្មករនេះមកធ្វើការប្រចាំសប្តាហ៍ចំនួន 40 ម៉ោងនៅក្នុងរោងជាងហើយកម្មករមានករណីយកិច្ចត្រូវប្រតិបត្តិតាមចំនួនម៉ោងនិងពេលម៉ោងធ្វើការនោះ។ គេអាចនឹងបង្កើនចំនួនឧទាហរណ៍បែបនេះបានដោយងាយ។ បើខ្ញុំត្រូវគេចោទនៅក្នុងកាសែតមួយ ខ្ញុំមានសិទ្ធិនឹងឆ្លើយដោះសារដោយសរសេរទៅចាងហ្វាងកាសែត ដែលគេហៅថា "សិទ្ធិឆ្លើយតប" ហើយចាងហ្វាងការសែតក៏មានករណីយកិច្ចនិងចុះផ្សាយចម្លើយរបស់ខ្ញុំនៅក្នុងកាសែតលេខបន្ទមកទៀតដែរ។ បើខ្ញុំមានករណីយកិច្ច និងសិក្សាសង្គមត្រូវជួយសម្រួលមធ្យោបាយឱ្យខ្ញុំ។

ប៉ុន្តែ តើគេត្រូវបកស្រាយទំនាក់ទំនងទៅវិញទៅមករវាងសិទ្ធិ និងករណីយកិច្ចនេះយ៉ាងដូចម្តេច?

អូគុសកុង (Auguste Comte) ក្រោយពីបានធ្វើការពិចារណាមក បានឱ្យយោបល់ថាគេអាចលុបបំបាត់សិទ្ធិចោលបានដោយគ្មានខូចប្រយោជន៍អ្វីឡើយ ហើយគេទុកតែករណីយកិច្ចមួយមុខប៉ុណ្ណោះសម្រាប់ឱ្យមនុស្សបំពេញក៏ជាការគ្រប់គ្រាន់ណាស់ទៅហើយព្រោះថា«កាលបើមនុស្សបំពេញករណីយកិច្ចរបស់ខ្លួនចំពោះគ្នាទៅវិញទៅមកបានល្អត្រឹមត្រូវហើយ «សិទ្ធិ» របស់ជនទាំងអស់ក៏នឹងមានការធានាដោយមិនចាំបាច់រំឭកអំពីសិទ្ធិនេះឡើយ»។ តាមកុង គេគួរតែកុំរំឭកអំពើសិទ្ធិឱ្យសោះ ព្រោះម្នាក់ៗតែងតែមានសញ្ចេតនាយ៉ាងមុះមុតទៅលើសិទ្ធិរបស់ខ្លួន ហើយក្នុងនាមសិទ្ធិនេះគេតែងចង់ទាមទារឱ្យបានច្រើនហួសអ្វីដែលខ្លួនត្រូវបានជានិច្ច។ ឆន្ទៈចង់ត្រួតត្រាគេ ចង់ពង្រីកអំណាចរបស់ខ្លួន អត្តទត្ថភាពនិងចំណង់បានខ្លាំង អាចមានសំអាងយ៉ាងស្រួលបំផុតទៅលើ «សិទ្ធិ» ប្រកបទៅដោយគ្រោះថ្នាក់នេះ ហើយលើកយកមកធ្វើជាលេសសម្រាប់អាងយ៉ាង ក្អេងក្អាងក្រអើតក្រទមទៅទៀតផង។ ដូចនេះ យើងគួរតែនិយាយអំពើករណីយកិច្ចរបស់យើងចំពោះអ្នកដទៃវិញ ហើយកុំនិយាយអំពីសិទ្ធិរបស់យើងធ្វើអ្វី ព្រោះខ្លាចក្រែងការនិយាយនេះផ្តល់សំអាងដល់ការទាមទារប្រយោជន៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗដែលជាហេតុបណ្តាលឱ្យមានគ្រោះថ្នាក់របៀបរៀបរយនៃសង្គមបាន។

ទស្សនៈនេះមិនអាចឱ្យគេទទួលបានឡើយ។ រូបមន្តដែលថែងដោយខ្វះការប្រុងប្រយ័ត្នៈ «មនុស្សមានសិទ្ធិតែម៉្យាង គឺសិទ្ធិបំពេញករណីយកិច្ចរបស់ខ្លួន» គឺជារូបមន្តនៃរបបផ្តាច់ការ។ រូបមន្តនេះនឹងនាំទៅរកលទ្ធិផ្តាច់ការដែលបុគ្គលត្រូវលិចកប់បាត់ទៅក្នុងសហគមន៍។ ផ្ទុយទៅវិញ គេគួរតែថែងថាៈ «ដោយសារមនុស្សមានតម្លៃចម្បងជាងគេ មនុស្សមានករណីយកិច្ចត្រូវការពារសិទ្ធិរបស់ខ្លួន»។ ហើយព្រមជាមួយនោះ «ប្រជាជាតិនីមួយៗក៏មានករណីយកិច្ចត្រូវការពារសិទ្ធិរបស់ខ្លួនដែរ»។ សិទ្ធិពិតប្រាកដជាតម្លៃមួយ។ ការមិនអើពើនឹងការពារសិទ្ធិរបស់ខ្លួនគឺជាការបណ្តែតបណ្តោយឱ្យតម្លៃមួយរលត់រលាយបាត់បង់ទៅ ដោយការធ្វេសប្រហែសដោយការខ្ជិលច្រអូស ឬក៏ដោយការខ្លាចកំសាកតែម្តង។

ដូចនេះ នៅក្នុងការអះអាងថា មានទំនាក់ទំនងទៅវិញទៅមករវាងករណីយកិច្ចនិងសិទ្ធនេះយើងនៅតែឱ្យសារៈសំខាន់ស្មើគ្នាទៅសិទ្ធិនិងទៅករណីយកិច្ចដដែល។ យើងយល់ថាៈ«សិទ្ធិរបស់អ្នកដទៃជាមូលដ្ឋាននៃករណីយកិច្ចរបស់យើងចំពោះគេ» ហើយ «ករណីយកិច្ចរបស់យើងចំពោះអ្នកដទៃជាមូលដ្ឋានសិទ្ធិរបស់គេមកលើយើង»៕

# មេរៀនទី៨ យុត្តិធម៌

## ៨.១ យុត្តិធម៌

ពាក្យយុត្តិធម៌សំដៅទៅលើឧត្តមគតិសកលផងទៅលើគុណធម៌នៃជនម្នាក់ៗផង។ គេអាចនិយាយអំពីយុត្តិធម៌ផង និងមនុស្សធម៌ផង។ ប៉ុន្តែ គំនិតនេះតែងបញ្ជាក់ឱ្យឃើញជានិច្ចនូវគំនិតនៃភាពត្រូវល្អិតល្អន់ស្របទៅតាមវិចារណញ្ញាណ។ មនុស្សយុត្តិធម៌ គឺមនុស្សប្រកបដោយគំនិតត្រឹមត្រូវ ស្ទើរតែមានលក្ខណៈជាទ្រឹស្តីបទគណិតវិទ្យាទៅហើយ មនុស្សនេះតែងបំពេញករណីយកិច្ចរបស់ខ្លួនដោយឥតខ្ចោះ។

យុត្តិធម៌អាចមានន័យថា«ការគោរពយ៉ាងទៀងទាត់នូវសិទ្ធិរបស់ជនម្នាក់ៗពោលគឺការបើកឱ្យជនម្នាក់ៗមានសិទ្ធិរបស់ខ្លួន»។ ដូចនេះភាពត្រូវល្អិតល្អន់នៃគណិតវិទ្យាតែងតែមានជានិច្ចនៅក្នុងសញ្ញាណនៃយុត្តិធម៌។ម្យ៉ាងទៀតគំនិតនៃយុត្តិធម៌ក៏ដូចជាសិទ្ធិដែរ មានមូលដ្ឋានផ្អែកទៅលើតម្លៃនមនុស្ស។

យុត្តិធម៌ប្រឆាំងនឹងទំនោរដ៏ខ្លាំងក្លានៃអត្តទត្តភាពមុនអ្វីៗទាំងអស់។ ដូចជា សូប៉ិនហាវ៉រ(Schopenhawer) បានមានប្រសាសន៍ថាមនុស្សម្នាក់ៗស្មានថាខ្លួនអាចរស់នៅបានតាមចិត្ត ពោលគឺខិតលើផលប្រយោជន៍អ្នកដទៃ ប៉ុន្តែយុត្តិធម៌ចូលមកលំអក់ដល់សញ្ចេតនា ដែលកើតឡើងដោយឯកឯងនៃជីវិតនេះដោយថែងថា ម្នាក់ៗត្រូវបានចំណែករៀងៗខ្លួន។ គេត្រូវតែគិតដល់អ្នកដទៃ ហើយចែកប្រយោជន៍ជាមួយអ្នកទាំងនោះតាមសមាមាត្រដ៏ត្រឹមត្រូវ (une juste proportion)។

## ៨.២ សណ្ឋានបីយ៉ាងនៃយុត្តិធម៌

តាំងពីសម័យលោក អារីស្តូត មកម្ល៉េះគេតែងសម្គាល់ឃើញថាមានយុត្តិធម៌បីសណ្ឋានគឺៈ យុត្តិធម៌ក្នុងការប្តូរ (justice commutative), យុត្តិធម៌ក្នុងការចែក (justice distributive) និងយុត្តិធម៌ក្នុងការបង្ក្រាប (justice répressive)។ នៅក្នុងយុត្តិធម៌មួយសណ្ឋានៗ យើងតែងប្រទះឃើញការតម្រូវនៃសមភាពនៃសមាមាត្រភាពស្របទៅតាមវិចារណញ្ញាណ។

### ៨.២.១ យុត្តិធម៌ក្នុងការប្តូរ

គឺជាយុត្តិធម៌ដែលជាអធិបតីនៃការប្តូរនិយាមរបស់យុត្តិធម៌នេះគេសមភាពនៃគណិតវិទ្យា។ ការប្តូរមួយអាចត្រឹមត្រូវបានលុះត្រាតែវត្ថុដែលគេប្តូរទៅមកទាំងពីរមានតម្លៃដូចគ្នា។ ពីក្រោយសមមូល(équivalence)តម្រូវទៅតាមយុត្តិធម៌នៃវត្ថុដែលគេប្តូរ យើងតែងសម្គាល់ឃើញថាមានសមភាពរវាងមនុស្សដែលជាអ្នកប្តូរ។ ដោយសារមនុស្សម្នាក់ៗមានសិទ្ធិដូចគ្នានេះហើយបានជាអ្នកប្តូរម្នាក់ៗមិនត្រូវខូចប្រយោជន៍ក្នុងការប្តូរនេះឡើយ។

### ៨.២.២ យុត្តិធម៌ក្នុងការចែក

នៅកន្លែងនេះ ការតម្រូវនៃសមភាពមានភាពផ្សេង ព្រោះថា វាហាក់ដូចជាអយុត្តិធម៌ បើគេឱ្យរង្វាន់ស្មើគ្នាទៅមនុស្សដែលមានសមត្ថភាពមិនស្មើគ្នា។ បេក្ខជនពូកែត្រូវទទួលពិន្ទុល្អចំណែកឯបេក្ខជនខ្សោយត្រូវទទួលពិន្ទុអាក្រក់។

### ៨.២.៣ យុត្តិធម៌ក្នុងការបង្ក្រាប

ទោះជាក្នុងភាពដើម និងក្នុងភាពសាមញ្ញបំផុតក៏ដោយ ក៏ការបង្ក្រាបរបស់យុត្តិធម៌តែងយកសមាមាត្រនៃគណិតវិទ្យាមកគិតដែរ។ ច្បាប់តាលីយុង(loi de Talion)«យកភ្នែកទៅសងភ្នែក ធ្មេញទៅសងធ្មេញ» គឺជាសមមូលមួយពិតប្រាកដ។ នៅក្នុងសណ្ឋានជឿនលឿនបំផុតនៃយុត្តិធម៌ក្នុងការបង្ក្រាបយើងជួបប្រទះការតម្រូវនៃសមភាពទៀត។

ពិតមែនតែអ្នកមានពិរុទ្ធមិនបានទទួលទោស ដែលមានធម្មជាតិដូចគ្នាសុទ្ធសាធនឹងកំហុសដែលខ្លួនបានធ្វើក៏ដោយ ក៏គេនៅតែថ្លឹងទម្ងន់ទោសនោះឱ្យបានស្មើនឹងទម្ងន់នៃកំហូចខាតដែរ។ នៅក្នុងការថ្លឹងនេះគេតែងយកពិរុទ្ធភាពនៃអ្នកប្រព្រឹត្តបទល្មើសមកពិនិត្យដែរដោយគេគិតថាតើអ្នកប្រព្រឹត្តបទល្មើសនោះប្រព្រឹត្តដោយឆន្ទៈឬទេ។

## ៨.៣ យុត្តិធម៌ និងសមភាពរវាងបុគ្គល

ចំពោះកំណត់សម្គាល់នេះក៏ដូចជាចំពោះភាពខុសគ្នារវាងសមភាពសុទ្ធសាធនៃយុត្តិធម៌ក្នុងការប្តូរ និងសមភាពសមាមាត្រនៃយុត្តិធម៌ក្នុងការចែកដែរ គេឃើញថាក្នុងការប្រតិបត្តិពិតប្រាកដ គោលការណ៍នៃសមភាពរវាងបុគ្គលអាចឱ្យគេយកមកអនុវត្តបានផ្សេងៗគ្នា។

ដូចនេះ យើងនឹងខិតខំសាកល្បងពិចារណាឱ្យល្អិតល្អន់អំពីសញ្ញាណនៃសមភាពរវាងបុគ្គលដែលគេទទួលស្គាល់ថាសំខាន់តែដែលគេមិនសូវស្គាល់ច្បាស់លាស់សោះ។

ការប្រកាសសិទ្ធិមនុស្សថ្លែងថា "មនុស្សទាំងអស់កើតឡើងមានសិទ្ធិស្មើៗគ្នា" យើងនឹងយករូបមន្តនេះមកពិចារណាឱ្យច្បាស់លាស់ ដើម្បីបំបាត់ការមន្ទិល។ គេមិនអះអាងថាមនុស្សទាំងអស់ស្មើគ្នាគ្រប់លក្ខណៈនោះទេ ប៉ុន្តែ ទោះជាមានភាពផ្សេងៗគ្នានិងវិសមភាពក្នុងការពិតក៏ដោយក៏មនុស្សទាំងអស់មានសិទ្ធិស្មើគ្នាដោយសារខ្លួនមានវិចារណញ្ញាណដែលជាសេចក្តីថ្លៃថ្នូរនៃមនុស្សទូទៅ។

វិសមភាពមែនទែនរវាងមនុស្ស គឺមួយផ្នែកជាវិសមភាពធម្មជាតិ ដូចជាវិសមភាពនៃកោសល្យនិងសម្បទា ឧទាហរណ៍៖ មនុស្សមានសុខភាពល្អឬមិនសូវល្អ បញ្ញាវៃឬមិនសូវវៃ លំនឹងនៃគំនិតទៀង ឬមិនសូវទៀង សីលចរិយាល្អឬមិនសូវល្អជាដើម។ ក្រៅពីមនុស្សយុត្តិធម៌និងសន្តបុគ្គលនៅមាន «មនុស្សខូចតាំងពីកំណើត»ដែរ។

មួយផ្នែកទៀតគឺវិសមភាពនិមិត្តដែលកើតឡើងដោយសារលក្ខខណ្ឌនៃសង្គមនិងដោយសារប្រាក់កាស(អ្នកខ្លះមានភោគផលសម្ភារៈយ៉ាងច្រើនមានពេលលំហែ អ្នកខ្លះទៀតស្ទើរតែគ្មានអ្វីបង្គ្រប់ការចាំបាច់ផង។ ក្នុងចំណោមមនុស្សដែលស្លាប់បួននាក់ក្នុងពិភពលោកឥឡូវនេះមានម្នាក់ស្លាប់ព្រោះតែការអត់ឃ្លានទៅហើយ)។ ស្ថាប័ននៃមរតកបញ្ចូលឱ្យមានវិសមភាពតាំងពីដើមទី ហើយជួនកាលស្ថាប័ននេះត្រូវបានប្រព័ន្ធនៃវណ្ណៈបន្ថែមធ្វើឱ្យរឹតតែខ្លាំងថែមទៀតជនម្នាក់ៗមិនអាចចេញពីវណ្ណៈដែលខ្លួនកើតបានឡើយ។

ដូចនេះអ្នកខ្លះត្រូវវេទនាតាំងពីដំបូងដោយសារភាពក្រីក្រចំណែកឯអ្នកខ្លះទៀត «គ្រាន់តែកើតឡើង» ក៏ត្រូវបានសប្បាយតែម្តង។ ទោះជានៅក្នុងសង្គមដែលគ្មានវណ្ណៈ គ្មានកម្មសិទ្ធិឯកជន គ្មានមរតកអ្វីក៏ដោយ ក៏វិសមភាពពីដើមទីនៅតែមានជានិច្ច។ យើងជឿជាក់ថាកូនរបស់ឧត្តមមន្ត្រីសូវៀតម្នាក់ ដោយបានទទួលគុណប្រយោជន៍អំពីផាសុកភាព និងអំពីកម្រិតវិជ្ជាខ្ពស់នៃមជ្ឈដ្ឋានរបស់គ្រួសារខ្លួន ច្បាស់ជាងាយមានជោគជ័យក្នុងជីវិតជាងក្មេងដែលឋិតនៅក្នុងគ្រួសារនៃអ្នកភ្ជួរកូកាស។

ឥឡូវនេះ បើយើងទទួលស្គាល់ថាវិសមភាពទាំងនេះមានមែន តើយើងអាចឱ្យតម្លៃទៅលើសមភាពបានដោយមធ្យោបាយណា?

ដំបូងរដ្ឋដែលកាន់លទ្ធិប្រជាធិបតេយ្យ មានបំណងចង់ឱ្យមានសមភាពនៃពលរដ្ឋគេត្រូវតែតម្រូវឱ្យពលរដ្ឋទាំងអស់ ទោះជានរណាក៏ដោយ ចូលទៅក្នុងប្រព័ន្ធតែមួយនៃសិទ្ធិនិងករណីយកិច្ច។ ឥឡូវនេះ ពលរដ្ឋម្នាក់ៗត្រូវមានករណីយកិច្ចចូលទៅបម្រើកងទ័ព។ ទោះក្រឬមាន អ្នកប្រព្រឹត្តទោសកម្មនឹងត្រូវគេប្តឹងឱ្យតុលាការជំនុំជម្រះដូចគ្នា។ ពលរដ្ឋម្នាក់ៗមានសិទ្ធិបោះឆ្នោត កុមារម្នាក់ៗមានសិទ្ធិចូលរៀនក្នុងគ្រឹះស្ថានបឋមសិក្សា។ បេក្ខជននៅក្នុងសម័យប្រឡងមួយត្រូវឋិតនៅក្នុងលក្ខខណ្ឌដូចគ្នា។ នេះជាសមភាពដែលគេឃើញច្បាស់ជាញឹកញយដោយសារអនាមិកភាពនៃកិច្ចការរបស់បេក្ខជន(កូនរដ្ឋមន្ត្រី ក៏ដូចជាកូនអ្នកបោសថ្នល់ដែរអាចប្រឡងធ្លាក់មធ្យមសិក្សាបត្រដូចគ្នា)។

ការតម្រូវនៃសមភាពនេះគ្មានបំណងនឹងធ្វើមនុស្សឱ្យដូចគ្នាទេឬក៏ធ្វើឱ្យកោសល្យនិងភាពខុសគ្នាពីធម្មជាតិមានកម្រិតស្មើគ្នាឡើយ។ ផ្ទុយទៅវិញក្នុងការ «ធ្វើឱ្យភ័ព្វសំណាងពីដើមទីស្មើគ្នា»គេចង់អនុញ្ញាតឱ្យម្នាក់ៗអាច

បញ្ចេញនិស្ស័យធម្មជាតិរបស់ខ្លួន។ គេជឿថានឹងមានយុត្តិធម៌ហើយនឹងមានគុណប្រយោជន៍សម្រាប់សហគមន៍ទាំងមូលបើឱ្យមនុស្សមានសមត្ថភាពច្រើនជាងគេមានមុខងារខ្ពស់ជាងគេ។ ជួនកាលវិវត្តន៍នៃតិចនិចនិងបញ្ហាសង្គមហើយនិងបញ្ហាជាតិតម្រូវឱ្យមានដូចនេះតែម្តង។

បើយុត្តិធម៌ក្នុងការចែកតម្រូវឱ្យបុគ្គលដែលមានលក្ខណៈមិនស្មើគ្នាពីធម្មជាតិរក្សាទុកដដែលនូវវិសមភាពរបស់ខ្លួនដូចជានាយករោងចក្រមានប្រាក់បៀវត្សច្រើនជាងកម្មករការបំបាត់អយុត្តិធម៌សង្គម និងការបំបាត់វិសមភាពនិមិត្ត មុខជានឹងធ្វើឱ្យឃើញកាន់តែច្បាស់ឡើងនូវភាពឃោរឃៅនៃវិសមភាពធម្មជាតិ។ នៅក្នុងពិភពមួយដែលប្រាក់កាស សេចក្តីគាប់គួរ ចៃដន្យមានគុណប្រយោជន៍ច្រើនម្នាក់ៗអាចលួងលោមចិត្តខ្លួនឯងអំពីភាពក្រីក្រនៃការរស់នៅរបស់ខ្លួនបាន ដោយចោទប្រកាន់អយុត្តិធម៌នៃមនុស្ស។ ក៏ប៉ុន្តែនៅក្នុងពិភពលោកមួយដែលមាន «យុត្តិធម៌» ដែលម្នាក់ៗអាចនៅកន្លែងរបស់ខ្លួនអាស្រ័យទៅតាមសម្បទាពិតប្រាកដ តើអ្នកដែលបានចំណែកតិចត្រូវតែអស់សង្ឃឹមឬទេ?

ចំពោះរឿងនេះគេអាចធ្វើកំណត់សម្គាល់បានពីរះ

- ដំបូងតាមការពិត វិសមភាពធម្មជាតិរវាងមនុស្ស ប្រហែលជាមិនសំខាន់ដូចយើងឃើញឥឡូវនេះទេ។ មិនដូចមតិរបស់ អាឡិចស៊ីសការ៉ែល(Alexis Carel)ដែលយល់ខុសស្របទៅតាមវណ្ណៈដែលមានឯកសិទ្ធិ ហើយដែលពន្យល់វិសមភាពនៃសង្គមនៅពេលបច្ចុប្បន្ននេះថា ចេញពីវិសមភាពធម្មជាតិនោះឡើយ(គាត់ហ៊ានរហូតដល់ទៅសរសេរថា «ឥឡូវនេះមនុស្សដែលជាអ្នកអធន ទទួលវណ្ណៈទាបរបស់ខ្លួនអំពីវិកលភាពនៃតំណពូជនៃខ្លួនប្រាណនិងនៃចិត្តរបស់ខ្លួន»។ យើងគួរតែចោទសួរទៅវិញថាអ្វីដែលគេហៅថា វិសមភាពធម្មជាតិនោះមិនច្រើនតែជាវិបាកនៃវិសមភាពអយុត្តិធម៌នៃសង្គមទេឬ? លក្ខខណ្ឌដ៏ពិបាកនៃការរស់នៅកង្វះខាតប្រាក់កាស ការនឿយហត់ដោយធ្វើការយូរពេកក្នុងមួយថ្ងៃ ភាពកខ្វក់នៃលំនៅស្មោកគ្រោក បន្លប់ជាស្ថាពរនូវបុគ្គលិកលក្ខណៈហើយធ្វើឱ្យនិស្ស័យ(dons) លែងរីកចម្រើន។ សុខភាពនៃរាងកាយទៅជាខូច បញ្ញាចុះអន់ខ្សោយជាលំដាប់ដោយគ្មានសមត្ថភាពនឹងដុះដាល។ ម៉្យាងទៀត អសន្តិសុខ ភាពក្រីក្រ អាចធ្វើឱ្យសីលពុទ្ធិនឿយណាយ។ គឺសេចក្តីអស់សង្ឃឹមមិនមែន «សភាវគតិអាក្រក់»ទេ ដែលនាំមនុស្សឱ្យពឹងផ្អែកទៅលើពុំនឹងអាក្រក់នៃសុរា និងអបាយមុខផ្សេងៗ។ និស្ស័យធម្មជាតិក៏លែងទៅជាអ្វីកើតដោយគ្មានទីកន្លែងដើម្បីរីកចម្រើន។ ប្រសិនបើមនុស្សទាំងអស់រស់នៅក្នុងលក្ខខណ្ឌដ៏ប្រសើរនៃសង្គមច្បាស់ជាក្នុងចំណោមមនុស្សទាំងនោះវិសមភាពដែលយើងពោលយ៉ាងងាយថាមាន«ពីធម្មជាតិ» នឹងមានយ៉ាងតិចបំផុត។

- ពិតមែនហើយ វិសមភាពខ្លះប្រហែលជានៅមានតទៅទៀត។ ក៏ប៉ុន្តែតើវិសមភាពទាំងនោះនឹងនាំឱ្យមានភាពខុសគ្នាយ៉ាងខ្លាំងនៃលក្ខខណ្ឌខាងផ្នែកសម្ភារៈដោយចៀសមិនរួចឬអ្វី? ទោះជាអ្នកបោសថ្នល់បានប្រាក់បំណាច់តិចជាងរដ្ឋមន្ត្រីជានិច្ចក៏ដោយក៏គេជឿថាសាធារណរដ្ឋដែលប្រកាន់យក «លទ្ធិប្រជាធិបតេយ្យនិងសង្គម» នឹងជួយឱ្យអ្នកបោសថ្នល់មានលទ្ធភាពនឹងរស់នៅដោយសមរម្យះ មានទីលំនៅ ការចិញ្ចឹមជីវិត និងសម្លៀកបំពាក់ត្រឹមត្រូវផង។ គោលការណ៍នៃយុត្តិធម៌ក្នុងការចែក «ម្នាក់ៗត្រូវបានទៅតាមស្នាដៃរបស់ខ្លួន» ត្រូវចែងទៅតាមគោលការណ៍មនុស្សធម៌ជាងនេះ៖«ម្នាក់ៗត្រូវបានទៅតាមសេចក្តីត្រូវការរបស់ខ្លួន»។ និយាមដែលគេអនុវត្តក្នុងពេលឥឡូវនេះដោយឱ្យវិភាជន៍គ្រួសារស្មើគ្នាសម្រាប់ចំនួនកូនដូចគ្នា(ទោះជាប្រាក់បៀវត្សខាងវិជ្ជាជីវៈនៃមេគ្រួសារប៉ុន្មានក៏ដោយ)ពិតជាមានគំនិតចេញពីគោលការណ៍នេះ។

តាមពិតសមភាពនៃបុគ្គល គឺជាសញ្ញាណមួយសំខាន់ណាស់ ហើយដែលគេស្គាល់យ៉ាងច្បាស់បំផុត នៅពេលណាដែលទុក្ខវេទនាបានធ្វើឱ្យមនុស្សភ្លេចវិសមភាពនិមិត្តដែលកើតឡើងដោយសារអេរិយធម៌សាំញ៉ាំមួយ។ ពិតមែនហើយថាវិសមភាពនៃសង្គមបានធ្វើឱ្យមនុស្សភ្លេចសមភាពធម្មជាតិយ៉ាងងាយបំផុត ប៉ុន្តែសមភាពនេះនឹងត្រូវគេនឹកឃើញឡើងវិញ នៅពេលដែលមនុស្សឋិតនៅទាំងអស់គ្នាក្នុងភាពក្រីក្រ។ អ្នកដែលធ្លាប់មានបទពិសោធ

ក្នុងចំបាំង ហើយជាពិសេសទៅទៀត អ្នកដែលធ្លាប់ជាឈ្លើយសង្គ្រាមត្រូវគេនិរទេសដឹងរឿងនេះច្បាស់ណាស់។ នៅទីនោះ គេលែងគិតដល់ទ្រព្យសម្បត្តិ ឋានៈ កោសល្យអ្វីទាំងអស់ នៅសល់តែមនុស្សប៉ុណ្ណោះ ហើយជីវិតម្នាក់ៗមានភាពមិនឋិតថេរនិងមានតម្លៃស្មើគ្នាផង។

## ៨.៤ សប្បុរសធម៌

តាមន័យទស្សនវិជ្ជា សប្បុរសធម៌គឺជាស្នេហាចំពោះអ្នកដទៃ ពោលគឺសញ្ចេតនាដែលរុញច្រានយើងឱ្យធ្វើល្អចំពោះអ្នកដទៃ។ ឥឡូវនេះ ពាក្យនេះត្រូវបានគេប្រើជាទូទៅនៅក្នុងសីលវិជ្ជា ដែលគេច្រើនតែធ្វើឱ្យមានលក្ខណៈផ្ទុយគ្នាជាមួយនឹងពាក្យយុត្តិធម៌។

យុត្តិធម៌មានលក្ខណៈបញ្ញាដែលចូលទៅក្នុងលំដាប់នៃវិចារណញ្ញាណ ចំណែកឯសប្បុរសធម៌វិញមានលក្ខណៈវេទនា លក្ខណៈសញ្ចេតនា ដែលចូលទៅក្នុងលំដាប់នៃចិត្តទៅវិញ។ ប៉ុន្តែសប្បុរសធម៌បានត្រូវពួកគ្រិស្តសាសនិក លើកតម្កើងបញ្ចូលទៅក្នុងលំដាប់នៃគុណធម៌ផ្នែកទេវវិជ្ជា គឺជាស្នេហាចំពោះអាទិទេព ហើយនិងស្នេហាចំពោះមនុស្សដូចគ្នា ដោយសារមនុស្សមានទំនាក់ទំនងជាមួយអាទិទេព។ ក្នុងន័យនេះសប្បុរសធម៌មានលក្ខណៈសាសនាដែលខុសពីស្នេហាមនុស្សជាតិធម្មតា ហើយមាន ព្រំដែនធំជាង «ករណីយកិច្ចនៃសប្បុរសធម៌» ឬ«ករណីយកិច្ចនៃមេត្តាធម៌» ដែលគេច្រើនតែច្រឡំជាមួយវាញឹកញយ។ គឺនៅក្នុងន័យនេះហើយ ដែលសន្តបុគ្គលប៉ូល (Saint Paul) បានពោលថា«ទោះបីខ្ញុំចែកទ្រព្យសម្បត្តិរបស់ខ្ញុំទាំងអស់ទៅឱ្យអ្នកក្រក៏ដោយ ប្រសិនបើខ្ញុំគ្មានសប្បុរសធម៌ ក៏ខ្ញុំគ្មានគុណធម៌ទាំងអស់»។

### ៨.៤.១ ភាពផ្ទុយគ្នាជាប្រពៃណីរវាងយុត្តិធម៌ និងសប្បុរសធម៌

(1). យុត្តិធម៌ដែលមានមុខងារការពាររបៀបរៀបរយនៃសង្គមបានត្រូវគេចាត់ទុកជាញឹកញយថាមានលក្ខណៈអវិជ្ជមានសុទ្ធសាធ (កុំលួច កុំធ្វើអាក្រក់ដល់អ្នកដទៃ) ឬក៏យ៉ាងច្រើនណាស់ គ្រាន់តែជួយជួសជុលតែប៉ុណ្ណោះ (សងបំណុល)គឺជាគោលការណ៍នៃការរក្សាទុកនិងនៃលំនឹង។ ផ្ទុយទៅវិញសប្បុរសធម៌ដែលដាស់តឿនយើងឱ្យធ្វើល្អចំពោះអ្នកដទៃមានលក្ខណៈវិជ្ជមាន(ជួយសម្រាលទុក្ខអ្នកក្រ)ដោយទុកអ្នកដទៃជាគោលដៅ។ ចំពោះគោលការណ៍អវិជ្ជមាននៃយុត្តិធម៌ «កុំធ្វើចំពោះអ្នកដទៃ នូវអំពើណាដែលឯងមិនចង់ឱ្យគេធ្វើមកចំពោះឯងវិញ»សប្បុរសធម៌ចូលចិត្តយកគោលការណ៍វិជ្ជមានវិញ«ចូរឯងធ្វើចំពោះអ្នកដទៃតែអំពើណាដែលឯងចង់ឱ្យគេធ្វើចំពោះឯង»។

(2). ក្នុងការធ្វើឱ្យការប្តូរមានលក្ខណៈត្រឹមត្រូវនិងធ្វើឱ្យមុខងារមានលក្ខណៈសមរម្យហើយនិងក្នុងការបង្កើតឱ្យមានសហព័ន្ធមួយនៃសិទ្ធិ និងករណីយកិច្ចទៅវិញទៅមកយុត្តិធម៌បង្កើតឱ្យសាមគ្គីភាពរវាងមនុស្សចំណែកសប្បុរសធម៌មានគោលបំណងបង្កើតសហគមន៍ទៅវិញ។ ម៉ាឌីញ៉េ(Madinier) ឱ្យនិយមន័យទៅសហគមន៍ថាជា«ឯកភាពនៃសង្គម ដែលនៅក្នុងនោះមនុស្សស្រឡាញ់គ្នាទៅវិញទៅមក ហើយដែលម្នាក់ៗស្រង់យកសេចក្តីសប្បាយរបស់ខ្លួនអំពីអំណោយដែលខ្លួនបានបរិច្ចាគដោយខ្លួនឯងតែម្តងចំពោះអ្នកដទៃ»។

(3). ក្នុងការអនុញ្ញាតឱ្យយើងទាមទារយកចំណែកដែលយើងត្រូវបានយុត្តិធម៌អាចត្រូវគេចោទបានថាមានភាគខ្លះឋិតនៅក្រោមឥទ្ធិពលនៃទំនោរនិងសេចក្តីត្រូវការ។ ពិតមែនហើយថាយុត្តិធម៌មិនមែនជាអត្តទត្តភាពសុទ្ធសាធនោះទេ តាម ម៉ាឌីញ៉េ «យុត្តិធម៌ជាអាផ្លាកណ្តាលរវាងអត្តទត្តភាពនៃរូបរាងកាយនិងសប្បុរសធម៌»។ មានតែសប្បុរសធម៌តែមួយគត់ ដែលបង្ហាញឱ្យឃើញនូវការមិនគិតដល់ផលប្រយោជន៍ ហើយនិងនូវចិត្តបុណ្យសុទ្ធសាធ ព្រោះសប្បុរសធម៌មិនគន់គូរធ្វើលេខដូចយុត្តិធម៌ឡើយ។ សប្បុរសធម៌មិនបង្កើតឱ្យមានការចែកទេតែបង្កើតឱ្យមានជាអំណោយទៅវិញ។ «យុត្តិធម៌តម្រូវឱ្យទៅអ្នកដទៃនូវអ្វីដែលជារបស់គេ រីឯសប្បុរសធម៌ វិញតម្រូវឱ្យនូវអ្វីដែលជារបស់ខ្លួនទៅវិញ»។

(4). ហើយតមកទៀត ករណីយកិច្ចនៃយុត្តិធម៌មានលក្ខណៈប្រិតប្រៀន និងចាំបាច់ស្របនឹងករណីយកិច្ច និងច្បាប់ដែលរដ្ឋទទួលស្គាល់និងធានារ៉ាប់រង (ចោរត្រូវរដ្ឋតាមរកចាប់ខ្លួនជាដើម) ផ្ទុយទៅវិញករណីយកិច្ចនៃសប្បុរសមានលក្ខណៈទូលាយនិងគ្មានហេតុផលជាក់លាក់កំណត់ច្បាស់លាស់ឡើយ (ទោះជាឱ្យក៏បាន មិនឱ្យក៏បាន)ហើយការធ្វើអំណោយទៀតអាចធ្វើបានច្រើនប្រភេទ ឧទាហរណ៍ដូចជាគ្មានអ្វីកំណត់ចំនួនម៉ោងដែលត្រូវទៅជួយកំដរអ្នកជំងឺម្នាក់ដែលនៅតែម្នាក់ឯងជាដើម។

(5). នៅទីបំផុត បើតាមសំដីរបស់ ប៊ែសុន គេអាចពោលបានថា៖«យុត្តិធម៌មានលក្ខខណៈផ្ទុយគ្នាដូចជាអ្វីដែលជាវិជ្ជមាន និងអ្វីដែលជាអវិជ្ជមាន ឬក៏ដូចជាអ្វីដែលបិទនិងអ្វីដែលបើក ឬដូចជាសុភវិនិច្ឆ័យដែលប្រកាន់នូវទំនៀមទម្លាប់ និងការបង្កើតថ្មី ឬពុំនោះសោតដូចជាវិចារនិងអព្ភន្តរញ្ញាណ»។ យុត្តិធម៌ដៅទៅលើគោលបំណងនៃការរក្សាទុកនូវសង្គម«ចង្អៀតចង្អល់» ចំណែកសប្បុរសធម៌វិញឋិតនៅក្នុងការអំពាវនាវនៃវីរបុរសនិងសន្តបុគ្គល។ បើពោលឱ្យខ្លីយុត្តិធម៌គឺជាសប្បុរសស្តូកស្តឹង ចំណែកឯសប្បុរសធម៌វិញគឺជាការបង្កើតថ្មីផ្នែកសីលវិជ្ជាដែលស្ថិតនៅក្នុងសំទុះដ៏ខ្លាំងបំផុត។

**៨.៤.២ ពិភាក្សាប្រតិនិក្ខេប**

ប៉ុន្តែ ភាពខុសគ្នារវាង យុត្តិធម៌ និងសប្បុរសធម៌នេះដែលហាក់ដូចជាមានមូលដ្ឋានមាំមួនហើយដំបូងហាក់ដូចជាគ្មានមន្ទិលសោះនៅបច្ចុប្បន្នកាលបានត្រូវពួកអ្នកវិចារណញ្ញាណនិយមនិងពួកសង្គមនិយមទិតៀនយ៉ាងខ្លាំង។

(1). ដំបូង គំនិតនៃយុត្តិធម៌ដែលប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់សុទ្ធសាធ«ចង្អៀតចង្អល់» ដែលបានត្រឹមតែគោរពរបៀបរៀបរយ ដែលមានមកហើយនោះគឺជា បញ្ញត្តិកម្មមួយខុសទទេ ពីព្រោះនៅទីនេះមានការយល់ច្រឡំរវាងអ្វីដែលយុត្តិធម៌ និងអ្វីដែលត្រឹមត្រូវតាមលក្ខណៈច្បាប់ ព្រោះថាអ្វីដែលស្របទៅតាមច្បាប់អាចនឹង អយុត្តិធម៌តាមសីលវិជ្ជាដែរ។ ឧត្តមគតិនៃសីលយុត្តិធម៌ មិនមែនចង្អៀតចង្អល់ មិនមែនជាអវិជ្ជមាននិងមិនមែនប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ទេ។ គឺជាឧត្តមគតិអតិសេដ្ឋនៃវិចារណញ្ញាណ ហើយតាងនាមនោះតែម្តងដែលគេអាចរិះគន់ច្បាប់ជាលាយលក្ខណ៍អក្សរ ហើយធ្វើឱ្យច្បាប់នោះកាន់តែប្រសើរឡើង។

(2). តមកទៀតគំនិតនៃសប្បុរសធម៌ «ទូលាយ» និង «តាមបាន» ហាក់ដូចជាអាចនាំឱ្យមានបំណកស្រាយប្រកបដោយគ្រោះថ្នាក់។ តាមពិតគេអាចចាត់ទុកទ្រឹស្តីប្រពៃណីនិយម អំពីទំនាក់ទំនងរវាងយុត្តិធម៌ និងសប្បុរសធម៌ថាមិនសមហេតុសមផល។ មិនសមហេតុផលដំបូង ក្នុងការដែលធ្វើឱ្យយុត្តិធម៌មានលក្ខណៈចង្អៀតចង្អល់បំផុតដោយបន្ថយយុត្តិធម៌ឱ្យមានមុខងារត្រឹមតែរក្សារបៀបរៀបរយ ដែលមានមកហើយ។ មិនសមហេតុផលម្យ៉ាងទៀត ក្នុងការចាត់ទុកអំពើណាដែលចេញពីរបៀបនេះថាជាអំពើដែលគេចង់ធ្វើក៏បាន មិនចង់ធ្វើក៏បាន។

ដូចនេះ មនុស្សសប្បុរសធម៌ហាក់ដូចជាដឹងខ្លួនថាធ្វើលើសពីករណីយកិច្ចរបស់ខ្លួនធ្វើលើសពីយុត្តិធម៌។ ប៉ុន្តែបើតាមការពិតវិញអ្នកនេះគ្រាន់តែសម្រាលអយុត្តិធម៌ដែលមានមកហើយនោះបានបន្តិចបន្តួចប៉ុណ្ណោះ។ គេឃើញថាជួនកាលការបំពេញសប្បុរស ធម៌បិទបាំងគំនិតប្រកបដោយកលល្បិចគ្រប់យ៉ាង ដើម្បីឱ្យសម្រេចផលប្រយោជន៍ ដើម្បីនឹងធ្វើឱ្យអ្នកដែលគេចំរាញ់យកផលប្រយោជន៍យល់ព្រមទទួលយកយុត្តិធម៌។ សង់កេលេវិត (Jankelévitch) បានសង្ខេបការរិះគន់នៃពួកសង្គមនិយមច្បាស់លាស់ណាស់ «ឧបាយកលនៃគំនិតសប្បុរសដែលបានពិចារណាត្រឹមត្រូវល្អិតល្អន់ឋិតនៅលើការឱ្យទៅអ្នកក្រដូចជាអំណោយនូវអ្វីដែលអ្នកនោះត្រូវបានជាសិទ្ធិរបស់ខ្លួន បើសង្ខេបទៅគឺឱ្យដូចជារង្វាន់សប្បុរសបំផុត នូវសម្បត្តិផ្ទាល់របស់អ្នកនោះ...។ អ្នកក្រត្រូវគេដណ្តើមយកធនធាន ហើយថែមទាំងត្រូវគេធ្វើឱ្យជឿថា ខ្លួនគ្មានសិទ្ធិលើអ្វីទាំងអស់ ដូចនេះអ្នកក្រត្រូវអរគុណចំពោះចោរដែលលួចខ្លួន។ ត្រូវគេប្លន់ហើយដឹងគុណគេទៀត នេះមិនជាការមួយគួរឱ្យអស់សំណើចទេឬ? ដើម្បីរក្សាទុកភាពដ៏គួរឱ្យអស់សំណើចនេះអ្នកមានគេមិនខ្លាចធ្វើពលិកម្មខ្លះ ៗទេ គេអាចធ្វើពលិកម្មហួតទៅប៉ះកន្ទបឱ្យសុំទានទៀតក្នុង

គោលបំណងនឹងបញ្ជាក់ប្រាប់ខ្លួនគេថា អ្នកសុំទាននោះនឹងរស់តទៅក្នុងសភាពរហេមរហាម សម្លៀកបំពាក់រយ៉ីរយ៉ៃ តែមានចិត្តប្រកបទៅដោយការដឹងគុណចំពោះគេ»។

(3). សប្បុរសធម៌មានពេលខ្លះអាចនឹងល្អៀង ហើយធ្វើបានតែចំពោះអ្នកខ្លះតែប៉ុណ្ណោះ។

- មានពេលខ្លះល្អៀង ពីព្រោះអ្នកឱ្យគិតថាចិត្តបុណ្យរបស់គេធ្វើបានស្រេចនិងចិត្តសទ្ធា ហើយយល់ថាគេអាចធ្វើទានចំពោះមនុស្សខ្លះ ហើយមិនធ្វើទានចំពោះអ្នកខ្លះទៀតក៏បាន។គេបានជួបប្រទះរួចមកហើយនូវក្រុមអ្នកមានជំនឿសាសនាខ្លះដែលធ្វើទានចំពោះតែអ្នកក្រដែលនៅក្នុងនិកាយជាមួយគ្នា។

- សប្បុរសធម៌តែងតែធ្វើបានចំពោះតែភាគខ្លះប៉ុណ្ណោះ ព្រោះសប្បុរសធម៌ធ្វើទៅលើតែជនខ្លះ មិនអាចនឹងផ្លាស់ប្តូរទម្រង់នៃសង្គមបានឡើយ។ ការជួយសម្រាលសេចក្តីក្រីក្ររបស់អ្នកនេះឬរបស់អ្នកនោះ មិនមែនជាដំណោះស្រាយគ្រប់គ្រាន់ចំពោះបញ្ហាអយុត្តិធម៌សេដ្ឋកិច្ចបានឡើយ។

(4). នៅទីបំផុត ពិតមែនហើយថា នៅក្នុងប្រវត្តិសាស្ត្រគំនិតនៃសប្បុរសធម៌បានកើតមុនអង្គការយុត្តិធម៌ ប៉ុន្តែក្នុងរបបនៃតម្លៃគឺជាការតម្រូវអតិសេដ្ឋនៃយុត្តិធម៌ដែលជាមូលដ្ឋាននៃការបំពេញសប្បុរសធម៌។ ហេតុអ្វីបានជាអំពើដែលកើតឡើងដំបូងដោយសារសប្បុរសធម៌នៃជនម្នាក់ៗ(ការទទួលឱ្យស្នាក់អាស្រ័យដោយឥតគិតថ្លៃ)ការអត់ឱន ការសង្គ្រោះបានក្លាយមកជាកម្មវត្ថុនៃការរៀបចំតាមលក្ខណៈច្បាប់? នេះមិនគឺដោយសារតែអំពើទាំងនេះមានយុត្តិធម៌ខ្លួនឯងទេឬ? ដូចនេះសប្បុរសធម៌កើតចេញមកតែពីការតម្រូវនៃយុត្តិធម៌តែប៉ុណ្ណោះ ហើយអំពើណាមួយក៏ដោយអាចនឹងមានលក្ខណៈជាសប្បុរសធម៌បានមានតម្លៃបានលុះត្រាតែអំពើនោះផុសចេញពីឧត្តមគតិនៃយុត្តិធម៌។

### ៨.៤.៣ សំយោគបញ្ចប់

ប៉ុន្តែគឺជាការច្រឡំមួយដែលចង់លើកតម្លៃយុត្តិធម៌ ហើយបន្ថោកតម្លៃនៃសប្បុរសធម៌។ តាមពិតសប្បុរសធម៌មិនមែនជាការដាក់ទាននោះទេ គឺជាស្នេហាចំពោះមនុស្សដូចគ្នា។ ក្នុងភាពសុខដុមនៃសីលជីវិត ករណីយកិច្ចនៃយុត្តិធម៌និងករណីយកិច្ចនៃសប្បុរសធម៌ត្រូវតែរួបរួមគ្នា និងបង្គ្រប់គ្នាទៅវិញទៅមក។ នៅក្បែរយុត្តិធម៌ សប្បុរសធម៌រក្សាទុកតម្លៃរបស់ខ្លួនទាំងមូល។ យុត្តិធម៌ឱ្យនិយមន័យទៅឧត្តមគតិ ចំណែកឯសប្បុរសធម៌គឺជាកម្លាំងចលករនៃសីលអំពើជាសំទុះដែលជំរុញយើងឱ្យសម្រេចយុត្តិធម៌។ យុត្តិធម៌ បើគ្មានសប្បុរសធម៌ មិនអាចនឹងឈោងទៅដល់សីលកុសលពិតប្រាកដបានឡើយ ហើយសប្បុរសធម៌ បើគ្មានយុត្តិធម៌វិញ អាចនឹងក្លាយទៅជាភាពសាវ៉ានៃសញ្ចេតនា ហើយបានសម្រេចតែភាគខ្លះប៉ុណ្ណោះ៕

# មេរៀនទី៩ ក្រមនីតិវិធីរដ្ឋប្បវេណី

បណ្ដឹងរដ្ឋប្បវេណី ជាបណ្ដឹងទាក់ទងនឹងសិទ្ធិឯកជន ឬជាបណ្ដឹងដែលទាមទារឱ្យជនប្រព្រឹត្ត ជួសជុលសង ការខូចខាតផ្នែកសម្ភារៈ ការព្យាបាលរូបរាងកាយ និងការសងជំងឺចិត្តទៅតាមភាពជាក់ស្ដែងនៃការរងគ្រោះ។ ប្រភេទនៃបណ្ដឹងរដ្ឋប្បវេណីមានដូចជា បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក បណ្ដឹងទាមទារឱ្យបញ្ជាក់ បណ្ដឹងទាមទារឱ្យបង្កើត ផ្លាស់ប្ដូរ ឬរម្លត់នូវទំនាក់ទំនងគតិយុត្ត។ សកម្មភាពបណ្ដឹងរដ្ឋប្បវេណី ត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណី។

## ៩.១ គោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណី

❖ ក្រមនេះមានគោលបំណង

- ឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិបុគ្គលឯកជន។
- ទាមទារឱ្យមានការសាកសួរ ឬកោះហៅទាំងដើមចោទ ទាំងចុងចម្លើយនៅមុនពេលជម្រះក្ដី ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ(មាត្រា៣)នៅពេលអនុវត្តបណ្ដឹង និងប្រឹងប្រែងដើម្បីរ៉ាប់រងបណ្ដឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយយុត្តិធម៌ និងឆាប់រហ័ស។ ឯភាគីបណ្ដឹងត្រូវ មានភាពសុចរិត និងស្មោះត្រង់(មាត្រា៤)។

## ៩.២ សមត្ថកិច្ចសាលាជម្រះក្ដី

យោងមាត្រា៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្ដឹង វិនិច្ឆ័យលើរឿងក្ដី ហើយចេញសាលក្រម ឬសាលដីកាបាន។

សមត្ថកិច្ចសាលាជម្រះក្ដីដែលមានដែនយុត្តាធិការមួយកំណត់ ក្នុងនោះមានសមត្ថកិច្ចលើដែនដីដែលខ្លួនគ្រប់គ្រង និងដែនសមត្ថកិច្ចត្រូវអនុវត្ត(មាត្រា៨)៖

### ៩.២.១ សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមលំនៅដ្ឋាន

ជម្រះរឿងក្ដីណាដែលកើតមាននៅក្នុងរង្វង់ដែនដីខ្លួនគ្រប់គ្រង។ ដើមបណ្ដឹងអាចប្ដឹងចុងចម្លើយទៅតុលាការដែលមានសមត្ថកិច្ចជម្រះក្ដីនៅទីកន្លែងដែលមានកំណត់នៅក្នុងចំណុចដូចខាងក្រោម៖

**ក-រូបវន្តបុគ្គល[1]**

- លំនៅឋានរបស់ចុងចម្លើយ
- ទីសំណាក់ បើពុំមានលំនៅឋាន ឬលំនៅឋានមិនច្បាស់លាស់ក្នុងប្រទេសកម្ពុជា

**ខ-នីតិបុគ្គល[2]ក្នុងប្រទេស**

- ទីតាំងនៃស្នាក់ការ ឬទីកន្លែងធ្វើអាជីវកម្មជាចម្បង
- លំនៅឋានរបស់អ្នកតំណាង ឬរបស់អ្នកទទួលខុសត្រូវភារកិច្ច ចាត់ចែងការងារជាចម្បង បើគ្មានទីស្នាក់ការ ឬទីកន្លែងអាជីវកម្មទេ ។

**គ-នីតិបុគ្គលបរទេស**

- ទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បង
- លំនៅដ្ឋានរបស់អ្នកតំណាងប្រចាំកម្ពុជា ឬរបស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែង បើគ្មានទីស្នាក់ការ ឬទីកន្លែងអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជាទេ។

### ៩.២.២ សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមទ្រព្យសម្បត្តិ (មាត្រា៩)

---

[1] រូបវន្តបុគ្គល( Natural person ) មនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល។

[2] នីតិបុគ្គល( Juridical person ) ក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្តហើយជាម្ចាស់នៃសិទ្ធិនិងកាតព្វកិច្ច។

ជាសមត្ថកិច្ចរបស់តុលាការក្នុងការអនុវត្តពាក្យបណ្តឹងពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិ។ ដើមចោទអាចប្តឹងទៅតុលាការដែលមានសមត្ថកិច្ច នៅទីកន្លែងដែលកើតមានរឿងក្តី តាមកំណត់៖

**បណ្តឹងទាមទារឱ្យអនុវត្តភារកិច្ច**

- បណ្តឹងទាមទារឱ្យបង់ប្រាក់ដោយរូបិយាណត្តិ[3]
- បណ្តឹងទាក់ទងនឹងអំពើអនីត្យានុកូល[4]
- បណ្តឹងទាក់ទងអចលនវត្ថុ[5]
- បណ្តឹងទាក់ទងនឹងមរតក

### ៩.២.៣ សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នានិងរឿងក្តីអំពីបុត្តភាព

បណ្តឹងបញ្ជាក់ពីអត្ថិភាព ឬនត្ថិភាពនៃបុត្តភាព(កូន) គឺជាសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីបណ្តឹង ប្រសិនបើភាគីបណ្តឹង មានលំនៅមិនពិតប្រាកដ ត្រូវកំណត់យកលំនៅឋានចុងក្រោយ ។

ក្រៅពីសមត្ថកិច្ចដែលបានរៀបរាប់ខាងលើសាលាជម្រះក្តីនៅមានសមត្ថកិច្ចមួយចំនួនទៀតដូចជា៖

- ជម្រះក្តីដោយគ្មានការតវ៉ាពីចុងចម្លើយ នៅពេលដែលចុងចម្លើយបានធ្វើសេចក្តីដោះសាអំពីខ្លឹមសារបណ្តឹង
- ពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ[6]
- ផ្ទេរបណ្តឹងទៅសាលាជម្រះក្តីមួយផ្សេងទៀត តាមការស្នើសុំរបស់ភាគីបណ្តឹង ឬតាមឆន្ទានុសិទ្ធិខ្លួន

## ៩.៣ សមត្ថភាពក្នុងការធ្វើបណ្តឹង

❖ ភាគីទាំងពីរមានសមត្ថភាពធ្វើបណ្តឹងលុះត្រាតែ៖

✓ បុគ្គលដែលមានសិទ្ធិនិងករណីយកិច្ចតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀត អាចជាដើមចោទ ឬចុងចម្លើយនៅក្នុងបណ្តឹងរដ្ឋប្បវេណី

✓ បុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯង តាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីនិងច្បាប់ផ្សេងទៀតអាចដាក់ពាក្យបណ្តឹងដោយខ្លួនឯងដោយតាំងខ្លួនជាដើមចោទឬអាចឆ្លើយដោះសារចំពោះបណ្តឹងដោយតាំងខ្លួនជាចុងចម្លើយ ឬអាចធ្វើសកម្មភាពផ្សេងទៀតដែលចាំបាច់។ ចំពោះអនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ[7] អាចធ្វើសកម្មភាពបណ្តឹងបានតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់។ ក្នុងករណីដែលគ្មានអ្នកតំណាង ឬតំណាងនោះពុំអាចប្រតិបត្តិនូវសិទ្ធិតំណាង បុគ្គលផ្សេងទៀតដែលមានបំណងជួយធ្វើសកម្មភាពបណ្តឹងអាចដាក់ពាក្យសុំទៅតុលាការដែលទទួលពាក្យបណ្តឹងឱ្យជ្រើសតាំងអ្នកតំណាងពិសេសដើម្បីធ្វើបណ្តឹងនេះ។ ការសម្រេចជ្រើសតាំង ឬផ្លាស់ប្តូរ ជាសមត្ថកិច្ច

---

[3] រូបិយាណត្តិ មូលបត្រមួយប្រភេទដែលបហារ៉កប្រើសម្រាប់បង្គាប់បញ្ជាបហារិតឱ្យផ្តល់ទឹកប្រាក់ជាក់លាក់មួយចំនួននៅក្នុងកាលបរិច្ឆេទណាមួយទៅបុគ្គលទី៣ហៅថាគាហកៈ។

[4] អំពើអនីត្យានុកូល គឺអំពើដែលបំពានដោយខុសច្បាប់លើសិទ្ធិ ឬប្រយោជន៍អ្នកដទៃដោយកំហុសចេតនា ឬអចេតនា (មាត្រា៧៤២ ក្រមរដ្ឋប្បវេណី) ។

[5] អចលនវត្ថុ ដីធ្លី និងវត្ថុជាប់នៅនឹងដី ហើយមិនអាចផ្លាស់ប្តូរ ទីកន្លែងបានដូចជា អាគារ សំណង់ ដំណាំរុក្ខជាតិ។ល។

[6] ឆន្ទានុសិទ្ធិ (Discretion) អំណាចដែលប្រគល់ដល់ចៅក្រមឱ្យរើសយកតាមចិត្តរបស់ខ្លួននូវមធ្យោបាយណាមួយ ដែលមានចែងនៅក្នុងច្បាប់ដើម្បីយកមកដោះស្រាយបញ្ហាណាមួយ។

[7] ជននៅក្រោមអាណាព្យាបាលទូទៅ សំដៅដល់បុគ្គលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹងនិងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។

របស់តុលាការ។

## ៩.៤ ប្រាក់ប្រដាប់ក្តី ៖

ជាពន្ធសរុបត្រូវចំណាយផ្សេងៗក្នុងរឿងរដ្ឋប្បវេណី។ ក្នុងនោះរួមមាន ពន្ធដាក់ពាក្យសុំ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងប្រាក់ប្រដាប់ក្តីភាគី ។

### ៩.៤.១ ពន្ធដាក់ពាក្យសុំ (មាត្រា ៦១)

❖ គេត្រូវគណនាតាមកម្មវត្ថុនៃបណ្តឹង។ ពាក្យសុំដែលមិនបង់ពន្ធ ចាត់ទុកជាពាក្យសុំមិនស្របច្បាប់។ ពន្ធនៃការដាក់ពាក្យសុំធ្វើបណ្តឹងមាន៖

- ការដាក់ពាក្យបណ្តឹងទៅតុលាការ
- ការដាក់ពាក្យបណ្តឹងសុំជំនុំជម្រះសាជាថ្មី[8]
- ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍
- ការដាក់ពាក្យបណ្តឹងសាទុក្ខ
- ការដាក់ពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្តី ។

### ៩.៤.២ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ (មាត្រា ៦២)

❖ ជាចំនួនទឹកប្រាក់ដែលភាគី ឬបុគ្គលទាក់ទងនឹងរឿងក្តីត្រូវបង់មាន ៖

- ចំនួនទឹកប្រាក់ចាំបាច់ដើម្បីតុលាការធ្វើការពិនិត្យភស្តុតាង ការបញ្ជូនឯកសារឬសកម្មភាពផ្សេងទៀតតាមនីតិវិធីក្នុងបណ្តឹងរដ្ឋប្បវេណី ។
- ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរ សោហ៊ុយស្នាក់នៅ សម្រាប់ការពិនិត្យភស្តុតាងការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀតដែលប្រព្រឹត្តទៅនៅក្រៅតុលាការ ។

### ៩.៤.៣ ប្រាក់ប្រដាប់ក្តីភាគី (មាត្រា៦៣)

❖ តាមលទ្ធភាពនៃទ្រព្យធនរបស់ភាគី ។ ត្រូវបង់ទៅតុលាការសម្រាប់ ៖

- ថ្លៃធ្វើលិខិតបណ្តឹង ពាក្យសុំផ្សេងៗទៀត ដូចជាឯកសារត្រៀម និងថ្លៃដាក់ឯកសារនោះ:
- សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងសោហ៊ុយស្នាក់នៅសម្រាប់ភាគីនិងអ្នកតំណាង ដើម្បីបង្ហាញខ្លួនតាមការកំណត់ ។
- សោហ៊ុយផ្សេងទៀតដែលតុលាការទទួលស្គាល់ថា ចាំបាច់សម្រាប់អនុវត្តនីតិវិធីបណ្តឹងសម្រាប់សកម្មភាពដែលធ្វើឡើងដោយពាក្យសុំគឺអ្នកដាក់ពាក្យបណ្តឹងត្រូវបង់ជាមុន។ ករណីមិនបានបង់ប្រាក់ជាមុន តុលាការអាចមិនធ្វើសកម្មភាពណាដែលចាំបាច់ត្រូវមានប្រាក់ប្រដាប់ក្តីនោះទេ ។

## ៩.៥ បណ្តឹងឧទ្ធរណ៍

❖ បណ្តឹងឧទ្ធរណ៍ អាចធ្វើចំពោះសាលក្រមចុងក្រោយរបស់សាលាដំបូងបាន លើកលែងតែករណីដូចខាងក្រោម (មាត្រា២៦០) ៖

- ភាគីបានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ ថាមិនប្តឹងឧទរណ៍ដោយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខក្រោយពេលតុលាការបានចេញសាលក្រមចុងក្រោយ។

---

[8] បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាមធ្យោបាយឧបាស្រ័យមិនប្រក្រតីមួយ ដែលភាគីប្តឹងទាមទារឱ្យតុលាការដែលចេញសាលក្រមឬសាលដីកាចុងក្រោយ ដែលបានចូលជាស្ថាពរ ឱ្យជំនុំជម្រះសាជាថ្មីដើម្បីលុបចោលសាលក្រមឬសាលដីកានោះដោយយកមូលហេតុនីតិវិធីនៃបណ្តឹងនោះមានវិការៈធ្ងន់ធ្ងរ ឬឯកសារដែលជាមូលដ្ឋាននៃសេចក្តីវិនិច្ឆ័យនោះ មានការខ្វះខាតមិនប្រក្រតី។

- សាលក្រមចុងក្រោយនោះ វិនិច្ឆ័យទៅលើរឿងក្ដីរដ្ឋប្បវេណី ឬពាណិជ្ជកម្មដែលមានតម្លៃកម្មវត្ថុនៃបណ្ដឹង មិនលើសពី ប្រាំលានរៀល។

**៩.៥.១ របៀបប្ដឹងឧទ្ធរណ៍**

តុលាការដើមមានសមត្ថកិច្ចធ្វើពាក្យប្ដឹងឧទ្ធរណ៍ និងសំណុំរឿងទៅសាលាឧទ្ធរណ៍។ បណ្ដឹងឧទ្ធរណ៍ត្រូវសរសេរពីឈ្មោះ អាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ និងបញ្ជាក់ពីមូលហេតុ។ ប្រសិនបើលិខិតបណ្ដឹងឧទ្ធរណ៍សរសេរពុំបានច្បាស់លាស់អំពីមូលហេតុនៃការទាមទារទេ ដើមបណ្ដឹងគប្បីដាក់លិខិតជាលាយលក្ខណ៍អក្សរដែលសរសេរពីចំណុចនោះទៅតុលាការនៃបណ្ដឹងនៅក្នុងពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដាក់ពាក្យប្ដឹងឧទ្ធរណ៍ ។ អំឡុងពេលឧទ្ធរណ៍មានរយៈពេលមួយខែ គិតចាប់ពីថ្ងៃដែលបានជូនដំណឹងអំពីការសម្រេចប្រានចោលឬលើកចោលនូវបណ្ដឹងទាស់ ចំពោះសាលក្រមកំបាំងមុខ និងចាប់ពីថ្ងៃប្រកាសសាលក្រម សម្រាប់សាលក្រមចំពោះមុខ ។

**៩.៥.២ សិទ្ធិសាលាឧទ្ធរណ៍**

តុលាការមានសិទ្ធិលុបចោលបណ្ដឹងឧទ្ធរណ៍ដោយដីកាសម្រេច ប្រសិនបើបណ្ដឹងនោះៈ

- មិនមានលក្ខណៈស្របច្បាប់ ដូចជាមិនបានបង់ពន្ធ ពុំបានកែតម្រូវចំណុចខ្វះខាតជាដើម
- សាលក្រមជំនុំជម្រះលើកទីមួយត្រឹមត្រូវ
- សាលក្រមទីមួយនោះមិនត្រឹមត្រូវ ប៉ុន្តែតុលាការឧទ្ធរណ៍យល់ថា សេចក្ដីសម្រេចបញ្ចប់នៃសាលក្រមទីមួយនោះ ត្រឹមត្រូវដោយផ្អែកលើសម្អាងហេតុផ្សេងទៀត
- សាលក្រមចុងក្រោយនោះមិនត្រឹមត្រូវ ឬនីតិវិធីផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ។ តុលាការឧទ្ធរណ៍ធ្វើការជំនុំជម្រះលើបណ្ដឹងនោះលើកលែងតែបញ្ជូនរឿងក្ដីនោះត្រឡប់ទៅសាលាដំបូងវិញ ក្នុងករណីចាំបាច់បន្ថែមអំពីរឿងក្ដីនោះ។

## ៩.៦ បណ្ដឹងសាទុក្ខ

ជាបណ្ដឹងឧបាស្រ័យទៅតុលាការកំពូល ចំពោះសាលក្រម ឬសាលដីកាចុងក្រោយដែលទាមទារឱ្យវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាចុងក្រោយ ចំពោះការអនុវត្តច្បាប់ប៉ុណ្ណោះ។

**៩.៦.១ មូលហេតុនៃបណ្ដឹងសាទុក្ខ (មាត្រា២៨៤)**

- បណ្ដឹងសាទុក្ខអាចធ្វើបានដោយយកមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្ត ដែលមានឥទ្ធិពលលើសាលក្រម ឬសាលដីកា។

❖ **មូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ (មាត្រា២៨៥)**

- តុលាការដែលចេញសាលក្រមនិងសាលដីកាមិនត្រូវបានចាត់តាំងដោយស្របទៅតាមច្បាប់
- ចៅក្រមដែលច្បាប់មិនបានអនុញ្ញាតឱ្យចូលរួមក្នុងការចេញសាលក្រម ឬសាលដីកា តែបានចូលរួម។
- ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការ
- ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬការប្រគល់សិទ្ធិចាំបាច់ សម្រាប់អ្នកតំណាងដែលធ្វើសកម្មភាពបណ្ដឹង។
- ភាពផ្ទុយគ្នានឹងបញ្ញត្តិស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ។
- សាលក្រម ឬសាលដីកាគ្មានសំអាងហេតុ ឬមានសំអាងហេតុតែផ្ទុយនឹងគ្នា។

**៩.៦.២ របៀបប្ដឹងសាទុក្ខ(មាត្រា២៨៧)**

ដើម្បីប្ដឹងសាទុក្ខ ភាគីត្រូវដាក់ពាក្យបណ្ដឹងសាទុក្ខទៅតុលាការដើម។ នៅក្នុងករណីនេះ តុលាការដើមត្រូវផ្ញើឱ្យបានឆាប់រហ័ស នូវពាក្យបណ្ដឹងសាទុក្ខ និងសំណុំរឿងទៅតុលាការនៃបណ្ដឹងសាទុក្ខ។ រយៈពេលនៃបណ្ដឹងសា

ទុក្ខគឺមានអំឡុងពេលមួយខែ។

## ៩.៧ បណ្តឹងជំទាស់

បណ្តឹងជំទាស់ គឺជាបណ្តឹងដែលកើតឡើងពីការមិនយល់ព្រមចំពោះសាលក្រម ឬពាក្យតវ៉ា សុំបដិសេធសេចក្តីសម្រេចរបស់ចៅក្រម ដែលត្រូវបើកឱ្យភាគីមិនមានវត្តមាននៅពេលជំនុំជម្រះ។

ដើម្បីប្តឹងជំទាស់ ភាគីត្រូវដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការជំនុំជម្រះរឿងក្តីដើម។ ក្នុងករណីនេះតុលាការដើមត្រូវធ្វើឱ្យបានឆាប់រហ័សពាក្យបណ្តឹងជំទាស់និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់ ។

បណ្តឹងជំទាស់ ត្រូវធ្វើនៅក្នុងអំឡុងពេល ១សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច ហើយអំឡុងពេលនេះមិនអាចពន្យាបានឡើយ។[9]

---

9 មាត្រា៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

# មេរៀនទី១០ ក្រមនីតិវិធីព្រហ្មទណ្ឌ

មេរៀនមុនយើងបានសិក្សារួចមកហើយពីក្រមនីតិវិធីរដ្ឋប្បវេណីដែលជាច្បាប់នីតិវិធីសម្រាប់ដោះស្រាយវិវាទរវាងបុគ្គលឯកជន និងបុគ្គលឯកជនស្ថិតក្នុងវង្វង់នៃវិស័យឯកជន ក្នុងការទាមទារឱ្យអនុវត្តការផ្តល់នូវតាវកាលិក[10] ទាមទារឱ្យមានការបញ្ជាក់ ទាមទារឱ្យមានការបង្កើត កែប្រែ ឬរម្លត់នូវសិទ្ធិរបស់ភាគី តាមរយៈសេចក្តីសម្រេចរបស់តុលាការ។ រឿងក្តីរដ្ឋប្បវេណី គឺត្រូវដោះស្រាយដោយច្បាប់នៃនីតិឯកជន មានន័យថា ត្រូវដោះស្រាយដោយយកក្រមនីតិវិធីរដ្ឋប្បវេណីនិងច្បាប់ពិសេសមកអនុវត្តតាមផ្លូវបណ្តឹងនៃវិវាទរដ្ឋប្បវេណី។ តុលាការសម្រេចសេចក្តីត្រឹមតែពិន័យជាទឹកប្រាក់តែប៉ុណ្ណោះ។ តាមរយៈនេះ តុលាការគ្មានសិទ្ធិវិនិច្ឆ័យឱ្យភាគីចាញ់ក្តីជាប់ពន្ធនាគារឡើយ។ ផ្ទុយទៅវិញ ក្នុងរឿងក្តីព្រហ្មទណ្ឌ តុលាការត្រូវផ្តន្ទាទោសជនល្មើសឱ្យជាប់ពន្ធនាគារព្រមទាំងទោសពិន័យជាប្រាក់ផងដែរ។ ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមាននៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។ ក្រមនេះមានចំនួន១១គន្តី និង ៦១២មាត្រា។

## ១០.១ គោលបំណងនៃក្រមនីតិវិធីព្រហ្មទណ្ឌ

### ១០.១.១ ក្រមព្រហ្មទណ្ឌ

ជាបទបញ្ញត្តិសម្រាប់កំណត់ពីអំពើទាំងឡាយណាដែលជាបទល្មើស[11]ដោយរួមទាំងធាតុផ្សំនៃបទល្មើសដែលសម្តែងពីបទល្មើសនិងទណ្ឌកម្ម ដែលបង្កគ្រោះថ្នាក់ដល់មនុស្ស សង្គម ការដាក់ទណ្ឌកម្ម ឬផ្តន្ទាទោសចំពោះជនប្រព្រឹត្តបទល្មើស និងបណ្តាករណីដែលត្រូវអនុវត្តទៅលើជនដែលត្រូវទទួលទោស។

ជាបទល្មើសដែលប្រឆាំងការគ្រប់គ្រងរដ្ឋ ការរំលោភបំពានលើអាយុជីវិត សិទ្ធិ សេរីភាព កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលរដ្ឋ ប្រព្រឹត្តអំពើរំលោភបំពានបណ្តាលឱ្យប៉ះពាល់ទ្រព្យសម្បត្តិឯកជន ទ្រព្យសម្បត្តិសាធារណៈ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌជាធរមាន។

ឧទាហរណ៍៖ បទលួច បទរំលោភសេពសន្ថវៈ បទមនុស្សឃាត បទបង្ខាំងមនុស្សដោយខុសច្បាប់...។ បទល្មើសទាំងនេះជាបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។ ជនល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារនិងចេញសងការខូចខាតដល់ជនរងគ្រោះសមល្មមទៅនឹងទំហំនៃការខូចខាត។

### ១០.១.២ ក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រមនេះត្រូវបានប្រើនៅពេលដែលមានរឿងក្តីព្រហ្មទណ្ឌកើតឡើង ដោយឆ្លងកាត់ដំណើរការប្រព័ន្ធតុលាការតាំងពីចាប់ផ្តើមរហូតដល់ចប់ ដើម្បីធានាឱ្យរឿងក្តីនោះបញ្ចប់ដោយយុត្តិធម៌ និងការពារសិទ្ធិរបស់ជនដែលត្រូវចោទប្រកាន់។ បទល្មើសព្រហ្មទណ្ឌកើតឡើងអាចនាំឱ្យមានបណ្តឹងពីរផ្សេងគ្នាគឺបណ្តឹងអាជ្ញានិងបណ្តឹងរដ្ឋប្បវេណី។

ក្រមនីតិវិធីព្រហ្មទណ្ឌមានទំនាក់ទំនងទៅនឹងដំណើរការព្រហ្មទណ្ឌទាំងមូលដោយចាប់ផ្តើមពីការទទួលបានរបាយការណ៍ ឬការរកឃើញមានបុគ្គលណាម្នាក់បានប្រព្រឹត្តបទល្មើស ការស៊ើបសួរដំណើរការរឿងក្តីនៃបទល្មើស ការនាំខ្លួនជនជាប់ចោទទៅតុលាការ និងការជំនុំជម្រះធ្វើការសម្រេចចេញសាលក្រម។ នៅក្នុងដំណើរ

---

[10] តាវកាលិក អ្វីៗដែលជាកម្មវត្ថុនៃកាតព្វកិច្ច, កម្មវត្ថុនៃកិច្ចសន្យា, វត្ថុជាទីតាំងនៃកាតព្វកិច្ចណាមួយ។ ឧទាហរណ៍៖ ស្រូវដែលជនម្នាក់ខ្ចីពីជនម្នាក់ទៀតហៅថា តាវកាលិកនៃការខ្ចី។

[11] បទល្មើស (Offense) អំពើប្រឆាំងនឹងរដ្ឋ, អំពើដែលនាំឱ្យគ្រោះថ្នាក់ដល់សង្គម, អំពើប្រឆាំងនឹងច្បាប់ជាធរមានដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនឹងត្រូវផ្តន្ទាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។

ការនៃនីតិវិធីព្រហ្មទណ្ឌគឺត្រូវបានបែងចែកជាបួន(៤)ដំណាក់កាលគឺ ដំណាក់កាលស៊ើបអង្កេត ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរនិងដំណាក់កាលជំនុំជម្រះ។

## ១០.២ បណ្តឹងអាជ្ញា

បណ្តឹងអាជ្ញា (មាត្រា៣) ជាបណ្តឹងស្របច្បាប់មួយដែលរដ្ឋទទួលបន្ទុកធ្វើបណ្តឹងដោយអយ្យការ[12] ជាតំណាងដើម្បីចោទប្រកាន់ទោសលើបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តបទល្មើសទាក់ទងនឹងរឿងក្តីព្រហ្មទណ្ឌ។

**១០.២.១ បណ្តឹងរដ្ឋប្បវេណី** (មាត្រា១៣-២៦) ទាមទារឱ្យភាគីម្ខាងទៀតជួសជុលការខូចខាត ឬសំណងជំងឺចិត្ត។

**១០.២.២ ការធ្វើបណ្តឹងអាជ្ញានិងបណ្តឹងរដ្ឋប្បវេណី** អាចត្រូវបានផ្តើមបង្កសំណុំរឿងនិងប្តឹងដោយៈ

- អង្គការអយ្យការ
- ជនរងគ្រោះនៃបទល្មើស
- អ្នកតំណាងដែលច្បាប់បានកំណត់ ប្រសិនបើជននោះជាអនីតិជន
- ការបោះបង់មិនធ្វើបណ្តឹងរដ្ឋប្បវេណី មិនអាចបញ្ឈប់ ឬព្យួរការអនុវត្តនៃបណ្តឹងអាជ្ញាបានទេ លើកលែងតែមានមូលហេតុផ្សេង។

## ១០.៣ អាជ្ញាយុកាលនៃបទល្មើស

ចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា បានចែកជាបីប្រភេទ តាមកម្រិតពីទោសធ្ងន់ទៅស្រាលដូចជា ១៥ឆ្នាំចំពោះបទឧក្រិដ្ឋ ៥ឆ្នាំចំពោះបទមជ្ឈិម និង១ឆ្នាំចំពោះបទលហុ[13]។ គ្មានការផុតអាជ្ញាយុកាលទេចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មសង្គ្រាម និងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

## ១០.៤ អង្គការអយ្យការ

អង្គការអយ្យការ ជាស្ថាប័នឯករាជ្យមួយនៅក្នុងប្រព័ន្ធតុលាការដោយធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌនិងធ្វើការសន្និដ្ឋានដើម្បីបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរហើយត្រូវបញ្ជូនជនជាប់ចោទឱ្យតុលាការជំនុំជម្រះតាមនីតិវិធីច្បាប់។ សាលាជម្រះក្តីជាន់ទាប ឬតុលាការដំបូង(សាលាដំបូងរាជធានី-ខេត្ត) សាលាជម្រះក្តីជាន់ខ្ពស់ (តុលាការឧទ្ធរណ៍និងតុលាការកំពូល)[14]។

- សាលាជម្រះក្តីជាន់ខ្ពស់ៈ ត្រូវមានអង្គការអយ្យការអមមួយក្នុងនោះមានសមាសភាព អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា។
- សាលាជម្រះក្តីជាន់ទាបៈ ត្រូវមានអង្គការអយ្យការអមមួយក្នុងនោះមានមានសមាសភាព ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង[15]។

## ១០.៥ ប្រាក់ប្រដាប់ក្តី

ក្នុងរឿងក្តីព្រហ្មទណ្ឌ ប្រាក់ប្រដាប់ក្តីមានពីរប្រភេទគឺ ៖

---

[12] អយ្យការ (Prosecution) ស្ថាប័នរបស់ព្រះរាជអាជ្ញា, ភាគីដើមចោទក្នុងរឿងព្រហ្មទណ្ឌ។

[13] មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[14] មាត្រា៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[15] មាត្រា៧៤ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា

- ប្រាក់ប្រដាប់ក្តី[16] ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់រដ្ឋ។ បញ្ជីនៃប្រាក់ប្រដាប់ក្តី តារាងតម្លៃនៃប្រាក់ប្រដាប់ក្តី និងវិធីទូទៅត្រូវកំណត់ដោយប្រកាស។

- ប្រាក់ពន្ធនៃនីតិវិធី[17] ទណ្ឌិតម្នាក់ៗ ត្រូវបង់សរុបនៃនីតិវិធីជូនរដ្ឋ។ ចំនួនប្រាក់នៃនីតិវិធីអាចប្រែប្រួលទៅតាមប្រភេទរឿងក្តី។ ចំនួនប្រាក់នៃនីតិវិធីត្រូវកំណត់ដោយប្រកាស។

## ១០.៦ចៅក្រមស៊ើបសួរ

ការស៊ើបសួរត្រូវតែជាការសម្ងាត់[18]។ ការបំពានទៅលើការសម្ងាត់នៃការស៊ើបសួរ នោះគឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

ប្រសិនបើ ចៅក្រមស៊ើបសួរណាម្នាក់ មិនអាចបំពេញមុខងាររបស់ខ្លួនបានដោយមូលហេតុផ្សេងៗ ប្រធានតុលាការ អាចចាត់ចៅក្រមស៊ើបសួរណាម្នាក់ផ្សេងទៀតដើម្បីជំនួស ឬអាចចាត់ចៅក្រមផ្សេងទៀត ដើម្បីបំពេញមុខងារស៊ើបសួរជាបណ្តោះអាសន្ន។

ចៅក្រមស៊ើបសួរ គឺស៊ើបសួររឿងរ៉ាវអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ប៉ុន្តែចៅក្រមស៊ើបសួរក៏អាចស៊ើបសួរបានដែរដោយមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ បើអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសទៅលើអង្គហេតុចាស់។ ចៅក្រមស៊ើបសួរមិនអាចចូលរួមក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌណាដែលខ្លួនបានស៊ើបសួររួចឡើយ បើពុំនោះទេ ការជំនុំជម្រះនឹងត្រូវចាត់ទុកជាមោឃៈ។ ចំពោះការបើកការស៊ើបសួរត្រូវធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន[19]។

## ១០.៧ នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ។ នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង[20]។

### ១០.៧.១ សមត្ថភាពនគរបាលយុត្តិធម៌[21]

- មន្ត្រីនគរបាលយុត្តិធម៌ (មាត្រា៦០-៧៥)
- ភ្នាក់ងារនគរបាលយុត្តិធម៌ (មាត្រា៧៦-៨០)
- មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន(មាត្រា៨២) ។

### ១០.៧.២ សកម្មភាពមន្ត្រីនគរបាលយុត្តិធម៌

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌

- ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា
- ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើសជាក់ស្តែង
- ត្រូវធានារ៉ាប់រង រក្សាទុកតម្រុយភស្តុតាង

---

16 មាត្រា៥៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

17 មាត្រា៥៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

18 មាត្រា១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

19 មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

20 មាត្រា៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

21 មាត្រា៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- ហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅណាឆ្ងាយពីទីកន្លែងបទល្មើសរហូតបញ្ចប់ប្រតិបត្តិការរបស់ខ្លួន
- ត្រូវធ្វើកំណត់ហេតុ ស្ដីពីការស្រាវជ្រាវនិងការពិនិត្យរបស់ខ្លួន
- អាចហៅនិងនាំមកកាន់អង្គភាពរបស់ខ្លួនចំពោះបុគ្គលណាដែលសង្ស័យថាបានប្រព្រឹត្តបទ ល្មើស ។

## ១០.៨ ការឃាត់ខ្លួន និងការចាប់ខ្លួន

### ១០.៨.១ ការឃាត់ខ្លួន

បុគ្គលដែលអាចជាកម្មវត្ថុនៃការចាប់ខ្លួនគឺ ជនសង្ស័យថាបានប្រព្រឹត្ត ឬចូលរួមប្រព្រឹត្តបទល្មើសនិងបុគ្គលដែលអាចផ្ដល់ព័ត៌មាន ដោយបានប្រកែកមិនព្រមផ្ដល់ព័ត៌មាននិងមានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។ ជនដែលជានីតិជនអាចឃាត់ខ្លួនបានរយៈពេល៤៨ម៉ោង អាចពន្យាពេលឃាត់ខ្លួនបានដោយសុំទៅព្រះរាជអាជ្ញាដើម្បីធ្វើការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អក្នុងករណីមានតម្រុយដែលបង្ហាញឱ្យឃើញថាមានតម្រុយពិរុទ្ធភាព[22]។ ការពន្យាពេលនេះមិនអាចធ្វើលើសរយៈពេល២៤ម៉ោងឡើយ នេះមិនគិតពីពេលវេលាចាំបាច់ក្នុងការដឹកជញ្ជូនជនសង្ស័យ។ ការឃាត់ខ្លួនហួសរយៈពេលកំណត់ត្រូវបញ្ជូនជនសង្ស័យទៅព្រះរាជអាជ្ញា ឬត្រូវដោះលែងឱ្យមានសេរីភាពឡើងវិញតាមសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញា។

❖ **រយៈពេលនៃការឃាត់ខ្លួនចំពោះ**

- អនីតិជន អាយុពី១៤ទៅក្រោម ១៦ឆ្នាំ ៣៦ម៉ោង(ឧក្រិដ្ឋ) ២៤ម៉ោង(មជ្ឈិម)
- អនីតិជន អាយុពី១៦ទៅក្រោម១៨ឆ្នាំ ៣៨ម៉ោង(ឧក្រិដ្ឋ) ៣៦ម៉ោង(មជ្ឈិម)
- អនីតិជន អាយុក្រោម១៤ឆ្នាំ មិនអាចឃាត់ខ្លួនបានឡើយ។

គ្រប់អនីតិជនមិនអាចពន្យាពេលនៃការឃាត់ខ្លួនឡើយ។ រាល់ការឃាត់ខ្លួន ត្រូវជូនដំណឹងដល់អាណាព្យាបាល អ្នកតំណាងស្របច្បាប់លើអនីតិជននោះ សិទ្ធិរបស់បុគ្គលឃាត់ខ្លួនមានពីរគឺ សិទ្ធិសន្ទនាជាមួយមេធាវីឬបុគ្គលផ្សេងទៀត និងសិទ្ធិឱ្យពេទ្យពិនិត្យលើស្ថានភាពសុខភាពរបស់បុគ្គលឃាត់ខ្លួនថាតើអាចទទួលស្ថិតនៅក្នុងស្ថានភាពឃុំខ្លួនដែរឬទេ។

### ១០.៨.២ ការចាប់ខ្លួន

ការចាប់ខ្លួន ជាសកម្មភាពរបស់កម្លាំងសាធារណៈ ជាពិសេសសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការចាប់ខ្លួន និងនាំខ្លួនជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាព នៅចំពោះមុខចៅក្រមស៊ើបសួរ។

ការចាប់ខ្លួន នគរបាលយុត្តិធម៌ត្រូវតែមានដីកាពីព្រះរាជអាជ្ញា។ ពុំចាំបាច់ត្រូវមានដីកាទេ ចំពោះករណីបទល្មើសជាក់ស្ដែង (ដេញប្រដាប់ចាប់ប្រកឹង)៕

---

[22] ពិរុទ្ធភាព គឺភាពជាអ្នកមានពិរុទ្ធ(ស្ថិតក្នុងការត្រួតពិនិត្យរកកំហុស)

# ជំពូកទី២ ទស្សនវិជ្ជាសង្គមនយោបាយ

# មេរៀនទី១ ប្លាតុង

( Plato/ARISTOCLES 427-347 BC )

## ១.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ

ប្លាតុង គឺជាទស្សនវិទូក្រិចដ៏ល្បីល្បាញដែលបានកើតនៅឆ្នាំ៤២៧មុនគ.សក្នុងត្រកូលអភិជនមួយនៅទីក្រុងអាថែន។ ឪពុកលោកឈ្មោះ អារីស្តុង( Ariston )ជាម្ចាស់ទាសករនៅអេហ្ស៊ីនដែលកើតក្នុងរាជវង្សCodreជាព្រះរាជាចុងក្រោយនៃក្រុងអាថែន ហើយម្តាយគាត់ឈ្មោះ Perictione ជាបុត្រីនៃអ្នកតាក់តែងច្បាប់នីតិក្រមដ៏ល្បីល្បាញម្នាក់ឈ្មោះ Solona នាទីក្រុងអាថែន។ ឈ្មោះដើមរបស់គាត់គឺ Aristocles ប៉ុន្តែដោយគាត់មានមាឌធំ ទើបគេហៅលោកថា ប្លាតុង ដែលតាមភាសាក្រិចមានន័យថាធំសម្បើម។ លោករីកធំធាត់ក្នុងសម័យសង្គ្រាម និងធំពេញពេញវ័យនៅពេលសង្គ្រាមត្រូវបានបញ្ចប់។ លោកមានរូបរាងស្អាតបាតសុភាពរាបសារ និងមិនវាយឬកលើកកម្ពស់ ឬមើលងាយអ្នកដែលមានសមត្ថភាពទាបជាងគាត់ឡើយ។ លោកបានរៀនសូត្រជាមួយគ្រូជាច្រើនមុនស្គាល់លោកសូក្រាត។ សូក្រាត មុនពេលត្រូវបានប្រហារជីវិតបានផ្តាំទៅប្លាតុងថា " *ប្លាតុង! ចូរអ្នកដើរតាមមាគ៌ាសច្ចធម៌ ហើយចូរអ្នកកសាងសង្គមផ្លូវចិត្តឱ្យរស់ក្នុងភាពយុត្តិធម៌ ហើយបើស្លាប់ក៏ស្លាប់ដោយយុត្តិធម៌ ចូរកុំបំបាត់សេចក្តីពិតដែលប្រជាជនចង់បាន ចូរអ្នកបម្រើមនុស្សទាំងអស់ដែលនៅជុំវិញឱ្យលើសពីអ្វីដែលអ្នកចង់ ផ្លូវមួយទៀតដែលអ្នកត្រូវមានហើយដោយខានមិនបាននោះគឺ* មេត្តាធម៌"។

ប្លាតុង សង្ឃឹមចង់បានសាធារណរដ្ឋនៃយុត្តិធម៌ និងសន្តិភាព ចង់ឱ្យទស្សនវិទូគ្រប់គ្រងប្រទេសដែលមានសង្គមមួយដ៏ល្អឥត ខ្ចោះក្នុងមនោគតិគឺ " គំនិតដ៏ល្អឥតខ្ចោះ "។ លោកបានភៀសខ្លួនចេញពីទីក្រុងអាថែនក្រោយពេលដែលតុលាការចេញដីការចាប់ខ្លួន ហើយទីបំផុតបានទៅដល់ក្រុងស៊ីរ៉ាគុសដោយចងសម្ព័ន្ធមិត្តជាមួយ ឌីយ៉ុងជាប្អូនថ្លៃស្តេចឌីនីស ដែលចាប់ប្លាតុងដាក់គុកដោយសង្ស័យពីការរួមគំនិតក្បត់។ នៅឆ្នាំ៣៦១មុនគ.ស លោកបានទៅទស្សនកិច្ចលើកទី៣នៅក្រុងស៊ីរ៉ាគុស ហើយក្លាយជាទីប្រឹក្សាស្តេចឌីនីសទី២ (Dionysius II)។ លោក ប្លាតុងធ្វើការអង្កេតរបបគ្រប់គ្រងផ្សេងៗដែលនៅជុំវិញប្រទេសគាត់ ដោយឱ្យនិយមន័យពីគុណប្រយោជន៍ និងផលវិបាកនៃរបបគ្រប់គ្រងរដ្ឋនីមួយៗ។ គំនិតដែលលោករកឃើញដំបូង គឺគំនិតគ្រប់គ្រងសង្គមដ៏ល្អឥតខ្ចោះ គឺមាននៅក្នុងស្នាដៃ៣៖ La République, Les Lois, La Politique។

## ១.២ ទស្សនៈនយោបាយ

ទស្សនវិជ្ជារបស់ប្លាតុងបានទទួលឥទ្ធិពលពីសង្គ្រាមក្នុងស្រុកយ៉ាងខ្លាំងពិសេសឥទ្ធិពលពីវណ្ណៈម្ចាស់ទាសករអភិជន។ តែការសិក្សាពីបញ្ហានយោបាយរបស់ ប្លាតុង មានលក្ខណៈពិបាកយល់បន្តិច ព្រោះអ្វីៗត្រូវបានបកស្រាយតាមទ្រឹស្តីពិភពគំនិតដែលជាឫសកែវនៃទស្សនវិជ្ជាប្លាតុងទាំងអស់។

លោក ប្លាតុង គឺឃ្លាតឆ្ងាយពីនយោបាយនាក្រុងអាថែន ហើយក៏មិនដែលមានតួនាទីអ្វីក្នុងរដ្ឋាភិបាលសោះ។ លោកមានការនឹកស្រម៉ៃបង្កើតបុរីដែលពុំមានអត្ថិភាពសោះ ដែលចេញពីការពិចារណាលើទស្សនវិជ្ជារបស់គាត់។ នៅក្នុងស្នាដៃដ៏សំខាន់មួយគឺសាធារណរដ្ឋរបស់ ប្លាតុង គេមានលទ្ធភាពទាញចេញគំនិតជាមូលដ្ឋានបីដូចតទៅ៖

### ១.២.១ធម្មជាតិនៃនយោបាយ

លោក ប្លាតុង នយោបាយបានលេចឡើងជាបឋមដូចចំណេះដឹងនៃសភាវគតិសម្រាប់អប់រំមនុស្សទូទៅ។ បន្ទាប់មកនយោបាយបានក្លាយទៅជាសិល្បៈនៃការដឹកនាំសង្គមមនុស្សដោយមានការយល់ព្រមជាមួយ។ ប្លាតុងបានបញ្ជាក់ថា ការគ្រប់គ្រងបែបផ្តុំអំណាចលើមនុស្សតិចបំផុត (Tyrannie) ជាសិល្បៈនៃការគ្រប់គ្រង " ដោយ

កម្លាំង "។ ដោយឡែកចំពោះអ្នកធ្វើនយោបាយ (Politique) គឺជាអ្នកដែលស្គាល់នូវសិល្បៈដ៏លំបាកនេះ។ អ្នកធ្វើនយោបាយមិនមែនជាអ្នកប្រើប្រាស់មុខងារតែមួយនោះទេ តែជាអ្នកប្រើប្រាស់នូវគុណសម្បត្តិជាមនុស្សជាតិ។

លោក ប្លាតុង បានបែងចែករវាងនយោបាយ និងសិល្បៈផ្សេងៗទៀតដូចតទៅនេះ៖

- នយោបាយមិនមែនជាវិទ្យាសាស្ត្រយោធាទេ។ ពិតមែនហើយថាអ្នកនយោបាយជាអ្នកសម្រេចថាធ្វើសង្គ្រាម ឬកសាងសន្តិភាព ប៉ុន្តែល្បិចជាយុទ្ធសាស្ត្រទេដែលពង្រឹងឱ្យទទួលបានជ័យជម្នះ។

- នយោបាយមិនមែនជាសាលក្រមតុលាការដែលជាសិល្បៈសម្រេចក្តីកេយុត្តិធម៌នោះទេ។ យុត្តិធម៌ចំណុះនយោបាយដែលជាអ្នកកំណត់ច្បាប់។

-នយោបាយមិនមែនជាការអួតសរសើរនោះទេ ទោះបីជាការអួតសរសើរនោះបានរួមចំណែកដល់នយោបាយក៏ដោយ។ សិល្បៈនៃសំនួនវោហាមានភាពចាំបាច់ណាស់ដល់នយោបាយសម្រាប់ធ្វើឱ្យគេជឿ។ ដូចនេះ នយោបាយមាននៅគ្រប់ទីកន្លែងទាំងអស់។ លោក ប្លាតុង បានធ្វើការវិភាគអ្នកនយោបាយមួយចំនួនដែលកំពុងធ្វើប្រតិបត្តិការពិតប្រាកដ មិនមែនមានលក្ខណៈតែសកម្មភាពនយោបាយទេ តែមានភាពចំណុះគ្នាទៅវិញទៅមក។ ក្នុងតថភាពនយោបាយជារដ្ឋបាល ច្បាប់ ជាការទូត។ រដ្ឋមួយដែលគ្មានការគ្រប់គ្រង ជារដ្ឋដែលមានបទបញ្ជាខុសប្លែកគ្នា គ្មានភាពសម្របគ្នាដោយគំនិតឆន្ទៈតែមួយនៃឋានានុក្រមថ្នាក់លើ។

**១.២.២ គោលការណ៍នៃរដ្ឋអំណាច**

យោងតាមគំនិត ប្លាតុង អំណាចគឺជាអាជ្ញាកណ្តាលផង និងជាភាពផ្តាច់ការផង។

ភាពជាអាជ្ញាកណ្តាល៖ ពីព្រោះថាពន្លកនៃនយោបាយគឺស្ថិតនៅលើថ្នាក់ច្បាប់ដែលសង្គមបានកំណត់។ ដើម្បីបញ្ជាឱ្យបានល្អ គេត្រូវបញ្ជាផ្ទាល់ទៅបុគ្គលម្នាក់ៗ ពោលគឺមិនត្រូវបញ្ជាក្នុងផ្លូវទូទៅនោះទេ។ តើបញ្ជាតាមផ្លូវណាទើបមានលទ្ធភាព?

ភាពផ្តាច់ការ៖ គឺមានការយល់ច្រឡំថាទុកឱ្យមនុស្សម្នាក់ៗរស់នៅតាមបំណងរបស់ខ្លួនត្រូវជឿថា មិនចាំបាច់អ្នកទាំងអស់គ្នាសុទ្ធតែស្ថិតនៅក្រោមអាជ្ញានោះទេ។ ប្លាតុង បញ្ជាក់ទៀតថា អ្វីៗដែលបានកើតឡើងនៅក្នុងរដ្ឋតាមបទបញ្ជា និងក្រោមការដឹកនាំរបស់ច្បាប់ នោះប្រភពនៃទ្រព្យសម្បត្តិនឹងកើតមានហូរហៀរមិនចេះចប់។ ប្លាតុង គិតដល់ការធានាសុភមង្គលរបស់រដ្ឋតាមរយៈស្ថិរភាព និងសន្តិភាព តែភ្លេចគិតដល់បុគ្គល។ ដូច្នេះ ដើម្បីប្រើប្រាស់អំណាចក្នុងកេរ្តិ៍ឈ្មោះរបស់ប្លាតុងគេត្រូវបង្ហាញនូវគុណភាពជាមូលដ្ឋានគឺបញ្ញា ទេពកោសល្យ និងសច្ចធម៌។ នយោបាយមនោគតិគឺជាអ្វីៗដែលមានវិទ្យាសាស្ត្រនយោបាយ និងសច្ចធម៌មិនខ្សោយពេក និងមិនប្រើហិង្សាពេក។ គំនិតប្លាតុងគឺចង់ឱ្យរដ្ឋគ្រប់គ្រងបានល្អ លោកចង់ឱ្យទស្សនវិទូក្លាយទៅជាស្តេចហើយឱ្យស្តេចក្លាយជាទស្សនវិទូ។

ចេញពីការសន្និដ្ឋាននេះ យើងអាចទាញចេញពីគំនិតប្លាតុងនូវគោលការណ៍ជាសារវន្តមួយចំនួនដែលកំណត់លក្ខខ័ណ្ឌនៃអំណាចដូចតទៅ៖

**១.២.២.១ គោលការណ៍ទី១**

អំណាចត្រូវធ្លាក់លើដៃអ្នកចេះដឹង គឺស្ថិតនៅក្នុងដៃពិតនៃមេដឹកនាំឆ្លាតវៃ។ មេដឹកនាំរដ្ឋត្រូវដឹកនាំបម្រើឆន្ទៈទូទៅ ទោះបីជាអ្នកមានឬអ្នកក្រ។ មេដឹកនាំត្រូវមានចំណេះដឹង ហើយរួមទាំងមានបទពិសោធន៍ ទេពកោសល្យខ្ពស់នៃការបញ្ជាទូទៅ។

**១.២.២.២ គោលការណ៍ទី២**

រដ្ឋាភិបាលនៃពួកទស្សនវិទូជារដ្ឋាភិបាលដែលប្លាតុងបានអនុវត្តនូវគោលការណ៍ដោយប្រគល់ការប្រើប្រាស់អំណាចទៅឱ្យជនផ្តាច់ការភ្លឺស្វាងដែលព្រមទទួលយកការណែនាំល្អត្រឹមត្រូវភ្លឺស្វាងពីទស្សនវិទូម្នាក់។ តាមរយៈគំនិតនេះលោកប្លាតុងបានរំលឹកពីបំណងរបស់ខ្លួនបីដងដើម្បីក្លាយជាទីប្រឹក្សានៃស្តេចកោះស៊ីស៊ីល។

### ១.២.២.៣ គោលការណ៍ទី៣

ការផ្ទេរអំណាចដែលប្រព្រឹត្តិទៅពីអ្នកប្រាជ្ញម្នាក់ទៅអ្នកប្រាជ្ញម្នាក់ទៀតដូចជំនាន់មុនរបស់លោកដែរ ប្លាតុង បានបែងចែកប្រជាពលរដ្ឋជាវណ្ណៈបីប្រទេស។ អ្នកច្បាប់ជាអ្នកគ្រប់គ្រងក្នុងរដ្ឋាភិបាល ពួកអ្នកធ្វើចំបាំងជាអ្នកការពារ និងកសិករ សិប្បករ ជាអ្នកធ្វើហត្ថកម្ម។ ពលរដ្ឋនីមួយៗជាអាទិភាពត្រូវតែចាត់ចូលទៅក្នុងវណ្ណៈមួយក្នុងចំណោមវណ្ណៈទាំងបីនេះ។ តាំងពីកុមារភាពតាមរយៈការសិក្សា គេនឹងកត់សម្គាល់ថា អ្នកណានឹងក្លាយទៅជាអ្នកច្បាប់ អ្នកណានឹងក្លាយទៅជាអនាគតអ្នកចំបាំង។

ប្លាតុង បានប្រកាសសមភាពរវាងភេទ ចំណុចនេះលោកបានកំណត់យ៉ាងច្បាស់លាស់ ″ ស្ត្រីភេទត្រូវតែមានតួនាទីយ៉ាងសំខាន់នៅក្នុងការដឹកនាំ ហើយត្រូវតែធ្វើបាននូវអ្វីៗទាំងអស់ដូចបុរសដែរ ″។

### ១.២.៣ រដ្ឋ និងទម្រង់ផ្សេងៗនៃរដ្ឋាភិបាល

ចំពោះរដ្ឋ ប្លាតុងបាននិយាយថាសង្គមគឺជាការប្រមូលផ្តុំនៃបុគ្គលទាំងឡាយដែលមានឆន្ទៈរួមរស់ជាមួយគ្នា។ ការប្រមូលផ្តុំនេះបានបង្កើតឱ្យមានការងារជាច្រើន ហើយម្នាក់ៗកាន់តែមានជំនាញ។ ប៉ុន្តែការរស់នៅបែបនេះពុំទាន់មានស្ថិរភាពប៉ុន្មានទេ។ ហេតុនេះលោកបានប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីឱ្យបុគ្គលទាំងនោះរស់នៅក្រោមការគ្រប់គ្រងរបស់រដ្ឋ។

តាមប្លាតុង រដ្ឋគឺជាការប្រមូលផ្តុំមនុស្សនៅលើទឹកដីមួយ ហើយនៅលើទឹកដីនោះសណ្តាប់ធ្នាប់សង្គមនយោបាយ និងនីតិសាស្ត្រឆ្ពោះទៅរកផលប្រយោជន៍រួម ដែលគ្រប់គ្រងដោយរដ្ឋាភិបាលដែល មានអំណាចបង្ខំ។ រដ្ឋជាការប្រមូលផ្តុំបុគ្គលជាច្រើនហើយមានអត្ថិភាពសម្រាប់ដឹកនាំទៅរកជីវិតល្អ។ ប្លាតុងបានធ្វើការគូសបញ្ជាក់យ៉ាងច្បាស់ពីបុព្វហេតុនៃការបែងចែករដ្ឋ។ វាតែងមានអ្នកដែលត្រូវគេដឹកនាំ និងអ្នកដែលដឹកនាំគេ។ យ៉ាងហោចណាស់ក៏គាត់មានការយល់ដូចគោលការណ៍របស់អារីស្តូតដែលថាបុព្វហេតុនៃអស្ថិរភាព និងការផ្លាស់ប្តូររបបនយោបាយគឺគ្មានឯកភាពទេនៅក្នុងក្រុមដឹកនាំ។ ការរកឃើញគោលការណ៍ដែលអាចរក្សាក្រុមដឹកនាំឱ្យមានឯកភាពនោះ ប្លាតុង យល់ថាគាត់បានរកឃើញក្នុងគោលការណ៍យុត្តិធម៌។ មានក្រមសីលធម៌ដាច់ខាតមួយដែលគ្រប់គ្រងមនុស្ស និងរដ្ឋទាំងអស់។ ប្លាតុង មិនបានមើលរដ្ឋថាជាលក្ខណៈឬជាអង្គការដែលអភិវឌ្ឍខ្លួនឯងដោយគ្មានព្រំដែនដោយគ្មានខ្វល់នឹងច្បាប់សីលធម៌នោះទេ។ ប្រភពនៃក្រមសីលធម៌ផ្ទាល់របស់វា ជាអ្វីអាចមាននៅពេលក្រោយ វាមិនមែនជាអាជ្ញាកណ្តាលនៃត្រូវ និងខុស ហើយមិនមែនជាការយល់ឃើញថាត្រូវដាច់ខាតនៃសកម្មភាពផ្ទាល់របស់វាដែរ។ អ្វីដែលពាក់ព័ន្ធនឹងគោលការណ៍យុត្តិធម៌ គឺដូចគ្នាទៅនឹងបុគ្គល និងរដ្ឋ ពីព្រោះសូក្រាតបានស្នើសុំថា៖″ យើងស៊ើបអង្កេតធម្មជាតិយុត្តិធម៌ និងអយុត្តិធម៌នៅពេលកើតឡើងទី១ នៅក្នុងរដ្ឋ ហើយទី២នៅក្នុងបុគ្គលដែលបណ្តាលមកពីយុត្តិធម៌មានកាន់តែច្រើន អយុត្តិធម៌មានកាន់តែតិច ហើយប្រៀបធៀបពួកវា ″។

ប្រសិនបើបុគ្គលរស់នៅក្នុងជីវិតរបស់គេជាសមាជិកនៃរដ្ឋ ហើយប្រសិនបើយុត្តិធម៌នៃបុគ្គល ជាយុត្តិធម៌នៃអ្នកផ្សេងៗទៀត គឺត្រូវបានគេកំណត់ដោយយុត្តិធម៌ឧត្តមគតិ ខណៈនោះគ្មានបុគ្គលណា ឬ រដ្ឋណាអាចឱ្យរួចខ្លួនពីក្រមសីលធម៌អមតៈឡើយ។ សព្វថ្ងៃនេះគ្មានរដ្ឋធម្មនុញ្ញ ឬរដ្ឋាភិបាលណាដែលតំណាងឱ្យគោលការណ៍យុត្តិធម៌ឧត្តមគតិឡើយ។ ប៉ុន្តែ ប្លាតុង ខ្វាយខ្វល់ដើម្បីកំណត់ថាតើអ្វីជារដ្ឋបែបពិសោធន៍ច្រើន ដូចអ្វីដែលរដ្ឋគួរធ្វើនោះទេ។ នៅក្នុងសៀវភៅ The Republic គាត់បានរកឃើញរដ្ឋគំនិត(Ideal State) ដែលជារដ្ឋគំរូចំពោះរដ្ឋទាំងអស់។ តម្រូវការដំបូងរបស់រដ្ឋគឺជាការគិតនៃកង្វះខាតផ្ទាល់ខ្លួនរបស់មនុស្ស។ ប្លាតុង ពោលថាៈ″ រដ្ឋចាប់ផ្តើមមានអត្ថិភាពព្រោះគ្មានបុគ្គលណាមានការ គ្រប់គ្រាន់ផ្ទាល់ខ្លួនទេ យើងទាំងអស់គ្នាមានតម្រូវការជាច្រើន ″។

តម្រូវការជាច្រើនរបស់យើងតម្រូវឱ្យមានជំនាញជាច្រើនដែរ។ ដូច្នេះអត្ថិភាពរដ្ឋដែលបច្ចុប្បន្នកំពុងត្រូវបានគេពិចារណាអំពីទស្សនៈសេដ្ឋកិច្ច និងតម្រូវការឱ្យមានវត្តមាននៃមេគ្រួសារ អ្នកតម្បាញ អ្នកផលិតស្បែកជើង ជាងឈើ ជាងដែក ឬមាស អ្នកគង្វាលចៀម ពាណិជ្ជករ ឈ្មួញតូចតាច និងអ្នកគេ ជួលធ្វើការ។ល។ ប៉ុន្តែវាជាប្រភេទរដ្ឋ

គ្រោតគ្រាតនៃជីវិតដែលរដ្ឋត្រូវបានដឹកនាំដោយពួកទាំងនេះ។ ប្រសិនបើពិតជាមានបុរីរីកចម្រើនអ្វីៗបន្ថែមទៀត នឹងត្រូវបានគេតម្រូវឱ្យមានអ្នកតន្ត្រី កវី គ្រូបង្រៀន ពេទ្យ ជាងកាត់សក់ អ្នកធ្វើម្ហូប អ្នកធ្វើបង្អែម និងអ្នកផ្សេងៗទៀតនឹងធ្វើឱ្យឃើញពីលក្ខណៈខាងក្រៅរបស់ពួកគេ។ ប៉ុន្តែជាមួយនឹងការកើនឡើងនៃប្រជាពលរដ្ឋដែលជាផលវិបាកទៅលើការរីកលូតលាស់ នៃទីក្រុង ទឹកដីនឹងមានការខ្វះខាតសម្រាប់តម្រូវការទីក្រុង ហើយទឹកដីអ្នកជិតខាងខ្លះនឹងត្រូវបានគេបញ្ចូលជាឧបសម្ព័ន្ធ។ ប្លាតុង រកឃើញប្រភពដើមនៃសង្គ្រាម គឺបុព្វហេតុសេដ្ឋកិច្ច។ ម្យ៉ាងវិញទៀត ប្លាតុង បាននិយាយថា រដ្ឋនឹងជះឥទ្ធិពលទៅលើប្រភេទមនុស្សដែលបានក្លាយទៅជាសហគម។ អ្វីដែលគាត់មាននៅក្នុងគំនិត គឺតាមរយៈធម្មជាតិមនុស្សដែលគេបានកំណត់ ក្នុងនោះពួកគេទាំងអស់គ្នាមានបីផ្នែក។ ប្រភេទមនុស្សផ្អែកទៅលើកម្រិតនៃភាពស្រុះស្រួលគ្នាខាងក្នុងដែលពួកគេបានសម្រេចគោលបំណង។

ប្លាតុងបានបែងចែករដ្ឋជាពីរទម្រង់ គឺទម្រង់សុក្រិត និងទម្រង់អសុក្រិត។ នៅក្នុងទម្រង់នីមួយៗទាំងពីរប្រភេទនេះ លោកបានធ្វើការបែងចែកជាបីបន្តទៀត ដែលសរុបទាំងអស់ចំនួន៦ទម្រង់រដ្ឋ។ ទម្រង់រដ្ឋនីមួយៗទាំង៦នេះ លោកបានសម្គាល់ទៅលើការប្រើប្រាស់អំណាចក្នុងរូបភាពបីយ៉ាងគឺ៖

- អំណាចស្ថិតក្នុងដៃបុគ្គលម្នាក់
- អំណាចស្ថិតក្នុងដៃមនុស្សមួយក្រុម
- អំណាចស្ថិតក្នុងដៃមហាជនទូទៅ

| ដឹកនាំដោយ | ទម្រង់សុក្រិត(ស្របច្បាប់) | ទម្រង់អសុក្រិត(មិនស្របច្បាប់) |
|---|---|---|
| បុគ្គលម្នាក់ | រាជានិយម (Monarchy) | ប្រជាហិង្សា (Tyranny) |
| បុគ្គលមួយក្រុម | អភិជនាធិបតេយ្យ (Aristocracy) | អប្បជនាធិបតេយ្យ (Oligarchy) |
| មហាជនទូទៅ | ប្រជាធិបតេយ្យ (Tymocracy) | ប្រជាធិបតេយ្យ (Democracy) |

ប្លាតុង ការជ្រើសរើសទម្រង់រដ្ឋាភិបាលដែលមានទម្រង់ល្អជាងគឺរបបរាជានិយម និងអភិជនាធិបតេយ្យដែលបានសេចក្ដីថា ជារដ្ឋាភិបាលនៃពលរដ្ឋដឹកនាំដោយទស្សនវិទូ។

ប្លាតុង អះអាងថា «សមភាពពីកំនើត បង្ខំឱ្យមានច្បាប់សមភាពសម្រាប់ទាំងអស់គ្នាដែលបានសរសេរទុកនៅក្នុងច្បាប់ និងជាកាតព្វកិច្ចសម្រាប់ទាំងអស់គ្នាធ្វើសកម្មភាពចំពោះគ្នាទៅវិញទៅមកក្នុងលក្ខខណ្ឌដ៏ប្រកបមួយគឺពោរពេញទៅដោយកម្លាំងកិត្យានុភាព វីរភាព និងវិចារណញ្ញាណ»។

ទស្សនៈរបស់ Plato ចំពោះតួនាទីរបស់មេដឹកនាំរដ្ឋគំរូ គឺចំពោះអ្នកណាមួយដែលស្ម័គ្រចិត្តមិនចង់ធ្វើជាអ្នកដឹកនាំទាល់តែសោះ តែចង់ធ្វើការកែកំហុសរបស់អ្នកដទៃ។ អ្នកដែលមិនមែនជាអ្នកដឹកនាំគំរូគឺសំដៅទៅលើអ្នកណាដែលស្រលាញ់ខ្លួនឯងស្រលាញ់លុយនិងស្រលាញ់បុណ្យស័ក្តិ។ ពីព្រោះអ្នកដឹកនាំណាមួយដែលមានលក្ខណៈដឹកនាំល្អសុទ្ធសាធនោះ មិនមែនធ្វើសកម្មភាព ដើម្បីតែខ្លួនឯងនោះទេ គឺដើម្បីភាពសំបូរសប្បាយរុងរឿងជូនអ្នកដែលនៅក្រោមបង្គាប់របស់ខ្លួន។

ប្លាតុង បានបង្ហាញថាបើនៅក្នុងរដ្ឋសុទ្ធតែមនុស្សល្អនោះលទ្ធភាពក្នុងការកាន់អំណាចនឹងមានច្រើន។ ប៉ុន្តែមេដឹកនាំពិតប្រាកដ ត្រូវមានគុណសម្បត្តិល្អ សម្រាប់ខ្លួនឯងផងនិង សម្រាប់អ្នកនៅក្រោមបញ្ជាផង។ ហេតុដូច្នេះអ្នកដែលដឹកនាំល្អបំផុតមានលក្ខណៈវិសេសវិសាលឆ្លាតវៃជាងគេមានសមត្ថភាពខ្ពស់ជាងគេមានវង្សត្រកូលប្រកបទៅដោយគុណធម៌ ហើយលើសពីនេះទៅទៀត គឺត្រូវគិតគូរដល់អ្នកដទៃ និងរដ្ឋ។ មានន័យថាការងាររួម គឺជាការងាររបស់ខ្លួនផ្ទាល់ជ័យជម្នះទៅលើការងាររួមក៏ជាជ័យជម្នះរបស់ខ្លួនឯងដែរ។ ត្រូវតែជ្រើសរើសមេដឹកនាំដែលមានគុណសម្បត្តិដូច្នេះ។ ព្រោះទិសដៅនៅក្នុងជីវិតគឺដើម្បីវឌ្ឍនភាពរដ្ឋ។

គុណសម្បត្តិដ៏សំខាន់សម្រាប់មេដឹកនាំតាមទស្សនៈរបស់ប្លាតុង គឺសីលធម៌ ភាពនឹងធ្ងន់ មិនឆេវឆាវ។ ប្លាតុងបានចង្អុលបង្ហាញគុណសម្បត្តិមេដឹកនាំ ដើម្បីអាចបង្កឱកាសឱ្យអ្នកធ្វើការជុំវិញបណ្ដុំទៅដោយមនុស្សស្ម័គ្រចិត្តធ្វើការដោយសុទ្ធចិត្ត ហើយសុទ្ធតែជាមនុស្សមានគុណសម្បត្តិល្អប្រពៃហើយក៏ជាសម្ព័ន្ធមិត្តមួយដ៏ល្អប្រសើររបស់ប្រជាពលរដ្ឋផងដែរ ។

ទាំងអស់នេះត្រូវតែដឹកនាំដោយវិចារណញ្ញាណ។ ភាពឆ្លាតវៃ គឺជាផ្លូវចង្អុលបង្ហាញគំនិតដ៏ល្អប្រសើរ។ អពមង្គលនឹងកើតឡើងមិនចេះចប់ ទាំងចំពោះរដ្ឋទាំងចំពោះពលរដ្ឋ ក្នុងខណៈណាដែលអ្នកដឹកនាំមិនមែនជាទស្សនវិទូ ពីព្រោះទស្សនវិទូនេះហើយ គឺជាផលវិជ្ជមាននៃសច្ចធម៌ និងអត្ថិភាពហើយក្រៅអំពីទស្សនវិទូនេះ គឺមិនដែលនាំមកសមិទ្ធិផលអ្វីដ៏គាប់ប្រសើរធំធេងទេ សម្រាប់បច្ចេកបុគ្គលខ្លួនឯងក៏ដូចជាសម្រាប់រដ្ឋឬពលរដ្ឋ។ ធម្មជាតិរបស់ទស្សនវិទូ គឺជាលទ្ធភាពល្អលើកកម្ពស់គំរូទស្សនៈ និងភាពក្លាហាន។

លក្ខណៈធម្មជាតិរបស់ទស្សនវិទូជាបងប្អូននឹងការលើកកម្ពស់ភាពរុងរឿង។ មានតែនៅក្នុងរដ្ឋប្រកបដោយយុត្តិធម៌ទេដែលជាកន្លែងអភិជននឹងដឹកនាំពោរពេញទៅដោយភាពសម្បូរសប្បាយ ប៉ុន្តែមិនមែនសម្បូរមាសប្រាក់ទេគឺសម្បូរសប្បាយដោយសុភមង្គលប្រកបដោយសីលធម៌ និង វិចារណញ្ញាណនៅក្នុងជីវិត។ ច្បាប់បង្ខំឱ្យកំណត់ទិស មិនមែនដើម្បីភាពសម្បូរសប្បាយតែម្នាក់ឯងទេ គឺដើម្បីរដ្ឋទាំងមូល។ នៅក្នុងរដ្ឋបច្ចុប្បន្ន ត្រូវតែមាននូវភាពយុត្តិធម៌ ព្រោះអំណាចរបស់រាជាអ្នកដឹកនាំតាមទស្សនៈប្លាតុង គឺឆ្លើយតបទៅនឹងគុណធម៌ពេញលេញ។

**១.២.៣.១ រាជានិយម** ( Monarchy )

រាជានិយមជារដ្ឋដែលគ្រប់គ្រងដោយមនុស្សម្នាក់ មានឈ្មោះជាព្រះមហាក្សត្រ។ ស្ដេចមានគោលបំណងពីធម្មជាតិផ្ទេរអំណាចរបស់ព្រះអង្គទៅកូនចៅជំនាន់ក្រោយ ហើយគ្មានការធានាថាពួកគេសមនឹងកាន់អំណាចនោះឬក៏អត់ទេ។ ព្រះមហាក្សត្រត្រូវតែមានអ្នកការពារ ហើយព្រះមហាក្សត្រអាចប្រើពួកគេបានតាមអំពើចិត្ត។ ប៉ុន្តែបញ្ហាចម្បងដែលត្រូវពិភាក្សា គឺថាស្ដេច ឬច្បាប់គួរស្ថិតនៅលើគេ? ម្យ៉ាងវិញទៀត គេនិយាយថាច្បាប់ដែលជាហេតុផលគ្មានតណ្ហា គួរតែនៅលើគេ។ ខ្លះយល់ថាច្បាប់នឹងមានលក្ខណៈរដ្ឋាភិបាលអសុក្រិត ព្រោះមនុស្សជាអ្នកបង្កើតវា។ បើចង់ឱ្យរបបរាជានិយមល្អ ព្រះមហាក្សត្រគួរតែស្វែងរកសុខមាលភាពជូនប្រជារាស្ត្ររបស់ព្រះអង្គដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន ហើយព្រះមហាក្សត្រគួរតែជាម្លប់ដល់ប្រជារាស្ត្រ។ ជាការពិតយើងពុំអាចបង្កើតរដ្ឋាភិបាលដ៏ល្អសម្រាប់បម្រើប្រជាជនដោយមើលពីលក្ខណៈធម្មជាតិពិសេសរបស់ប្រជាជននោះបានទេ។ តើរដ្ឋាភិបាលដែលគ្រប់គ្រងដោយព្រះមហាក្សត្រជារដ្ឋាភិបាលប្រកបដោយគុណធម៌ឬ? ប្រសិនបើដូច្នេះមែនរដ្ឋាភិបាលគ្រប់គ្រងដោយព្រះមហាក្សត្រជារដ្ឋាភិបាលល្អបំផុត។

**១.២.៣.២ អភិជនាធិបតេយ្យ** ( Aristocracy )

ជាការដឹកនាំមួយដ៏ល្អប្រសើរ មានទំនុកទុកចិត្តខ្លាំងពីប្រជាជន។ អំណាចរបស់រដ្ឋនៅក្នុងដៃអ្នកដែលប្រសើរជាង ដែលបានផ្ដល់ឱ្យដោយសុទ្ធចិត្តពីប្រជាជន។ អំណាចរបស់រដ្ឋ ដឹកនាំប្រកបទៅដោយគុណធម៌ និងវៃឆ្លាត។ នៅលើគោលការណ៍និងទ្រង់ទ្រាយនៃរចនាសម្ព័ន្ធដឹកនាំបែបនេះ គឺមានសមភាពតាំងពីកំណើតម្ល៉េះ។

រូបភាពរដ្ឋាភិបាលបែបនេះជារបបរចម្រុះ រៀបរៀងដោយ ប្លាតុង ក្នុងវណ្ណកម្មច្បាប់របស់លោក។ រដ្ឋាភិបាលនេះត្រូវបានជាប់ឆ្នោតតាមរយៈការបោះឆ្នោតមួយសម្រាប់ការជ្រើសរើសអ្នកប្រាជ្ញ។ រដ្ឋាភិបាលដែលជាអ្នកមានទ្រព្យសម្បត្តិជាអប្បរមាទើបអាចកាន់កាប់អំណាចរដ្ឋាភិបាលបាន។ បន្ថែមលើសពីនោះសេរីភាពស៊ីវិលនឹងត្រូវមានព្រំដែនកំណត់មួយ។ អ្នកច្បាប់ជាអ្នកទទួលខុសត្រូវរដ្ឋាភិបាល និងត្រូវទទួលបន្ទុកលើវិស័យអប់រំ យុវជន ហើយបង្កើននូវគំនិតច្នៃប្រឌិតឱ្យពួកគេ។

**១.២.៣.៣ ប្រជាធិបតេយ្យ ( ស្របច្បាប់ )** ( Timocracy )

ប្រជាធិបតេយ្យជារដ្ឋដែលគ្រប់គ្រងដោយមហាជន។ វាមានលទ្ធភាពសម្រាប់ការផ្លាស់ប្តូរតាំងពីគ្មានអ្វីៗនៅអចិន្ត្រៃយ៍មកម្ល៉េះ ហើយរបបអភិជនាធិបតេយ្យនឹងប្រែក្លាយអ្វីៗទាំងអស់ទៅជាប្រជាធិបតេយ្យ។ ប្រជាធិបតេយ្យតំណាងឱ្យសេចក្តីស្រឡាញ់កិត្តិយស។ ដរាបណាសមាជិកនៃវណ្ណៈណាមួយក្តាប់អំណាចស្រឡាញ់កិត្តិយសផ្ទាល់ខ្លួនជាងអំពើល្អសាធារណៈដរាបនោះផ្នែកស្មារតីនៃគំនិតរបស់ពួកគេបានដណ្តើមយកតួនាទីវិចារណញ្ញាណ។ ពីការស្រឡាញ់កិត្តិយសទៅជាការចង់បានទ្រព្យសម្បត្តិគឺជារយៈពេលខ្លីបំផុតដែលធ្វើឱ្យចំណង់គ្រប់គ្រងបាន។ កាលណាសេចក្តីស្រឡាញ់ទ្រព្យសម្បត្តិទ្រព្យសម្បត្តិកាន់តែកើនឡើង ពេលនោះហើយដែលរបបប្រជាធិបតេយ្យនិងផ្លាស់ទៅជារបបអប្បជនាធិបតេយ្យ ដែលអំណាចនយោបាយផ្អែកទៅលើទ្រព្យសម្បត្តិជាធំ។

**១.២.៣.៤ ប្រជាធិបតេយ្យ** ( **មិនស្របច្បាប់** ) ( Democracy )

លក្ខណៈពិសេសនៃរបបប្រជាធិបតេយ្យ គឺការស្រឡាញ់សេរីភាព និងសមភាព។ បញ្ញត្តិប្រជាធិបតេយ្យរបស់ប្លាតុង គឺផ្អែកទៅលើបទពិសោធន៍ដំបូងរបស់គាត់ដែលមានទម្រង់ប្រជាធិបតេយ្យ ពិសេសនៅក្នុងបុរីអាតែន។ ប្រជាធិបតេយ្យនៅទីនេះ គឺថាប្រជាពលរដ្ឋមានសិទ្ធិចូលរួមក្នុងរដ្ឋាភិបាល។ សេរីភាពក្នុងការនិយាយស្តីមានគ្រប់ទីកន្លែងទាំងអស់ ហើយពលរដ្ឋគ្រប់រូបត្រូវបានគេអនុញ្ញាតិឱ្យធ្វើអ្វីដែលគេចង់ធ្វើ។ ជីវិតដែលមានសេរីភាព និងសមភាពអះអាងថា ចំណង់មួយគឺល្អដូចនឹងចំណង់មួយផ្សេងទៀត ហើយពួកគេទាំងអស់គ្នាត្រូវមានសិទ្ធិស្មើគ្នា។ ដូច្នេះ តាមប្លាតុង ប្រជាធិបតេយ្យគឺជារដ្ឋាភិបាលមួយអន់បំផុតក្នុងចំណោមរដ្ឋាភិបាលដែលមានច្បាប់ទាំងអស់ ហើយជារដ្ឋាភិបាលដែលល្អបំផុត ក្នុងចំណោមរដ្ឋាភិបាលដែលអត់ច្បាប់។

តាំងពីមានរដ្ឋាភិបាលរបស់មហាជនមក ការគោរពបានចុះខ្សោយ ហើយមិនអាចធ្វើទាំងអំពើល្អ ឬអំពើអាក្រក់បើប្រៀបធៀបនឹងរដ្ឋាភិបាលផ្សេងៗទៀត ព្រោះនៅក្នុងរដ្ឋបែបនេះ ការិយាល័យត្រូវបានបែងចែកក្នុងចំណោមប្រជាជនដ៏ច្រើន។ ជាញឹកញាប់ ប្លាតុង ហាក់ដូចជាភ្ជាប់ពួកសូហ្វីសជាមួយនឹងប្រជាធិបតេយ្យ ហើយគាត់ប្រហែលជាយល់ថា ប្រជាធិបតេយ្យជាវប្បធម៌គំនិតរបស់ពួកសូហ្វីស។ ពួកសូហ្វីសបានផ្តល់នូវទម្រង់វោហាសាស្ត្រដែលយើងហៅថាសិល្បៈក្នុងការនិយាយជាសាធារណៈ និងសិល្បៈខាងនីតិក្រម។ ពួកសូហ្វីសបានបង្រៀនសិស្សរបស់ពួកគេពីរបៀបបញ្ចុះបញ្ចូល របៀបនិយាយពីផ្លូវចំពោះបញ្ហាតែមួយ។ ជួលកាលគេអាចនិយាយបញ្ហាខុសឱ្យទៅជាត្រូវ។ បញ្ហានេះគួរតែមាននៅក្នុងរដ្ឋប្រជាធិបតេយ្យដែលនឹងមានកន្លែងវិនិច្ឆ័យនិងសភាដើម្បីកាត់សេចក្តីនិងបញ្ចុះបញ្ចូលប្រជាពលរដ្ឋ។ បញ្ហាប្រជាធិបតេយ្យសម្រាប់ប្លាតុងគឺថាវាលេចឡើងជាផ្លូវជីវិតគួរឱ្យចាប់ចិត្តអ្នកដឹកនាំ នៃរបបប្រជាធិបតេយ្យក៏ចាប់ចិត្ត ប្រជាពលរដ្ឋក៏ចាប់ចិត្ត។ ប្លាតុងស្មោះត្រង់អំពីបញ្ហានេះណាស់។

នៅក្នុងលទ្ធិប្រជាធិបតេយ្យ គេរាល់គ្នាអាចជ្រើសរើសនូវប្រភេទនៃជីវិតដែលគេចង់រស់នៅ ហើយគេអាចផ្លាស់ប្តូរចិត្តគំនិតពីមួយថ្ងៃទៅមួយថ្ងៃបាន។ ជីវិតមានសេរីភាពនិងងាយស្រួលក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជាជនគឺអាចធ្វើតាមគោលបំណងដែលជ្រើសរើសដោយខ្លួនឯង និងមានសុភមង្គលជាងទម្រង់រដ្ឋដែលមានវិន័យតឹងរឹងដែលនាំមុខប្រជាធិបតេយ្យក្នុងគំពេងការណ៍អន់ថយរបស់ប្លាតុង។ ដូច្នេះដើម្បីធ្វើឡូឡឹករណ៍ប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ ប្លាតុង ត្រូវតែមានលទ្ធភាពនិយាយថា លទ្ធិ ប្រជាធិបតេយ្យមិនអាចនៅយូរអង្វែងទេ។ ប្រជាធិបតេយ្យមានស្ថិរភាពតិចតួចណាស់នៅក្នុងទម្រង់គ្រប់គ្រងរបស់គាត់។ គោលបំណងចុងក្រោយរបស់ប្រជាធិបតេយ្យ គឺប្រជាហិង្សា ( Tyranny )។

**១.២.៣.៥ អប្បជនាធិបតេយ្យ** ( Oligarchy )

អប្បជនាធិបតេយ្យ ជារដ្ឋដែលគ្រប់គ្រងដោយមនុស្សមួយក្រុម។ វាគ្មានស្ថិរភាពតាំងពីដើមមក ម្ល៉េះ ពិព្រោះវាមិនអាចផ្តល់នូវសន្តិសុខចំពោះវណ្ណៈដែលត្រូវគេដឹកនាំ។ ពួកអប្បជនាធិបតេយ្យពិតជា គិតដូចពួកអភិជនាធិបតេយ្យដែរ ដែលបានទាត់ចោលការទាក់ទងនឹងសង្គ្រាម។ ការស្រឡាញ់ប្រាក់កាស ពួកគេពិតជាចង់ចំណាយសម្រាប់ការរៀបចំធ្វើសង្គ្រាម។ នៅពេលសង្គ្រាមកើតឡើង ពួកគេបានបាត់បង់នូវអ្វីដែលត្រូវធ្វើ។ សូម្បីតែនៅក្រោមការ

គ្រប់គ្រងនៃរបបអភិជនាធិបតេយ្យក៏មានប្រព័ន្ធទ្រព្យសម្បត្តិឯកជននៅខាងដើមដែរ។ ហើយចំណង់នេះសម្រាប់ពួកអ្នកមានបានត្រួសត្រាយផ្លូវឱ្យប្រព័ន្ធរដ្ឋាភិបាលដែលគេហៅថា អប្បជនាធិបតេយ្យ ដែលអំណាចនៅក្នុងដៃប្រជាជន ហើយកង្វល់ជាចម្បង របស់ពួកគេគឺទ្រព្យសម្បត្តិ។ ប្លាតុង ពោលថា៖ " ពេលដែលអ្នកមានកើនឡើងក្នុងការគោរពនៃសង្គម ពេលនោះគុណធម៌ធ្លាក់ចុះ "។ តាម ប្លាតុង អ្វីដែលនិយាយអំពីអប្បជនាធិបតេយ្យ គឺវាបំបែកឯកភាពរដ្ឋទៅជាពីរវណ្ណៈដែលប្រឈមមុខគ្នាគឺអ្នកមាន និងអ្នកក្រ។ ជាងនេះទៅទៀត ពួកអប្បជនាធិបតេយ្យជាអ្នកប្រើប្រាស់ទំនិញ និងអ្វីៗដែលពួកគេទម្លាប់ប្រើ។ ពួកអប្បជនាធិបតេយ្យជាមនុស្សដែលស្វែងរកសេចក្តីរីករាយ។ ប៉ុន្តែរាល់ធម្មជាតិនៃសេចក្តីសប្បាយរីករាយមានរយៈពេលខ្លីណាស់។ អាស្រ័យហេតុនេះគេត្រូវតែធ្វើវាឡើងវិញ។ មិនដែលមានពេលណាមួយពេញចិត្តឡើយ។ អ្នកស្វែងរកសេចក្តីរីករាយមិនអាចបំពេញសេចក្តីរីករាយណាមួយឡើយ។ ពួកអប្បជនាធិបតេយ្យចេះនូវរបៀបបែងចែកចំណង់ទាំងបីប្រភេទគឺ៖

- ទី១ ភាពចាំបាច់ ( Necessary)
- ទី២ ភាពមិនចាំបាច់ (Unnecessary)
- ទី៣ ភាពគ្មានច្បាប់ (Lawless)

ដូច្នេះហើយគាត់បានដកខ្លួនចេញពីចំណង់ជាច្រើនទាំងបង្ខំ។ លោក ប្លាតុង ពោលថាពួកអប្បជនាធិបតេយ្យបង្ហាញការមើលឃើញខាងក្រៅសមរម្យជាងអ្នកជាច្រើនទៀត។ ប្លាតុង ជឿថាវាមាន ភាពរឹងមាំនៅក្នុងក្រុមអ្នកដឹកនាំដែលជួយធ្វើឱ្យរដ្ឋាភិបាលនេះនៅបានយូរ។ សុភមង្គលរបស់ពួកអប្ប ជនាធិបតេយ្យ គឺជាការសាកល្បងរបស់ប្លាតុងដើម្បីយុត្តិធម៌។

**១.២.៣.៦ ប្រជាហិង្សា** (Tyranny)

របបប្រជាហិង្សា (Tyranny) គឺជារបបផ្តាច់ការដែលមានទ្រង់ទ្រាយរចនាសម្ព័ន្ធរឹងមាំ ហើយក៏ជារបបកាចសាហាវ ។ ពេលដែលពួកមហាជនឱនលំទោនស្តាប់បង្គប់តាម នៅពេលនោះមេដឹកនាំនឹងក្លាយជាមេដឹកនាំផ្តាច់ការ ហើយមេដឹកនាំចាប់អារម្មណ៍ទៅនឹងសេចក្តីសម្រេចចិត្តរបស់តុលាការដែលមានលក្ខណៈអយុត្តិធម៌ កាត់ផ្តាច់ពីមនុស្សដោយប្រើមធ្យោបាយដាក់ទណ្ឌកម្មយ៉ាងកាចសហាវ នៅពេលនោះគេបានឈរនៅលើផ្លូវនៃមេដឹកនាំរដ្ឋដែលមិនមែនជាតំណាងរបស់ប្រជាជនទេគឺជាមេដឹកនាំផ្តាច់ការ។

កម្មវិធីមួយរបស់មេដឹកនាំផ្តាច់ការ គឺការទាក់អារម្មណ៍របស់ប្រជាជន ដើម្បីធ្វើសង្គ្រាមដើម្បីឱ្យប្រជាជនមានអារម្មណ៍ត្រូវគ្នាជាមួយមេដឹកនាំជានិច្ច។ ដើម្បីការពារអំណាចមេដឹកនាំផ្តាច់ការត្រូវការតាមដានសកម្មភាពអ្នកណាដែលក្លាហាន មានទឹកចិត្តទូលំទូលាយប្រកបដោយវិចារណញ្ញាណ និងប្រាជ្ញាឈ្លាសវៃ។ ភាពរឹងមាំរបស់អំណាចផ្តាច់ការ គឺធ្វើយ៉ាងណាដើម្បីបោសសំអាតពួកនេះចេញពីជួររដ្ឋាភិបាល។ មធ្យោបាយរបស់មេដឹកនាំផ្តាច់ការនៅពេលដែលគេធ្វើអំពើកាចសាហាវទៅលើប្រជាជន កាន់តែខ្លាំងនោះ គេកាន់តែត្រូវការអ្នកការពារខ្លួនរបស់គេកាន់តែច្រើនថែមទៀត។

ដូច្នេះប្រជាជនដែលមានសេរីភាពត្រូវបានធ្លាក់ចូលទៅក្នុងស្ថានភាពនូវអំណាចផ្តាច់ការសេរីភាពរបស់ពួកគេត្រូវបាត់បង់ទៅក្នុងរបបផ្តាច់ការ សេរីភាពត្រូវបានប្រែក្លាយទៅជាទាសភាពយ៉ាងធ្ងន់ធ្ងរនិងជូរចត់ជាទីបំផុតក្នុងភាពជាទាសករ។ បើនិយាយពីគុណសម្បត្តិរបស់មេដឹកនាំផ្តាច់ការខ្សោយបំផុត ប្លាតុង(Plato)បានបង្ហាញថា ទោះបីគេមានទំនាក់ទំនងជាមួយអ្នកណាក៏ដោយក៏គេតែងតែចង់ទាមទារឱ្យអ្នកនោះក្លាយជាទាសកររបស់គេ។ មេដឹកនាំផ្តាច់ការប្រៀបដូចជាអំណាចគ្មានច្បាប់របស់មនុស្សម្នាក់សម្រាប់ប្រជាជនទាំងអស់ក្នុងសង្គម ហើយផលប្រយោជន៍របស់ពួកគេបានកំណត់ខ្ពស់ជាងផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់។ ប្លាតុងបង្ហាញទៀតថា «របបផ្តាច់ការគឺជារបបកាចសាហាវជាទីបំផុតពីព្រោះ

ទី១៖ ប្រជាពលរដ្ឋនៅក្នុងរបបនេះ មិនមែនចាប់ផ្តើមគោរពឱនលំទោនចំពោះមនោគមន៍វិជ្ជានោះទេ គឺចំពោះមនុស្សម្នាក់។

ទី២៖ ចំណុចសំខាន់សម្រាប់រដ្ឋត្រូវអាស្រ័យនឹងមនោគមន៍វិជ្ជារបស់ខ្លួន។ ផលប្រយោជន៍រដ្ឋត្រូវតែមានតម្លៃខ្ពស់ជាងប្រយោជន៍របស់បុគ្គល ឬផលប្រយោជន៍ពលរដ្ឋក្នុងសង្គម។ មេដឹកនាំអំណាចផ្តាច់ការ និងផលប្រយោជន៍ឯកជនរបស់ខ្លួនតែងតែត្រូវបានកំណត់ថាជាផលប្រយោជន៍របស់ប្រជាជនទូទៅ ហើយគោលបំណងរបស់រដ្ឋត្រូវបានគេយកមកប្រើជាគោលបំណងរបស់ប្រជាជន»។

សរុបមក រដ្ឋាភិបាលអាចដឹកនាំដោយបុគ្គលម្នាក់ ឬបុគ្គលមួយក្រុម ឬបុគ្គលច្រើន។ ប្រសិនបើយើងនិយាយពីរដ្ឋសុក្រិត រដ្ឋដែលគ្រប់គ្រងដោយបុគ្គលម្នាក់ល្អជាងគេបង្អស់ បន្ទាប់មករដ្ឋដែលគ្រប់ គ្រងដោយបុគ្គលមួយក្រុម ហើយរដ្ឋដែលអន់ជាងគេគឺរដ្ឋដែលដឹកនាំដោយមហាជន។ ផ្ទុយទៅវិញ បើ យើងនិយាយអំពីទម្រង់រដ្ឋអសុក្រិត យើងឃើញថា រដ្ឋដែលអន់ជាងគេគឺរដ្ឋដែលដឹកនាំដោយបុគ្គលម្នាក់ បន្ទាប់មករដ្ឋដឹកនាំដោយមនុស្សមួយក្រុម បន្ទាប់មកទៀតគឺរដ្ឋដឹកនាំដោយមហាជន។

### ១.២.៤ ឋានានុក្រមសង្គម

ប្លាតុង យល់ថាមនុស្សគ្រប់រូបមានទេពកោសល្យ និងមានការបែងចែកមុខងារផ្សេងៗគ្នា។ ទេពកោសល្យ និងការងារបានកំណត់ឱ្យមានវណ្ណៈបីនៅក្នុងរដ្ឋ គឺវណ្ណៈអ្នកដឹកនាំ វណ្ណៈអ្នកការ ពារ និងវណ្ណៈអ្នកផលិត។

#### ១.២.៤.១ វណ្ណៈអ្នកដឹកនាំ

វណ្ណៈអ្នកដឹកនាំជាមនុស្សដែលស្ថិតនៅក្បាលម៉ាស៊ីនរបស់រដ្ឋ។ វាជាមុខងាររបស់ទស្សនវិទូក្នុងការគ្រប់គ្រងរដ្ឋ។ ប្លាតុងនិយាយថាអ្នកដឹកនាំគួរតែគេជ្រើសរើសយ៉ាងប្រុងប្រយ័ត្នពីវណ្ណៈអ្នកការពារ។ ពួកគេត្រូវតែជាមនុស្សល្អបំផុតក្នុងថ្នាក់របស់ពួកគេ ហើយត្រូវតែមានបញ្ញា អំណាច និងការអប់រំ ស្រឡាញ់រដ្ឋ និងចាត់ទុកផលប្រយោជន៍របស់រដ្ឋជាផលប្រយោជន៍ជាតិ ដោយមិនគិតពីផល ប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ អ្នកដឹកនាំគួរតែជាមនុស្សដែលមានសមត្ថភាពបំពេញនូវមុខងាររបស់ខ្លួន។ ប្លាតុង បានបន្ថែមទៀតថា អ្នកដឹកនាំដែលមានការអប់រំពេញលេញជាមនុស្សយល់ពីភាពខុសគ្នារវាងពិភពដែលអាចមើលឃើញនិងពិភពដែលយល់បាន រវាងវិស័យគំនិត និងវិស័យពុទ្ធិ រវាង លក្ខណៈខាងក្រៅ និងតថភាព។ ទស្សនវិទូនឹងធ្វើឱ្យរីកចម្រើនតាមដំណាក់កាលជាច្រើននៃការអប់រំ ដែលបានផ្តល់ដោយរដ្ឋ។ តាំងពីពេលគេមានអាយុ ១៨ឆ្នាំ គេនឹងបានរៀនអក្សរសាស្ត្រ និងគណិតវិទ្យាដំបូង។ ពីរ ឬបីឆ្នាំក្រោយមក នឹងមានការហាត់រៀនខាងយោធា និងរូបវិទ្យាដ៏ទូលំទូលាយ ហើយនៅពេលអាយុ២០ឆ្នាំ អ្នកខ្លះត្រូវបានគេជ្រើសរើសទៅបន្តមុខវិជ្ជាដែលសំខាន់ខាងផ្នែកគណិតវិទ្យា។ នៅពេលអាយុ ៣០ឆ្នាំ គេនឹងចាប់ផ្តើមរៀនទស្សនវិជ្ជាបដិសំយោគ និងទស្សនវិជ្ជាសីលធម៌រយៈពេល៥ឆ្នាំ។១៥ឆ្នាំក្រោយមកគេបានចំណាយពេលទាញយកបទពិសោធន៍អនុវត្តតាមរយៈការងារសាធារណៈ។ ចុងបញ្ចប់នៅពេលអាយុ៥០ឆ្នាំ គេនឹងអាចឈានទៅដល់កម្រិតពុទ្ធិខ្ពស់បំផុតគឺការយល់ដឹងអំពីអំពើល្អ ហើយខណៈនោះនឹងត្រៀមខ្លួនសម្រាប់ការងារគ្រប់គ្រងរដ្ឋ។ អ្នកដឹកនាំត្រូវបដិសេធទ្រព្យសម្បត្តិ និង គ្រួសារ ដើម្បីពួកគេអាចត្រួតត្រាលើផលនៃទ្រព្យសម្បត្តិ និងគ្រួសារដែលស្មោះត្រង់នឹងអ្នកផ្សេងៗនៅក្នុងរដ្ឋ។

សៀវភៅ The Republic ទាំងមូលរបស់ ប្លាតុង ជាលំហាត់ក្នុងបដិសំយោគ។ វាមានការប្រើបដិសំយោគសមហេតុផល ដើម្បីបង្ហាញវិធីបង្ហាត់បង្រៀនដ៏ល្អបំផុតសម្រាប់ការដឹកនាំ។ ប្លាតុង យល់ដូចប្រជាជនក្រិចទាំងអស់ដែរថា រដ្ឋពិបាកគ្រប់គ្រងណាស់។ អាស្រ័យហេតុនេះអ្នកដឹកនាំទស្សនវិទូ ត្រូវតែសម្រេចឱ្យបាននូវទម្រង់ពុទ្ធិខ្ពស់បំផុតមុនពេលពួកគេយល់ដឹងពីបញ្ហាដំបូងអំពីមុខងាររបស់គេ ដែលជាការរក្សានូវយុត្តិធម៌ក្នុងរដ្ឋ។ ប្លាតុង យល់ថាមនុស្សពិតជាត្រូវបានគេវិនិច្ឆ័យតាមវិធីដែលពួក គេបានប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក។ អ្នកដឹកនាំប្រព្រឹត្តចំពោះ

អ្នកដឹកនាំផ្សេងៗទៀតខុសពីវិធីដែល ពួកគេប្រព្រឹត្តចំពោះអ្នកដែលពួកគេគ្រប់គ្រង។ ប្រហែលជាប្លាតុងចង់និយាយថា បញ្ហានេះជាការសាក ល្បង ថាតើអ្នកដឹកនាំទាំងនោះប្រតិបត្តិតាមការហាត់រៀនរបស់អ្នកដឹកនាំ ឬសមជាអ្នកដឹកនាំឬទេ? អ្នក ដឹកនាំមានពុទ្ធិរបស់ពួកគេ ដើម្បីបែងចែកពួកគេពីអ្នកមិនដឹកនាំ។ អ្នកដឹកនាំទស្សនវិទូជាអ្នកដឹកនាំស្ទាក់ស្ទើរ។ ចិត្តរបស់គេគឺជក់ជាប់តែអំពើល្អ ហើយគេទទួលបន្ទុកភាពជាអ្នកដឹកនាំ ពីព្រោះអំពើល្អអាចមាននៅ និងរីកចម្រើនក្នុងរដ្ឋដែលគ្រប់គ្រងដោយមនុស្សត្រឹមត្រូវ។ គ្រប់គ្រងដោយអ្នកដឹកនាំ គឺជាការប៉ុនប៉ងដើម្បីធ្វើយុត្តិធម៌ឱ្យមានជាសាកលដរាបណាវាអាចធ្វើទៅបាន ហើយគោលបំណងចុង ក្រោយគឺសុភមង្គល ពីព្រោះយុត្តិធម៌វាគ្រាន់បើជាងអយុត្តិធម៌។

អ្នកដឹកនាំពិតមិនដូចអ្នកដឹកនាំធ្វើពុតឬក្រុមដឹកនាំផ្សេងៗ ឬបុគ្គលដឹកនាំនោះទេ គឺត្រូវតែបញ្ចុះបញ្ចូលដើម្បីដឹកនាំ។ ម្យ៉ាងវិញទៀត អ្នកដឹកនាំមានបញ្ហាអ្វីមួយដែលមនុស្សហៅយ៉ាងសាមញ្ញថា អំពើល្អដែលចេញមកពីការអនុវត្តន៍នៃមុខងាររបស់គេ។ ហើយបញ្ហាជាច្រើនទៀតដែលហៅថាអំពើល្អដោយមិនរាប់ចូលក្នុងការរស់នៅរបស់ពួកគេ។ ក្រុមអ្នកដឹកនាំនៅតែមានលទ្ធភាពប្រកួតប្រជែងគ្នាដើម្បីត្រួតត្រារដ្ឋ។ ប្លាតុង មិនដែលគិតថាមានស្តេចទស្សនវិទូច្រើនជាងមួយទេ។ ម្យ៉ាងវិញទៀត ការ រៀបចំតាមការអប់រំយ៉ាងល្អិតល្អន់ អាចបន្សល់ឱ្យយើងនូវចម្ងល់បន្តិចបន្តួចដែលពួកគេធ្វើគំរោងបង្កើត ក្រុមអ្នកដឹកនាំ។

### ១.២.៤.២ វណ្ណៈអ្នកការពារ

វណ្ណៈអ្នកការពារ គឺជាបេះដូងរបស់រដ្ឋ។ ប្រសិនបើពិតជាមានការប្រកួតប្រជែងចំពោះការគ្រប់ គ្រងរបស់អ្នកដឹកនាំនៅក្នុងរដ្ឋគំនិតរបស់ប្លាតុងនឹងមានបេក្ខជនមកពីវណ្ណៈការពារមកចូលរួមប្រកួតច្រើនជាងវណ្ណៈអ្នកផលិត។ វណ្ណៈការពារមានបេក្ខជនជាច្រើន ដែលត្រូវបានគេជ្រើសរើសសម្រាប់ការដឹកនាំ។ ប្លាតុង បានយល់ឃើញថាអ្នកការពារជាក្រុមសាមគ្គីភាពមួយប្រភេទដែលវណ្ណៈដឹកនាំខ្វះខាតគឺអំណាចយោធា និងប៉ូលីសរបស់រដ្ឋ ដែលជាកម្លាំងប្រដាប់អាវុធយ៉ាងអង់អាចក្លាហាន។ នៅក្នុងរដ្ឋរបស់ប្លាតុង យើងពុំដឹងអំពីចំនួននៃវណ្ណៈនីមួយៗច្បាស់លាស់ទេ ប៉ុន្តែយើងដឹងច្បាស់ថា វណ្ណៈការពារមានចំនួនច្រើនជាងវណ្ណៈដឹកនាំ ហើយវណ្ណៈផលិត ឬកម្មករមានចំនួនច្រើនជាងវណ្ណៈការពារ។ ប្លាតុង ប្រៀបធៀបវណ្ណៈការពារទៅនឹងឆ្កែចាំផ្ទះដែលសុភាពរាបសារនឹងម្ចាស់ ហើយប្រឆាំងនឹងសត្រូវ។ ប៉ុន្តែជាការពិតវណ្ណៈនេះមានកិច្ចការតិចតួចណាស់ដើម្បីធ្វើ។ ត្រង់ចំណុចនេះប្លាតុងពុំបានបញ្ជាក់ពី រដ្ឋមានសង្គ្រាម ឬក៏អត់សង្គ្រាមនោះទេ។ បើសិនរដ្ឋមានសង្គ្រាមវិញ វណ្ណៈនេះមានតួនាទីសំខាន់ណាស់ ហើយប្រហែលប្លាតុងមិនហ៊ាននិយាយថា វណ្ណៈអ្នកការពារនេះមានការងារតិចតួចទេមើលទៅ។ យើងអាចនិយាយបានថានៅពេលនោះសង្គ្រាមបានបញ្ចប់ហើយ។ ប្លាតុង ចង់ឱ្យរដ្ឋរបស់គាត់ល្អ ដាច់គេ។ ម្យ៉ាងទៀត វណ្ណៈយោធាមានមុខងារដែលមានកិត្តិយសជាងវណ្ណៈកម្មករ។ ពួកគេមិនមែនជាសត្វសាហាវចាប់វណ្ណៈទាបឱ្យនៅពីក្រោមទេ។ ប៉ុន្តែប្រសិនបើពួកគេខ្លាំងជាងពលរដ្ឋ ពួកគេនឹងជា សម្ព័ន្ធមិត្តយ៉ាងជិតស្និទ្ធិជាមួយពលរដ្ឋ។ ពួកគេចាំបាច់ត្រូវតែមានការអប់រំត្រឹមត្រូវ និងមានរបៀបរស់នៅឱ្យបានល្អ។ ប្លាតុង ពោលថា ពួកគេគ្មានទ្រព្យសម្បត្តិកម្មសិទ្ធិឯកជនផ្ទាល់ទេ ប៉ុន្តែពួកគេនឹងទទួល បានវត្ថុចាំបាច់ពីពលរដ្ឋរបស់គេ។ ពួកគេមានរឿងស្មុគស្មាញ ហើយពួកគេរួមគ្នាដូចទាហានក្នុងជុំរុំ។ ហើយនេះជាការសង្គ្រោះរបស់ពួកគេ និងការសង្គ្រោះរបស់រដ្ឋ។ ប៉ុន្តែប្រសិនបើពួកគេមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ពួកគេនឹងក្លាយយ៉ាងឆាប់រហ័សទៅជាអ្នកប្រជាហិង្សា។

### ១.២.៤.៣ វណ្ណៈអ្នកផលិត

វណ្ណៈអ្នកផលិតជារាងកាយនិងជាអវយវៈរបស់រដ្ឋ។ វណ្ណៈនេះតំណាងឱ្យផ្នែកទាបជាងគេរបស់រដ្ឋហើយមានតម្រូវការជាច្រើន។ បញ្ហាសំខាន់ដែលយើងចាំបាច់ត្រូវសួរគឺថាតើហេតុអ្វីបានជាកម្មករគួរតែស្រុះស្រួលទៅតាមការដឹកនាំរបស់ទស្សនវិទូ? មានយោបល់ផ្ទុយគ្នាខ្លះៗនៅក្នុងការសន្មត របស់របស់ប្លាតុងទៅលើចំណុចនេះ ប៉ុន្តែការ

រំពឹងគិតជាមូលដ្ឋានគឺថា តើកម្មករអាចយល់ពីតម្លៃនៃការដឹកនាំរបស់ទស្សនវិទូឬទេ? ប្លាតុង បានចាត់ទុកថាពួកវណ្ណៈទី៣ គ្មានសមត្ថភាពយល់ដឹងអ្វីទេ ហើយគាត់កម្រនឹងអធិប្បាយវណ្ណៈទី៣នេះឱ្យបានច្បាស់លាស់ណាស់។

កម្មករដែលប្លាតុងថាគ្មានសមត្ថភាពសមហេតុផល គឺពិតក្នុងខណៈដំបូងពីការពិចារណាជាទូទៅដែលថា ពួកគេនឹងគ្មានសមត្ថភាពធ្វើកិច្ចការរបស់ពួកគេទេ។ ដូច្នេះ វណ្ណៈទី៣ មានគំនិតចង់បានទ្រព្យ ពួកគេគ្មានភស្តុតាងទេដែលថាប្លាតុងបដិសេធពួកគេថាគ្មានវិចារណញ្ញាណ។ ជាងនេះទៅទៀត ពួកគេមានបំណងស្វែងរកអំពើល្អ ហើយវាជាវិចារណញ្ញាណដែលប៉ាន់ស្មានអំពើល្អ។ ដូចនេះ មនុស្ស គ្រប់រូបត្រូវតែមានវិចារណញ្ញាណ។ ជាងនេះទៅទៀតគ្មានអ្វីនៅក្នុងសទិសភាពរវាងគំនិត និងសភាវៈ ណាដែលសំដៅឆ្ពោះទៅរកកម្មករថាខ្វះវិចារណញ្ញាណនោះទេ។ ប្រសិនបើផ្នែកមានតម្រូវការគ្មាន សមត្ថភាពនូវកម្រិតខ្លះៗ ការសមហេតុផលវានឹងធ្វើឱ្យគ្មានន័យសម្រាប់ប្លាតុង ដែលនិយាយអំពីវាក្នុង ការយល់ព្រមចំពោះការគ្រប់គ្រងតាមវិចារណញ្ញាណ ឬការជ្រៀតជ្រែកក្នុងការងាររបស់ផ្នែកដ៏ទៃ។

កម្មករដែលមានវិចារណញ្ញាណខ្លះ គឺគ្រប់គ្រាន់ណាស់ទៅហើយ។ គ្មានអ្វីរាំងយើងពីការគិតថា ពួកគេអាចយល់ពីតម្លៃនៃការដឹកនាំរបស់ទស្សនវិទូទេ។ ប្លាតុង សន្មតថាគំនិតរបស់ពួកគេអាចស្មានអ្វីដែលល្អសម្រាប់ពួកគេ ប្រសិនបើមិនអាចស្មានចំពោះសហគមន៍ទាំងមូលបានទេនោះនឹងគ្រប់គ្រាន់សម្រាប់ពួកគេ ដើម្បីសុខចិត្តក្នុងការគ្រប់គ្រងខ្លួន។ ពួកគេមិនត្រូវបានគេបង្ខំឱ្យធ្វើតាមបញ្ជាទេ ហើយក៏គ្មានអ្វីទប់ស្កាត់យើងពីការយល់នូវការពិភាក្សារបស់ប្លាតុងស្តីពីការបង្ខិតបង្ខំ ជាការបង្ខិតបង្ខំ នៃទឡ្ហីករណ៍វិចារណញ្ញាណដែរ។ ប្រសិនបើវណ្ណៈកម្មករមិនមានការរីកចម្រើនខាងវិចារណញ្ញាណ ទស្សនវិជ្ជាទេ បញ្ហានេះមិនចាំបាច់ធ្វើឱ្យយើងបារម្ភឡើយ។ នោះមិនមែនមុខងាររបស់ពួកគេទេនៅក្នុងរដ្ឋ។ ប៉ុន្តែជួនកាលវាត្រូវបានគេអះអាងថា មានតែទស្សនវិទូទេ ដែលអាចមានសីលធម៌ ហើយប្លាតុងបានបដិសេធលទ្ធភាពនេះចំពោះអ្នកផ្សេងទៀត។ ចាប់តាំងពីសីលធម៌ត្រូវបានកំណត់ថា ជាការដឹកនាំតាមបែបវិចារណញ្ញាណទៅលើផ្នែកផ្សេងៗនៃគំនិត។

ប្លាតុង មិនសង្ឃឹមថា វណ្ណៈទី៣មានសមត្ថភាពខាងសីលធម៌ទេ ប៉ុន្តែពួកគេត្រូវការសីលធម៌របស់ពួកគេដើម្បីកំណត់ក្នុងពាក្យដូចគ្នាថា សីលធម៌ទស្សនវិជ្ជា។

វណ្ណៈកម្មករអាចទទួលបាននូវសីលធម៌ តាំងពីបញ្ហានោះត្រូវបានគេកំណត់ថាជាការថែរក្សាការងាររបស់នរណាម្នាក់។ ពីការអះអាងថា សីលធម៌សង្គមនាំមកនូវសីលធម៌ខាងក្នុងដែលជាការស្រុះស្រួលគ្នាខាងស្មារតីក្រោមវិចារណញ្ញាណ។ វណ្ណៈកម្មករទុកទ្រព្យសម្បត្តិឯកជន និងគ្រួសារ។ ចំណែកវណ្ណៈពីរខាងលើទ្រព្យសម្បត្តិឯកជន និងគ្រួសារត្រូវបានគេលុបចោល ហើយបញ្ហានោះសម្រាប់អំពើល្អរបស់រដ្ឋ។

ប្លាតុង យល់ថាជាការចាំបាច់ណាស់ ដើម្បីឱ្យគេជឿរឿងកុហក រឿងទើបនឹងប្រឌិតឡើង។ គាត់សរសេរថា៖ ខ្ញុំនឹងព្យាយាមជឿដំបូងការដឹកនាំ និងយោធា ហើយបន្ទាប់មកសហគមន៍ទាំង អស់ដែលមានការប្រដៅ និងការអប់រំដែលយើងបានផ្តល់ឱ្យពួកគេជាបទពិសោធន៍។ នៅក្នុងតថភាព ពួកគេមានពេលច្រើនឱ្យគេបំពាក់បំប៉ន និងធ្វើតាមអ្វីដែលមានរួចហើយ។ ចុងបញ្ចប់នៅពេលដែលពួក គេបានបំពេញភារកិច្ចសព្វគ្រប់ហើយ ពួកគេក៏បានចេញផុតពីភាពងងឹតទៅរកភាពភ្លឺថ្លា។

ប្លាតុង បានអប់រំមនុស្សដោយបណ្តុះគំនិតទេវកថាដល់ពលរដ្ឋទាំងអស់ឱ្យជឿថាព្រះអាទិទេពធ្វើសំលោហៈទៅក្នុងព្រលឹងមនុស្សជាលោហៈច្រើនប្រភេទ។ អ្នកដែលមានលោហៈដែក ឬទង់ ដែងនៅក្នុងព្រលឹងជាកសិករ ឬសិប្បករ ដែលស្ថិតនៅស្រទាប់ក្រោម។ ឯចំណែកអ្នកមានលោហៈមាស និងប្រាក់ គឺស្ថិតនៅក្នុងស្រទាប់អ្នកដឹកនាំ និងអ្នកការពារ។ ប៉ុន្តែបើសិនជាពួកមនុស្សស្រទាប់ ក្រោមមានកូនដែលមានលោហៈមានតម្លៃ គេអនុញ្ញាតិឱ្យកូននោះឡើងទៅស្រទាប់លើបានអាស្រ័យដោយតម្លៃរបស់វា ឬការផ្តួចផ្តើមពីអ្នកដឹកនាំ។ ប្រការសំខាន់បំផុត ប្លាតុង យល់ថា គេរាល់គ្នាគួរតែយល់ស្របថា តើនរណាពិតជាអ្នកដឹកនាំ ហើយយល់ស្របផងដែរថាទៅលើហេតុផលដែល

ថា ហេតុអ្វីបានជាអ្នកដឹកនាំគួរតែត្រូវបានគេគោរព ? ទាំងនេះហើយដែលជំរុញឱ្យមានការបែងចែកវណ្ណៈទាំងបីខាងលើ។ តំណែងប្រមុខរដ្ឋគួរប្រគល់ឱ្យទស្សនវិទូព្រោះពួកគេមានលក្ខណៈប្រកបដោយ វិចារណញ្ញាណខ្ពស់បំផុតពីធម្មជាតិ និងឈានទៅដល់ការយល់ដឹងពុទ្ធិសច្ចៈប្រព្រឹត្តិអំពើប្រកបដោយ គុណធម៌។ វណ្ណៈការពារ និងវណ្ណៈទី៣នឹងផ្តល់នូវតម្រូវការសេដ្ឋកិច្ច និងសន្តិសុខជូនពលរដ្ឋទាំងមូល។

**១.២.៥ ច្បាប់**

គំនិតរបស់ប្លាតុងនៅតែមានតម្លៃជានិច្ច។ សៀវភៅដែលសរសេរជាការសន្ទនា(Dialogues)មានបីគឺ The Republic, Statesman និងThe Law បង្ហាញឱ្យឃើញពីការគិតខាងនយោបាយរបស់គាត់។ បញ្ហាជាមូលដ្ឋានមួយបានលេចឡើងនៅក្នុងសៀវភៅ The Statesman គឺថា តើអំណាច ដំបូងនៅក្នុងរដ្ឋគួរតែស្ថិតនៅក្នុងដៃបុគ្គលដែលតំណាងឱ្យការប៉ិនប្រសប់ក្នុងការដឹកនាំ ឬស្ថិតនៅលើច្បាប់? ប្លាតុង ធ្វើទឡ្ហីករណ៍ថាច្បាប់មានភាពអសុក្រិតចៀសមិនផុត ច្បាប់ទាំងនោះជាទូទៅទាក់ទងនឹងភាពស្មុគស្មាញនៃជីវិតពិតប្រាកដព្រោះវាជានីតិវិន័ (Static)។ ពួកវាមិនទាក់ទងនឹងលក្ខខណ្ឌផ្លាស់ ប្តូរឡើយ។ គាត់យល់ថា វាជាការល្អសម្រាប់ការដឹកនាំដែលស្ថិតនៅក្នុងដៃបុគ្គលមានជំនាញ ដែលអាចដាក់បញ្ញត្តិចំពោះករណីនីមួយៗនៅពេលវាកើតឡើង។ ប្លាតុង ប្រហែលជានៅតែគិតអំពីរដ្ឋបុរស ដែលមានឧត្តមគតិមានសិទ្ធិចូលដល់សច្ចភាពអមតៈ។ ច្បាប់មិនអនុញ្ញាតិឱ្យមានការសម្រាលទោសទៅលើបុគ្គលណាដែលប្រព្រឹត្តខុសពីគោលបំណងរបស់ច្បាប់ឡើយ។ គោលបំណងទាំងនោះ បម្រើ យ៉ាងល្អនូវការអនុលោមតាមច្បាប់ មិនមែនតាមការគិតរបស់បុគ្គលម្នាក់ៗទេ។ ការពិចារណាបែបនេះ បានដឹកនាំឱ្យមនុស្សធ្វើការបែងចែកបញ្ហាថាតើត្រូវធ្វើអ្វីដែលត្រូវ ហើយនឹងទម្រង់ការអ្វីដែលគេសម្រេចចិត្តធ្វើតាម។ ***ប្រសិនបើច្បាប់មានអត្ថិភាពនៅក្នុងសង្គមហើយនោះ យើងមិនចាំបាច់ខ្លាចអំណាចបុគ្គលទេ។*** យើងមានសិទ្ធិធ្វើអ្វីៗស្របតាមច្បាប់។ លទ្ធផលនេះនឹងជាសកម្មភាពគ្មានបំណង ប៉ុន្តែលទ្ធផលសរុបគួរឱ្យពេញចិត្តនោះ គឺនរណាក៏អាចចូលរួមប្រកួតប្រជែងបានដែរ។

អំណាចត្រឹមត្រូវតាមច្បាប់មិនដូចជាកម្លាំងទេ។ កម្លាំងមានព្រំដែនធម្មជាតិរបស់វាតែមួយគត់ នៅពេលដែលអំណាចត្រឹមត្រូវតាមច្បាប់ជាប្រធានចំពោះការកម្រិតព្រំដែនរបស់ច្បាប់។ ពីសម័យបុរាណប្រជាជនក្រិចមានគំនិតស្តីពីច្បាប់ ដែលពួកគេប្រៀបធៀបជាមួយភាពក្រអឺតក្រអាងនៃអំណាច។ នៅក្នុងពិភពលោក មនុស្សយើងសុំនឹងផលមិនអាចដោះស្រាយបាននៃកំហឹងរបស់ស្តេចក៏ដូចជាសុំនឹងផលនៃកម្លាំងរបស់ព្រះដែរ។

ប្រជាធិបតេយ្យ អប្បជនាធិបតេយ្យ និងប្រជាហិង្សា ទាំងអស់នេះគ្មានចំណង់ទេ ព្រោះពួកវាជាវណ្ណៈរដ្ឋហើយច្បាប់របស់ពួកគេត្រូវបានអនុម័តសម្រាប់អំពើល្អនៃវណ្ណៈដោយឡែកៗ មិនសម្រាប់អំពើល្អរបស់រដ្ឋទាំងមូលទេ។ រដ្ឋដែលមានច្បាប់ដូចនេះមិនមែនជានយោបាយពិតប្រាកដទេ ប៉ុន្តែជាគណ បក្ស។

ប្លាតុង បានពិភាក្សាអំពីការតែងតាំង និងមុខងាររបស់ចៅក្រមផ្សេងៗយ៉ាងយូរ។ ឧទាហរណ៍ មានអ្នកដឹកនាំច្បាប់៣៧រូបដែលនឹងមានអាយុតិចជាង៥០ឆ្នាំនៅពេលបោះឆ្នោតហើយនឹងកាន់តំណែង រហូតដល់អាយុ៧០ឆ្នាំ។ រដ្ឋនឹងមានរដ្ឋធម្មនុញ្ញ សមាជិកសភា រដ្ឋមន្ត្រីមួយចំនួន ដូចជារដ្ឋមន្ត្រីថែរក្សា ខាងតន្ត្រី និងកីឡាជាដើម។ រដ្ឋមន្ត្រីសំខាន់បំផុតដែលថែរក្សាយុវជន បុរស ស្ត្រី ត្រូវតែមានអាយុយ៉ាង ហោចណាស់ ៥០ឆ្នាំ។

ប្លាតុង អះអាងថា៖ ឪពុករបស់ក្មេងដែលបានបង្កើតច្បាប់ពេញលេញស្តីពីភេទទាំងពីរ ឬក៏ភេទ ណាក៏ដោយ អ្នកដែលត្រូវបានគេជ្រើសរើស និងអ្នកដែលជាអ្នកបោះឆ្នោត គួរតែពិចារណាទៅលើតំណែងសំខាន់ៗរបស់រដ្ឋនោះជាតំណែងល្អបំផុត។

ប្លាតុង បានស្នើថា ទោសបញ្ញត្តិត្រូវដាក់ទៅលើកំហុសរបស់ពួកគេមិនជឿអាទិទេព និងត្រូវគេដាក់ទណ្ឌកម្មយ៉ាងហោចណាស់៥ឆ្នាំ នៅក្នុងកន្លែងកែប្រែដែលមានសមាជិកក្រុមទៅសួរសុខទុក្ខ និងផ្តល់ហេតុផលពីកំហុសរបស់គេ។ បើមានការបញ្ជូនមកជាលើកទី២នឹងត្រូវគេដាក់ទណ្ឌកម្មដល់ស្លាប់។

### ១.២.៦ យុត្តិធម៌

នៅក្នុងសង្គមមនុស្ស យើងមាននិយមន័យយុត្តិធម៌ជាច្រើន។ សីហ្វា (Cephalus) ដែលជាមនុស្សចាស់ម្នាក់បានផ្តល់យោបល់ថា វិធានពីរបស់យុត្តិធម៌គឺការជួយមិត្តភក្តិ និងការសងបំណុល។ សូក្រាត បានគូសបញ្ជាក់ថា វាមិនមែនជាយុត្តិធម៌ទេក្នុងការយកកាំបិតដែលខ្ចីពីមិត្តភក្តិទៅសងវិញ ប្រសិនបើមិត្តភក្តិនោះទៅជាឆ្កួតនៅពេលចន្លោះនោះ។ នោះគឺជាការសងបំណុល គេពិបាកហៅថាជាការជួយមិត្តភក្តិណាស់។ សីហ្វា សារភាពថា គាត់ត្រូវបានគេឃោសនាតាមការជំទាស់នេះ។ គាត់អាចនិយាយបានថា យុត្តិធម៌ជាការជួយមិត្តភក្តិ និងសងបំណុល ប៉ុន្តែមិនមែនក្នុងករណីនោះទេ។ សុភមង្គល ជាហេតុដែលជំរុញឱ្យមានយុត្តិធម៌ ហើយសុភមង្គលមិនកំណត់អត្ថិភាពចេញជាអ្វីផ្សេងទៀតទេ។

ប្លាតុង យុត្តិធម៌ជាគុណធម៌នយោបាយដែលក្នុងន័យនេះគុណធម៌ផ្សេងទៀតគ្មាន។ គាត់ចង់ឱ្យយើងជឿជាក់ថាយុត្តិធម៌ជាគុណធម៌នយោបាយកណ្តាលដែលមានប្រយោជន៍ក្នុងនយោបាយមួយដែល គុណធម៌ផ្សេងទៀតគ្មាន។ យុត្តិធម៌ជាគុណធម៌នយោបាយយ៉ាងចាំបាច់ ព្រោះវាត្រូវបានគេអនុវត្តទូលំ ទូលាយសម្រាប់ភាពត្រឹមត្រូវក្នុងការរស់នៅ។ ភាពត្រឹមត្រូវមានប្រយោជន៍ក្នុងការរីករាលដាលរបស់ យុត្តិធម៌ ហើយវាមានប្រយោជន៍ក្នុងការបង្កើតយុត្តិធម៌ផ្សេងៗក្នុងស្រមោលរបស់ពួកគេ។ ប្លាតុង យល់ ថា ***យុត្តិធម៌ស្ថិតនៅនឹងមនុស្សទាំងអស់***។ ម្យ៉ាងទៀត ពុទ្ធិអាចត្រូវ និងខុស។ ប្រភេទនៃពុទ្ធិខុស គឺនិយាយអំពីយុត្តិធម៌។ ប្រភេទពុទ្ធិត្រូវគឺជាការស្គាល់ពីព្រំដែននៃទស្សនៈផ្សេងៗស្តីពីយុត្តិធម៌។

ប្លាតុងបាននិយាយពីយុត្តិធម៌នៅក្នុងសៀវភៅ The Republic ថា៖ ធ្វើត្រឹមត្រូវដូច សីហ្វា ជីវិតរបស់គាត់គួរឱ្យស្ញើចសរសើរ។ ដូច្នេះធ្វើតាមគាត់ទៅ។ នៅពេលសីហ្វាលាចាកលោកទៅ អំណាចសីលធម៌នៃជីវិតរស់នៅក៏ចាកចេញដែរ។ យុត្តិធម៌ត្រូវបានគេរកឃើញនៅទីដទៃទៀតក្នុងបច្ចុប្បន្នកាល មិនមែនក្នុងអតីតកាលទេ។ យុត្តិធម៌ជាផលប្រយោជន៍របស់អ្នកខ្លាំង ហើយអយុត្តិធម៌ជារបស់អ្នកខ្សោយ។ លោក ត្រាស៊ីម៉ាកូស (Thrasymachus) និយាយថា ***យុត្តិធម៌ជានិច្ចកាលជាប្រយោជន៍របស់អ្នកខ្លាំង ហើយអ្នកខ្លាំងប្រកាសថាជាផលប្រយោជន៍របស់អ្នកពាល់គ្នា។*** ក្នុងរដ្ឋគំរូរបស់ប្លាតុង ***យុត្តិធម៌ជាគោលការណ៍រួម***។ វាភ្ជាប់វណ្ណៈទាំងពីរទៅវិញទៅមក ជាមូលដ្ឋាន សម្រាប់ឯកភាពនៅក្នុងក្រុមអ្នកដឹកនាំ។ នៅពេលដែលគេបានផ្តល់ទស្សនៈស្តីអំពីយុត្តិធម៌របស់រដ្ឋ គេត្រូវចាប់ផ្តើមពីយុត្តិធម៌របស់បុគ្គលម្នាក់ៗជាមុនសិន។ *បើបុគ្គលម្នាក់ៗមានយុត្តិធម៌ហើយ នោះរដ្ឋក៏មានយុត្តិធម៌ដែរ។*

រដ្ឋគំរូ គឺត្រូវមានយុត្តិធម៌។ យុត្តិធម៌នៅត្រង់ថា ពលរដ្ឋម្នាក់ៗត្រូវតែមានការងារធ្វើ ហើយអាស្រ័យទៅតាមឧបនិស្ស័យរបស់គេ និងស្របទៅតាមសមត្ថភាព និងអត្តិភាពខ្លួនផ្ទាល់។ ដូច្នេះ យុត្តិធម៌ គឺជាកុសលដ៏ធំបំផុតដែលរដ្ឋនីមួយៗត្រូវតែចង់បាន និងធ្វើអ្វីៗដើម្បីយុត្តិធម៌។ ប្រការនេះ គេអាចសម្រេចបានពេលណាដែលមនុស្សម្នាក់ៗនៅក្នុងរដ្ឋភ្ជាប់ខ្លួនគេ នៅក្នុងអាជីពមួយសមស្របទៅនឹងគុណធម៌ផ្លូវកណ្តាលរបស់ខ្លួន។ ប្រការនេះបញ្ជាក់ថាសុខុមាលភាព និងសុភមង្គលរបស់រដ្ឋផ្សារភ្ជាប់ទៅនឹងមនុស្សទាំងឡាយដែលជាសមាជិកនៃរដ្ឋនោះ។ " ធ្វើកិច្ចការរបស់ខ្លួន ហើយមិនលូកដៃក្នុងកិច្ចការរបស់អ្នកដទៃ គឺមានយុត្តិធម៌ "។

## ១.៣ ទស្សនវិជ្ជាមួយចំនួនរបស់ ប្លាតុង

តាមទស្សនៈរបស់ ប្លាតុង ថា «ពិភពលោកកើតឡើងដោយជាតុ២យ៉ាងគឺពិភពទស្សនៈ និងរូបធាតុ។ ពិភពទស្សនៈមិនសំដៅទៅលើរចនាសម្ព័ន្ធគំនិតនោះទេ ប៉ុន្តែជាពិភពសច្ចៈដែលសម្តែងបង្ហាញនូវភាពជាក់ស្តែង។ ចំណែករូបធាតុនិយមនៅក្នុងដំណើរវិវត្តន៍របស់ខ្លួន គ្មានភាពសច្ចៈទេ»។ ប្លាតុង បានបង្ហាញថា «គ្មានរូបធាតុណាមួយ មិនប្រែប្រួលបាត់បង់នូវស្ថានភាពរបស់វាទេ គឺមានតែការប្រែប្រួលប៉ុណ្ណោះដែលមិនប្រែប្រួល »។ បានន័យថា

គឺមានតែពិភពទស្សនៈទេ ដែលមានភាពសច្ចៈ និងមិនប្រែប្រួល ចំណែកឯរូបធាតុវិញ មានលក្ខណៈស្រពិចស្រពិល មិនមានភាពសច្ចៈ គឺវាមិនឆ្លើយតបទៅ នឹងសភាពលក្ខណៈខាងក្រៅខ្លួនរបស់វាគ្រប់ពេលវេលានោះទេ ប្លាតុងបាន រិះរកទស្សនៈរបស់មេដឹកនាំដ៏ល្បីល្បាញជាងគេដែលមាននៅក្នុងស្នាដៃរបស់គាត់ស្តីអំពី «ពលកម្ម និងពេលវេលា» ដែលត្រូវបានគេទទួលស្គាល់ និងចាត់ទុកថាជាទេវកថា ឬ ជាសតវត្សមាសដ៏ល្អ អាចយកធ្វើជាគំរូបាន ហើយជា ស្នាដៃដែលប្រកាន់ភ្ជាប់នូវរបបនយោបាយល្អប្រសើរ។

នៅអតីតកាល ប្រវត្តិសាស្ត្រធ្វើដំណើរលើផ្លូវដែលមិនត្រូវដើរចេញពីសតវត្សមាសទៅកាន់សតវត្សដែក គឺថា រចនាសម្ព័ន្ធរបស់រដ្ឋគំរូ មានតែនៅក្នុងសតវត្សមាសទេ។ តើរដ្ឋគំរូរបស់ប្លាតុងមានសញ្ញាណយ៉ាងដូចម្តេច? បើតាម ទស្សនៈរបស់ ប្លាតុង ដែលបាននិយាយនៅក្នុងស្នាដរដ្ឋសញ្ញាណដ៏សំខាន់របស់រដ្ឋជាគំរូ គឺភាពយុត្តិធម៌។ ភាព យុត្តិធម៌បើតាមទស្សនៈរបស់ ប្លាតុង គឺស្ថិតនៅត្រង់ថាពលរដ្ឋម្នាក់ត្រូវតែមានការងារធ្វើ ហើយអាស្រ័យទៅតាម ឧបនិស្ស័យរបស់គេ។

ដូច្នេះភាពយុត្តិធម៌របស់រដ្ឋ គឺពលរដ្ឋត្រូវមានការងារធ្វើ ហើយធ្វើសកម្មភាពស្របទៅតាម សមត្ថភាព និង អត្តិភាពរបស់ខ្លួនផ្ទាល់។ លោកប្លាតុង បានធ្វើការបែងចែកយ៉ាងច្បាស់នូវឋានានុក្រមស្រទាប់របស់មនុស្ស ក្នុង សង្គមថា ពួកទស្សនវិទូដែលដឹកនាំប្រទេស (វណ្ណៈជាន់ខ្ពស់) អ្នកយាម និងទាហានមន្ត្រីរាជការ (វណ្ណៈកណ្តាល អ្នកសិប្បករ និងកសិករ វណ្ណៈក្រោម) ។ មិនតែប៉ុណ្ណោះ ប្លាតុង បានពិនិត្យយ៉ាងហ្មត់ចត់លើបញ្ហាការសិក្សា និង ការអប់រំ។ ប្លាតុង បានធ្វើការបែងចែកដូច្នេះ «អាស្រ័យលើឧបនិស្ស័យរបស់មនុស្ស គឺភាពវៃឆ្លាត ភាពម៉ឺងម៉ាត់ និង ការទទួលខុសត្រូវក្នុងភាពជាអ្នកដឹកនាំ»។

សម្រាប់លោក ប្លាតុង រចនាសម្ព័ន្ធល្អគឺនៅកន្លែងណាដែលពលរដ្ឋម្នាក់ៗធ្វើការដើម្បីប្រយោជន៍ របស់ខ្លួននៅ ក្នុងទិសដៅអភិវឌ្ឍន៍សង្គម។ រដ្ឋ និងសង្គមពលរដ្ឋរបស់ប្លាតុងគឺមានលក្ខណៈតែមួយ។ តាមការពិនិត្យវណ្ណៈ ទាំងឡាយដូចជាមេដឹកនាំ(ក្សត្រ)កងទ័ព(អាមាត្យឈ្មួញ សិប្បករ និងម្ចាស់ដី លោកប្លាតុង បានបង្ហាញថា «វណ្ណៈ ដែលមានតួនាទីសំខាន់ជាងគេក្នុងរដ្ឋគឺមេដឹកនាំ(ក្សត្រ) និងកងទ័ព(អាមាត្យ)។ រីឯឈ្មួញកសិករ និងដែលមាន ជីវិតផ្សារភ្ជាប់នឹងផលិតផលសម្ភារៈនោះពួកគេមិនអាច ជៀសផុត ពីការអាស្រ័យនូវរដ្ឋនោះទេ ទីបំផុតពួកវណ្ណៈ ទាំងពីរ នេះប្រឹងប្រែងសន្សំទ្រព្យសម្បត្តិ ដែលជាហេតុនាំឱ្យកើតមានឡើងនូវអ្នកមានពេកនិងអ្នកក្រពេក»។ ដើម្បី រក្សាស្ថានភាពនេះប្លាតុងទាមទារឱ្យមានការបង្កើត ប្រព័ន្ធអប់រំពិសេសមួយសម្រាប់ក្រុមអ្នកដឹកនាំ និងអ្នកការពារ។ នៅក្នុងមូលនៃប្រព័ន្ធអប់រំនេះ ត្រូវមានសិល្បៈតូរ្យតន្ត្រី និងអត្តពលកម្មចូលរួមផងដែរ។ តូរ្យតន្ត្រីពង្រឹងដួងព្រលឹង អប់រំឱ្យស្រលាញ់ជាតិមាតុភូមិ ចំណែកឯអត្តពលកម្មពង្រឹងរាងកាយឱ្យរឹងមាំរៀបចំពលរដ្ឋដើម្បីរដ្ឋរបស់ខ្លួន។

តាមទស្សនៈប្លាតុង ការសិក្សាវិទ្យាសាស្ត្រជាការស្វែងរកពិភពសច្ចភាពហើយមិនភូតភរ ដូចជាលក្ខណៈ រូបធាតុទេ។ បន្ទាប់ពីបានបញ្ចប់នូវមុខវិជ្ជាទាំងអស់នេះយុវវ័យមានការចេះដឹង និងប្រកប ដោយសីលធម៌ នោះអាច រៀបចំខ្លួនដើម្បីដើរតួរជាមេដឹកនាំ។ ពេលនេះគេសិក្សាវិភាគ អំពីសិល្បៈ និងដឹកនាំជជែកពិភាក្សា បន្ទាប់មកសិក្សា ទស្សនវិជ្ជាដែលជាប្រភពដើមនៃរាល់ប្រព័ន្ធចំណេះដឹង។ នៅចុងកម្មវិធីសិក្សាពួកគេត្រូវតែងតាំងឱ្យមានមុខងារជា បុគ្គលិករដ្ឋ ប៉ុន្តែមិនទាន់មានមុខងារដឹកនាំរដ្ឋទេ លុះត្រាតែមានវ័យចាប់ពី៥០ឆ្នាំឡើងទៅស្គាល់នូវទិសដៅនៃជីវិត ច្បាស់លាស់។ ចេះធ្វើការអង្កេតពិនិត្យទទួលយកនូវទស្សនៈដែលជឿនលឿន និងមានការសម្របសម្រួលទទួល យកបទពិសោធន៍ជាច្រើនអំពីរដ្ឋ។ នៅពេលនោះគេមានលក្ខណៈសម្បត្តិពេញលេញក្លាយជាមេដឹកនាំរដ្ឋពិតប្រាក ដ។ បើតាមទស្សនៈប្លាតុង ទិសដៅរបស់រដ្ឋដែលប្លាតុង គិតថាជារដ្ឋគំរូ គឺត្រូវជួយផ្គត់ផ្គង់អតិបរមាដល់កង្វះ ខាត ក្នុងជីវិតប្រជាពលរដ្ឋទាំងសម្ភារៈទាំងស្មារតី។ ស្ថានភាពនៃជីវិតនេះហើយដែលគេបានគិតទទួលយកនៅក្នុង សម័យបុរេក្រិច និងរ៉ូម ។ គុណធម៌ទាំងបួនយ៉ាង ដែលឋានានុក្រមនៃស្រទាប់សង្គមក្នុងរដ្ឋគំរូត្រូវទទួលយកមាន៖

១. ចំណេះដឹងជ្រៅជ្រះ ត្រូវបំពេញដោយអ្នកដឹកនាំរដ្ឋ

២. សេចក្តីក្លាហានអង់អាច ត្រូវបំពេញដោយទាហានដែលជាអ្នកការពារ
៣. វិចារណញ្ញាណត្រូវបំពេញដោយពលរដ្ឋគ្រប់រូប
៤. យុត្តិធម៌ត្រូវបំពេញដោយពលរដ្ឋគ្រប់រូប។

# មេរៀនទី២ អារីស្តូត

( Aristotle 384-322 BC )

## ២.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ

អារីស្តូត កើតក្នុងឆ្នាំ៣៨៤ មុនគ.ស នៅទីក្រុង Stagire ទីក្រុងនេះមានទីតាំងជាប់មាត់សមុទ្រ អេហ្សេ ជិតប្រទេស ម៉ាកសេដូន (Macedonia)។ ឪពុកលោកឈ្មោះ នីកូម៉ាក(Nichomaque) ជាគ្រូពេទ្យ និងម្តាយឈ្មោះ ហ្វេស្ទីដា (Festida)។ លោកអារីស្តូត មានភរិយាឈ្មោះ Pythias ដែលជាវណ្ណៈកម្មករ ត្រូវបានគេលក់នាងបីដងរួចមកហើយ។ នៅឆ្នាំ៣៦៨ មុនគ.ស ពេលលោកអាយុ១៧ឆ្នាំ បានចូលរៀននៅសាលាបណ្ឌិតសភារបស់ប្លាតុងរហូតដល់លោកប្លាតុងស្លាប់អស់រយៈពេល២០ឆ្នាំ។ លោក អារីស្តូត គឺជាសិស្សដែលមានប្រាជ្ញាវាងវៃមានគំនិតលើសគេរបស់ប្លាតុងតែទស្សនៈរបស់លោកគឺដោយឡែកពីប្លាតុងហើយថែមទាំងរិះគន់គ្រូរបស់លោកទៀតផង។ ក្នុងនាមជាទស្សនវិទូដ៏ឆ្នើមម្នាក់ដែលបានបង្កើតប្រព័ន្ធទស្សនៈដោយខ្លួនឯងដាច់ដោយឡែកពីគ្រូរបស់ខ្លួននោះ អារីស្តូត គឺល្បីល្បាញពុំមែនក្នុងនាមជាអ្នកបន្តនិកាយទស្សនវិជ្ជារបស់ប្លាតុងឡើយ។

ក្រោយមរណភាពរបស់ប្លាតុង លោកអារីស្តូត បានបង្កើតសាលាទស្សនវិជ្ជាផ្ទាល់ខ្លួនមួយដែលមានឈ្មោះថា Le Lycee ដោយបានរកវិធីបង្រៀនសិស្សតាមរបៀបថ្មីមួយ គឺលោកនាំសិស្សដើរលេងបណ្តើរពន្យល់ទស្សនវិជ្ជាបណ្តើរ។ កិត្តិស័ព្ទរបស់លោកបានល្បីសុះសាយរហូតទៅដល់ស្តេចហ្វីលីព ហើយនៅឆ្នាំ៣៤៣ មុនគ.ស ព្រះអង្គផ្ញើលិខិតអញ្ជើញអារីស្តូតមកគាល់ព្រះអង្គ និងបានសុំឱ្យលោករស់នៅក្នុងវាំងដើម្បីបង្ហាត់បង្រៀនចំណេះវិជ្ជាដល់ព្រះរាជបុត្រព្រះអង្គព្រះនាម អាឡិចហ្សង់ដឺ។

អារីស្តូត បានសិក្សាពីជីវិតពិតៗនៅលើផែនដី ពិសេសបញ្ហាមនុស្សលោកលើផែនដីនេះ អាស្រ័យទៅលើការពិសោធន៍ និងការវិភាគបញ្ហាតាមបែបសនិទានភាព (សមហេតុសមផល) ដែលការវិភាគបែបនេះនាំឱ្យគេចាត់ទុកលោកថាបិតានៃវិទ្យាសាស្ត្រនយោបាយ។

ស្នាដៃសំខាន់ពីររបស់អារីស្តូតដែលបង្ហាញពីទស្សនៈនយោបាយនោះគឺនយោបាយ (Politics) និងសីលវិជ្ជា (Ethics) ព្រមទាំងស្នាដៃបន្ទាប់បន្សំផ្សេងៗទៀត។ តាមរយៈស្នាដៃទាំងនេះ អារីស្តូត បង្ហាញឱ្យឃើញថានៅក្នុងនយោបាយមាន ផ្ទុកបញ្ហាចម្បងធំៗពីរ គឺសីលវិជ្ជា និងសេដ្ឋកិច្ច។

## ២.២ ទស្សនៈនយោបាយ

លោក អារីស្តូត ចាត់ទុកថា នយោបាយ គឺជាវិទ្យាសាស្ត្រនៃភាពថ្កុំថ្កើង សម្បូរសប្បាយរបស់មនុស្សលោក និងរដ្ឋ។ គោលបំណងរបស់នយោបាយ និងសីលវិជ្ជាមានតែមួយ គឺដើម្បីសុភមង្គល និងភាពសម្បូរសប្បាយរបស់មនុស្ស និងរដ្ឋ។

### ២.២.១ អំពីរដ្ឋ

លោកបានអះអាងថា រដ្ឋគឺជាផលិតផលរីកចំរើន ឬជាសមិទ្ធិផលរបស់ធម្មជាតិ។ ចំណែកឯ ***មនុស្សវិញ គឺជាសត្វចេះធ្វើនយោបាយ តាមធម្មជាតិរបស់ខ្លួន។*** រដ្ឋកើតចេញពីបណ្តុំនៃភូមិគ្រឹះៗ កើតពីគ្រួសារៗ កើតពីមនុស្ស។ ដូច្នេះ មនុស្សមិនអាចរស់នៅតែម្នាក់ឯងបានទេ  គឺត្រូវការចាំបាច់នូវទំនាក់ទំនងគ្នានិងគ្នាដើម្បីបង្កើតរដ្ឋរបស់ខ្លួនក្នុងទិសដៅសុវត្ថិភាព និងអភិវឌ្ឍន៍សង្គម។ មានតែសង្គមរដ្ឋប្រភេទនេះហើយដែលនាំឱ្យមនុស្សមានភាពរុងរឿង។ រដ្ឋ គឺជាផ្លែផ្កានៃយុត្តិធម៌ និងគិតគូរប្រយោជន៍រួមសម្រាប់ពលរដ្ឋទាំងអស់គ្នា។

អារីស្តូត បានបញ្ញត្តិនូវពាក្យថា Polis ដែលមានន័យស្មើនឹងពាក្យថា នីតិរដ្ឋ ក្នុងសម័យសព្វថ្ងៃនេះ ព្រោះនៅក្នុងរដ្ឋមានការចាត់ចែងទៅតាមផ្លូវច្បាប់។ រដ្ឋ Polis ត្រូវគ្រប់គ្រងដោយច្បាប់ ពុំមែនដោយមនុស្សម្នាក់ ឬបុគ្គលមួយក្រុមឡើយ។

សណ្តាប់ធ្នាប់គឺមាននៅក្នុងច្បាប់។ ច្បាប់ គឺជាកម្រងអត្ថបទសម្រាប់រៀបចំជីវភាពសង្គមឱ្យមានសណ្តានមួយជាក់លាក់ និងមានស្ថិរភាព។ សន្ទស្សន៍ច្បាប់ គឺជាកម្លាំង។ ច្បាប់មានតម្លៃស្មើនឹងយុត្តិធម៌។ ច្បាប់មានមកពីប្រភពច្រើនអាចពីធម្មជាតិ អាចពីការកំណត់ដោយច្បាប់ និងអាចតាមការឯកភាពគ្នាជាគោល។ច្បាប់ចែកចេញជាច្បាប់សរសេរ និងច្បាប់ឥតសរសេរឬច្បាប់ទម្លាប់តាមលក្ខណៈ ធម្មជាតិ ហើយរដ្ឋគឺជាអង្គរួមដែលត្រូវតែដើរមុខអង្គដោយឡែកៗពីបុគ្គល។ រដ្ឋមានអត្ថិភាពឡើងដើម្បីធ្វើឱ្យពលរដ្ឋរបស់ខ្លួនមានលក្ខណៈប្រសើរឡើង។

ពលរដ្ឋ គឺជាមនុស្សមានសេរីភាព ពុំមែនជាទាសករទេ។ គ្មានអ្នកណាម្នាក់មានពលរដ្ឋទេ គឺមានតែរដ្ឋប៉ុណ្ណោះដែលមានពលរដ្ឋសម្រាប់បំរើការងារជាអ្នកចំបាំងជាអ្នកបង្កើតច្បាប់និងជាអ្នកកាន់ការងារតុលាការ។ ចំណែកឯបញ្ហាផលិតកម្មវិញ (កសិកម្ម សិប្បកម្ម)ជានិច្ចកាលគឺជារបស់ទាសករ។ បញ្ញត្តិសេរីភាព និងសមភាពមិនត្រូវបានគេលើកយកមកពិចារណាក្នុងស្រទាប់ទាសករឡើយ។

កម្មសិទ្ធិឯកជន គឺជាមករតកនៃការស្រឡាញ់ខ្លួនឯងរបស់មនុស្ស។ ដូច្នេះកម្មសិទ្ធិឯកជនមានភាពអាស្រ័យទៅនឹងធម្មជាតិរបស់មនុស្ស ព្រោះមនុស្សម្នាក់ៗសុទ្ធតែស្រឡាញ់ខ្លួនឯងទាំងអស់។ ចំណែកឯកម្មសិទ្ធិរួម គឺជាអ្វីដែលប្រឆាំងនឹងធម្មជាតិរបស់មនុស្ស។ វាគឺជាការកំណត់របស់មនុស្ស ដើម្បីប្រយោជន៍រួម។

ពលរដ្ឋអាចមានរបបកម្មសិទ្ធិឯកជន។ ដើម្បីប្រើប្រាស់កម្មសិទ្ធិនេះពលរដ្ឋត្រូវប្រតិបត្តិតាមគោលការណ៍រួមមួយគឺច្បាប់ដែលតម្រូវឱ្យអ្នកមានទ្រព្យសម្បត្តិត្រូវប្រកបដោយគុណធម៌ និងចិត្តសប្បុរស។ វិសមភាពក្នុងសង្គម គឺជារឿងគួរឱ្យបារម្ភព្រោះវាគឺជាមូលហេតុនាំឱ្យមានការតូចចិត្ត ទំនាស់សង្គម និងរដ្ឋប្រហារ ដើម្បីរំលំរដ្ឋតាមគ្រប់រូបភាព។

ក្នុងការសិក្សាពីបញ្ហាទម្រង់រដ្ឋ គឺត្រូវផ្អែកលើគោលការណ៍ពីរយ៉ាង ៖

- ទី១ គឺភាពអាស្រ័យទៅនឹងបរិមាណនៃអ្នកដឹកនាំ ដែលអំណាចរដ្ឋអាចជារបស់បុគ្គលម្នាក់ បុគ្គលភាគតិច និងប្រជាជនភាគច្រើន។

- ទី២ គឺនិន្នាការនៃរបបគ្រប់គ្រងរដ្ឋដែលមានទម្រង់ត្រឹមត្រូវ និងទម្រង់មិនត្រឹមត្រូវ។

គ្រប់ទម្រង់រដ្ឋទាំងអស់សុទ្ធតែមានគោលការណ៍របស់ខ្លួនយ៉ាងជាក់លាក់ ៖

- អភិជនាធិបតេយ្យ ៖ គោលការណ៍គុណធម៌ និងចិត្តសប្បុរស វានឹងរឹងមាំនៅពេលដែលអ្នកដឹកនាំជាពពួកមនុស្សមានប្រាជ្ញាឈ្លាសវៃ ខ្លាំងពូកែ មានស្ថានភាពសង្គមសមរម្យ មានបំណង់ចង់បម្រើផលប្រយោជន៍រួម សម្រាប់គ្រប់ពលរដ្ឋទាំងអស់ គឺជាមនុស្សដែលកម្ររកបាន *"មហាមនុស្ស"*។

- អប្បជនាធិបតេយ្យ ៖ គោលការណ៍ធនធាន និងទ្រព្យសម្បត្តិ វាកើតឡើងនៅពេលដែលកិច្ចការដឹកនាំរដ្ឋធ្លាក់ចូលទៅក្នុងដៃបុគ្គលក្រីក្រតោកយ៉ាក ដែលបំពេញកិច្ចការគ្រប់បែបយ៉ាង ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន (ទោះជាបុគ្គលក្រុមតូច ភាគច្រើនក្តី) ដោយឈរលើមូលដ្ឋាន ៖

១) បដិសេធចោលនូវផលប្រយោជន៍ប្រជាជនទាំងមូល

២) មិនទទួលស្គាល់នូវផលប្រយោជន៍របស់ប្រជាជនផ្នែកណាមួយ

៣) មិនទទួលស្គាល់នូវផលប្រយោជន៍របស់អ្នកក្រ។

- ប្រជាធិបតេយ្យ ៖ គោលការណ៍សេរីភាព។

អារីស្តូត បានបង្ហាញនូវទម្រង់រដ្ឋគំរូមួយ គឺ Policy ដែលជាទម្រង់សាធារណៈរដ្ឋមួយនាសម័យក្រិចបុរាណ។ ក្នុងទម្រង់រដ្ឋនេះអំណាចស្ថិតនៅក្នុងកណ្តាប់ដៃនៃសភាបុរស (ភាពប្រមូលផ្តុំនៃបុរសៗ) ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់អាវុធ (អ្នកមានកម្លាំង មានអាវុធ និងមានអំណាច)។ សភានេះមានសមត្ថភាពគ្រប់គ្រាន់

ក្នុងការដោះស្រាយបញ្ហាសង្គម បញ្ហាសន្តិភាព និងបង្កើតច្បាប់។ សភានេះ គឺជាអំណាចកំពូល និងជាអ្នកនាំមកនូវគុណប្រយោជន៍យ៉ាងច្រើនដល់សង្គមពលរដ្ឋទាំងអស់។ ដូច្នេះ ទម្រង់រដ្ឋនេះ បានប្រមូលផ្តុំនូវគោលការណ៍សរុបរបស់ទម្រង់រដ្ឋផ្សេងៗខាងលើ។ រដ្ឋគំរូ Policy ជាទម្រង់រដ្ឋដែលពោរពេញដោយគុណធម៌ ធនធាន និងសេរីភាព។

**២.២.២ អំពីយុត្តិធម៌**

បញ្ហាសំខាន់ដែលត្រូវរែកញែកចំពោះយុត្តិធម៌ និង អយុត្តិធម៌ គឺថា តើសកម្មភាពបែបណាដែល យើងចង់សំដៅយក ? តើអត្ថន័យប្រភេទណាដែលចាត់ទុកជាយុត្តិធម៌ ? តើអ្វីជាភាពហួសហេតុ ឬជ្រុល និយម រវាងយុត្តិធម៌ទូទៅ និងភាពជាកណ្តាល ?

ក្នុងស្នាដៃរបស់លោកស្តីពីយុត្តិធម៌ អារីស្តូត បានចាប់ផ្តើមទទួលស្គាល់នូវអត្ថន័យពីរយ៉ាងរបស់ពាក្យ Just ដែលអាចមានន័យថា ដែលត្រឹមត្រូវតាមច្បាប់ ឬដែលមានលក្ខណៈត្រឹមត្រូវនិងស្មើភាពគ្នា។ នេះជាអត្ថន័យដែលមានលក្ខណៈជាសកល និង មានលក្ខណៈដោយឡែករបស់ពាក្យ Justice។ អត្ថន័យទីមួយ "ដែលត្រឹមត្រូវតាមច្បាប់" មានលក្ខណៈស្មើទៅនឹងការគោរព ឬស្តាប់បង្គាប់តាមច្បាប់ ច្បាប់ត្រូវត្រួតពិនិត្យមើលមនុស្សពេញមួយជីវិត ហើយបង្ខំឱ្យប្រតិបត្តិតាម មិនមែនតែលើភាពត្រឹមត្រូវតាមសីលធម៌ទេ ព្រោះវាមិនអាចធានាបានថាមនុស្សគ្រប់រូបសុទ្ធតែធ្វើសកម្មភាពដើម្បីភាពថ្លៃថ្នូរឡើយ។ ប៉ុន្តែសកម្មភាពទាំងឡាយនឹងមានលក្ខណៈស្របតាមគុណធម៌ ប្រសិនបើច្បាប់នៃរដ្ឋណាមួយអនុវត្តបានមួយផ្នែកណានោះ។

បើតាមអារីស្តូត យុត្តិធម៌ ក្នុងន័យនេះមានលក្ខណៈស្របនឹងគុណធម៌។ វាបានសំដៅលើចរិតលក្ខណៈសង្គមដែលត្រូវអនុវត្តន៍ស្របតាមសីលគុណធម៌។

ក្នុងស្នាដៃស្តីពីនយោបាយ លោកបាននិយាយយ៉ាងលំអិតពីគំនិតនយោបាយជាងក្នុងស្នាដៃស្តីពី សីលវិទ្យា ហើយលោកបានអះអាងពីភាពត្រឹមត្រូវថា៖ ច្បាប់មានគោលបំណងស្វែងរកប្រយោជន៍ទូទៅ ជូនពលរដ្ឋ ឬប្រយោជន៍របស់អ្នកកាន់អំណាច ដែលត្រូវកំណត់ដោយយុត្តិធម៌។ ធ្វើរបៀបនេះ គឺដើម្បីឱ្យយើងអាចយល់បានថាភាពត្រឹមត្រូវ ឬអ្វីដែលត្រឹមត្រូវពិតជាជួយឱ្យកើតមាន ឬជួយធានាឱ្យមានសុភមង្គល ឬថាវាជាធាតុផ្សំនៃសុភមង្គលសម្រាប់សហគមន៍នយោបាយ។

អារីស្តូត ក៏ដូចជា ប្លាតុង ដែរសុទ្ធតែបានជឿជាក់យ៉ាងខ្លាំងលើតួនាទីវិជ្ជមាន និង ប្រកបដោយការចេះដឹងរបស់រដ្ឋ។ តែអារីស្តូត បានយកចិត្តទុកដាក់ជាពិសេសលើទស្សនៈយុត្តិធម៌ មានលក្ខណៈពិសេសដោយឡែកប៉ុណ្ណោះ។ មនុស្សដែលមិនត្រឹមត្រូវមិនយុត្តិធម៌ ក្នុងន័យនេះជាមនុស្សដែលយក ចំណែកច្រើនជាងអ្វីដែលជារបស់ខ្លួននូវចំណែកដែលគេត្រូវបាន។ ហើយខ្លួនយកតែចំណែកណាដែលជារបស់ខ្លួនយ៉ាងពិតប្រាកដ ដោយមិនលួចបន្លំ ឬគំរាមកំហែងយករបស់គេផ្សេងឡើយ។

ពេលណាដែលយុត្តិធម៌មានលក្ខណៈជារដ្ឋ ទំនាក់ទំនងរបស់វា និងសកម្មភាពត្រឹមត្រូវ ខុសប្លែកពីទំនាក់ទំនងនៃលទ្ធភាពមួយទៅនឹងសកម្មភាពរបស់វា។ គឺជួនកាលអ្វីដែលជាការពិតសម្រាប់វិទ្យាសាស្ត្រ និងសមត្ថភាពគឺមិនពិតនៅក្នុងរដ្ឋឡើយ។ ក្នុងពេលដែលអ្វីមួយនិងលទ្ធភាពតែមួយឬវិទ្យាសាស្ត្រ មានលក្ខណៈហាក់បីដូចជាមានអំពើផ្ទុយរដ្ឋមួយដែលមានលក្ខណៈបញ្ច្រាស់ គឺហាក់ដូចជាបញ្ច្រាស់ ឧទាហរណ៍ ដូចជាសុខភាពនាំឱ្យយើង ឬអាចត្រឹមតែធ្វើឱ្យយើងមានសុខភាពល្អ មាំមួន និង អំពើដែលប្រកបដោយភាពមាំមួនតែប៉ុណ្ណោះ ពុំមែនផ្ទុយពីនេះទេ។ យើងនិយាយថាយើងដើរតាមផ្លូវមួយដែលនាំឱ្យមានសុខភាព ប្រសិនបើយើងដើរតាមផ្លូវដែលអ្នកមានសុខភាពល្អមាំមួនបានប្រព្រឹត្ត ?

យុត្តិធម៌ដែលមានអត្ថន័យពិសេសដោយឡែក ត្រូវបានបែងចែកជា៣យ៉ាង គឺយុត្តិធម៌ក្នុងការបែងចែក យុត្តិធម៌ក្នុងការដោះដូរ និង យុត្តិធម៌ក្នុងការកែតម្រូវ។

**២.២.២.១ យុត្តិធម៌ក្នុងការបែងចែក**

ព្រោះតែមនុស្សមិនត្រឹមត្រូវ គឺវាមិនយុត្តិធម៌ ហើយអ្វីដែលមិនយុត្តិធម៌ គឺមិនត្រឹមត្រូវ។ នៅពេល នេះអ្វីដែលជាផ្លូវកណ្តាលរវាង ខ្លាំងជ្រុល ខ្សោយជ្រុល គឺជាការត្រឹមត្រូវ។ ហេតុនេះអ្វីដែលមិនយុត្តិធម៌ គឺមិនត្រឹមត្រូវ ហើយអ្វីដែលយុត្តិធម៌ គឺអ្វីដែលត្រឹមត្រូវ គឺត្រូវបានមនុស្សគ្រប់រូបឯកភាពយក។

អ្វីដែលត្រឹមត្រូវ ហើយស្មើភាពគ្នានោះគឺកណ្តាល (Intermediate) អ្វីដែលយុត្តិធម៌ គឺជាប្រភេទ មួយនៃផ្លូវកណ្តាល។ ហេតុនេះដែលស្មើភាព គឺយ៉ាងហោចណាស់ពាក់ព័ន្ធទៅនឹងវត្ថុពីរស្មើគ្នា។ វាជា កណ្តាលនូវអ្វីដែលច្រើន និងតិច។ ជាទូទៅ អ្វីដែលស្មើភាពពាក់ព័ន្ធទៅនឹងរបស់ពីរ ព្រមទាំងមនុស្សពីរនាក់។ ដូច្នេះអ្វីដែលយុត្តិធម៌ក្នុងការបែងចែក គឺទាក់ទងទៅនឹងវត្ថុបួនយ៉ាងគឺ មនុស្សពីរនាក់ និងវត្ថុពីរដែលត្រូវបែងចែក។ ហើយអ្វីដែលស្មើគ្នាគឺពាក់ព័ន្ធនឹងរបស់ពីរ។

មនុស្សក៏ដូចវត្ថុដែរ ភាពស្មើគ្នាចំពោះមនុស្សប្រសិនបើទំនាក់ទំនងមិនស្មើគ្នា ពួកគេនឹងទទួលបាននូវចំណែកដែលមិនស្មើគ្នា។ ជាការពិតណាស់នៅពេលដែលស្មើគ្នា តែទទួលបាននូវចំណែកមិនស្មើគ្នា ហើយមិនស្មើគ្នាទទួលបានចំណែកស្មើគ្នានៅក្នុងការបែងចែកអ្វីមួយនោះ គឺជាប្រភពនៃជម្លោះ និងការចោទប្រកាន់គ្នា។ វាមានន័យច្បាស់លាស់ណាស់ដែលថា ជាអ្វីដែលសក្តិសមនឹងតម្លៃរបស់មនុស្សម្នាក់។ មនុស្សគ្រប់រូបឯកភាពថា អ្វីដែលត្រឹមត្រូវយុត្តិធម៌គឺអ្វីដែលសក្តិសមទៅនឹងតម្លៃរបស់មនុស្សនៅក្នុងការបែងចែក ប៉ុន្តែអ្វីដែលហៅថាតម្លៃនោះ គឺវាមានន័យពុំដូចគ្នាឡើយ។ អ្នកគាំទ្រប្រជា ធិបតេយ្យយល់ថាតម្លៃគឺសេរីភាពរបស់ពលរដ្ឋ ខ្លះទៀតថា តម្លៃគឺជាអំពើល្អ ឯខ្លះថាគុណធម៌។

អ្វីដែលយុត្តិធម៌ត្រឹមត្រូវ តម្រូវឱ្យមានការបែងចែកស្មើគ្នាចំពោះមនុស្សស្មើគ្នា នេះជាសមាមាត្រ។ សម្រាប់សមាមាត្រមានលក្ខណៈពិសេសគ្រប់ចំនួនទាំងអស់ និងស្មើភាពគ្រប់ទំនាក់ទំនង ហើយយ៉ាង ហោចណាស់តម្រូវឱ្យមានទំនាក់ទំនងរបស់បួន។ ពេលដែលបន្ទាត់ A គឺជាបន្ទាត់ B ហើយបន្ទាត់ B គឺជាបន្ទាត់ C ពេលនោះយើងឃើញថា B ត្រូវបានគេប្រើពីរដង គឺ [AB] និង [BC] : ដូច្នេះអ្វីដែលត្រឹមត្រូវ គឺពាក់ព័ន្ធទៅនឹងវត្ថុបួនយ៉ាង។ ហើយទំនាក់ទំនងនោះត្រូវបែងចែកជាគូដូច្នេះ [A&B] ក៏ដូចជា[B&D] ត្រូវបានបែងចែកដូចគ្នា។ ហេតុនេះអ្វីដែលជាសមាមាត្រ គឺកណ្តាល អ្វីដែលយុត្តិធម៌ គឺសមាមាត្រ។ សមាមាត្រប្រភេទនេះ អ្នកគណិតវិទូហៅថា ធរណីមាត្រសមាមាត្រ ព្រោះក្នុងសមាមាត្រធរណីមាត្រមានទំនាក់ទំនងទៅនឹងអ្វីទាំងមូលដូចទៅនឹងផ្នែកវានីមួយៗ។

អ្វីដែលយុត្តិធម៌ គឺអ្វីដែលសមាមាត្រ ហើយអ្វីដែលមិនយុត្តិធម៌នៅក្នុងការបែងចែក គឺជាអ្វី ដែលផ្ទុយទៅនឹងសមាមាត្រ។ ក្នុងសកម្មភាពមិនយុត្តិធម៌មួយក្លាយទៅជាច្រើន ហើយច្រើនក្លាយទៅជាតិច។ នេះគឺជាអ្វីដែលមនុស្សកំពុងធ្វើបច្ចុប្បន្ន ដែលធ្វើអំពើអយុត្តិធម៌ទទួលបានគុណសម្បត្តិ និងផលល្អជាច្រើន ហើយជនរងគ្រោះទទួលបានតិចតួច។ ចំពោះអំពើអាក្រក់វិញទំនាក់ទំនងក្នុងការបែងចែកគឺផ្ទុយគ្នា។ ពេលណាអាក្រក់តិចធៀបទៅនឹងអាក្រក់ច្រើនបំផុតការដែលអាក្រក់តិចមានតម្លៃជ្រើសរើសជាងអាក្រក់ច្រើន អ្វីដែលជាតម្លៃនៃការជ្រើសរើសគឺល្អ អ្វីដែលជាតម្លៃនៃការជ្រើសរើសយកនេះកាន់តែខ្ពស់ កាន់តែប្រសើរ។ ហេតុនេះ កត្តាជំបូងសម្រាប់អ្វីដែលហៅថា យុត្តិធម៌។

### ២.២.២.២ យុត្តិធម៌ក្នុងការកែតម្រូវ

វាមានលក្ខណៈខុសគ្នានឹងយុត្តិធម៌ក្នុងការបែងចែក។ វិធីសាស្ត្រផ្សេងទៀតនៃយុត្តិធម៌ គឺការ កែតម្រូវមានមុខជំនួញ ទាំងស្ម័គ្រចិត្ត និងមិនស្ម័គ្រចិត្ត ហើយយុត្តិធម៌បែបនេះខុសពីលក្ខណៈមុន ដោយតាមរូបភាពផ្សេងគ្នា។ សម្រាប់អ្វីដែលត្រឹមត្រូវក្នុងការបែងចែកទ្រព្យសម្បត្តិរួម ជានិច្ចកាលតែងសក្តិសមនឹងសមាមាត្រដូចអត្ថាធិប្បាយខាងលើ។ មួយវិញទៀត អ្វីដែលយុត្តិធម៌ក្នុងមុខជំនួញគឺ ពិតជាស្មើភាពក្នុងវិធីសាស្ត្រណាមួយ ហើយអ្វីដែលមិនយុត្តិធម៌គឺមិនស្មើភាព ប៉ុន្តែវានៅតែស្របទៅតាមសមាមាត្រជាច្រើន ពុំមែនជាសមាមាត្រធរណីមាត្រតែមួយទេ។

ទីនេះយើងមិនសំដៅថា ប្រសិនបើមនុស្សល្អម្នាក់ចេញពីមនុស្សថោកទាបម្នាក់ ឬមនុស្សថោកទាបម្នាក់ចេញពីមនុស្សល្អណាមួយឡើយ ឬក៏មនុស្សទាំងពីរនេះប្រព្រឹត្តអំពើក្បត់។ ច្បាប់មើលតែចំពោះភាពផ្សេងៗគ្នានៃការបង្ក

ឱ្យមានការឈឺចាប់ ហើយព្យាបាលអ្នកនោះតាមរយៈស្មើភាពពេលដែលនរណាម្នាក់ធ្វើអំពើអយុត្តិធម៌ ហើយនរណាម្នាក់ទទួលរងរបួស និងម្នាក់នោះបានធ្វើឱ្យរងការឈឺចាប់ពេលដែលអ្នកដទៃរងការឈឺចាប់។ ត្រង់នេះការវិនិច្ឆ័យព្យាយាមកែតម្រូវភាពមិនត្រឹមត្រូវនេះតាម ស្ថានភាពទូទៅជាលក្ខណៈស្មើភាពក្នុងពេលអ្វីមួយដែលវាមិនស្មើគ្នា។

មិនចំពោះថាទាំងអ្នកទទួលរងរបួស ឬអ្នកលួចរបស់ពីអ្នកណាម្នាក់ឡើយ ឬសំឡាញ់ និងនរណាម្នាក់ត្រូវបានសម្លាប់។ អំពើ និងការទទួលរងគ្រោះជាចំណែកពុំស្មើគ្នាជាមួយនឹងទឹកប្រាក់ រវាងអ្នកប្រព្រឹត្តបទល្មើសទៅនឹងការបាត់បង់របស់ជនរងគ្រោះ ហេតុនេះចៅក្រមខិតខំរកវិធីជួសជុល និងថ្លឹងថ្លែងឱ្យបានស្មើភាពនូវប្រាក់កម្រៃរវាងអ្នកទាំងពីរដោយដកប្រាក់ពីអ្នកប្រព្រឹត្តបទល្មើសដើម្បីសង។ ពេលដែលអ្វីមួយទទួលរងគ្រោះ ត្រូវបានចាត់វិធានការ ឬវាស់វែងផ្នែកមួយហៅថា ការបាត់បង់របស់ជន រងគ្រោះ ហើយមួយទៀតគឺប្រាក់កម្រៃរបស់ជនល្មើស។

ជាការពិតណាស់ទោះបីជាយ៉ាងណាក៏ដោយ ក៏ឈ្មោះថា បាត់បង់ និងកម្រៃ មានប្រភពពីសកម្ម ភាព ឬអំពើស្ម័គ្រចិត្តក្នុងការដោះដូរគ្នា។ ជាធម្មតាការដែលមានចំនួនច្រើនជាងលើសពីចំណែករបស់ ខ្លួនដែលត្រូវទទួលបានគេហៅថា ការបង្កើតកម្រៃ ឯអ្នកដែលទទួលបានតិចនៅចំណុចចាប់ផ្តើមនៃការបែងចែកនោះគឺអ្នករងគ្រោះ ឬបោះបង់ក្នុងការទិញ ឬលក់ក្នុងមុខជំនួញផ្សេងទៀតដែលអនុញ្ញាតិដោយច្បាប់។ តិចតួចច្រើនក្តីអ្វីដែលពួកគេទទួលបានគឺពួកគេយល់ថា វាជាកម្មសិទ្ធិរបស់គេ ហើយគេនិយាយថា គេមានចំណែក។

ដូច្នេះអ្វីដែលស្មើភាព គឺជាចំនួនកណ្តាលរវាងច្រើន និងតិច ឯកម្រៃ និងការខាតបង់ គឺតិច និង ច្រើន ក្នុងផ្លូវផ្ទុយ ព្រោះល្អច្រើន និងអាក្រក់តិច គឺជាផលចំណេញ ហើយផ្ទុយពីនេះគឺការបោះបង់ ហើយចំណុចកណ្តាលរវាងចំណេញ និងបាត់បង់ ដែលយើងរកឃើញថា ជាអ្វីស្មើភាពគឺជាអ្វីដែលយើង និយាយថា យុត្តិធម៌។ ហេតុដូច្នេះ អ្វីដែលយុត្តិធម៌ក្នុងការកែតម្រូវ គឺជាអ្វីដែលកណ្តាល ឬមធ្យមរវាង កម្រៃ និងការបាត់បង់។ នេះត្រូវបានគេអះអាងថាជាផ្លូវកណ្តាល និងឯកភាពថា ផ្លូវកណ្តាលជាអ្នកសម្របសម្រួល។ ការសន្និដ្ឋានថា ប្រសិនបើការដោះស្រាយអ្វីមួយទទួលបានផលជាកណ្តាល ផលនោះនឹងត្រឹមត្រូវ ហើយប្រសិនបើចៅក្រមជាមនុស្សកណ្តាល អ្វីដែលយុត្តិធម៌ គឺភាពកណ្តាល។

ក្នុងកម្មវិធីនេះយើងត្រូវចាំថា យើងត្រូវតែដកពីនរណាម្នាក់ដែលមានចំនួនច្រើនទៅឱ្យនរណាម្នាក់ដែលមានតិច ដើម្បីជួសជុលកែលម្អឱ្យបានស្មើភាព។ ដូច្នេះអ្វីដែលយុត្តិធម៌ គឺជាភាពកណ្តាល រវាងការសងបាត់បង់ និងទទួលបាន។

**២.២.២.៣ យុត្តិធម៌ក្នុងការដោះដូរ**

យុត្តិធម៌ គឺពុំមែនគ្រាន់តែជាទំនាក់ទំនងធម្មតា។ ប៉ុន្តែវាហាក់បីដូចជាថា ចំពោះមនុស្សខ្លះការដោះដូរទៅវិញទៅមក គឺត្រូវបានយល់ថា យុត្តិធម៌។

ជាករពិតណាស់ ការដោះដូរមិនដូចនឹងការបែងចែក និងកែតម្រូវ។ សម្រាប់ករណីជាច្រើន ដល់ការដោះដូរផ្ទុយទៅនឹងយុត្តិធម៌ក្នុងការបែងចែក និងកែតម្រូវ។ ប្រសិនបើនាយកការិយាល័យមួយ អនុវត្តកិច្ចការរបស់គាត់ធ្វើឱ្យប៉ះពាល់ដល់ជនណាម្នាក់ គាត់មិនត្រូវបានទទួលរងរបួសវិញនោះទេ ប៉ុន្តែ ប្រសិនបើនរណាម្នាក់ធ្វើឱ្យគាត់រងរបួសវិញ គាត់មិនត្រឹមតែទទួលរងរបួសវិញទេ គឺថែមទាំងទទួលនូវ ការស្តីបន្ទោស និងកែតម្រូវទៀតផង។ លើសពីនេះទៅទៀតសកម្មភាពស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្តមាន លក្ខណៈខុសគ្នាស្រឡះ។

ប៉ុន្តែយុត្តិធម៌ក្នុងការដោះដូរ គឺជាសមាមាត្រនៃការដោះដូរ។ ក្នុងទំនាក់ទំនងនៃការដោះដូរ យុត្តិ ធម៌បែបនេះគឺមានលក្ខណៈសមាមាត្រជាជាងស្មើភាព ដើម្បីរក្សាឱ្យមនុស្សរស់នៅជាមួយគ្នាបាន រដ្ឋ មួយត្រូវតែធានាដោយការដោះដូរតាមរបបសមាមាត្រ។ សម្រាប់មនុស្សទូទៅ តែងពិនិត្យឃើញថាគេ តែងតបអំពើអាក្រក់ ដោយអំពើអាក្រក់ ហើយអំពើល្អដោយអំពើល្អ ទាំងនេះពួកគេចាត់ទុកថាជាការដោះដូរក្នុងសង្គមមួយ។ នេះជាលក្ខណៈពិសេស ពេលដែលនរណាធ្វើល្អមកយើង យើងនឹងធ្វើល្អមក អ្នកនោះវិញ ហើយសកម្មភាពនេះ វានឹងដោះដូរទៅវិញទៅមកជានិច្ច។

នេះគឺជាការលាយបញ្ចូលគ្នា ដែលបង្កើតឱ្យមានសមាមាត្រក្នុងការផ្លាស់ប្តូរ។ ឧទាហរណ៍ថា A គឺជាអ្នកសង់ផ្ទះម្នាក់ B ជាជាងស្បែកជើង C ជាមេផ្ទះមួយ ហើយ D ជាស្បែកជើង។ អ្នកសង់ផ្ទះត្រូវ ទទួលផលិតផលស្បែកជើងពីគាត់ហើយឱ្យគាត់វិញនូវឧបករណ៍សាងសង់ជាសំណង់។ បន្ទាប់មកទៀតប្រសិនបើសមាមាត្រស្មើភាពត្រូវបានគេរកឃើញ ក្រោយមកការដោះដូរក៏ត្រូវបានទទួលដែរ ពេលនោះសំណង់សមាមាត្រ និងត្រូវបានទទួល។ ផ្ទុយទៅវិញ វាពុំស្មើភាព ហើយការដោះដូរ និងមិនអាច ធានាបាន ព្រោះផលិតផលមួយអាចមានតម្លៃខ្ពស់ជាងផលិតផលផ្សេងទៀត។ ផលិតផលទាំងនេះ ក្រោយមកត្រូវតែធ្វើឱ្យស្មើ។

ហេតុនេះប្រាក់ត្រូវបានកំណត់ដើម្បីធានានូវសមាមាត្រ។ ដូច្នេះបានជាគ្រប់វត្ថុទាំងអស់សម្រាប់ ផ្លាស់ប្តូរត្រូវបានធៀបក្នុងវិធីផ្សេងៗ។ ប្រាក់គឺទីនេះមានតួនាទីយ៉ាងពិតប្រាកដ ហើយក្នុងផ្លូវមួយវានឹងជាភាពកណ្តាល ព្រោះវាអាចធានានូវអ្វីៗទាំងអស់ ព្រោះថាប្រសិនបើដោះដូរឱ្យស្មើគ្នានោះ តើស្បែក ជើងចំនួនប៉ុន្មានទើបស្មើនឹងផ្ទះមួយ។ ដូច្នេះ ចំពោះអ្នកសង់ផ្ទះ និងជាងស្បែកជើងត្រូវផលិតចំនួន ស្បែកជើងឱ្យស្មើនឹងទំហំផ្ទះមួយ ប្រសិនបើពុំដូច្នោះទេ វាគ្មានការផ្លាស់ប្តូរ ឬទំនាក់ទំនងឡើយ ហើយ ស្មើភាពសមាមាត្រ និងមិនអាចឈោងចាប់បានដរាបណាពួកគេស្មើភាពក្នុងផ្លូវណាមួយ។ ហេតុនេះ អ្វី ទាំងអស់ត្រូវតែវាស់វែងដោយអ្វីមួយដែលឯកភាព។

ការផ្លាស់ប្តូរ គឺជាតម្រូវការ ដូច្នេះប្រាក់ជាកត្តាសំខាន់ក្នុងការជួសជុល។ វាជាការពិតណាស់ការ វាស់វែងនេះគឺចាំបាច់ដែលធ្វើឱ្យអ្វីៗទាំងអស់អាចនៅជាមួយគ្នាបាន ប្រសិនបើពុំដូច្នោះទេ វាពុំមែនជាការផ្លាស់ប្តូរ ឬការផ្លាស់ប្តូរដែលពុំដូចគ្នា។ ប្រាក់ ក្លាយជាប្រភេទនៃកិច្ចសន្យាតម្រូវការ។ វាជាការព្រម ព្រៀង ពុំមែនកើតចេញពីធម្មជាតិ ប៉ុន្តែតាមច្បាប់នៃការបង្កើតប្រាក់។

ការកែតម្រូវ និងត្រូវបានធានានៅពេលណារបស់អ្វីៗធ្វើឱ្យមានលក្ខណៈស្មើភាព ហេតុនេះផលិតផលជាងស្បែកជើង គឺសម្រាប់ជាងផ្ទះ ឯផលិតផលជាងផ្ទះក៏សម្រាប់ជាងស្បែកជើងដែរ។ ទោះ ជាយ៉ាងណាក៏ដោយ វានឹងត្រូវបានបង្ហាញតាមរូបភាពសមាមាត្រ ពុំមែនបន្ទាប់ពីការដោះដូរនោះដែលម្នាក់ទទួលបានហួសហេតុ ប៉ុន្តែនៅពេលណាមួយដែលពួកគេនៅតែមាន។ Aគឺជាកសិករម្នាក់ Cជាអាហារ Bជាជាងស្បែកជើង ហើយDគឺជាផលិតផលរបស់គាត់។ ប្រសិនបើការកែតម្រូវប្រភេទនេះ មិនអាចប្រព្រឹត្តទៅរួច ពួកគេពុំអាចមានទំនាក់ទំនងបានឡើយ។

ប្រសិនបើវត្ថុ ឬរបស់មួយពុំអាចធានាបាននៅពេលណាមួយ ប្រាក់អាចជួយធានាឱ្យយើងសម្រាប់ការផ្លាស់ប្តូរនាពេលអនាគត ធានារាល់វត្ថុទាំងអស់ និងអាចជារបស់យើង ប្រសិនបើយើងចង់បានវា វានឹងស្ថិតនៅទីនោះសម្រាប់យើង បើយើងចង់បាន យើងគ្រាន់តែចំណាយប្រាក់តែប៉ុណ្ណោះ។ មានពេលខ្លះ ប្រាក់ក៏មានបញ្ហាកើតឡើងដូចជាទំនិញដែរ តែវាពុំមែនតែងតែកើតរឿងដូចគ្នានោះទេ ប្រាក់នៅតែល្អជាសម្រាប់ធានាស្ថិរភាព។ ហេតុនេះអ្វីៗទាំងអស់ត្រូវតែមានតម្លៃ។ នេះជាវិធីក្នុងការ ផ្លាស់ប្តូរ និងទំនាក់ទំនង។

បន្ទាប់មកប្រាក់នឹងធ្វើឱ្យទំនិញ វត្ថុមានតម្លៃសមាមាត្រតាមការវាស់វែង តម្រឹមឱ្យស្មើហើយគ្មានការទំនាក់ទំនងឯណាដែលគ្មានការដោះដូរឡើយ គ្មានការដោះដូរឯណាដោយគ្មានភាពស្មើគ្នាទេ ហើយក៏គ្មានភាពស្មើគ្នាឯណាដោយគ្មានតម្លៃសមាមាត្រដែរ។ ដូច្នេះទោះជាវត្ថុខុសគ្នាមិនអាចសមាមាត្រគ្នាបានក្នុងតថភាព វានឹងអាចក្លាយជាសមាមាត្រ ឬប្រភាគគ្រប់គ្រាន់ក្នុងទំនាក់ទំនងតម្រូវការរបស់យើង។ នេះជាអ្វីដែលយើងហៅថាប្រាក់។ វាធ្វើឱ្យអ្វីៗទាំងអស់ត្រូវបានវាស់វែង ព្រោះអ្វីទាំង អស់នោះត្រូវបានវាស់ដោយទឹកប្រាក់។

### ២.២.២.៤ យុត្តិធម៌នយោបាយ

មនុស្សជាសត្វធ្វើនយោបាយ។ មនុស្សគ្រប់រូបទាំងអ្នកគ្រប់គ្រង និងអ្នកត្រូវគេគ្រប់គ្រងមានសិទ្ធិក្នុងការចូលរួមនយោបាយ។ យុត្តិធម៌នយោបាយត្រូវបានបង្ហាញក្នុងទំនាក់ទំនងនយោបាយ។ យើងរកឃើញថាអ្វីដែលយុត្តិធម៌នយោបាយ គឺត្រូវឆ្លើយតបនឹងច្បាប់ ហេតុនេះទើបធ្វើឱ្យស្មើភាពគ្នារវាងអ្នកដឹកនាំ និងអ្នកដែលត្រូវគេដឹកនាំ។

ផ្នែកមួយនៃយុត្តិធម៌នយោបាយគឺធម្មជាតិ ឯផ្នែកមួយទៀតគឺច្បាប់(legal)។ អ្វីដែលជាធម្មជាតិគឺជាអ្វីដែលមានសុពលភាពដូចគ្នាគ្រប់ទីកន្លែងទាំងអស់ មានលក្ខណៈឯករាជ្យ មិនចំណុះឱ្យញាណ។ អ្វីដែលស្របច្បាប់គឺអ្វីដែលបង្កើតមកមិនថាធ្វើក្នុងវិធីណាមួយឡើយ គឺពុំមានលក្ខណៈខុសគ្នាទេ ប៉ុន្តែ ខុសគ្នានៅពេលណាដែលមនុស្សត្រូវគ្រប់គ្រងដោយច្បាប់អនុម័តក្នុងករណីផ្សេងៗគ្នា។

អារីស្តូត យល់ថាជាទូទៅអយុត្តិធម៌តែងទទួលផលសក្ការៈជាជាងអំពើយុត្តិធម៌ ហើយដែលមនុស្សចាត់ទុកថាល្អ អ្វីដែលមានគុណសម្បត្តិតិចតួច ចាត់ទុកថាមិនល្អ។ យុត្តិធម៌នយោបាយពីធម្មជាតិពន្យល់ថា ហេតុអ្វីបានជាបុគ្គលម្នាក់ចង់ធ្វើរឿងមិនត្រឹមត្រូវ។ នេះជាហេតុផលដែលយើងចាត់ទុក ថា មិនត្រឹមត្រូវចំពោះមនុស្សដែលកើបយកសម្បត្តិតែខ្លួនឯង ដែលមនុស្សទូទៅតែងគិតថា អ្វីមានគុណ សម្បត្តិច្រើនគឺល្អ ហើយអ្នកនោះក៏ក្លាយទៅជាជនផ្តាច់ការ។ ហេតុនេះក្នុងនាមជាអ្នកដឹកនាំគឺជាអង្គរក្សរបស់យុត្តិធម៌ និងអ្វីដែលស្មើភាព ហេតុនេះមិនគួរកើបប្រមូលយកល្អតែខ្លួនឯងនោះទេ។

ប្រសិនបើមេដឹកនាំម្នាក់ជាមនុស្សយុត្តិធម៌ត្រឹមត្រូវ គាត់ហាក់ដូចជាមិនបានកម្រៃអ្វី ឬធ្វើកម្រៃ ចំពោះខ្លួនឯងសោះ។ គាត់ពុំមែនជាអ្នកធ្វើអ្វីដើម្បីលាភសក្ការៈខ្លួនគាត់ ឬក៏អ្វីដែលយើងហៅថា ជា សេចក្តីសុខសាន្ត ប្រសិនបើវាមិនសមាមាត្រចំពោះខ្លួនគាត់ គាត់ហាក់បីដូចជាទាសករនៃអ្នកបម្រើឱ្យ ផលប្រយោជន៍អ្នកដទៃ ហេតុនេះហើយបានជាយុត្តិធម៌ដូចដែលបានបកស្រាយកន្លងមក គឺជាភាពល្អ សុខសាន្តរបស់អ្នកដទៃ។ ដូច្នេះការចំណាយសម្រាប់ការគ្រប់គ្រងដឹកនាំគួរតែត្រូវបានផ្តល់ជូន នេះហើយដែលយើងហៅថា ជាកិត្តិយស អភ័យឯកសិទ្ធិ។ អ្នកដែលពុំពេញចិត្តនូវសកម្មភាពទាំងអស់ខាង លើនេះ គឺជាមនុស្សម្នាក់ដែលផ្តាច់ការ។

ហេតុនេះតាម អារីស្តូត យុត្តិធម៌ ឬមេដឹកនាំមនុស្សណាដែលប្រកបដោយយុត្តិធម៌ត្រឹមត្រូវ គឺជាអ្នកបម្រើឱ្យផលប្រយោជន៍ សេចក្តីល្អសុខសាន្តរបស់អ្នកដទៃ ពុំមែនអត្មានិយម កើបយកផលសក្ការៈតែបុគ្គលឯង។

### ២.២.៣ សីលវិជ្ជា និងនយោបាយ

និក្ខេបបទរួមនៃទស្សនវិទូក្រិច គឺការប្រកាសថាគោលដៅរបស់រដ្ឋាភិបាលគឺធ្វើឱ្យមនុស្សមានសច្ចធម៌។ ប៉ុន្តែគោលការណ៍សីលធម៌របស់ អារីស្តូត គឺ " មនុស្សធ្វើឡើងសម្រាប់សុភមង្គល "។ គេឈានដល់សុភមង្គលបាន បើសិនជាគេឆ្លងបានដំណាក់កាលសម្ភារៈ ហើយគេត្រូវផ្តល់ឱ្យមនុស្សនូវក្តីរីករាយសេរីភាពសប្បាយរីករាយក្នុងគំនិត។

សុភមង្គលនេះអាចមានលទ្ធភាពរកបាននៅក្នុងជីវភាពសមូហភាពនៃបុរី ជារដ្ឋតូចមួយរួមមានភូមិជាច្រើន។ បុរីនេះរស់ដោយខ្លួនឯង គ្រប់គ្រងដោយខ្លួនឯង។ អារីស្តូត ទទួលស្គាល់ថា មនុស្សជាធម្មជាតិ ជាសត្វស៊ីវិលមួយធ្វើនយោបាយ។ មនុស្សគ្មានអ្វីប្រដូចបានទេ គេជាអ្នកពាក់កណ្តាលនៃអាទិទេព។ អ្នកដែលមិនព្រមទទួលស្គាល់នូវចំណុចល្អនៃជីវភាពក្នុងសង្គមគឺជាសត្វដែលរស់នៅដោយសង្វែក។

ទិសដៅគឺធានាដល់ពលរដ្ឋនូវអ្វីដែលគេត្រូវតែបាន ប៉ុន្តែអ្វីៗដែលអាចសម្រេចបានលុះណាតែពលរដ្ឋទាំងអស់មានប្រាជ្ញា មានសីលធម៌ និងសច្ចធម៌។ តួនាទីរដ្ឋគឺជាការបណ្តុះបណ្តាលពលរដ្ឋឱ្យមានសច្ចធម៌ ណែនាំគេឱ្យធ្វើអ្វីដោយកិត្តិយសឱ្យគេមានក្នុងជីវិតនូវគោលដៅល្អ សុភមង្គល។ ពលរដ្ឋត្រូវមានគុណសម្បត្តិៈ មានសេចក្តីក្លាហាន មានអត្តចរិតល្អ សេរីភាព យុត្តិធម៌ និងមាន សមធម៌។ គោលដៅនយោបាយ គឺសច្ចធម៌សមូហភាព។ នយោបាយបន្តគ្រប់គ្រងដោយសីលធម៌ ហើយឈរនៅលើវិស័យទូទៅនៃសង្គម។ រដ្ឋាភិបាលនៃរដ្ឋជារបស់ដែលល្អបំផុត ព្រោះវាជាកិត្តិយសនៃមនុស្សដែលធ្វើអ្វីៗ ដើម្បីផលប្រយោជន៍ទូទៅ។

### ២.២.៤ សេដ្ឋកិច្ច និងសង្គម

តាមន័យដើមរបស់សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រនៃគេហដ្ឋាន និងការប្រើប្រាស់ក្នុងផ្ទះនៃវត្ថុនានាក្នុងជីវភាពឯកជនដែលលោកអារីស្តូតបានកំណត់នូវទំនាក់ទំនងសំខាន់ៗ៤យ៉ាងគឺៈ

- ទំនាក់ទំនងរវាងប្តី និងប្រពន្ធ
- ទំនាក់ទំនងរវាងឪពុក និងកូន

- ទំនាក់ទំនងរវាងម្ចាស់ទាសករ និងទាសករ

- ទំនាក់ទំនងរវាងម្ចាស់ផ្ទះ និងមនុស្សផ្សេងៗ

អារីស្តូតបានមើលឃើញក្នុងអំណាចឪពុកជាអាជ្ញានៃព្រះរាជា។ ប៉ុន្តែបុរីជាវត្ថុផ្សេងពីគ្រួសារធំមួយ។ អាជ្ញានៃម្ចាស់លើទាសករ ជាបទបញ្ជាដែលប្រើទៅលើឧបរណ៍។

### ២.២.៥ លក្ខណៈនៃអំណាចរដ្ឋ

តាមគំនិតរបស់លោកអំណាចទាក់ទងទៅនឹងការរៀបចំ និងដឹកនាំបុរី។ ការរៀបចំត្រូវឋិតនៅលើគ្រួសារ និងការងារ។ គ្រួសារ គឺជាផែនគ្រឹះនៃបុរី។ គ្រួសារត្រូវឋិតនៅក្រោមអំណាចរបស់ឪពុក។ ទាក់ទងទៅនឹងគ្រួសារ លោកមិនអនុញ្ញាតឱ្យរៀបការប្ដីប្រពន្ធដោយចាប់ឆ្នោតនោះឡើយ។

យោងតាមគំនិតអារីស្តូតថា រដ្ឋត្រូវធ្វើអន្តរាគមន៍ទៅក្នុងជីវភាពនៃបុគ្គល ក្នុងទស្សនៈនេះលោក កំណត់ថា៖ អាយុរៀបអាពាហ៍ពិពាហ៍១៨ឆ្នាំសម្រាប់នារី ៣៧ឆ្នាំ សម្រាប់មនុស្សប្រុស។ អាយុអតិបរមាសម្រាប់មានកូន ៥០ឆ្នាំ សម្រាប់មនុស្សស្រី ៥៥ឆ្នាំ សម្រាប់មនុស្សប្រុស។

លោកអារីស្តូតបានគិតថាត្រូវឱ្យស្ត្រីមានផ្ទៃពោះចាប់ពីសិសិររដូវ ដើម្បីឱ្យកូនកើតនៅក្នុងរដូវស្លឹកឈើជ្រុះ ចៀសវាងភាពត្រជាក់ខ្លាំង និងកំដៅខ្លាំង។ បន្ថែមពីលើនេះលោកបានឱ្យរដ្ឋកំណត់ចំនួនកុមារដែលមានកំណើត។ លោកអារីស្តូតបានបង្ហាញនូវការគិតគូរពីប្រជារាស្ត្រ ដោយរដ្ឋត្រូវធានាបន្ទុក អប់រំសិក្សា ហ្វឹកហ្វឺន កាយសម្បទា និងបញ្ញា និងភ្លេង។

លោកបានដកអំណាចពីបុគ្គលម្នាក់ៗ ហើយបានប្រគល់អំណាចនោះឱ្យទៅច្បាប់វិញ ពិព្រោះបើធ្វើបានដូច្នេះអំណាចមានលក្ខណៈទៅទៅ ល្អប្រសើរ និងមានកម្រិតខ្ពស់ជាងអំណាចនៅលើបុគ្គល។ ការដឹកនាំបុរី ត្រូវស្ថិតនៅលើរដ្ឋាភិបាលដែលមានរូបភាពបីជាសំខាន់គឺ៖ រាជាធិបតេយ្យ អភិជនាធិបតេយ្យ និងសាធារណរដ្ឋ។ លោកមិនបានផ្ដោតការនិយមចូលចិត្តទៅលើរូបភាពរដ្ឋាភិបាលណាមួយទេ។ ប៉ុន្តែក្នុងមនោគតិរបស់លោក គឺរបបចម្រុះដែលជាការលាយបញ្ចូលគ្នារវាងអភិជនាធិបតេយ្យ និងសាធារណរដ្ឋដែលក្នុងនោះអំណាចនីតិបញ្ញត្តិត្រូវទុកឱ្យប្រជាពលរដ្ឋ(បរិមាណច្រើន) ហើយអំណាច នីតិប្រតិបត្តិទុកឱ្យអ្នកដែលមានបរិមាណតិច។ ដូច្នេះ លោកអារីស្តូតជាអ្នកផ្ដើមគំនិតក្នុងការបែងចែក អំណាច។

អំណាចទាំងអស់មិនមានជីវិតអមតៈទេ អំណាចទាំងនោះអាចរលំរលាយទៅបានដោយមូលហេតុជាច្រើន៖

- ហេតុផលចម្បង គឺអំពើផ្ដាច់ការ ខ្វះសមភាពនៅក្នុងសង្គម ឬខ្វះយុត្តិធម៌ក្នុងសង្គម។ សមភាព មិនអាចធ្វើបានមួយរយភាគរយទេ ប៉ុន្តែយើងក៏មិនត្រូវពង្រីកឱ្យមានវិសមភាពមួយធំពេកដែរ។

- ហេតុផលបន្ទាប់បន្សំ គឺការបែងចែកវណ្ណៈក្នុងសង្គមដោយវណ្ណៈនីមួយៗឃ្លាតឆ្ងាយពីគ្នា ឬខុស គ្នាខ្លាំងពេកធ្វើឱ្យមានទំនាស់ក្នុងសង្គម ហើយចុងក្រោយធ្វើឱ្យអំណាចនោះដួលរលំ។ ត្រូវធ្វើឱ្យមានវណ្ណៈមជ្ឈមភាគច្រើន ទើបអាចផ្សារភ្ជាប់គ្នាបានរវាងវណ្ណៈលើ និងវណ្ណៈក្រោម ទើបសង្គមអាចបន្តស្ថិតស្ថេរទៅបាន។ មួយទៀតគឺមូលហេតុផ្ទាល់ខ្លួននៃអ្នកកាន់អំណាច ដោយធ្វើការបំពានលើអំណាចរបស់អ្នកដទៃ ឬជាន់ឈ្លីកិត្តិយសអ្នកដទៃ។ ចុងក្រោយគឺការភ័យខ្លាចបាត់បង់អំណាចគឺមេដឹកនាំមិនល្អ តែងតែនាំឱ្យមានអ្នកប្រឆាំងច្រើន អំណាចត្រូវដួលរលំ។

### ២.២.៦ ចំណាត់ថ្នាក់រដ្ឋាភិបាល

លោក ប្លាតុង បានបង្កើតគំរូបុរីមួយដែលមានរដ្ឋាភិបាលគំនិតនិយមមួយ តែអារីស្តូតបានកំណត់ ជាបឋមថាមានប្រព័ន្ធនយោបាយល្អផ្សេងៗគ្នា។ ក្នុងន័យនេះលោកចាត់ទុកថារដ្ឋាភិបាលល្អមានភាពមិនដូចគ្នាទេសម្រាប់គ្រប់ពេលវេលានោះក៏ដូចសម្រាប់គ្រប់ប្រទេសទាំងអស់ដែរ។

យោងតាមគំនិតអារីស្តូតគេអាចកំណត់បានថា អំណាចត្រូវប្រគល់ទៅឱ្យមនុស្សម្នាក់ ទៅឱ្យក្រុម តូចមួយ ឬ ទៅឱ្យហ្វូងមនុស្សជាច្រើន។ គេមានរូបភាពផ្សេងៗនៃរដ្ឋាភិបាល។ រូបភាពរដ្ឋាភិបាលទាំង នោះសុទ្ធតែមានតម្លៃ ឬ បរិសុទ្ធនៅពេលដែលរដ្ឋាភិបាលនោះធ្វើការបម្រើផលប្រយោជន៍ទូទៅ។ បើរដ្ឋាភិបាលនោះមិនបម្រើផលប្រយោជន៍ទូទៅទេនោះ ជារដ្ឋាភិបាលពុករលួយនៅពេលផលប្រយោជន៍ដោយឡែកគ្របដណ្តប់លើរដ្ឋាភិបាល។

គេអាចសង្ខេបរូបភាពរដ្ឋាភិបាលដែលបានកំណត់ដោយអារីស្តូតជាពីរប្រភេទដូចតទៅៈ

**ក្រុមរដ្ឋាភិបាលល្អបរិសុទ្ធៈ**

- រដ្ឋាភិបាលនៃមនុស្សម្នាក់ បម្រើផលប្រយោជន៍មនុស្សទាំងអស់ក្នុងបុរី (រាជាធិបតេយ្យ)
- រដ្ឋាភិបាលនៃមនុស្សមួយចំនួនតូច ដើម្បីបម្រើឱ្យផលប្រយោជន៍បុរី (អភិជនាធិបតេយ្យ)
- រដ្ឋាភិបាលនៃមនុស្សមួយចំនួនធំ ដើម្បីបម្រើឱ្យផលប្រយោជន៍បុរី (សាធារណរដ្ឋ)

**ក្រុមរដ្ឋាភិបាលមិនបរិសុទ្ធៈ**

- រដ្ឋាភិបាលនៃមនុស្សម្នាក់ ដែលគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន (រដ្ឋាភិបាលផ្តាច់ការ)
- រដ្ឋាភិបាលនៃមនុស្សមួយចំនួនតូច ដែលគិតពីផលប្រយោជន៍ក្រុមខ្លួន អប្បជនាធិបតេយ្យ)
- រដ្ឋាភិបាលនៃមនុស្សភាគច្រើន ប្រឆាំងនឹងអ្នកមាន (ប្រជាធិបតេយ្យ) [ក្នុងន័យប្រជាភិថុត]

# មេរៀនទី៣ នីកូឡូ ម៉ាគីអាវែល្លី

( Niccolò Machiavelli 469-1527 )

## ៣.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ

លោក ម៉ាគីអាវែល្លី គឺជាជនជាតិ អ៊ីតាលីម្នាក់ ដែលអ្នកសិក្សាស្គាល់ជាទូទៅថាជាអ្នកបង្កើតឡើងនូវវិទ្យាសាស្ត្រនយោបាយ។ លោក ម៉ាគីអាវែល្លី បានកើត និងស្លាប់នៅទីក្រុង ហ្លូរេនី (Florenee) ប្រទេសអ៊ីតាលី។ កាលណាគេប្រៀបប្រដូចមនុស្សទៅនឹង ម៉ាគីអាវែល្លី គឺគេសំដៅទៅមនុស្សម្នាក់ដែលជាអ្នកនយោបាយអនុវត្តនូវទ្រឹស្តីម៉ាគីអាវែល្លីនិយម(Machiavallisme)។ ម៉ាគីអាវែល្លីនិយមគឺជានាមស័ព្ទនៅក្នុងវចនានុក្រមភាសាបារាំងសំដៅដល់ប្រព័ន្ធនយោបាយដែលអនុវត្តតាមទ្រឹស្តីរបស់លោក ម៉ាគីអាវែល្លី ឬនយោបាយដែលទាត់ចោលសីលធម៌ឬជានយោបាយដែលប្រកាន់នូវអាកប្បកិរិយាមួយដែលបត់បែនដោយមិននឹករអែងអ្វីទាល់តែសោះ។ ក្នុងវាក្យស័ព្ទភាសាបារាំង កាលណាគេប្រើជាគុណនាម ម៉ាក្យាវ៉ែលលី(Marchiavellique)គឺសំដៅលក្ខណៈដែលផ្ទុយពីសីលធម៌។

លោក ម៉ាគីអាវែល្លី ធ្លាប់បានធ្វើជាលេខាទូត និងបានបំពេញបេសកម្មនៅបរទេសជាញឹកញាប់។ ដោយប្រទេសអ៊ីតាលីសម័យនោះមានការផ្លាស់ប្តូរអ្នកកាន់អំណាចធ្វើឱ្យម៉ាគីអាវែល្លីបានបាត់បង់អាជីពយ៉ាងឈឺចាប់។ ដើម្បីជាកាសុំខមាលទោសដល់ Laurent Médicis ដែលជាប្រមុខដឹកនាំប្រទេស លោកម៉ាគីអាវែល្លីបានសរសេរស្នាដៃមួយឈ្មោះថា "Le Prince" ថ្វាយដល់ព្រះអង្គ ដោយសង្ឃឹមថា នឹងបានទទួលនូវកិត្តិយសដ៏សមស្របមួយមកវិញ ប៉ុន្តែជាអកុសលស្ថានភាពជីវិតរបស់លោកម៉ាគីអាវែល្លី ពុំមានការប្រែប្រួលដោយស្នាដៃនេះឡើយ។

## ៣.២ ទស្សនៈនយោបាយ

លោក នីកូឡូ ម៉ាគីអាវែល្លី មិនមែនជាអ្នកនិពន្ធដែលមានឈ្មោះល្បីខាងពាក្យពេចន៍ក្បោះក្បាយ បិតបាំងអ្វីដែលជាការពិតនោះទេ ដូចអ្នកអាននឹងឃើញការអធិប្បាយ និងការបញ្ចេញគំនិតក្នុងផ្នែកតៗគ្នាខាងក្រោមនេះស្រាប់។ គាត់ មានទេពកោសល្យពិសេសខាងពិនិត្យពិចារណានូវអាកប្បកិរិយារបស់មនុស្សក្នុងបញ្ចេញប្រតិកម្មចំពោះហេតុផលឬសភាពការណ៍ផ្សេងៗ យ៉ាងពោពេញទៅដោយភាពប្រា កដនិយមមិនត្រឹមតែមនុស្សជំនាន់គាត់ប៉ុណ្ណោះទេគឺសម្រាប់បើមនុស្សគ្រប់ជំនាន់តៗមកក្រោយទៀត។ គំនិតរបស់លោក នីកូឡូ មិនមានលក្ខណៈជាទ្រឹស្តីនយោបាយអ្វីខ្លាំងខ្លាទេ តែជាការសង្កេតផ្ទត់គំនិត និងចរិយានៃមនុស្សជាតិក្នុងក្របខណ្ឌនយោបាយយ៉ាងល្អិតល្អន់ប៉ុណ្ណោះ។ តាមពិតទៅដើម្បីបង្ហាញ ភាពចរិកាលនៃឧវាទរបស់លោក យើងអាចនិយាយជាទូទៅបានថាអ្វីដែលលោកបានសរសេរគឺពិតជាមានន័យប្រហាក់ប្រហែលនឹងអ្វីដែលបានសង្កេតឃើញ ឬយល់ស្រប គ្រាន់តែយើងមិនបានសរសេរទុកជាឯកសារប៉ុណ្ណោះ។ លោកបានឱ្យនិយមន័យពាក្យ "សម្តេច" គឺជាឋានន្តរសក្តិរបស់អ្នកដឹកនាំនៅជំនាន់នោះដែលជាជំនាន់មួយក្នុងប្រវត្តិសាស្ត្រ ដែលគេស្គាល់ថាជាជំនាន់សក្តិភូមិ។ ម្លោះហើយតែកាលណាអ្នកធម្មតាណាបានទទួល ឬ ដណ្តើមបានកិត្តិយសធ្វើជាអ្នកដឹកនាំ ឬជាមេត្រូត្រា អ្នកនោះនឹងមានងារជា "សម្តេច" ឬ "ស្តេច" ឬជា "ព្រះមហាក្សត្រ" ជាស្វ័យប្រវត្តិ។ បើអ្នកត្រូត្រាជាអ្នកកាន់សាសនា ឬ អាចារ្យអ្នកដឹកនាំនោះនិងមានងារជា "ព្រះសង្ឃរាជ"។ លោកឱ្យតម្លៃទៅលើភាពពីរសណ្ឋាន ដែលគេយល់ថាជាភាពដែលគ្មានសិលធម៌ទាល់តែសោះ ពីការឱ្យតម្លៃទៅលើកម្លាំងអាវុធ ឬកងទ័ព និងការឱ្យតម្លៃលើឧបាយកលបោកបញ្ឆោត។

មធ្យោបាយរបស់លោកដែលគេទុកជានយោបាយ "ឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ" ជាមធ្យោបាយដែលអ្នកដឹកនាំប្រទេសនាសតវត្សយើងនេះយកមកអនុវត្តជាញយៗ។ ម្លោះហើយកាលណាអ្នកនយោបាយប្រើវិធីនយោបាយខិតលើរបៀបប្រើឧបាយកលថោកទាប ឬជានយោបាយបោកបញ្ឆោត គេតែងហៅអ្នកនយោបាយនោះ

ថាជាមនុស្សគ្មានសីលធម៌ទាល់តែសោះ គឺគេទុកបណ្ដាជនជាហ្វូងសត្វមួយ ឬជាម៉ាស៊ីនមួយដែលសម្រាប់មេដឹកនាំបញ្ជាបទបែនតាមអំពើចិត្ត ដើម្បីទៅរកទិសដៅអ្វីមួយដែលមេដឹកនាំបានដៅទុកជាស្រេច។

បើពិនិត្យឱ្យជិតដល់ពីគំនិត ពីការសសេររបស់លោក គេពិនិត្យឃើញថាគំនិតរបស់លោកពិតប្រាកដនិយម ជាគំនិតដែលជាកញ្ចក់ឆ្លុះឱ្យឃើញនូវសន្តានចិត្តឥរិយាបថ ផ្នត់គំនិត នៃបណ្ដាមនុស្សជំនាន់លោក។ ម៉ាគីអាវែល្លី ទុកបណ្ដាមនុស្សដូចជាឧបករណ៍ ជាយន្តដែលមានប្រតិកម្មរបៀបម្យ៉ាងៗ តាមរបៀបដែលគេអាចចុចគន្លិះ ហើយទុកអ្នកដឹកនាំជាអ្នកប្រើឧបករណ៍នោះ។ បើអ្នកដឹកនាំចេះប្រើបញ្ជាយន្តបានត្រឹមត្រូវដើម្បីតម្រង់កម្លាំងសំដៅទិសណាមួយជាគោលដៅ អ្នកដឹកនាំនោះនឹងបានជោគ ជ័យជានិច្ច។ ផ្ទុយទៅវិញ បើអ្នកដឹកនាំប្រើឧបករណ៍មិនត្រឹមត្រូវដោយធ្វេសប្រហេស ឬដោយមើលងាយ អ្នកដឹកខ្វះក្ដីស្រលាញ់ អ្នកដឹកនាំនោះនឹងទទួលក្ដីវិនាសជាចុងក្រោយជាមិនខាន។ ក្នុងគំនិតរបស់លោកគ្មានគំនិតអ្វីទេដែលហៅថាសិទ្ធិមនុស្ស ឬ សេរីភាពបុគ្គល។ សៀវភៅរបស់លោកមិនមែនបានកំណត់មេរៀនប្រជាធិបតេយ្យទេ តែជាក្បួនសម្រាប់ឱ្យអ្នកនយោបាយ និងអ្នកដឹកនាំអាចដណ្ដើម និងពង្រីករក្សាអំណាចឱ្យបានឋិតថេរ។ ដូចច្នេះ សៀវភៅនេះត្រូវផ្ដល់នូវមេរៀនសំខាន់ៗខាងគំនិតប្រជាធិបតេយ្យដល់សិស្សសាលានយោបាយ និងឧបាយកលផ្សេងៗដែលអាចដឹកនាំសម្ដេចម្នាក់ៗទៅរកការកសាងអំណាចផ្ដាច់ការគ្រប់សព្វ គឺស្រេចតែនិងយើងទេដែលអាចយកគំនិត និងបង្កើតសភាពការណ៍ ដើម្បីតម្រង់កម្លាំងដែល ម៉ាគីអាវែល្លី ឱ្យតម្រង់ទៅរកទិសស្របនឹងឆន្ទៈរបស់ប្រជាជន ដែលមែនទែនទៅត្រូវជាម្ចាស់ស្រុកជាអ្នករៀបចំ ជាអ្នកធ្វើច្បាប់ គ្រប់គ្រងប្រទេសជាតិពិតៗនោះទៅវិញទេ។ យ៉ាងណាមិញសៀវភៅពីឧវាទនយោបាយរបស់លោក ចំពោះនិស្សិតសាលានយោបាយក៏ប្រៀបបានទៅនឹងសៀវភៅស្ដីពីឥទ្ធិពលរបស់មេរោគចំពោះនិស្សិតសាលាពេទ្យដែលក្នុងន័យថានិស្សិតម្នាក់ៗអាចធ្វើខ្លួនឱ្យទៅជាអ្នកដឹកនាំដ៏ចំណាន អ្នកនយោបាយដ៏ឧត្ដម ឬ គ្រូពេទ្យដ៏សក្ដិសិទ្ធិ ក៏ដោយសិក្សាហើយយល់ឱ្យបានច្បាស់នូវឥរិយាបទ នូវពួកឈ្លានពានអំណាច រំលោភសិទ្ធិមនុស្ស ឬយល់ឱ្យបានច្បាស់នូវឥទ្ធិពលមេរោគនានា។

ចំនុចសំខាន់មួយទៀត គឺផ្នត់គំនិតឥរិយាបថរបស់បណ្ដាជនជំនាន់ ម៉ាគីអាវែល្លី និង ផ្នត់គំនិតឥរិយាបថរបស់បណ្ដាជននាសម័យយើងនេះមិនមានលក្ខណៈខុសគ្នាទេ។ អ្វីដែលលោក បាននិយាយពីផ្នត់គំនិតឥរិយាបថរបស់មហាជនម៉ាគីអាវែល្លី(ក្នុងសតវត្សទី១៥) ក៏នៅត្រូវក្នុងសតវត្សទី២១យើងដែរ។ យើងសន្និដ្ឋានបានថាក្នុង៥ ឬ ១០ សតវត្ស តទៅមុខទៀត បើសិនជាមនុស្សជាតិនៅមានវត្តមានលើផែនដីនេះដដែល គេគ្មានអ្វីជំរុញឱ្យជឿថាមនុស្សនឹងផ្លាស់ប្ដូរផ្នត់គំនិត ឬប្ដូរផ្នត់គំនិតឱ្យខុសពីមុន ឡើយ។ រដ្ឋទាំងឡាយ និងក្រោមទឹតំបន់ក្រោមអាណានិគមរបស់គេដែលកំពុងត្រួតត្រាឬបានត្រួតត្រាមនុស្សម្នាក់មកជាយូរហើយ អាចមានលក្ខណៈជាសាធារណរដ្ឋ។

ក្នុងសម័យកាលរបស់ ម៉ាគីអាវែល្លី ប្រទេសអ៊ីតាលី មានការគ្រប់គ្រងប្រទេសជាក្រុង(Villes)និងជារដ្ឋ(Etats)ជាច្រើនដែលស្របពេលជាមួយគ្នានោះប្រទេសជិតខាងគឺបារាំង អេស្បាញ អង់គ្លេស ជាដើមពុំមានលក្ខណៈបែបនេះឡើយ។

ម៉ាគីអាវែល្លី យល់ថា ប្រទេសអ៊ីតាលីត្រូវមានមនុស្សម្នាក់ដែលមានសមត្ថកិច្ចពិតប្រាកដអាចបង្រួបបង្រួមជាតិបានដែលមនុស្សនោះត្រូវបានតំណាងដោយ Le Prince នោះឯង។ ដូច្នេះបំណងសំខាន់របស់ម៉ាគីអាវែល្លី ពុំមែនចង់ក្លាយទៅជាបិតាទ្រឹស្ដីគំនិតនយោបាយនោះទេ គឺលោកចង់ឱ្យប្រទេសអ៊ីតាលីមានលក្ខណៈ៣សំខាន់គឺៈ

- មានការឯកភាពជាតិ មិនបែកបាក់គ្នា
- មានកងទ័ពមួយខ្លាំងពូកែ
- មិនយកសាសនាមកលាយឡំនឹងនយោបាយ

ម៉ាគីអាវែល្លី គិតថា ប្រទេសមួយដើម្បីធ្វើនយោបាយបានល្អ ត្រូវមានការឯកភាពគ្នា និងមានកងទ័ពមួយខ្លាំងពូកែ ហើយការធ្វើសង្គ្រាម គឺជាសិល្បៈមួយនៃការបង្កើត និងថែរក្សារដ្ឋ ហើយនយោបាយត្រូវតែស្អិតជាប់គ្នា

ជាមួយសង្គ្រាម។ ជាមួយគ្នានេះដែរ គាត់ក៏បានយល់ថា ការឯកភាពនៃរដ្ឋមួយមិនមែនអាស្រ័យលើការគ្រប់គ្រង ដែលលាយឡំគ្នារវាងប៉ាប (អ្នកដឹកនាំសាសនាគ្រិស្ត) និងអ្នកនយោបាយនោះទេ ព្រោះបុព្វជិត និងគ្រហស្ថមាន បុព្វហេតុ និងផលប្រយោជន៍ដែលត្រូវការពារដោយឡែកៗពីគ្នា។ ដោយសារគោលគំនិតសំខាន់ ៣ យ៉ាងខាងលើ ធ្វើអោយលោក ម៉ាគីអាវែល្លី ណែនាំឱ្យប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់តាមដែលអាចធ្វើទៅបានដើម្បីសម្រេច គោលដៅខាងលើ ហើយពន្យល់ថាមធ្យោបាយទាំងអស់សុទ្ធតែល្អ។ ជំហររបស់លោក ម៉ាគីអាវែល្លី គឺ

ទី១ អង្កែល ឬកំទេចចោល

ទី២ សុខចិត្តសម្លាប់ប្រសើរជាងសំឡុតគំរាមគំហែង និងព្រមានសត្រូវ។ សម្លាប់ គឺដកខ្លួនចេញផុតពីសត្រូវ យ៉ាងពិតប្រាកដ។

ទី៣ សុខចិត្តកាចសាហាវឃោរឃៅប្រសើរជាងធ្វើចិត្តជាអ្នកល្អ កាចសាហាវនាំឱ្យមនុស្សពាលឈឺចាប់តិច តែបើសណ្តោសប្រណីនាំសង្គមឥតមានសណ្តាប់ធ្នាប់(អំពើឆក់ប្លន់សម្លាប់)នាំឱ្យប្រជាជនស្លូតត្រង់រងទុក្ខវេទនា។

### ៣.២.១ សញ្ញាណនៃពាក្យ "រដ្ឋ" របស់លោក ម៉ាគីអាវែល្លី

កម្មវត្ថុនៃការសិក្សាសំខាន់របស់ ម៉ាគីអាវែល្លី គឺរដ្ឋ។ គាត់បានពន្យល់ថាក្នុងចំណោមរដ្ឋមានសាធារណរដ្ឋ និងទម្រង់បែបរាជានិយម។ រាជានិយមស្ថិតក្រោមអាណាព្យាបាលបន្តពូជ បានន័យថា អ្នកដឹកនាំចេញពីគ្រួសារតែ មួយរាប់ច្រើនឆ្នាំ ឬក៏ទើបនឹងតែងតាំងឡើងថ្មីទៀត ឬទើបវាយដណ្តើមបាន ដើម្បីកាន់កាប់បន្តពូជថ្មីទៀត។

តាមទស្សនៈរបស់លោក ម៉ាគីអាវែល្លី ទម្រង់រដ្ឋដែលល្អជាងគេ គឺ "សាធារណរដ្ឋចំរុះ" ដែលបានមកពីការ បង្រួបបង្រួម បញ្ចូលគ្នារវាងធាតុរាជានិយម អភិជនាធិបតេយ្យ និងប្រជាធិបតេយ្យ

### ៣.២.២ ឧត្តមគតិរបស់អ្នកគ្រប់គ្រងរដ្ឋ

ព្រះអង្គម្ចាស់ (Le Prince) ជាតួអង្គសំខាន់នៅក្នុងស្នាដៃនិពន្ធរបស់លោក ម៉ាគីអាវែល្លី ដែលមានចំណង ជើងថា "Le Prince" ដែរ។ ក្នុងនាមជាអ្នកគ្រប់គ្រងរដ្ឋម្នាក់ ដែលត្រូវស្រោចស្រង់ប្រទេសឱ្យរួមពីឱនភាព និង ហាយនភាព ព្រះអង្គម្ចាស់ ត្រូវមានឧត្តមគតិដូចតទៅៈ

**៣.២.២.១ ប្រាកដនិយម** (Le réalisme) ៖ ត្រូវចាត់ទុកថា មនុស្សម្នាក់ៗ ពុំមានសារៈសំខាន់ប៉ុន្មាន ទេ ហើយមនុស្សរួមគ្នាវិតតែគ្មានសារសំខាន់ទៅទៀត។ មានតែមនុស្សសរុបទេដែលសំខាន់ មិនត្រូវបារម្ភពីអ្វីដែល ជាមនោគមនោះទេ គឺត្រូវបារម្ភតែពីអ្វីដែលជាការពិតដែលមានពិតប្រាកដ។ ដូច្នេះ មិនត្រូវគិតអ្វីដែលជាទ្រឹស្តីពេក នោះទេ តែត្រូវគិតថាការអនុវត្តជាក់ស្តែង និងអ្វីដែលមានចំពោះមុខទើបមានសារៈសំខាន់។ ត្រូវស៊ើបឱ្យដឹងសព្វ គ្រប់ទាំងអស់ តែមិនត្រូវឆាប់ជឿអ្វីដែលគេនិយាយប្រាប់ពេកទេ ហើយក៏មិនត្រូវខ្លាចដោយងាយៗនោះដែរ។

**៣.២.២.២ អត្តទត្តភាព**(L'égoisme)៖ ត្រូវហាត់ចិត្ត មិនធ្វើចិត្តល្អក្នុងចំណោមមនុស្សអាក្រក់។ ត្រូវ ហាមមិនឱ្យមានការគោរព ការបណ្តុះអាត្មា ការពង្រឹងឆន្ទៈ ឱ្យមានវិន័យក្នុងគំនិត ក្នុងមនោសញ្ចេតនា និងហាត់រាង កាយឱ្យបានមាំមួនខ្លាំងក្លា។

**៣.២.២.៣ ការត្រិះរិះ**(Le calcul)៖ ត្រូវធ្វើឱ្យគេខ្លាចជាជាងធ្វើអោយគេស្រឡាញ់។ ការពិតអ្នកដឹកនាំ ចង់បានទាំងពីរ ប៉ុន្តែតាមធម្មតាមិនអាចធ្វើឱ្យគេខ្លាចផង និងធ្វើឱ្យគេស្រឡាញ់ផងជាមួយគ្នាបានទេ។ ដូច្នេះ ព្រះ អង្គម្ចាស់ ត្រូវជ្រើសរើសតែមួយ គឺធ្វើឱ្យគេខ្លាច ពីព្រោះការធ្វើឱ្យគេស្រឡាញ់វាសម្រេចលើ អ្នកដ៏ទៃ ឯការធ្វើអោយគេខ្លាចវាសម្រេចលើខ្លួនឯង។

**៣.២.២.៤ ការមិនអើពើចំពោះអំពើល្អ និងអំពើអាក្រក់**(L'indifférence au bien ou au mal)៖ ព្រះអង្គម្ចាស់ ចង់ធ្វើអំពើល្អណាស់ តែអាចធ្វើអំពើអាក្រក់វិញដោយបង្ខំចិត្តបើចាំបាច់។ការណ៍នេះបណ្តាល មកពី បទពិសោធន៍របស់ព្រះអង្គម្ចាស់ធ្លាប់បានស្គាល់មនុស្សជាច្រើនដែលក្បត់ពាក្យសម្បថបានទទួលជោគជ័យក្នុងជីវិត និងមានជ័យជម្នះលើមនុស្សដែលគោរពភាពសច្ចៈ និងសម្បថរបស់ខ្លួន។

**៣.២.២.៥ការប៉ិនប្រសប់**( L'habilete ) ៖ ត្រូវមានការច្នៃប្រឌិត និងមានការប្រឹងប្រែងជាប់ជានិច្ច ដើម្បីឆ្ពោះទៅគោលដៅរបស់ខ្លួន ដូច្នេះអ្នកដឹកនាំត្រូវប៉ិនសន្សំថាមពល ភាពអង់អាចនិងកម្លាំងជំរុញជានិច្ច។

**៣.២.២.៥ ភាពសម្បើម**( La grandeur ) ៖ ត្រូវស្ថិតនៅខ្ពស់ពីលើអ្វីដែលសាមញ្ញជានិច្ច។ ព្រះអង្គម្ចាស់ត្រូវស្ថិតនៅឆ្ងាយពីអំពើល្អ និងអំពើអាក្រក់។ ឱ្យតែទទួលបានលទ្ធផល ពុំមានមធ្យោបាយណាមួយដែលមិនត្រូវបានចាត់ទុកថាល្អប្រសើរជាងមធ្យោបាយណានោះទេ។ ត្រូវសំអាងទៅលើតែហេតុផលរដ្ឋ ( Raision d'Etat ) តែមួយគត់ បានន័យថាប្រយោជន៍រដ្ឋជាធំ។

**៣.២.២.៦ ការក្លែង ការធ្វើពុត និងការលាក់បំបាំង លាក់គំនិត**( La dissimulation )៖ អ្នកដឹកនាំ ជាអ្នកស្គាល់ឱកាស មិនត្រូវរាថយចំពោះមុខ វិសមធម៌ ល្បិចកល ការលាក់បំបាំង អំពើក្បត់ និងអំពើហឹង្សា។

**៣.២.៣ ច្បាប់**

ចំពោះបញ្ហាច្បាប់ លោកចាត់ទុកថា ច្បាប់ជាឧបករណ៍អំណាច។ ច្បាប់ស្តែងឡើងក្នុងរូបភាពជាកម្លាំង។ គ្រប់រដ្ឋទាំងអស់ អំណាចកំពូលបានមកពីច្បាប់ល្អៗ និងមានទាហានល្អៗ ប៉ុន្តែច្បាប់ដែលល្អពុំមែនមានអត្ថិភាពនៅទីណាដែលអវត្តមានទាហានល្អៗនោះទេ។ ផ្ទុយទៅវិញ ទីណាដែលមានទាហានល្អៗទីនោះក៏មានច្បាប់ល្អៗដែរ។ ដូច្នេះ ជាតុចម្បងរបស់រដ្ឋ គឺអង្គការយោធា វិជ្ជាយោធា និងយោធា។ គាត់យល់ថា គេត្រូវពិចារណាពីនយោបាយដោយពុំគិតពីទិដ្ឋភាពទេវវិទ្យា និង អស្តិរូបវិជ្ជាទេ។ មនុស្សត្រូវតែទទួលបន្ទុកកិច្ចការ និងធ្វើនយោបាយដោយខ្លួនឯង ជាជាងបន់ស្រន់អាទិទេព ប្រសិនបើខ្លួនមានបំណងរាតត្បាតយករដ្ឋមួយ និងរក្សារដ្ឋនោះទុកឱ្យបានល្អ។

**៣.២.៤ របៀបទទួលបានងារជាស្តេច**

**៣.២.៤.១ ការដណ្តើមងាបានដោយកម្លាំងអាវុធរបស់ខ្លួនឯង**

បណ្តាមនុស្សសឹងតែទាំងអស់ រមែងតែដើរតាមមាគាដែលគេដើរមុនខ្លួនត្រួសត្រាយគឺយកតម្រាប់អ្នកដែលបានធ្វើមុន។ដោយមកមិនអាចយកតម្រាប់តាមគេបានទាំងអស់សុទ្ធសាធឬធ្វើតាមដល់កម្រិតកំពូលដូចអ្នកមុនបាន អ្នកដែលមានភាពប្រុងប្រយ័ត្នត្រូវខំដើរតាមមាគ៌ាមហាបុរស និងធ្វើតាមអ្នកដែលមានលក្ខណៈកំពូលក្នុងគោលគំនិតថាបើមិនអាចដល់កម្រិតដ៏អស្ចារ្យដូចមហាបុរសទាំងនោះទេយ៉ាងណាក៏អាចទទួលចំហាយខ្លះដែរ។ អ្នកដែលមិនសូវមានធនធាន អាចត្រួតត្រាទឹកដីចំណុះបានខ្ជាប់ខ្ជួនជាងគេ។ មនុស្សដែលក្លាយជាស្តេចដោយសមត្ថភាពរបស់ខ្លួន មិនមែនដោយធនធាន តែងតែមាន ភាពសមសួនហើយទទួលការស្ញប់ស្ញែង។ ដើម្បីសម្រេចការងារថ្មីៗ ត្រូវមានគំនិតរៀបចំគំរោង ចេះផ្លាស់ប្តូរ រួចហើយអនុវត្តគំរោងដោយប្រើ វិធីសាស្ត្រគ្រប់បែបយ៉ាងដើម្បីទទួលបានជោគជ័យ។

**៣.២.៤.២ ការដណ្តើមងាបានដោយកម្លាំងអ្នកផ្សេង ឬ បានដោយសារធនធាន**

ពលរដ្ឋធម្មតាដែលឡើងជាស្តេចដោយសារធនធាន មានឧបសគ្គតិចតួចក្នុងការឡើងបុណ្យតែមានឧសគ្គច្រើនណាស់ក្នុងការរក្សាទុកបុណ្យនោះ។ អ្នកដែលបានឡើងជាព្រះមហាក្សត្រដោយសារគេជួយ អ្នកនោះនិងត្រូវរណបគេជារៀងរហូត។ ត្រូវមានភាពក្លាហានក្នុងការការពារអំណាចក្ររបស់ខ្លួន ដោយមានឥរិយាបថតឹងរឹង ការគោរព បូជាស្មោះត្រង់ទើបរក្សាការពារបានពីខ្មាំងផ្ចាញ់ខ្លួន។

**៣.២.៤.៣ ការដណ្តើមងារបានដោយមធ្យោបាយយង់ឃ្នង**

មានផ្លូវពីរទៀតដែលនាំទៅកាន់ងារជាស្តេចដោយមិនចាំបាច់ពឹងធនធាន ឬលើសមត្ថភាពទាំងស្រុងទេ។ យើងត្រូវរំលងចោលផ្លូវទាំងពីរនេះ ពិតមែនតែមានផ្លូវមួយក្នុងចំណោមផ្លូវពីរនេះ ដែលយើងអាចពិនិត្យឱ្យបានពេញលេញ បើនិយាយពីសាធារណរដ្ឋ។ ផ្លូវមួយឡើងងារតាមរយៈឧបាយកលអាក្រក់ ឬមធ្យោបាយខុច។ ផ្លូវមួយទៀត ពលរដ្ឋធម្មតាបានទទួលងារជាសម្តេចគ្រប់គ្រងប្រទេស តាមរយៈការជ្រើសរើសរបស់ប្រជាពលរដ្ឋ។

**៣.២.៥ របៀបគ្រប់គ្រងរបស់ស្តេច**

**៣.២.៥.១ អំពីចិត្តសុទ្ធា ឬ ចិត្តកំណាញ់**

លោក ម៉ាគីអាវែល្លី បាននិយាយថា ស្តេចដើម្បីឱ្យប្រជាពលរដ្ឋទូទៅស្គាល់ទ្រង់ថាជាស្តេចដែល មានភាពទូលំទូលាយនោះ ទ្រង់ត្រូវតែប្រើនយោបាយរិតត្បិតរបស់ស្តេច ដើម្បីគ្រប់គ្រងធនធានទ្រព្យសម្បត្តិបានគ្រប់គ្រាន់ ព្រោះថាអាចមានធនធានគ្រប់គ្រាន់ ដើម្បីធ្វើសង្គ្រាមការពារខ្លួនទ្រង់ផ្ទាល់ និង ប្រជារាស្ត្រទ្រង់ដោយមិនបាច់ធ្វើការជំរិតទារពន្ធពីប្រជារាស្ត្ររបស់ខ្លួនពេលខ្វះនោះទេ ពេលនោះធ្វើឱ្យប្រជាពលរដ្ឋយល់ពីភាពទូលាយរបស់ទ្រង់ពេលមានអាសន្ននោះ។ ម៉្យាងទៀត ស្តេចដែលមានភាពទូលាយដោយធនធានទ្រព្យសម្បត្តិអ្នកដទៃធ្វើឱ្យទ្រង់កាន់តែទទួលបានភាពល្បីល្បាញថែមទៀត ហើយទ្រង់អាចថែរក្សាទ្រព្យសម្បត្តិផ្ទាល់ខ្លួន និង ថវិការជាតិ ដើម្បីបង្កើនកម្លាំងទ័ពសព្វាវុធសម្រាប់ការពារទឹកដីប្រទេស។

លោកនិយាយទៀតថា មានតែចាយប្រាក់ខ្លួនឯងទេ ដែលបណ្តាលឱ្យខ្លួនវិនាស។ គ្មានអ្វីដែលធ្វើឱ្យវិនាសខ្លួនឯងខ្លាំងដូចភាពទូលាយទេ ព្រោះថាបើទ្រង់ប្រព្រឹត្តអំពើទូលាយទ្រង់នឹងបាត់អំណាចដោយសារតែទ្រង់គ្មានកម្លាំងទ័ពព្រោះតែធនធានមិនគ្រប់គ្រាន់ដោយសារតែការបង្កើតទ័ព លុះត្រាតែមានប្រាក់ឱ្យកម្លាំងទ័ពទាំងនោះ បើមិនអីចឹងទេ ទ័ពនោះមិនបំរើព្រះអង្គទេ ហើយទ្រង់នឹងក្លាយជាអ្នកក្រ និងត្រូវគេមើលងាយ ឬដើម្បីចៀសវាងសេចក្តីក្រទ្រង់នឹងទៅជាអ្នកលោភលន់ហើយត្រូវគេស្អប់។

**៣.២.៥.២ អំពីមាគ៌ាធ្វើទារុណ្ណកម្ម ឬ អត់ឱនទោសព្រមទាំងការសម្រេចចិត្តថាគេស្រលាញ់ ឬ គេស្អប់**

សម្តេចម្នាក់ៗ ចង់ឱ្យគេមើលមកឃើញថាមានមេត្តាធម៌ ហើយមិនឃោរឃៅ។ ប៉ុន្តែ សត្រូវប្រយ័ត្ន កុំប្រើមេត្តាធម៌នោះខុសរបៀប។ លោកបានលើកពីសេហ្សារ៍ប៉ូហ្សា ត្រូវបានគេមើលឃើញថាជាមនុស្សឃោរឃៅ ប៉ុន្តែអំពើឃោរឃៅរបស់ទ្រង់ធ្វើឱ្យមានរបៀបរៀបរយ សន្តិភាព និងភក្តីភាព ក្នុងរដ្ឋកាលរបស់ទ្រង់។ ហេតុនេះសម្តេចមិនត្រូវបានបារម្ភពីគេចោទថាមានចិត្តឃោរឃៅនោះទេ បើអំពើឃោរឃៅជាមធ្យោបាយសម្រាប់រក្សាសេចក្តីសាមគ្គី និង ភក្តីភាព។ ដោយសារមានសេចក្តីទន់ភ្លន់ហួសខ្នាតពេក ធ្វើឱ្យប្រទេសមានភាពអនាធិបតេយ្យដែលជាហេតុបណ្តាលឱ្យមានការបង្ហូរឈាម និងការរឹបអូសយកទ្រព្យសម្បត្តិ។ សម្តេចដែលទើបឡើងគ្រប់គ្រងប្រទេសថ្មីៗ ត្រូវបំពេញភាពឃោរឃៅខ្លះ ព្រោះរដ្ឋថ្មីមានគ្រោះ ថ្នាក់ច្រើនណាស់ សម្តេចត្រូវប្រយ័ត្នប្រយែងទាំងការជឿ និងការធ្វើ ហើយមិនត្រូវខ្លាចស្រមោលខ្លួនឯងទេ ប៉ុន្តែ មិនត្រូវទុកចិត្តខ្លួនឯងជ្រុលពេកនាំឱ្យមានការធ្វេសប្រហែសហើយក៏មិនត្រូវមិនទុកចិត្តគេជ្រុលពេកហួតមិនអនុគ្រោះឱ្យគេនោះទេ។ សម្តេច មិនត្រូវធ្វើឱ្យគេស្អប់ខ្លួនពេកហើយក៏មិនត្រូវឱ្យគេស្រលាញ់ខ្លួនជ្រុលពេកដែរ សម្តេចត្រូវឱ្យគេខ្លាច ព្រោះគេមិនហ៊ានស្អប់ទ្រង់ទេព្រោះសេចក្តីខ្លាចដើរជាមួយភាពមិនមានសេចក្តីស្អប់។ ប៉ុន្តែ ត្រូវប៉ះពាល់ទ្រព្យសម្បត្តិ និងប្រពន្ធកូនរបស់គេ ព្រោះថាមនុស្សធាប់ភ្លេចនូវមរណភាពរបស់ឪពុកគេជាងការបាត់បង់ទ្រព្យសម្បត្តិគេ ជាហេតុធ្វើឱ្យគេអាចងើបបះបោរជាមួយទ្រង់បាន។

**៣.២.៥.៣ របៀបដែលសម្តេចត្រូវមានជំនឿជានិច្ច**

ជាការគួរឱ្យសរសើរណាស់ដែលសម្តេចអាចរក្សាបានទុកបាននូវជំនឿល្អ និង រស់នៅក្នុងបូណភាពមិនមែនដោយឧបាយកលបោកបញ្ឆោតនោះទេ សម្តេចត្រូវគ្រប់គ្រងរដ្ឋដោយប្រើច្បាប់ និងកម្លាំងហេតុនេះ ដើម្បីទទួលបានជោគជ័យ សម្តេចត្រូវតែជាបុគ្គលមួយរូប ដែលមានការយកតម្រាប់តាមសត្វពីរ គឺសត្វកញ្ជ្រោងដើម្បីស្គាល់អន្ទាក់ និងជាសត្វតោដើម្បីបន្លាចសត្វឆ្កែចចក។ បើកាលណាទ្រង់យកតម្រាប់តាមសត្វទាំងពីរនោះ ធ្វើឱ្យទ្រង់មានភាពជឿជាក់លើការគ្រប់គ្រងរបស់ខ្លួន ព្រោះទ្រង់ជាមនុស្សឆ្លាត ចេះបត់បែនបានគ្រប់កាលៈទេសៈ យល់ពីកលល្បិចសត្រូវ ហើយទ្រង់ជាមនុស្សមានអំណាចព្រោះទ្រង់មានកម្លាំងទ័ពខ្លាំងក្លា។

**៣.២.៥.៤ អំពីរដ្ឋមន្ត្រីរបស់សម្តេច**

ការជ្រើសរើសរដ្ឋមន្ត្រីរបស់សម្តេចមិនមែនជាភារកិច្ចដែលសំខាន់បន្តិចបន្តួចនោះទេ។ ឬមួយរដ្ឋមន្ត្រីទាំងនោះបានល្អ ឬមួយលទ្ធផលបានមិនស្របនឹងលក្ខណៈប្រយ័ត្នប្រយែងរបស់សម្តេចតែម្តង។ កាលណាមនុស្សទាំង

នោះមានសមត្ថភាព និង ភក្តីភាព គេថាសម្តេចជាក្សត្រមានសុភវិនិច្ឆ័យណាស់ ព្រោះថាសម្តេចស្គាល់សមត្ថភាពរបស់អ្នកទាំងនោះ ហើយអាចរក្សាទុកបាននូវភក្តីភាពរបស់អ្នកទាំងនោះផង។ ប៉ុន្តែ បើមនុស្សទាំងនោះមានលក្ខណៈផ្ទុយទៅវិញ គេអាចមានតែអារម្មណ៍អាក្រក់ចំពោះ សម្តេច ព្រោះថាក្នុងការជ្រើសរើសរដ្ឋមន្ត្រីទាំងនោះសម្តេចបានធ្វើកំហុសទីមួយ។ មនុស្សមានខួរក្បាល ៣ យ៉ាង មួយយល់ដោយគ្មាននណាជួយ មួយយល់ដោយការមានគេបង្ហាញ។ មួយទៀត យល់មិនដោយខ្លួនឯង ឬ មិនដោយអ្នកណាពន្យល់ឡើយអ្នកទីមួយប្រសើរល្អបំផុត។ កាលណាសម្តេច និងរដ្ឋមន្ត្រីរបស់ទ្រង់ស្ថិតក្នុងរចនាសម្ព័ន្ធរបៀបនេះ ហើយទ្រង់ និងរដ្ឋមន្ត្រី អាចពឹងពាក់គ្នាទៅវិញទៅមក។ កាលណាបើមិនអីចឹងទេ លទ្ធផលតែងតែបណ្តាលឱ្យមានការឈឺចាប់ម្ខាងៗពុំខានឡើយ។

**៣.២.៥.៥ របៀបបង្ក្រាបមនុស្សបញ្ជោរ**

ម៉ាគីអាវែល្លី មិនរំលងកម្មវត្ថុមួយដ៏សំខាន់ទេ គាត់បានអធិប្បាយនូវកំហុសមួយ ដែលសម្តេចមានការលំបាកនឹងចៀសវាងណាស់ បើសម្តេចមិនបានប្រុងប្រយ័ត្ន ឬ ក៏ទ្រង់មិនបានជ្រើសរើសបានល្អ។ នេះ ជារឿងរ៉ាវទាក់ទងនឹងអ្នកបញ្ជោរ។ សម្តេច គ្មានវិធីណាផ្សេងសម្រាប់ការពារព្រះអង្គប្រឆាំងនឹងការបញ្ជោរនេះ ប្រសិនប្រាប់ទៅពួកបញ្ជោរនោះថា ព្រះអង្គមិនខឹងទេបើសិនជានិយាយត្រង់ៗមក។ ប៉ុន្តែ បើអ្នកណាអាចនិយាយត្រង់ជាមួយសម្តេចនោះបានដែរនោះ សម្តេចនឹងអស់ការគោរពពីសំណាក់ពួកអស់ទាំងនោះហើយ។ ដូច្នេះ សម្តេចដែលមានការប្រយ័ត្នប្រយែងត្រូវតែមានវិធី ៣ គឺថាជ្រើសរើសអ្នកមានសុភវិនិច្ឆ័យធ្វើជាសមាជិកក្រុមប្រឹក្សាទ្រង់ ហើយបើកសិទ្ធិពេញលេញឱ្យតែអ្នកទាំងនោះនិយាយត្រង់ៗមកសម្តេចចំពោះតែកម្មវត្ថុអ្វីដែលសម្តេចសួរ ហើយគ្មានអ្វីផ្សេងពីនោះទៀតទេ។ ក្បួនមួយដែលមិនចេះខុសបានចែងថា សម្តេចអង្គណាដែលគ្មានសុភវិនិច្ឆ័យខ្លួនឯងទេ សម្តេចអង្គនោះពុំអាចទទួលយោបល់ល្អពីគេបានដែរ លើកលែងតែដោយចៃដន្យសម្តេចនោះស្ថិតក្នុងការដឹកនាំរបស់អ្នកណាម្នាក់ដែលត្រួតត្រាទ្រង់គ្រប់ផ្នែក ហើយជាមនុស្សដែលមានភាពប្រុងប្រយ័ត្នប្រយែងយ៉ាងប្រសើរផង។

**៣.២.៥.៦ ក្នុងបញ្ហាទាក់ទងជាមួយមនុស្ស តើធនធានប៉ុន្មានទើបគ្រប់គ្រាន់ហើយក្នុងករណីណាដែលគេមិនត្រូវប្រើធនធាន?**

មិនជាការស្ងប់ស្ងាត់ចំពោះព្រះអង្គនោះទេ ដែលជាមនុស្សមួយចំនួនធំបានយល់ និងកំពុងជឿថាព្រឹត្តការណ៍ក្នុងលោកទាំងឡាយបណ្តាលពីព្រេងវាសនា និង ពីព្រះជាម្ចាស់ ហើយថាមនុស្សម្នាក់ទាំងឡាយពុំអាចផ្លាស់ប្តូរព្រឹត្តិការណ៍ទាំងណាទេ ទុកជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយ ផ្ទុយទៅវិញគ្មានថ្នាំសង្កូវឯណាអាចយកមកផ្សះបានឡើយ។ មនុស្សដែលមានសេចក្តីប្រុងប្រយ័ត្នប្រយែងកាល ណាពេលវេលាតម្រូវឱ្យធ្វើអ្វីភ្លាមស្រាប់តែពុំអាចផ្លាស់ប្តូរឱ្យបានរហ័ស ម្លោះហើយត្រូវវិនាស។ បើដូច្នេះហើយ ដូចជាស្រីអីចឹង ជោគវាសនាមានដល់តែមនុស្សក្នុងវ័យក្មេង ពីព្រោះថាយុវជនមិនសូវប្រយ័ត្នប្រយែង ចិត្តមោះមុតហើយត្រួតត្រាស្ត្រីដោយលក្ខណៈក្លាហានជាងប្រយោជន៍ដល់សង្គម។

# មេរៀនទី៤ តូម៉ាស ហាប្ស

( Thomas Hobbes 1588-1679 )

## ៤.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ

លោក Thomas Hobbes កើតនៅទីក្រុងវែស៍ស្ព័ត( Westport )ជិតម៉ាល់ម៉េសប៊ូរី ( Malmesbury ) ប្រទេសអង់គ្លេសនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ១៥៨៨។ លោកកើតមកមិនគ្រប់ខែនៅពេលស្រុកមានសង្គ្រាមជាមួយអេស្ប៉ាញ។ លោកតែងតែនិយាយថាម្តាយរបស់គាត់បានកើតកូនភ្លោះ គឺរូបលោក និងភាពភ័យខ្លាច។ ជីវប្រវត្តិពីក្មេងរបស់លោកគឺពុំសូវមានការដឹងឮឡើយ សូម្បីតែឈ្មោះម្តាយរបស់លោកក៏ពុំត្រូវបានរកឃើញឈ្មោះដែរ។ ឯឪពុករបស់លោកមានឈ្មោះ Thomas ផងដែរ ហើយគាត់គឺជាភូឈួយគ្រីក្រមួយរូប ដែលត្រូវបានគេបណ្តេញចេញដោយសារតែមានជម្លោះជាមួយអាចារ្យសាសនាគ្រីស្ត។ ពេលនោះ Hobbes ត្រូវបានឪពុកធំ ហ្វ្រង់ស៊ីស (Francis) យកទៅចិញ្ចឹមជាមួយនឹងបងប្អូនពីរនាក់ទៀត។

លោក Hobbes បានទទួលការសិក្សាតាំងពីអាយុ៤ឆ្នាំនៅព្រះវិហាររបស់សាសនាគ្រីស្តមួយឈ្មោះ Westport។ Hobbes ជាសិស្សពូកែម្នាក់។ នៅអាយុ៦ឆ្នាំលោកបានរៀនភាសាក្រិច និងឡាតាំង។ នៅឆ្នាំ ១៦០៣ គាត់បានបន្តការសិក្សានៅសាលាម៉ាល់ម៉េសប៊ូរី ( Malmesbury school ) ហើយបន្តការសិក្សានៅសាលាឯកជនមួយ ទើបបានចូលរៀននៅសាកលវិទ្យាល័យOxford នៅអាយុ១៥ឆ្នាំ។ លោកស្នាក់នៅទីនោះរហូតបញ្ចប់ការសិក្សា និងក្លាយជាគ្រូបង្ហាត់។ លោកបានបង្ហាត់ William ដែលលោកជាកូនអភិជនម្នាក់ឈ្មោះ William Cavendish។ នៅឆ្នាំ១៦១០ លោក និង កូនសិស្សរបស់លោក William បានធ្វើដំណើរទៅប្រទេសបារាំង ហើយបានជួបជាមួយឥស្សរជនសំខាន់ៗដូចជាលោក Francis Bacon លោក Gallile និងលោក Harvey។

បន្ទាប់ពីបង្ហាត់បង្រៀនអស់រយៈពេលជាច្រើនឆ្នាំ Hobbe បានពង្រីកបន្ថែមនូវចំនេះដឹងជាច្រើនទាក់ទិននឹងទស្សនវិជ្ជា ធ្វើឱ្យលោកមានការចង់ដឹងចង់ឮកាន់តែច្រើនលើបញ្ហានេះ ហើយក្នុងឆ្នាំ ១៦៣៦ លោកបានទៅទស្សនកិច្ចនៅ Florence ក្រោយមកលោកក្លាយជាអ្នកវែកញែកតស៊ូមតិជុំវិញទស្សនវិជ្ជានៅទីក្រុងប៉ារីស។ ឆ្នាំ ១៦៣៧ លោកបានត្រលប់មកប្រទេសអង់គ្លេសវិញ ហើយលោកបានចាត់ទុកខ្លួនលោកជាទស្សនវិទូម្នាក់ និងជាអ្នកប្រាជ្ញមួយរូប។ លោកបានផ្សព្វផ្សាយសេចក្តីអធិប្បាយរួមមួយស្តីពីទ្រឹស្តីចលនា ( Little Treatise on the theory of motion )។ ពេលនោះប្រទេសអង់គ្លេសមានជម្លោះរវាងស្តេច Charles និងពួកសភា។ Hobbeបានបំពេញការងារបុព្វសិទ្ធិរបស់ស្តេច។ ពួកសភាបានឡើងកាន់អំណាចក្នុងខែវិច្ឆិកា ឆ្នាំ១៦៤០។ ក្នុងឆ្នាំនោះដែរ លោកខិតខំសរសេរស្នាដៃរបស់លោកដូចជា សារធាតុនៃច្បាប់ ( Elements Of Law ), ធម្មជាតិ និងនយោបាយ ( Nature and Politic )។ លោកត្រូវបានគេឃាត់ខ្លួនដោយសារការចេញផ្សាយស្នាដៃទាំងពីរនោះ។

ពេលនោះហើយដែល Hobbe បានរត់គេចខ្លួនទៅបារាំង។ លោកបានក្លាយទៅជាគ្រូបង្ហាត់ផ្នែកគណិតវិទ្យាចំពោះស្តេចអង់គ្លេសឈ្មោះវែលស៍ ( Wales ) និងហ្សាល់ទីII ( CharlesII ) ពីឆ្នាំ១៦៤៦-១៦៤៨។ ១១ឆ្នាំគត់ដែលលោកមិនបានត្រឡប់ទៅប្រទេសអង់គ្លេសវិញទេ រហូតដល់ឆ្នាំ ១៦៥១។ ឆ្នាំ ១៦៥១ មុននិងត្រឡប់មកប្រទេសអង់គ្លេសវិញ លោកបានចេញផ្សាយស្នាដៃមួយទៀតឈ្មោះ ឡេវីយ៉ាតង់ ( Leviathan ) ដែលជាស្នាដៃបង្កប់ទៅដោយទ្រឹស្តីនយោបាយជាលើកដំបូងរបស់លោក។

ឆ្នាំ១៦៥១ ស្នាដៃមួយទៀតដែលសរសេរទុកតាំងពីឆ្នាំ១៦៤២ ឈ្មោះ ឡឺជីស៊ីវ ( De Cive ) ត្រូវបានយកទៅបកប្រែ និងធ្វើការរជ្ជថ្មី ហើយរស់នៅទីនោះរហូតដល់ឆ្នាំ ១៦៧២(អាយុ ៨៤ឆ្នាំ ) លោកបានខិតខំសរសេរជីវប្រវត្តិ

ផ្ទាល់របស់លោកឡើងជាពាក្យកាព្យឡាតាំង ដែលបកប្រែជាពាក្យកាព្យភាសាអង់គ្លេសហើយលោកធ្វើមរណកាលនៅថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ១៦៧៩។ លោកទទួលមរណភាពក្នុងជន្មាយុ ៩១ឆ្នាំ។

### ៤.២ ទស្សនៈនយោបាយ

Thomas Hobbes ចង់ផ្ដល់ឱ្យមនុស្សនូវសន្តិភាព។ សេចក្ដីប្រាថ្នាតែមួយគត់របស់គាត់ គឺការចង់បានការធានាឱ្យមានភាពសុខសាន្ត និងការរួបរួមគ្នាតែមួយ។ ប៉ុន្តែមិនមានលទ្ធភាពណាមួយដែលអាចផ្ដល់នូវសន្តិភាពនេះបានទេដរាបណានៅមានការប្រឆាំងតទល់គ្នារវាងនយោបាយ និងសាសនានោះ។ ឆ្នាំ១៦៥០ ក្នុងប្រទេសអង់គ្លេសមានបដិវត្តន៍គហបតីមួយផ្ទុះឡើង គឺជាការរួបរួមគ្នាតស៊ូរបស់ពួកនាយទុន និងពួកអភិជនថ្មី ក្នុងគោលបំណងប្រឆាំងនឹងរាជានិយមផ្ដាច់ការ គឺប្រឆាំងនឹងទ្រឹស្ដីថា«អំណាចរដ្ឋកើតចេញពីអាទិទេព»។ ដោយឈរលើទស្សនរូបធាតុនិយម ហើយបូកផ្សំនឹងបទពិសោធន៍ នាសម័យសង្គ្រាមនោះបានធ្វើឱ្យ Thomas Hobbes ក្លាយជាមនុស្សដ៏សំខាន់ក្នុងបដិវត្តន៍គហបតី។ ដោយឃើញអំពើហិង្សា និងទំនាស់ឥតឈប់ឈរក្នុងរវាងពួកគហបតី និងអភិជនថ្មីThomas Hobbes ប្រឹងប្រែងរកច្រកចេញឱ្យផុតពីការភ័យខ្លាចរបស់គាត់ ដោយដាក់បុគ្គលរបស់ខ្លួនឱ្យស្ថិតក្រោមការគាំពារនៃរបបផ្ដាច់ការនិយម ដោយប្រគល់អំណាចទាំងអស់ដល់ព្រះមហាក្សត្រ ព្រោះមានតែព្រះមហាក្សត្រទេដែលធានាបានឱ្យមានសន្តិសុខ និងភាពសុខសាន្ត។ គំនិតនេះ ឃើញមាននៅក្នុងស្នាដៃទីមួយរបស់គាត់ឈ្មោះថា « The Element of Law » សៀវភៅនេះបោះពុម្ពនៅក្នុងឆ្នាំ១៦៥០។

ការភ័យខ្លាចជាកម្លាំងចលករជំរុញឱ្យ Thomas Hobbes ក្លាយទៅជាអ្នករដ្ឋនិយម ដ៏ស្មោះត្រង់ម្នាក់។ ជំរកសង្គ្រោះជីវិតគាត់ឱ្យមានភាពសុខសាន្ត ត្រូវបានប្ដូរជាមួយនឹងតួនាទីបុគ្គលខ្លួនឯងទាំងអស់ ប៉ុន្តែការចុះចាញ់នេះ មិនបានធ្វើឱ្យមូលដ្ឋានគំនិតរបស់គាត់ផ្លាស់ប្ដូរទេ។ Thomas Hobbes ក៏មិនខុសពីអ្នកនិពន្ធដទៃទៀតរបស់សាលាច្បាប់ជាតិ និងសាលាច្បាប់អន្តរជាតិដែរគឺគាត់ខិតខំស្រាវជ្រាវរកឃើញមូលដ្ឋានគ្រឹះរបស់អំណាច និងលក្ខខណ្ឌរបស់វា តាមការវិភាគ រកមូលហេតុដែលនាំឱ្យមនុស្សសុខចិត្ត សុខកាយ ហើយមកផ្ដុំគ្នារួមរស់ជាមួយគ្នាក្នុងសង្គមដោយការធ្វើកិច្ចសន្យាសង្គម( Social Contract )។ Thomas Hobbes យល់ឃើញថា «ជម្រៅធម្មជាតិរបស់មនុស្ស គឺអត្តទត្តភាព អាត្មានិយម មិនមានការចង់រស់នៅជាមួយអ្នកដទៃឡើយ។ កាលណាមនុស្សរត់ទៅរកកន្លែងថ្មី ដើម្បីរស់នៅក្នុងសង្គម គឺមិនមែនដោយសារ គេចង់បានការរីកចម្រើនលូតលាស់ របស់សង្គមនោះទេ តែគឺដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ»។ សង្គមកើតឡើងពីការខ្លាចរវាងមនុស្សនិងមនុស្សមិនមែដោយសារការស្វាគមន៍រកគ្នាទៅវិញទៅមកនោះទេ។ សភាពធម្មជាតិ ដែលមនុស្សរស់នៅ មុននឹងមកចុះចូលរស់នៅជាមួយគ្នានេះ ជាសភាពមួយប្រកបដោយគ្រោះថ្នាក់ និងការវិនាស។ បានន័យថា «មនុស្សជាឆ្កែចចកសម្រាប់មនុស្សគ្នាឯង» គឺថាមនុស្សនៅក្នុងសភាពធម្មជាតិតែងច្បាំងគ្នា ប្រឆាំងគ្នា ប្រណាំងគ្នា ឈ្លោះគ្នាឯងជានិច្ច និងប្រឆាំងអ្នកដទៃនៅក្នុងក្រុមផ្សេងៗទៀតផងដែរ ដោយសារមនុស្សមានសិទ្ធិស្មើគ្នាចំពោះអ្វីដែលមាន ពួកគេក៏ដណ្ដើមគ្នាយកនូវអ្វីនោះគេមានគំនិតបំផ្លិចបំផ្លាញគ្នាទៅវិញទៅមក ។ គេទាំងអស់គ្នារៀងៗខ្លួនជាប្រភពនៃគ្រោះថ្នាក់ និងការភ័យខ្លាច។ នៅក្នុងសភាពធម្មជាតិ មានតែសង្គ្រាមជាអចិន្ត្រៃយ៍ មានតែអសន្តិសុខ ដែលមនុស្សខ្សោយ តែងតែជាអ្នករងគ្រោះរបស់អ្នកខ្លាំងជាងខ្លួន ឬរបស់អ្នកដែលមានល្បិចជាងខ្លួន។ ច្បាប់ធម្មជាតិ ក្នុងគោលការណ៍របស់វាមានលក្ខណៈជាអត្តទត្តភាព ប៉ុន្តែនៅក្នុងសភាពធម្មជាតិ បញ្ញារបស់ច្បាប់ធម្មជាតិ មិនមែនជាកាតព្វកិច្ចត្រូវគោរពទេ។ ល្គិកណាគេមិនប្រាកដថាអ្នកដទៃបានបំពេញកិច្ចសន្យារបស់គេហើយ យើងធ្វើតែយើងនោះប្រាកដជាគ្មានបានប្រយោជន៍អ្វីឡើយ។ ផលប្រយោជន៍តែមួយគត់ គឺត្រូវចេញពីសភាពធម្មជាតិ ដើម្បីមករស់នៅក្នុងសង្គមវិញ។

Thomas Hobbes បានបង្ហាញនូវទិដ្ឋភាពអនាធិបតេយ្យ មហន្តរាយសង្គម មុនពេលកកើតរដ្ឋនៅពេលនោះមនុស្ស បានធ្វើសង្គ្រាមកាប់ចាក់ ឥតឈប់ឈរ គឺជាសង្គ្រាមទាំងអស់គ្នា ប្រឆាំងទាំងអស់គ្នា។ ប៉ុន្តែ មនុស្សមាន

វិចារណ្ញាណ ហើយទទួលស្គាល់នូវភាពមិនរឹងមាំ ក្នុងការរស់នៅរបស់ពួកគេ ទីបំផុតគេក៏បានរកឃើញនូវមធ្យោបាយ ដើម្បីរំដោះខ្លួនគេឱ្យចេញពីមហន្តរាយរបស់មនុស្ស ហើយមករួបរួមផ្តុំគ្នាជាចំនួនច្រើនឥតគណនា ដើម្បីបង្កើត សម្ព័ន្ធភាពមួយសម្រាប់ធានាប្រឆាំងនឹងអសន្តិសុខ ដែលតែងតែយាយីកាលគេរស់នៅក្នុងសភាពធម្មជាតិ។ ការរួបរួមនេះបង្កើតបានជារដ្ឋ។ ដូច្នេះ គឺនៅពេលដែលមនុស្សបោះបង់ចោលការរស់នៅក្នុងសភាពធម្មជាតិ ទើបកើតមានឡើងនូវសង្គមមួយមាន ច្បាប់ទម្លាប់ គឺរដ្ឋ ដែលបានបង្កើតឱ្យមានអ្វីជារបស់ខ្ញុំ អ្វីជារបស់អ្នក ហើយបង្ខំឱ្យមានការគោរពកម្មសិទ្ធិអ្នកដទៃ ។

### ៤.២.១ រដ្ឋធម្មជាតិ

ការបើកសកវាជមួយដែលមានមនុស្សរស់នៅលើផែនដីមានធម្មជាតិ បានដើរតួនាទីនៅក្នុងរដ្ឋ ខណៈនោះមនុស្សប្រកបរបរចិញ្ចឹមជីវិតដោយមិនគិតដល់ការប៉ះពាល់លើច្បាប់ វិធាន ឬហានានុក្រមអ្វីឡើយ។ តូម៉ាស ហប្សពិពណ៌នាអំពីមនុស្សនៅក្នុង"**រដ្ឋធម្មជាតិ**" ដែលមានលក្ខណៈរស់នៅមុនសង្គមស៊ីវិល។ មនុស្សនៅក្នុងរដ្ឋធម្មជាតិគឺមានភាពដូចគ្នាពីធម្មជាតិទាំងផ្លូវកាយនិងផ្លូវចិត្ត។ ពួកគេមិនមានភាពស្មើគ្នាខាងសរីរៈនិងស្មារតីទេ។ ប៉ុន្តែមានភាពស្មើគ្នាខាងសិទ្ធិដើម្បីពិចារណាសម្រាប់ការរស់នៅ។ ពាក្យថាស្មើគ្នានៅទីនេះមានន័យថាមនុស្សមានសមត្ថភាពធ្វើឱ្យអ្នកនៅក្បែរខ្លួនរបស់គេ ក្នុង បំណងបម្រើកិច្ចការពារផ្ទាល់ខ្លួន។ ក្រុមមនុស្សទាំងឡាយណាដែលមានភាពទន់ខ្សោយខាងផ្លូវកាយ អាចធ្វើជាម្ចាស់នៃក្រុមមនុស្សដែលមានកម្លាំងកាយពេញលេញ ដោយផ្អែកលើភាពវៃឆ្លាតរបស់គេ។ ចំពោះឃ្លាមួយដែលសរសេរថា សិទ្ធិលើអ្វីៗទាំងអស់ (Right of all to all) គឺមានន័យថា មនុស្សមានសិទ្ធិសេរីភាពគ្រប់កាល និងលំហ ដើម្បីរស់នៅក្នុងរដ្ឋដូចគ្នា។ ប៉ុន្តែមិនមានន័យថា មនុស្សខ្លះមានគ្រប់ សិទ្ធិដើម្បីសម្រេចនូវអ្វីដែលគេចង់ ហើយមានមនុស្សផ្សេងទៀតត្រូវតែទទួសខុសត្រូវលើភារកិច្ចនោះឡើយ។ ពួកគេគ្រប់ៗគ្នាស្វែងរកគំនិតអភិរក្សនិយមសម្រាប់ផ្ទាល់ខ្លួន ហើយម្យ៉ាងទៀតត្រូវតែស្វែងរក សន្តិភាព ឬសុភមង្គល។ នៅក្នុងរដ្ឋនេះ ពួកគេបន្តធ្វើគ្រប់សកម្មភាពដោយឥតឈប់ឈរតាមអ្វីដែលពួកគេគិតថា នឹងការពារនូវសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ។ ការប្រតិបត្តិនៅក្នុងរដ្ឋធម្មជាតិ គឺធ្វើឱ្យ មនុស្សព្យាយាមដើម្បីយកឈ្នះលើអ្នកដទៃ បានន័យថាពួកគេធ្វើសង្គ្រាមតទល់នឹងអ្នកដទៃដែលនៅក្នុងសហគមន៍តែមួយដូចគ្នា។ តាមលក្ខណៈសង្គមបែបអនាធិបតេយ្យមួយបែបនេះ លោក ហប្ស បាន ហៅថា "សង្គ្រាមដែលមនុស្សទាំងអស់ប្រឆាំងគ្នា" (The war of all against all)។ ហេតុដែលមនុស្សគ្រប់រូបចង់បានកិច្ចការពារ និងភាពរុងរឿងផ្ទាល់ខ្លួន បណ្តាលឱ្យពួកគេបង្កើតការប្រណាំងប្រជែងគ្នា ហើយនិងប្រព្រឹត្តិអំពើក្បត់នឹងអ្នកដទៃ។ ហេតុដូចនេះមនុស្សគ្រប់រូបទាមទារឱ្យអ្នងទៀតឱ្យតម្លៃខ្លួនដូចដែលខ្លួនឱ្យតម្លៃលើខ្លួនឯងដែរ ជាងនេះទៅទៀតពួកគេធាប់តូចចិត្តនឹងរាល់ ចំណែកដែលបានតិចនិងរាល់ការមើលងាយដាក់គ្នា។ យើងឃើញថា តាមវិធីដែលនាំទៅដល់ជម្លោះ នៅក្នុងរដ្ឋ មានមូលហេតុចម្បងៗបីគឺ

ទី១ ការប្រកួតប្រជែងគ្នាៈ ការចង់ចំណេញតែម្នាក់ឯង

ទី២ ការមិនទុកចិត្តគ្នាៈ ការចង់មានសុវត្ថិភាពតែម្នាក់ឯង

ទី៣ មហិច្ឆិតាៈ ការចង់ខ្ពង់ខ្ពស់តែម្នាក់ឯង។

Thomas Hobbes បានបញ្ជាក់ថាតណ្ហាទាំងនេះហើយដែលធ្វើឱ្យមនុស្សក្លាយទៅជាសត្រូវនឹងគ្នា។ មនុស្សបានរស់នៅក្នុងស្ថានភាពប្រឆាំងទាំងអស់។ ដើម្បីអត្ថិភាពរបស់ខ្លួន មនុស្សបានប្រឆាំងប្រយុទ្ធគ្នាដូចឆ្កែចចក។

ពាក្យថា សិទ្ធិ នៅក្នុងរដ្ឋធម្មជាតិ ជាសេរីភាពរបស់មនុស្ស(ធ្វើអ្វីតាមគេគួរធ្វើ ហើយប្រឆាំងនឹងអ្នកណាដែលគេបានគិតទុក, ចង់ធ្វើកម្មសិទ្ធិ, រីករាយនឹងរាល់អ្វីដែលគេគិតថាសម ឬគួរទទួល) ដែលលេចចេញនូវកំហឹងក្នុងខ្លួន គឺជាឆន្ទៈដើម្បីរស់នៅ ហើយតាមលក្ខណៈចិត្តសាស្ត្រ ដែលរាលដាលដល់ រាល់មនុស្ស គឺសេចក្តីភ័យខ្លាច ដូចជាខ្លាចនឹងសេចក្តីស្លាប់ ពិសេសខ្លាចស្លាប់ដោយអំពើហិង្សា។

ដោយយោងលើរដ្ឋមួយដែលមានជម្លោះគ្នាដូចនេះ Hobbes បានទាញសន្និដ្ឋានថា នៅក្នុងរដ្ឋនោះមនុស្សពោរពេញដោយជម្លោះគ្នានឹងគ្នា គេរស់នៅក្រោមអំណាចសកលមួយដូចជារដ្ឋនៃសង្គ្រាមពីបុគ្គលម្នាក់ទៅអ្នកដទៃ។ ពាក្យថា សង្គ្រាម មិននិយាយតែនៅលើសមរភូមិ ឬការប្រយុទ្ធគ្នាប៉ុណ្ណោះ ទេ ប៉ុន្តែថែមទាំងពេលទៅដល់ការចងចិត្ត អាឃាដគ្នាដែលឈានទៅដល់ការមិនទទួលខុសត្រូវលើជម្លោះទៀតផង។ ទោះយ៉ាងណា រដ្ឋដែលមានសង្គ្រាមពីធម្មជាតិ គឺជារដ្ឋពោរពេញដោយភារកិច្ចដែល តាមរយៈភារកិច្ចនេះ មនុស្សរស់នៅដោយមានឯករាជ្យភាពតាមសន្តិសុខ កម្លាំង និងឥទ្ធិពល ដែលមានហេតុផលរបស់ពួកគេ។

ក្នុងរដ្ឋធម្មជាតិគ្មានកន្លែងណាមួយដែលត្រូវធ្វើវិនិយោគទុន ឬពាណិជ្ជកម្មអ្វីទេ ព្រោះផលិតផល ឬលទ្ធផលដែលគេទទួលបាន មិនបានតាមបំណងរបស់គេទេ។ ឆ្លងតាមរដ្ឋដដែលនេះ ជារដ្ឋដែលគ្មាន វប្បធម៌ គ្មានការដឹកជញ្ជូន គ្មានការប្រើប្រាស់សម្ភារៈទំនើប គ្មានអាគារ គ្មានប្រព័ន្ធអប់រំ ហើយគ្មានការប្រកាសធ្វើជំនួញ។ ជាងនេះទៅទៀត វាជារដ្ឋដែលនាំទៅដល់ការបន្តសេចក្តីភ័យខ្លាច និងគ្រោះថ្នាក់ កើតពីអំពើហិង្សាដែលធ្លាក់ទៅដល់មរណភាព ហេតុនេះជីវភាពរស់នៅរបស់ពួកគេ គឺក្នុងស្ថានភាពក្រខ្សត់ និងអាក់អន្លួលទាំងស្ថានភាពផ្លូវកាយ និងចិត្តសាស្ត្រ។

គ្រប់សិទ្ធិទាំងអស់គួរតែនៅក្នុងដៃរបស់អ្នកខ្លាំង ចំណែកឯអ្នកខ្សោយ មិនមានសិទ្ធិអ្វីទាំងអស់ លើកលែងតែសិទ្ធិធម្មជាតិ។ ហើយម្យ៉ាងទៀត ច្បាប់គួរតែនៅក្រោមការកាន់កាប់របស់អ្នកខ្លាំង ដែលអ្នកខ្លាំងខ្លួនគេអាចមិនដឹងនូវការពង្រីងនូវដែនដីរបស់ខ្លួន ហើយពួកគេអាចមិនដឹងនូវយុទ្ធវិធីដើម្បីយក ឈ្នះលើអ្នកឯទៀតដោយអហិង្សា។

មនុស្សដែលរស់នៅក្នុងរដ្ឋធម្មជាតិក៏ដូចគ្នានឹងមនុស្សនៅក្នុងសង្គមស៊ីវិលដែរ។ Hobbes បាន ចែកទៅជាពីរវិធីដែលវិធីទាំងពីរនេះសំដៅទៅលើច្បាប់ធម្មជាតិដែលត្រូវមានកាតព្វកិច្ចឱ្យអនុវត្តតាមមហិច្ឆតាមួយដែលកើតមានស្របតាមច្បាប់ធម្មជាតិ។ វានឹងគ្មានសង្គ្រាមបង្ហូរឈាមអ្វីទេ ប្រសិនបើគ្មានកាតព្វកិច្ចអ្វីទាំងអស់នៅក្នុងរដ្ឋធម្មជាតិ។ ហេតុនេះហើយទើបពួកគេមានសិទ្ធិបំពេញតាមកាតព្វកិច្ចដែលស្ថិតនៅក្នុងក្រឹត្យក្រមធម្មជាតិ។ តណ្ហា ជាសារជាតុចាំបាច់ដែលរុញច្រានឱ្យមនុស្សក្នុងរដ្ឋត្រូវតែ បំពេញកាតព្វកិច្ចរបស់ខ្លួន ដោយមិនគិតដល់ផលរបស់វាយ៉ាងណានោះឡើយ។ តើមានកត្តាអ្វីខ្លះដែលរុញច្រានឱ្យទៅជារដ្ឋពោរពេញដោយសង្គ្រាម ? នេះមិនមែនដោយសារតែគ្មានកាតព្វកិច្ចនៅក្នុងរដ្ឋទេ ប៉ុន្តែបើបុគ្គលចេះបន្ទាបខ្លួន ស្លូតបូត ហើយគោរពតាមការសន្យា បុគ្គលរូបនោះ គួរធ្វើឱ្យអ្នកដទៃធ្វើដូច្នោះដែរ ហើយបដិសេធនឹងច្បាប់ដទៃទៀត ដែលទាមទារទៅរកការរស់នៅតាមបែបធម្មជាតិ។ មនុស្សក្នុងរដ្ឋពេលពួកគេចង់មានកិច្ចការពារផ្ទាល់ខ្លួន គេមិនអាចមានសេរីភាពពីវិចារណញ្ញាណនិងច្បាប់ធម្មជាតិទេ។ ហេតុនេះពួកគេគួរតែប្រតិបត្តិតាមទឹកចិត្តស្មោះត្រង់ល្អជាមួយគ្នា។ បើមានមនុស្សណាម្នាក់ចង់បានជាកិច្ចការពារផ្ទាល់ខ្លួន ប៉ុន្តែខ្លួនគេមិនបានជឿជាក់លើកិច្ច ការពារនោះយ៉ាងដូចម្តេច គេនឹងអាចប្រព្រឹត្តិផ្ទុយពីច្បាប់ធម្មជាតិ។

Hobbes បានដឹងពីការសម្រេចចិត្តដែលកើតពីលទ្ធផលនៃការគិតត្រឹមត្រូវរបស់បុគ្គល។ ដើម្បីបញ្ចៀសនូវស្ថានភាពអនាធិបតេយ្យ មនុស្សគួរតែដើរតាមធម្មជាតិរបស់ធម្មជាតិ ដូចនេះពួកគេត្រូវតែឈានជើងចូលក្នុងកិច្ចសន្យាសង្គម ហើយបង្កើតនូវមនុស្សដែលជាភាគីនៃកិច្ចសន្យា។ មនុស្សនៅក្នុងរដ្ឋធម្មជាតិតម្រូវឱ្យរស់នៅតាមលក្ខណៈធម្មជាតិ ពោលគឺច្បាប់ធម្មជាតិ ដោយបូកបញ្ចូលនឹងសេចក្តីត្រូវការសម្រាប់សេចក្តីស្រេកឃ្លានអាហារ ការស្រេកទឹក និងការដកដង្ហើម។ ហេតុ ដូចម្តេចបានជាមនុស្សត្រូវធ្វើដូចនេះ? ពិព្រោះគ្រប់ភារៈទាំងអស់ត្រូវតែគោរពច្បាប់នេះជាកំណត់ ពុំ មានភារៈណាអាចចៀសផុតពីច្បាប់ធម្មជាតិបានទេ។

### ៤.២.២ ច្បាប់ធម្មជាតិ

តាមទស្សនៈរបស់ Hobbes ច្បាប់ធម្មជាតិ គឺជាបញ្ញត្តិ ឬជាមាគ៌ាទូទៅមួយ ត្រូវបានរកឃើញដោយ ហេតុនិងផលដែលនៅក្នុងច្បាប់នោះ គ្មានអ្នកណាម្នាក់ត្រូវអនុវត្តផ្ទុយពីផលប្រយោជន៍ប្រចាំ ជីវិតផ្ទាល់ខ្លួនរបស់គេឡើយ ហើយគេក៏មិនត្រូវបំផ្លាញការរស់នៅរបស់អ្នកដទៃដែរ។ ឆ្លងតាមច្បាប់ធម្មជាតិនេះ មនុស្សមានតណ្ហា និងវិចារណញ្ញាណពីធម្មជាតិ។ ប្រការដែលមនុស្សប្រតិបត្តិតាមចំណង់ របស់គេម្នាក់ៗនៅក្រោមច្បាប់ដែលគេចេះ

ដោយខ្លួនឯង គួបផ្សំនឹងការចែកចំណាង់មិនស្មើនៅក្នុងរដ្ឋបាននាំទៅដល់រដ្ឋមួយពោរពេញទៅដោយសង្គ្រាម ប៉ុន្តែមនុស្សក៏ចៀសមិនផុតពីសេចក្តីភ័យខ្លាច ពី សេចក្តីស្លាប់បានដែរ។ ចំណង់ ឬតណ្ហា ជាសេចក្តីចូលចិត្ត បណ្តាលឱ្យមនុស្សដើរទៅរកសន្តិភាពដោយខ្លួនឯង ហើយមិនគ្រប់តណ្ហាទាំងអស់សុទ្ធតែនាំទៅដល់ការបង្កើតសង្គ្រាម និងការប្រមូលផ្តុំហេតុ ផល ដើម្បីឈានទៅដល់សន្តិភាពទេ។ តណ្ហាខ្លះរុញច្រានឱ្យមនុស្សទៅរកសន្តិភាពដោយខ្លួនឯង ហើយតណ្ហាមួយចំនួនទៀតដឹកនាំឱ្យមនុស្សបង្កសង្គ្រាមរវាងគ្នានឹងគ្នា។ ជាលើកដំបូងដើម្បីឱ្យមានសន្តិភាពនៅក្នុងសង្គមដោយផ្អែកលើច្បាប់ធម្មជាតិ គេម្នាក់ៗគួរតែបង្កើតការព្រមព្រៀងនៅក្នុងសង្គម នោះ។ ហប្ស អះអាងថា គោលបំណងមានហេតុផលនៃកិច្ចការពារផ្ទាល់ខ្លួន ជាមូលហេតុនាំឱ្យមនុស្ស បង្កើតនូវក្រុមមនុស្សដែលរស់នៅក្រោមកិច្ចសន្យា ឬបង្កើតជារដ្ឋស៊ីវិល។ ហើយម្យ៉ាងទៀត ច្បាប់ធម្មជាតិផ្តល់នូវលក្ខខណ្ឌនានាសម្រាប់ការបង្កើតឡើងនូវរដ្ឋាភិបាលសង្គម និងរដ្ឋាភិបាលស្ថិរភាពមួយ។ រដ្ឋនៃច្បាប់ធម្មជាតិខ្លួនឯងគឺជាលទ្ធផលនៃការអនុវត្តច្បាប់ទាំងឡាយដោយប្រើកម្លាំង ឬវិចារណញ្ញាណ របស់មនុស្ស។ ហប្ស បានចងជាច្បាប់ធម្មជាតិតាមរបៀបផ្សេងៗគ្នាទៅតាមលំហ និងកាលខុសគ្នា។ ដោយយោងតាមស្នាដៃមួយរបស់លោកឈ្មោះថា Leviathan មូលដ្ឋានគ្រឹះនៃច្បាប់ធម្មជាតិគឺជាគោល ការណ៍ទូទៅនៅក្នុងវិចារណញ្ញាណ ដែលមនុស្សម្នាក់ៗត្រូវតែស្វែងរកអ្វីដែលគេយល់ថាជាសន្តិភាព របស់គេ បន្ទាប់មកត្រូវគោរព និងដើរតាមសន្តិភាពនោះទៅ។ នៅពេលដែលគេមិនអាចប្រតិបត្តិវាបាន គេអាចប្រើគ្រប់វិធីដើម្បីស្វែងរកជំនួយទោះក្នុងដំណាក់កាលបង្កើតជាសង្គ្រាមក៏ដោយ។

រួមសេចក្តីមក សន្តិភាពមានស្រាប់ហើយនៅតែមនុស្សខ្លួនឯងទេដែលរកមិនទាន់ឃើញ បើកាល ណាគេអាចរកឃើញហើយ គេក៏អាចប្រើសិទ្ធិរបស់គេ ដើម្បីថែរក្សាសន្តិភាពនោះឱ្យនៅស្ថិតស្ថេរបាន តាមការយល់ឃើញរបស់គេ។ ម្យ៉ាងវិញទៀត មនុស្សនៅក្នុងច្បាប់ធម្មជាតិ នៅពេលគេគិតឃើញពីអត្ថប្រយោជន៍នៃការប្រើសន្តិភាព ដោយគ្រាន់តែប្រើសិទ្ធិធម្មជាតិនោះ គេនឹងរួមចំណែកធ្វើឱ្យមានសេរីភាពនៅក្នុងសង្គមដោយមិនគិតដល់មានសង្គ្រាមអ្វីកើតឡើង។ គេត្រូវរស់នៅដោយដើរតាមមាគ៌ាមួយ ដែលមានតែនៅក្នុងស្មារតី និងអ្វីៗជាកម្មសិទ្ធិរបស់ធម្មជាតិ។

*" មនុស្សគ្រប់ៗគ្នា បន្តកិច្ចការពារខ្លួនឯង និងសន្តិសុខតាមសភាវគតិ។*
*ប៉ុន្តែមនុស្សមិនគ្រាន់តែជាភាវៈមានសភាវគតិទេ ថែមទាំងមានឥទ្ធិពល*
*អាចកំកំបាំងទៀតផង។ ការដែលមានដូចនេះហើយគឺជាកិច្ចការពារ*
*ដោយខ្លួនឯងនោះ។ អ្វីដែលគេហៅថាច្បាប់ធម្មជាតិនោះគឺប្រកាសជា*
*លក្ខខណ្ឌនូវការការពារផ្ទាល់តាមវិចារណញ្ញាណ"។*

ទោះបីជាមនុស្សនៅក្នុងរដ្ឋធម្មជាតិ រស់នៅដោយធ្វើអំពើឃោរឃៅ ក៏ពួកគេមានវិចារណញ្ញាណនៅក្នុងខ្លួនរបស់គេដែរ ពិព្រោះមនុស្សជាសត្វដែលមានវិចារណញ្ញាណ ចេះវិភាគលើបញ្ហា និងចងចាំព្រឹត្តិការណ៍។ ហេតុនេះធ្វើឱ្យពួកគេត្រូវរកសន្តិភាព និងសន្តិសុខដោយពឹងលើវិចារណពុទ្ធិ និងភារកិច្ច ការពារខ្លួនឯង ដែលជាហេតុធ្វើឱ្យគេអាចចងក្រងច្បាប់សម្រាប់សង្គមរបស់គេ។

### ៤.២.៣ ធម្មជាតិមនុស្ស

អ្វីនៅក្នុងលោកសុទ្ធតែមានធាតុដំបូងរបស់វា ដែលបណ្តាលឱ្យវត្ថុមួយក្លាយជាវត្ថុមួយទៀត។ មនុស្សពីធម្មជាតិគឺជាផលបូកសរុបនៃកម្លាំងធម្មជាតិ និងញាណសតិធម្មជាតិ។

ក្នុងសភាពធម្មជាតិមនុស្សបានបណ្តោយខ្លួនតាម សភាវគតិ អត្តទត្តភាព និងចំណង់។ នេះគឺជាចលកររបស់មនុស្ស គេចាត់ទុកមនុស្សជា )ម៉ាស៊ីនមួយ(។ ដោយសារចលករទាំង៣នេះ បានធ្វើឱ្យមនុស្សក្លាយជាសត្រូវនឹងគ្នា។ លោកបានចាត់ទុកមនុស្សជាឆ្កែចចកសម្លាប់មនុស្សគ្នាឯង ដែលប្រខាំគ្នាឯង។ បើតាមធម្មជាតិរបស់មនុស្ស មនុស្សជាអត្តទត្តបុគ្គល អនាធិបតេយ្យ ដែលមានបំណងលោភលន់។ មានន័យថាកំណើតរបស់មនុស្សភ្ជាប់ជាមួយនឹងសេចក្តីឃោរឃៅ ព្រៃផ្សៃកាចសាហាវគួរឱ្យខ្លាច។ តាមលោក Thomas Hobbes មនុស្សនៅក្នុងសភាពធម្មជាតិ

បណ្តោយឱ្យតែសភាវគតិរក្សាជីវិតដឹកនាំ។ មនុស្សនឹងមានសិទ្ធិធ្វើអ្វីៗទាំងអស់ ដើម្បីបំពេញសេចក្តីត្រូវការ និង រក្សាជីវិតខ្លួនឱ្យគង់វង្ស។ សិទ្ធិនេះគ្មានព្រំដែន ហើយដាច់ខាត ប៉ុន្តែនៅក្នុងការពិតជាក់ស្តែងមនុស្សពុំអាចប្រើសិទ្ធិនេះបានឡើយ ពីព្រោះកាលបើសិទ្ធិរបស់ខ្លួនទូលំទូលាយគ្មានព្រំដែន គឺជាការខុសឆ្គងខ្លាំង។ សភាពធម្មជាតិរបស់មនុស្ស គឺជាសភាពគ្មានសន្តិសុខ ដោយសារមនុស្សឋិតនៅក្រោមអំណាចនៃអ្នកខ្លាំងជាងខ្លួន ឬអ្នកដែលពូកែបោកប្រាសជាងខ្លួន។ តាមសភាពធម្មជាតិមនុស្សមានសមត្ថភាពផ្នែកខួរក្បាលនិងមានកម្លាំងគ្រប់គ្រាន់ដើម្បីសម្លាប់អ្នកដែលខ្លាំងជាងខ្លួនដោយសម្ងាត់ ឬ ដោយចងសម្ពន្ធភាពជាមួយអ្នកផ្សេងទៀតដើម្បីសម្រេចគោលដៅនោះ។ តាមសភាពធម្មជាតិ បើមនុស្សពីរនាក់ចង់បានរបស់មួយដូចគ្នា ហើយបែរជាមិនបានវិញនោះ អ្នកទាំងពីរអាចក្លាយជាសត្រូវនឹងគ្នា ហើយរិះរកមធ្យោបាយដើម្បីកម្ទេចគ្នាទៅវិញទៅមក។ បើសិនជាគ្មានអំណាចមួយសម្រាប់ឃាត់យាំងទេនោះ មនុស្សនឹងឋិតក្នុងសង្គ្រាមគ្រប់ពេលវេលា ហើយមុខជាទៅរកសេចក្តីវិនាស ពីព្រោះជាសង្គ្រាមឥតព្រំដែនហើយ ពុំអាចបញ្ចប់បានឡើយ។

**មនុស្សគឺជាឆ្កែចចកសម្រាប់មនុស្ស**

លោក ហាប្ស គឺជាទស្សនវិទូទីមួយម្នាក់ក្នុងចំណោមទស្សនវិទូជាច្រើន ដែលណែនាំឱ្យឃើញអំពីគំនិតនៃស្ថានភាពធម្មជាតិ។ ជាអ្នកដែលបានជញ្ជឹងគិតទៅលើគំនិតនយោបាយរបស់ អារីស្តូត លោក ហាប្ស ប្រឆាំងទៅនឹងទំនៀមទម្លាប់អារីស្តូតពីបុរាណដែលនិយាយថា តាមធម្មជាតិមនុស្សគឺជាសត្វសង្គម។ សម្រាប់លោក ហាប្ស មនុស្សគឺជាអ្នកដែលចេះសម្របរស់នៅក្នុងសង្គម មិនមែនសត្វធម្មជាតិជាយថាហេតុណាមួយទេ។ ស្ថានភាពធម្មជាតិ មិនត្រូវមានរួមបញ្ចូលនូវការពិពណ៌នាភាពពិតប្រវត្តិ សាស្ត្រណាមួយទេ ប៉ុន្តែគឺជាការរួមបញ្ចូលគំនិតច្នៃប្រឌិតដែលជាទ្រឹស្តី។ ប្រាកដណាស់ ស្ថានភាពធម្មជាតិមិនដែលមានទេពីការពិពណ៌នាភាពពិតដែលជាប្រវត្តិសាស្ត្រ តែវាមានសម្មិតិកម្មទស្សនវិជ្ជាដែលអាចឱ្យផលច្រើន នោះគឺការកសាងនូវគំនិតដែលសំដៅយល់នូវអ្វីដែលនាំមកឱ្យយើងនូវអត្ថិភាពសង្គម។ ស្ថានភាពនេះបង្ហាញនូវអ្វីដែលមនុស្សមាន បង្ហាញនូវភាពអរូបីដែលបង្កើតចេញពីអំណាចនយោបាយ ហើយជាវិបាកគឺច្បាប់នោះតែម្តង។ នៅក្នុងស្ថានភាពនេះ មនុស្សគឺត្រូវបានគ្រប់គ្រងដោយសភាវគតិនៃការអភិរក្សតែមួយគត់ដែលលោក ហាប្ស ហៅថា "សេចក្តីប្រាថ្នា"។ តែនៅក្នុងស្ថានភាពធម្មជាតិ មនុស្សគឺស្មើភាពគ្នាដែលមានន័យថា មនុស្សមានសេចក្តីប្រាថ្នាដូចៗគ្នា សិទ្ធិដូចៗគ្នាទៅលើគ្រប់វត្ថុទាំងអស់ និងលើគ្រប់មធ្យោបាយទាំងអស់ ទាំងតាមរយៈឧបាយកល ឬទាំងតាមសម្ព័ន្ធមិត្តដើម្បីឱ្យបានទៅដល់គោលប្រាថ្នារបស់ខ្លួន។ មនុស្សម្នាក់ប្រាថ្នាតាមធម្មានុរូបនូវអ្វីដែលល្អសម្រាប់ខ្លួនគេ។ ម្នាក់ៗសាកល្បងធ្វើរឿងល្អ និងម្នាក់គឺជាចៅក្រមតែម្នាក់នៃមធ្យោបាយសំខាន់ៗ ដើម្បីឱ្យបានដល់គោលដៅនៃសេចក្តីប្រាថ្នា។ ហេតុដូច្នេះហើយទើបបានជាញឹកញាប់ មនុស្សមាននិន្នាការចូលទៅក្នុងអធិករណ៍ពីមួយទៅមួយ ដើម្បីបាននូវអ្វីដែលគេគិតថាបានយុត្តិធម៌សម្រាប់ពួកគេ។

ស្ថានភាពធម្មជាតិ គឺជាស្ថានភាពនៃសង្គ្រាមរបស់គ្រប់គ្នាប្រឆាំងទៅនឹងគ្រប់គ្នា។ លោក ហាប្ស ចង់និយាយថា"មនុស្សគឺជាសត្វឆ្កែចចកសម្រាប់មនុស្ស"។ គាត់បង្កើតទ្រឹស្តីនយោបាយនិងអភិសមាចារ របស់គាត់ទៅលើមូលដ្ឋានអ្នកធម្មជាតិនិយម។ នៅក្នុងស្ថានភាពធម្មជាតិមនុស្ស គឺខ្វះនូវភាពល្អគ្រប់យ៉ាង គឺមនុស្សប្រៀបដូចជាសត្វដែលរស់នៅក្នុងច្បាប់ព្រៃ។ មនុស្សសោយរាជ្យនៅក្នុងច្បាប់ព្រៃដោយអំណាចអនាធិបតេយ្យនៃភាពចម្រុះបញ្ចូលគ្នានៃហ្វូងមនុស្ស។

ដោយមានសម្បទាពីកំណើតជាអ្នកមានហេតុផល (មានន័យថា ឥន្ទ្រីយក្នុងការគណនា និងគិតជាមុខ) មនុស្សបង្ការជាមុននូវភាពគ្រោះថ្នាក់ និងការវាយប្រហារ មុនពេលត្រូវគេវាយប្រហារ។ មនុស្សដែលខ្សោយបំផុតតែមានឧបាយកលអាចមានប្រៀបលើអ្នកខ្លាំង។ ហេតុនេះ មនុស្សម្នាក់ៗត្រូវបានបញ្ចុះបញ្ចូលឱ្យមានសមត្ថភាពមានប្រៀបលើអ្នកដទៃទៀតបាននិងមិនស្ទាក់ស្ទើរចំពោះការវាយប្រហារ ដើម្បីការពារទ្រព្យសម្បត្តិរបស់ខ្លួន។ សម្ព័ន្ធមិត្តដែលមិនឋិតថេរ ចងសម្ព័ន្ធគ្នាដើម្បីឱ្យមានប្រៀបលើបុគ្គលណាមួយ។ ប៉ុន្តែរៀវលែងតែជ័យជម្នះមិនអាចទទួលបាន

ទើបក្រុមអ្នកឈ្នះពួតដៃគ្នាដើម្បីប្រឆាំងអ្នកដទៃ ដើម្បីទទួលបានអត្ថប្រយោជន៍តែមួយពីទ្រព្យរបស់ឈ្លើយសឹក សត្រូវ។ សង្គ្រាមនេះគឺឃោរឃៅបំផុតរហូតដល់មនុស្សជាតិប្រឈមហានិភ័យទៅនឹងការលាយសាបសូន្យ។ ចំពោះអ្នកដែលនឹងគិតថា ទស្សនៈរបស់មនុស្សជាតិ គឺសុទិដ្ឋិនិយមលោក ហាប្ស ជំទាស់ថា ទោះបីនៅក្នុងស្ថានភាព សង្គមដែលមានច្បាប់ហើយក្ដី នគរបាលហើយក្ដី ចៅក្រមហើយក្ដី ប៉ុន្តែនៅក្នុងត្រង់ចំណុចសំខាន់នេះ យើងនៅតែ បិទហិបនៅផ្ទះរបស់យើងដោយខ្លាចទទួលរងនូវការលួចឆក់ប្លន់ដដែល។តែសភាពធម្មជាតិ គឺគ្មានច្បាប់ គ្មាន ចៅក្រម និងគ្មាននគរបាល ដែលនេះគឺជាសេចក្តីតានតឹងនៃសេចក្តីស្លាប់ ដែលកើតចេញពីវិសមភាពធម្មជាតិ ដែល ទទួលខុសត្រូវចំពោះសភាពសង្គ្រាម និងធ្វើការថ្លឹងថ្លែងទៅលើជីវិតគ្រប់គ្នាពីការគំរាមគំហែងមួយជាអចិន្ត្រៃយ៍។ សភាពនេះ គឺអាក្រក់បំផុត មិនអាចអនុញ្ញាតិ្តឱ្យមានវិបុលភាព ពាណិជ្ជកម្ម វិទ្យាសាស្ត្រ សិល្បៈ និងសង្គមបាន ឡើយ។ មនុស្សជាតិដែលរស់នៅដោយខ្លួនឯងដោយគ្មានសណ្តាប់ធ្នាប់សង្គម នឹងអាចបញ្ចប់ជីវិតដោយការលាយ សាបសូន្យ។ អ្វីដែលនឹងចេញមកជួយសង្គ្រោះមនុស្សនោះ គឺភាពភ័យខ្លាចនឹងការស្លាប់របស់មនុស្ស និងសភាវគិត នៃការសន្ទនាគ្នារបស់មនុស្ស។ មនុស្សយល់ថាដើម្បីដាក់ឱ្យមានការជំនួស គឺវាមិនមានដំណោះស្រាយដទៃទៀត ដែលចេញពីសភាពធម្មជាតិនោះទេ។ ប៉ុន្តែ សម្រាប់លោក ហាប្ស វិញ មិនមែនមានន័យថា មិនមានច្បាប់ធម្មជាតិ ក្រោយបង្កស់សម្រាប់បង្កើតសង្គមនោះទេ។ ផ្ទុយទៅវិញ វាមានច្បាប់ធម្មជាតិមួយដែលសរសេរចេញពីវិទ្យាសាស្ត្រ របស់យើង នោះគឺច្បាប់ហេតុផល។ ជម្រើសគ្រឹះទីមួយនៃធម្មជាតិ គឺថាត្រូវស្វែងរកសន្តិភាព ហើយត្រូវស្វែងរក ជំនួយនៃសង្គ្រាមតែក្នុងករណីដែលសន្តិភាពមិនអាចទទួលបាន។ ដើម្បីដល់ទីនោះលោក ហាប្ស និយាយថា ចាំបាច់ ត្រូវបោះបង់ចោលសិទ្ធិមួយចំនួនរបស់ពួកគេ។ នេះគឺជាការចូលអន្តរាគមន៍របស់ទ្រឹស្តីនៃកិច្ចសន្យា។ អ្វីដែលនឹង អនុញ្ញាតឱ្យឆ្លងពីធម្មជាតិទៅដល់សង្គម និងពីសង្គ្រាមទៅសន្តិភាពនោះគឺកិច្ចសន្យាដែលធ្វើឡើយរវាងបណ្តា ប្រធាននៃអធិបតេយ្យ។

### ៤.២.៤ សិទ្ធិពីធម្មជាតិ

ហាប្ស បាននិយាយថា មនុស្សគ្រប់គ្នាតាមធម្មជាតិមានសិទ្ធិស្មើៗគ្នា ដូចជាសិទ្ធិក្នុងការនិយាយ សិទ្ធិក្នុងការ គិត សិទ្ធិរស់នៅ សិទ្ធិធ្វើពាណិជ្ជកម្ម...។ តាមរយៈសិទ្ធិធម្មជាតិទាំងនេះ ពុំមានការបែងចែក ព្រំខ័ណ្ឌ ឬដែនកំណត់ អ្វីឡើយ។ ប៉ុន្តែផ្ទុយមកវិញ ក៏នៅមានភាពមិនស្មើគ្នាជាច្រើន ស្ទើរគ្រប់ទីកន្លែង រវាងអ្នកខ្លាំង និងអ្នកខ្សោយ រវាង អ្នកចេះ និងអ្នកមិនចេះ ...។ បន្ថែមលើសពីនេះទៅទៀត មនុស្សមានភាពមិនស្មើគ្នាខាងកម្លាំងកាយ បទពិសោធ ការវិភាគ ដែលជាហេតុធ្វើឱ្យមនុស្សពុំមានលក្ខណៈដូចគ្នា។ ឆ្លងតាមការបែងចែករបស់ ហាប្ស អំពីញាណសតិស្តីពី រូបកាយធម្មជាតិ មានញាណសតិផ្លូវចិត្ត និងញាណសតិផ្លូវកាយ ដែលមនុស្សអាចទាក់ទងគ្នាពីម្នាក់ទៅម្នាក់តាម ញាណសតិទាំងពីរ ដើម្បីសម្រេច បំណងរបស់គេ ដូចជាការយកញាណសតិទៅប្រើប្រាស់ទប់ទល់នឹងអំពើហិង្សា ឬការពារឧត្តមគតិ។ មនុស្សប្រើសិទ្ធិធម្មជាតិ ដើម្បីដោះស្រាយបញ្ហាលំបាកនានានៅក្នុងបញ្ហាសង្គមដែលដូចមាន បង្ហាញនៅក្នុងរដ្ឋធម្មជាតិ មនុស្សធ្វើការប្រយុទ្ធគ្នាតាមសមត្ថភាពពីធម្មជាតិរបស់គេ ដែលត្រង់នេះលោកហៅថា សង្គ្រាមប្រឆាំងគ្នាទាំងអស់។ នៅក្នុងធម្មជាតិពោរពេញទៅដោយការរំលោភសិទ្ធិគ្នាទៅវិញទៅមក ដូចនេះពួកគេគួរ តែដាក់បង្ហាញសិទ្ធិស្មើៗគ្នានោះឱ្យគេបានឃើញដោយផ្ទាល់។ ប៉ុន្តែមានផ្នែកផ្សេងគ្នា ចម្បងៗនៃសិទ្ធិក្នុងបំណង របស់បុគ្គលដោយលើកឡើងនូវការរៀបចំមួយដែលគ្រប់គ្រងដោយថ្នាក់ដឹកនាំដែលពោរពេញទៅដោយក្តីសង្ឃឹម ទៅអនាគត។ តាមទស្សនៈខាងលើនេះ មនុស្សមានសិទ្ធិគ្រប់ទីកន្លែង ហេតុនេះហើយទើបយើងឃើញថា អ្នក ខ្សោយ ខ្លាចអ្នកខ្លាំង ក៏ព្រោះតែអំណាចបុគ្គលមិនស្មើគ្នា ពីធម្មជាតិ។ សិទ្ធិធម្មជាតិបន្តពីសិទ្ធិនៅក្នុងសភាពផ្សេង គ្នាទូទៅនៃសកម្មភាពរបស់មនុស្ស ដែលជាហេតុធ្វើឱ្យមនុស្សខ្លាចគ្នាទៅវិញទៅមក។ ម្យ៉ាងទៀតសិទ្ធិក្នុងចំណង់ ធម្មជាតិរបស់មនុស្ស តែងតែសាហាវឃោរឃៅ និងរំលោភលើសិទ្ធិអ្នកដទៃ។ ធម្មជាតិមនុស្សគិតពីប្រយោជន៍ផ្ទាល់ ខ្លួនជាងអ្នកដទៃ ស្អប់អ្នកណាដែលយកចំណេញពីខ្លួន។ ហេតុដូចនេះ មនុស្សប្រឆាំងគ្នាតាំងពីការប្រើពាក្យសម្តី

ការប្រើ សញ្ញាជាភាសា ក្នុងបំណងដើម្បីទាញយកប្រយោជន៍ផង និងដើម្បីទំនាក់ទំនងធម្មតាក្នុងសង្គមផង។ ទោះយ៉ាងណាគេត្រូវតែប្រើកម្លាំង និងសិទ្ធិ មានឥទ្ធិពលលើសវីរៈគួបផ្សំនឹងសិទ្ធិពីធម្មជាតិរបស់គេ ដោយមិនរាប់បញ្ចូលទាំងចំណង់របស់មនុស្សដែលមានដូចគ្នានេះទេ។ តួយ៉ាងដូចជាពេលដែលមនុស្ស ម្នាក់ត្រូវការវត្ថុមួយ ហើយមានមនុស្សផ្សេងទៀតគេត្រូវការវត្ថុនោះដែរ ក្នុងករណីនេះគេទាំងពីរខាង ត្រូវរកវិធីដើម្បីយកឈ្នះលើគ្នា។

រួមសេចក្តីមក សិទ្ធិធម្មជាតិថ្មីដ្បិតតែវាគ្មានគោលការណ៍ច្បាស់លាស់ តែវាមានព្រំដែនកំណត់របស់វាគឺមានស្មារតីរបស់មនុស្សជាអ្នកកំណត់ ឯសិទ្ធិធម្មជាតិមិនអាចដាក់កម្រិតបានទេ តែបើមិនចេះប្រើសិទ្ធិនេះវានឹងនាំទៅដល់សង្គមអនាធិបតេយ្យ។ ផ្ទុយទៅវិញ បើបង្កើតច្បាប់សង្គមដែលកំណត់សិទ្ធិបុគ្គល វាស្របនឹងឆន្ទៈរបស់មនុស្សតែមួយក្រុម។ ប៉ុន្តែយ៉ាងណា ការបង្កើតឋានានុក្រមមួយ ច្បាស់លាស់ ជារបៀបវារៈរៀបចំសង្គមដែលពោរពេញទៅដោយភាពមានសេរីភាព និងភាពរុងរឿង។

តណ្ហារបស់មនុស្សដូចជាតណ្ហារបស់អ្នកខ្លាំងមួយក្រុម គេរីករាយនឹងចំណង់បានសម្រេចរបស់គេ សម្រាប់តែក្រុមរបស់គេយ៉ាងខ្លាំង ដូចនេះវាហាក់ដូចជាមិនសមហេតុផលសោះ ក្នុងខណៈដែលចំណង់ ទាំងនោះប៉ះពាល់ដល់ការរស់នៅរបស់អ្នកឯទៀត រីឯអ្នកខ្សោយអាចនឹងបង្កសង្គ្រាមជាមួយអ្នកខ្លាំងដោយប្រើគ្រប់យុទ្ធវិធី។ វាចាំបាច់ណាស់ថាសិទ្ធិធម្មជាតិធ្វើឱ្យមនុស្សមានឆន្ទៈ និងចំណង់ ដែលដើរស្របនឹងការប៉ងប្រាថ្នារបស់គេ ហើយក៏បញ្ចៀសនូវអ្វីដែលមានគ្រោះថ្នាក់ និងការឈឺចាប់នានា។ បើមនុស្សស្លាប់ទាំងឥទ្ធិពលផ្លូវកាយ និងចិត្តក៏ត្រូវបាត់បង់ដែរ។ វានឹងប្រឆាំងហេតុផលដែលថា មនុស្សធ្វើអ្វីៗបានគ្រប់យ៉ាងដើម្បីបម្រើបំណងសម្រាប់រូបគេ ទោះបីជាមរណៈភាពនោះ ឬអ្វីដែលធ្វើឱ្យ គេឈឺចាប់ក៏ដោយ។ ម្យ៉ាងទៀតវាដើរស្របនឹងហេតុផលមួយថា មនុស្សហៅថា **សិទ្ធិ** ដែលតាមរយៈសិទ្ធិនោះ ជាការមិនរិះគន់សេរីភាពនៃការប្រើអំណាច និងលទ្ធភាពធម្មជាតិផ្ទាល់ខ្លួន។ ហេតុនេះហើយសិទ្ធិធម្មជាតិដែលមនុស្សគ្រប់រូបអាចបម្រើជីវិតផ្ទាល់របស់គេបាន ពុំមែនសុទ្ធតែទទួលលទ្ធផលល្អទាំងអស់ទេ ហើយមនុស្សអាចជួបឥទ្ធិពលមិនល្អពីការប្រើសិទ្ធិនោះ។

*មនុស្សមានសិទ្ធិរហូតដល់ចប់ជីវិត ហើយទីបញ្ចប់នៃជីវិត មិនអាចទទួលបានដោយគ្មានមធ្យោបាយដែលថាបើគ្មានវត្ថុចាំបាច់ទេ ក៏គ្មានភាពចាំបាច់សម្រាប់ទីបញ្ចប់នៃជីវិតដែរ។ វាមិនមែនជាផលវិបាកដែលវាមិនប្រឆាំងនឹងវិចារណញ្ញាណ។ ហេតុដូចនេះសិទ្ធិសម្រាប់មនុស្សម្នាក់ គឺបម្រើបានតែខ្លួនគេម្នាក់ប៉ុណ្ណោះ។*

ដូចគ្នានេះដែរ មនុស្សគ្រប់រូបដោយផ្អែកលើសិទ្ធិធម្មជាតិ វិនិច្ឆ័យខ្លួនឯងថាមានសារៈប្រយោជន៍ គ្រប់ពេលវេលា ហើយអាចដោះស្រាយបញ្ហាបានយ៉ាងច្រើន និងចៀសផុតពីគ្រោះថ្នាក់ ឬទុក្ខលំបាក នានា។ វាជាលក្ខណៈស្មើគ្នាមួយថា ប្រសិនបើមានមនុស្សចេះដាក់ទោសខ្លួនឯង ពេលនោះមានលក្ខណៈសមរម្យណាស់ ដែលគួរដាក់ទោសលើអ្នកដទៃឱ្យដូចខ្លួនទទួលទោសផងដែរ។ ការសម្រេចចិត្តរបស់មនុស្សតាមសិទ្ធិធម្មជាតិ វាបម្រើឱ្យផលប្រយោជន៍បុគ្គល ដូចនេះរាល់ឥទ្ធិ ពលកម្លាំង ពុទ្ធិ និងទង្វើរបស់មនុស្ស គឺពិតជាបម្រើផលប្រយោជន៍ដល់ខ្លួនក៏ព្រោះតែមនុស្សគ្រប់គ្នា មានសិទ្ធិស្មើគ្នា។

### ៤.២.៥ កិច្ចសន្យាសង្គម

មនុស្សនៅក្នុងរដ្ឋធម្មជាតិនឹងត្រូវតែផ្តល់សិទ្ធិមួយចំនួនរបស់គេ ដើម្បីបង្កើតការព្រមព្រៀងមួយនៅក្នុងសង្គមស៊ីវិល ដែលមនុស្សត្រូវលះបង់ផ្នែកខ្លះនៃសិទ្ធិដោយស្ម័គ្រចិត្តទៅឱ្យមនុស្សឯទៀត ឬទៅឱ្យអ្នកដឹកនាំ។ វាជាកិច្ចព្រមព្រៀងមួយរវាងបុគ្គល និងអ្នកផ្សេងទៀត ឬអ្នកនោះជាអ្នកដឹកនាំ ប៉ុន្តែកិច្ច សន្យានេះត្រូវតែជាការទទួលខុសត្រូវខាងសីលធម៌។ ហេតុនេះអ្វីៗដែលផ្ទុយនឹងមនសិការ ពោលគឺធ្វើ ផ្ទុយនឹងអ្វីដែលគេបានសន្យារួចមកហើយនោះជាអំពើបាបកម្ម ដែលភាគីនេះត្រូវទទួលទណ្ឌកម្មពីអ្នកដឹកនាំ។ មានគោលការណ៍ពីរលេចចេញយ៉ាងច្បាស់នៅក្នុងកិច្ចសន្យានេះដែល ទី១ គឺភាគីកិច្ចសន្យាជាបុគ្គលដែលបានសន្យាជាមួយនឹងភាគីម្ខាងទៀតថា នឹងប្រគល់

សិទ្ធិរបស់គេទៅតាមកិច្ចព្រមព្រៀង ដើម្បីគ្រប់គ្រងខ្លួនគេ តាមដែលបានចែងក្នុងកិច្ចសន្យា ចំពោះអ្នកដឹកនាំមិនមានកិច្ចសន្យាជាមួយប្រជា ពលរដ្ឋទេ។ ហើយម្យ៉ាងទៀតថ្នាក់ដឹកនាំ មានអំណាចយ៉ាងពេញលេញក្នុងដៃដើម្បីគ្រប់គ្រង។ អ្នកដឹកនាំគ្មានវិធីសមគួរសម្រាប់ធ្វើជាអ្នកដឹកនាំ ដោយធ្វើកិច្ចសន្យាជាមួយប្រជាពលរដ្ឋ។ ទី២ ហាប្សបាន អះអាងថា ថ្នាក់ដឹកនាំអាចជាមនុស្សម្នាក់ ឬមួយក្រុម តាមការស្នើសុំនៅក្នុងទ្រឹស្តីដែលយ៉ាងហោចណាស់តាមការមើលឃើញរបស់គេ គឺមិនត្រូវបានគេផ្តល់អត្តសញ្ញាណនៅក្នុងទម្រង់ពិសេសណាមួយ ក្នុងរដ្ឋាភិបាល។ តាមពិតនេះជាកិច្ចសន្យាដែលបានចែងនៅពេលមនុស្សយល់ព្រមប្រគល់សិទ្ធិខ្លះរបស់គេទៅឱ្យភាគីម្ខាងផ្សេងទៀតពិសេសគឺដើម្បីកំណត់សិទ្ធិខ្លួនឯងផង។ ក្នុងករណីនេះថ្នាក់ដឹកនាំ មិនគ្រាន់តែមានតួនាទីជំនួសឱ្យប្រជាពលរដ្ឋប៉ុណ្ណោះទេ ថែមទាំងជាតំណាងឱ្យឆន្ទៈរបស់ប្រជាពលរដ្ឋ ទៀតផង ត្រង់នេះហើយដែលជាការបញ្ជាក់អះអាងពីអត្តសញ្ញាណរវាងឆន្ទៈរបស់អ្នកដឹកនាំ និងប្រជា ពលរដ្ឋសាមញ្ញ។ ម្យ៉ាងវិញទៀត មនុស្សដែលស្ថិតនៅជាភាគីនៃកិច្ចសន្យា ទោះតាមរយៈបុគ្គល ឬរដ្ឋា ភិបាលនៅក្នុងលក្ខខ័ណ្ឌនៃមនុស្សដែលរស់នៅដោយគ្មានរដ្ឋាភិបាល ត្រង់នេះហើយទើប ហាប្ស ហៅថា រដ្ឋធម្មជាតិ ប្រសិនបើគ្មានសេចក្តីត្រូវការសម្រាប់មនុស្សរស់នៅដោយគ្មានកិច្ចសន្យារឿងនោះវានាំទៅ ដល់ការបង្កើតសង្គ្រាម។ ជារួមកិច្ចសន្យាស្តែងពីរូបភាពគឺៈ កិច្ចសន្យាមានលក្ខណៈជាសមាគមដែលបុគ្គលទាំងឡាយបានសម្រេចចិត្តថាត្រូវតែប្រមូលផ្តុំគ្នាដើរតាមឆន្ទៈទាំងឡាយរួមបញ្ចូលមកជាឆន្ទៈតែមួយដូចគ្នា និងកិច្ចសន្យានៅក្រោមបង្គាប់ ដែលក្នុងនោះបុគ្គលទាំងឡាយបានលះបង់ប្រគល់ទៅឱ្យបុគ្គលម្នាក់ ឬច្រើនក្នុងចំណោម បុគ្គលទាំងឡាយរបស់ខ្លួន ដោយប្តូរយកមកវិញនូវ ការធានា សន្តិសុខផ្ទាល់។

ហាប្ស អះអាងថា អ្នកដឹកនាំគឺជាអ្នករស់នៅផុតពីចំណងនៃកិច្ចសន្យា ហើយជាងនេះទៅទៀត គេ មិនមែនជាភាគីនៃកិច្ចសន្យាទេ។ ភាពជាអ្នកដឹកនាំនៅក្នុងកិច្ចសន្យាសង្គម គឺមិនត្រូវបានគេបង្កើតឡើងនូវសង្គមទាំងមូលឱ្យទៅជារដ្ឋទេ ពួកទាំងនោះជាអ្នកដឹកនាំពិតៗ ហើយមិនអាចផ្លាស់ប្តូរតំណែង បានឡើយ។

លោក ហាប្ស អះអាងថា *"កិច្ចសន្យាសង្គម មិនអាចដាក់ការកំណត់លើអ្នកដឹកនាំទេ"*។

ទោះយ៉ាងណា កិច្ចសន្យាសង្គម គឺជាកិច្ចព្រមព្រៀងរវាងភាគីនៃកិច្ចសន្យាទាំងឡាយនៅក្នុង សហគម ដែលមនុស្សយល់ព្រមបង្កើតកិច្ចសន្យាជាមួយអ្នកដទៃ ដើម្បីបញ្ចៀសឱ្យផុតពីជីវិតនៅក្នុងរដ្ឋ ធម្មជាតិដែលពោរពេញទៅដោយសង្គ្រាមប្រឆាំងគ្នាទាំងអស់។ តាមកិច្ចសន្យានេះ គេបង្កើតឡើងដោយស្ម័គ្រចិត្ត ពុំមានប្រើអំពើហិង្សាណាមួយ ដើម្បីល្មើសនឹងកិច្ចសន្យារបស់ពួកគេ ចំណែកឯមនុស្ស ក៏សុខចិត្តលះបង់សិទ្ធិមួយចំនួនរបស់គេទៅឱ្យភាគីម្ខាងទៀតនៃកិច្ចសន្យាផងនិងឱ្យទៅអ្នកដឹកនាំផង។ អាស្រ័យដោយកិច្ចសន្យាពុំមានការបង្ខិតបង្ខំ ហេតុនេះកិច្ចសន្យាសង្គម គឺជាកាតព្វកិច្ចផ្នែកសីលធម៌ ដែលកាតព្វកិច្ចនោះភាគីត្រូវទទួលខុសត្រូវចំពោះអ្វីដែលគេបានសន្យាក្រោមលក្ខខណ្ឌសង្គម ដែលស្ថិតនៅលើផលប្រយោជន៍ផ្ទាល់ និងភាពម្ចាស់ការនៃភាគីកិច្ចសន្យា។ ចំពោះ ហាប្សគ្រប់ចំណុចនៅក្នុងទ្រឹស្តីកិច្ចសន្យាសង្គម គឺដើម្បីអះអាងថា មានប្រភេទខ្លះនៃកិច្ចព្រមព្រៀងរវាងអ្នកដឹកនាំ និងអ្នកដឹក នាំ ដែលអាចពេលខ្លះល្មើសនឹងកិច្ចសន្យា អំពើបែបនោះបានចាកផុតពីតួនាទីជាអ្នកដឹកនាំផង និងផុតពីកាតព្វកិច្ចរបស់ខ្លួននៅក្នុងកិច្ចសន្យាសង្គមផង។

### **៤.២.៦ សង្គមស៊ីវិល**

ការរស់នៅប្រមូលផ្តុំគ្នា ជាសង្គមដែលសម្បូរទៅដោយបញ្ហាជាច្រើនរាប់មិនអស់ ក្នុងកិច្ចការដោះស្រាយជូនទាំងសេចក្តីសុខ និងសុភមង្គលសង្គម។ នៅក្នុង សង្គម ដែល ហាប្ស បានិយាយគឺជារដ្ឋដែលមានច្បាប់។ លោកពោលថា មនុស្សគ្រប់រូបត្រូវតែគោរពច្បាប់ក្រោមកិច្ចសន្យាសង្គម។ ច្បាប់មានអត្ថិភាពនៅពេលដែលមានអ្នកគ្រប់គ្រងច្បាប់ និងមានអ្នកគោរពច្បាប់ ហើយច្បាប់នោះស្ថិតនៅពី លើថ្នាក់ដឹកនាំ។ វានឹងច្បាស់ជាងនេះទៅទៀតថា ទោះបីនៅក្នុងរដ្ឋធម្មជាតិ មនុស្សក៏ប្រកាន់ការគោរព ច្បាប់ធម្មជាតិ ហើយច្បាប់ធម្មជាតិត្រូវគេអនុវត្តន៍យ៉ាងពាសពេញនៅក្នុងរដ្ឋធម្មជាតិ។ ប៉ុន្តែក្រោយពី បានបង្កើតអ្នកដឹកនាំ ច្បាប់បានប្រគល់ឆន្ទានុសិទ្ធិឱ្យទៅអ្នកដឹកនាំ

ហើយពេលនោះក៏មានបទបញ្ញត្តិ ស្របច្បាប់ ពិព្រោះថា នៅពេលដែលមានគោលការណ៍នៃច្បាប់ដែលអំណាចនានាត្រូវបានអនុវត្តន៍ ពេលនោះត្រូវបានគេចាត់ទុកជាច្បាប់មជ្ឈការ។ ហប្ស បានិយាយថា កិច្ចសន្យា ជា **ពាក្យក្នុងអារម្មណ៍** ហើយលោកបានផ្ដល់នូវលក្ខណៈច្បាប់តាមរយៈបទបញ្ជារបស់អ្នកដឹកនាំ និងបានបង្កើតនូវចំណុចបន្ថែមថានឹងគ្មានច្បាប់អយុត្តិធម៌ទេ។ តាមទស្សនៈនេះ បង្ហាញថាអ្វីៗដែលវាពិតត្រឹមត្រូវ ហើយសីលធម៌ចាប់ផ្ដើមជាមួយអ្នកដឹកនាំ។ ដូច្នេះវានឹងគ្មានគោលការណ៍នៃយុត្តិធម៌ ឬសីលធម៌ ដែលកំណត់និង បន្តពីសកម្មភាពថ្នាក់ដឹកនាំទេ។ មានតែច្បាប់នៅក្នុងដៃអ្នកដឹកនាំទេ ដែលស្ថិតនៅក្នុងលក្ខខណ្ឌមួយ ដែលមនុស្សគ្រប់គ្នាប្រតិបត្តិតាមច្បាប់ ក្រោមកិច្ចព្រមព្រៀងរវាងពលរដ្ឋ និងពលរដ្ឋដូចគ្នា និងពលរដ្ឋជាមួយអ្នកដឹកនាំរដ្ឋ។

នឹងគ្មានច្បាប់ណាអយុត្តិធម៌ទេៈ Hobbes បានផ្ដល់ហេតុផលពីរយ៉ាងចំពោះចំណុចនេះថា នៅពេលមានអ្នកដឹកនាំច្បាប់និងមានអ្នកអនុវត្តន៍ច្បាប់ ពេលនោះវានឹងមានច្បាប់ គ្មានទេច្បាប់អយុត្តិធម៌។ ទី១ ដោយសារតែយុត្តិធម៌ មានន័យថា ការគោរពច្បាប់។ នេះជាហេតុផលទី១ ដែលថាហេតុអ្វីបានជាយុត្តិធម៌មានអត្ថិភាព តែពេលក្រោយមានច្បាប់ត្រូវគេបង្កើត ហើយមិនអាចធ្វើជានិម្មិតសញ្ញាសម្រាប់សម្គាល់ច្បាប់អនុវត្ត។ ទី២ ពេលអ្នកដឹកនាំបង្កើតច្បាប់ វាក៏ដូចជាប្រជាពលរដ្ឋបានបង្កើតច្បាប់ដែរ។ ហេតុនេះអ្វីដែលគេបានព្រមព្រៀងនៅក្នុងកិច្ចសន្យា មិនមែនជារឿងអយុត្តិធម៌ទេ។ លក្ខខណ្ឌមួយផ្សេងទៀត គឺជាច្បាប់ធម្មជាតិ។ តាមរយៈច្បាប់នេះហប្ស និយាយថា មនុស្សអនុវត្តន៍កិច្ចព្រមព្រៀងតាមអ្វីដែលគេបានបង្កើត ហើយអ្វីដែលជាការគោរពនោះជាប្រភពនៃយុត្តិធម៌។

ទោះយ៉ាងណាក៏ដោយ ដើម្បីថែរក្សាកិច្ចសន្យាដែលគេបានយល់ព្រមថាគោរពតាមមេដឹកនាំគឺជាសារជាតិនៃយុត្តិធម៌របស់ហប្ស។ ការណ៍នេះផ្ដល់ភស្តុតាងថា ហប្ស ចង់វែកញែកថា ប្រសិនបើច្បាប់មានន័យថា ជាបទបញ្ជារបស់អ្នកដឹកនាំ ហើយម្យ៉ាងទៀត បើយុត្តិធម៌មានសេចក្ដីថា ជាការតម្រូវ ឱ្យគោរពតាមច្បាប់ នោះនឹងគ្មានច្បាប់អយុត្តិធម៌ទេ។ បើពលរដ្ឋមិនយល់ព្រមគោរពតាមកិច្ចសន្យាដែលគេបានបង្កើតជាមួយពលរដ្ឋដូចគ្នា ឬជាមួយនឹងអ្នកដឹកនាំ វានឹងរុញច្រានសង្គមឱ្យទៅដល់ភាព អនាធិបតេយ្យ។ ក្រៅពីនេះ បើថ្នាក់ដឹកនាំប្រព្រឹត្តិអំពើទុច្ចរិត នោះជាបញ្ហារវាងថ្នាក់ដឹកនាំជាមួយនឹង អាទិទេព។ ហេតុនេះ ដើម្បីកុំឱ្យមានសង្គមអនាធិបតេយ្យ លោកបានបន្ទន់ឥរិយាបថទៅកាន់សាសនា រីឯវិហារគ្រីស្តសាសនាជាអ្នកទ្រទ្រង់រដ្ឋ។ ហប្ស បានចាត់ទុកថាអ្នកដឹកនាំមិនមែនជាអ្នកពិគ្រោះសុវត្ថិភាពឥតន័យទេ តែជាកាតព្វកិច្ចសីល ធម៌តឹងរ៉ឹង ហើយកាតព្វកិច្ចនោះនាំទៅដល់ថ្នាក់ដឹកនាំតាមច្បាប់ធម្មជាតិ **គ្មានទីបញ្ចប់** ដែលសេចក្ដីស្មោះស្ម័គ្រត្រូវបានគេថែរក្សា។ ជាសង្គមដែលត្រូវបានបង្កើតឡើងដោយពលរដ្ឋដូចគ្នា និងពលរដ្ឋជាមួយអ្នកដឹកនាំ។ ពលរដ្ឋគ្រប់រូបមានតួនាទីរៀបចំគោរពតាមបទបញ្ជារបស់ថ្នាក់ដឹកនាំដែលគេយល់ព្រមតាមកិច្ចសន្យាសង្គម។

អធិបតេយ្យភាពមិនបានកំណត់តាមកិច្ចសន្យាទេៈ ទឡ្ហីករណ៍របស់ ហប្ស ដែលថាអធិបតេយ្យភាពមិនត្រូវបានកំណត់ដោយកិច្ចសន្យា ផ្អែកលើភាពពិតនៃការគ្រប់គ្រងដោយបានបង្កើតឡើងនូវកិច្ច សន្យាមួយតាមបំណងក្នុងអនាគតនៅក្នុងរដ្ឋធម្មជាតិ។ តាមភាពខុសគ្នាពីនេះ មនុស្សគួរធ្វើកិច្ចសន្យាជាមួយគ្នានៅក្នុងសង្គមស៊ីវិល ចំណែកឯនៅក្នុងសង្គមស៊ីវិល វាជាការសមហេតុសមផលណាស់ ដែល មេដឹកនាំបង្កើតកិច្ចសន្យាជាមួយពលរដ្ឋ ព្រោះដើម្បីឱ្យមាននិរន្តភាពក្នុងការរស់នៅក្នុងសង្គមតែមួយ ដោយចៀសវាងនូវការបែងចែកនូវវណ្ណៈ អំណាចខ្លាំងហួសហេតុពេក។

គ្មានមនុស្សណាម្នាក់នៅក្នុងរដ្ឋធម្មជាតិ ក៏ដូចជាសង្គមស៊ីវិលអាចប្រព្រឹត្តិខុសពីការគោរពតាមកិច្ចសន្យាទេ ព្រោះអ្នកដែលប្រព្រឹត្តិខុសគេខ្លាចចំពោះការមិនលេចឡើងកិច្ចសន្យាដែលបាត់បង់ប្រព័ន្ធអនុវត្តច្បាប់។ កិច្ចសន្យាមួយដែលកំណត់ពីអធិបតេយ្យភាពនៅក្នុងរដ្ឋធម្មជាតិគឺជាការពិតថា មិនមែនជាកិច្ចសន្យាមានសុពលភាពមួយនោះទេ។ ដូចនោះវាទុកឱ្យសង្គមស៊ីវិល គ្រាន់តែជាសង្គម មួយនៅក្នុងច្បាប់តែមិនទាន់មានសន្តិភាព ប៉ុន្តែមេដឹកនាំអាចបង្កើតកិច្ចព្រមព្រៀងជាមួយប្រជាពលរដ្ឋ គឺដើម្បីកំណត់នូវអធិបតេយ្យភាពនៃសង្គម។

Hobbes បានគិតថាមេដឹកនាំដែលបង្កើតកិច្ចសន្យាមួយនេះ អាចយល់ច្រឡំលើធម្មជាតិនៃ អធិបតេយ្យភាពរបស់ខ្លួនឯង។ ការរស់នៅតាមឆន្ទៈសេរី គឺជាសេរីភាពរបស់មនុស្សដែលផ្តល់ដោយ ធម្មជាតិលើមនុស្សគ្រប់រូប។ រាល់ការជ្រើសរើសនៅក្នុងរដ្ឋធម្មជាតិ ជាការជ្រើសរើសបុគ្គល។

មនុស្សក្នុងសង្គមស៊ីវិលត្រូវគេតម្រូវឱ្យគោរពច្បាប់ដែលតាក់តែង និងអនុវត្តដោយខ្លួនឯង។ ការជ្រើសរើសមនុស្សម្នាក់ ឬមនុស្សមួយក្រុមឱ្យធ្វើជាមេដឹកនាំមនុស្សបានបង្កើតការដឹកនាំរបស់ខ្លួនតាមផលចំណេញពីកិច្ចសន្យា ប៉ុន្តែមិនមែនជាភាគីនៃកិច្ចសន្យាទេ។ សង្គមស៊ីវិលមួយដើរតួនាទីជាការប្រមូលផ្តុំពីថ្នាក់ដឹកនាំដែរ គួបផ្សំនឹងការជួយជ្រោមជ្រែងពីថ្នាក់លើ និងថ្នាក់ក្រោមទាំងអស់គ្នា លុះណាតែធ្វើឱ្យមានសុវត្ថិភាពសង្គម។ នៅក្នុងសង្គមមួយបែបនេះ ពលរដ្ឋអាចកំណត់នូវអំណាច របស់អ្នកដឹកនាំ ហើយថ្នាក់ដឹកនាំក៏គួរចេះវិនិច្ឆ័យលើខ្លួនឯង ឬក៏ត្រូវសម្រេចក្តី តាមអ្វីដែលធ្វើឡើងដោយតាមប្រសិទ្ធភាពនៃមេដឹកនាំផ្សេងទៀត។ អ្នកដឹកនាំអាចបដិសេធថា គេបានល្មើសនឹងកិច្ចសន្យា នៅពេលដែលគូប្រជែងជាមេដឹកនាំដូចគ្នាចោទប្រកាន់ថាបានប្រព្រឹត្តផ្ទុយនឹងកិច្ចសន្យា ព្រោះថានោះ ជាវិធីតែមួយគត់សម្រាប់មេដឹកនាំប្រឆាំងដើម្បីសម្រេចនូវសេចក្តីត្រូវការផ្តាច់ការរបស់ខ្លួន។

### ៤.២.៧ ទ្រឹស្តីអធិបតេយ្យភាព និងដាច់ខាតនិយម ( Souveraineté et absolutisme )

### ៤.២.៧.១ អធិបតេយ្យភាពដាច់ខាត

យើងបានឃើញថា ដើម្បីអភិរក្សជីវិតរបស់ពួកគេ និងដើម្បីដើរឆ្ពោះទៅរកសន្តិភាព មនុស្សបដិសេធដោយខ្លួនឯងនូវស្ថានភាពសង្គ្រាម ហើយជ្រើសរើសអាជ្ញាធរខ្ពង់ខ្ពស់មួយ គឺអធិបតេយ្យ។ អធិបតេយ្យទទួលមរតកពីអ្វីៗទាំងអស់ដែលបុគ្គលឯកជនមាននៅក្នុងស្ថានភាពធម្មជាតិ ដើម្បីឱ្យក្លាយជាអ្នកកាន់កាប់ផ្តាច់មុខនូវអំណាច។ Le Léviathan កាន់កាប់នូវអំណាចដាច់ខាត និងគ្មានព្រំដែនមួយជាថ្នូរទៅនឹងសន្តិភាពស៊ីវិលដែលនាំមកដោយបុគ្គលឯកជន។ សិទ្ធិនៃអធិបតេយ្យ ជាបុគ្គលក្តី ឬជាសមូហភាពក្តីគឺតាមការចាំបាច់ត្រូវតែគ្មានព្រំដែនកំរិតព្រោះសិទ្ធិដែលបុគ្គលម្នាក់ៗផ្ទេរឱ្យអធិបតេយ្យគឺគ្មានព្រំដែនកំណត់។ ដូចនេះ អធិបតេយ្យ គឺជាអំណាចអធិបតេយ្យដាច់ខាតមួយ និងមិនអាចបែងចែកបានថែមទាំងមិនអាចអត់អាស្រ័យបានដូចជាអធិបតេយ្យរបស់លោក ហ្សង់ បូឌាំងឡើយ។ លោក ហប្ស គាំទ្រភាពដាច់ខាតនិយម និងមិនគាំទ្រការធ្វើតាមអំណាចចិត្ត និងអំណាចផ្តាច់ការនិយម។

នៅក្នុងការបកស្រាយសាសនាទំនៀមទម្លាប់នៃអំណាចព្រះមហាក្សត្រ សញ្ញាណនៃអំណាចដាច់ខាតមានន័យថា ស្តេចភ្ជាប់ខ្លួនផ្ទាល់ទៅនឹងអាទិទេពដែលគាត់គ្រាន់តែរាយការណ៍ទៅអាទិទេព ដែលគាត់គឺជាវរៈសេនីឯក ឬជាអ្នកតំណាងរបស់អាទិទេព និងដែលចេញដំណើរពីអំណាចទាំងអស់ទៅរកអធិបតេយ្យភាពរបស់អាទិទេព។ ប៉ុន្តែករណីនៃអំណាចទាំងស្រុងរបស់លោក ហប្ស គឺខុសគ្នាទាំងអស់។ អំណាចលែងជារបស់មនុស្សខ្លាំងដែលផ្តល់អត្ថិភាព និងផ្តល់អត្ថន័យអត្ថិភាពនៃអំណាចដាច់ខាតដែលតំណាងឱ្យមនុស្សខ្លាំងទៀតហើយ។ ផ្ទុយទៅវិញគឺជាមនុស្សគ្មានអំណាចដែលបង្កើតអំណាចដើម្បីកែបំបាត់ភាពអន់ខ្សោយរបស់ខ្លួន។ អំណាចផ្តាច់ការរបស់លោក ហប្ស លែងជាអំណាចនៃអ្នកតំណាងរបស់អាទិទេពទៀតហើយ តែជាអំណាចរបស់មនុស្ស។

### ៤.២.៧.២ ទម្រង់ផ្សេងៗគ្នានៃរដ្ឋាភិបាល

លោកទទួលស្គាល់ទម្រង់ជាច្រើនរបស់រដ្ឋាភិបាល( រាជាធិបតេយ្យ ប្រជាធិបតេយ្យ ឬអភិជនាធិបតេយ្យ ) ប៉ុន្តែមិនកាច់បំបាក់ចោលសេចក្តីស្រឡាញ់ខ្លាំងបំផុតរបស់គាត់ទៅលើរាជាធិបតេយ្យដែលកាន់កាប់អំណាចដោយមានប្រសិទ្ធភាពបំផុតនោះទេ។ នៅក្នុងរបបរាជាធិបតេយ្យ អត្ថប្រយោជន៍ផ្ទាល់ខ្លួនរបស់រដ្ឋាភិបាលមានឡើងព្រមគ្នាជាមួយនឹងប្រយោជន៍សាធារណៈ។វាមិនមានភាពអយុត្តិធម៌ទេក្រៅអំពីច្បាប់ ហើយវាមានរឿងល្អបន្តិចបន្តួចនៅក្នុងច្បាប់ដែលអាក្រក់។ លោក ហប្ស ញែកយ៉ាងច្បាស់អំពីរាជាធិបតេយ្យ អភិជនាធិបតេយ្យ និងប្រជាធិបតេយ្យ។ ផ្ទុយទៅវិញ គាត់ទាត់ចោលទាំងស្រុងនូវរដ្ឋាភិបាលចម្រុះទាំងអស់។ គាត់ប្រានចោលគំនិតបុរាណតាំងពីបុរាណកាលដែលថាវាមានទម្រង់បរិសុទ្ធមួយ និងទម្រង់ដែលមានភាពអន់ថយមួយសម្រាប់ប្រភេទនីមួយៗនៃរដ្ឋាភិបាល។

សង្គមទាំងអស់ចាប់ផ្តើមតាមការចាំបាច់ ដោយរបបប្រជាធិបតេយ្យ។ មានន័យថាជាសភារបស់អ្នកដែលស្ថិតនៅក្នុងស្ថានភាពធម្មជាតិព្រមព្រៀងគ្នាជាឯកច្ឆ័នដើម្បីបង្កើតកិច្ចសន្យាសង្គមមួយនិងព្រមចំណុះក្រោមការសម្រេចចិត្តនៃមតិភាពច្រើន។ ប្រព័ន្ធផ្តួចផ្តើមដំបូងនេះអាចបំលែងជាអភិជនាធិបតេយ្យ ឬរាជាធិបតេយ្យអាស្រ័យតាមអាជ្ញាធរដែលសភាអធិបតេយ្យព្រមប្រគល់អំណាចរបស់ខ្លួនឱ្យដែលមានអំណាចរាជាធិបតេយ្យ ឬអភិជនាធិបតេយ្យ។ តែការព្រមប្រគល់អំណាចឱ្យនេះ មិនត្រូវធ្វើឡើយដោយកិច្ចសន្យាទេ។ ចាប់ពីពេលព្រមប្រគល់អំណាចឱ្យមក គឺសភាបានក្លាយទៅជាពហុភាពនៃប្រជាន និងជាអាជ្ញាធរដែលទទួលបាននូវអធិបតេយ្យភាពភ្លាម។ ប្រសិនបើមានកិច្ចសន្យាជាមុខ យើងនឹងនិយាយអំពីរដ្ឋាភិបាលដែលទទួលប្រតិភូកម្ម មិនមែនជារដ្ឋាភិបាលដែលអធិបតេយ្យទេ។ ជាគោលការណ៍អាជ្ញាធរអធិបតេយ្យមិនងាយស្លាប់ទេ វៀរលែងតែម្ចាស់របស់ពួកគេស្លាប់ ឬក៏បោះបង់វាចោលដោយមិនចាត់តាំងឱ្យមានអ្នកទទួលមរតកបន្ត។ ក្នុងសម្មតិកម្មនេះ វាមានការវិលត្រឡប់ទៅរកស្ថានភាពធម្មជាតិវិញដែរ។ សម្រាប់លោក ហប្ស រាជាធិបតេយ្យ គឺទម្រង់រដ្ឋាភិបាលដែលល្អបំផុត។ តែទោះជាល្អយ៉ាងនេះក្តីក៏នៅមានអាក្រក់ដែរ ប៉ុន្តែរឿងអាក្រក់ៗទាំងនេះគឺងាយស្រួលបង្ហូរឱ្យគេដឹងនៅក្នុងសង្គមប្រជាធិបតេយ្យ។ ដោយសារតែប្រជាពលរដ្ឋមិនចូលរួមក្នុងការបង្កើតច្បាប់ ដូចនេះពួកគេត្រូវបានអនុញ្ញាតឱ្យលះបង់ពេលវេលាទាំងស្រុងនៅក្នុងកិច្ចការប្រចាំថ្ងៃនិងកិច្ចការផ្ទាល់ខ្លួនរបស់ពួកគេ។

**៤.២.៧.៣ អត្តាធិបតេយ្យនិយម (អំណាចផ្តាច់ការ)**

នៅក្នុងកែវភ្នែករបស់លោក ហប្ស សិទ្ធិតស៊ូតបត គឺត្រូវបានច្រានចោល។ អធិបតេយ្យ មិនអាចធ្វើអ្វីបានទាំងអស់ប្រឆាំងនឹងផលប្រយោជន៍របស់ប្រជាជន ទោះបីគេប្រើអំពើហិង្សាចុងក្រោយបង្អស់ក៏ដោយព្រោះហេតុថាវាមានប្រភេទអាក្រក់នៃស្ថានភាពមួយ គឺស្ថានភាពធម្មជាតិ។ គ្រប់បដិវត្តទាំងអស់មានហានិភ័យទៅនឹងការលេចឡើងសារជាថ្មីនៃស្ថានភាពធម្មជាតិរបស់មនុស្ស។ តែ "ប្រសិនបើនៅក្នុងស្ថានភាពធម្មជាតិវិញ មនុស្សគឺជាសត្វឆ្កែចចកសម្រាប់មនុស្ស បើនៅក្នុងសង្គម មនុស្សគឺជាអាទិទេពមួយសម្រាប់មនុស្ស"។ គឺចំណុចនេះហើយដែលលោករូហ្សូ និងលោក ហប្ស ការពារគំនិតអត្តាធិបតេយ្យនិយម។ ប៉ុន្តែ មិនមែនកាត់បន្ថយល្បឿនពេកនោះទេសម្រាប់ករណីនេះ។ លោក ហប្ស សារភាពថា អំណាចផ្តាច់ការមិនមែនគ្មានហានិភ័យនោះទេ។ គាត់បង្ហាញឱ្យឃើញថា នៅចំណុចនេះ ប្រសិនបើអំណាចគឺធ្វើតាមទំនើងចិត្ត និងផ្តាច់ការដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិតរបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋទាំងនេះអាចការពារខ្លួន (ដើម្បីការពារអ្វីដែលគាត់បានអនុញ្ញាតនៅក្នុងកិច្ចសន្យា) ប៉ុន្តែ នេះមិនមែនមានន័យថា ពួកគេមានសិទ្ធិតស៊ូប្រឆាំងតបតទេ ព្រោះជានិច្ចជាកាលតែងតែមានសេរីភាពខាងគំនិត និងសិទ្ធិក្នុងការការពារច្បាប់ធម្មជាតិ។ អំណាច គឺដាច់ខាត ព្រោះវាជាអ្នកធានានូវស្ថេរភាពរបស់សិទ្ធិ។ នេះមិនមែនមានន័យថាអំណាចដាច់ខាត គឺចាំបាច់ត្រូវតែធ្វើតាមទំនើងចិត្ត ឬអត្តាធិបតេយ្យនិយមនោះដែរ។ អំណាចទាំងស្រុងនិយមរបស់លោក ហប្ស គឺត្រូវបានទទួលរងការរិះគន់ ហើយលទ្ធិរបស់គាត់ត្រូវបានបកស្រាយថាជាអ្នកបង្ហាញឱ្យដឹងមុននូវទម្រង់រដ្ឋផ្តាច់ការ។ ប៉ុន្តែទោះមានការរិះគន់ក្តី ដោយសារតែបានផ្តល់មូលដ្ឋានច្បាប់ទៅឱ្យរដ្ឋ លោក ហប្ស តាមពិតទៅអាចត្រូវបានចាត់ទុកថាជាអ្នករៀបចំមុនគេនូវអ្វីដែលយើងហៅសព្វថ្ងៃនេះថាជា "នីតិរដ្ឋ"។ ទោះយ៉ាងណាក៏ដោយ បេះដូងនៃការជញ្ជឹងគិតរបស់គាត់ គឺចោទជាសំណួរពីរដែលថា មិនមានប្រជាធិបតេយ្យណាមួយអាចបង្វែរបានទេ ទី១ តើផ្នែកណានៃការមិនគោរពតាមអំណាច អាចត្រូវការចាំបាច់ដោយស្របច្បាប់ដោយគ្មានធ្វើឱ្យហួសសិទ្ធិដទៃរបស់មនុស្ស? ប៉ុន្តែក៏ដូចគ្នាដែរ ទី២ តើផ្នែកណានៃសេរីភាពរបស់មនុស្សដែលរស់នៅក្នុងសហគម អាចទាមទារដោយស្របច្បាប់ដោយមិនគំរាមគំហែងដល់សន្តិភាពស៊ីវិល? ទោះបីជាដូច្នោះក្តី ប្រសិនបើ ហប្ស មិនមែនជាទ្រឹស្តីវិទូនៃប្រជាធិបតេយ្យដែលធ្វើការស្វែងរកដំណោះដោះស្រាយនូវបញ្ហារដ្ឋ និងមូលដ្ឋាននៃអំណាច និងការគោរពតាមទេ គាត់ក៏មិនអះអាងខ្លួនគាត់ថាជាអ្នកបង្កើតគំនិតនយោបាយទំនើបយ៉ាងពិតប្រាកដដែរ។

**៤.២.៨ ដើមទុនទស្សនៈនយោបាយដទៃទៀតរបស់លោក** Thomas Hobbes

#### ៤.២.៨.១ លោក Hobbes និងសាសនា

ការបន្ទោសបដិសេធចំពោះលទ្ធិអាទិទេពនិយមដែលលោក Hobbes បានអះអាង គឺថាវាជាការដែលនាំឱ្យរំខាន ព្រោះវាមិនមានសំណួរអ្វីពាក់ព័ន្ធនឹងលទ្ធិអាទិទេពទេ។ លោក Hobbes បញ្ជាក់ថា ត្រូវគោរពតាមសង្គមស៊ីវិលទាំងអស់សម្រាប់អ្វីដែលមិនផ្ទុយទៅនឹងការបញ្ជារបស់អាទិទេព។ ប៉ុន្តែប្រសិនបើវាមានភាពងាយស្រួលក្នុងការកំណត់ថា តើអ្វីខ្លះជាការបញ្ជារបស់អាទិទេព ចាំបាច់ត្រូវតែធ្វើការបកស្រាយការបញ្ជាទាំងនោះ។ ការបញ្ជាទាំងនេះត្រូវឱ្យសង្គមស៊ីវិលជាអ្នកធ្វើការបកស្រាយដោយខ្លួនឯង។ សម្រាប់លោក ហប្ស គឺថាមិនចាំបាច់មានការបែងចែករវាងអំណាចបណ្ដោះអាសន្ន និងអំណាចខាងសាសនាទេ។ យោងតាមលោក ហប្ស នៅក្នុងសភាពគ្រិស្តសាសនិក ព្រះវិហារសាសនា និងរដ្ឋគឺមានការភ័ន្តច្រឡំគ្នា ប៉ុន្តែសម្រាប់បញ្ហាសាសនា ព្រះមហាក្សត្រត្រូវដាក់វាទុកសម្រាប់ឱ្យបុគ្គលដែលបូជាឧទ្ទិសចំពោះសាសនានោះ។ ចំណែកឯសភាពនៃអ្នកមិនមែនគ្រិស្តសាសនិក អំណាចបណ្ដោះអាសន្ន មានរួមទាំងអំណាចសាសនា តែមិនមែនមានន័យថាមិនគោរពតាមរឿងគ្រិស្តសាសនាបានឡើយ។

#### ៤.២.៨.២ ទីតាំងសេរីភាពរបស់លោក ហប្ស

អំណានរបស់លោកហប្សអាចចោលជាសំណួរតាមធម្មានុរូបទៅលើជោគវាសនាដែលរក្សាទុកនូវជោគវាសនានេះទៅដល់សេរីភាព។ សម្រាប់រឿងនានានេះ ភាពមិនអាចធ្វើទៅបានដើម្បីប្រឆាំងតវ៉ានឹងសេចក្ដីសម្រេចរបស់អធិបតេយ្យ ផ្ដល់ឱ្យគិតថា សេរីភាពកាត់បន្ថយទៅដល់សូន្យ។ សេរីភាព និងភាពចាំបាច់ គឺមានចំណងភ្ជាប់គ្នាយ៉ាងជិតស្និត។ នេះគឺជាការពិចារណាដោយសេរីទៅលើសន្តិភាព និងសន្តិសុខដែលមនុស្សបានបង្កើត Léviathan និងច្បាប់ស៊ីវិល។ សេរីភាព នឹងមិនអនុញ្ញាតឱ្យបុគ្គលឯកជនប្រឈមមុខនឹងច្បាប់បានឡើយ។ ការប្រឆាំងទាមទារសេរីភាពបែបនេះគឺមិនទំនងទេ ព្រោះការទាមទារនេះទម្លាក់បុគ្គលម្នាក់នៅក្នុងស្ថានភាពធម្មជាតិ។ ប៉ុន្តែ ការចំណុះទាំងស្រុងនៅក្រោមច្បាប់ ទទួលស្គាល់ព្រំដែនដែលមិនអាចប៉ះពាល់បានមួយដែលចងភ្ជាប់ទៅនឹងច្បាប់ធម្មជាតិ។ អធិបតេយ្យ មិនអាចទៅប្រឆាំងនឹងហេតុផលដូចគ្នានៃអត្ថិភាពរបស់ធម្មជាតិបានទេ។ មូលដ្ឋាននៃសេរីភាពនិយមគឺភាពចែកដាច់គ្នារវាងសង្គមស៊ីវិល និងរដ្ឋ ព្រោះរដ្ឋជាអ្នកតំណាង និងជាឧបករណ៍របស់សង្គមស៊ីវិល។ ដោយកំណត់និយមន័យអំណាចធម្មជាតិរបស់បុគ្គលឯកជនថា ជាអំណាចមួយមានទៅលើវត្ថុ លោក ហប្ស បានផ្ដល់នូវក្របខណ្ឌទ្រឹស្ដីសេរីភាពនិយមមួយ គឺថាសិទ្ធិ ផលប្រយោជន៍ សេចក្ដីប្រាថ្នា និងកម្មសិទ្ធិ។ លោក តូម៉ាស ហប្ស មានជាតុផ្សំដែលប្រកាសអំពីសេដ្ឋកិច្ចទំនើប និងសេរីភាពនិយមខាងសេដ្ឋកិច្ច។

#### ៤.២.៨.៣ បុគ្គលឯកជនប្រៀបដូចមូលដ្ឋានគ្រឹះរបស់សង្គម

លោក ហប្ស ត្រូវបានរំអុករំខានដោយភាពភ័យខ្លាចនៃការស្លាប់ដោយអំពើហិង្សា។ ដោយសារហេតុផលនេះហើយទើបគាត់ចង់ផ្ដល់នូវសន្តិភាពទៅដល់មនុស្ស។ ដោយមានបំណងប្រាថ្នាការពារបុគ្គលឯកជនដែលគាត់មើលឃើញថាជាមូលដ្ឋានគ្រឹះរបស់សង្គម ហើយដើម្បីធ្វើបែបនេះ គាត់ចង់ឱ្យអំណាចគួរត្រូវបានទុកចិត្តផ្ដល់ឱ្យទៅអធិបតេយ្យមួយដែលមានអំណាចទាំងអស់នោះគឺ Léviathan។ បុគ្គលឯកជនបង្កើតបាននូវភាពពិតគ្រឹះ។ មនុស្សផ្ដល់ហេតុផលនៅក្នុងក្រមខណ្ឌបុគ្គលឯកជនរបស់ខ្លួនគឺមនុស្សស្វែងរកទីបញ្ចប់របស់ពួកគេដោយខ្លួនឯង និងតម្រង់ទិសដៅរបស់ខ្លួនតាមឆន្ទៈរបស់ខ្លួនឯង។ ប្រសិនបើមនុស្សរស់នៅក្នុងសង្គម គឺជាហេតុផលដើម្បីស្វែងរកផលប្រយោជន៍ដើម្បីសេចក្ដីបំពេញចិត្តរបស់ខ្លួនតែប៉ុណ្ណោះ។ សម្រាប់លោក ហប្ស ធម្មជាតិរបស់មនុស្ស គឺអត្តទត្តបុគ្គល។ មនុស្សការពារបុគ្គលភាពនិយមដោយទុទិដ្ឋិនិយម និងដោយមិនបើកចំហរ។ សង្គម និងកើតចេញពីភាពឃោឃៅរបស់បុគ្គលម្នាក់ៗចំពោះបុគ្គលដ៏ទៃ។ នៅក្នុងសភាពធម្មជាតិ មនុស្ស គឺមានសង្គ្រាមជាអចិន្ត្រៃយ៍ គឺអ្នកនេះប្រឆាំងនឹងអ្នកនោះ ហើយម្នាក់ៗត្រូវការពារជីវិតរបស់ខ្លួនជានិរន្ត វៀរលែងតែស្លាប់ ឬយល់ព្រមចំណុះជាមួយគេ។ នៅក្នុងសភាពធម្មជាតិ មនុស្ស គឺជាសត្វឆ្កែចចក សម្រាប់មនុស្ស។

# មេរៀនទី៥ ចន ឡុក

( John Locke 1632-1704 )

## ៥.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ

លោក John Locke ជាទស្សនវិទូ និងជាអ្នកទ្រឹស្តីនយោបាយជនជាតិអង់គ្លេស។ គាត់កើតនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៦៣២ នៃគ.សក្នុងភូមិ Wrington ក្រុង Somerset ខាងត្បូងឈៀងខាងលិចនៃប្រទេសអង់គ្លេស។ លោកបានធំធាត់ក្នុងពេលដែលប្រទេសមានបដិវត្តវិទ្យាសាស្ត្រ។ ហើយបានទទួលមរណកាលនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៧០៤ នៃគ.ស ក្នុងក្រុង Essex ក្នុងជន្មាយុ៧២ឆ្នាំភាគខាងកើតនៃប្រទេសអង់គ្លេស។ គាត់ក៏ជាស្ថាបនិកទ្រឹស្តីសេរីនិយម ( Liberalism ) ម្នាក់ដែរ។

ទោះបីត្រូវបានចាត់បញ្ចូលក្នុងក្រុមអ្នកទ្រឹស្តីច្បាប់ធម្មជាតិដែរក្តីក៏ទស្សនៈនយោបាយរបស់លោកខុសពី Hobbes។ ចន ឡុក បង្កើតទ្រឹស្តីសេរីនិយម។ ស្នាដៃរបស់លោកមានឥទ្ធិពលយ៉ាងខ្លាំងលើវិទ្យាសាស្ត្រនយោបាយ និងទស្សនវិជ្ជានយោបាយ។

ទស្សនៈនយោបាយលោក John Locke ដែលធ្វើឱ្យលោកមានកិត្យានុភាពល្បីល្បាញក្លាយជាអ្នកនយោបាយវិទ្យា គឺស្នាដៃ «អភិប្រាយពីរនៃការដឹកនាំរដ្ឋ ( Two Treatises of Government )» ដែលបានបោះពុម្ពផ្សាយលើកទីមួយនៅក្នុងឆ្នាំ១៦៩០។ នៅក្នុងស្នាដៃលោក John Locke បានបង្ហាញយ៉ាងច្បាស់នូវការកំណត់មូលន័យនៃសេរីនិយម ដូចជា «បុគ្គលភាព» «សង្គម» «រដ្ឋ» ហើយបានដាក់បុគ្គលភាពឱ្យខ្ពស់ជាងសង្គម និងរដ្ឋ។ ពោលគឺបានបកស្រាយអំពីបញ្ហារបស់មនុស្សតាមសភាពធម្មជាតិ ការកកើតសង្គម និងការកកើតរដ្ឋ។ « អ្វីដែលមាននៅក្នុងគំនិត គឺអ្វីដែលធ្លាប់មានក្នុងពិសោធន៍ » នេះជាការអះអាងរបស់ John Locke។ យោងតាមទស្សនៈរបស់លោក John Locke ថា «មនុស្សមានសិទ្ធិរស់ សេរីភាព កម្មសិទ្ធិ» នេះជាលក្ខណៈពិសេសរបស់មនុស្សដែលមានមកតាំងពីកំណើត។ លោក John Locke មានការចាប់អារម្មណ៍ទៅលើបញ្ហាកម្មសិទ្ធិជាឯកជន ចាត់ទុកជាច្បាប់ធម្មជាតិរបស់មនុស្ស ហើយការសន្សំទ្រព្យសម្បត្តិអាចផ្តល់លទ្ធភាពឱ្យមនុស្សផ្គត់ផ្គង់ចិញ្ចឹមខ្លួនឯង និងគ្រួសារ នូវអ្វីដែលខ្លួនចាំបាច់។ ប៉ុន្តែនៅពេលដែលមនុស្សមាននូវអ្វីជាចាំបាច់ហើយនោះ គេនឹងយកចិត្តទុកដាក់ថែមទាំងធ្វើឱ្យរីកចម្រើននូវទ្រព្យសម្បត្តិរបស់គេបន្ថែមទៀត។ តែទោះជាយ៉ាងណាក៏ដោយ ក៏លោក John Locke មិនធ្ងន់តែកម្មសិទ្ធិជារបស់ឯកជនតែម្យ៉ាងទេ ថែមទាំងរិះរកមធ្យោបាយ ដើម្បីរក្សាកម្មសិទ្ធិដែលជាធាតុចាប់ផ្តើមរបស់សង្គមសេរីនិយម ។

លោក John Locke យល់ថា «រដ្ឋ ត្រូវមានស្ថានភាពជាអ្នកនាំមុខសង្គម» ។ រដ្ឋ ជាយន្តការមានលទ្ធភាព និងប្រសិទ្ធិភាពការពារយុត្តិធម៌។ ចំណែកការរស់នៅក្នុងធម្មជាតិមានលក្ខណៈខុសពីរដ្ឋ។ លោក John Locke សរសេរថា «ដោយឈរលើវិចារណញ្ញាណ មនុស្សបានសន្មតគ្នាដើម្បីអនុវត្តន៍ច្បាប់ដោយឆ្ពោះទៅរកគោលការណ៍នៃកិច្ចព្រមព្រៀងគ្នាដោយរួមជាសង្គម ( Social Contract ) ហើយបង្កើតបានជារដ្ឋ»។ John Locke គឺជាអ្នកបង្កើតទ្រឹស្តីបែងចែកអំណាច ដែលជាមូលដ្ឋាននៃនីតិរដ្ឋ។

និយាយជារួមទេពកោសល្យដែលបានបង្ហាញក្នុងស្នាដៃរបស់លោកមានឥទ្ធិពលយ៉ាងខ្លាំងទៅលើវិទ្យាសាស្ត្រនយោបាយ និងទស្សនវិជ្ជានយោបាយ ក្នុងសតវត្សទី២០ និងទី ២១។ ជីវិតរបស់លោក បានឆ្លងកាត់ព្រឹត្តិការណ៍ជាច្រើនចំពេលដែលប្រទេសអង់គ្លេសមានបដិវត្តន៍ប្រឆាំងនឹងវិទ្យាសាស្ត្រ។ ដោយឈរលើទ្រឹស្តីច្បាប់ធម្មជាតិ Locke បានសិក្សាពីស្ថានភាពរបស់មនុស្សក្នុងដំណាក់កាលដំបូងគឺចាប់ពីពេលដែលរដ្ឋមិនទាន់ចាប់បដិសន្ធិ។ ចំណុចថ្មីមួយដែល John Locke រកឃើញគឺកម្មសិទ្ធិឯកជនដែលកើតមានមុនការកកើតសង្គម ឬកកើតនៃអំណាច

នយោបាយ។ កម្មសិទ្ធិឯកជនកើតមាននៅក្នុងសភាពធម្មជាតិ។ កម្មសិទ្ធិឯកជនជាសារជាតុមិនអាចញែកចេញពីមនុស្សបានទេ ព្រោះកម្មសិទ្ធិជាសមិទ្ធិផលនៃការងាររបស់មនុស្ស ។ តាមរយៈបទពិសោធន៍ទ្រឹស្តីធម្មជាតិ ហើយនឹងតាមរយៈការបកស្រាយស្តីពីការគ្រប់គ្រងរដ្ឋ John Locke បានពន្យល់ថា «ដំបូងមនុស្សត្រូវការចំណីអាហារ ផ្លែឈើ បរិភោគចំអែតក្រពះ»។ គាត់ថា «ដោយសារតែកម្លាំងពលកម្មរបស់គេ មនុស្សត្រូវបេះផ្លែឈើឱ្យបានច្រើន ដាំដើមឈើហូបផ្លែឱ្យបានច្រើន នេសាទឱ្យបានច្រើន ឬផលិតគ្រឿងឧបភោគបរិភោគឱ្យបានច្រើន ដើម្បីទុកសម្រាប់ពេលក្រក្សត់»។ ដូច្នេះ ចេញពីផលិតផលដែលគេខំផលិតសម្រាប់ទុកបរិភោគនេះឯង ដែលទាំងនេះជាប្រភព ឬជាហេតុនាំឱ្យកើតមានកម្មសិទ្ធិ។ កម្មសិទ្ធិពីធម្មជាតិរបស់មនុស្សដែល John Locke លើកមកបង្ហាញផងដែរ គឺសិទ្ធិនិងសេរីភាព។ គាត់យល់ថា «មនុស្ស មានវិចារណញ្ញាណដែលបង្ខំឱ្យគេមានការងារ ឬករណីយកិច្ចជាច្រើន ហើយកិច្ចមុនដំបូងគេបង្អស់នោះ គឺការរក្សាអាត្មាខ្លួនឯងជាមុនសិន។ បើការរក្សាខ្លួនឯងជាករណីយកិច្ចនោះក៏បញ្ជាក់ឱ្យឃើញថា មនុស្សម្នាក់ៗមានសិទ្ធិលើខ្លួនឯងផ្ទាល់គេគឺជាកម្មសិទ្ធិរបស់ខ្លួនគេផ្ទាល់។ ពីធម្មជាតិគេមានខ្លួនគេជាប់ជាមួយនឹងកម្លាំងការងារ ដូច្នេះអ្វី ដែលកើតចេញពីកម្លាំងរបស់គេ ក៏ជាកម្មសិទ្ធិរបស់ខ្លួនគេដែរ»

## ៥.២ ទស្សនៈនយោបាយ

នៅក្នុងប្រទេសអង់គ្លេស កើតមាននូវព្រឹត្តិការណ៍ជាច្រើនដែលទាក់ទងទៅនឹងបញ្ហានយោបាយ និងការគ្រប់គ្រងប្រទេស។ ការណ៍នេះបានបង្កឱ្យមានការធ្វើបដិវត្តន៍ និងធ្វើឱ្យមានសង្គ្រាមស៊ីវិលផ្ទុះឡើង។ សង្គ្រាមនេះបានធ្វើឱ្យសង្គមមានភាពច្របូកច្របល់ គ្មានសណ្តាប់ធ្នាប់ ហើយក៏បានជះឥទ្ធិពលមិនល្អទៅលើរចនាសម្ព័ន្ធផ្នែកនយោបាយ និងការគ្រប់គ្រងរដ្ឋដែលជាក្បាលម៉ាស៊ីននៃការដឹកនាំប្រទេស។ ក្រៅពីនេះក៏មានផលប៉ះពាល់យ៉ាងខ្លាំងដល់ស្ថានភាពរស់នៅរបស់ប្រជាជន ធ្វើឱ្យបាត់បង់នូវសិទ្ធិសេរីភាពរបស់ពួកគេដែលជាហេតុធ្វើឱ្យពួកគេបាត់បង់ស្មារតីក្នុងការទទួលខុសត្រូវចំពោះមុខ និងគ្មានឆន្ទៈក្នុងការប្រកបរបរសម្រាប់ជីវិត និងការអភិវឌ្ឍសង្គមជាតិ។

ស្របជាមួយស្ថានភាពបែបនេះលោក ចន ឡុក ដែលជាទស្សនវិទូមួយរូបដែលមានការសិក្សាស្រាវជ្រាវ និងបានចូលប្រឡូកក្នុងសង្គមនៃប្រទេសអង់គ្លេសសម័យនោះ លោកមានការចាប់អារម្មណ៍ទៅលើបញ្ហាសិទ្ធិ សេរីភាពរបស់មនុស្ស។ លោកជាអ្នកធ្វើការទាមទារបង្កើតគ្រឹះគំនិតនៃប្រជាធិបតេយ្យអាស្រ័យធម្មនុញ្ញសម័យទំនើបនៅអឺរ៉ុបដែលជាចលនាទស្សនវិទូសតវត្សទី១៧។ លោកបានបដិសេធសង្គមសាសនានយោបាយបែបចាស់ និងគូសបញ្ជាក់ទៅលើភាពសមហេតុផល។

### ៥.២.១ រដ្ឋធម្មជាតិ

ក្នុងនាមជាអ្នកទ្រឹស្តីច្បាប់ធម្មជាតិលោកសិក្សាយកចិត្តទុកដាក់ចំពោះស្ថានភាពរបស់មនុស្សក្នុងដំណាក់កាលដំបូងតាំងពីពេលដែលមនុស្សរស់នៅតាមបែបធម្មជាតិមកម្ល៉េះ។ ស្ថានភាពធម្មជាតិរបស់មនុស្សដែលលោកចាប់អារម្មណ៍ជាងគេ គឺបញ្ហាសិទ្ធិ និងសេរីភាពរបស់មនុស្ស។ លោកតែងយល់ថាស្ថានភាពធម្មជាតិរបស់មនុស្សជាស្ថានភាពដែលមានសេរីភាពគ្រប់គ្រាន់ក្នុងការទំនាក់ទំនងរវាងបុគ្គល និងបុគ្គល។ ស្ថានភាពធម្មជាតិជាស្ថានភាពដែលពោរពេញដោយសមភាពទាំងអំណាចទាំងសិទ្ធិសុទ្ធតែស្មើគ្នាសម្រាប់គ្រប់បុគ្គលទាំងអស់ដោយមិនមានបុគ្គលណាមួយមានសិទ្ធិ អំណាចច្រើនជាងបុគ្គលដទៃឡើយ។ តាមទស្សនៈរបស់លោក សេរីភាពកើតឡើងពីធម្មជាតិ។

រដ្ឋធម្មជាតិ ជារដ្ឋឯករាជ្យមួយដែលមិនទាន់មានរដ្ឋាភិបាលគ្រប់គ្រង ហើយមនុស្សរស់នៅដោយមានសិទ្ធិសេរីភាពស្មើគ្នាពីធម្មជាតិ។ ចន ឡុក បានពោលថា រដ្ឋធម្មជាតិមិនមែនជារដ្ឋនៃសង្គ្រាមទេ តែជារដ្ឋនៃសន្តិភាព ជារដ្ឋបរិបូរណ៍ ជារដ្ឋមានសេរីភាព និងលក្ខណៈសម្បត្តិពេញលេញ។ នៅក្នុងរដ្ឋធម្មជាតិ មនុស្សមានសិទ្ធិ សេរីភាពស្មើៗគ្នា។ គេម្នាក់ៗរស់នៅដោយឯករាជ្យគ្មានអ្នកណាមកបង្ខិតបង្ខំ ឬប្រព្រឹត្តអំពើឃោរឃៅព្រៃផ្សៃទៅលើពួកគេឡើយ។ រដ្ឋធម្មជាតិ មនុស្សរស់នៅជាមួយគ្នាអាស្រ័យទៅលើវិចារណញ្ញាណ ទោះបីជាស្ថានភាពនោះពុំទាន់មានការរៀបចំឡើងពីរដ្ឋាភិបាលក៏ដោយ។ ពួកគេរស់នៅដោយប្រើវិចារណញ្ញាណ មិនមែនពឹងផ្អែកលើតណ្ហានោះទេ។

ដូចដែលទ្រឹស្តីពុទ្ធិរបស់លោក បានពោលថា សារជាតិរបស់មនុស្ស មិនអាក្រក់ពីកំណើតទេ។ លោកអះអាងថា មនុស្សកើតមកខួរក្បាលរបស់មនុស្សប្រៀបដូចជាក្រដាសសស្អាត ហេតុនេះមនុស្សមានទំនាក់ទំនងល្អ មានភាពស្មើគ្នា និងឯករាជ្យ គ្មាននរណាម្នាក់ធ្វើអំពើអាក្រក់ទៅលើអ្នកដទៃនៅពេលពួកគេមានជីវិត សុខភាព សេរីភាព និងកម្មសិទ្ធិបានល្អនោះឡើយ។

លោកយល់ថា រដ្ឋធម្មជាតិ ជាសភាពសន្តិភាព ជាសភាពដែលមនុស្សមានឆន្ទៈចង់ជួយគ្នាទៅវិញទៅមក ជាសភាពដែលមនុស្សមានវិចារណញ្ញាណ អាចយល់ដឹងពីច្បាប់ធម្មជាតិ និងជាសភាពដែលមនុស្សចេះសម្រុះសម្រួលអាកប្បកិរិយារបស់ខ្លួនទៅនឹងច្បាប់ធម្មជាតិ។ លោកជឿថាមនុស្សម្នាក់ៗតែងមានចិត្តចង់ការពារខ្លួនឯងដោយផ្ទាល់ និងចិត្តសណ្តោសគ្នាទៅវិញទៅមក។ រដ្ឋធម្មជាតិក៏ជាសភាពខ្វះខាតផងដែរ គឺថាក្នុងសភាពធម្មជាតិ មិនមានការកំណត់ច្បាប់ និងប្រកាសឱ្យប្រើប្រាស់ច្បាប់សម្រាប់ទាំងអស់គ្នាឡើយ។ ក្នុងសភាពនេះក៏ខ្វះខាតនូវអំណាចតុលាការសម្រាប់ទប់ស្កាត់មិនឱ្យ មានការសងសឹកគ្នា ការជជែកគ្នាយកឈ្នះចាញ់តាមលក្ខណៈបុគ្គលដែលស្តែងឡើងក្នុងរូបភាពជាកូន ក្តីផង ជាមេធាវីផង និងជាចៅក្រមផងដែរ។

### ៥.២.២ ច្បាប់ធម្មជាតិ

យើងបានដឹងរួចមកហើយថា រដ្ឋធម្មជាតិរបស់ ចន ឡុក គឺជាស្ថានភាពដែលមនុស្សរស់នៅដោយមានសិទ្ធិសេរីភាពគ្រប់គ្រាន់ដោយគ្មានអ្នកណាគ្រប់គ្រង ឬឈ្លានពានលើអ្នកណាម្នាក់ទេ។ ពួកគេរស់នៅទៅតាមសមត្ថភាពលទ្ធភាពនៃការយល់ដឹងដោយប្រើវិចារណញ្ញាណក្នុងការដោះស្រាយរាល់បញ្ហាផងទាំងពួង។ ក្នុងសភាពធម្មជាតិ គឺពុំទាន់មានច្បាប់រដ្ឋជាអ្នកគ្រប់គ្រងមនុស្សឡើយ គឺមានតែច្បាប់ធម្មជាតិជាអ្នកគ្រប់គ្រងមនុស្សជាតិដែលពួកគេស្ថិតនៅក្នុងសហគមន៍ជាមួយគ្នាដោយគ្មានការកាប់សម្លាប់។ ច្បាប់ធម្មជាតិ គឺជាច្បាប់ដែលមនុស្សគ្រប់រូបតែងទទួលស្គាល់ ហើយមនុស្សតែងធ្វើ ការវិភាគលើច្បាប់ទាំងនោះ និងយកច្បាប់ទាំងនោះមកអនុវត្តនៅក្នុងស្ថានភាពរស់នៅ។ ដូចជាទឹកតែងហូរពីទួលខ្ពស់ចុះទៅកាន់ទីទាប បុរស និងស្ត្រីនៅពេលពេញវ័យតែងមានស្នេហា នេះជាក្រិតក្រមធម្មជាតិ។ វិធីបដិសំយោគអះអាងថា "*លក្ខណៈពិសេសនៃក្រឹត្យក្រមធម្មជាតិ គឺជាការពង្រីកឥទ្ធិពលដោយឯកឯង។ មនុស្សគ្រាន់តែរកឃើញក្រឹត្យក្រមបានុម័តប៉ុណ្ណោះ តែមនុស្សមិនអាចបង្កើត ឬលុបបំបាត់ក្រឹត្យក្រមនេះបានឡើយ។ ប៉ុន្តែមនុស្សមានពុទ្ធិ អាចយល់ដឹងចំពោះក្រឹត្យក្រមនេះ ហើយឆ្លៀតយកផលប្រយោជន៍ក្នុងការអនុវត្តន៍ក្រឹត្យក្រមនេះ*"។

ចំពោះ ចន ឡុក យល់ថា រដ្ឋធម្មជាតិគ្រប់គ្រងដោយច្បាប់ធម្មជាតិ ឬក្រឹត្យក្រមធម្មជាតិដែលក្នុងនោះមនុស្សយល់ដឹងអំពីវាដោយវិចារណញ្ញាណរបស់ខ្លួន។ ច្បាប់ឬក្រឹត្យក្រមនេះកំណត់ដោយធម្មជាតិដែលរកឃើញដោយវិចារណញ្ញាណរបស់មនុស្សហើយប្រឆាំង ឬមានលក្ខណៈខុសពីច្បាប់ ឬក្រឹត្យក្រម ដែលបង្កើត ឬប្រកាសឡើងដោយមនុស្ស។ ម្យ៉ាងទៀតក្នុងសភាពធម្មជាតិ មនុស្សមានសិទ្ធិ សេរីភាព មានកាតព្វកិច្ចពីធម្មជាតិ ដើម្បីការពារខ្លួននៅពេលដែលមានស្ថានភាពគ្រោះថ្នាក់មកដល់ខ្លួន និងអ្នកដទៃ។ ក្នុងការដោះស្រាយនូវរាល់បញ្ហាវិវាទរវាងបុគ្គល និងបុគ្គល ធ្វើឡើងតាមរយៈការជជែក ពិភាក្សា រកហេតុផលដែលពួកគេអាចធ្វើបានដូចជាលក្ខណៈក្នុងការយោគយល់ និងការសម្របសម្រួល គោរពគ្នាទៅវិញទៅមកដោយពុំមានច្បាប់សង្គម ឬរដ្ឋ។ ម្យ៉ាងវិញទៀត ច្បាប់ធម្មជាតិ គឺជាច្បាប់ដែលទាក់ទងទៅនឹងកម្មសិទ្ធិឯកជន សិទ្ធិផ្លាស់ទី សិទ្ធិធ្វើការ និងសិទ្ធិទទួលផលពីការងារ។

### ៥.២.៣ សិទ្ធិធម្មជាតិ

ស្ថានភាពធម្មជាតិជាស្ថានភាពដែលពោរពេញដោយសមភាព គឺថាទាំងអំណាច ទាំងសិទ្ធិ សុទ្ធតែស្មើៗគ្នាសម្រាប់បុគ្គលទាំងអស់ដោយគ្មានបុគ្គលណាម្នាក់មានសិទ្ធិអំណាចច្រើនជាងបុគ្គលដទៃទៀតឡើយ។ លោកពោលថា សេរីភាពកើតឡើងពីធម្មជាតិ។ ធម្មជាតិ ជាកន្លែងដែលមនុស្សមានសិទ្ធិស្មើៗគ្នាហើយសិទ្ធិរបស់បុគ្គលទាំងនោះគឺមិនធ្វើឱ្យប៉ះពាល់អ្នកដទៃឡើយគឺគេប្រព្រឹត្តិនូវរាល់សកម្មភាពរបស់ពួកគេតាមវិចារណញ្ញាណដែលជាហេតុធ្វើឱ្យ

ពួកគេមានសេរីភាពគ្រប់គ្រាន់សម្រាប់ប្រកបមុខរបរចិញ្ចឹមជីវិត មានសិទ្ធិក្នុងការជ្រើសរើសគូស្រករដែលខ្លួនស្រឡាញ់ ព្រមទាំងសិទ្ធិក្នុងការ ដាក់ទណ្ឌកម្មចំពោះបុគ្គលដែលប្រព្រឹត្តិខុសនឹងក្រឹត្យក្រមធម្មជាតិ។

ដោយសង្គមមនុស្សមានការវិវត្តន៍ បានប្រែក្លាយឱ្យស្ថានភាពមានការរីកចម្រើន និងធ្វើឱ្យមនុស្សដែលពីមុនមានការរស់នៅជាក្រុម ឬកុលសម្ព័ន្ធបានមកនៅជាគ្រួសារតូចៗ ហើយបានធ្វើអាជីវកម្មទៅតាមនោះដែរ។ លក្ខណៈនេះបានបង្កឱ្យមានកម្មសិទ្ធិឯកជន ហើយនេះជាសិទ្ធិឯកជនមួយរបស់មនុស្ស គ្រប់រូប ព្រោះគេចង់ឱ្យមានសង្គមត្រឹមត្រូវដែលអាចឈានទៅរកការគ្រប់គ្រងបានល្អ។

ចំពោះ ចន ឡុក យល់ថាការដែលមនុស្សមានកម្មសិទ្ធិនេះមិនមែនជាអ្វីម្យ៉ាងដែលប្រឆាំងនឹងសង្គមឡើយ។ តែផ្ទុយទៅវិញ កម្មសិទ្ធិឯកជននេះបានជំរុញសង្គមឱ្យមានសន្ទុះទៅមុខយ៉ាងឆាប់រហ័ស។ ប៉ុន្តែកម្មសិទ្ធិទាំងនេះមិនត្រូវបានរក្សាការពារបានល្អឡើយ ប្រសិនបើមនុស្សទ្រាំរស់នៅក្នុង ស្ថានភាពបែបធម្មជាតិ ពិព្រោះកម្មសិទ្ធិឯកជនមិនអាចស្មើគ្នាឡើយ។ ម្យ៉ាងវិញទៀត លោកបានពោលថាមនុស្សមានវិចារណញ្ញាណដែលអាចបង្ខំឱ្យគេមានករណីកិច្ចជាច្រើន ហើយករណីកិច្ចនេះមានមុន គេបង្អស់ គឺរក្សាអាត្មាខ្លួនឯងផ្ទាល់។ បើការរក្សាអាត្មាខ្លួនឯងផ្ទាល់ ជាករណីកិច្ចនោះក៏មានន័យថា មនុស្សម្នាក់ៗមានសិទ្ធិសេរីភាពលើខ្លួនគេផ្ទាល់ គេជាម្ចាស់កម្មសិទ្ធិលើខ្លួនគេផ្ទាល់។ ពីធម្មជាតិ គេមានខ្លួនគេជាប់នឹងកម្លាំងការងារ។ ដូច្នេះអ្វីដែលចេញពីកម្លាំងការងារក៏ជាកម្មសិទ្ធិរបស់ពួកគេដែរ។ នេះជាគោលការណ៍សំខាន់ដែលឃើញមានក្នុងសេដ្ឋកិច្ចសេរីនិយមស្តីពីការមកធ្វើជាកម្មសិទ្ធិតាមរយៈការងារ។

វាមានហេតុផលបីយ៉ាងដែលចេញពីលទ្ធិស្តីពីកម្មសិទ្ធិលើរូបកាយ និងផ្លែផ្កាដែលចេញពីការងារ៖

១) ការយកមកធ្វើជារបស់ខ្លួន វាត្រឹមត្រូវពីធម្មជាតិ ពីព្រោះគេជាម្ចាស់លើបុគ្គលគេ និងរូបកាយគេ ហើយអ្វីដែលចេញពីរូបកាយគេក៏ជាមរតកដែលអាចបន្តបាន។

២) ការចេញពីសភាពធម្មជាតិមិនមែនជាការចាំបាច់ដាច់ខាតទេ តែការចូលមករស់នៅក្នុងសភាពជាសង្គមវាមានការធានាមួយខ្ពស់ជាង។ សង្គមមួយដែលមិនមានគោលដៅសម្រាប់ថែរក្សាកម្មសិទ្ធិក៏មិនអាចមានឈ្មោះថាសង្គមដែរ។ សារៈសំខាន់របស់សង្គម គឺការការពារកម្មសិទ្ធិ។

៣) មានកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្តរវាងបុគ្គលជាម្ចាស់កម្មសិទ្ធិ ពោលគឺកិច្ចព្រមព្រៀងសំដៅធានាដល់កម្មសិទ្ធិដែលអាចបង្កើតបានជាសង្គមនយោបាយនោះ។

លក្ខណៈទាំងនេះដែលមាននៅក្នុងសភាពធម្មជាតិគឺមានសារៈសំខាន់ណាស់ចំពោះ ឡុក ព្រោះ ថាសេរីភាពដែលជាទ្រព្យសម្បត្តិដ៏ពិសិដ្ឋរបស់មនុស្សនោះក៏កើតមានពីធម្មជាតិដែរ។ គឺដោយសារសេរីភាពនេះហើយដែលធ្វើឱ្យមនុស្សមានសិទ្ធិជាប់មកជាមួយខ្លួនគេដែរ។ សង្គមគ្រាន់តែផ្តល់ជាកម្លាំងដល់សិទ្ធិដែលមានពីធម្មជាតិតែប៉ុណ្ណោះ។ គំនិតរបស់លោកឃើញមានចារក្នុងសេចក្តីប្រកាសឯករាជ្យ របស់អាមេរិកផងដែរ។ ហើយនៅក្នុងសភាពធម្មជាតិ លោកមើលឃើញថា ការស្វែងរកយុត្តិធម៌នៅមានលក្ខណៈជាការស្វែងរកយុត្តិធម៌នៃបុគ្គលម្នាក់ប៉ុណ្ណោះដែលគេឱ្យឈ្មោះថា យុត្តិធម៌ឯកជន។ ក្នុងករណីនេះ ជនរងគ្រោះមិនមានសមត្ថភាព និងលទ្ធភាពស្វែងរកយុត្តិធម៌នោះពួកគេត្រូវស្ថិតក្នុងសភាពជាជនរងគ្រោះដោយអំពើអយុត្តិធម៌។

ដូចនេះដើម្បីបញ្ចប់រាល់បញ្ហា និងចៀសវាងការរំលោភបំពានទៅលើសិទ្ធិសេរីភាព ការពារនូវកម្មសិទ្ធិឯកជននិងឱ្យមនុស្សឃ្លាតឆ្ងាយពីសភាពធម្មជាតិឈានទៅរកសង្គមមួយដែលមានសណ្តាប់ធ្នាប់ល្អ រកយុត្តិធម៌ពិតប្រាកដដើម្បីការពារអាយុជីវិតរបស់បុគ្គលម្នាក់ៗ គឺយើងត្រូវចុះកិច្ចសន្យាសង្គម។ ការចុះកិច្ចសន្យាសង្គមនេះ គឺមនុស្សគ្រប់រូបព្រមទទួលនៅក្រោមការគ្រប់គ្រងពីសង្គម ឬរដ្ឋ។

### ៥.២.៤ អំណាចរដ្ឋ

ចំពោះសង្គម ឬរដ្ឋ គឺជាសមាគមរបស់អ្នកមានកម្មសិទ្ធិដែលចង់បានមធ្យោបាយដ៏មានប្រសិទ្ធិភាពដើម្បីថែរក្សាកម្មសិទ្ធិដែលគេរកបានសមស្របទៅនឹងសមត្ថភាពពីធម្មជាតិរបស់ពួកគេ។ ក្នុងន័យនេះ រដ្ឋ គឺគ្រាន់តែជា

ឧបករណ៍សម្រាប់បម្រើឱ្យកម្មសិទ្ធិតែប៉ុណ្ណោះ។ រដ្ឋ គឺជាអង្គការជានាវ៉ាប់រងមុខងារខាងប៉ូលីស និងតុលាការដែលកាលពីមុនមនុស្សទាំងនោះស្ថិតនៅក្នុងកណ្តាប់ដៃបុគ្គលដោយឡែកៗ។

សម្រាប់ ចន ឡុក រដ្ឋមានតួនាទីសំខាន់តែម្យ៉ាងគត់ គឺដាក់ទណ្ឌកម្មដល់អ្នករំលោភច្បាប់។ ក្រៅពីនេះរដ្ឋមានតួនាទីតិចតួចបំផុតគឺធានាឱ្យបាននូវសិទ្ធិ សេរីភាព សមភាព និងសុវត្ថិភាពរបស់ពលរដ្ឋ។ រដ្ឋរបស់ ចន ឡុក ជារដ្ឋដែលមានព្រំដែន។ ប៉ុន្តែមិនមែនជារដ្ឋផ្តាច់ការនោះទេ។ ក្នុងរដ្ឋមានព្រំដែន អំណាចរបស់រដ្ឋត្រូវបានបែងចែកឱ្យដាច់ពីគ្នាដែរ។ នៅក្នុងអំណាចរដ្ឋ ចន ឡុក បានបែងចែកជា៣គឺ

**៥.២.៤.១ អំណាចនីតិបញ្ញត្តិ**

ជាអំណាចមិនជាប់លាប់ ព្រោះវាមិនចាំបាច់ធ្វើច្បាប់ជានិច្ចកាលនោះទេ។ អំណាចនេះត្រូវកាន់កាប់ដោយសភាមួយ ដែលប្រជុំគ្នាតាមកាលកំណត់។ សភាពុំមែនជាអ្នកប្រតិបត្តិច្បាប់ទេ តែជាអំណាចកំពូលរបស់រដ្ឋ ហើយអំណាចនេះមិនអាចស្ថិតនៅក្នុងដៃរបស់បុគ្គលណាម្នាក់ឡើយ។

**៥.២.៤.២ អំណាចនីតិប្រតិបត្តិ**

ជាអំណាចជាប់លាប់ ព្រោះមានភារកិច្ចប្រតិបត្តិតាមច្បាប់យ៉ាងខ្ជាប់ខ្ជួន ដែលសភាបានអនុម័ត។ អំណាចនេះត្រូវកាន់កាប់ដោយអង្គការផ្សេងៗក្រៅពីអំណាចនីតិបញ្ញត្តិ។ ព្រះមហាក្សត្រជាប្រមុខនៃអំណាចនេះ ប៉ុន្តែសកម្មភាពរបស់ព្រះមហាក្សត្រ និងរបស់រដ្ឋាភិបាល ត្រូវតែស្ថិតនៅក្រោមអំណាចនីតិបញ្ញត្តិ។ តុលាការ និងយោធាត្រូវស្ថិតនៅក្នុងដៃរបស់រដ្ឋាភិបាល។ លោក ឡុក មិនអនុញ្ញាតិឱ្យព្រះ មហាក្សត្រមានអន្តរាគមន៍ទៅលើការកោះហៅរបស់សភាឡើយ។

**៥.២.៤.៣ អំណាចសហព័ន្ធ ឬអំណាចទំនាក់ទំនងអន្តរជាតិ**

ជាអំណាចសម្រាប់ចុះសន្ធិសញ្ញានានា ប្រកាសសង្គ្រាម ឬសន្តិភាព។ អំណាចនេះកាន់កាប់ដោយអ្នកកាន់អំណាចនីតិប្រតិបត្តិ។ អំណាចនេះត្រូវស្ថិតនៅក្នុងដៃរបស់ស្តេច និងរដ្ឋមន្ត្រីនានា។

ចន ឡុក មិនបានបែងចែកអំណាចទី៣នេះជាអំណាចតុលាការឡើយ។ បន្ថែមលើការបែងចែកអំណាចនេះ ចន ឡុក បានដាក់ចូលនូវវិធានការណ៍ ២ផ្សេងទៀត ដើម្បីឱ្យរដ្ឋស្គាល់ពីមុខងាររបស់ខ្លួននៅក្នុងសង្គមគឺ

១) ត្រូវបែងចែកសាសនាឱ្យដាច់ពីរដ្ឋ ពោលគឺត្រូវបែងចែកអំណាចសាសនាឱ្យដាច់ចេញពីអំណាចរដ្ឋ។

២) ត្រូវរក្សាសិទ្ធិតស៊ូចំពោះការគាបសង្កត់។ តាម ចន ឡុក ការបះបោរមានសារៈសំខាន់ណាស់ បើរដ្ឋមិនបានបំពេញករណីយកិច្ចរបស់ខ្លួនទេនោះ។

ចន ឡុក អះអាងបន្ថែមទៀតថា អំណាចនីតិបញ្ញត្តិត្រូវតែជាអំណាចកំពូល។ ចំណែកអំណាចដទៃទៀតដែលប្រសូតចេញពីអំណាចនេះត្រូវតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់វា ទោះអំណាចនេះស្ថិតនៅក្នុងកណ្តាប់ដៃមនុស្សប្រភេទណាក៏ដោយ។ គោលបំណងសំខាន់នៃទ្រឹស្តីនេះគឺធានាវ៉ាប់រងនូវ សន្តិសុខពលរដ្ឋ ផ្តត់ផ្គង់ សេរីភាពនយោបាយដល់ពលរដ្ឋឱ្យបានត្រឹមត្រូវ និងធ្វើឱ្យសង្គមចាកផុតពីអំណាចផ្តាច់ការ និងការនាំអំណាចទៅរកផលអាក្រក់។ ដើម្បីឱ្យសេរីភាពកើតមាននៅក្នុងសង្គមលុះត្រាតែរដ្ឋាភិបាលធ្វើយ៉ាងណាឱ្យមនុស្សទាំងអស់គ្មានការភ័យខ្លាចគ្នាទៅវិញទៅមក។

នៅក្នុងរដ្ឋ ឬសង្គមមួយមានស្ថេរភាព សន្តិសុខ សណ្តាប់ធ្នាប់ និងមានការរីកចម្រើន ដែលប្រកប ដោយលទ្ធិប្រជាធិបតេយ្យ គឺគោលការណ៍សំខាន់ផ្តោតទៅលើរដ្ឋាភិបាលដែលជាក្បាលម៉ាស៊ីនដឹកនាំ រដ្ឋ។ សម្រាប់ ចន ឡុក មិនត្រឹមតែមានគោលគំនិតទៅលើស្ថានភាពនៃការរស់នៅរបស់មនុស្ស និងរដ្ឋ ប៉ុណ្ណោះទេ លោកមានការចាប់អារម្មណ៍លើរដ្ឋាភិបាល និងទម្រង់រដ្ឋាភិបាលថែមទៀត ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញថាមានលក្ខណៈសុក្រិត សច្ចភាព យុត្តិធម៌ គ្មានការរំលោភបំពាន ការការពារសិទ្ធិ សេរីភាព សមភាពនៅក្នុងសង្គម។

**៥.២.៥ រដ្ឋាភិបាល**

រដ្ឋាភិបាលគឺជាយន្តការដ៏ចម្បងមួយដែលអាចធ្វើឱ្យរក្សាបាននូវសុវត្ថិភាពរបស់ខ្លួនបានគង់វង្ស។ រដ្ឋាភិបាលគឺជាអ្នកកាន់កាប់ និងប្រតិបត្តិនូវមុខងាររបស់រដ្ឋ និងជាអ្នកធ្វើឱ្យគោលនយោបាយរបស់រដ្ឋ ឈានទៅសម្រេចគោលដៅ។ ប៉ុន្តែរដ្ឋាភិបាលមិនមានអត្តសញ្ញាណរួមជាមួយរដ្ឋឡើយ ពីព្រោះរដ្ឋាភិបាលគ្រាន់តែជាអង្គការនយោបាយមួយដែលកើតមកពីក្រុមមនុស្សជំពូកណាមួយ ឬអាចនិយាយម្យ៉ាងទៀតថា មកពីគណបក្សនយោបាយដែលឈរឈ្មោះក្នុងចំណោមប្រជាជនទូទាំងប្រទេស។ ចំណែករដ្ឋ គឺជាអង្គអត្ថិភាពដែលប្រែប្រួលជាប្រចាំប៉ុណ្ណោះ ពីព្រោះរដ្ឋាភិបាលអាចត្រូវបានផ្លាស់ប្តូរដោយប្រការ ផ្សេងៗដូចជាការធ្វើបដិវត្ត ការធ្វើរដ្ឋប្រហារ ឬដោយសង្គ្រាមឈ្លានពានជាដើម។ រដ្ឋមួយចំនួនអាចបាត់ បង់អត្ថិភាពរបស់ខ្លួនដោយប្រការផ្សេងៗដូចជាការឈ្លានពានពីសំណាក់ខាងក្រៅឬដោយបង្កើតរដ្ឋថ្មីៗ ចេញពីរដ្ឋចាស់ៗដោយកម្លាំងសំពាធខាងក្រៅ។

តាមច្បាប់អន្តរជាតិ សិទ្ធិ និងកាតព្វកិច្ចគ្រប់គ្រងរដ្ឋទាំងអស់មិនអាចត្រូវបានលុបចោលដោយការ ធ្វើបដិវត្តផ្លាស់ប្តូរ ឬដោយការធ្វើរដ្ឋប្រហារឡើយ។ រដ្ឋាភិបាលក្នុងរដ្ឋនោះអាចផ្លាស់ប្តូរបាន ប៉ុន្តែរដ្ឋវិញ មិនអាចត្រូវបានផ្លាស់ប្តូរឡើយ មានន័យថា រដ្ឋគឺត្រូវមានជីវិតជាអមតៈ។

ចំពោះ ចន ឡុក រដ្ឋាភិបាល គឺជាប្រភព ឬជាការចាប់កំណើតនៃការព្រមព្រៀងគ្នាឡើង ដើម្បីការពារសិទ្ធិសេរីភាព អាយុជីវិត និងទ្រព្យសម្បត្តិរបស់ពលរដ្ឋផ្សេងៗ។ រដ្ឋាភិបាលត្រូវបានបង្កើតឡើងតាមរយៈកិច្ចសន្យាសង្គម ដែលពលរដ្ឋបានយល់ព្រមបង្កើតឡើងជាច្បាប់សម្រាប់រៀបចំរដ្ឋាភិបាល ព្រមទាំងគ្រប់គ្រងដោយយោលទៅតាមមតិភាគច្រើន។ ដូចនេះ គំនិតយោបល់ ឬឆន្ទៈភាគច្រើន និងសិទ្ធិរបស់ពលរដ្ឋម្នាក់ៗអាចកំណត់នូវអំណាចរបស់រដ្ឋាភិបាល។ លោកអះអាងដែរថា កម្មសិទ្ធិឯក ជន គឺតម្រូវធ្វើការទៅតាមធម្មជាតិ គឺមិនមានលក្ខណៈបង្ខិតបង្ខំពីបុគ្គលណាម្នាក់ឡើយ ធ្វើការងារទៅ តាមកម្លាំង និងវិចារណញ្ញាណរបស់ខ្លួន។ ឡុក បានបន្ថែមទៀតថា ទោះបីជាបុគ្គលម្នាក់ៗមានសិទ្ធិពី ធម្មជាតិក៏ដោយវានឹងបាត់បង់នូវសិទ្ធិទាំងនោះវិញ នៅពេលណាដែលយើងលែងទទួលស្គាល់នូវតួនាទីនៃវិចារណញ្ញាណ ហើយជំនួសមកវិញនូវអំពើប្រព្រឹត្តិដូចសត្វជាតុ។ ចុះបើប្រជាជនមានសិទ្ធិពីធម្មជាតិ ហើយយល់ដឹងពីច្បាប់ធម្មជាតិ ហេតុអ្វីបានជាគេប្រាថ្នាចេញពីរដ្ឋធម្មជាតិ ? ចន ឡុក ថា គោលបំណងដ៏សំខាន់បំផុតរបស់មនុស្ស គឺរួបរួមគ្នានៅក្នុងរដ្ឋាភិបាលដើម្បីការពារទ្រព្យសម្បត្តិរបស់ពួកគេ។

រដ្ឋាភិបាលនេះគឺត្រូវធានានូវសន្តិភាព និងសណ្តាប់ធ្នាប់សង្គមទាំងគោលនយោបាយ សេដ្ឋកិច្ច ក្នុងនោះគឺរដ្ឋាភិបាលមានអំណាចគ្រប់គ្រាន់ក្នុងការដាក់ទណ្ឌកម្ម។ ការពារនូវទ្រព្យសម្បត្តិឯកជនដែលពលរដ្ឋម្នាក់ៗខំធ្វើការងារទៅតាមសមត្ថភាពរបស់គេ ហើយរដ្ឋាភិបាលត្រូវប្រើអំណាចក្នុងការធ្វើឱ្យ មាន សេចក្តីទុកចិត្តចំពោះអំពើផ្សេងៗដើម្បីគោលដៅជាក់លាក់ណាមួយ។

ពួកគេបានយល់ព្រមនឹងគ្នាដើម្បីបង្កើតច្បាប់ និងអនុវត្តច្បាប់តាមសង្គម ក៏ប៉ុន្តែគ្មាននរណាម្នាក់បង្កើតច្បាប់ឡើង ហើយផ្លាស់ប្តូរនូវលក្ខខណ្ឌរបស់គេដោយគោលបំណងអាក្រក់ទេ។ គឺបង្កើតច្បាប់សម្រាប់គ្រប់គ្រងឱ្យបានល្អរីកចម្រើន ទោះមានការខុសឆ្គងនៅផ្នែកណាក៏គេធ្វើការផ្លាស់ប្តូរឱ្យមានលក្ខណៈសមស្របនឹងលក្ខខណ្ឌដ៏ត្រឹមត្រូវ។ ច្បាប់នេះត្រូវបានបង្កើតឡើងដើម្បីបង្ហាញបញ្ជាក់ពីសិទ្ធិ របស់គេដែលបានពីធម្មជាតិដោយគោរពល់គ្នាធ្វើយ៉ាងណាដើម្បីពង្រឹកកម្លាំងហើយអនុវត្តន៍ដោយយោលទៅតាមការយល់ព្រមគ្នាភាគច្រើន។ ក្នុងហេតុផលខាងលើ ចន ឡុក បានចាត់ទុករបបរាជានិយម ថាមិនមែនជារដ្ឋាភិបាលរបស់ប្រជាជនទាល់តែសោះ។

John Locke ប្រឆាំងនឹងរបបរាជានិយមផ្តាច់ការដែលយកពន្ធដារតាមទំនើងចិត្ត រឹបអូសយកកម្មសិទ្ធិរំលោភលើសេរីភាព។ ល។ លើសពីនេះ អំណាចផ្តាច់ការ ឬរាជានិយមផ្តាច់ការ រឹតតែធ្វើឱ្យ John Locke កាន់តែព្រួយបារម្ភណ៍ថែមទៀត។ គំនិតរបស់ John Locke ចង់ឱ្យវត្តមានរដ្ឋដែលអនុញ្ញាត និងថែរក្សាឱ្យមាននូវកម្មសិទ្ធិឯកជន។ ដូច្នេះទស្សនៈរបស់គាត់ផ្តោតខ្លាំងទៅលើអំណាច និងកម្មសិទ្ធិឯកជន ។ ចំណុចទាំងពីរនេះវាត្របាញ់ចូលគ្នាក្នុងទស្សនៈវិស័យវឌ្ឍនភាពសេដ្ឋកិច្ច ដែលជាកត្តាដ៏សំខាន់ ដែលត្រូវលើកឡើងជាបញ្ហាក្នុងបច្ចុប្បន្ន។

រដ្ឋាភិបាលរបស់ ឡុក គឺជារដ្ឋាភិបាលបែបលទ្ធិប្រជាធិបតេយ្យដែលយកគោលគំនិតមតិភាគ ច្រើននៅក្នុងការបង្កើតច្បាប់ ដើម្បីរក្សានូវសណ្តាប់ធ្នាប់សង្គមឱ្យមានគោលនយោបាយក្នុងការដឹកនាំ ប្រកបដោយសុភវិនិច្ឆ័យត្រឹមត្រូវ ឯកភាពជ្ប។ ព្រោះមនុស្សម្នាក់ៗតែងចង់បាន និងប្រាថ្នាស្វែងរកយុត្តិ ធម៌ក្នុងសង្គមមានតម្លាភាពទាំងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនៅក្នុងករណីមានការរំលោភបំពានមក លើខ្លួន និងអ្នកដទៃពីសំណាក់ជនមានអំណាច និងអ្នកនយោបាយ ដែលយកប្រជារាស្រ្តធ្វើជាឈ្នាន់ សម្រាប់ជាន់ដើម្បីសម្រេចបំណងរបស់គេ។ រដ្ឋាភិបាល ឡុក ជារដ្ឋាភិបាលមួយដែលមានលក្ខណៈ ត្រឹមត្រឹមដែលចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋទាំងអស់។

### ៥.២.៦ លក្ខណៈធម្មជាតិរបស់មនុស្ស

John Locke បានបកស្រាយស្ថានភាពធម្មជាតិរបស់មនុស្ស ជាស្ថានភាពដែលមានសេរីភាពគ្រប់គ្រាន់ក្នុងការទំនាក់ទំនងរវាងបុគ្គល និងបុគ្គល។ ស្ថានភាពធម្មជាតិជាស្ថានភាពដែលពោរពេញទៅដោយសមភាពទាំងអំណាច ទាំងសិទ្ធិ សុទ្ធតែស្មើៗគ្នាគ្រប់បុគ្គលទាំងអស់ ដោយមិនមានបុគ្គលណាម្នាក់មានសិទ្ធិអំណាចច្រើនជាងអ្នកដទៃនោះទេ ហើយមានសិទ្ធិសេរីភាពមិនអាចមិនអាចកាត់ផ្តាច់ពីបុគ្គលឡើយក្នុងស្ថានភាពធម្មជាតិ។ សភាពធម្មជាតិ ជាកន្លែងដំបូងដែលបានផ្តល់សិទ្ធិឱ្យមនុស្ស។ ស្ថានភាពធម្មជាតិ មានសភាពសន្តិភាព និងជាសភាពដែលមនុស្សមានសុឆន្ទៈចង់ជួយគ្នាទៅវិញទៅមកជាសភាពដែលមានវិចារណញ្ញាណអាចយល់ដឹងពីច្បាប់ធម្មជាតិបាន និងជាសភាពដែលមនុស្សចេះសម្របសម្រួលនូវអាកប្បកិរិយារបស់ខ្លួនទៅនឹងច្បាប់ធម្មជាតិ។ តាមតែសភាពធម្មជាតិក៏ជាសភាពដែលខ្វះខាត ព្រោះមិនមានការកំណត់ច្បាប់ និងប្រកាសឱ្យប្រើប្រាស់ច្បាប់សម្រាប់អ្នកទាំងអស់គ្នាឡើយ។ ក្នុងសភាពធម្មជាតិ ខ្វះនូវអំណាចតុលាការ សម្រាប់ទប់ស្កាត់ មិនឱ្យមានការសងសឹកគ្នា ការជជែកគ្នាយកចាញ់ឈ្នះ តាមលក្ខណៈជាក់ស្តែងឡើង ដូចរូបភាពជាកូនក្តីផងជាមេធាវីផង ជាចៅក្រមផងនោះឡើយ។ ប្រព័ន្ធរស់នៅក្នុងសភាពធម្មជាតិមិនអាចឋិតនៅបាន ដូច្នេះកម្មសិទ្ធិរបស់មនុស្សមិនអាចរក្សាទុកល្អបានទេ បើគ្មានសង្គមក៏គ្មានរដ្ឋដែរ។ ដូច្នេះ សង្គមជាអ្នកថែរក្សា ជាអ្នកជួយសម្រួលស្ថានភាពដល់កម្មសិទ្ធិទាំងនោះ។ ធម្មជាតិនេះមានសារៈសំខាន់ណាស់ ពីព្រោះសេរីភាពជាសម្បត្តិដ៏ពិសិដ្ឋរបស់មនុស្សដែលកើតចេញពីធម្មជាតិហ្នឹងឯង។ John Locke យល់ថា «តាមធម្មជាតិមនុស្សកើតមកនាំមកជាមួយគំនិតចង់បានកម្មសិទ្ធិឯកជន ។ កម្មសិទ្ធិឯកជនចាក់ឫសយ៉ាងជ្រៅក្នុងសភាពធម្មជាតិ។ ការដែលមនុស្សចង់បានកម្មសិទ្ធិនោះគឺមិនមានអ្វីប្រឆាំងនឹងសង្គមដែរ។ ប៉ុន្តែផ្ទុយទៅវិញកម្មសិទ្ធិឯកជននេះហើយ ដែលបានជួយរុញច្រានសង្គមឱ្យមានសំទុះទៅមុខជាមួយនឹងវឌ្ឍនភាពយ៉ាងឆាប់រហ័ស» ។

### ៥.២.៧ មូលហេតុដែលនាំឱ្យមនុស្សត្រូវការកិច្ចព្រមព្រៀងគ្នាជាសង្គម

ទី១-មនុស្សចូលមករួមគ្នាជាសង្គម មូលហេតុ គឺព្យាយាមរកសន្តិភាព សុវត្ថិភាព និងការថែរក្សាសម្បត្តិកម្មសិទ្ធិរបស់ខ្លួនឱ្យគង់វង្ស។ ដូច្នេះដើម្បីទទួលបាននូវសុវត្ថិភាពចាំបាច់ត្រូវការច្បាប់ និងតុលាការក្នុងសង្គមនោះ។ ក្នុងសភាពធម្មជាតិ បើមានការរំលោភបំពានណាមួយកើតឡើងក៏ពុំទាន់មាន ការដាក់ទណ្ឌកម្មឱ្យសមស្របទៅនឹងឆន្ទៈរបស់ជនរងគ្រោះដែរ។ ដូច្នេះ ការដាក់ទណ្ឌកម្ម គឺធ្វើឡើងតាមគំនិតផ្តួចផ្តើមនៃជនរងគ្រោះនិងប្រជារាស្រ្តទូទៅ។ ការស្វែងរកយុត្តិធម៌ក្នុងសភាពធម្មជាតិនៅមាន លក្ខណៈជាការស្វែងរកសម្រាប់បុគ្គលម្នាក់ៗដែលជាអ្នករងគ្រោះនោះ ឬទង្វើនោះ ធ្វើតាមកំហឹងផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ យ៉ាងនេះគេឱ្យឈ្មោះថា«យុត្តិធម៌ឯកជន»។ ក្នុងករណីជនរងគ្រោះ មិនមានសមត្ថភាព និងលទ្ធភាពស្វែងរកយុត្តិធម៌នោះ ពួកគេត្រូវឋិតនៅក្នុងជនរងគ្រោះអយុត្តិធម៌។ John Locke មើលឃើញថា « ក្នុងសភាពបែបធម្មជាតិ មនុស្សទាំងឡាយមិនត្រូវបានការពារដោយច្បាប់ពីសំណាក់ការរំលោភបំពានឡើយ ព្រោះមនុស្សពុំទាន់បានបង្កើតអង្គការ រៀបចំសណ្តាប់ធ្នាប់សង្គម និងការដាក់ទណ្ឌកម្ម ទៅលើបទល្មើសនៅឡើយ។ ដោយចង់បញ្ចប់នូវជម្លោះពីម្នាក់ទៅម្នាក់ និងទទួលបាននូវយុត្តិធម៌នោះទើបមនុស្សទាំងឡាយយល់ព្រមគ្នានឹងគ្នា បង្កើតឱ្យមានជាអង្គការសង្គមមួយដែលអាចការពារជីវិតបុគ្គល និងសិទ្ធិសេរីភាព គ្រប់យ៉ាងរបស់ពួកគេ។

ទី២- ហេតុផល ដែលតម្រូវឱ្យមនុស្សប្រួបរួមគ្នាជាសង្គមតូចៗ ឬធំៗ គឺជួយកាត់បន្ថយនូវបន្ទុកនៃការលំបាក។ ដូចនេះ ចាំបាច់បង្កើតវត្ថុដែលតំណាងឱ្យសម្ភារៈពោល គឺពាក់ព័ន្ធនឹងការប្រើប្រាស់រូបិយប័ណ្ណនេះក្នុងគោលបំណងរក្សានូវកម្មសិទ្ធិផ្ទាល់ខ្លួន។ នេះជាកត្តាចម្បងដែលបង្ហាញឱ្យឃើញថាមនុស្សកំពុងតែដកខ្លួនបន្តិចម្តងៗឱ្យឃ្លាតឆ្ងាយពីជីវភាពបែបធម្មជាតិ។ ចរន្តនេះបានធ្វើឱ្យមនុស្សក្នុងសង្គមមានភាពខុសប្លែកពីគ្នាកាន់តែខ្លាំង។ ដូច្នេះ រដ្ឋគឺជាទីកន្លែងបង្អែក ជាកន្លែងដែលមានសុវត្ថិភាព មាន សណ្តាប់ធ្នាប់ មានច្បាប់ហើយក៏ជាក្តីសង្ឃឹមរបស់គេនាពេលអនាគតដែរ។

ទី៣- មនុស្សបានទទួលផលប្រយោជន៍ពេលគេចាកចេញពីសភាពធម្មជាតិ គឺដោយសារគេមានបញ្ហាសន្តិសុខ បញ្ហាចាញ់ប្រៀប ហើយគេទាំងអស់គ្នាតែងគិតថា គេនឹងបានស្រួលជាងនេះ ប្រសិនបើមានច្បាប់ជាធរមានមានចៅក្រមសម្រាប់បកស្រាយច្បាប់ និងអនុវត្តន៍ច្បាប់នោះផង ។

ទី៤- ដើម្បីបញ្ចប់សង្គ្រាម មិនចេះឈប់ឈររវាងមនុស្ស និងមនុស្ស ជាបុគ្គលជាក្រុម និងដើម្បីការពារជីវិតបុគ្គលនោះឯង ។

ទី៥- មនុស្សចាកចេញពីសភាពធម្មជាតិមករស់នៅក្នុងសភាពបែបថ្មីក្នុងរដ្ឋនេះសុទ្ធតែមានមូលហេតុបានន័យថា បើគ្មានភ្លើងក៏គ្មានផ្សែងដែរព្រោះកាលណាកម្មសិទ្ធិរបស់ពួកគេកាន់តែសម្បូរក៏ធ្វើឱ្យពួកគេកាន់តែមានវិសមភាពធំធេងជាងមុន។ សុវត្ថិភាពរបស់ពួកគេក៏កាន់តែត្រូវបានទទួលការគំរាមកំហែង។ ច្បាប់ដែលបានអនុម័តនៅក្នុងរដ្ឋចាំបាច់ត្រូវតែការពារសុវត្ថិភាពសង្គម និងរដ្ឋខ្លួនឯងតែម្តង។ តាមទស្សនៈរបស់លោក John Locke រដ្ឋមានតួនាទីសំខាន់ គឺដាក់ទណ្ឌកម្មដល់អ្នករំលោភច្បាប់ ក្រៅពីនេះរដ្ឋមានតួនាទីផងដែរក្នុងការធានាឱ្យមាននូវសិទ្ធិសេរីភាព សមភាព និងសុវត្ថិភាពរបស់ពលរដ្ឋ។ រដ្ឋគឺជាអង្គការរបស់អ្នកមានសិទ្ធិដែលចង់បានមធ្យោបាយដ៏មានប្រសិទ្ធិភាពដើម្បីថែរក្សាកម្មសិទ្ធិដែលគេរកបានសមស្របទៅនឹងស្ថានភាពធម្មជាតិរបស់ពួកគេ។ ក្នុងន័យនេះរដ្ឋ គឺគ្រាន់តែជាឧបករណ៍សម្រាប់បម្រើកម្មសិទ្ធិតែប៉ុណ្ណោះ ។

# មេរៀនទី៦ ម៉ុងតេស្គីយើ

( Montesquieu 1689-1755 )

## ៦.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ

ម៉ុងតេស្គីយើ កើតនៅ Brède ក្បែរទីក្រុង Bordeaux ប្រទេសបារាំងហើយស្លាប់នៅទីក្រុងប៉ារីស។ លោកបានសិក្សាផ្នែកនីតិសាស្ត្រ តែគាត់ពុំពេញចិត្តចំពោះចំណេះដែលបានពីសាលានោះទេ ព្រោះគាត់ចង់ស្វែងយល់ពីគោលការណ៍ខាងក្នុង(spirit)របស់វា។ ពាក្យគោការណ៍នៅទីនេះ មានន័យថាជាកម្លាំងជំរុញ ឬអាចនិយាយថាជានិន្នាការដែលនាំឱ្យគេដើរទៅមុខ។

នាក់ឡុងឆ្នាំ ១៧២៦ ដោយចំណងនៃការស្រាវជ្រាវ និងការជញ្ជឹងគិតបានធ្វើឱ្យគាត់លះបង់ការងារដែលធ្លាប់ធ្វើជាទីប្រឹក្សាសភា និងប្រធានសភា Bordeaux ចេញដំណើរទៅក្រៅប្រទេស មានអ៊ីតាលី ហុងគ្រី ហូឡង់ អង់គ្លេស។ល។ ដើម្បីស្វែងនិងសិក្សាថា ហេតុដូចម្ដេចបានជានៅក្នុងប្រទេសមួយផ្សេងគ្នាមានច្បាប់ខុសគ្នា? ហេតុដូចម្ដេចបានច្បាប់ខ្លះមានប្រសិទ្ធិភាព ច្បាប់ខ្លះទៀតគ្មានប្រសិទ្ធិភាព ?

ការសិក្សាស្រាវជ្រាវ និងស្នាដៃសំខាន់ៗនានាបានធ្វើឱ្យគាត់ក្លាយជាទស្សនវិទូនយោបាយ កវីនិពន្ធ អ្នកទ្រឹស្ដីច្បាប់រដ្ឋបារាំង និងត្រូវបានគេចាត់ទុកថាជាបិតានៃវិទ្យាសាស្ត្រនយោបាយ និងជាស្ថាបនិកសង្គមវិជ្ជាដ៏ល្បីល្បាញមួយរូប។ លោកគឺជាអ្នកប្រឆាំងទៅនឹងទ្រឹស្ដីផ្ដាច់ការនិយម និងព្យាយាមបកស្រាយឱ្យយល់ពីគោលការណ៍ផ្ដត់ផ្ដង់ច្បាប់ និងការបែងចែកអំណាចក្នុងរដ្ឋ ព្រមទាំងបង្ហាញលក្ខណៈខ្វះខាតនៃទម្រង់គ្រប់គ្រងរដ្ឋតាមបែបផ្សេងៗ។ ស្នាដៃល្បីល្បាញពីរបស់លោកគឺ ៖ (១)The Spirit of Law បោះពុម្ពលើកទី ១ នាឆ្នាំ១៧៤៨ និង២) ទ្រឹស្ដីនៃការបែងចែកអំណាច។

## ៦.២ ទស្សនៈនយោបាយ

### ៦.២.១ អំពីច្បាប់

Montesquieu ឱ្យនិយមន័យពាក្យច្បាប់ថា «ក្នុងន័យទូលាយរបស់វា ច្បាប់គឺទំនាក់ទំនងចាំបាច់ទាំងឡាយដែលចេញមកពីអ្វី និងអ្វីនឹងកើតឡើង។ តាមនិយមន័យនេះ ច្បាប់ដូចជាទំនាក់ទំនងចាំបាច់ មានន័យថា ច្បាប់លែងមានន័យទៅតាមទស្សនៈទាន ទេវវិជ្ជា ឬតាមប្រពៃណីដូចមុនទៀតហើយ។ ការធ្វើឱ្យមានទំនាក់ទំនងមានភាពត្រឹមត្រូវ គឺជាភារៈកិច្ចចាំបាច់របស់ច្បាប់ សម្រាប់ភាវៈទាំងអស់តាំងពីធំដល់តូច។ ក្នុងន័យនេះភាវៈទាំងអស់សុទ្ធតែមានច្បាប់របស់វាអាទិទេពក៏មានច្បាប់  អ្នកមានបញ្ញាខ្ពស់ជាងមនុស្សក៏មានច្បាប់ សត្វក៏មានច្បាប់ មនុស្សសាមញ្ញក៏មានច្បាប់»។ គាត់អះអាងថា «ច្បាប់ទំនៀមទម្លាប់ ប្រពៃណី និងច្បាប់បញ្ញត្តិគ្រប់ជាតិសាសន៍ទាំងអស់សុទ្ធតែមានប្រភពកំណើតរបស់ខ្លួនចេញពីមូលហេតុ២យ៉ាងគឺកាយមូលហេតុ និងសីលមូលហេតុ។

កាយមូលហេតុគឺជាមូលហេតុដែលមានចំណងទាក់ទងទៅនឹងអាកាសធាតុ ទឹកដី ទំហំ ទីតាំង ភូមិសាស្ត្រ និងដង់ស៊ីតេប្រជាជន។ ធាតុអាកាសមានឥទ្ធិពលទៅលើចរឹតមនុស្ស។ ដោយមនុស្សជាអ្នកបង្កើតច្បាប់ ដូចនេះអាកាសធាតុក៏មានឥទ្ធិពលទៅលើច្បាប់ដែរ។ ច្បាប់ដែលកើតចេញពីចរឹតមនុស្ស តណ្ហាមនុស្ស លក្ខណៈមនុស្សគឺសុទ្ធតែនាំមកជាមួយនូវឥទ្ធិពលនៃអាកាសធាតុ ដូច្នេះសម្រាប់តំបន់ពីរខុសគ្នាច្បាប់ក៏មានលក្ខណៈខុសគ្នាដែរ។ សង្គមបែបណា បរិយាកាសបែបណា ភូមិសាស្ត្របែបណា ប្រវត្តិសាស្ត្របែបណា វប្បធម៌បែបណា មុខជំនាញឯកទេសបែបណា មនុស្សបែបណា នាំឱ្យច្បាប់មានលក្ខណៈបែបនោះដែរ។

លោកបានបញ្ជាក់ថា «ច្បាប់បញ្ញត្តិទាំងឡាយ មានចំណងទាក់ទងយ៉ាងជិតស្និទ្ធបំផុតទៅនឹងការប៉ិនប្រសប់នានាដែលប្រជាជនខុសៗគ្នាមានពីធម្មជាតិស្រាប់ សម្រាប់ធ្វើជាមធ្យោបាយចិញ្ចឹមជីវិត»។ ក្នុងចំណោមកាយមូលហេតុ កត្តាភូមិសាស្ត្រ ក៏ជាមូលហេតុចម្បងនៃកំណាក់កំណើតច្បាប់ និងរដ្ឋ។

សីលមូលហេតុៈ ជាមូលហេតុដែលស្តែងឡើងជាសកម្មភាពយឺតបន្តិច បើធៀបទៅនឹងកាយមូលហេតុគឺកើតឡើងនៅពេលដែលសង្គមមានការរីកចម្រើនផ្នែកអរិយធម៌។ទាក់ទងទៅនឹងមូលហេតុប្រភេទនេះមានគោលការណ៍ នៃរបបនយោបាយ ជំនឿ សាសនា សីលធម៌ និងទំនៀមទម្លាប់ ប្រពៃណី។ សីលមូលហេតុ គឺជាមូលហេតុនៃស្មារតី ឬព្រលឹងរបស់មនុស្សគ្រប់ៗ រូប។ មូលហេតុនេះ មានឥទ្ធិពលទៅលើការបង្កើតច្បាប់ប្រជាជាតិខ្លាំងជាងកាយមូលហេតុ។

- ប្រភពច្បាប់ចែកជាពីរៈ

**- ច្បាប់ពិភពរូបវន្ត** គឺជាច្បាប់វិទ្យាសាស្ត្រ ច្បាប់ទំនាក់ទំនង និងច្បាប់ពិពណ៌នា ក្នុងពិភពសច្ចៈ។ ច្បាប់នេះមិនប្រែប្រួលទេហើយថែមទាំងគ្រប់គ្រងលើពិភពរូបធាតុទាំងអស់ទៀតផង ច្បាប់នេះមានចរឹតជាច្បាប់ធម្មជាតិ។

**- ច្បាប់ពិភពបញ្ញា** គឺជាច្បាប់ដែលកើតចេញពីសមត្ថភាពនៃខួរក្បាលរបស់មនុស្ស។ ច្បាប់នេះ មានបង្កប់នូវតំលៃកាតព្វកិច្ច និងបញ្ញត្តិយ៉ាងច្រើនដែលមានការប្រែប្រួល ព្រោះភាវៈមានបញ្ញាច្រើនមានការភាន់ច្រលំដោយសារតែឋិតនៅក្រោមតណ្ហារបស់មនុស្ស។ គាត់ចែកច្បាប់ពិភពបញ្ញា ចែកចេញជា ៣ ទៀត គឺ

**ក. ច្បាប់សាសនា** គឺជាច្បាប់ ដែលប្រកាសឱ្យប្រើប្រាស់ដោយអាទិទេព សម្រាប់ក្រើនរំលឹកស្មារតីមនុស្សឱ្យចងចាំនូវករណីយកិច្ចរបស់ខ្លួនចំពោះព្រះអាទិទេព។

**ខ. ច្បាប់សីលធម៌** គឺជាច្បាប់ ដែលប្រកាសឱ្យប្រើប្រាស់ដោយទស្សនវិទូ សម្រាប់ក្រើនរំលឹកស្មារតី មនុស្សឱ្យចងចាំនូវករណីយកិច្ច របស់ខ្លួនចំពោះខ្លួនឯង។

**គ. ច្បាប់នយោបាយ និងច្បាប់រដ្ឋប្បវេណី** គឺជាច្បាប់ដែលប្រកាសឱ្យប្រើប្រាស់ដោយអ្នកតែង ច្បាប់សម្រាប់ក្រើនរំលឹកដល់ស្មារតីរបស់មនុស្សឱ្យចងចាំនូវករណីយកិច្ចរបស់ខ្លួនចំពោះអ្នកដទៃនិងសង្គម។ លោកបានបែងចែកច្បាប់បែបនេះតាមកម្មវត្ថុរបស់វា។ ច្បាប់រដ្ឋប្បវេណី ជាច្បាប់ដែលទាក់ទងទៅនឹងការកកើតរដ្ឋ។ ច្បាប់នយោបាយគឺជាច្បាប់ដែលទាក់ទងទៅនឹងការរក្សា រដ្ឋ។ ពិតមែនតែច្បាប់ទាំងពីរនេះ មានកម្មវត្ថុខុសគ្នាក្តី ក៏ច្បាប់ទាំងពីរនេះមិនអាចដាច់ពីគ្នាបានឡើយក្នុងន័យនេះ បានជាគេចាត់ទុក Montesquieu ថាជាអ្នកទ្រឹស្តីនៃរដ្ឋប្រវត្តិសាស្ត្រ។ ច្បាប់នយោបាយ និងច្បាប់រដ្ឋប្បវេណីមានទំនាក់ទំនងជាមួយនឹងច្បាប់នៃប្រភពរូបវន្ត។

ឧត្តមគតិរបស់លោក Montesquieu គឺចង់បានឱ្យច្បាប់នយោបាយ និងច្បាប់រដ្ឋប្បវេណី មាន លក្ខណៈសុក្រឹតមិនប្រែប្រួលដូចច្បាប់វិទ្យាសាស្ត្រ ឬច្បាប់នៃប្រភពរូបវន្តដែរ។ ហើយច្បាប់ទៀតសោត មានរូបរាងប្លែកៗទៅតាមលក្ខ័ណ្ឌនយោបាយ និងធាតុអាកាស។

### ៦.២.២ ឥទ្ធិពលនៃបទដ្ឋានភូមិសាស្ត្រ

លោក Montesquieu ពិនិត្យឃើញថាអាកាសធាតុមានឥទ្ធិពលទៅលើចរិតមនុស្ស ហើយដោយសារមនុស្សជាអ្នកបង្កើតច្បាប់ ដូច្នេះធាតុអាកាសក៏មានឥទ្ធិពលទៅលើច្បាប់ដែរ។

***-ឥទ្ធិពលអាកាសធាតុទៅលើចរិតមនុស្ស***

ខ្យល់ត្រជាក់ធ្វើឱ្យមានកម្លាំង ខ្យល់ក្តៅបន្ថយកម្លាំង។ លោកសរសេរថា« គេមានកម្លាំងកាយ កម្លាំងចិត្តនៅក្នុងអាកាសធាតុត្រជាក់ គេមានការទុកចិត្តលើខ្លួនឯងជាងគេមានសេចក្តីក្លាហានជាងគេមានចំណង់សងសឹកតិចជាងគេ មានភាពស្មោះត្រង់ជាង»។

***-ឥទ្ធិពលអាកាសធាតុទៅលើច្បាប់***

ច្បាប់ដែលសម្ដែងចេញពីចរិតមនុស្សតណ្ហា របស់មនុស្សលក្ខណៈរបស់មនុស្សក៏មានជាប់ស្នាមធាតុអាកាសនៅជាមួយដែរ។ ធាតុអាកាសក៏មានឥទ្ធិពលទៅលើដី និងទៅលើជីវិតសេដ្ឋកិច្ច ហើយច្បាប់ ក៏មិនដូចគ្នាទេ សម្រាប់ប្រជាជនជាកសិករ ប្រជាជនជាអ្នកប្រមាញ់ និងប្រជាជនជាអ្នកនេសាទ។ លោក Montesquieu បានសរសេរថា «ច្បាប់ ត្រូវមានទំនាក់ទំនង ជាមួយនឹងរូបសាស្ត្ររបស់ប្រទេស ធាតុអាកាសត្រជាក់ ក្ដៅ ទំហំ របៀបរស់នៅរបស់ប្រជាកសិករ អ្នកប្រមាញ់ ជាអ្នកគង្វាល កម្រិត សេរីភាព ជំនឿរបស់អ្នកស្រុក ធនធានរបស់គេ ទំនៀមរបស់គេ»។ ដូច្នេះ ពាក្យអាកាសធាតុនេះ លោកMontesquieu ពិនិត្យមិនត្រឹមតែលក្ខណៈ អាកាសធាតុភូមិសាស្ត្រប៉ុណ្ណោះទេ គឺថែមទាំងលក្ខណៈសេដ្ឋកិច្ច ប្រវត្តិសាស្ត្រ វប្បធម៌ និយាយរួមគ្រប់លក្ខណៈសង្គមសាស្ត្រទាំងអស់។

ហេតុនេះហើយ បានជាគេចាត់ទុកលោក Montesquieu ជាស្ថាបនិកសង្គមវិជ្ជាពិតៗ។

### ៦.២.៣ អំពីរបបគ្រប់គ្រងរដ្ឋ

លោកបានធ្វើការបែងចែករបបនយោបាយជា ៣ ប្រភេទគឺ

ក. របបសាធារណរដ្ឋ: ជារបបគ្រប់គ្រងដែលអំណាចស្ថិតក្នុងកណ្ដាប់ដៃ ឬជារបស់ប្រជាជនទាំងមូល ឬរបស់អ្នកមានមួយក្រុមតូច។ ប្រសិនបើសាធារណរដ្ឋជារដ្ឋរបស់ប្រជាជនទាំងមូល នោះឈ្មោះថា ប្រជាធិបតេយ្យ (Democracy)។ ប្រសិនបើសាធារណរដ្ឋ ជារដ្ឋរបស់អ្នកមានមួយក្រុមតូចនោះឱ្យឈ្មោះថាជាអភិជនាធិបតេយ្យ (Aristocracy)។ គោលការណ៍របស់សាធារណរដ្ឋ ទោះជា ប្រជាធិបតេយ្យ ឬអភិជនាធិបតេយ្យក៏ដោយ ក៏វានៅតែស្ដែងឡើងជាគុណធម៌ ជាការស្រឡាញ់មាតុភូមិ ការស្រឡាញ់សមភាព ច្បាប់ លះបង់ផលប្រយោជន៍ផ្ទាល់ខ្លួនដើម្បីផលប្រយោជន៍សាធារណៈដែរ។

**- សាធារណរដ្ឋប្រជាធិបតេយ្យ:** ធម្មជាតិរបស់សាធារណរដ្ឋប្រជាធិបតេយ្យ គឺជាការប្រគល់អំណាចអធិបតេយ្យទៅឱ្យសំណុំប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋមានអំណាចអធិបតេយ្យ។ អ្នកតំណាង ឡើងកាន់អំណាចបានតាមរយៈការបោះឆ្នោត។ ការបោះឆ្នោតនេះបញ្ជាក់នូវឆន្ទៈប្រជាពលរដ្ឋ ដូចនេះ ឆន្ទៈនៃអ្នកកាន់អំណាចអធិបតេយ្យជាឆន្ទៈរបស់ពលរដ្ឋ ដែលក្នុងន័យនេះប្រជារាស្ត្រជាសំណុំពលរដ្ឋ ដែលអ្នកតំណាងកាន់អំណាចត្រូវគោរពឆន្ទៈរបស់ពលរដ្ឋ។មើលពីជ្រុងម្ខាងទៀតឃើញថាពលរដ្ឋបញ្ជានៅជ្រុងម្ខាងទៀត ពលរដ្ឋជាអ្នកគោរព ដូចពួកគេក្លាយជាអ្នកកាន់អំណាចតាមរយៈតំណាង។ សំណួរ ចោទថា តើការពិតពលរដ្ឋគោរពច្បាប់ជាងបញ្ជាមែនឬទេ? សំណួរនេះអាចឆ្លើយបានយោលទៅតាម ពេលវេលា និងទីកន្លែង។

ចំណែកឯគោលការណ៍សាធារណរដ្ឋប្រជាធិបតេយ្យ គឺជាសច្ចធម៌ នោះជាទេពកោសល្យនៃ ពលរដ្ឋម្នាក់ៗ ឬជាបុគ្គលជូនដល់ផលប្រយោជន៍ទូទៅ។ ការបូជាជាការលំបាកខ្លាំងណាស់ តែបើគ្មាន ការបូជាដល់ផលប្រយោជន៍ទូទៅនៃរដ្ឋទេនោះ រដ្ឋត្រូវដួលរលំ ព្រោះនៅក្នុងប្រជាធិបតេយ្យអ្វីៗចំណុះ ទៅនឹងមតិភាគច្រើន តែម្នាក់ៗចំណុះទៅនឹងលក្ខណៈនៃបុគ្គលជាពលរដ្ឋ ផ្ដុំឡើងពីបុគ្គលនីមួយៗឡើង ទៅ។

**- សាធារណរដ្ឋអភិជនាធិបតេយ្យ:** ជាធម្មជាតិសាធារណរដ្ឋអភិជនាធិបតេយ្យ អំណាចអធិបតេយ្យស្ថិតនៅក្នុងដៃមនុស្សមួយចំនួនតូចដែលមិនព្រួយបារម្ភការគោរពដល់ច្បាប់កំណត់ខ្លួនឡើយ។ សច្ចធម៌នៃគោលការណ៍សមភាពមិនត្រូវបានដាក់ឱ្យអនុវត្តន៍ទេ ព្រោះវិសមភាពកើតមានជាធម្មជាតិនៅក្នុងរបបបែបនេះទៅហើយ។ ពាក្យថាសមល្មមក្នុងន័យនេះបានន័យថា វិសមភាពដែលជា ទស្សនទានរបស់អារីស្តូត។ គេត្រូវការនូវការជំរុញបន្ថែមឱ្យឃ្លាតទៅកាន់តែវិសមភាពដែលជាមូលដ្ឋាននៃរបបនេះ។ នៅក្នុងស្ថានភាពរបបអភិជនាធិបតេយ្យសាធារណរដ្ឋ ច្បាប់ក៏ត្រូវបានសាកល្បងរៀបចំឱ្យមានសមភាពដែរ តែស្ថិតនៅដោយឡែកតាមនិយមន័យនៃរបប។

ខ. របបរាជាធិបតេយ្យ: ជារដ្ឋរបស់មនុស្សម្នាក់ ដែលស្ថិតនៅក្រោមច្បាប់ដែលមិនប្រែប្រួល និងដែលច្បាប់នោះបម្រើគោលបំណងតែមនុស្សម្នាក់ខាងលើ។

**- តាមធម្មជាតិមនុស្សតែម្នាក់ជាអ្នកគ្រប់គ្រងៈ** យើងត្រូវប្រុងប្រយ័ត្នដែរ ព្រោះយោងតាមធម្មជាតិ របស់វាពាក្យថា**មនុស្សតែម្នាក់**គ្រប់គ្រងមិនទៅតាមចិត្តខ្លួនទាំងអស់នោះទេព្រោះមិនចំណុះទៅនឹងឆន្ទៈដោយសេរី និងតាមល្បិចរបស់ខ្លួនទាំងអស់នោះទេ។ ជាធម្មជាតិនៃរបបនេះមានកម្លាំងនានាបង្ខំ ព្រះរាជាឱ្យគោរពច្បាប់កំណត់នៃការរៀបចំអង្គការផងដែរ។ កម្លាំងការប្រឆាំងកម្លាំង នោះជាអង្គ ឬជាអំណាចកណ្តាលដែលម៉ុងតេស្គីយើហៅថាច្បាប់តម្កល់។ ច្បាប់បានបំបែកនូវអំណាចអធិបតេយ្យ តែមួយ របស់អ្នកគ្រប់គ្រង ឬព្រះរាជា។ អំណាចកណ្តាលនោះគឺពួកអភិជន ពួកមេសាសនាដូចជាបុរី បុព្វសិទ្ធិ ដែលមានបន្ទុកច្បាប់ដោយខ្លួនផ្ទាល់រួមទាំងសភា និងតុលាការផងដែរ។

**- កិត្តិយសគោលការណ៍នៃរាជាធិបតេយ្យៈ** មិនមែនសច្ចធម៌ទេ ន័យប្រាកដនិយមនៃគំនិតបូជាដល់វត្ថុ សាធារណៈនៅមានគំនិតបូជានេះដែរ តែរាជាធិបតេយ្យឈានទៅឆ្ងាយទៀត ដែលសាធារណរដ្ឋប្រជាធិបតេយ្យមិនអាចធ្វើបាន។ ហើយក៏មិនមែនភាពសម្របក្នុងន័យដែលគេបានឃើញក្នុងសាធារ ណរដ្ឋអភិជនាធិបតេយ្យទៅទៀត។ កិត្តិយស និងកិត្តិយស ក្នុងន័យពិសេសដោយឡែក គឺមានទម្ងន់ជាសក្តិភូមិ ជាអភិជនក្នុងន័យនៃពួកអ្នកនៅជុំវិញព្រះរាជបល្ល័ង្គដែលជាកិត្តិយសខុសបែបបទ។

គ. របបផ្តាច់ការនិយមៈ មនុស្សម្នាក់ដឹកនាំដោយគ្មានច្បាប់ និងវិធានការគ្រប់គ្រង យោលតាមឆន្ទៈ និងពុតត្បុតនោះជាធម្មជាតិនៃរបបនេះ។ គោលការណ៍នៅក្នុងរបបផ្តាច់ការ គឺ*ការភ័យខ្លាច ការគោរពដោយគ្មានការតវ៉ាចំពោះអ្នកដឹកនាំ*។ របបនេះគ្មានលទ្ធភាពដឹកនាំមនុស្ស ក្រៅពីការធ្វើឱ្យគេ ភ័យខ្លាចគឺធ្វើឡើងតាមទម្លាប់នឹកឃើញពីធម្មជាតិ ហើយជាលក្ខណៈពីធម្មជាតិដ៏ទាបបំផុតថែមទៀត។ នោះជាការចាត់ទុកមនុស្ស មិនមែនមនុស្សតែជាសត្វ។ ការគោរពដោយល្ងិតល្ងង់ចេះតែធ្វើតាមតម្រូវការរបស់អ្នកកាន់អំណាចផ្តាច់ការដូចសត្វ។ ច្បាប់ជាកិត្តិយសគ្មានតម្លៃទេ គេគ្រាន់តែទទួលបញ្ជាធ្វើតាមគឺគ្រប់គ្រាន់។

ជារួម សាធារណរដ្ឋ ទោះជាប្រជាធិបតេយ្យក្តី ឬជាអភិជនាធិបតេយ្យក្តី គោលការណ៍របស់វា គឺគុណធម៌ ការស្រលាញ់មាតុប្រទេស ស្រលាញ់សមភាព ស្រលាញ់ច្បាប់ ការលះបង់ផលប្រយោជន៍ខ្លួនឯងដើម្បីផលប្រយោជន៍សាធារណៈ។ ចំណែកនៅក្នុងរបបរាជាធិបតេយ្យ គោលការណ៍របស់វា គឺកិត្តិយស ពោលគឺការចេះគោរពគ្នាទៅតាមឋានៈក្នុងសង្គម ការស្គាល់នាទីខ្ពស់ទាប ឯរបបផ្តាច់ការនិយមវិញ គោលការណ៍របស់វា គឺការភ័យខ្លាច ការគោរពដោយគ្មានការតវ៉ាចំពោះអ្នកដឹកនាំ។

♦ ការរលាយបែកបាក់របបទាំងបី

របបគ្រប់គ្រងបែកបាក់របបទាំង ៣ ប្រភេទនេះ អាចរលំរលាយ ប្រែក្លាយជាលក្ខណៈដើមរបស់វា ធ្លាក់ចុះទៅក្នុងរបបមួយគួរឱ្យខ្លាចដែលមានការរំលោភបំពានពីអ្នកដឹកនាំធ្វើអ្វីតាមអំណាចចិត្ត។ លោកបានសរសេរថា «ការរលំរលាយនៃរដ្ឋនីមួយៗ ចាប់ផ្តើមសឹងតែទាំងអស់ពីការរលំរលាយគោលការណ៍របស់វា »។ការរលំរលាយសាធារណរដ្ឋអាចបណ្តាលមកពីការបាត់បង់សិទ្ធិ សេរីភាព យុត្តិធម៌ (គុណធម៌) ដែលជាគោលការណ៍របស់សាធារណរដ្ឋ។ គ្រោះថ្នាក់របស់របបអភិជនាធិបតេយ្យកើតមាននៅពេលណាដែលគោលការណ៍គុណធម៌ ប្រែក្លាយជាទៅជាវិសមភាព គ្មានគុណធម៌ អំពើពុករលួយ ពោលគឺនៅពេលដែលគេអនុគ្រោះឱ្យមានមហិច្ឆិតារបស់បុគ្គលធ្វើតាមទំនើងចិត្តដោយមិនរវល់ដល់ផលប្រយោជន៍សាធារណៈ។ ចំពោះការរលំរលាយរបបរាជាធិបតេយ្យកើតមាននៅពេលដែលការគោរពកិត្តិយសត្រូវជំនួសដោយស័ក្តិយស ដោយមាសប្រាក់ និងសំណូក។ ចំណែកការលាយរបស់របបផ្តាច់ការនិយម វារលំរលាយ ពីព្រោះរបបនេះវាខូចដោយសារលក្ខណៈសាហាវ ព្រៃផ្សៃរបស់វារួចទៅហើយ។

### ៦.២.៤ អំណាច

ក្នុងចំណោមរបបគ្រប់គ្រងទាំង៣ លោក Montesquieu យល់ឃើញថា « របបដែលប្រសើរល្អជាងគេ បើមិនគិតទៅដល់លក្ខណៈស្ថានភាពអ្វីទេ គឺរបបប្រជាធិបតេយ្យ ព្រោះគោលការណ៍របស់វាគឺគុណធម៌។ គុណធម៌ គឺជាគោលការណ៍ប្រជាធិបតេយ្យ វាខ្ពស់ជាងកិត្តិយសដែលជាគោលការណ៍របស់រាជាធិបតេយ្យហើយវារឹតតែខ្ពស់

ជាងសេចក្តីភ័យខ្លាច ដែលជាគោលការណ៍របស់របបផ្តាច់ការធិបតេយ្យទៅទៀត។ តាមការជាក់ស្តែង គិតទៅដល់លក្ខណៈផ្សេងៗ នោះ គឺរាជាធិបតេយ្យជារបបប្រសើរជាងគេ ពីព្រោះរបបរាជាធិបតេយ្យ ជារបបដែលត្រូវតាមរដ្ឋដែលមានទំហំធំ»។ គំនិតនេះ លោកMontesquieu លើកយកគំនិតដែលគេដឹងឮសុះសាយតាំងពីបុរាណកាលដែលយល់ថា « ប្រជាធិបតេយ្យត្រូវតែសម្រាប់រដ្ឋដែលមានទំហំតូច»។ ម្យ៉ាងទៀតរបបរាជាធិបតេយ្យជារបបដែលមានសម្បទានជាងគេក្នុងការធានាសេរីភាព។ របបរាជាធិបតេយ្យក៏អាចធ្លាក់ទៅក្នុងរបបផ្តាច់ការធិបតេយ្យដែរគឺជាផ្តាច់ការធិបតេយ្យតែម្នាក់។ របបរាជាធិបតេយ្យបានក្លាយទៅជារបបផ្តាច់ការធិបតេយ្យ កាលណាភាពឯករាជ្យ និងឯកសិទ្ធិរបស់ប្រជាជន របស់អង្គការនានា និងរបស់ប្រជាជាតិមិនត្រូវបានគេគោរពនោះ។ ដើម្បីធានាឱ្យមានការគោរពនេះ លោក ម៉ុនតេស្គីយើ (Montesquieu) បានគ្រោងទុកនូវយន្តការចំនួនពីរទៀតសម្រាប់បំពេញបន្ថែមនៅក្នុងការរៀបចំអំណាចដែលគេអាចឱ្យឈ្មោះថា« ទ្រឹស្តីនៃការបែងចែកអំណាចបញ្ឈរ និងទ្រឹស្តីនៃការបែងចែកអំណាចផ្តេក»។

♦ការបែងចែកអំណាចផ្តេក

ដើម្បីមានស្ថិរភាពនៅក្នុងសាធារណរដ្ឋក៏ដូចជានៅក្នុងរាជានិយម ចាំបាច់ត្រូវតែមានការបែងចែកអំណាចរដ្ឋព្រោះថាការបែងចែកអំណាចរដ្ឋអាចធ្វើឱ្យមានសមាជិកនៃសង្គមទទួលបាននូវសេរីភាពសុវត្ថិភាព យុត្តិធម៌ ពិសេសគឺស្ថិរភាពសង្គមតែម្តង។ លោក Montesquieu បានបែងចែកអំណាច ៖

អំណាចនីតិប្បញ្ញត្តិ

ជាអំណាចធ្វើច្បាប់ កែច្បាប់ និងលុបច្បាប់។ អំណាចនិតិបញ្ញត្តិ ត្រូវប្រគល់ទៅឱ្យសភាពីរជាន់ជាអ្នកកាន់កាប់ គឺសភាអភិជន (សភាជាន់ខ្ពស់) និងសភាប្រជារាស្ត្រ (សភាជាន់ទាប)។ ក្រៅពីបង្កើតឬលុបច្បាប់ អំណាចនេះនៅមានតួនាទី ជាអ្នកតាមដានត្រួតពិនិត្យការប្រតិបត្តិរបស់ព្រះរាជា និងមានតួនាទីជាអ្នកកាត់ក្តី វិនិច្ឆ័យទៅលើសកម្មភាព ប្រតិបត្តិក្នុងសង្គមទាំងមូល។

អំណាចនីតិប្រតិបត្តិ

ជាអំណាចប្រតិបត្តិ តាមឆន្ទៈរបស់អំណាចនីតិប្បញ្ញត្តិ សម្រាប់រៀបចំការដឹកនាំសង្គម ទាំងផ្ទៃក្នុងប្រទេស ទាំងលើឆាកអន្តរជាតិ ថែមទាំងជាអំណាច ដែលមានសិទ្ធិប្រកាសសង្គ្រាម និងសន្តិភាព។ អំណាចនេះ មានបង្កប់នូវចរិតជាអំណាចនៃច្បាប់អន្តជាតិផងដែរ។ អំណាចនេះ ត្រូវប្រគល់ទៅឱ្យព្រះមហាក្សត្រជាអ្នកកាន់កាប់។ អំណាចនេះ ក្រៅពីការប្រតិបត្តិ គឺនៅមានសិទ្ធិជំទាស់ចំពោះអំណាចនីតិប្បញ្ញត្តិផងដែរតាមនិតិវិធីនៃការប្រើសិទ្ធិរបស់ស្តេច។

អំណាចតុលាការ

ជាអំណាចវិនិច្ឆ័យ ដែលត្រូវបានគេប្រើប្រាស់នៅក្នុងក្របខ័ណ្ឌនៃច្បាប់រដ្ឋប្បវេណី។ អំណាចនេះ ត្រូវប្រគល់ឱ្យទៅសភាខេត្ត សភាក្រុងនិមួយៗ ដែលកាន់កាប់អំណាចតុលាការ។ គោលការណ៍នៃការបែងចែកអំណាចនេះគឺធ្វើឡើងក្នុងគោលបំណងទប់ស្កាត់មិនឱ្យអំណាចដែលស្ថិតនៅក្នុងដៃបុគ្គលណាម្នាក់ នោះអាចនាំទៅរកសេចក្តីវិនាសដល់ប្រទេសជាតិបាន និងដើម្បីឱ្យទ្រឹស្តី នៃការបែងចែកអំណាចនេះលុះទៅតាមរូបភាពជារចនាសម្ព័ន្ធ និងដើម្បីរក្សានូវតុល្យភាពនៃអំណាចទាំង ៣ របស់រដ្ឋ។ មួយទៀតគោលដៅនៃការបែងចែករក្សាអំណាចនោះ លុះដល់ដំណាក់ឈាមចុងអំណាចនេះ គឺធ្វើឡើងដើម្បីប្រឆាំងនឹងរបបរាជានិយមផ្តាច់ការ ហើយសម្របសម្រួលទំនាស់រវាងរបបមូលធននិយម និងពួកវណ្ណៈអភិជន និងជាការគ្រោងទុកជាមុនដើម្បីការពារគ្រោះថ្នាក់ ចៀសវាងការដណ្តើមយកអំណាចផ្តាច់មុខព្រោះលោកយល់ថា «សារជាតិរបស់មនុស្ស បើកាលណាបានអំណាចនៅក្នុងដៃរបស់ខ្លួនហើយមនុស្សនោះនឹងតស៊ូដើម្បីក្រោយ»។ ដូច្នេះ ធ្វើយ៉ាងណាឱ្យអំណាចទប់ទល់នឹងអំណាច ពីព្រោះមនុស្សទាំងអស់ដែលមានអំណាច តែងតែមានការប្រើប្រាស់នូវអំណាចទាំងនោះជ្រុលហួស។

♦ការបែងចែកអំណាចបញ្ញូរ

ទ្រឹស្តីនេះមានន័យថាត្រូវឱ្យមានការទទួលស្គាល់ អង្គកណ្តាលផ្សេងៗ ដែលស្ថិតនៅចន្លោះរវាងស្តេច និង ប្រជារាស្ត្រ ក្នុងនោះមានវណ្ណៈទាំង៣ដែលមាននៅក្នុងរបបចាស់ គឺវណ្ណៈអភិជន សហធម្មិក (clerge) និងវណ្ណៈ ផ្សេងៗទៀត។ វណ្ណៈទាំងឡាយដែលនៅចន្លោះរវាងស្តេច និងប្រជារាស្ត្រ សម្រាប់ធ្វើជាកម្លាំងទប់អំណាចរបស់ ស្តេច ប៉ុន្តែទ្រឹស្តី នៃការបែងចែកអំណាចបញ្ញូរនេះមានន័យពេញលេញបាន លុះត្រាតែមានទ្រឹស្តីនៃការបែងចែក អំណាចផ្តេកមកបង្គ្រប់បន្ថែមដែរ។

**៦.២.៥ សេរីភាព**

ចំពោះ ម៉ុតេស្គីយើ សេរីភាពមិនត្រឹមតែជាឯករាជ្យភាពនោះទេតែជាចំណុចដែលគេធ្វើអ្វីបានគ្រប់យ៉ាង ពិសេស សិទ្ធិធ្វើយោលតាមច្បាប់អនុញ្ញាតិ ដូចជាច្បាប់ជានាតាម ចំណុចជានានៃកម្មវត្ថុ ដែលរាំង ស្ទះដល់ការ រំលោភអំណាច ព្រោះ ជាបទពិសោធន៍ជាអវសាន្ត ដែលរាល់មនុស្សទាំងអស់ដែលមានអំ ណាចច្រើនតែចង់រំលោភ ច្បាប់ ដូចនេះគេត្រូវតែកំណត់ព្រំដែនអំណាចដោយច្បាប់។ និយាយឱ្យខ្លីគឺថា សេរីភាពជាអ្វីៗគ្រប់យ៉ាងដែលច្បាប់ អនុញ្ញាតិ។

ម៉ុងតេស្គីយើ ក្រោយពីមានការជ្រើសរើសយកចំណុចល្អរបស់ ចន ឡុក ដែលគេហៅថាការបែងចែកអំណាច មិនទាន់ស្អាតនោះ។ ក្នុងសច្ចភាពនៃម៉ុតេស្គីយើ គឺជានិច្ចកាលក្នុងគំនិតប្រឆាំងកម្លាំងដែល ជំរុញឱ្យលោកខិតទៅ ការចែកអំណាចដល់ចុងបំផុត ហើយសម្រេចនូវសមិទ្ធិផលនៃរូបភាពរដ្ឋាភិបាល ចម្រុះមួយ។

វាមានអំណាចបី ធ្វើច្បាប់ ប្រតិបត្តិច្បាប់ ផ្តល់យុត្តិធម៌ដល់ឧក្រិដ្ឋកម្ម ឬទំនាស់រវាងបុគ្គលនានា... បើអំណាច ទាំងបីនេះស្ថិតនៅក្នុងដៃនៃមនុស្សដដែល ឬអង្គការសំខាន់ៗ ឬក្នុងដៃអភិជន ឬក្នុងដៃពល រដ្ឋដោយប្រើនូវអំណាច ទាំងបី នោះនឹងមានការបាត់បង់នូវសេរីភាព។ ដូចនេះគេត្រូវបែងចែកអំណាច នេះនៅក្នុងដៃនៃអង្គការផ្សេងៗគ្នា... ដើម្បីកុំឱ្យមនុស្សម្នាក់កាន់អំណាចបង្កនូវហានិភ័យ ធ្វើឱ្យច្របូកច្របល់ ក្នុងដៃនៃមនុស្សដដែល។ សេរីភាពបានត្រូវ ជានាតាមរយៈការ បែងចែកអំណាចគ្នា។

# មេរៀនទី៧ ហ្សង់ ហ្សាក់ រូស្សូ

(Jean-Jacques Rousseau 1712-1778)

## ៧.១ ប្រវត្តិ និងបុគ្គលិកលក្ខណៈ

លោក ហ្សង់ ហ្សាក់រូស្សូ ជាជនជាតិបារាំង កើតនៅក្នុងត្រកូលក្រីក្រមួយ ដែលកាន់សាសនាប្រូ តែសស្តង់ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស កើតនៅថ្ងៃទី២៨ ខែមិនា ឆ្នាំ១៧១២។ កើតបាន៨ថ្ងៃ ម្តាយក៏ស្លាប់ចោល ឯឪពុក (អ៊ីសាក់ រូស្សូ) ក៏ពុំបានយកចិត្តទុកដាក់បីបាច់ថែរក្សាដោយបោះបង់កុមារ ហ្សង់ ហ្សាក់ រូស្សូ ឱ្យរសាត់អណ្តែត តាមយថាកម្ម និងពោរពេញដោយការផ្សងព្រេង។

រូស្សូ គឺជាទស្សនវិទូ ទ្រឹស្តីនយោបាយវិទូ និងជាអ្នកក្រមសីលធម៌ជាតិបារាំងម្នាក់។ គាត់ត្រូវបានគេកំណត់ថា ជាមនុស្សដែលធាប់មានអារម្មណ៍រំភើប ស្រឡាញ់ធម្មជាតិ អណ្តែតអណ្តូងនិយមនិងជាមនុស្សមិនទុកចិត្តវិទ្យាសា ស្ត្រនិងបច្ចេកទេសតែលោកជាអ្នកកំណែទម្រង់និយម (Réformiste) និងជាអ្នកសនិទាននិយម (Rationaliste) ដ៏ធំមួយរូប ដោយលោកជាជនជាតិទីមួយដែលបានធ្វើកំណែទម្រង់ទៅលើទ្រឹស្តីនយោបាយបែបរដ្ឋប្បវេណីឱ្យក្លាយ ទៅជាទ្រឹស្តីនយោបាយសង្គម។

វណ្ណកម្មនយោបាយរបស់លោក រូស្សូ តែងផ្អែកទៅដោយការរិះគន់យ៉ាងខ្លាំងចំពោះទ្រឹស្តីនយោបាយបែបរដ្ឋ ប្បវេណី។ លោកផ្តោតការកែទម្រង់ក្នុងនាមវិចារណញ្ញាណ។ ស្នាដៃសំខាន់របស់លោក គឺ "កិច្ចសន្យាសង្គម" (le contrat social) ដែលបានសរសេរនៅឆ្នាំ១៧៦២។ ក្នុងពេលដែលគាត់ផ្សងព្រេងទៅក្នុងប្រទេសបារាំង ដែល មានស្ថានភាពខុសពីប្រទេសដែលគាត់ធ្លាប់រស់នៅ ពោលគឺ វាំងស្តេចដ៏ស្កឹមស្កៃពោរពេញទៅដោយទ្រព្យសម្បត្តិ និងភាពអស្ចារ្យ និងមានវណ្ណៈអភិជន តែនៅមានប្រជាជនក្រីក្រលំបាកវេទនានៅលាយឡំជាមួយនោះ នាំឱ្យគាត់ លំបាកចិត្តជាមួយគេដែរ។

ដោយសារមានមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅលើប្រជាជនក្រីក្រ ហ្សង់ ហ្សាក់ រូស្សូ ពិចារណាទៅលើការ អានយ៉ាងច្រើនរបស់គាត់ ហើយដាក់សំណួរថា ក្នុងរបបរាជាធិបតេយ្យ ហេតុអ្វីបានជាប្រជាជនក្រីក្រលំបាកវេទនា ដូច្នេះ? អ្វីដែលនាំឱ្យអ្នកទាំងនោះវេទនា? កត្តាទាំងនេះជំរុញឱ្យគាត់សរសេរស្នាដៃមួយ គឺ "កិច្ចសន្យាសង្គម"។

## ៧.២ ទស្សនៈនយោបាយ

លោក ហ្សង់ ហ្សាក់ រូស្សូ បានធ្វើការវិភាគអំពីបញ្ហារបស់រដ្ឋ និងបានផ្តល់នូវខ្លឹមសារមូលដ្ឋាននៃគំនិត នយោបាយមួយដែលឈរលើទស្សនទាន២បែបសំខាន់ៗ៖

### ៧.២.១ ខ្លឹមសារមូលដ្ឋានរបស់លោក រូស្សូ

### ៧.២.១.១ មិនឈរលើមូលដ្ឋាននៃធម្មជាតិ

សមាគមដែលកើតឡើងដោយការធ្វើកិច្ចព្រមព្រៀងគ្នាក្នុងសង្គមនោះ គឺជាអង្គរួមដែលមានផ្អែកទៅដោយ ក្រមសីលធម៌ និងបណ្តុំមនុស្ស។ សមាគមនោះគឺជាសង្គមមនុស្សដែលមានអត្តសញ្ញាណរួម ជីវភាពរួមឆន្ទៈ និងអង្គ ឯកភាពរួមតែមួយនិងច្បាស់លាស់។ គេមិនអាចប្រៀបធៀបសង្គមមនុស្សដែលជាអ្នករួមនេះនឹងបុគ្គលណាម្នាក់។

រដ្ឋមានឆន្ទៈផ្ទាល់ដែលមិនមែនជាឆន្ទៈរបស់បុគ្គលណាមួយទេ តែសិទ្ធិរបស់បុគ្គលដែលរដ្ឋយកទៅប្រើប្រាស់ គឺដើម្បីជាផលប្រយោជន៍របស់បុគ្គលដែលជាអ្នកបង្កើតរដ្ឋនោះដែរ។

សមាជិកនីមួយៗនឹងក្លាយទៅជាផ្នែកមួយមិនអាចកាត់ផ្តាច់បានពីសង្គម មានន័យថាសង្គមមនុស្ស ឬ សមាគមបុគ្គល ពុំមែនគ្រាន់តែជាការប្រមូលផ្តុំតាមលំដាប់ច្បាប់ និងកាតព្វកិច្ចសង្គមប៉ុណ្ណោះទេ គឺថែមទាំងតាម លំដាប់ស្មារតីទទួលខុសត្រូវបែបសីលធម៌ថែមទៀតផង។

សុរបមកបាននន័យថា រដ្ឋកើតចេញពីទំនោរធម្មជាតិ ឬសភាវធម្មជាតិរបស់មនុស្ស។

**៧.២.១.២ ការបង្កើតក្រុមសីលធម៌ និងស្ថាប័ននានារបស់រដ្ឋត្រូវធ្វើក្នុងពេលជាមួយគ្នា**

លោក ហ្សង់ ហ្សាក់ រូស្សូ បានបញ្ជាក់ថា សីលធម៌ពុំមែនគ្រាន់តែជាផ្នែកមួយនៃច្បាប់ និងកាតព្វកិច្ចប៉ុណ្ណោះទេ តែវាជាផ្នែកមួយសម្រាប់អប់រំប្រជាពលរដ្ឋ អាស្រ័យដោយស្ថានភាព និងអារម្មណ៍របស់ពលរដ្ឋផ្ទាល់។ សីលធម៌មានអត្ថិភាពចាំបាច់ និងយ៉ាងខ្លាំងក្នុងសង្គម។

ដោយបុគ្គលជាធាតុរបស់រដ្ឋ នាំឱ្យសីលធម៌ និងសកម្មភាពសប្បុរសធម៌របស់បុគ្គល នឹងកើតឡើងនៅពេលរដ្ឋត្រូវបានបង្កើតដែរ។

ផ្អែកលើទស្សនៈទានទាំងពីរខាងលើ លោក រូស្សូបានបង្ហាញថា ៖

- ដើម្បីបង្កើតនូវឆន្ទៈរួមចាំបាច់ត្រូវមានលក្ខខ្ខ័ណ្ឌ:មួយចំនួន ហើយជាបឋមគឺត្រូវមានសមភាពនៅក្នុងសង្គម។
- សម្បត្តិឯកជន មិនមែនជាច្បាប់ធម្មជាតិទេ គឺជាច្បាប់សង្គម។
- ការលុបបំបាត់សម្បត្តិឯកជន ជាការខុសឆ្គង តែក៏ត្រូវប្រឆាំងនឹងការបែងចែកសម្បត្តិមិនស្មើគ្នាផងដែរ។
- មូលដ្ឋាននយោបាយ ត្រូវមានការបង្រួមបង្រួមតែមួយ បាននន័យថា ស្មារតីនយោបាយនៅក្នុងសង្គមស្តែងឡើងក្នុងរូបភាពជាឆន្ទៈរួមដែលតម្រូវអោយពលរដ្ឋទាំងអស់បានចូលរួមយ៉ាងសកម្មក្នុងការបញ្ចេញមតិផ្ទាល់ខ្លួន។
- ក្នុងសង្គម ប្រសិនបើមានក្រុមហ៊ុនឯកជនជាច្រើន នឹងនាំទៅរកវិសមភាពនិងការប្រេះឆាឆន្ទៈសង្គមរួម។
- ជៀសវាងក្រុមវណ្ណៈណាមួយ កាន់កាប់អំណាចរដ្ឋផ្តាច់មុខតែម្នាក់ឯង។
- ដោយឆន្ទៈមិនអាចប្តូរបាន និងមិនអាចលក់បាន ដូច្នេះឆន្ទៈក៏មិនអាចតំណាងបានដែរ ព្រោះថាអំណាចបែបតំណាងជាអំណាចបែបទាសភាព។
- មិនត្រូវអនុញ្ញាតឱ្យមានទម្រង់រដ្ឋដែលប្រកាន់របបគ្រប់គ្រងបែបតំណាងឡើយ គឺត្រូវគាំទ្ររបបគ្រប់គ្រងបែបប្រជាធិបតេយ្យផ្ទាល់។
- ប្រជាធិបតេយ្យ គឺជាអធិបតេយ្យរបស់ប្រជាជន ជាអំណាចរបស់ប្រជាជន។ ជារបបមួយដែលប្រជាជនមានអំណាចអធិបតេយ្យ។
- ចំពោះអភិជនាធិបតេយ្យ និងឯកធិបតេយ្យ (Monocratie) សុទ្ធសឹងតែជាទ្រឹស្តីនយោបាយដែលបង្ហាញពីយុទ្ធសាស្ត្ររបស់ស្តេច ឬអ្នកកាន់អំណាចផ្តាច់ការ ឬមនុស្សភាគតិចអាចគ្រប់គ្រងដឹកនាំប្រជាជនទាំងមូលបាន។

**៧.២.២ អំពីរដ្ឋ**

មានការខុសគ្នាខ្លះពីទស្សនវិទូ និងអ្នកនិពន្ធអំពីបញ្ហារដ្ឋដែលផ្អែកលើមូលដ្ឋាននៃច្បាប់ធម្មជាតិដូចជាលោក Hobbes ជាដើម។ លោក រូស្សូ បានវិភាគថា ក្នុងសភាពធម្មជាតិមនុស្សរស់នៅដោយសប្បាយរីករាយ គ្មានជម្លោះ គ្មានសង្គ្រាមអចិន្ត្រៃយ៍អ្វីនោះទេ តែជាសភាពមួយដែលមនុស្សរស់នៅដាច់ឆ្ងាយពីគ្នាតែឯង ហើយត្រូវដោះស្រាយបញ្ហាគ្រប់បែបយ៉ាងដោយខ្លួនឯង រួមទាំងការលំបាកពីគ្រោះធម្មជាតិផង។

សភាពធម្មជាតិ គឺជាសភាពសប្បាយក្រៃលែង ជាសភាពប្រកបដោយសុភមង្គលសម្រាប់មនុស្សជាតិ បង្ហាញពីភាពមនុស្សធម៌របស់មនុស្ស។ មនុស្សម្នាក់ៗ និងគ្រួសារអាចធ្វើដំណើរទៅទីកន្លែងណាក៏បានឱ្យតែគេចង់ទៅ គេអាចបេះផ្លែឈើ ឬចង់បានអ្វីៗគ្រប់យ៉ាងដែលមិនមែនជារបស់នណាម្នាក់ ឡើយ។ តែជាសភាពធម្មជាតិ មិនមែនជាសភាពដែលលូតលាស់នោះទេ ពុំមានកម្មសិទ្ធិឯកជនទេ គ្មានអ្វីជារបស់នណាម្នាក់ឡើយ ដូច្នេះគ្មានចោរទេ ហើយក៏គ្មានព្រំដែន និងគ្មានរដ្ឋដែរ។ បើគ្មានរដ្ឋ ដូច្នេះសង្គ្រាមក៏គ្មានដែរ។

ការរកឃើញកសិកម្ម និងលោហកម្មធ្វើឱ្យមានកម្មសិទ្ធិឯកជនលើដីធ្លី ជាបុព្វហេតុនៃការប្រកួតប្រជែង និងជម្លោះដែលបណ្តាលមកពីវិសមភាពនៃភាពសម្បូរសប្បាយ និងទុរគត ព្រមទាំងតណ្ហា។ ដើម្បីជៀសវាងពីជម្លោះ មនុស្សត្រូវប្រមូលគ្នាជាសមាគម ដើម្បីជៀសវាងការបំផ្លាញទ្រព្យសម្បត្តិគ្នាទៅវិញទៅមក ហើយឈប់ប្រយុទ្ធគ្នា។

តាមការវិភាគនេះបង្ហាញថា ក្នុងសភាពធម្មជាតិមានពីរដំណាក់កាល គឺសេចក្តីសុខពីដំបូង និងភាពប្រកួតប្រជែងក្នុងដំណាក់កាលចុងក្រោយ។

ដើម្បីជាថ្នូរនឹងសេចក្តីសុខពីដំណាក់កាលដំបូង មនុស្សត្រូវលះបង់ភាពរស់នៅដាច់ឆ្ងាយពីគ្នាមករស់នៅជាសមាគមវិញ ដោយការចុះកិច្ចសន្យាមួយហៅថា កិច្ចសន្យាសង្គម។ កម្មវត្ថុនៃកិច្ចសន្យាសង្គម គឺការបង្កើតឱ្យមានសង្គម ព្រោះថាវាមានអត្ថប្រយោជន៍ច្រើន បើកាលណារស់នៅជាមួយគ្នា ធ្វើការជាមួយគ្នា។ កិច្ចសន្យាត្រូវធ្វើឡើងរវាងបុគ្គលម្នាក់ៗ ជាមួយនឹងសង្គម។

កិច្ចសន្យាសមាគមនេះ( contrat d'association )ខុសពីកិច្ចសន្យាព្រមលះបង់( contrat de renonciation ) របស់លោក Hobbes។ មនុស្សស្ថិតនៅចំណុចសង្គម ព្រោះមនុស្សបានប្រគល់សិទ្ធិ និងសេរីភាពរបស់គេ។ ប៉ុន្តែមនុស្សនៅតែរក្សាសេរីភាពរបស់ពួកគេ ព្រោះសង្គមជាសំណុំនៃមនុស្សទាំងអស់ដោយគ្មាននរណាបាត់បង់សេរីភាពទេ បើទាំងអស់គ្នាមិនបាត់បង់នោះ។ សេរីភាព និងសមភាពត្រូវបានធានាយ៉ាងម៉ឺងម៉ាត់។ សង្គមនយោបាយជាអ្នកធានានូវអ្វីដែលមនុស្សមានកាលពីសភាពជាធម្មជាតិ ដោយបន្ថែមលើការធានាលើសន្តិសុខថែមទៀត។

អធិបតេយ្យគឺជាបាតុភូតអំណាចដែលកើតឡើងស្របពេលគ្នានឹងការចាប់កំណើតរបស់សង្គមដែរ។ អធិបតេយ្យមិនប្រជាធិបតេយ្យ គឺជាអធិបតេយ្យមិនល្អ ហើយអធិបតេយ្យមិនអាចផ្ទេរទៅអ្នកណាម្នាក់បានឡើយ។ ដូច្នេះ គេមិនអាចប្រគល់អំណាចអោយទៅស្តេចមួយអង្គទេ ព្រោះការរស់នៅចំណុះស្តេចមិនប្រសើជាងការរស់នៅក្នុងសភាពធម្មជាតិទេ។

ប្រព័ន្ធរាជាធិបតេយ្យ ( ពិសេសរាជាធិបតេយ្យផ្តាច់ការដែលពុំអាចទទួលយកបានទេ )។ ចំពោះភាពជាតំណាងទោះតាមរូបភាពណាក៏មិនជាការល្អដែរ។ ប្រជារាស្ត្រត្រូវតែជាអ្នកកាន់កាប់អធិបតេយ្យ និងត្រូវសម្រេចអ្វីៗដោយផ្ទាល់ខ្លួនឯង។ការតំណាងអាចធ្វើឱ្យប្រជាធិបតេយ្យក្លាយពីល្អទៅអាក្រក់បាន ព្រោះអ្នកតំណាងប្រាកដជាជ្រើសរើសយកអ្វីតាមបំណងផ្ទាល់របស់ពួកគេ មិនមែនតាមបំណងរាស្ត្រនោះទេ។ គេអាចប្រតិបត្តិឆន្ទៈរបស់អ្នកណាម្នាក់បានតែគេមិនអាចតំណាងឆន្ទៈរបស់អ្នកនោះបានទេ។ ដូច្នេះបើមានការបោះឆ្នោតរើសតំណាង មានន័យថា គេកំពុងតែលក់សេរីភាពរបស់គេហើយ ព្រោះគេមានសេរីភាពក្នុងថ្ងៃបោះឆ្នោតនោះ បន្ទាប់មកគេក៏ក្លាយទៅជាទាសកររបស់អ្នកដែលខ្លួនបានជ្រើសរើសនោះជាក់ជាមិនខាន។ អ្នកតំណាងនឹងបង្កើតនូវអភិជនាធិបតេយ្យមួយក្នុងរដ្ឋ។

### ៧.២.៣ អំពីរដ្ឋាភិបាល

រូស្សូ អះអាងថាសកម្មភាពសេរីទាំងអស់កើតឡើងដោយមូលហេតុពីរយ៉ាង ទី១ គឺឆន្ទៈដែលបានសម្រេចចិត្តទៅលើសកម្មភាពនោះហើយទីពីរគឺជាកម្លាំងដែលស្តែងចេញជាសកម្មភាព។ លោកបានលើកឧទាហរណ៍លើបញ្ហានេះថា ពេលដែលខ្ញុំដើរទៅរកវត្ថុមួយ វាគឺជាភាពចាំបាច់នៃទីតាំង ទីមួយដែលខ្ញុំចង់ទៅរកវា ( ឆន្ទៈ ) ហើយទីពីរ គឺជើងរបស់ខ្ញុំដែលអាចនាំខ្ញុំទៅទីនោះ។ បើមនុស្សខ្វិនចង់រត់ ហើយបើលទ្ធភាពរាងកាយរបស់មនុស្សនោះមិនចង់ទៅ (មិនអាចទៅរួច) ពេលនោះទាំងឆន្ទៈ និងខ្លួនគេនឹងនៅកន្លែងដែលគាត់នៅនោះដដែល។ អង្គការនយោបាយក៏ដូចគ្នាដែរ ដែលសកម្មភាពត្រូវការ "កម្លាំង" និង "ឆន្ទៈ" នោះគឺជាអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ។ សកម្មភាពមួយ នឹងប្រព្រឹត្តទៅបាន ឬមិនអាចប្រព្រឹត្តទៅបានលុះត្រាតែអំណាចទាំងពីរនេះស្រុះស្រួលគ្នា។

រូស្សូ យល់ថា ត្រូវតែបែងចែកឱ្យដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិដែលមានឈ្មោះថាអធិបតេយ្យប្រជាជន ( sovereign people ) និងអំណាចនីតិប្រតិបត្តិ ឬរដ្ឋាភិបាល។ ដំបូងត្រូវផ្តល់ឱ្យមានការបង្ហាញឆន្ទៈទូទៅនៅក្នុងច្បាប់ជាសកល( universal law )ហើយមិនត្រូវឱ្យមានជាប់ទាក់ទងជាមួយសកម្មភាពដោយឡែក ឬផលប្រយោជន៍បុគ្គលឡើយ។ រដ្ឋាភិបាល គឺជាអង្គការកណ្តាលមួយដែលវា បង្កើតឡើងរវាងការគ្រប់គ្រងថ្នាក់ក្រោម និងអំណាចកំពូល( sovereign )ក្នុងការធ្វើឱ្យមានភាពស៊ីគ្នា ច្បាស់លាស់រវាងគ្នាទៅវិញទៅមក និងមានតួនាទីប្រតិបត្តិច្បាប់ដោយមានការថែរក្សាសេរីភាពទាំងសង្គម និងនយោបាយ។ រូស្សូ គិតថាប្រជាជនអាចចូលរួមដោយផ្ទាល់នៅក្នុង

អំណាចកំពូលគឺដូចជារដ្ឋ ស្ទើសដ៏តូចរបស់លោក ដែលវាផ្តល់លទ្ធភាពងាយស្រួលក្នុងការជួបជុំប្រជាជន។ ទោះជាយ៉ាងណាក៏ដោយគោលការណ៍ជាទូទៅ រដ្ឋាភិបាលគឺគ្រាន់តែជាឧបករណ៍ ឬជាមន្ត្រីអធិបតេយ្យភាពប្រជាជនដែលត្រួតត្រាល្អសម្រាប់គ្រប់រដ្ឋទាំងអស់។ ពិតមែនហើយក្នុងការនិយាយថាប្រជាជនអាច ទទួលបានមកវិញនូវអំណាចនីតិប្រតិបត្តិនោះគឺមិនមែនមានន័យថាប្រជាជនអាចសម្រេចអនុវត្តនូវអំណាចនេះដោយខ្លួនឯងនោះទេ។ ចំពោះគោលការណ៍របស់ រូស្សូ អធិបតេយ្យប្រជាជនគឺជាប់ទាក់ទងច្រើនករណីជាមួយនឹងការតែងច្បាប់គឺមិនមែនជាប់ទាក់ទងជាមួយរដ្ឋាភិបាលនោះទេ លើកលែងតែក្នុងករណីដែលប្រជាជនគ្មានការពេញចិត្តជាមួយអត្ថិភាពនៃការគ្រប់គ្រងរបស់រដ្ឋាភិបាលនោះវាត្រូវបណ្តេញចេញឱ្យប្រគល់អំណាចនីតិប្រតិបត្តិនេះទៅឱ្យរដ្ឋាភិបាលផ្សេងទៀត។

រូស្សូ យល់ថាប្រសិនបើអធិបតេយ្យចង់ទាមទារលើការគ្រប់គ្រង ឬមន្ត្រីរដ្ឋាភិបាលទាមទារចង់បង្កើតច្បាប់ ឬមន្ត្រីថ្នាក់ក្រោមមិនគោរពថ្នាក់លើ ពេលនោះការត្រួតត្រាត្រូវជំនួសមកវិញដោយភាពឥតសណ្តាប់ធ្នាប់ ធន្ធៈ និងកម្លាំងមានភាពមិនស្រុះស្រួលគ្នាហើយរដ្ឋនឹងត្រូវបែកបាក់ធ្លាក់ចូលក្នុងរបបផ្តាច់ការ ឬអនាធិបតេយ្យ។ ទាំងនេះគឺដោយសារតែមានភាពមិនច្បាស់លាស់ក្នុងការប្រតិបត្តិទៅតាម តួនាទីនីមួយៗនៃអំណាចរបស់រដ្ឋ។

នៅក្នុងកិច្ចសន្យាសង្គម(Social Contract) រូស្សូ និយាយថា រដ្ឋាភិបាលត្រូវរៀបចំឱ្យស៊ីគ្នាទៅអធិបតេយ្យប្រជាជនដែលធ្វើទៅតាមសមាមាត្រនៃចំនួនប្រជាជន និងត្រូវកែប្រែយ៉ាងទន់ភ្លន់ទៅតាមកំណើនប្រជាជនជាក់ស្តែង ឬក៏ធ្វើតាមចំនួនប្រហាក់ប្រហែល។ រដ្ឋាភិបាលដែលល្អបំផុតនោះគឺត្រូវរៀបចំទៅតាមសភាពធម្មជាតិ ហើយគំនិតដែលប្រកបទៅដោយគតិបណ្ឌិតនោះគឺថាអ្នកដឹកនាំប្រជាជន គួរតែដឹកនាំសម្រាប់ផលប្រយោជន៍រដ្ឋាភិបាល និងមិនមែនដើម្បីពួកគេខ្លួនឯងទេ។ លោកយល់ថាពួកគេគួរតែជាអ្នកបម្រើប្រជាជន មិនមែនថៅហ្វាយរបស់ប្រជាជនទេ មានន័យថារដ្ឋាភិបាលត្រូវធ្វើពលិកម្មដើម្បីប្រជាជន មិនមែនប្រជាជនធ្វើពលិកម្មដើម្បីរដ្ឋាភិបាលឡើយ។ ម្យ៉ាងទៀត លោកអះអាងថាចំនួនច្រើននៃមន្ត្រីរដ្ឋាភិបាលគឺជាមូលហេតុដែលនាំឱ្យរដ្ឋាភិបាលនោះចុះខ្សោយ។

### ៧.២.៤ ការបែងចែកប្រភេទរដ្ឋាភិបាល

សម្រាប់ រូស្សូ លោកបដិសេធយ៉ាងសមហេតុផលបំផុតចំពោះការអះអាងថាមានទម្រង់រដ្ឋាភិបាលល្អឥតខ្ចោះដែលសមស្របទៅនឹងប្រជាជនទាំងអស់ និងគ្រប់កាលៈទេសៈ។ តើអ្វីជារដ្ឋាភិបាល ល្អបំផុតយ៉ាងដាច់ខាតនោះ? រូស្សូ យល់ថារដ្ឋាភិបាលមួយត្រូវសមស្របទៅនឹងទំហំរដ្ឋ ចំណង់ចំណូលចិត្តប្រជាជន ទីកន្លែង និងកាលៈទេសៈ។ ដូចនេះ យើងមិនអាចកំណត់បានថា រដ្ឋាភិបាលមួយត្រឹមត្រូវ ឬល្អ សម្រាប់គ្រប់ទីកន្លែង និងគ្រប់ពេលវេលានោះទេ។ ប៉ុន្តែសម្រាប់ រូស្សូ ចំពោះហេតុផលនៃការ បែងចែករដ្ឋាភិបាលជាប្រភេទផ្សេងនេះ គឺបង្កើតទៅតាមសមាជិកចូលរួមរបស់វា ក្នុងនោះលោកបានបង្ហាញប្រាប់យើងដូចតទៅ៖

ទីមួយ៖ អំណាចកំពូលនៃរដ្ឋាភិបាលអាចត្រូវបានប្រគល់ការទុកចិត្តទៅឱ្យប្រជាជនទាំងអស់ គឺប្រគល់ទៅឱ្យផ្នែកដ៏សំខាន់ណាមួយរបស់ប្រជាជន ដូចនេះពលរដ្ឋភាគច្រើននឹងក្លាយទៅជាសមាជិករដ្ឋាភិបាលជាងពលរដ្ឋសាមញ្ញជាបុគ្គលដោយឡែក។ ឈ្មោះនៃទម្រង់រដ្ឋាភិបាលនេះត្រូវបានហៅថា ប្រជាធិបតេយ្យ (Democracy)។ ជារបបមួយល្អឥតខ្ចោះ ប្រសិនបើរបបនយោបាយនេះអាចធ្វើឱ្យ អំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិមានតុល្យភាពគ្នានោះ(Checks and Balances)។ លោក រូស្សូ យល់ថា បើប្រជាជនមានការយល់ដឹងកម្រិតខ្ពស់ ទើបរបបប្រជាធិបតេយ្យមានដំណើរការល្អ។

ទីពីរ៖ រដ្ឋាភិបាលដែលមានសមាជិកចំនួនតិចដែលពលរដ្ឋទាំងនោះជាពលរដ្ឋសាមញ្ញ ច្រើនជាងសមាជិករបស់រដ្ឋាភិបាល ហើយទម្រង់នេះកំណត់ឱ្យឈ្មោះថា អភិជនាធិបតេយ្យ។ នៅក្នុងរបបនេះ អំណាចនីតិប្រតិបត្តិត្រូវប្រគល់ទៅឱ្យមនុស្សមួយចំនួនជាអ្នកប្រកប ដោយគតិបណ្ឌិតដែលត្រូវជ្រើសតាំងតាមការបោះឆ្នោត។

ទីបី៖ រដ្ឋាភិបាលអាចត្រូវបានប្រមូលផ្តុំក្តាប់រួមក្នុងដៃរបស់មន្ត្រីតែម្នាក់គត់ ហើយមានអំណាចលើពលរដ្ឋ និងអ្នកដទៃទៀតទាំងអស់។ ទម្រង់រដ្ឋាភិបាលទីបីជាទម្រង់ទូទៅបំផុត និងត្រូវគេហៅថារាជានិយម ឬរាជរដ្ឋាភិបាល

(Monarchy or Royal Government)។ រូស្សូ ទទួលស្គាល់របបគ្រប់គ្រងបែបនេះប្រសិនបើរាជាធិបតេយ្យត្រូវទទួលស្គាល់ពីប្រជារាស្ត្រទាំងមូល បានសេចក្តីថាប្រសិន បើព្រះរាជាត្រូវបានបោះឆ្នោតជ្រើសតាំងនេះ។

រូស្សូ យល់ថាទម្រង់រដ្ឋាភិបាលប្រជាធិបតេយ្យគឺសមស្របទៅនឹងរដ្ឋដែលមានទំហំតូច និងទម្រង់ រដ្ឋាភិបាលអភិជនាធិបតេយ្យគឺសមស្របទៅនឹងរដ្ឋមានទំហំធំ ហើយទម្រង់រដ្ឋាភិបាលរាជាធិបតេយ្យសមស្របទៅនឹងរដ្ឋដែលមានទំហំធំទូលាយ។

### ៧.២.៤.១ រដ្ឋាភិបាលប្រជាធិបតេយ្យ

ក្នុងទម្រង់នេះ រូស្សូ បានទាមទារឱ្យពលរដ្ឋម្នាក់ៗយល់ឱ្យបានច្បាស់លាស់អំពីច្បាប់ ពិសេស ពីរបៀបនៃការប្រតិបត្តិវា។ វាអាចជារដ្ឋាភិបាលមួយល្អឥតខ្ចោះ ប្រសិនបើរដ្ឋាភិបាលនេះអាចធ្វើឱ្យ អំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ មានការព្រមព្រៀងគ្នាបានប្រសើ។ លោកយល់ថាប្រសិនបើមានមនុស្សម្នាក់មិនធ្លាប់ប្រើប្រាស់អំណាចរដ្ឋាភិបាលខុស មនុស្សនោះតែងតែគ្រប់គ្រងបាន ល្អ។ ម្យ៉ាងទៀត រដ្ឋាភិបាលបែបនេះនឹងមិនអាចកើតមានទេ ប្រសិនបើប្រជាពលរដ្ឋគ្មានលទ្ធភាពចូលរួមប្រជុំជាអចិន្ត្រៃយ៍ដែលទាក់ទងទៅនឹងកិច្ចការសាធារណៈនិងប្រសិនបើអ្នកគ្រប់គ្រងគេមិនអាចក្លាយជាអ្នកដែលគេគ្រប់គ្រងវិញទាំងអស់ផងទេនោះ។ លោកគិតថា វាប្រឆាំងនឹងសណ្តាប់ធ្នាប់ធម្ម ជាតិដែលមនុស្សភាគច្រើនបានគ្រប់គ្រងលើគេ ហើយមនុស្សភាគតិចត្រូវបានគេគ្រប់គ្រង។

រូស្សូ តម្រូវឱ្យអ្នកបង្កើតច្បាប់គួរតែប្រតិបត្តិច្បាប់ដោយតម្រង់ទិសពីការពិចារណាជាទូទៅឆ្ពោះទៅរកបញ្ហាដោយឡែក។ ជាការពិតហើយអ្នកបង្កើតច្បាប់មិនសូវខ្លាចញញើតនឹងច្បាប់ដែលខ្លួនជាអ្នក បង្កើតនោះទេ ដែលវាដូចគ្នាទៅនឹងបញ្ហាឪពុកមិនខ្លាចឥទ្ធិពលរបស់កូនយ៉ាងដូច្នោះដែរ។ ជាពិសេស ជាងនេះទៅទៀតលោកអះអាងថា *" គ្មានអ្វីគ្រោះថ្នាក់ជាងឥទ្ធិពលនៃផលប្រយោជន៍ឯកជននៅក្នុងកិច្ចការសាធារណៈ ហើយការអនុវត្តច្បាប់ខុសដោយរដ្ឋាភិបាល គឺវាមានផលអាក្រក់តិចជាងអំពើពុករលួយ នៃអង្គការនីតិបញ្ញត្តិ "*។ ចំពោះបញ្ហានេះវាតែងកើតមានដោយឡែកនៃអ្នកដឹកនាំគឺចៀសមិនរួច។

រូស្សូ បង្ហាញពីមធ្យោបាយមួយចំនួនផងដែរ ដើម្បីធ្វើឱ្យមានអត្ថិភាពនៃទម្រង់រដ្ឋាភិបាលប្រជាធិបតេយ្យនេះ ក្នុងនោះមាន៖

**ទីមួយៈ** រដ្ឋត្រូវតែតូចបំផុត រដ្ឋបែបនេះអាចផ្តល់លទ្ធភាពឱ្យប្រជាជនចូលរួមប្រជុំដោយផ្ទាល់គ្មាន ការលំបាក និងវាផ្តល់ភាពងាយស្រួលសម្រាប់ពលរដ្ឋគ្រប់រូបក្នុងការស្គាល់ពលរដ្ឋដទៃទៀតទាំងអស់។

**ទីពីរៈ** ត្រូវរៀបចំមធ្យោបាយសង្គមឱ្យមានលក្ខណៈសាមញ្ញបំផុត ហើយត្រូវចៀសវាងបរិមាណ កម្រិតខ្ពស់នៃមុខងារ និងត្រូវចៀសវាងការរំខានដល់ការបញ្ចេញមតិលើសពីនេះទៅទៀតគួរពិចារណាទៅរកកម្រិតនៃសមភាពក្នុងតំណែង និងទ្រព្យសម្បត្តិ ដោយគ្មានសមភាពនៅក្នុងសិទ្ធិ និង ច្បាប់ គឺមិនអាចឋិតថេរបានយូរអង្វែងឡើយ។

ទម្រង់រដ្ឋាភិបាលបែបនេះ រូស្សូ បានរម្លឹកដល់ពលរដ្ឋទាំងនោះឱ្យមានការប្រុងប្រយ័ត្នមែនទែន ព្រោះលោកយល់ថា ប្រសិនបើទម្រង់នេះមានអត្ថិភាពយូរទៅនឹងក្លាយទៅជាអនាធិបតេយ្យ ហើយត្រូវ តាមដានជាប្រចាំនូវគុណធម៌មេដឹកនាំ ដើម្បីកុំឱ្យពួកគេប្រែក្លាយទៅរកភាពផ្តាច់ការ។ រូស្សូ ថា ប្រសិន បើប្រជារាស្ត្រទាំងមូលជាអ្នកដឹកនាំ នោះអំណាចនីតិបញ្ញត្តិនឹងស្រូបយកអំណាចនីតិប្រតិបត្តិអស់។

### ៧.២.៤.២ រដ្ឋាភិបាលអភិជនាធិបតេយ្យ

រូស្សូ ប្រាប់ថាសង្គមដំបូង (First Societies) ត្រូវបានគ្រប់គ្រងដោយរបបបែបនេះ។ មេគ្រួសារជាអ្នកដឹកនាំកិច្ចការទូទៅ និងដោះស្រាយបញ្ហាផ្សេងៗទៀតទៅតាមបទពិសោធន៍របស់ពួកគេផ្ទាល់។ កុលសម្ព័ន្ធនៃមនុស្សជំនាន់ដើមនាអាមេរិកខាងជើង នៅតែគ្រប់គ្រងតាមមធ្យោបាយនេះរហូតមកដល់ សព្វថ្ងៃនេះ (សម័យកាលរូស្សូ) ហើយពួកគេគ្រប់គ្រងបានល្អណាស់។ ប៉ុន្តែដោយសារការវិវត្តន៍របស់ របស់សង្គមមនុស្ស បណ្តាលឱ្យវិសមភាព

សង្គមក្លាយជាបញ្ហាសំខាន់ជាងវិសមភាពធម្មជាតិទៅទៀត ទ្រព្យសម្បត្តិ និងអំណាចបានក្លាយទៅជាចំណង់ចំណូលចិត្តរបស់មនុស្សនៅក្នុងសម័យនោះ។ មូលហេតុនេះហើយបានធ្វើឱ្យរបបអភិជនាធិបតេយ្យក្លាយទៅជារបបជ្រើសតាំង។ ចុងក្រោយនេះគឺកើត ចេញមកពីការផ្ទេរអំណាចពីឪពុកទៅកូន នោះហើយដែលគេហៅថា គ្រួសារអភិជនដែលជាមូលហេតុ នាំឱ្យកើតមានរដ្ឋាភិបាលអភិជនាធិបតេយ្យមួយដែលផ្ទេរអំណាចពីឪពុកទៅកូន។ ទម្រង់រដ្ឋាភិបាល បែបនេះ វាកើតឡើងតាមមធ្យោបាយបីប្រភេទគឺៈ កើតឡើងតាមបែបធម្មជាតិ, តាមបែបជ្រើសតាំង និង តាមបែបផ្ទេរពីឪពុកទៅកូន។ លោកបញ្ជាក់ថា ទី១ តាមបែបធម្មជាតិ គឺសមរម្យតែទៅនឹងសង្គមសាមញ្ញធម្មតា ហើយទី៣ ផ្ទេរពីឪពុកទៅកូន គឺអាក្រក់ជាងគេបំផុតក្នុងចំណោមទម្រង់រដ្ឋាភិបាលទាំងអស់។ ទី២ តាមបែបជ្រើសរើស គឺជាទម្រង់មួយល្អបំផុត វាជាអត្ថន័យពិតប្រាកដរបស់ពាក្យអភិជនាធិបតេយ្យ។

នៅក្នុងទម្រង់រដ្ឋាភិបាលអភិជនាធិបតេយ្យរបស់ រូស្សូ មិនគ្រាន់តែមានគុណប្រយោជន៍នៃការបែងចែកអំណាចពីរប៉ុណ្ណោះទេ ប៉ុន្តែសមាជិករបស់វាត្រូវបានជ្រើសរើសដោយសមរម្យបំផុត។ ធម្មតា រដ្ឋាភិបាលនៃប្រជាជនមួយ ពលរដ្ឋទាំងអស់ជាសមាជិករបស់វាដោយពួកគេជាអ្នកបង្កើតឡើង។ ប៉ុន្តែ សមាជិកភាពនៃរដ្ឋាភិបាលអភិជនាធិបតេយ្យត្រូវបានកំណត់តិចតួចប៉ុណ្ណោះ ហើយវាត្រូវបានគេទទួលយកដោយការបោះឆ្នោត។ ចំពោះការបោះឆ្នោតនោះទៀត ត្រូវជ្រើសរើសលើមនុស្សដែលមានលក្ខណៈ សម្បត្តិដូចជាៈ មានចិត្តសុចរិត មានបញ្ញា មានបទពិសោធន៍ និងតាមហេតុផលផ្សេងទៀតដែលរួមទាំង មានការធានាយ៉ាងច្រើនថានឹងមានរដ្ឋាភិបាលមួយប្រកបដោយគតិបណ្ឌិត ដើម្បីធ្វើឱ្យមានការពេញចិត្ត និងមានការគោរពរជាសាធារណៈ។

**៧.២.៤.៣ រដ្ឋាភិបាលរាជាធិបតេយ្យ**

តាមគំនិតរបស់ រូស្សូ បង្ហាញថារដ្ឋាភិបាលរាជាធិបតេយ្យគឺជារដ្ឋាភិបាលដែលឋិតនៅក្រោមការ គ្រប់គ្រងរបស់មនុស្សតែម្នាក់គត់។ ហើយប្រមូលផ្តុំទៅដោយមនុស្សតែងតាំងដែលទទួលបន្ទុកកិច្ចការ រដ្ឋជាមួយនឹងអំណាចនីតិប្រតិបត្តិ។ អំណាចនេះឋិតក្នុងដៃមនុស្សម្នាក់ទាំងស្រុងដែលមានអំណាចពីធម្មជាតិស្រាប់។ ដូចនេះ មានតែបុគ្គលម្នាក់នោះមានសិទ្ធិអនុវត្តដោយអាស្រ័យតាមច្បាប់។ បុគ្គលនោះត្រូវបានគេហៅថា ព្រះមហាក្សត្រ ឬស្តេច។

ក្នុងរបបរដ្ឋាភិបាលបែបនេះ ឆន្ទៈរបស់ប្រជារាស្ត្រ ឆន្ទៈអ្នកដឹកនាំ កម្លាំងសាធារណៈរបស់រដ្ឋ កម្លាំងដោយឡែកនៃរដ្ឋាភិបាល គ្រប់ថាមពលមេកានិក និងអ្វីៗផ្សេងទៀតគឺសុទ្ធតែឋិតនៅក្រោមការគ្រប់គ្រងរបស់មនុស្សម្នាក់។ ការធ្វើអ្វីៗទៅតាមបំណងតែមួយដោយគ្មានការប្រឆាំងតវ៉ា បើមានក៏គ្មាន ឥទ្ធិពលអ្វីដែរ។ រូស្សូ ទទួលស្គាល់រដ្ឋាភិបាលរាជាធិបតេយ្យ បើរដ្ឋាភិបាលនេះត្រូវបានទទួលស្គាល់ពីសំណាក់ប្រជារាស្ត្រទាំងមូល បានសេចក្តីថា ប្រសិនបើរាជាធិបតេយ្យត្រូវបានបោះឆ្នោតជ្រើសតាំងនោះ។ ក្នុងករណីនេះរដ្ឋាភិបាលរាជាធិបតេយ្យជារដ្ឋាភិបាលពេញច្បាប់។ នៅក្នុងរបបរាជាធិប តេយ្យមនុស្សណាមានសមត្ថភាពតិចតួចដែលចេះអែបអប ឬមានស្នាដៃបង្ហាញជាសាធារណៈណាមួយ ពួកគេនឹងទទួលបានអំណាចភ្លាម ដួនកាលដំណែងនោះបានមកដោយការរៀបចំគម្រោងអាក្រក់របស់មនុស្សមួយចំនួនក៏មាន។

**៧.២.៥ អធិបតេយ្យភាព**

អធិបតេយ្យ នៅទីនេះគឺអ្វីដែលជាអំណាចរបស់ប្រជាជនដែលបានចូលរួមនៅក្នុងកិច្ចការរដ្ឋ។ អធិបតេយ្យ គឺជាអង្គការទាំងមូលរបស់ប្រជាជនដែលពាក់ព័ន្ធដល់ការតែងច្បាប់ និងជាប្រភពនៃច្បាប់។ ច្បាប់មានន័យថាជាការបង្ហាញនៃឆន្ទៈ។ រូស្សូ ចង់និយាយថា អធិបតេយ្យគឺគ្មានអ្វីក្រៅពីការប្រតិបត្តិតាមឆន្ទៈទូទៅទេ។ ពលរដ្ឋម្នាក់ៗមានលទ្ធភាពទ្វេ គាត់ជាសមាជិកនៃអធិបតេយ្យ ភាពផង និងជាសមាជិករបស់រដ្ឋផង ប៉ុន្តែពលរដ្ឋត្រូវប្រុងប្រយ័ត្នចំពោះការអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ក្នុងច្បាប់ស៊ីវិល ដោយមិនឱ្យចាកចេញឆ្ងាយពីភាពជាសមាជិករបស់ខ្លួនឡើយ។

តាម រូស្សូ នៅពេលដែលសង្គមកើតឡើង បាតុភូតអំណាចក៏លេចឡើងជាចាំបាច់ដែរ។ ស្តីពីអធិបតេយ្យ លោកចង្អុលបង្ហាញថា អធិបតេយ្យមិនប្រជាធិបតេយ្យជាអធិបតេយ្យមិនល្អ។ បានន័យថា ការយកប្រជាជនជាធំ

អធិបតេយ្យប្រជាជនគឺឋិតនៅត្រង់វាជារបស់ប្រជាជន។ ដូចនេះប្រជាជនជាសមាជិករបស់អធិបតេយ្យដោយមានអំណាចស្មើៗគ្នានៅក្នុងអំណាចកំពូលនេះ។ រូស្សូ ពន្យល់ដោយលើកឧទាហរណ៍ថា រដ្ឋមួយមានពលរដ្ឋ ១០០០០ នាក់ ចំនួនមនុស្ស ១០០០០ នាក់នេះបានប្រមូលផ្តុំ ជាអធិបតេយ្យភាពមួយដែលអង្គការទោល។ យ៉ាងណាក៏ដោយអំណាចអធិបតេយ្យទាំងមូលគឺជាការ រួមផ្សំនៃអំណាចអធិបតេយ្យរបស់បុគ្គលម្នាក់ៗ។ ហេតុនេះអធិបតេយ្យភាពរបស់បុគ្គលម្នាក់ៗនោះស្មើ នឹងមួយភាគមួយម៉ឺន។ ហើយនៅក្នុងករណីនេះ ប្រសិនបើចំនួនពលរដ្ឋចូលរួមជាសមាជិកកាន់តែច្រើននោះ តម្លៃនៃអធិបតេយ្យភាពរបស់បុគ្គលត្រូវបានថយចុះ។

ពិតប្រាកដហើយបុគ្គលម្នាក់ៗជាឆន្ទៈដោយឡែក។ ប៉ុន្តែឆន្ទៈដោយឡែកវាអាចមិនស្របគ្នាជា មួយឆន្ទៈទូទៅ។ ទោះជាយ៉ាងណាដោយនេះជាកិច្ចការរបស់ពលរដ្ឋម្នាក់ៗដែលត្រូវធ្វើឱ្យឆន្ទៈដោយឡែករបស់ខ្លួនក្លាយទៅជាឆន្ទៈទូទៅរបស់អធិបតេយ្យដែលខ្លួនគាត់ផ្ទាល់ជាសមាជិករបស់វា។ សម្រាប់ រូស្សូ អធិបតេយ្យ មិនអាចផ្ទេរបានទេ ព្រោះវាជាឆន្ទៈរបស់បុគ្គល។ ការផ្ទេរអធិបតេយ្យទៅឱ្យមនុស្ស ផ្សេង វាអាចធ្វើឱ្យប្រាសចាកពីអំពើល្អទូទៅបើយ៉ាងដូចនោះប្រជាជនត្រូវបានបាត់បង់អធិបតេយ្យរបស់ខ្លួន។ ដូចនេះ អធិបតេយ្យភាព មិនត្រូវបានតំណាងដោយលើកលែងខ្លួនវាផ្ទាល់សម្រាប់អំណាច អាចតំណាង ឬចែករំលែកបាន ប៉ុន្តែឆន្ទៈមិនអាចឡើយ។ អធិបតេយ្យភាពមិនអាចបែងចែកបានឡើយ លោកបានប្រៀបធៀបវាទៅនឹងរាងកាយរបស់មនុស្សដែលត្រូវផ្សំដោយដៃជើង ភ្នែក និងអ្វីៗផ្សេងទៀត។ ប្រសិនបើយើងយកផ្នែកដោយឡែកៗទៅប្រើប្រាស់ដោយមិនបានសហការណ៍ជាមួយផ្នែកដទៃទៀត នោះវាគ្មានប្រសិទ្ធភាពឡើយ។ ការបែងចែកឆន្ទៈដោយបុគ្គលម្នាក់ៗមានឆន្ទៈផ្ទាល់ខ្លួនតែ មួយ ដូចនេះហើយឆន្ទៈនោះពុំមែនជាអធិបតេយ្យភាពទេ។ យើងមិនអាចបែងចែកអធិបតេយ្យទៅជាអំណាចផ្សេងៗទេ ដូចជាអំណាចនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ។ អំណាចនីតិប្រតិបត្តិ ឬរដ្ឋាភិបាល គឺមិន មែនជាអធិបតេយ្យ ថែមទាំងវាមិនមែនជាផ្នែករបស់វាដែរ។ រដ្ឋាភិបាលជាការគ្រប់គ្រងរបស់ច្បាប់ និង វាគ្រាន់តែជាឧបករណ៍ជំនួយរបស់អធិបតេយ្យប៉ុណ្ណោះ។ ដូចនេះសម្រាប់ រូស្សូ អធិបតេយ្យ គឺជាការតែងច្បាប់ ហើយការងារនេះជារបស់ប្រជាជន។ រូស្សូ រិះគន់លើប្រជាជនអង់គ្លេសដោយលោកនិយាយថា ប្រជាជនអង់គ្លេសមានសេរីភាពតែកំឡុងពេលពួកគេជ្រើសរើសតំណាងរាស្ត្រតែប៉ុណ្ណោះ ហើយបន្ទាប់មកពួកគេធ្លាក់ចូលទៅក្នុងទាសភាពវិញដដែល។

ជារួមយើងឃើញថា អធិបតេយ្យភាពរបស់ រូស្សូ គឺមានចំណុចសំខាន់ត្រង់វាមិនអាចតំណាង ឬ ផ្ទេរ ឬបែងចែកបានឡើយ។ តំណាងរាស្ត្រមិនមែនជាតំណាងអធិបតេយ្យ ឬឆន្ទៈរបស់រាស្ត្រឡើយ នោះគ្រាន់តែជាភ្នាក់ងារ ឬតំណាងការងាររបស់រាស្ត្រតែប៉ុណ្ណោះ។ ដូចនេះ អធិបតេយ្យភាព គឺជាការ អនុវត្តនូវឆន្ទៈទូទៅ និងជាអធិបតេយ្យភាពប្រជាជន របស់ប្រជាជន និងជារបស់អ្នករស់នៅ។

### ៧.២.៦ ឆន្ទៈទូទៅ

ឆន្ទៈទូទៅនេះហើយដែលតែងតែរក្សាសុវត្ថិភាព និសុខមាលភាពនៃអ្វីៗទាំងអស់គ្រប់ផ្នែក និងជា ប្រភពនៃច្បាប់ដែលបង្កើតឡើងសម្រាប់គ្រប់សមាជិករបស់រដ្ឋទាំងអស់ នៅក្នុងទំនាក់ទំនងពីម្នាក់ទៅម្នាក់ទៀត និងចំពោះខ្លួនវាដែលធ្វើឱ្យឃើញអ្វីដែលត្រឹមត្រូវ និងមិនត្រឹមត្រូវ។

រូស្សូ កំណត់ថាឆន្ទៈទូទៅគឺជាទិសដៅចំពោះមុខដែលល្អ និងគួរយកចិត្តទុកដាក់ កាន់តែមានឆន្ទៈទូទៅច្រើនតែងតែមានយុត្តិធម៌ច្រើនដែរ ហើយសំឡេងរបស់ប្រជាជនជាសំឡេងពិតប្រាកដរបស់អាទិទេព។ ទាំងអស់នេះមានន័យថា រូស្សូ ឱ្យតម្លៃខ្ពស់លើការសម្រេចរបស់ប្រជាជនទាំងមូលគឺលោកយកប្រជាជនជាប្រមុខការសម្រេចដោយឡែកណាមួយក្រៅពីប្រជាជនត្រូវបានចាត់ទុកជាភាព ឥតបានការ។ ឆន្ទៈទូទៅរបស់រដ្ឋមានលក្ខណៈទូទៅជាងឆន្ទៈទូទៅរបស់សង្គមខ្លះនៅក្នុងរដ្ឋ សម្រាប់ឆន្ទៈទូទៅរបស់រដ្ឋនេះគឺត្រូវតែឈានទៅរកភាពត្រឹមត្រូវច្រើនហើយបង្ហាញផ្លូវទៅរកភាពល្អជាសាកល។ កិច្ចការទី១នៃអ្នកតាក់តែងច្បាប់គឺបង្កើតច្បាប់ដោយអនុលោមតាមឆន្ទៈ

ទូទៅ ឆន្ទៈទូទៅតែងតែឋិតនៅខាងអ្វីមួយដែលពេញចិត្តបំផុត ចំពោះប្រយោជន៍សាធារណៈដែលអាចនិយាយថា សមភាពបំផុតនោះគឺតម្រូវការយ៉ាងពេញលេញដោយគ្រាន់តែបង្ហាញយ៉ាងត្រឹមត្រូវពិតប្រាកដទៅតាមឆន្ទៈទូទៅ។

រូស្សូ បានធ្វើការបែងចែករវាងឆន្ទៈទូទៅ និងឆន្ទៈមនុស្សគ្រប់រូប។ ទាំងនេះគឺជាការខុសគ្នារវាង ឆន្ទៈទូទៅ(General Will) និងឆន្ទៈរួមទាំងអស់(Will of All)។ ឆន្ទៈទូទៅគឺជាភាពទូទៅនៅក្នុងវិញ្ញាណ ដែលនោះជាឆន្ទៈរបស់មនុស្សទូទៅ ដែលជាការពិតគឺអធិបតេយ្យរបស់ប្រជាជន។ ប៉ុន្តែការសង្កត់ធ្ងន់នៅចំកន្លែងដែល រូស្សូ និយាយថា ទូទៅ គឺជាផលប្រយោជន៍ទូទៅ ឬអំពើល្អ ឬគុណសម្បត្តិ។ ហើយ ឆន្ទៈទូទៅនេះគេមិនអាចស្គាល់បានដោយមិនគិតពីការរួមបញ្ចូលដោយឡែកនោះទេ។

ឆន្ទៈទូទៅរបស់ក្រុមមួយ មនុស្សមួយ សហគមមួយ ពុំមែនជាឆន្ទៈទូទៅរបស់រដ្ឋទេ ហើយឆន្ទៈនោះអាចមានកំហុស។ បើក្រុម ឬបក្សនីមួយៗបានបង្កើតឡើងនូវឆន្ទៈទូទៅនោះ ភាពទូទៅនឹងឆន្ទៈទូ ទៅបង្ហាញកាន់តែតិចទៅ។ ឆន្ទៈទូទៅ គឺត្រូវបានកើតឡើង ឬបង្ហាញឱ្យឃើញដោយការរាប់សន្លឹកឆ្នោត ហើយគុណភាពនៃឆន្ទៈទូទៅនេះនៅតែឋិតក្នុងចំនួនភាគច្រើនដដែល។ ប្រសិនបើលទ្ធផលបោះ ឆ្នោតនោះកើតចេញពីការគំរាមកំហែង នោះពុំមែនជាឆន្ទៈទូទៅរបស់ប្រជាជនដែលរូស្សូចង់បានទេ។

### ៧.២.៧ កិច្ចសន្យាសង្គម

កាលដើមឡើយមនុស្សរស់នៅដាច់ៗពីគ្នា និងមានសេរីភាពពេញលេញដោយគ្មានសង្គម គ្មានរដ្ឋ។ ដោយសារតែការរស់នៅតាមរបៀបនេះបានជួបនូវបញ្ហាខ្លះៗទៅតាមការវិវត្តន៍នៃក្រឹត្យក្រមធម្មជាតិ។ ដូចនេះការដែលមនុស្សបានលះបង់ការរស់នៅដាច់ឆ្ងាយពីគ្នាមករស់នៅជាសមាគម គឺដើម្បីសង្គ្រោះ ដល់សេរីភាពដែលពួកគេមានតាំងពីដំបូងនៅក្នុងសភាពធម្មជាតិ។ មនុស្សចាកចេញចោលភាពដាច់ឆ្ងាយពីគ្នាដើម្បីចុះកិច្ចសន្យាមួយគឺកិច្ចសន្យាសង្គម។ ពិតមែនហើយដែលមនុស្សអាចរស់នៅដោយគ្មានសង្គម មនុស្សអាចរស់នៅដោយស្វែងរកអ្វីៗដោយខ្លួនឯង ប៉ុន្តែមនុស្សយល់ឃើញថាវាមានអត្ថ ប្រយោជន៍ច្រើនបើគេរស់នៅជាមួយគ្នា ធ្វើការជាមួយគ្នា។ សមាគមជាកិច្ចសន្យាដែលធ្វើឡើងរវាងបុគ្គលម្នាក់ៗជាមួយនឹងសង្គម។ នេះជាការព្រមព្រៀងគ្នារវាងសមាជិកសង្គមនីមួយៗ និងជាការយល់ ព្រមទាំងសងខាងរវាងអ្នកដឹកនាំ និងអ្នកដែលត្រូវគេដឹកនាំ។ កិច្ចសន្យាសមាគម (Contract of Association) របស់លោក រូស្សូ ខុសគ្នាពី កិច្ចសន្យាព្រមលះបង់(Contract of Renunciation) របស់លោក តូម៉ាស ហប្ស។

កិច្ចសន្យាសង្គមរបស់ រូស្សូ គឺជាការបង្កើតឱ្យមានសង្គមមួយដែលមនុសស្ថិតនៅចំណុះសង្គមពីព្រោះមនុស្សបានប្រគល់សិទ្ធិ និងសេរីភាពរបស់ពួកគេ។ ប៉ុន្តែមនុស្សនៅតែរក្សាសេរីភាពរបស់ពួកគេដដែល ពីព្រោះសង្គមជាសំណុំនៃមនុស្សទាំងអស់ ហើយគ្មាននរណាម្នាក់បាត់បង់សេរីភាពរបស់ពួក គេទេ បើមនុស្សទាំងអស់នោះមិនបានបាត់បង់ទៅណាទេនោះ។ សេរីភាព និងសមភាពរបស់គេម្នាក់ៗ ត្រូវបានធានា។ សង្គមនយោបាយជាអ្នកសង្គ្រោះអ្វីដែលមនុស្សមានកាលនៅក្នុងសភាពធម្មជាតិ គឺសេរីភាព និងសមភាពដោយធានានូវសន្តិសុខរបស់បុគ្គលផងដែរ។ បញ្ហានេះវាខុសគ្នាពីទ្រឹស្តីរបស់របស់ Thomas Hobbes ដែលមនុស្សព្រមលះបង់សេរីភាពរបស់ខ្លួនដើម្បីប្តូរយកសន្តិសុខតាមរយៈកិច្ចសន្យាសង្គម រូស្សូ យល់ឃើញថា បុគ្គលធានាសន្តិសុខរបស់គេបានព្រមទាំងរក្សា និងលើកស្ទួយ សេរីភាព និងសមភាពរបស់គេទៀតតាមរយៈការចុះកិច្ចសន្យាសង្គម។

ទោះយ៉ាងណាក្តី រូស្សូ ហាក់មិនពេញចិត្តចំពោះឥទ្ធិពលសង្គមមកលើមនុស្ស។ ក្នុងនោះគាត់និយាយក្នុងស្នាដៃ កិច្ចសន្យាសង្គម របស់លោកថា *មនុស្សកើតមកមានសេរីភាព ហើយនៅគ្រប់ទីកន្លែងគេឋិតនៅក្នុងច្រវ៉ាក់។* រូស្សូ ឱ្យតម្លៃយ៉ាងច្រើនចំពោះធម្មជាតិ ហើយគិតថាធម្មជាតិរបស់មនុស្សគឺល្អ និងមានសេរីភាពស្រាប់ពីធម្មជាតិ។

រូស្សូ និយាយថាច្បាប់ជាមាគ៌ាមួយសម្រាប់បញ្ឈប់ជម្លោះរបស់ប្រជាជន និងធ្វើឱ្យមានសិទ្ធិស្មើគ្នា។ ប៉ុន្តែច្បាប់បច្ចុប្បន្នមិនសុក្រឹតដូចសម័យបុរាណទេ។

ទាក់ទងសណ្ដាប់ធ្នាប់សង្គមនេះដែរ ហ្សង់ ហ្សាក់ រូស្សូ មានគន្លឹះដោះស្រាយប្រឆាំងនឹងទ្រឹស្ដី នយោបាយរបស់ Thomas Hobbes និងJohn Locke។ រូស្សូ គ្មានបំណងស្វែងរកសណ្ដាប់ធ្នាប់សង្គមដោយប្រើកម្លាំងនោះទេ ហើយការប្រើកម្លាំងនោះ មិនធ្វើឱ្យកើតមាននូវសិទ្ធិនោះឡើយ។ កម្លាំង ជាអង្គការអំណាចដែលគេមិនធ្លាប់ឃើញលទ្ធផលសីលធម៌អ្វីកើតមានឡើយ។ វាពុំមែនជាធន្ទះទេ ដែលផ្ដល់ឱ្យមានការសំដែងកម្លាំងជាចាំបាច់នោះ ភាគច្រើននៃកម្លាំងគឺបង្ហាញនូវការប្រុងប្រយ័ត្ន។ ប្រសិនបើពលរដ្ឋម្នាក់ៗគោរពច្បាប់គ្រប់ៗគ្នា នោះកម្លាំងនៃអំណាចដោយសារមនុស្ស និងមនុស្សដែល ត្រូវគេគោរព មិនត្រូវបានកើតឡើងជាដាច់ខាត។ សណ្ដាប់ធ្នាប់សង្គមគឺជាការត្រឹមត្រូវ និងសមហេតុផល ត្រូវតែមានកិច្ចព្រមព្រៀង។ នៅពេលជួបឧបសគ្គ និងដើម្បីការពារខ្លួនឯងផង មនុស្សត្រូវតែឯកភាពគ្នា ហើយបង្កើតជាសមាគម។ ប៉ុន្តែជាការលំបាកនឹងធ្វើឱ្យមានការគោរពមនុស្ស និងអំពើល្អរបស់សមាជិកនីមួយៗ។ តែជាលទ្ធផលនៃការចូលរួមនៅក្នុងសង្គម បុគ្គលនីមួយៗនៅតែត្រូវបានចាត់ទុកជា សមាជិកមួយដោយឡែក និងនៅតែមានសេរីភាពដូចពេលមុនដដែល។ កិច្ចសន្យាសង្គម មានន័យថា យើងម្នាក់ៗបានដាក់ខ្លួន និងប្រគល់អំណាចរួមក្រោមទិសដៅខ្ពស់របស់ធន្ទះទូទៅនៅក្នុងលទ្ធភាពប្រតិ បត្តិការរបស់យើង យើងទទួលយកភាពជាសមាជិកម្នាក់ៗដែលជាផ្នែកមួយនៃអង្គការទាំងមូលដែលមិន អាចបែងចែកបាន។

កិច្ចសន្យាសង្គមរបស់ រូស្សូ គឺសេរីភាពនៃសមាជិកចូលរួមនីមួយៗ។ គាត់ចង់បានកិច្ចសន្យាសង្គមថ្មីមួយដែលមិនឃ្លាតចាកឆ្ងាយពីសភាពធម្មជាតិរបស់មនុស្ស ព្រោះតែលោកមើលឃើញមនុស្ស ភាគច្រើនដែលឋិតនៅក្នុងកិច្ចសន្យាសង្គមនោះហាក់ដូចជាអ្នកបង្កើតច្បាប់ប្រហាក់ប្រហែលទៅនឹងការ យកច្រវាក់មកដាក់ខ្លួនឯង។

**៧.២.៨ អំពីច្បាប់**

ចំពោះបញ្ហាច្បាប់វិញលោកបានបញ្ជាក់ថា ច្បាប់ដែលអនុម័តមិនមានការចូលរួមពីសំណាក់រាស្ត្រ ទេ នោះមិនមែនជាច្បាប់ឡើយ។ លោកថា បើការបង្កើតច្បាប់នេះ រាស្ត្រមិនអាចចូលរួមបាន នោះគួរតែ ធ្វើប្រជាមតិជាការអនុម័តចុងក្រោយ។

រូស្សូ យល់ថា ច្បាប់ត្រូវបង្កើតឡើងដោយរាស្ត្រនេះពិតជាមិនអាចធ្វើប្រជារាស្ត្របាត់បង់សេរីភាពរបស់ខ្លួនឡើយ ព្រោះថាច្បាប់ដែលអនុម័តដោយមនុស្សទាំងអស់។ ដូចនេះចង់មិនចង់ក៏ច្បាប់នេះ ក៏ច្បាប់នេះបម្រើឱ្យមនុស្សទាំងអស់នោះវិញដែរ នៅពេលដែលគេអនុវត្តច្បាប់នេះ។ ក្នុងករណីយើងឃើញថា អ្នកភាគតិចតែងតែរងនូវការបង្ខិតបង្ខំ និងការប្រឆាំងពីសំណាក់អ្នកប្រតិបត្តិច្បាប់។ ហេតុនេះ ទើបលោក រូស្សូ តម្រូវឱ្យអ្នកភាគតិចគោរពអ្នកភាគច្រើន។ ច្បាប់សំខាន់ៗរបស់រដ្ឋទាំងអស់ត្រូវតែរាស្ត្រ ទាំងអស់ជាអ្នកសម្រេចតាមរយៈការធ្វើប្រជាមតិ ចំពោះច្បាប់ដែលមិនសូវសំខាន់ទុកនាទីនេះឱ្យអ្នកតំណាងរាស្ត្រជាអ្នកសម្រេច។

លោក Rousseau បានបង្ហាញឱ្យឃើញ មានភាពខុសគ្នារវាងអំណាចអ្នកតំណាង និងកាតព្វកិច្ចអ្នកតំណាង។ តំណាងដែលជ្រើសតាំងសម្រាប់រយៈពេលយូរច្រើនតែភ្លេចរាស្ត្រដែលជាអ្នកបោះឆ្នោតឱ្យនោះ។ ចំណែកតំណាងរាស្ត្រដែលជ្រើសតាំងរយៈពេលខ្លី គេមិនទាន់មានទម្លាប់យកមុខងារអ្នកតំណាងជាមុខរបរនៅឡើយ ហើយស្ថិតនៅជាអ្នកតំណាងពិតៗ។ លោក Rousseau មានគំនិតថា «ចំនួននៃការជ្រើសរើស ត្រូវមានកម្រិតពេលវេលា ព្រោះថាអ្នកតំណាងរាស្ត្រដែលប្រជារាស្ត្រលើកច្រើនសារនោះនឹងយកតំណែងតំណាងរាស្ត្រមកធ្វើជាមុខរបរមិនខាន ។ គេនឹងមានទម្លាប់ជាអ្នកមានមុខរបរធ្វើជាអ្នកតំណាងរាស្ត្រ។ ដូច្នេះ គេត្រូវមានការកម្រិតនៃការជ្រើសរើសឱ្យមានតែម្ដង ឬពីដង ហើយត្រូវរង់ចាំ២ ឬ៣ឆ្នាំទៀត ទើបអាចមកឈរឈ្មោះឱ្យគេជ្រើសសារជាថ្មីម្ដងទៀត»។

លោក Rousseau ថា«ត្រូវបង្កើតច្បាប់សម្រាប់ដាក់ទោសចំពោះតំណាងរាស្ត្រ ឬ ត្រូវដាក់ទណ្ឌកម្មចំពោះអ្នកតំណាងរាស្ត្រណាដែលមិនអនុវត្តន៍តាមឆន្ទៈរបស់ប្រជាជន និងមិនអនុវត្តន៍តាមកាតព្វកិច្ចរបស់ខ្លួន»។

មិនត្រូវឱ្យមានរបាំងរាំងឆន្ទៈទូទៅ និងពលរដ្ឋ។ ដូច្នេះប្រជាពលរដ្ឋត្រូវចូលរួមដោយខ្លួនឯង មិនតាមរយៈអ្នកណាផ្សេងៗទៀតទេ។ ពលរដ្ឋម្នាក់ៗត្រូវយល់អ្វីដែលជាប្រយោជន៍រួម ហើយគេមិនត្រូវធ្វើតាមរយៈក្រុមមនុស្សទេ។ ពលរដ្ឋមានវិចារណញ្ញាណ មានបញ្ញា ដូច្នេះគេមានមតិ គេអាចសម្រេច ដោយខ្លួនគេផ្ទាល់។ ឆន្ទៈរួម ត្រូវតែបញ្ចេញដោយផ្ទាល់ពីប្រជារាស្ត្រទៅតាមផលប្រយោជន៍ផ្ទាល់របស់ប្រជារាស្ត្រ។ នេះជាចំណុចសំខាន់ នៅក្នុងគំនិតប្រជាធិបតេយ្យ។

អំពីការអនុវត្តន៍ច្បាប់ លោក រូស្សូ ថាគេត្រូវអនុវត្តន៍ច្បាប់ឱ្យបានត្រឹមត្រូវ និងប្រិតព្រាងបំផុត។ ពេលណាដែលច្បាប់ត្រូវបានអនុម័តហើយ តាមមនសិការរបស់ពលរដ្ឋទាំងមូល ច្បាប់នោះក៏ត្រូវយកទៅអនុវត្តន៍យ៉ាងតឹងរឹងបំផុតដែរ។ អំណាចនិតិប្រតិបត្តិ គឺរដ្ឋាភិបាលជាអ្នកអនុវត្តន៍ច្បាប់។ រដ្ឋភិបាល ទាល់តែខ្លាំង ពីព្រោះរដ្ឋាភិបាលត្រូវប្រតិបត្តិចំពោះទាំងអស់។ បើច្បាប់អនុវត្តន៍មិនចំពោះមនុស្សទាំងអស់នោះ មិនមែនជាប្រជាធិបតេយ្យទេ។ នៅក្នុងរបបប្រជាធិបេយ្យ រដ្ឋភិបាលត្រូវតែខ្លាំង ប៉ុន្តែជាអំណាចចំណុះ។ រដ្ឋាភិបាលជាអ្នកប្រតិបត្តិច្បាប់ មានប្រជាជនជាអធិបតី។ អត្ថិភាពរបស់រដ្ឋ គឺធ្វើអធិបតេយ្យឱ្យមានដល់ប្រជារាស្ត្រ។ អធិបតេយ្យរបស់ប្រជារាស្ត្រស្ថិតនៅក្នុងអំណាចនីតិបញ្ញត្តិដែលជាអំណាចធ្វើច្បាប់ និងលុបច្បាប់។ អធិបតេយ្យរបស់ប្រជារាស្ត្រ គឺប្រជារាស្ត្រជាអ្នកចាត់ចែងដោយខ្លួនឯង។ ចំពោះអត្ថិភាពរបស់រដ្ឋាភិបាលគឺទាក់ទងនឹងការអនុវត្តន៍ច្បាប់។ រដ្ឋាភិបាលគ្រាន់តែជាតំណាងរបស់ប្រជារាស្ត្រ និងរបស់ច្បាប់។ រដ្ឋមន្ត្រីជាខ្ញុំបម្រើរបស់ប្រជារាស្ត្រ ហើយរដ្ឋមន្ត្រីក៏អាចត្រូវ គេដកហូតងារបានដែរ។

# ជំពូកទី៣ ទ្រឹស្តីពុទ្ធិ

# មេរៀនទី១ លំនាំទូទៅនៃទ្រឹស្តីពុទ្ធិ

## ១.១ តើទ្រឹស្តីពុទ្ធិជាអ្វី?

ជាផ្នែកមួយនៃទស្សនវិជ្ជា, ជាការសិក្សាវិស័យក្លាស៊ិក (classic) មួយក្នុងចំណោមវិស័យក្លាស៊ិកទាំងប្រាំមាន សោភ័ណវិជ្ជា សីលវិជ្ជា តក្កវិជ្ជា អស្តិរូបវិទ្យា និងទ្រឹស្តីពុទ្ធិ។

ជាវិទ្យាសាស្ត្រនៃការរុករកតម្លៃសច្ចភាពនៃពុទ្ធិរបស់មនុស្ស។

❖ **ប្រភពនៃទ្រឹស្តីពុទ្ធិ**

ក. ផ្តើមពីចំណង់ដឹង៖ អំណាចបញ្ញារបស់មនុស្សស្វែងរកពុទ្ធិ

ខ. វិស័យពុទ្ធិនេះអភិវឌ្ឍនៅក្រិកបុរាណ

ឧទាហរណ៍៖ សុក្រាត(Socrates) ការស្វែងរកពុទ្ធិតាមរយៈការសួរ។

ឧទាហរណ៍ ប្លាតុង (Plato) ល្បែងសួរស្វែងរកការសិក្សាធ្វើឲ្យទៅជាប្រព័ន្ធ។

❖ **ប្រភពនៃពាក្យទ្រឹស្តីពុទ្ធិ**

ពាក្យ epistemology មកពីពាក្យក្រិក

- Episteme = Knowledge (ចំណេះដឹង)
- Logos = Theory, study, reason, rational, account (ការពន្យល់ហេតុផល)

ពាក្យ epistemology=ទ្រឹស្តីពុទ្ធិ=ទស្សនវិជ្ជាពុទ្ធិ

❖ **ទ្រឹស្តីពុទ្ធិ**

និយមន័យ និងទ្រឹស្តីទស្សនវិទូ

- Plato: ពុទ្ធិ គឺជាជំនឿ (ត្រឹមត្រូវ) រួមនឹងការពន្យល់ដែលមានហេតុផល។
- Thomas Aquinas: ពុទ្ធិគឺជាតថភាពសកម្មនៃទំនាក់ទំនងរវាងប្រធានវិស័យ និងវត្ថុវិស័យនៅក្នុងញាណ។
- Karl mark: ពុទ្ធិ គឺជាការស្តាបនាទំនាក់ទំនងសេដ្ឋកិច្ច។
- Descartes: ពុទ្ធិគឺជាការយល់ដឹងជាក់ច្បាស់ដែលមិនអាចសង្ស័យដោយផ្អែកលើមូលបដិញ្ញាជាក់ច្បាស់។
- Ludwig Wittgenstein (ទស្សនវិទូអូទ្រីស) ពុទ្ធិជាចំណេះជាក់ស្តែងនៅក្នុងបរិបទសង្គមជាក់លាក់មួយ។

❖ **លក្ខខណ្ឌនៃការយល់ដឹង**

ក. ចំណង់ដឹង

- Aristotle: ជាសារជាតិមនុស្សទាំងអស់ គឺចង់ដឹង។
- Plato: នរណាខ្វះសមត្ថភាពចង់ដឹងជាបឋមនេះ មិនអាចសម្រេចបានការយល់ដឹងជ្រៅខាងទស្សនវិជ្ជាបានឡើយ។
- Socrates: ចូរស្គាល់ខ្លួនឯង។ ជីវិតគ្មានការត្រួតពិនិត្យ រស់នៅគ្មានតម្លៃ។
- Buddha: អត្តាហិ អត្តនោនាថោ។
- Martin Heidegger (ទស្សនវិទូអាល្លឺម៉ង់): មនុស្សជាភាវជិតបំផុតឆ្ងាយបំផុត និងចម្លែកបំផុតក្នុងចំណោមភាវទាំងអស់។

**មតិទូទៅ ឬពុទ្ធិសាមញ្ញ**

ពុទ្ធិចែកជាបី គឺពុទ្ធិសាមញ្ញ ពុទ្ធិវិទ្យាសាស្ត្រ ពុទ្ធិទស្សនវិជ្ជា។

- ទស្សនៈគ្មានលក្ខណៈជាប្រព័ន្ធ ឬរិះគន់ច្បាស់លាស់។

- វាតែងតែផ្លាស់ប្តូរជាមួយបរិបទ សម័យកាល។

- ជាពុទ្ធិគ្មានលក្ខណៈវិទ្យាសាស្ត្រ។

+Thomas Reid: ពុទ្ធិសាមញ្ញមានលក្ខណៈសភាវគតិធម្មជាតិ ជាមួយនោះយើងត្រូវសម្របទៅតាមការរីកចម្រើនក្នុងពិភពលោក។

ពុទ្ធិធម្មជាតិ គឺពុទ្ធិអព្ភន្តរញាណ និងពុទ្ធិសភាវគតិ។

## ១.២ ស័ព្ទមូលដ្ឋាននៃទ្រឹស្តីពុទ្ធិ

**ការដឹង** (knowing)

ក. ការដឹង ជាការវិនិច្ឆ័យខាងក្នុងមួយ អនុវត្តដោយញាណសតិយល់ដឹង ដោយផ្អែកលើភស្តុតាងផ្តើមពីវត្ថុ។

ប្រធានពុទ្ធិ → វត្ថុពុទ្ធិ

ខ. ដឹង

- មានលទ្ធភាពគូសបញ្ជាក់ (ស្គាល់, ទទួលស្គាល់)

- មានលទ្ធភាពអធិប្បាយ ពន្យល់ (បទពិសោធ)

គ. ដឹង

- ធ្លាប់ទាក់ទងជាមួយ

- យល់ដឹង ឬឮពីវា

- ចេះ (មានជំនាញ, មានទម្លាប់

**ភាពជាក់ច្បាស់**

និយមន័យ: ជាក់ច្បាស់ ជាការយល់ស្របទៅនឹងសំណើរមួយ

ភាពជាក់ច្បាស់ ត្រូវមានលក្ខណៈបរានុម័ត=មិនសង្ស័យ មានភស្តុតាង។

**ភស្តុតាង** (Evidence)

- ភស្តុតាងគឺជាលក្ខខណ្ឌបំពេញដែលបញ្ជាក់អំពីសច្ចភាពនៃសំណើរ។ឧ.ទា.បើភ្លៀងនោះដីសើម។

**កំហុស** (error)

- និយមន័យ: កំហុសជាកាអះអាងអ្វីមួយមិនពិតឬបដិសេធពិត

- ប្រភពកំហុស: ខ្វះភស្តុតាង ធន្ទៈរុញបញ្ញាហួសពីភស្តុតាង និងកម្រិតសមត្ថភាពយល់ដឹង សមត្ថភាពធន្ទៈទំនោរ។

- លទ្ធភាពកំហុស: ប្រញាប់ ប្រហើន ច្របូកច្របល់ បុរេវិនិច្ឆ័យ

## ១.៣ ប្រភពពុទ្ធិ

ប្រភពពុទ្ធិមានច្រើន ក្នុងនោះរួមមាន៖

១. ទំនៀមទម្លាប់ប្រពៃណី

២. អ្នកឯកទេស

៣. ប្រត្យក្សារម្មណ៍ឥន្ទ្រីយ៍

៤. វិចារណៈ

៥. អព្ភន្តរញ្ញាណ=ពុទ្ធិ

៦. បទពិសោធ

៧. ការចងចាំ

៨. ភស្តុតាង

៩. ចំណង់ដឹង

១០. គំនិត+ការពិចារណា+ស្វ័យញាណ

១១. ភាសា (ស័ព្ទ=ការនិយាយ, ពាក្យ=ការកត់, សរសេរ)

១២. logic (ជាគោលការនាំឲ្យមានការនិយាយ សរសេរបានត្រឹមត្រូវ)

**១.៤ សារៈសំខាន់នៃទ្រឹស្តីពុទ្ធិ**

**ផ្តល់យុទ្ធសាស្ត្រ**

យុទ្ធសាស្ត្រ(strategy): អ្វីដែលត្រូវធ្វើ, ការធ្វើ

- ព្រោះវាសិក្សាអំពីធម្មជាតិ, ទំហំ, ភាពត្រឹមត្រូវនៃពុទ្ធិ។

ឧ.ទា. លោក Francis bacon : ពុទ្ធិ គឺជាអំណាច (អំណាចទីនេះ គឺអំណាចបញ្ជាធម្មជាតិ)។

- Buddha: អវិជ្ជានិងតណ្ហាជាប្រភពនៃភាពឥតសណ្តាប់ធ្នាប់

- ពុទ្ធិបច្ចេកវិជ្ជា ជាពុទ្ធិមូលដ្ឋានទាក់ទងទៅនឹងអំណាចសេដ្ឋ-កិច្ច នយោបាយ យោធា...។

**វប្បធម៌** (culture)

- វប្បធម៌ គឺជារបៀបរស់នៅ។

- វប្បធម៌ គឺជាប្រព័ន្ធស្តង់ដាសង្គមខាងវប្បធម៌ នៃការវិនិច្ឆ័យ ជំនឿ និងអំពើប្រព្រឹត្តក៏ដូចជានិមិត្តរូប និង ផលិតផលសម្ភារៈនៃគំរូអាកប្បកិរិយាដែលបានសន្មត់។

- ពុទ្ធិ ជាផ្នែកនៃវប្បធម៌។ បើមានពុទ្ធិមនុស្សអាចបណ្តុះបណ្តាល ប្រើប្រាស់បរិស្ថាន ធម្មជាតិ និងសង្គម។ មនុស្សអាចយល់ដឹងបញ្ហាសំខាន់ៗ ចេះវិភាគ បកស្រាយ និងសម្រេចចិត្តល្អៗក្នុងការធ្វើសកម្មភាព។

**ពុទ្ធិសម័យទំនើប**

- លោក ដេកាត៖ រកឃើញទ្រឹស្តីវិចារណញ្ញាណនិយម។

- លោក Hume៖ រកឃើញទ្រឹស្តីពិសោធនិយម។

វិចារណញ្ញាណនិយម+ពិសោធនិយម = អតិសេដ្ឋ(ខ្ពស់បំផុត,ល្អិតល្អន់បំផុត)។

**អប់រំ**

ស័ព្ទអប់រំ មកពីអក្សរឡាតាំង educare = bring up (ចិញ្ចឹមឬ បណ្តុះបណ្តាល)។

- Plato: គោលដៅនៃការអប់រំគឺការអភិវឌ្ឍរាងកាយ ព្រលឹង សោភ័ណ សុក្រឹតកម្មទាំងអស់ដែលគេអាច ឬ អភិវឌ្ឍញាណសតិរឹងមាំនៅក្នុងរាងកាយឲ្យរឹងមាំ។ (ព្រលឹង=វិចារណញ្ញាណ, ឆន្ទៈ)

- Aristotle: ការអប់រំគឺដើម្បីអភិវឌ្ឍសតិមនុស្ស ជាពិសេសញាណសតិរបស់គេ ដើម្បីគេអាចមានលទ្ធភាព ពេញចិត្តការសញ្ជឹងគិតពីសច្ចភាពខ្ពស់ កុសល សោភ័ណ នៅក្នុងនោះមានសុភមង្គលឥតខ្ចោះ។ (សតិ=អំណាច)

# មេរៀនទី២ ទ្រឹស្តីពុទ្ធិរបស់ព្រះពុទ្ធ

## ២.១ សេចក្តីផ្តើម

ការចាប់កំណើតរបស់មនុស្សនៅលើផែនដី មានការវិវឌ្ឍន៍ ពីមួយថ្ងៃទៅមួយថ្ងៃ ដោយ សារការសម្បូរបែបនៃអាហារ ដែលធ្វើឲ្យខួរក្បាលរបស់មនុស្សមានការវិវឌ្ឍឥតឈប់ឈរ។ ការរីកចម្រើននេះ បានធ្វើឲ្យមនុស្សយើងខិតខំគិតធ្វើអ្វីគ្រប់យ៉ាង ដើម្បីស្វែងរកអ្វីដែលថ្មី និងមានប្រយោជន៍ សម្រាប់បន្សល់ទុកឲ្យកូនចៅជំនាន់ក្រោយ។ ដោយសារមនុស្សកើតមកតែងតែមានឧបស្ស័យខុសៗគ្នា ដូច្នេះហើយទើបស្នាដៃដែរពួកគាត់បានបន្សល់ទុកនោះមានលក្ខណៈខុសប្លែកៗពីគ្នា។ ចំពោះមនុស្សដែលបានបន្សល់ទុកនូវស្នាដៃទាំងនោះត្រូវបានគេហៅថា អ្នកប្រាជ្ញ ឬពួកទស្សនវិទូ ពួកគាត់ទាំងនោះរកឃើញនៅទស្សនៈខុសៗគ្នាជាច្រើន ដោយប្រកបដោយហេតុផលសមរម្យ ដែលមនុស្សជំនាន់ក្រោយយកមកអនុវត្តរហូតមកដល់សព្វថ្ងៃនេះ។ ហើយសីលធម៌រស់នៅប្រចាំថ្ងៃដែលជាទ្រឹស្តីមានគុណសម្បត្តិបន្ទន់ចិត្តឲ្យមនុស្សចេះរស់នៅរួមគ្នា ជាសង្គមប្រកបដោយសុខសាន្ត វៀរចាកពីជំលោះទាស់ទែញគ្នា។ ហើយលើសពីនេះទៅទៀត ធ្វើឲ្យមនុស្សរស់នៅប្រកបដោយសុភមង្គលក្នុងសង្គមរហូតដល់ប្រទេសជាតិ។ ទស្សនៈដែលមានភាពទន់ភ្លន់ និងមានភាពវ៉ៃចំណាស់ជាងគេ គឺព្រះពុទ្ធ ដែលទ្រឹស្តីរបស់ព្រះអង្គមានលក្ខណៈសន្តិភាព និងប្រកបដោយធម៌ ដូចជាទ្រឹស្តីនិយាយពី ពុទ្ធិរបស់ព្រះពុទ្ធជាដើម។ នៅក្នុងកិច្ចការស្រាវជ្រាវត្រូវបានបង្ហាញអំពើជីវប្រវត្តិរបស់ព្រះពុទ្ធ និងទ្រឹស្តីពុទ្ធិរបស់ព្រះអង្គផងដែរ។

## ២.២ ពុទ្ធប្រវត្តិ

### ក.ការប្រសូត្ររបស់ព្រះពុទ្ធ

ព្រះពុទ្ធជាបុត្រព្រះបាទ សុទ្ធោទនៈ និងព្រះនាងសិរិហាមាយា សោយរាជ្យនៅក្នុងរដ្ឋឈ្មោះ កបិលពស្តុ ដែលសព្វថ្ងៃហៅថាប្រទេស ណេប៉ាល់។ ព្រះអង្គទ្រង់ប្រសូតនៅថ្ងៃសុក្រ១៥កើត ខែពិសាខ ឆ្នាំច (៦២៣ឆ្នាំ មុន គ.ស .) នៅក្រោមដើមសាលព្រឹក្ស(ដើមរាំង) នៅត្រង់ព្រំដែនចន្លោះនៃនគរ ទេវទហៈ និងនគរ កបិលពស្តុ នៅវេលាថ្ងៃត្រង់(ព្រះពុទ្ធ គឺជាបុត្រារាជសក្យវង្ស នៃប្រទេសឥណ្ឌាភាគខាងជើងបុរាណ សព្វថ្ងៃស្ថិតក្នុងប្រទេសនេប៉ាល)។ ព្រះអង្គមានព្រះជន១៦វស្សា ព្រះអង្គក៏បានរៀបអភិសេកជាមួយព្រះនាង ពិម្ពាយសោធរា នៅថ្ងៃអាទិត្យ ពេញបូរមីខែកត្តិក ឆ្នាំឆ្លូវ។ ទ្រង់សោយរាជ្យបាន ១៣ ឆ្នាំ ក៏បានព្រះរាជបុត្រមួយព្រះអង្គព្រះនាម រាហុលកុមារ ។ ទ្រង់សាងព្រះផ្នួស ក្នុងគម្រប់ព្រះជន្ម២៩ ព្រះវស្សា ព្រះសិទ្ធត្ថៈ ទ្រង់យាងចេញពីព្រះនគរ ដើម្បីសាងព្រះផ្នួសនៅថ្ងៃព្រហស្បតិ៍ ពេញបូណ៌មី ខែអាសាឍ ឆ្នាំថោះ ក្បែរឆ្នេរស្ទឹងអនោមគឺ ក្នុងថ្ងៃដែលព្រះរាហុលកុមារប្រសូត្រនោះ។

### ខ. ការត្រាស់ដឹងរបស់ព្រះពុទ្ធ

ព្រះអង្គជាកុមារម្នាក់ដែលប្រកបដោយទឹកចិត្តមេត្តា ករុណាតាំងពីព្រះអង្គនៅតូច ជាពិសេសព្រះអង្គមានបញ្ញាឆ្លាតខ្លាំងណាស់ អាចរៀនចេះចប់គ្រប់មុខវិជ្ជា ដែលមាននៅក្នុងសម័យនោះ យ៉ាងឆាប់រហ័ស និងល្អជាទីបំផុត ហើយព្រះអង្គមាននិស្ស័យខាងធ្វើសមាធិតាំងតែពីនៅវ័យកុមារ និងពេលដែល ព្រះជន្ម២៩ ព្រះវស្សា ព្រះសិទ្ធត្ថ បានលះបង់ព្រះរាជសម្បិត្តិ ព្រះអគ្គមហេសី និងព្រះរាជបុត្រ ដើម្បីស្វែងរកសច្ចធម៌ ក្នុងជីវភាពជាសង្ឃ បន្ទាប់ពីយល់ឃើញថា ចំណេះដឹង ដែលបានមកពីគម្ពីរវេទពុំអាចផ្តល់នូវសុខៈដល់មនុស្សលោកបានឡើយ។ ក្នុងរយៈពេល ៦ឆ្នាំក្រោយមក ព្រះអង្គបានរកឃើញនូវសច្ចធម៌ ដោយព្រះអង្គហៅថា ការត្រាស់ដឹងនូវសម្មាសម្ពោធិញាណ ឬហៅថា(ការសម្រេចដឹងនូវអ្វីៗ គ្រប់យ៉ាងក្នុងធម្មជាតិ) ក្នុងព្រះជន្ម៣៥ព្រះវស្សា នៅថ្ងៃពុធ ពេញបូរណ៍មី ខែពិសាខ ឆ្នាំរកា ក្រោមដើមពោធិ៍ព្រឹក្សនៅខាងលិច ស្ទឹងនេរញ្ជរា នាមណ្ឌលគយា ឬ ហៅថា ពុទ្ធគយា។ ក្រោយពីបានរស់នៅសុខសាន្តអស់មួយរយៈពេល ថ្ងៃមួយ មាទោនិម្មិតទាំងបួនលេចឡើង។ ដោយអផ្សុកខ្លាំងពេកព្រះអង្គបានចេញ

ទៅក្រសាលឧទ្យានដែលស្ថិតនៅមុខព្រះបរមរាជវាំងដើម្បីយាងទតមើលការរស់នៅរបស់ប្រជារាស្ត្រដទៃ។ នៅពេលដែលព្រះអង្គយាងក្រសាលឧទ្យានព្រះអង្គទតឃើញ៖ មនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងបព្វជិត។

បន្ទាប់ពីបានទតឃើញទេពនិមិត្តទាំង៤រួចមក ទ្រង់ព្រះចិន្តាថា អាត្មាអញត្រូវតែបួស មានតែភេទជាអ្នកបួសនេះទេ ទើបអាចស្វែងរកសច្ចធម៌បាន។ បន្ទាប់ពីការចេញបួស ទ្រង់បានធ្វើទុក្ករកិរិយាអស់៦វស្សា ទ្រង់បានត្រាស់ដឹងសច្ចធម៌ជាព្រះពុទ្ធ ក្នុងព្រះជន្ម ៣៥ វស្សា ( ៥៩០ ឆ្នាំ មុន គ.ស ) នៅថ្ងៃ១៥ កើត ខែពិសាខ។ នៅក្រោមដើមឈើមួយឈ្មោះ ពោធិ៍ ដោយបែរព្រះភក្ត្រទៅទិសខាងកើត ហើយតាំងព្រះទ័យយ៉ាងហ្មត់ចត់ថា បើទោះជាស្បែកសរសៃ និងឆ្អឹងរបស់ខ្ញុំត្រូវរេឡេះរលួយ ជីវិតត្រូវឈាមហូរវីងស្ងួតយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនក្រោកចេញពីនេះជាដាច់ខាត លុះត្រាទទួលបានគតិបណ្ឌិតខ្ពស់បំផុតមានឈ្មោះថាសម្មាសម្ពោធិញ្ញាណដែលឈានទៅរកសុភមង្គល។

**គ. ការបរិនិព្វាននៃព្រះពុទ្ធ**

ព្រះពុទ្ធទ្រង់បរិនិព្វានក្នុងព្រះជន្ម៨០ព្រះវស្សា នៅថ្ងៃអង្គារ១៥កើត ខែពិសាខ ក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ ( ៥៤៣ ឆ្នាំមុន គ.ស. ) នៅក្រោមដើមពោធិ៍ព្រឹក្សក្រុងកុសិនារា នៃមល្លៈក្សត្រ។ ទ្រង់បានផ្តាំនឹងព្រះអានន្ទថា ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគត សម្តែងហើយ បញ្ញត្តិហើយ ធម៌ និងវិន័យនោះជាគ្រូរបស់អ្នកទាំងឡាយ។ តថាគតមិនមែនជាគ្រូដែលហួង ហែងវិជ្ជា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម្មវិន័យនេះ ភិក្ខុនោះ នឹងលះបង់ នូវជាតិសង្សារ ធ្វើនូវព្រះនិព្វានជាទីបំផុតបានពុំខាន។ ពុទ្ធកិច្ច ៥ យ៉ាងនោះគឺ

១. ពេលព្រឹក ទ្រង់យាងបិណ្ឌបាត

២. ពេលរសៀល ទ្រង់ប្រទានធម៌ទេសនា

៣. ពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ

៤. ពេលអាធ្រាត្រ ទ្រង់ដោះប្រស្នាជាមួយពួកទេវតា ដែលមកទូលសួរ

៥. ពេលជិតភ្លឺ ទ្រង់ប្រមើលមើល ឧបនិស្ស័យសត្វត្រូវប្រោស។

ព្រះសកម្មភាពរបស់ព្រះអង្គគ្មានពេលសម្រាក គិតទៅយប់១ ថ្ងៃ១ រយៈពេញ២៤ម៉ោងព្រះអង្គទ្រង់ផ្ទុំមិនលក់( ស្កប់ស្កល់ )ដូចមនុស្សធម្មតាទេ ទ្រង់ប្រព្រឹត្តយ៉ាងនេះអស់រយៈពេល៤៥ព្រះវស្សារហូតដល់ថ្ងៃបរិនិពាន្វ គ្រាន់តែសម្រាកព្រះវរកាយមួយស្របក់លាតតម្រង់ព្រះបដ្ឋិលើសង្ឃាដីដែលព្រះអានន្ទត្តេរតែងតែក្រាលថ្វាយ។

## ២.៣ ទ្រឹស្តីពុទ្ធិរបស់ព្រះពុទ្ធ

ព្រះពុទ្ធស្វែងរកធម៌ ឃើញដោយប្រាជ្ញាញាណរបស់ព្រះអង្គ ឥតបានរៀនពីគ្រូបាអាចារ្យណាទេ ហើយជាទីប្រជុំនៃធម៌ ប្រជុំធម៌៨៤០០០ធម្មក្ខន្ធ ដែលព្រះពុទ្ធសម្តែងក្នុងរយៈពេល៤៥ឆ្នាំ។ ក្នុងការស្វែងរករបស់ព្រះអង្គចំពោះសច្ចភាព នៃអត្ថិភាពមនុស្សញ៉ាំងឲ្យមានឡើងដោយចំណងសេចក្តីទុក្ខ ព្រោះព្រះគោតមត្រូវបានគេនិយាយថា បានទៅសិក្សាជាមួយគ្រូម្នាក់ហើយម្នាក់ទៀតជាបន្តបន្ទាប់។ ព្រះអង្គបានជួបប្រទះជាមួយ នឹងទស្សនវិជ្ជាខុសគ្នាជាច្រើនក៏ដូចជាការប្រតិបត្តិនានាខាងសាសនានៃសម័យកាលនោះ។ ព្រះអង្គបានដឹងថា មនុស្សម្នាក់បានចាប់ផ្តើមរួចជាស្រេចពីការសង្ស័យសុពលភាពនៃការទាញវិចារណកិច្ច និងតក្កវិជ្ជា ថាជាមធ្យោបាយឈានទៅរកទៅដល់ពុទ្ធិស្តីពីសច្ចភាពនិងតថភាព។ ការត្រាស់ដឹងរបស់ព្រះអង្គព្រះគោតម ប៉ុនប៉ងបញ្ជាក់ពីប្រភពខុសៗគ្នានៃពុទ្ធិ គូសបញ្ជាក់ព្រំដែន និងសុពលភាពដោយមិនធ្លាក់ចូលក្នុងលទ្ធិមិននិយមជឿទេវៈ។

### ២.៣.១ ព្រះពុទ្ធគិតពិចារណាពុទ្ធិមាន៣ប្រភេទ

១.បុព្វេនិវាសានុស្សតិញ្ញាណ ការដឹងត្រឡប់ក្រោយ គឺជាសមត្ថភាពដឹងពីប្រវត្តិអតីតកាលផ្ទាល់របស់ខ្លួន។ វាជាការចងចាំ / លំនឹកហើយ លំនឹកជាការចងចាំអត្ថិភាព( កំណើត ) អតីតកាលនេះត្រូវបានលំនឹក / តាមរយៈអំពើនានានៃការសម្មាធិល្អិតល្អន់ ដូចជាក្នុងការអភិវឌ្ឍសមត្ថភាព / សម្បទាទាំងឡាយដទៃទៀត។

២.ចុតូបបាតញ្ញាណ ការឈ្វេងយល់/ប្រាជ្ញាញាណ គឺជាពុទ្ធិស្តីពីអ្វីដែលទទួលមរណភាពហើយ និងអ្វីដែលនៅរស់រានមានជីវិតនៃការៈដទៃទាំងឡាយដែលធ្វើដំណើរត្រាចចរក្នុងវដ្តនៃអត្ថិភាព (ជាតិ) ផ្សេងៗ ស្របជាមួយនិងអាកប្បកិរិយា (កម្ម / អំពើ) របស់ពួកគេ។

៣. សព្វញ្ញុតញ្ញាណ ពុទ្ធិស្តីពីការបំផ្លាញនៃពេលវេលានានាដែលបន្តគ្នាដែលរួមគ្នាទាំងបី និងទូរវេទន៍ផ្តល់ឲ្យការយល់ធ្លុះជ្រៅ ការយល់ដឹងទៅក្នុងអរិយសច្ចទាំងបួន។ ព្រះពុទ្ធទទួលយកពិចារណញ្ញាណ និងប្រត្យក្សារម្មណ៍/សញ្ញាក្ខន្ធ ថាជាប្រភេទនានានៃព័ត៌មានផងដែរ ប៉ុន្តែព្រះអង្គមិនគិតគាំទ្រដល់ពិចារណា ជាប្រភេទនានាប្រកបទៅដោយសុពលភាពតែមួយគត់នៃពុទ្ធិនោះទេ។ អរិយសច្ចៈគឺជាការពិតដ៏ប្រសើរខ្ពង់ខ្ពស់។

### ២.៣.២ ចតុរារិយសច្ចៈ

អរិយសច្ចៈ ជាឫសគល់ថ្លើមប្រមាត់បេះដូងរបស់ព្រះពុទ្ធសាសនាគឺ អរិយសច្ចៈ គឺជាការដ៏ប្រសើរខ្ពង់ខ្ពស់។

១.ទុក្ខអរិយសច្ចៈ សេចក្តីទុក្ខជារបស់ពិតដែលកើតឡើងដល់មនុស្សសត្វគ្រប់រូបមិនរើសអាយុហើយមិនអាចចៀសវាងផុតបានឡើយ គឺគ្រាន់តែ អ្នកខ្លះមានទុក្ខច្រើន ហើយអ្នកខ្លះមានទុក្ខតិច។ ព្រះពុទ្ធបានទូន្មានមនុស្សឲ្យយើងយល់នូវ សេចក្តីអាក្រក់ បុណ្យបាប ហើយបង្ហាញផ្លូវឲ្យទៅរកសន្តិភាពសេចក្តីសុខ សេរីភាព និងសុភមង្គលក្នុងលោកនេះផង។

២.សមុទ្ទយអរិយសច្ចៈ តណ្ហាបង្កើតទុក្ខជារបស់ពិត។ តណ្ហាប្រែថាសេចក្តីប្រាថ្នា តម្រេក ការអន្ទះអន្ទែង។ តណ្ហាមាន៣យ៉ាងគឺៈ កាមតណ្ហា ភវតណ្ហា វិភតណ្ហា។

៣.និរោគអរិយសច្ចៈ ការផុតសេចក្តីទុក្ខ ហើយកន្លែងដែលអាចរំលត់សេចក្តីទុក្ខបានគឺ និព្វាន្ទ។ ហើយនិព្វាន្ទមាន២យ៉ាងគឺៈ

សឧបាទិសេសនិព្វាន ការរំលត់កិលេសតណ្ហាទាំងអស់នៅសល់តែខន្ធ៥គឺនិព្វាន្ទរស់។

អនុបាទិសេសនិព្វាន ការរំលត់តណ្ហា និងខន្ធ៥ គឺ និព្វាន្ទស្លាប់។

៤.មគ្គអរិយសច្ចៈ ផ្លូវប្រតិបត្តិទៅកាន់ព្រះនិព្វានជាសេចក្តីពិត។

### ២.៣.៣ សីល៥ សីល៨ និងសីល១០

ការរស់នៅរបស់មនុស្សតែងតែមានសេចក្តីសុខច្រើនជាងសត្វតិរច្ឆាននានា ព្រោះកំណើតរបស់មនុស្សគឺជាផលបុណ្យ ម្យ៉ាងទៀតមនុស្សមានបញ្ញា អាចដឹងខុសត្រូវដើម្បីកសាងគុណធម៌ឲ្យខ្លួនឯង ដូចជាចេះគោរពស្រឡាញ់មាតាបិតា មិត្តភក្តិ បងប្អូន និងមានចិត្តស្លូតបូត។ សីល៥ ជារបស់ដែលត្រូវរក្សាដូចច្បាប់រដ្ឋ ដែលពលរដ្ឋត្រូវគោរពដូចនេះដែរ។ សីល៨ ខុសសីល ៥គ្រង់ សីល៥ត្រូវបានគេអនុវត្តរាល់ថ្ងៃមិនប្រកាន់ថា ថ្ងៃណានោះទេ។ ចំពោះសីល៨ ត្រូវបានអនុវត្តនៅ ថ្ងៃ៨កើត ១៥កើត ឬ៨រោច ១៥រោច ហើយគោលការណ៍នេះមិនខុសពីសីល៥ប៉ុន្មាននោះទេ។ ហើយចំពោះសីល១០វិញ មិនខុសប្លែកពីសីល៥ និងសីល៨ប៉ុន្មាននោះទេ។

### ២.៣.៤ កុសលកម្ម និងអកុសលកម្ម

វាជាការពិតណាស់នៅ ពេលដែលយើងបានសិក្សា បានយល់ពី កុសលកម្ម និងអកុសលកម្មទាំងនោះ វានឹងធ្វើឲ្យយើងស្គាល់នូវអំពើល្អ និងអំពើអាក្រក់ ហើយយើងនិងប្រតិបត្តិតែតាមផ្លូវល្អ នឹងជៀសវាងអំពើអាក្រក់។

កុសលកម្មនោះមានក្រិតវិន័យ១០ប្រការ គឺ កាយកម្ម៣ វចីកម្ម៤ មនោកម្ម៣

**កាយកម្ម ៣**

កុសលកម្មដែលកើតមានឡើងដោយដោយកាយកម្មបី គឺៈ

បាណាតិបាតាវេរមណី

អទិន្នាទានាវេរមណី

កាមេសុមិច្ឆាចារាវេរមណី

**វចីកម្ម ៤**

កុសលកម្មដែលកើតចេញពីវចីកម្ម៤ គឺ៖

មុសាវាទាវេរមណី

បសុណាយវាចាយវេរមណី

ផរុសាយវាចាវេរមណី

សម្ផប្បលាបាវេរមណី

**មនោកម្ម ៣**

កុសលកម្មដែលកើតដោយមនោកម្មបី គឺ

អនភិជ្ឈា

អព្យាបាទ

សម្មាទិដ្ឋិ

## ២.៣.៥ ទ្រឹស្តីកម្ម និងផល

កម្មផល ជាទ្រឹស្តីធំមួយដ៏ស្មុគស្មាញណាស់ បើគេមិនខិតខំសិក្សាឲ្យយល់ទេ គេមុខជាមិនជឿលើកម្មផល ហើយប្រព្រឹត្តខុសឆ្គងរឹតតែច្រើនឡើងៗ ជាហេតុនាំឲ្យមានសេចក្តីទុក្ខដល់ខ្លួនឯងផង និងអ្នកដទៃផង។ បុគ្គលខ្លះ យល់ថា កម្មជាអំពើដែលពួកគេបានធ្វើពីជាតិមុន ដែលបានទទួលក្នុងជាតិនេះ តែត្រង់អំពើល្អឬ ផលល្អ គេអត់និយាយឬ គិតដល់ឡើយ។ ការយល់បែបនេះ ទុកជាការឃ្លៀងឃ្លាតមិនទាន់ត្រូវតាមអត្ថន័យដូចខាងក្រោម។

កម្ម គឺជាអំពើដែលគេធ្វើដោយកាយ វាចា ចិត្ត។ កម្មដែលធ្វើដោយកាយ ហៅថា កាយកម្ម កម្មធ្វើដោយវាចា ហៅថា វចីកម្ម កម្មដែលធ្វើដោយចិត្ត ហៅថា មនោកម្ម។ អំពើដែលគេអាចរាប់បញ្ចូលជាកម្មពិតប្រាដកបាន លុះត្រាតែ មានចេតនាចូលរួមផង ព្រោះព្រះពុទ្ធបានសម្តែងទុកថា ចេតនាជាតួរកម្ម។ ដូចនេះ អំពើដែលមិនមានចេតនា មិនរាប់ថាជាកម្មទេ ឬ ដោយគ្រាន់តែរាប់បញ្ចូលជាទូទៅតែប៉ុណ្ណោះ។ ហើយកម្មជារបស់កណ្តាលៗ អតីតក៏មាន ដោយអំពើល្អ ហៅថា កុសលកម្ម ឯអំពើអាក្រក់ ហៅថាអកុសលកម្ម។

## ២.៣.៦ ទ្រឹស្តីបដិច្ចសមុប្បាទធម៌

បន្ទាប់ពីការត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ព្រះពុទ្ធទ្រង់ពិចារណាបដិច្ចសមុប្បាទជាបដិលោមទៅវិញទៅមក ទ្រង់ឃើញយ៉ាងច្បាស់ថាជីវិតរបស់សត្វលោកតែងមានការជំពាក់គ្នាដោយហេតុនិងផល ព្រះពុទ្ធទ្រង់ត្រិះរិះពិចារណាថា សង្ខារទាំងឡាយកើតមានព្រោះបច្ច័យគឺអវិជ្ជា (សេចក្តីល្ងង់), វិញ្ញាណកើតមានព្រោះបច្ច័យគឺ សង្ខារ, នាមនិងរូបកើតមាន ព្រោះបច្ច័យគឺ វិញ្ញាណ, អាយតនៈកើតមាន ព្រោះបច្ច័យគឺ នាមនិងរូប, សម្ផស្សកើតមាន ព្រោះបច្ច័យគឺ អាយតនៈ, វេទនាកើតមាន ព្រោះបច្ច័យគឺ សម្ផស្ស, តណ្ហាកើតមាន ព្រោះបច្ច័យគឺ វេទនា, ភពកើតមាន ព្រោះបច្ច័យគឺតណ្ហា, សេចក្តីយំសោកខ្សឹបខ្សួល និងស្រណោះអាលោះអាល័យរមែងកើតមាន។ ព្រះពុទ្ធទ្រង់ពិចារណាបញ្ច្រាសមកវិញ ថា កាលណា អវិជ្ជា (សេចក្តីល្ងង់) រលត់ សង្ខារទាំងឡាយក៏មិនកើតមាន, សង្ខារទាំងឡាយរលត់ នាមនិងរូប ក៏មិនកើតមាន, នាមនិងរូបរលត់ វិញ្ញាណក៏មិនកើតមាន, វិញ្ញាណរលត់ អាយតនៈក៏មិនកើតមាន, អាយតនៈរលត់ សម្ផស្សក៏មិនកើតមាន សម្ផស្សរលត់ វេទនាក៏មិនកើតមាន, វេទនារលត់ តណ្ហាក៏មិនកើតមាន, តណ្ហារលត់ ភពក៏មិនកើតមានដែរ ភពមិនមានហើយ សេចក្តីយំសោកខ្សឹបខ្សួល ស្រណោះអាលោះអាល័យ ក៏មិនមានដែរ។ ទ្រង់ដឹងច្បាស់ថា ជីវិតនេះ រមែងមានការប្រទាក់គ្នាដោយហេតុ និងផល វាតែងមានការប្រាស្រ័យគ្នាទៅវិញទៅមក។

# មេរៀនទី៣ ទ្រឹស្តីពុទ្ធិរបស់លោក ចន ឡុក

## ៣.១ ជីវប្រវត្តិ ចន ឡុក

លោក John Locke កើតនៅថ្ងៃទី ២៩ ខែសីហាឆ្នាំ ១៦៣២ នៅទីក្រុង Wringtong ក្នុង Somerest នៃប្រទេសអង់គ្លេស។ ឪពុកលោក គឺជាមន្ត្រីច្បាប់មួយរូបនៅខាងក្រុមសភាប្រឆាំង។ កាលនៅតូចកុមារា ចន ឡុក បានចូលសិក្សានៅសាលា Westiminster។ ហើយនៅឆ្នាំ ១៦៥២ លោកបានចូលរៀននៅ សាលាវិហាគ្រិស្ត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់សាកលវិទ្យាល័យ Oxford ។ ក្នុងឆ្នាំ១៦៥៦ លោកបានទទួលសញ្ញាបត្របរិញ្ញាបត្រ និងទទួលសញ្ញាបត្របរិញ្ញាបត្រទោល ក្នុងឆ្នាំ១៦៥៨ ហើយលោកបានក្លាយជាគ្រូបង្រៀនទស្សនវិជ្ជា នៅសាលានោះផងដែរ។ នៅឆ្នាំ១៦៧៤ លោកបានទទួលសញ្ញាបត្រ ផ្នែកវេជ្ជសាស្ត្រ ព្រមទាំងទទួលអាជ្ញាប័ណ្ណក្នុងការប្រកបមុខរបរនេះទៀតផង។

លោក ចន ឡុក បានបោះពុម្ពស្នាដៃសៀវភៅទស្សនវិជ្ជាដ៏សំខាន់មួយ គឺ Essay Concerning Human Understanding ក្នុងឆ្នាំ១៦៩០ ដែលលោកបានព្យាយាមរៀបរៀងអស់រយៈពេលជិត២០ឆ្នាំ។ ហើយគាត់បានស្លាប់នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៧០៤ ជន្មានយុ ៧២ឆ្នាំ។ គាត់បានទទួលពានរង្វាន់ជា បិតានៃទស្សនវិជ្ជាសេរីមុនពេលមរណភាព។

## ៣.២ ទ្រឹស្តីពុទ្ធិ

លោក ចន ឡុក បានបែងចែកទ្រឹស្តីជាពីរផ្នែកសំខាន់ៗ ហើយទ្រឹស្តីពុទ្ធិទាំងពីរនេះនៅតែមានសារៈសំខាន់សម្រាប់មនុស្សជាតិទាំងមូល ជាពិសេសអ្នកសិក្សាផ្នែកទស្សនវិជ្ជា។

### ៣.២.១ ទ្រឹស្តីពិសោធន៍និយម

ពិសោធន៍និយម គឺជាទស្សនវិជ្ជាមួយបែបដែលឲ្យតម្លៃលើការពិសោធន៍ និងសញ្ញាខណ្ឌនៃញាណរបស់មនុស្សយើងម្នាក់ៗ។ ជួនកាលគេបានដាក់ឈ្មោះថា ជាប្រភព និងមូលដ្ឋាននៃចំណេះដឹង។ លោក ចន ឡុក បានបកស្រាយបញ្ហាមួយចំនួនដែលទាក់ទងនឹង ពុទ្ធិ ការយល់ដឹង គំនិត និងកម្រិតនៃពុទ្ធិ។ បន្ថែមពីនេះលោកបានបង្ហាញនូវពុទ្ធិរបស់មនុស្សតាមរយៈការពិសោធន៍។ ស្នាដៃ ពិសោធន៍ របស់លោកមួយទាក់ទងនឹងគំនិតរបស់មនុស្ស ដែលមានចំណងជើងថា ការយល់ដឹងរបស់មនុស្ស។

ចន ឡុក អះអាងថា ឥន្ទ្រិយារម្មណ៍ គឺជាប្រភពដ៏ធំបំផុតរបស់គំនិតរបស់មនុស្សទាំងឡាយ។ មានន័យថា មនុស្សយើងម្នាក់ៗ ពុំមាន គំនិត និងចំណេះពីកំណើតទេ ខួរក្បាលរបស់មនុស្សយើងពេលកើតមកគឺទទេស្អាត ប្រៀបដូចជាក្រដាសសស្អាតដែលមិនទាន់គូសវាស ឬសរសេរនៅឡើយ សូម្បីតែគំនិតបន្តិចក៏គ្មានដែរ ប៉ុន្តែបើយើងយកអ្វីមកធ្វើអន្តរកម្មជាមួយនឹងឥន្ទ្រិយទាំងឡាយរបស់មនុស្ស គេអាចទទួលបាននូវគំនិតដែលមានលក្ខណៈជាពុទ្ធិពិសោធន៍មួយ។ ដូចនេះ ឥន្ទ្រិយទាំងឡាយនេះហើយ ដែលលោក ចន ឡុក បានអះអាងថា ជាប្រភពផ្តល់នូវគំនិត និងពុទ្ធិ។ ឧទាហរណ៍ យើងអាចដឹងពី ពណ៌ ទំហំ គុណភាព រូបរាង...... បានតែក្នុងក្របខណ្ឌនៃឥន្ទ្រិយារម្មណ៍ប៉ុណ្ណោះ។ នៅពេលយើងដឹងថា វត្ថុមួយមានលក្ខណៈខុសពីវត្ថុមួយទៀត គឺជាលទ្ធផលនៃអំពើរបស់ឥន្ទ្រិយជាមួយវត្ថុនោះ។ កាលណាបាត់បង់ ឬអសកម្មនៃឥន្ទ្រិយណាមួយ នោះគំនិតរបស់មនុស្ស មិនអាចធ្វើវិចារទៅលើវត្ថុនោះបានត្រឹមត្រូវជាក់ប្រាកដឡើយ។ ឧទាហរណ៍ មនុស្សខ្វាក់ គឺមិនអាចមើលឃើញ ឬវិភាគទៅលើរូបរាងវត្ថុណាមួយបានឡើយដោយសារតែអវត្តមានចក្ខុវិញ្ញាណ។ ហើយការយល់ដឹងរបស់មនុស្សបានបង្កើតនូវគំនិតថ្មី ហើយធ្វើការអង្កេតទៅលើខួរក្បាល និងមានឥទ្ធិពលរវាងគ្នាទៅវិញទៅមក ដោយសារតែខួរក្បាលជាអ្នកប្រមូលនូវទិន្នន័យដែល

មានស្រាប់ បំបែកភាពខុសគ្នារវាងឥន្ទ្រិយារម្មណ៍ និងការយល់ដឹង។ ដូចនេះ ចន ឡុក បានបញ្ជាក់ថា មនុស្សយើងតែងមានគំនិតសាមញ្ញ គំនិតសាំញ៉ាំ។ កាលដែលយើងបានឮសំឡេង កម្តៅដែលបានប៉ះរាងកាយ ពណ៌ដែលយើងបានឃើញ ទាំងនេះគាត់ឲ្យឈ្មោះថា ជាគំនិតសាមញ្ញ ដែលឥន្ទ្រិយារម្មណ៍របស់យើងទទួលបាន។ វាជាមូលដ្ឋានគ្រឹះនៃពុទ្ធិដែលចាប់ផ្តើមពីតថភាពទាំងនេះមកឆ្លុះបញ្ចាំងលើឥន្ទ្រិយ និងញាណរបស់យើង។ ចន ឡុក បានលើកឡើងថា នៅពេលគំនិតសាមញ្ញរបស់យើង បានភ្ជាប់ជាមួយនឹងខួរក្បាល នោះខួរក្បាលរបស់យើងមានលក្ខណៈសកម្ម ហើយធ្វើការប្រមូលផ្តុំទាំងអស់។

ដោយឆ្លងកាត់ការពិសោធន៍លើពុទ្ធិ លោកបែងចែកការពិសោធន៍ជាពីរប្រភេទ គឺការពិសោធន៍ខាងក្នុង និងការពិសោធន៍ខខាងក្រៅ។ ការពិសោធន៍ខាងក្នុងគឺជាអ្វីដែលរកឃើញដោយការគិតរបស់ខួរក្បាលទាក់ទងនឹងគំនិតដើម្បីវិភាគទៅលើទម្រង់អ្វីមួយ ដែលទទួលបានតាមរយៈឥន្ទ្រីយារម្មណ៍ ក្នុងការវែងចែកលទ្ធផលឲ្យបានរូបភាពពិតប្រាកដមួយ។ ការពិសោធន៍ខាងក្រៅ គឺជាសេចក្តីត្រូវការរបស់ពុទ្ធិ ដែលឆ្លងកាត់ឥន្ទ្រិយារម្មណ៍ដូចជាការស្គាល់ក្លិនរសជាតិ រូបរាង និងការប៉ះពាល់ជាដើម ទាំងនេះគឺជាការផ្តល់ព័ត៌មានឲ្យគំនិត។

**៣.២.២ គំនិត**

**ក. គំនិតគ្មានពីកំណើត**

លោក ចន ឡុក អះអាងថា គំនិតគ្មានពីកំណើតទេ ហើយគាត់បានអះអាងថា រាល់គំនិតទាំងអស់ កើតពីការពិសោធន៍។ លោកចង់បញ្ជាក់ថា ពុទ្ធិរបស់យើងគ្មានកំណើតទេ រាល់គំនិត គឺបានមកពីឆ្លងកាត់ញាណពិសោធន៍។ លោកពោលថា បើមនុស្សមានគំនិតពីកំណើត ឬយកគំនិតពីកំណើតមកប្រើប្រាស់ ឬបង្កើតអ្វីមួយតាមគំនិតនោះ ដោយមិនបានធ្វើការឆ្លុះបញ្ចាំង ធ្វើវិចារ និងផ្ទៀងផ្ទាត់តាមញាណពិសោធន៍នោះទេ វាងាយនឹងធ្លាក់ចូលទៅក្នុងផ្លូវខុស ដែលគំនិតនិងមនុស្សផ្សេងៗទៀត មិនអាចទទួលយកបាន។ ឧទាហរណ៍ បើមនុស្សម្នាក់មានវិចារណញ្ញាណមានពុទ្ធិជ្រៅជ្រះ ហើយមានទេពកោសល្យ និងជាអ្នកនយោបាយ បានទៅបញ្ចុះបញ្ចូលបុគ្គលមិនមែនជាអ្នកនយោបាយអំពីគោលនយោបាយ ហើយបុគ្គលនោះបានប្រើគំនិតពីកំណើត នោះគាត់នឹងគិតថារឿងនោះពិតជាត្រឹមត្រូវ។ ប៉ុន្តែ បើគាត់យកគំនិតទៅពិចារណា ដោយឆ្លងកាត់ញាណពិសោធន៍ នោះប្រាកដជាគាត់ជឿថារឿងនោះអាចជារឿងកុហកបោកប្រាស់ ទៅនឹងការពិតរបស់សង្គម។

**ខ. គំនិតសាមញ្ញ**

តាមរយៈ ចន ឡុក គំនិតសាមញ្ញ គឺជាគំនិតត្រូវចាត់ទុកជាប្រភពដ៏សំខាន់នៃវត្ថុធាតុដើម ដែលបានមកពីពិភពខាងក្រៅ ដែលជួយបង្កើតចំណេះដឹងរបស់យើងឆ្លងកាត់តាមរយៈឥន្ទ្រីយារម្មណ៍។ លក្ខណៈនេះចង់បង្ហាញថាយើងយល់ដឹងពីវត្ថុមួយតាមការវិភាគ ពិចារណា ដោយឆ្លងកាត់តាមអង្គឥន្ទ្រិយទាំងប្រាំរបស់យើង។ ដូចនេះ គំនិតសាមញ្ញ គឺជាចំណេះដឹងរបស់មនុស្សដែលអាចយល់ដឹងទៅវត្ថុ ឬទៅលើអ្វីផ្សេងៗទៀត ទោះបីវាមានលក្ខណៈសាំញ៉ាំក៏ដោយ ក៏វាអាចវិភាគ វិនិច្ឆ័យទៅលើវត្ថុនោះដាច់ដោយឡែកពីគ្នាបានដែរ។

**គ. គំនិតសាំញ៉ាំ**

គំនិតសាំញ៉ាំ កើតឡើងនៅពេលដែលគំនិតសាមញ្ញទទួលបានពីឥន្ទ្រីយមកផ្តុំចូលគ្នា ពេលនោះគំនិតសាំញ៉ាំជាអ្នកគ្រប់គ្រងគំនិតសាមញ្ញ ហើយគំនិតទាំងពីរមានទំនាក់ទំនងគ្នា ដើម្បីបង្ហាញលក្ខណៈ ទ្រង់ទ្រាយ គុណភាពដែលគំនិតទាំងពីរបានទទួលពីវត្ថុ ឬបាតុភូត។ ចុងក្រោយគំនិតទាំងអស់បានបែក ឬ ញែកចេញជាលក្ខណៈផ្សេងៗចេញជាផ្នែកពេលនោះគេបង្កើតជាគំនិតមានលក្ខណៈច្បាស់លាស់។ ឧទាហរណ៍ នៅពេលយើងបានពិសារដុំស្ករហើយដឹងរសជាតិវាតាមរយៈឥន្ទ្រិយ ពេលនោះចូលទៅដល់ខួរក្បាល នេះជាគំនិតសាមញ្ញ។ នៅពេលគំនិតសាមញ្ញបានទទួលនូវរាល់គំនិតដែលឥន្ទ្រិយបានប៉ះលើដុំស្ករ វាបានប្រមូលផ្តុំគំនិតសាមញ្ញ ហើយគំនិតសាមញ្ញបានកើតឡើង។ ក្រោយមកខួរក្បាលបានទទួលគំនិតសាមញ្ញ និងគំនិតសាំញ៉ាំ និងធ្វើការញែកនូវលក្ខណៈនៃគំនិតទាំងនោះ

គឺអាចបំបែកនូវលក្ខណៈដុំស្ករ ថាមានរសជាតិផ្អែម មានពណ៌ស មានដុំតូចៗ។ ទាំងនេះ គឺជាគំនិតសាំញ៉ាំដែលបានមកពីគំនិតសាមញ្ញ។

### ៣.២.៣ កម្រិតនៃពុទ្ធិ

ពុទ្ធិអព្ភន្តរញាណជាពុទ្ធិដែលស្ថិតក្នុងគំនិតយើង អាចទទួលបានមកភ្លាមៗដោយច្បាស់លាស់ ជាក់ស្តែង ដែលភាពកំសោយរបស់មនុស្ស អាចទទួលយកបាន។ ឧទាហរណ៍ នៅពេលដែលយើងដើរហាលក្តៅ ពេលនោះពន្លឺព្រះអាទិត្យបានជះមកប៉ះយើង នោះខួរក្បាលរបស់យើងបានទទួលយកវា ធ្វើឲ្យញាណយើងបានដឹងភាពក្តៅ និងមានពន្លឺ។

#### ក. ពុទ្ធិតាមការបកស្រាយ

ពុទ្ធិតាមការបកស្រាយ កើតឡើងនៅពេលចិត្តរបស់យើងព្យាយាមស្វែងយល់ ឬមិនចង់ស្វែងយល់ ដោយចាប់យកទិន្នន័យនៃគំនិតផ្សេងទៀតដើម្បីធ្វើការបកស្រាយ។ លោក ចន ឡុក គិតថា បំណកស្រាយជាបែបបទមួយនៃញាណ ដែលនាំឲ្យខួរក្បាលឈានទៅដល់ពុទ្ធិនៃទម្រង់ផ្សេងៗទៀតរបស់តថភាព។ ដូចនេះ មនុស្សអាចយល់ដឹងបានតាមរយៈអព្ភន្តរញាណ ដែលបានបង្ហាញឲ្យឃើញនូវអ្វី ដែលក្រៅពីបង្កើតថ្មី និងលក្ខណៈពិត។

#### ខ. ឥន្ទ្រិយពុទ្ធិ

ចន ឡុក បានពោលថា វត្ថុដែលក្រៅពីខ្លួនយើង គឺពិតជាមានអត្ថិភាព បើមិនអ៊ីចឹងទេ តើយើងបានគំនិតសាមញ្ញមកពីណា? ប៉ុន្តែឥន្ទ្រិយពុទ្ធិមិនអាចផ្តល់ឲ្យយើងនូវពុទ្ធិច្បាស់លាស់ឡើយ។ យើងអាចបានដឹងតាមរយៈឥន្ទ្រិយដោយយើងអាចមើលឃើញមនុស្សម្នាក់បានយ៉ាងពិតប្រាកដ មនុស្សនោះមានអត្ថិភាព ប៉ុន្តែពេលមនុស្សចាកចេញពីយើង គឺយើងអាចភ្លេចរូបរាង និងលក្ខណៈសម្បត្តិរបស់មនុស្សនោះ។ ការសិក្សាស្វែងរកចំណេះដឹង គឺសំខាន់បំផុតការសិក្សាមិនមានទីបញ្ចប់ការចេះហ្វឹកហាត់ខ្លួនឯង។

សរុបមកយើងអាចសន្និដ្ឋានបានថា ទ្រឹះស្តីពុទ្ធិរបស់លោក ចន ឡុក គឺបានបង្ហាញនូវពុទ្ធិមួយ ដែលមានភាពច្បាស់លាស់ និងជាក់ច្បាស់ វាជាពុទ្ធិ ឬជាចំណេះដឹងរបស់មនុស្សពិតប្រាកដ ហើយមនុស្សអាចយកមកសិក្សាស្រាវជ្រាវ ឬយកមកប្រតិបត្តិតាម។

# មេរៀនទី៤ ទ្រឹស្តីពុទ្ធិរបស់លោក ហ្វ្រីឌ្រិស្ក៍ នីឆេ

## ៤.១ ជីវប្រវត្តិ នីឆេ

ហ្វ្រីដ្រិច នីតឈេ(Friedrich Nietzche, 1844- 1900) ជាកូនរបស់បព្វជិតគ្រិស្តសាសនានៅវិហារលូថេរ៉ាន (Lutheran Minister) ត្រូវបានចិញ្ចឹមបីបាច់នៅក្នុងបរិស្ថានសីលធម៌យ៉ាងហ្មត់ចត់។ នៅវ័យកុមារគាត់បានយកចិត្តទុកដាក់លើ ទស្សនវិជ្ជា ចម្រៀង និងអក្សរសាស្ត្រ។ ជានិស្សិតវ័យក្មេងម្នាក់ នីតឈេ បានសិក្សាភាសាសាស្ត្របែបបុរាណ។ អាយុ ២៤ឆ្នាំ គាត់ក្លាយជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យបាសែល(Basel)។ នៅឆ្នាំ១៨៧៩ គាត់លាលែងពីតំណែង ពីព្រោះមានជំងឺ។ គាត់សរសេរស្នាដៃទស្សនវិជ្ជារបស់ខ្លួនក្រោមលក្ខខណ្ឌរបស់ខ្លួនក្រោមលក្ខខណ្ឌវិបាកខាងហិរញ្ញវត្ថុ និងលក្ខខណ្ឌផ្ទាល់ខ្លួន។ ក្នុងដំណើរច្របូកច្របល់ពីឆ្នាំ១៨៧៨- ១៨៨៨។ នៅទូរីន (Turin)ខែមករា ឆ្នាំ១៨៨៩ គាត់មានជំងឺសរសៃប្រសាទដែលមិនអាចជាសះស្បើយ។ អំឡុងការសិក្សារបស់គាត់ នីតឈេ ស្គាល់ទស្សនវិជ្ជាទុទិដ្ឋិនិយមរបស់អាសើស្ហូផិនអាអឺ និងចម្រៀងរបស់ រីឆាត វ៉ែកណឺ (Richard Wagner, 1813- 1883)។ ផ្តើមពីស្ហូផឹនអាវអឺ គាត់មានការយល់ដឹងពីឆន្ទៈថាជាលក្ខណៈមូលដ្ឋាននៃជីវិត។ នៅក្នុងចម្រៀងរបស់វ៉ែកណឺ គាត់រកឃើញលទ្ធផលនៃឧត្តមគតិសិល្បៈ។ ឆ្នាំ១៨៨៨ ជកប្រែន(Georg Brandes)បានបង្រៀនទស្សនវិជ្ជានីតឈេ នៅសាកលវិទ្យាល័យកូពែនហាក និងនៅទសវត្ស១៨៩០ ការយកចិត្តទុកដាក់លើទស្សនវិជ្ជារបស់គាត់បានបង្កើតវិនាដកម្ម។ អ្នកនិពន្ធអឺរ៉ុបដូចជា ថូម៉ាសម៉ាន់ (Thomas Mann) អាល់ប៊ីត កាមុស (Albert Camus) ហ្សង់ ប៉ូលសាត្រ (Jean Paul Sartre) និងម៉ាទីន ហៃដឺហ្គឺ (Martin Heidegger) ជំពាក់គុណនីតឈេរបៀបខុសៗគ្នា។ នីតឈេ បានបន្សល់ទុកស្នាដៃ និងកំណត់ត្រាជាច្រើន ដែលមិនទាន់បានបោះពុម្ពផ្សាយនៅពេលគាត់មិនទាន់ស្លាប់។ បងស្រីគាត់ឈ្មោះ អេលីសាបែត ហ្វូស្ទ័រ នីតឈេ (Elisabeth Foster Neitzche) ដែលជាអ្នកប្រឆាំងជនជាតិជីហ្វ និងក្រោយមកប្រឆាំងនឹងណាស៊ី។ ស្នាដៃប្រវត្តិទស្សនវិជ្ជាបស្ចឹមប្រទេសសម័យទំនើប២ របស់គាត់បានត្រួតពិនិត្យ និងបោះពុម្ពផ្សាយក្រោយពីនីតឈេមរណភាព។ នាងក្លែងបន្លំស្នាដៃនីតឈេដោយបង្កើតជារឿងទេវកថា ដើម្បីប្រឆាំងជីហ្វនិយម(Anti- Semitism) និងណាស៊ីនិយម (Anti-Nazism) មុនគេ។ និតឆេ ក៏ដូចគៀកេហ្គាតដែរ ទាំងពីនាក់ស្អប់ការច្រៀងបួងសួងក្នុងព្រះវិហារ និងវណ្ណៈគហបតី ដែលអប់រំឱ្យពេញចិត្តដោយស្ងៀមស្ងាត់។ ទស្សនវិទូទាំងពីរត្រូវបានគេស្វែងយល់ឃើញថា ពួកគេត្រូវរស់នៅក្នុងសម័យធ្លាក់ចុះ ហើយត្រូវប្រឆាំងនឹងឥទ្ធិពលត្រួតត្រារបស់ខ្លួនទៀត។ នៅក្នុងស្នាដៃដែលគៀកេហ្គាត និងនីតឈេ គំនិតនយោបាយ នាំមកនូវ "មូលវិវដ្តនិយមបែបអភិជន" និងលោកទាំងពីរ ជាឥស្សរជនស្នូលនៅក្នុងទស្សនវិជ្ជាអត្ថិភាពនិយមទំនើប។

ស្នាដៃសំខាន់ៗរបស់នីតឈេ គឺកំណាត់សោកនាដកម្ម ផ្តើមពីស្មារតីចម្រៀង (The Birth of Tragedy from the Spirit of Music, 1872) មនុស្ស (Human) ហួសពីមនុស្ស (All-too-Human, 1878) អរុណោទ័យៈ ឆ្លុះបញ្ចាំងពីបុរេនិច្ឆ័យសីលធម៌ (The Dawn: Reflections on Moral Prejudices, 1881) វិទ្យាសាស្ត្ររីករាយ (The Gay Science, 1882) សារ៉ាធុសរ៉ា (Thus Spoke Zarathustra, 1886) ហួសពីល្អ និងអាក្រក់ (Beyond Good and Evil, 1886) និងឆ្ពោះទៅពង្សវិទ្យានៃសីលធម៌ (Toward a Genealogy of Morals, 1887) និងឆន្ទៈដើម្បីអំណាច (The will to Power) បោះពុម្ពផ្សាយក្រោយមរណភាពរបស់នីតឈេ។

## ៤.២ ទ្រឹស្តីពុទ្ធិ

យើងនឹងពិនិត្យឡើងវិញ នូវគំនិតរបស់ នីតឈេ និងពិនិត្យបញ្ញត្តិកម្ម របស់គាត់ស្តីអំពីសច្ចភាព។ យោងតាមនីតឈេ ប្រព័ន្ធអស្តិរូបវិទ្យាទាំងអស់ គឺជាការបង្ហាញឆន្ទៈដើម្បីអំណាច។ ទន្ទឹមនេះវាជាការប្រឌិត ពោលគឺការស្ថាបនាបញ្ញត្តិឡើងវិញ ដែលយើងផ្អែកលើតថភាពជាគំរូមួយដែលត្រូវចាប់បង្ខំតាមចិត្តដែលយើងបកស្រាយវាខុស

ដើម្បីស្វ័យការពារប្រភេទជីវិតមួយពិសេស។ អ្វីៗគឺគ្រាន់តែជាទស្សនវិស័យ និងរឿងប្រឌិត។ ទស្សនវិស័យ ត្រូវផ្អែកទៅលើការវាយតម្លៃ។ ហើយការវាយតម្លៃខាងសីលធម៌ គឺការបកស្រាយ ជាសញ្ញាមួយនៃសភាពសេរីវិទ្យាពិសេស។

នីតឈេ ចាត់ទុកថាមានទំនាក់ទំនងរវាងអំពើនៃការយល់ដឹង(Cognition)និងចំណាប់អារម្មណ៍(Interest) ប៉ុន្តែទន្ទឹមនឹងនេះ បញ្ហាត្រូវបង្រួមមកជាឥន្ទ្រីយធម្មជាតិមានលក្ខណៈជីវសាស្ត្រ។ បញ្ហាមួយក៏លេចឡើង៖ តើទ្រឹស្តីនីតឈេខ្លួនឯងយ៉ាងណាដែរ? តើវាជារឿងប្រឌិតឬ? ឬទ្រឹស្តីរបស់នីតឈេ អាចចៀសវាងទស្សនវិស័យនិយម និងផ្តល់ឱ្យយើងនូវសច្ចភាពអំពើពិភពលោកក្នុងន័យមួយដាច់ខាត? នីតឈេហាក់ដូចជា បដិសេធសំណួរចុងក្រោយនេះដោយខ្លាំងក្លា ពេលគឺគាត់បានទៅបញ្ហាសច្ចភាព។

ជំនឿជាក់របស់យើងលើវិទ្យាសាស្ត្រ ជាបន្តបន្ទាប់ស្ថិតលើជំនឿលើអស្តិរូបវិទ្យា ហើយយើងជាអ្នកមានពុទ្ធិ យើងជាអ្នកមិនជឿលើព្រះ និងប្រឆាំងនឹងអស្តិរូបវិទ្យា យើងក៏ជាអ្នកយកភ្លើងពីចន្ទុះដដែលដែលត្រូវដុតបំភ្លឺ ជំនឿអស់រយៈពេលមួយពាន់ឆ្នាំមកហើយ ជំនឿគ្រីស្តសាសនានេះក៏ជារបស់ប្លាតុងដែលថាអាទិទេពគឺសច្ចភាព សច្ចភាពគឺអាទិទេព។ ប៉ុន្តែចុះបើជំនឿជាក់ស្តែងនេះប្រែក្លាយជាគេមិនជឿកាន់តែច្រើនឡើង?

ប្រសិនបើអាទិភាពបច្ចុប្បន្នប្រែក្លាយជាពាក្យកុហកចំណាស់បំផុត? នីតឈេនិយាយថា ពេលដែលយើងបដិសេធជំនឿលើព្រះ បញ្ហាថ្មីមួយកើតឡើង បញ្ហាតម្លៃសច្ចភាព តម្លៃសច្ចភាពត្រូវគេហៅសាកល្បង ថាកំពុងពិភាក្សា។ ប៉ុន្តែតាមស្តង់ដាររបស់យើងយ៉ាងដូចម្តេចដែរ ប្រសិនបើមិនមែនជាសច្ចភាពខ្លួនវា?

ដូច្នេះវាហាក់ដូចជាថា នីតឈេ គាំទ្របញ្ញត្តិសច្ចភាពពីប្រពៃណី យើងយល់សច្ចភាពថាជាភាពសមស្របរវាងការអះអាងមួយ និងសភាពកិច្ចការ (អ្វីដែលភាពសមស្របនេះតម្រូវឱ្យមានជាក់ស្តែងជាបញ្ហាចម្រូងចម្រាស់មួយចាប់តាំងពីសម័យប្លាតុងមក)ជាញឹកញយនេះគេហៅថា បញ្ញត្តិសច្ចភាពសមស្រប។ ច្បាស់ណាស់នីតឈេត្រូវបដិសេធបញ្ញត្តិកម្មសច្ចភាពនេះ។ ហេតុផលផ្តល់ឱ្យ គឺមិនមែនគ្មានខ្លឹមសារទេ គ្មានហេតុការណ៍អព្យាក្រឹតដែលទ្រឹស្តីរបស់យើងសមស្រប។ ហេតុការណ៍ទាំងអស់ដែលគេបានហៅជានិច្ចកាល មានផ្ទុកដោយទ្រឹស្តីរួចស្រេចទៅហើយ។ ហេតុការណ៍សុទ្ធទាំងអស់ ឬការពណ៌នាអព្យាក្រឹត គឺគ្រាន់តែជាការបកស្រាយបិទបាំងមួយ ជាទស្សនវិស័យមួយរួមជាមួយការបកស្រាយទាំងឡាយផ្សេងទៀត។ ក្នុងន័យនេះ ទ្រឹស្តីអំពីឆន្ទៈ ដើម្បីអំណាច និងទ្រឹស្តី ការកើតឡើងច្រំដែលជានិរន្តន៍ក៏ត្រូវតែជារឿងប្រឌិត។ តើក្នុងគោលបំណងណា ដែលបែងចែកការខុសគ្នារវាងទ្រឹស្តីនិងរឿងប្រឌិត? តើមានន័យអ្វីខ្លះ ដែលគិតថាទ្រឹស្តីទាំងនេះគឺពិត ប្រសិនបើគ្មានលទ្ធភាពនៃភាពសមស្រប? ចម្លើយគឺថា ការបកស្រាយខ្លះបំរើជីវិត វាមានប្រយោជន៍សម្រាប់ជីវិត និងធានាជីវិត។ នីតឈេ មើលឃើញទ្រឹស្តីរបស់គាត់ថា ពិតនៅក្នុងន័យនេះ។ វាពិតមិនមែនក្នុងន័យថា វាបង្ហាញសច្ចភាព អំពីពិភពលោក (ចំពោះនីតឈេគ្មានសច្ចភាពបែបនេះទេ ប៉ុន្តែក្នុងន័យថាវាបំរើឱ្យជីវិត។ នេះជារបៀបដែលយើងអាចហៅថា បញ្ញត្តិសច្ចភាពបែបប្រតិបត្តិនិយម (Pragmatic Concept of Truth) និងនេះជារបៀបដែលយើងគួរយល់និយមន័យល្បីល្បាញអំពីសច្ចភាពរបស់នីតឈេថា ជាប្រភេទនៃកំហុស ដែលគ្មានប្រភេទជីវិតជាក់លាក់ណាមួយមិនអាចរស់បាន។ តម្លៃសម្រាប់ជីវិតមានសារៈសំខាន់បំផុត។ ប៉ុន្តែបញ្ញត្តិសច្ចភាពបែបប្រតិបត្តិនិយមនេះ នៅតែមិនអាចដោះស្រាយបញ្ហាបាន។ តើនីតឈេ ដឹងអំពីសច្ចភាពនេះយ៉ាងដូចម្តេច? តើប្រភេទនៃការយល់ដឹងអ្វីខ្លះដែលយើងកំពុងនិយាយ? ជាងនេះទៀត នីតឈេអះអាងថា ពិភពលោកខ្លួនវា គឺច្របូកច្របល់ ប៉ុន្តែតើគាត់មិនប្រើ បញ្ញត្តិសច្ចភាពសមស្របដែលគាត់កំពុងរិះគន់? ប្រសិនបើគាត់អះអាងថា គាត់ស្គាល់វា នោះគាត់មិនអាចបដិសេធទ្រឹស្តីសច្ចភាពបរានុម័តទាំងអស់ទន្ទឹមគ្នាបានទេ៖ ការអះអាងពិភពលោកក្នុងខ្លួនវាគឺច្របូកច្របល់ និងគ្មានសណ្តាប់ធ្នាប់ និងគ្មានគោលបំណងអាចពិត លុះត្រាតែពិភពលោកជាក់ស្តែងមានលក្ខណៈច្របូកច្របល់ នឹងគ្មានគោលបំណង។ ដូច្នេះ ការអះអាងសមស្របជាលក្ខខណ្ឌៈជាក់ស្តែង។ ដើម្បីរឹងមាំនីតឈេត្រូវពិនិត្យទស្សនវិជ្ជារបស់ខ្លួនជាទស្សនវិស័យមួយក្នុងចំណោមផ្សេងទៀតដែលអាច។ យើងឃើញថានីតឈេការពារទស្សនវិស័យនេះ ព្រោះតែភាពមានប្រយោជន៍

របស់វាសម្រាប់ជីវិត។ ប៉ុន្តែអ្វីដែលមានផលប្រយោជន៍សម្រាប់ជីវិត និងសម្រាប់នរណាម្នាក់? អ្វីដែលផលប្រយោជន៍សម្រាប់នីតឈេច្បាស់លាស់ គឺមិនមានផលប្រយោជន៍ចំពោះប្លាតុងទេ។ ប៉ុន្តែអ្វីជាលក្ខណៈវិនិច្ឆ័យដែលនិយាយថា អ្វីមួយជាការជានាជីវិត ឬបដិសេធជីវិត? តើនីតឈេនឹងមិនត្រូវនិយាយថា លក្ខណៈវិនិច្ឆ័យបរានុម័ត គឺគ្រាន់តែជារឿងប្រឌិត ឬជាទស្សនវិស័យមួយបិទបាំង។

ប្រហែលជាយើងកំពុងជំរុញប្រការនេះឱ្យឆ្ងាយពេក។ នីតឈេ មើលឃើញខ្លួនឯងនិងទស្សនវិជ្ជារបស់គាត់ថាជាបទពិសោធន៍។ គាត់ហៅខ្លួនឯងថា Don Juan23 នៅក្នុងទ្រឹស្តីពុទ្ធិ។ គាត់បានដាក់ជំនឿស៊ប់ ដែលមានឫសគល់ជ្រាលជ្រៅក្រោមការវិភាគ។ គាត់សួរអំពីតម្លៃដែលជាញឹកញយ យើងចាត់ទុកថា ពិតជាសណ្ឋាន និងមិនគួរឱ្យសង្ស័យ។ គាត់បំផ្លាញនូវអ្វីដែលយើងចាត់ទុកថាពិតខ្លួនឯង។ នីតឈេ អនុវត្តនូវបទពិសោធន៍មួយ ប្រកបដោយសច្ចភាព។ ប្រសិនបើទីបំផុតយើងរកឃើញថា បទពិសោធន៍នេះក្នុងន័យមួយចំនួន ឬក្នុងន័យបុរេសន្និតមួយទៀត នូវអ្វីដែលយើងបានសង្ស័យ ពោលគឺជាទស្សនៈអំពីសច្ចភាពដាច់ខាត នេះមិនបន្ថយតម្លៃនៃបទពិសោធន៍ទេ។ ផ្ទុយទៅវិញបទពិសោធន៍របស់នីតឈេ បានបង្រៀនយើងនូវអ្វីមួយ។

តាមវិធីជាច្រើន នីតឈេបាននិយាយរំឮកពីសូក្រាតថា៖ ជាសត្វរបោមមួយដែលមានភាពល្អប្រសើរ ពេលគាត់ធ្វើឱ្យយើងចេះការពារខ្លួនឯងបាន។

## ៤.៣ សច្ចភាពគឺអ្វីដែលមានប្រសិទ្ធភាព

ប្រតិបត្តិនិយម គឺនិកាយទស្សនវិជ្ជាខ្លាំងមួយនៅអាមេរិកនៅដើមសតវត្សទី២០ (តំណាងដោយវីលៀមជេម (William James, 1842-1910) ឆាលសាន់ដឺពៀរស៍ (Charles Sanders Peirce, 1839-1914) ជនដេវី (John Dewey, 1859-1952)។ ទាំងក្នុងការបកស្រាយប្រកបដោយភាពល្អស្មើរ និងមិនល្អប្រសើររបស់វា ទស្សនវិជ្ជានេះបានបន្តវេនក្នុងទស្សនវិជ្ជាសហសម័យ។ ហើយប្រតិបត្តិនិយម មិនគ្រាន់តែមានសារៈសំខាន់ ក្នុងវិស័យផ្សេងទៀតដូចជាកោសល្យ (សូមប្រៀបធៀបស្នាដៃរបស់ដេវីក្នុងវិស័យនេះ)។

បញ្ញត្តិសច្ចភាពផ្តោតលើប្រតិបត្តិនិយម។ ជាទូទៅ ប្រតិបត្តិនិយមអះអាងថា យោបល់ពិតពេលយោបល់នោះមានប្រសិទ្ធភាព ពេលវាមានផលប្រយោជន៍។ យើងនិយាយថា ជាទូទៅ ពីព្រោះនេះងាយមានន័យថា ឧទាហរណ៍ អ្វីដែលគេហៅថាពិត គឺអ្វីដែលមានផលប្រយោជន៍ចំពោះផលប្រយោជន៍ផ្ទាល់ខ្លួន។ ក្នុងករណីនេះ យើងផ្សារភ្ជាប់បញ្ញត្តិសច្ចភាពទៅនឹងប្រភេទបញ្ញត្តិខុសៗគ្នានៃផលប្រយោជន៍នយោបាយ និងជាក់ស្តែង។ ប៉ុន្តែការបកស្រាយប្រហែលជាកាន់តែតិចនឹងលេចឡើង បើយើងចាត់ទុកផលប្រយោជន៍ថាជាអ្វីបង្ហាញខ្លួនវាថាមានប្រសិទ្ធភាពពេលបានពិសោធន៍សាកល្បងប្រចាំថ្ងៃ និងក្នុងការពិនិត្យអង្កេតវិទ្យាសាស្ត្រ និងពិភាក្សា។

ការបកស្រាយកាន់តែមិនច្បាស់នៃបញ្ញត្តិកម្មសច្ចភាពរបស់លទ្ធិប្រតិបត្តិនិយម ត្រូវជំទាស់ដោយ ប៊ែរត្រង់រ៉ូសែល (Bertrand Russel) និងអ្នកផ្សេងទៀត ដែលជាញឹកញយពិបាកដឹងថា តើការអះអាងមួយមានប្រយោជន៍ជាងការអះអាងមួយទៀតពីសភាពកិច្ចការដូចគ្នា។ ឧទាហរណ៍ តើយើងដឹងដូចម្តេចថា កាន់តែមានផលប្រយោជន៍ដែលអះអាងថា កូឡុំប៊ីស (Columbus) ឆ្លងកាត់មហាសមុទ្រអាត្លង់ទិកក្នុងឆ្នាំ ១៩៤២ ជាការអះអាងថា គាត់បានឆ្លងកាត់វាក្នុងឆ្នាំ១៩៤១? ដើម្បីនរណា ឬដើម្បីអ្វីដែលការអះអាងមួយមានផលប្រយោជន៍ ច្រើនជាងការអះអាងផ្សេងទៀត? ហើយទ្រឹស្តីនេះក៏ត្រូវជំទាស់ថា ដើម្បីដឹងថា អ្វីមួយមានផលប្រយោជន៍ យើងត្រូវគិតថា វាពិតថា នេះជាអ្វីមួយមានប្រយោជន៍ យើងបញ្ចប់ដោយសំណួរដដែលជាថ្មីម្តងទៀត ដោយថយក្រោយគ្មានទីកំណត់។ ផ្ទុយទៅនឹងការបកស្រាយកាន់តែមិនប្រសើរនៃទស្សនៈសច្ចភាពរបស់ពួកប្រតិបត្តិនិយម (ដែលយើងក៏បានជួបប្រទះនៅក្នុងមនោគមវិជ្ជានយោបាយមួយចំនួន) ពៀរស៍ (Peirce) ក្នុងចំណោមអ្នកផ្សេងទៀតបានអះអាងថា បញ្ញត្តិសច្ចភាពត្រូវបានយល់លើមូលដ្ឋាននៃវិធី ដែលយើងរកឃើញសច្ចភាព (នោះគឺសុពលកម្ម) និងសុពលកម្ម

[23] Don Juan (Spanish), is a legendary, fictional libertine whose story has been told many times by many authors.

នេះត្រូវយល់ឯកភាពជាទូទៅថា មនុស្សមានសមត្ថភាពទាំងអស់នឹងឈានដល់ ប្រសិនបើពួកគេត្រូវបានអនុញ្ញាតឱ្យធ្វើការជាចំហ និងស្រាវជ្រាវដោយសេរីដោយមិនមានកម្រិតពេលវេលាទេនោះ។ វាមិនមែនជាហេតុការណ៍ពិសោធន៍នៃកិច្ចព្រមព្រៀងទេ ដែលជាទីសំចតនៃសច្ចភាព ប៉ុន្តែជាកិច្ចព្រមព្រៀង ដែលសម្រេចបានក្នុងចំណោមអ្នកស្រាវជ្រាវមួយគ្មានទីបញ្ចប់។ នេះជាទស្សនៈមួយស្មុគស្មាញ និងមានសារៈសំខាន់ (សូមប្រៀបធៀបបញ្ញត្តិកម្មសច្ចភាពរបស់ ហេបើ (Habermas)។ នៅក្នុងទំនាក់ទំនងនេះ វាមានភាពគ្រប់គ្រាន់នឹងកត់សម្គាល់ថា ទស្សនៈនេះផ្សារភ្ជាប់ប្រតិបត្តិនិយមជាមួយបញ្ហាស្នូលនៅក្នុងទស្សនវិជ្ជាវិទ្យាសាស្ត្រនិងនៅក្នុងការពិភាក្សាបែបទំនើប អំពីសិទ្ធិមនុស្ស និងយុត្តិកម្ម (Justification) របស់វា។

## ៤.៤ អច្ឆរិយបុគ្គល ឆន្ទៈដើម្បីអំណាច និងភាពច្រំដែលជានិរន្តរ៍

នីតឈេ មិនបានគូសបញ្ជាក់ច្រើនថា តើយើងគួរយល់ដឹងទ្រឹស្តីរបស់គាត់អំពីអច្ឆរិយបុគ្គលយ៉ាងដូចម្តេចទេ? ទាំងសេសា(Caesar) និងណាប៉ូឡេអុង (Napoleon) មិននិយាយពី អ៊ីត្លែ និងជនជាតិអារ្យាង្គ ត្រូវបានយកមកធ្វើជាឧទាហរណ៍ នៃអ្វីដែលចង់និយាយពីអច្ឆរិយបុគ្គល (Superman) ប៉ុន្តែឧទាហរណ៍បែបនេះមិនសមស្របណាស់ណាទេ។ លោក សេសា នៅរ៉ូម៉ាំង បានប្រែក្លាយជាអច្ឆរិយបុគ្គលមុនគេបង្អស់ពេលព្រលឹងរបស់ព្រះគ្រិស្តត្រូវប្រទានមកឱ្យគាត់។ ហើយមិនមែនណាប៉ូឡេអុងទេ ដែលបានធ្វើនូវឧត្តមគតិមួយ។ ចំពោះលោក នីតឈេ ណាប៉ូឡេអុង គឺគ្រាន់តែជាការសំយោគនៃវត្ថុចំឡែក អច្ឆរិយបុគ្គល។ ហើយលោក នីតឈេ មិនបានបង្ហាញសេចក្តីស្រឡាញ់ពិសេសណាមួយចំពោះជនជាតិអារ្យាង្គ ទោះបីជាជនជាតិ ជីហ្វ ឬអាល្លឺម៉ង់ក៏ដោយ។

លោកហ្គូតា (Goethe) ដែលហាក់ដូចជាជិតស្និទ្ធបំផុត នឹងឧត្តមគតិ អច្ឆរិយបុគ្គលរបស់ នីតឈេ។ លោកហ្គូតា ត្រូវជំរុញដោយតណ្ហាខ្លាំងក្លាបំផុត ប៉ុន្តែគាត់ជំនះខ្លួនឯង។ អ្វីដែលគាត់ចង់បានគឺភាពទាំងមូល។ គាត់ប្រយុទ្ធប្រឆាំងនឹងការបែងចែក វិចារណញ្ញាណ ការត្រេកត្រអាលផ្លូវភេទ មនោសញ្ចេតនា ឆន្ទៈ (ដូចគេបានបង្រៀននៅក្នុងនិកាយស្កូឡាស្ទិកដែលគួរឱ្យភ័យខ្លាចបំផុតឆ្លងតាមលោកខាន្ត ជាភាពផ្ទុយគ្នារបស់លោកហ្គូតា)។ គាត់បានអប់រំខ្លួនឯងចំពោះភាពទាំងមូល គាត់បានបង្កើតខ្លួនឯង។ យោងតាមលោកនីតឈេ ហ្គូតា ជាអ្នកអត់ឱនមិនមែនមកពីភាពខ្សោយទេ ប៉ុន្តែមកពីភាពខ្លាំងរបស់គាត់។ គាត់មិនមែនជាជនជាតិអាល្លឺម៉ង់ទេ ប៉ុន្តែជាជនជាតិអឺរ៉ុប។ ហ្គូតា ជាមនុស្សម្នាក់ដែលនិយាយយល់ស្របជាមួយជីវិត។ ស្មារតីសេរីបែបនេះមិនបដិសេធជីវិតទេ ប៉ុន្តែទទួលស្គាល់ជីវិត។ ជំនឿបែបនេះគឺមានលទ្ធភាពធំធេង។

នីតឈេកំណត់ខ្លួនឯង នូវភារកិច្ចស្ថិតស្ថេរ និងអភិវឌ្ឍន៍គោលដៅមួយ គឺជាកន្លែងដែលមានគំនិតអច្ឆរិយបុគ្គល រកឃើញ "អច្ឆរិយបុគ្គល គឺជាគោលបំណងនៃផែនដី"។ មនុស្សគឺជាអ្វីមួយដែលត្រូវជំនះ។ អ្វីដែលអាចឱ្យគេស្រឡាញ់នៅក្នុងមនុស្សគឺថា មនុស្សមានភាពវិសេស និងថយចុះតម្លៃរបស់មនុស្សមិនស្ថិតនៅលើយើងជាអ្វីទេ ប៉ុន្តែស្ថិតនៅលើខ្លួនរបស់យើងជាអ្នកកែប្រែ។ ប៉ុន្តែដើម្បីវិវត្តន៍ឆ្ពោះទៅរកអច្ឆរិយបុគ្គល យើងត្រូវបោះបង់ចោលនូវអ្វីដែលមនុស្សហួសហេតុពេក។ អ្វីដែលកំពុងខ្វះខាតគឺជាលក្ខណៈពិសេសវិជ្ជមានមួយ ប្រសិនបើយើងមិនមានបំណងប្រើប្រាស់តាមទ្រឹស្តីរបស់លោកហ្គូតា ដែលជាស្តង់ដារមួយ និងអះអាងច្បាស់លាស់មួយនៃសក្តានុភាពរបស់យើង។ វាអាចថា នីតឈេខ្លួនឯង យល់ពីភាពខ្វះខាតនេះ "មិនដែលមានអច្ឆរិយបុគ្គលនៅឡើយ" ។ នីតឈេ ក៏បានប្រកាសនូវទស្សនៈអំពី "ការកើតឡើងច្រំដែលជានិរន្តរ៍របស់វត្ថុទាំងអស់" ។ ប្រហែលជាទស្សនៈរបស់លោកនីតឈេ អ្វីៗប្រព្រឹត្តច្រំដែលក្នុងវដ្តគ្មានទីកំណត់។ យើងក៏រកឃើញទស្សនៈមុនសម័យលោកសូក្រាត គឺពួកស្តូអ៊ីក (Stoics) និងទស្សនវិជ្ជាឥណ្ឌាបុរាណ វានឹងមានសូក្រាត និងប្លាតុងម្តងទៀត មនុស្សម្នាក់នឹងលេចឡើងម្តងទៀតដែលមានមិត្តដូចគ្នា និងសត្រូវដូចគ្នា ដោយអនុវត្តសកម្មភាពដូចគ្នា និងឈឺចាប់ នឹងមានជោគវាសនាដូចគ្នា។

ទស្សនៈនេះអាចធ្វើឱ្យស្រឡាំងកាំង ប៉ុន្តែនីតឈេទទួលស្គាល់ថាជាសម្មតិកម្ម ជាបទពិសោធន៍គំនិតមួយ។ វាផ្អែកលើគំនិតថា អ្វីដែលកើតឡើងស្របជាមួយច្បាប់ធម្មជាតិដែលមិនអាចបំពានបាន។ សម្មតិកម្មវិទ្យាសាស្ត្រ

មួយ ទស្សនៈអំពីការកើតឡើងច្រំដែលជានិរន្តរ៍នៃវត្ថុទាំងអស់ស្ថិតលើបុរេសន្មតបញ្ហាមួយចំនួន។ យើងត្រូវសន្មត ថា មានចំនួនកត្តាជាក់លាក់ដែលកំណត់ដំណើរទាំងអស់ក្នុងធម្មជាតិ។ ទំនាក់ទំនងបញ្ហានេះ វាប្រព្រឹត្តឡើងថា វាមានចំនួនកំណត់នៃការរួមផ្សំ ដែលអាចមានលក្ខណៈពេញលេញឬច្រំដែលនិងមានការជាក់លាក់។

នីតឈេ យកចិត្តទុកដាក់ខ្លាំងទៅលើអត្ថន័យជាក់ស្តែងរបស់លទ្ធិ។ ហើយលទ្ធិនេះក៏គាំទ្រទស្សនៈស្តូអ៊ីកផងដែរ ដោយប្រព្រឹត្តទៅហួស ការខឹងសម្បានឹងគំនិតសងសឹក ពោលគឺប្រហែលជាវាបញ្ជាក់ថា យើងគួរសម្រុះសម្រួលខ្លួនយើងជាមួយទស្សនៈថា ភារកិច្ចរបស់ខ្លួនយើងក្នុងលោកនេះគឺគ្មានទីបញ្ចប់។ យ៉ាងហោចណាស់លទ្ធិនៃការកើតឡើងច្រំដែលរបស់វត្ថុទាំងអស់រំដោះយើងឱ្យចេញពីបញ្ញត្តិកម្មអស្តិរូបវិទ្យា ប្រពៃណី សាសនា ដែលសង្ឃឹមលើសុភមង្គល និងបរមសុខនៅអនាគត។ និរន្តរ៍ភាពនិងភាពគ្មានទីកំណត់ត្រូវរកឃើញក្នុងជីវិត។

គំនិតភាគច្រើនរបស់ នីតឈេ ផ្តោតលើបញ្ញត្តិឆន្ទៈដើម្បីអំណាច ប៉ុន្តែការណ៍នេះកម្រទទួលបានការវិភាគស៊ីជម្រៅដូចបញ្ញត្តិដែល នីតឈេ បានប្រយុទ្ធប្រឆាំង។ នីតឈេគិតថា មនុស្សជាតិមិនចង់បានការរីករាយ ឬអ្វីដែលមានប្រយោជន៍ជាចំបងនោះទេ។ ឆន្ទៈដើម្បីអំណាចក៏បង្ហាញឆន្ទៈដើម្បីពុទ្ធិ ជាសភាវគតិមួយដែលនាំយើងទៅរៀបចំការប្រឈមប្រចប់ដើម្បីធ្វើម្ចាស់ និងប្រែក្លាយបរិស្ថានរបស់យើង។ ដូច្នេះ ឆន្ទៈដើម្បីអំណាចប្រែក្លាយជាកម្លាំងអត្ថិភាពដែលមានរូបរាង។ ត្រឹមកម្រិតឆន្ទៈដើម្បីអំណាច គឺជាឆន្ទៈដើម្បីអ្វីមួយចំពោះអនាគត រូបភាពគំនិតនេះហាក់ដូចជាជម្លោះជាមួយលទ្ធិនៃការកើតឡើងច្រំដែលជានិរន្តរ៍ដែល រូបភាពទាំងនេះ ត្រូវសម្រុះសម្រួល គឺជាបញ្ហាចម្រូងចម្រាស់នៅក្នុងការស្រាវជ្រាវរបស់លោក នីតឈេ។

យោងតាមការបកស្រាយខាងលើ បានបង្ហាញឱ្យឃើញថា ទ្រឹស្តីពុទ្ធិរបស់លោក នីតឈេ ត្រូវវាបានគេយកមកសិក្សា ដើម្បីជាការឆ្លុះបញ្ចាំងនៅក្នុងសង្គម ចាប់តាំងពីសតវត្សទី១៩ រហូតដល់សម័យបច្ចុប្បន្នកាលនេះ។ លើសពីនេះទៅទៀត ទស្សនវិជ្ជារបស់លោកនីតឈេពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាបានដឹកនាំមនុស្សឱ្យស្គាល់ពីកំណើតនៃសោកនាដកម្ម ដែលផ្តើមចេញពីស្មារតី ឆន្ទៈរបស់បុគ្គល ដើម្បីស្វែងរកពុទ្ធិក្នុងការដោះស្រាយបញ្ហាដែលបុគ្គលគ្រប់រូបបានជួបប្រទះក្នុងសង្គមរស់នៅរបស់ខ្លួន។ ជាក់ស្តែងនៅក្នុងសង្គមកម្ពុជា នាសតវត្សទី២០នេះ គេសង្កេតឃើញថា សង្គមមនុស្សកំពុងប្រឈមមុខនឹងបញ្ហានៃការរស់នៅជាច្រើនដូចជា ការដណ្តើមអំណាចគ្នា អំពើពុករលួយ អសន្តិសុខសង្គម ការកេងប្រវ័ញ្ច ទំនាស់ដីធ្លី ការជួញដូរមនុស្ស គ្រឿងញៀន។ល។ កត្តាទាំងអស់នេះហើយ បានធ្វើឱ្យមនុស្សមានការភ្ញាក់រឭក យល់ដឹងបានកាន់តែច្បាស់លាស់ និងខិតខំកែប្រែ ដើម្បីបញ្ចៀសពីបញ្ហាទាំងឡាយដែលកើតមាននៅក្នុងសង្គមជាក់ស្តែង។

# ជំពូកទី៤ ទស្សនវិជ្ជា និងការអប់រំនៅក្នុងសង្គម

# មេរៀនទី១ ទស្សនវិជ្ជា និងទ្រឹស្ដីអប់រំរបស់លោក អូហ្គូស្ទីន

លោក អូហ្គូស្ទីន កើតនៅតាហ្កាស្តេ(Thagaste) ខេត្តនូមីឌៀ(Numidia) ក្នុងឆ្នាំ៣៥៤ លោកជាកូនរបស់ស្ត្រីម្នាក់កាន់សាសនាគ្រិស្តដែលមេម៉ាយក្នុងអាយុ២០ឆ្នាំចិញ្ចឹមកូនតែឯង។ អូហ្គូស្ទីន ក្រោយពីសិក្សាអក្សរសាស្ត្របានប្រកបវិជ្ជាជីវៈជាគ្រូបង្រៀនអក្សរសាស្ត្រ ហើយចូលសាសនាគ្រិស្តនៅឆ្នាំ៣៨៧ និងក្លាយជាអាចារ្យនៃសាសនានេះនៅឆ្នាំ៣៩២ បន្ទាប់មកក្លាយជាមេសាសនាគ្រិស្តនៅក្រុងហ៊ីបប៉ូន(Hippone)នៅឆ្នាំ៣៩៦។ នៅឆ្នាំ៤២៩ ទ្វីបអាហ្វ្រិកធ្លាក់ចូលក្នុងការទន្ទ្រាននៃពួកចោរព្រៃវ៉ាន់ដែល (Vandales) កាន់កាប់ទីក្រុងហ៊ីបប៉ូន (Hippone) ហើយលោក អូហ្គូស្ទីន ក៏បានស្លាប់ក្នុងពេលដែលពួកចោរព្រៃកាន់កាប់ទីក្រុងនោះ។

លោក អូហ្គូស្ទីន ជាមេដឹកនាំព្រះវិហារសាសនាគ្រិស្តដ៏ល្បីល្បាញនាសម័យកាលដែលគ្រិស្តសាសនានាំមុខគេនៅក្រុងរ៉ូមនាសតវត្សរ៍ទី៤-៥។ លោកជាទស្សនវិទូគ្រិស្តសាសនា ជាអ្នកទេវវិជ្ជា និងអ្នកតំណាងឱ្យពួកមហាថេរៈឡាតាំង។ អូហ្គូស្ទីន ជាអ្នកចេះចាំស្ទាត់នូវទស្សនវិជ្ជាក្រិចនិងរូម៉ាំង។ លោកជាបុគ្គលដែលមានជំហរនៅចន្លោះបុរាណសម័យ និងមជ្ឈិមសម័យ។ លោកបានទទួលឥទ្ធិពលពីទស្សនវិជ្ជារបស់លោក ប្លាតុង និងលោក ស៊ីសឺរ៉ុង។ តាមរយៈស្នាដៃដែលល្បីជាងគេ"បុរីអាទិទេព" (The city of God) បង្ហាញថាលោកមានទស្សនៈឈរលើមូលដ្ឋាននៃអធិធម្មជាតិរបស់គ្រិស្តសាសនា(Mystic Christianism) និងទេវវិជ្ជា(Mythology) ដែលបង្ហាញថាប្រវត្តិសាស្ត្ររបស់មនុស្សស្ថិតក្រោមឥទ្ធិពលទិព្វញាណរបស់អាទិទេពស្តីពីបាបរបស់អាដាមនិងនាងអេវ (Eve)។ លោកបង្ហាញថាការដោះស្រាយបញ្ហាមនុស្សដោយគ្មានទំនាក់ទំនងជាមួយអាទិទេពគឺជាគំរូនៃអំពើប្រឆាំងនឹងអាទិទេពដែលត្រូវជៀសវាងដាច់ខាត។ បានន័យថារាល់ការសម្រេចចិត្តរបស់មនុស្សដោយខ្លួនឯងខុសពីឆន្ទៈរបស់អាទិទេពសុទ្ធសឹងជាកំហុស។ លោក អូហ្គូស្ទីន ពោលថា "ជាមោទនភាពណាស់ដែលធ្វើឱ្យទេវតាក្លាយជាអារក្ស ហើយវាជាសេចក្តីគោរពប្រកបដោយកាយវិការសុភាពរាបសារដែលធ្វើឱ្យមនុស្សក្លាយជាទេវតា។ អូហ្គូស្ទីន ពោលថា "ឱព្រះអម្ចាស់អើយ ព្រះអង្គជាព្រះដ៏ឧត្តុង្គឧត្តម មនុស្សលោកគួរតែសរសើរ លើកតម្កើងព្រះអង្គ"!

ព្រះអង្គធ្វើឱ្យមនុស្សគោរពព្រះអង្គ បន់ស្រន់ព្រះអង្គដោយក្តីរំភើបរីករាយចេញពីខ្លួនរបស់ពួកគេផ្ទាល់។ មនុស្សមានចិត្តរឹងរូសរហូតទាល់តែយើងត្រូវតែស្ថិតនៅក្រោមការមើលខុសត្រូវពីសំណាក់ព្រះអង្គ និងត្រូវស្ថិតនៅចំពោះមុខព្រះភក្ត្រព្រះអង្គ។ លោក អូហ្គូស្ទីនមានការសោកស្តាយនៅពេលដែលលោកជឿលើការបង្រៀនរបស់សាសនាម៉ានី (Manicheism) ដែលថាលោកជាតុ ឬរូបជាតុមានលក្ខណៈទ្វិកវិទ្យាដោយរៀបរាប់ពីការតស៊ូបដិបក្ខរវាងពិភពនៃវិញ្ញាណល្អ ពិភពពន្លឺ និងពិភពនៃវិញ្ញាណអាក្រក់ ឬពិភពងងឹត។

## ១.១ ឥទ្ធិពលរបស់លោក អូហ្គូស្ទីន

ការតស៊ូរបស់អូហ្គូស្ទីនប្រឆាំងនឹងអំពើអាក្រក់ លោកជឿលើឋានានុក្រមនៃភាវៈដែលក្នុងនោះព្រះគឺជាភាវៈដ៏ខ្ពង់ខ្ពស់បំផុត និងគ្រប់ដណ្តប់លើគ្រប់ភាវៈទាំងអស់។ ជាមួយគ្នានេះគឺវាជាតំណភ្ជាប់ និងជាខ្សែសង្វាក់នៃភាវៈ ហើយភាវៈទាំងនោះមិនមានឯករាជ្យភាពទាំងស្រុងទេ។ គ្រប់ភាវៈទាំងអស់គឺល្អ ពីព្រោះភាវៈទាំងនោះមានទំនោរទៅរកអ្នកបង្កើតខ្លួន(ព្រះ) ក៏ដោយសារតែភាវៈទាំងនោះគ្មានអ្វីៗទាំងអស់។ ទោះយ៉ាងណា មនុស្សមានឆន្ទៈសេរីហើយងាកនិងមានទំនោររកព្រះតាមរយៈការប្រព្រឹត្តនៃឆន្ទៈរបស់ខ្លួន។ តាមការគិតរបស់មនុស្ស មនុស្សបដិសេធព្រះ គ្មានភាវៈឬអំពើអាក្រក់។ ដូច្នេះ ទោះបីជាភាវៈដែលបង្កើតឡើងសុទ្ធតែល្អក៏ដោយក៏អំពើអាក្រក់បានជ្រាបចូលក្នុងពិភពលោកតាមរយៈការបដិសេធរបស់មនុស្សពីអ្វីដែលល្អ សច្ចៈ និងសោភ័ណ ហើយអ្វីៗទាំងអស់គឺជាព្រះ។

ហេតុនេះ គោលបំណងចុងក្រោយនៃការអប់រំគឺការបែរព្រះភក្ត្រទៅរកព្រះ។ តាមការគិតរបស់ អូហ្គូស្ទីន លោកពោលថា ផ្លូវទៅកាន់ព្រះ គឺដើម្បីប្រមើលមើលអំពីខ្លួនឯង(ភាវៈខ្លួនឯង)។ ភាវៈនៅទីនេះគឺគេអាចរកឃើញ

ភាពផុយគ្នារបស់វា ពោលជាភារៈដែលស្គាល់អំពីអ្វីមួយ និងភារៈដែលយល់ដឹងពីអ្វីមួយ។ មនុស្សអាចដឹងពីខ្លួនឯង ប៉ុន្តែការដឹងនេះគឺត្រូវធ្វើឡើងតាមរយៈការឈ្វេងយល់ពីភាពអាថ៌កំបាំងរបស់ខ្លួនឯង ទើបមនុស្សអាចយល់ដឹងពីភាពអាថ៌កំបាំងរបស់ព្រះបាន។ ដូច្នេះដើម្បីបន្តស្វែងរកព្រះ ជាមធ្យោបាយបន្តស្វែងរកគោលដៅដំបូងនៃបញ្ហា។ ក្នុងនាមជាមនុស្សគឺយើងត្រូវតែស្វែងរកភាពអាថ៌កំបាំងរបស់មនុស្សខ្លួនឯង ចំណែកព្រះត្រូវបានគេយល់ថាជាភាពអាថ៌កំបាំងនៃអ្វីៗទាំងអស់។

ក្នុងចំណោមទំនៀមទម្លាប់ពីរដ៏អស្ចារ្យនៃការអប់រំបែបសេរីនិយម គឺសំនួនវោហាសាស្ត្រ និងទស្សនវិជ្ជា។ លោក អូហ្គូស្ទីន ជាអ្នកសំនួនវោហាសាស្ត្រខុសប្លែកគេ។ លោកជឿជាក់លើការចែករំលែកសច្ចភាពរបស់លោកដល់សិស្សជាជាងគាំទ្រឱ្យសិស្សសួរសំណួរដើម្បីស្វែងរកសេចក្តីពិត ឬសច្ចភាព។ លោក អូហ្គូស្ទីន បានប្រើប្រាស់របៀបសន្ទនាជាមួយមនុស្សដែលចេះដឹង ឬមនុស្សដែលស្គាល់ការពិត ឬសច្ចភាព មិនដូចជាទស្សនវិទូក្រិកបុរាណលោក សូក្រាតនោះឡើយដែលបានប្រើប្រាស់ការសន្ទនារបស់ខ្លួនជាមួយតែមនុស្សដែលមិនមានការយល់ដឹងអ្វីទាំងអស់។

ដូច្នេះទើប អូហ្គូស្ទីន បង្កើតទស្សនវិជ្ជាគ្រិស្តសាសនាដែលមានឥទ្ធិពលបំផុតទៅលើអ្នកប្រាជ្ញ និងអ្នកអប់រំមួយចំនួននៅលោកខាងលិច។ ជាមួយគ្នានេះដែរ ទ្រឹស្តីរបស់លោក អូហ្គូស្ទីន ក៏បានជះឥទ្ធិពលដោយផ្ទាល់ទៅលើរដ្ឋបុរសជនជាតិរ៉ូម៉ាំង អ្នកនិពន្ធ និងបព្វជិតជនជាតិអេស្ប៉ាញម្នាក់រួមទាំងអ្នកប្រាជ្ញអេស្ប៉ាញលោក អ៊ីស៊ីដ័រ សឺវីល (Isidore of Seville, 560-636)។ នៅសតវត្សទី៦ និងទី៧ លោក អូហ្គូស្ទីន បង្កើតសិល្បៈសេរី៧យ៉ាងសម្រាប់ជាមធ្យោបាយក្នុងការជួយបង្កើនដល់ការរៀនពីព្រះគម្ពីរ។ សតវត្សទី៨ អ្នកប្រាជ្ញ អង់គ្លូ សាហ្សុង(Anglo-Saxon) និងលោក អាល់គីន(Headmaster Alcuin)ប្រើប្រាស់អត្ថបទដែលជាស្នាដៃរបស់លោក អូហ្គូស្ទីន ដើម្បីយកទៅបង្រៀនគ្រិស្តសាសនិករបស់ខ្លួន។ សតវត្សទី១៨ គោលបំណងរបស់ ថូម៉ាស អាឃ្វីណាស (Thomas Aquinas) ជាទស្សនវិទូ អ៊ីតាលី និងអ្នកដឹកនាំសាសនាបានធ្វើការសំយោគទស្សនៈរបស់លោក អារីស្តូត ជាមួយជំនឿនៅក្នុងគ្រិស្តសាសនា។ គេអាចនិយាយបានថា ជាការពង្រីកការងាររបស់លោក អូហ្គូស្ទីន និងអាចជាមនុស្សគ្រិស្តសាសនារបស់អ្នកប្រាជ្ញហូឡង់ម្នាក់ឈ្មោះ អេរ៉ាស្មូស (Erasmus) ក្នុងសតវត្សទី១៥ និងទី១៩ផងដែរ។

នៅក្នុងទសវត្សរ៍ដំបូងនៃសហស្សវត្សរ៍ថ្មី លោក អូហ្គូស្ទីន យល់ថាការប្រើប្រាស់ជីវវិទ្យាខាងចិត្តសាស្ត្រ និងការនិយាយដោយផ្ទាល់ទៅកាន់អ្នកអប់រំ ដោយចាត់ទុកការសិក្សាស្រាវជ្រាវ និងការយល់ចិត្តគ្នាគឺជាលក្ខណៈសំខាន់របស់មនុស្សនៅក្នុងជីវិតជាគ្រូបង្រៀន។ មនុស្សត្រូវមានការយល់ដឹងពីចំណុចស្នូលនៃការតស៊ូដោយខ្លួនឯង និងស្ថានភាពអត្ថិភាពរបស់មនុស្ស, អំណាចនៃការអប់រំ និងអំណាចនៃការព្យាបាល។ ការសន្ទនារបស់មនុស្សអំពីបញ្ហាទាំងនេះគឺនៅតែនិយាយអំពីស្ថានភាពរបស់គ្រូបង្រៀន និងអ្នកអប់រំដដែល។

## ១.២ ការបង្រៀន

នាមជាគ្រូដែលស្ថិតនៅក្នុងបរិបទនៃការតស៊ូ និងការស្វែងរកអាថ៌កំបាំងពីខ្លួនឯង គាត់អះអាងថា ការបង្ហាត់បង្រៀនជាសកម្មភាពនៃការសម្តែងចេញសេចក្តីស្រឡាញ់។ លោកណែនាំដល់គ្រូឱ្យ "ធ្វើត្រាប់តាមអ្វីដែលល្អ ត្រូវចេះតស៊ូអត់ទ្រាំជាមួយនឹងអំពើអាក្រក់ និងត្រូវស្រឡាញ់អ្វីៗទាំងអស់"។ សេចក្តីស្រឡាញ់នេះត្រូវតែមាន ដោយលោក អូហ្គូស្ទីន បានយល់ដឹងពីភាពលំបាកនៃការសិក្សា ដូចនេះ យុវជនដែលស្ថិតក្នុងវ័យសិក្សាត្រូវតែតស៊ូឱ្យបានខ្លាំងក្លា និងខិតខំរៀនសូត្រដោយសកម្ម។

អូហ្គូស្ទីន ចាត់ទុកភាសាថាជាឧបសគ្គ ប៉ុន្តែក៏ជួយដល់ការរៀនដែរ។ គាត់និយាយថា ចិត្តគំនិត ឬវិញ្ញាណគឺលឿនជាងពាក្យពេចន៍ដែលនិយាយ នៅពេលគ្រូប្រើពាក្យពេចន៍ទាំងនោះ ហើយពេលខ្លះវាមិនបង្ហាញពីអ្វីដែលគ្រូមានបំណងបង្ហាញទាំងស្រុងទេ។ លើសពីនេះ សិស្សឮពាក្យពេចន៍ទាំងនេះតាមរបៀបផ្ទាល់ខ្លួន ហើយសិស្សមានបំណងមិនត្រឹមតែចាប់យកពាក្យទាំងនោះទេ ប៉ុន្តែមានបំណងចាប់យកការលើកដាក់សំឡេងរបស់គ្រូ និងសញ្ញាណមិនពិតផ្សេងទៀតរបស់គ្រូ។ ដូច្នេះ ជារឿយៗសិស្សតែងយល់ច្រឡំអំពីអត្ថន័យនៃពាក្យពេចន៍របស់គ្រូក៏មានដែរ។

ដូច្នេះ គ្រូត្រូវទទួលស្វាគមន៍ចំពោះសំណួររបស់សិស្ស ទោះបីពួកគេខំខានការនិយាយស្ដីរបស់ខ្លួនក៏ដោយ។ គ្រូត្រូវស្ដាប់សិស្សរបស់ខ្លួន និងនិយាយជាមួយពួកគេ សួរនាំពួកគេពីបំណង និងការយល់ដឹងរបស់ពួកគេផងដែរ។ លោក អូហ្គូស្ទីន មើលឃើញថាការអប់រំគឺជាដំណើរការនៃការបង្កើតបញ្ហា និងស្វែងរកចម្លើយតាមរយៈការសន្ទនា។ លើសពីនេះ គាត់មើលឃើញថា ការបង្រៀនគឺគ្រាន់តែជាការរៀបចំឱ្យមានការយល់ដឹងតែប៉ុណ្ណោះ ដោយលោកបានចាត់ទុកថាការបំភ្លឺរបស់គ្រូបង្រៀនគឺជាការបំភ្លឺដែលមាននៅក្នុងព្រះគ្រិស្ដ។

បន្ទាប់មក អូហ្គូស្ទីន គិតថាគ្រូបង្រៀនគួរតែសម្របសម្រួលការបង្រៀនរបស់ខ្លួនទៅតាមសិស្សរបស់ពួកគេ (Adapt their teaching to their students) ដោយក្នុងនោះលោកបានបែងចែកសិស្សជាបីប្រភេទគឺ៖

- សិស្សដែលរៀនពូកែខាងផ្នែកសិល្បៈ។
- សិស្សរៀនខ្សោយផ្នែកវោហារសាស្ត្រ (Rhetoric) ប៉ុន្តែយល់ដឹងអ្វីៗគ្រប់យ៉ាងដែលគេមិនធ្លាប់ដឹង។
- សិស្សមិនបានរៀនក៏ចេះដែរជាប្រភេទសិស្សពូកែ។

គ្រូបង្រៀនត្រូវបង្រៀនសិស្សដោយការចាប់ផ្ដើមសួរសំណួរពីអ្វីដែលសិស្សបានដឹងសិន។ នៅពេលពួកគេបង្រៀនសិស្សពូកែ ឬសិស្សមានការអប់រំខ្ពស់ អូហ្គូស្ទីន ព្រមានដល់គ្រូបង្រៀនថា កុំឱ្យនិយាយឡើងវិញដដែលៗចំពោះអ្វីដែលសិស្សទាំងនោះដឹងហើយ ប៉ុន្តែ គ្រូបង្រៀនត្រូវផ្លាស់ប្ដូរឱ្យបានលឿន និងស្របទៅនឹងសម្ភារៈឧបទេសដែលសិស្សមិនទាន់ធ្លាប់បានជួបប្រទះពីមុនមក។

នៅពេលបង្រៀនសិស្សដែលមានការអប់រំកាន់តែខ្ពស់ គ្រូត្រូវបង្ហាញពីភាពខុសគ្នារវាងការប្រើពាក្យពេចន៍ និងការយល់ដឹងរបស់ពួកគេ។ សិស្សទាំងនេះចាំបាច់ត្រូវរៀនធ្វើអំពើល្អ (Docility) និងអភិវឌ្ឍអាកប្បកិរិយាសុភាពរាបសារ ទោះបីមានកំហុសបន្តិចបន្តួចក្ដី ក៏មិនមានការរិះគន់ច្រើនពីមនុស្សដទៃដែរ។ ចំពោះបញ្ហាសិស្សដែលមិនទទួលបានការអប់រំវិញ អូហ្គូស្ទីន លើកទឹកចិត្តគ្រូឱ្យមានភាពសាមញ្ញ, ច្បាស់លាស់, មានទំនាក់ទំនងជាមួយសិស្សដោយផ្ទាល់ និងមានភាពអត់ធ្មត់។ ការបង្រៀនសិស្សខ្សោយទាមទារឱ្យគ្រូប្រើពាក្យដដែលៗឱ្យបានច្រើនដង ប៉ុន្តែអាចនាំឱ្យសិស្សធុញទ្រាន់ដែរ ប៉ុន្តែ អូហ្គូស្ទីន គិតថាភាពធុញទ្រាន់នឹងត្រូវបានយកឈ្នះដោយការអាណិតអាសូររបស់គ្រូដោយផ្អែកលើអ្វីដែលសិស្សបាននិយាយ និងអ្វីសិស្សបានឮក្នុងពេលវេលានៃកិច្ចសន្ទនាជាមួយគ្រូនោះ។ បែបបទនៃការអាណិតអាសូរនេះបង្កើតឱ្យមានសេចក្ដីអំណរ និងភាពសប្បាយរីករាយទាំងគ្រូទាំងសិស្ស។

ការបង្រៀនសិស្សទាំងបីប្រភេទនេះ គាត់ហៅថារបៀបកម្រិត (Restrained style)។ របៀបនេះទាមទារឱ្យគ្រូកុំផ្ទុកសិស្សលើសចំនួន និងប្រើសម្ភារៈច្រើនពេក ប៉ុន្តែត្រូវផ្អែកលើប្រធានបទតែមួយក្នុងពេលតែមួយ ដើម្បីបង្ហាញដល់សិស្សនូវអ្វីដែលជាអាថ៌កំបាំង។ ការដោះស្រាយបញ្ហាលំបាក និងធ្វើការប៉ាន់ស្មានសំណួរផ្សេងទៀតដែលអាចកើតមានឡើង។ អូហ្គូស្ទីន ទាមទារឱ្យគ្រូប្រើរបៀបចម្រុះដោយប្រើឃ្លា និងចង្វាក់ភ្លេងឱ្យបានល្អិតល្អន់ ប៉ុន្តែ ត្រូវមានតុល្យភាពជាមួយឃ្លាឃ្លោង និងចង្វាក់ភ្លេងទាំងនោះ។ ការធ្វើដូចនេះ លោកមានគោលបំណងធ្វើឱ្យសិស្សរីករាយ និងទាក់ទាញសិស្សឱ្យមានចិត្តរំភើប សប្បាយរីករាយក្នុងការប្រើប្រាស់សម្ភារៈល្អៗទាំងនោះទៀត។ គ្រូគួរតែអាចនិយាយបានទៅតាមលំនាំដ៏អស្ចារ្យក្នុងគោលបំណងផ្លាស់ប្ដូរ និងជំរុញសិស្សធ្វើសកម្មភាព។ អ្វីដែលធ្វើឱ្យមានរបៀបប្លែកអស្ចារ្យមិនមែនជាការនិយាយស្ដីនោះឡើយ ប៉ុន្តែតាមការពិតវាកើតចេញពីបេះដូង អារម្មណ៍ ឬសញ្ចេតនា និងចំណង់ចំណូលចិត្ត។

ដូច្នេះ ត្រូវជំរុញសិស្សឱ្យស្ដាប់បង្គាប់ព្រះ និងធ្វើខ្លួនជាភារៈដែលព្រះបង្កើតឡើងឱ្យបានពេញលេញ ដើម្បីឈានទៅដល់សុភមង្គលដែលព្រះប្រគល់ឱ្យ ឬព្រះចង់ប្រទានឱ្យ។ ដើម្បីឆ្លើយតបជាមួយសេចក្ដីសង្ឃឹមនេះគឺត្រូវធ្វើឱ្យស្របទាំងស្រុងជាមួយសម្រង់ដ៏ល្បីល្បាញបំផុតអំពីជីវប្រវត្តិរបស់លោកអូហ្គូស្ទីន៕

# មេរៀនទី២ ទស្សនវិជ្ជា និងទ្រឹស្តីអប់រំរបស់លោក ឌេស៊ីឌេរីអ៊ូស អេរ៉ាស្មូស

ជ័យជម្នះរបស់ពួកវិទ្យាសាស្ត្រអាចកើតឡើងបានដោយសារពួកទ្រឹស្តីមនុស្សនិយមនៅសម័យមុនភពដែលមានដូចជាលោក រីចលីន (Reuchlin) លោក អេរ៉ាស្មូស ជាគ្រីស្តបរិស័ទដែលគោរព និងទទួលយកជំនឿលើព្រះជាម្ចាស់ជាលក្ខខណ្ឌចម្បងនៅក្នុងជីវិត។ សាកលវិទ្យាល័យបានក្លាយជាមជ្ឈមណ្ឌលនយោបាយ និងសង្គមដែលជាភ្នាក់ងារកំណែទម្រង់សាសនាដ៏សកម្ម។ ពួកទ្រឹស្តីមនុស្សនិយមយកចិត្តទុកដាក់ខ្លាំងលើភាពជាក់លាក់ និងការអប់រំផ្លូវការ។ ពួកគេគោរពសិទ្ធិអំណាចរបស់ក្រិក និងឡាតាំងស្ទើរតែដល់កម្រិតដូចពួកទេវវិទូគោរពបូជាស្នាដៃរបស់លោកឪពុកនៃសាសនាគ្រីស្ត។ ទន្ទឹមនឹងនេះដែរ ការអប់រំផ្លូវការកាន់តែមានលក្ខណៈសកល។ អេរ៉ាស្មូស ជាអ្នកធ្វើដំណើរទៅប្រទេសជាច្រើនហើយលោកនិយាយថាគាត់ជាពលរដ្ឋអឺរ៉ុបមិនមែនជាតិសាសន៍ណាមួយទេ។ គាត់បង្រៀននៅខេមប្រីជ(Cambridge)ហើយរស់នៅប៉ារីស, វេនីស(Venice) និងបាហ្សល(Basel)។ អេរ៉ាស្មូស ជឿជាក់ថាមនុស្សគឺជាមជ្ឈមណ្ឌលនៃសាកលលោក។ លោកមានជំនឿមុតមាំលើព្រះ ប៉ុន្តែស្អប់ជំនឿដែលគ្មានមូលដ្ឋាន(អបិយជំនឿ) គាត់ប្រឆាំងឥតឈប់ឈរជាមួយពួកទេវវិទូ។

អេរ៉ាស្មូស (១៤៦៦/៩-១៥៣៦) កើតនៅហូឡង់ (Holland) ជាខេត្តមួយរបស់ចក្រភពរ៉ូម៉ាំងនៃប្រជាជាតិអាល្លឺម៉ង់។ ប្រទេសនេះមានភាសាជាតិពីរ អាល្លឺម៉ង់ និងបារាំង។ អេរ៉ាស្មូស ជាជនជាតិអាល្លឺម៉ង់ ជាញឹកញាប់គាត់និយាយដោយមោទនភាពថា "អាល្លឺម៉ង់របស់ខ្ញុំ" ប៉ុន្តែការកែទម្រង់ធ្វើឱ្យគាត់ខ្ពើមរអើម។ គាត់សារភាពនៅក្នុងលិខិតមួយទៅកាន់លោក ឌូក ចូដ្ឋ (Duke George) ថា "ខ្ញុំមិនស្គាល់ភាសាអាល្លឺម៉ង់ទេ"។

លោក អេរ៉ាស្មូស បន្តការសិក្សានៅក្នុងបណ្តាប្រទេសនិយាយភាសាឡាតាំង និងអាល្លឺម៉ង់។ ប៉ុន្តែ គាត់បានរកឃើញមិត្តភាពជិតស្និទ្ធបំផុតនៅប្រទេសអង់គ្លេស។ ប្រទេសដែលគាត់ចង់បានបំផុតនោះ គឺប្រទេសអ៊ីតាលី។ អេរ៉ាស្មូស ក្លាយជាអ្នកបួសមិនមែនចេញពីការសម្រេចចិត្តរបស់គាត់ទេ។ ដូច្នេះ ព្រះវិហារមិនអាចក្លាយជាទីលំនៅឬកន្លែងពិតប្រាកដរបស់គាត់ទេ។ លោកមិននៅផ្ទះក្នុងប្រទេស ឬក្នុងគ្រួសារមួយ ឬក្នុងសណ្តាប់ធ្នាប់របស់សាសនាហើយក៏មិនមែននៅក្នុងព្រះវិហារដែរ។ គាត់នៅផ្ទះជាពិសេសក្នុងពិភពវិញ្ញាណនៃអក្សរដែលមានដើមកំណើតនៅប្រទេសក្រិក រ៉ូម និងប៉ាឡេស្ទីន។

ភាគច្រើននៃចរិតលក្ខណៈ និងគំនិតរបស់លោក អេរ៉ាស្មូស ឆ្លុះបញ្ចាំងនៅក្នុងទ្រឹស្តីនៃការអប់រំរបស់គាត់។ ទស្សនៈវិស័យអប់រំគឺការអប់រំរបស់សម្តេចព្រះគ្រីស្ត និងតាមវិធីសាស្ត្រនៃការបង្រៀនត្រឹមត្រូវ។ លោក អេរ៉ាស្មូស យល់មិនដូច ម៉ាឃីអាវែល្លី (Machiavelli) នោះទេ លោកជឿថាព្រះអង្គម្ចាស់ (ស្តេច) គួរតែជាគំរូខាងសីលធម៌សម្រាប់ប្រជានុរាស្ត្របស់គាត់ហើយគាត់គួរតែបណ្តុះសិល្បៈសន្តិភាពជាជាងសង្គ្រាម។ លោកក៏ដូចជាពួកមនុស្សនិយមដទៃទៀត ជឿថាគេគួរអប់រំស្ត្រីឱ្យទទួលបានពុទ្ធិពិតប្រាកដ និងចំណងទំនាក់ទំនងគ្រួសាររឹងមាំ។ តាមវិធីសាស្ត្របង្រៀនត្រឹមត្រូវលោក អេរ៉ាស្មូស ជំរុញឱ្យមានប្រព័ន្ធបណ្តុះបណ្តាលគ្រូ។ ប្រសិនបើគ្មានគ្រូបង្រៀនគ្រប់គ្រាន់ តើអរិយធម៌អាចរីកចម្រើនឡើងយ៉ាងដូចម្តេច?

## ២.១ គោលបំណងនៃការអប់រំ

ក្នុងប្រព័ន្ធអប់រំរបស់ អេរ៉ាស្មូស លើកឡើងថាគោលបំណងនៃការអប់រំគឺការវិនិច្ឆ័យដោយឯករាជ្យ។ ការអប់រំជាការរួមបញ្ចូលគ្នានូវភាពស្មោះត្រង់ និងចំណេះដឹងពិតប្រាកដ។ យើងមិនត្រូវពឹងផ្អែកលើអ្វីដែលបុរាណៗនោះទេផ្ទុយទៅវិញយើងត្រូវរៀនឈរដោយខ្លួនឯង និងដោះស្រាយបញ្ហាដោយភាពឆ្លាតវៃរបស់យើង។ អេរ៉ាស្មូស ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការរៀនតាមបែបលើកទឹកចិត្ត។ ប្រសិនបើគ្រូប្រើកម្លាំង និងការបង្ខិតបង្ខំ នោះមានន័យថាគាត់លើកទឹកចិត្តសិស្សរបស់គាត់តាមរបៀបអវិជ្ជមាន។ គ្រូក្លាយជាអ្នកមានឥទ្ធិពលវិជ្ជមាន ប្រសិនបើគាត់ធ្វើជាគំរូ

ដល់សិស្ស។ ពិតណាស់វាមានភាពងាយស្រួលមែនចំពោះការប្រើដំបងធ្វើជាឧបករណ៍នៃវិន័យ ប៉ុន្តែទោះយ៉ាងណា ត្រូវប្រើការបំផុសគំនិតសីលធម៌គឺសំខាន់ជាង ដូច្នេះនាំឱ្យសិស្សចង់រៀន។ តើសិស្សអាចធ្វើដំណើរឆ្ពោះទៅមុខបាន យ៉ាងដូចម្តេច? ទីមួយ ជំរុញសមត្ថភាពនៅខាងក្នុងរបស់ពួកគេ(សិស្ស)ដែលនៅក្នុងនេះធម្មជាតិគឺជាមគ្គុទេសក៍។ ទីពីរ ការបង្រៀនត្រូវតែមានសង្គតិភាពដែលត្រូវបានកំណត់យ៉ាងល្អបំផុតដោយសេចក្តីស្រឡាញ់របស់គ្រូចំពោះសិស្ស។ ទីបី សិស្សត្រូវអនុវត្តអ្វីដែលខ្លួនបានរៀន។ បើតាមលោក អេរ៉ាស្មូស គតិបណ្ឌិតមានន័យថាចំណេះដឹងដែលបានអនុវត្ត។ លោកយល់ថាគោលបំណងសំខាន់នៃការអប់រំគឺដឹកនាំមនុស្សទៅរកចំណេះដឹង ភាពស្មោះត្រង់ និងការវិនិច្ឆ័យឯករាជ្យ។ ការបណ្តុះបណ្តាល ឬការអប់រំត្រឹមត្រូវ គឺបាននាំមនុស្សឆ្ពោះទៅរកសុភមង្គល។ ការអប់រំត្រឹមត្រូវគឺជាស្ថានភាពនៃគតិបណ្ឌិត។

## ២.២ គ្រូបង្រៀន និងវិធីសាស្ត្របង្រៀន

យើងរកឃើញអាកប្បកិរិយាស្រដៀងគ្នានៅក្នុងគរុកោសល្យរបស់ពួកមនុស្សនិយមដែលនៅទីនោះវាកើតចេញពីគំរូរបស់លោក គ្វីនទីល្លីន(Quintilian), ចំពោះលោក អេរ៉ាស្មូស ក្នុងការប្រយុទ្ធប្រឆាំងការរំលោភបំពានកុមារគឺជាសង្គ្រាមតែមួយគត់ដែលគាត់រីករាយក្នុងការប្រយុទ្ធ។ លោកបានសង្កេតឃើញថា គ្រូដែលអន់គឺស្វែងរកការពឹងផ្អែកទាំងស្រុងលើការបំភិតបំភ័យ និងការដាក់ទណ្ឌកម្មសិស្សដើម្បីជំរុញឱ្យធ្វើការ។ ដើម្បីបំភ័យថ្នាក់រៀនជារឿងងាយស្រួលជាងការបង្រៀនក្មេងម្នាក់ឱ្យបានត្រឹមត្រូវ។ គ្រូបង្រៀនល្អចេះគោរពភាពខុសគ្នារបស់កុមារម្នាក់ៗ។ លោក អេរ៉ាស្មូស ទាមទារម្តងហើយម្តងទៀតឱ្យការអប់រំចាប់ផ្តើមពីទារកមក ទោះបីមិនច្បាស់ថាតើគាត់ចង់ធ្វើវាយ៉ាងដូចម្តេច? ចំណាប់អារម្មណ៍របស់គាត់សម្រាប់ការលេងបង្ហាញពីការគោរពលក្ខខណ្ឌជាក់លាក់របស់ទារក។ ដើម្បីឱ្យការអប់រំមិនប្រើដំបង គ្រូបង្រៀនត្រូវយល់ពីលក្ខណៈរបស់កុមារ និងច្បាប់ដែលបានចែងនៅក្នុងដំណើរការអប់រំ។ ម៉្យាងវិញទៀត គ្រូបង្រៀនត្រូវមានការយល់ដឹងពីផ្លូវចិត្ត និងវិធីសាស្ត្របង្រៀនដែលអាចធ្វើការបាន។ នៅក្នុងការអង្កេតពីតម្រូវការចាំបាច់នៃការអប់រំ លោក អេរ៉ាស្មូស ភាគច្រើនបានដើរតាមគំនិតរបស់ អារីស្តូត (Aristotle), លោក ភ្លូថាវ (Plutarch) និងលោក គ្វីនទីល្លីន (Quintilian)។ ទោះបីជាយ៉ាងណា ឥទ្ធិពលដែលទទួលបានពីមនុស្សទាំងនេះគឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបទពិសោធផ្ទាល់របស់គាត់។ លោកសង្កេតឃើញថាមានលក្ខខណ្ឌបីដែលកំណត់វឌ្ឍនភាពបុគ្គលគឺ ធម្មជាតិ(Nature) ការបណ្តុះបណ្តាល(Training) និងការអនុវត្ត(Practice)។ តាមរយៈធម្មជាតិ មានន័យថាផ្នែកខ្លះនៃសមត្ថភាពខាងក្នុងត្រូវទទួលការបណ្តុះបណ្តាល ហើយនៅផ្នែកខ្លះទៀតដែលមានពីកំណើតឆ្ពោះទៅរកភាពល្អប្រសើរ។ តាមរយៈការបណ្តុះបណ្តាល ចង់មានន័យថាជាការអនុវត្តបំណិននៃការបង្រៀននិងការណែនាំ។ តាមរយៈការអនុវត្ត ជាការធ្វើចលនាដោយសេរីដែលជាផ្នែកផ្សេងៗនៃសកម្មភាពផ្ទាល់របស់យើងដែលបានមកពីធម្មជាតិ និងលើកកម្ពស់ដោយការបណ្តុះបណ្តាល។ ធម្មជាតិដែលគ្មានការបណ្តុះបណ្តាលបំណិនគឺមិនមានភាពល្អឥតខ្ចោះទេ ហើយការអនុវត្តដោយគ្មានវិធីសាស្ត្រដែលផ្តល់ឱ្យពីការបណ្តុះបណ្តាល នោះគឺដឹកនាំទៅរកការភាន់ច្រលំ។ ដោយសារលក្ខខណ្ឌទាំងបីនេះហើយដែលលោកបានប្រាប់ទៅអ្នកអប់រំថាត្រូវចាប់អារម្មណ៍ទាំងការអភិវឌ្ឍរាងកាយ និងការអភិវឌ្ឍបញ្ញារបស់កុមារ។

## ២.៣ ការលើកទឹកចិត្តសម្រាប់ការអភិវឌ្ឍសក្តានុពល

លោក អេរ៉ាស្មូស មិនបានសូវយកចិត្តទុកដាក់ទៅលើផ្នែកនៃការអប់រំរាងកាយដូចជាកីឡា និងការលូតលាស់ផ្នែកឥរិយាបថខាងក្រៅទេ។ មិនមែនគាត់មិនដឹងអំពីតម្រូវការអនាម័យទេ។ ភាពយល់ដឹងពីរាងកាយរបស់គាត់បានទាក់ទាញឱ្យគាត់ចេះថែរក្សាសុខភាព។ លោកបានចាប់អារម្មណ៍នឹងការស្វែងរកគំនិតជាងការធ្វើលំហាត់ប្រាណនៃរាងកាយ។ លើសពីនេះទៀត លោកគឺជាអ្នកអប់រំដំបូងគេដែលតំណាងឱ្យស្មារតីរបស់វណ្ណៈកណ្តាល។ ធម្មជាតិរបស់មាតាបានបង្កើតមនុស្សមានចរិតជាក់លាក់ដែលគ្រូត្រូវតែដឹងដើម្បីប្រើប្រាស់វា។ មនុស្សមានមនោគតិ និងការជំរុញពីកំណើត ឬសក្តានុពលផ្សេងទៀតដូចជា ការពារខ្លួនឯង ការត្រាប់តាម មហិច្ឆតា និងចំណង់។ ដើម្បីទទួល

បានគុណសម្បត្តិទាំងនេះ គ្រូអាចជំរុញឱ្យកុមារស្ម័គ្រចិត្តទទួលបានបទពិសោធ ហើយថែមទាំងរីករាយនឹងភាពលំបាកជាច្រើនដែលទាក់ទងនឹងដំណើរការអប់រំ។ ដូច្នេះ ការអប់រំល្អកើតឡើងពីការលើកទឹកចិត្ត, សមត្ថភាពក្នុងការដាក់បញ្ចូលគ្នារវាងការលើកទឹកចិត្តនិងវិន័យ, ដាក់បញ្ចូលគ្នានូវភាពអត់ធ្មត់ ការយល់ដឹងឱ្យបានត្រឹមត្រូវជាមួយនឹងភាពជាក់ស្តែងគឺជាលក្ខណៈវិនិច្ឆ័យរបស់គ្រូល្អ។ គាត់យល់ថាការលេងសម្រាប់កុមារមិនត្រឹមតែជាការសម្រាកលម្ហែ ឬភាពរីករាយប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាផ្នែកមួយនៃជីវិត និងការរៀនរបស់ពួកគេដែរ។ លោក អេរ៉ាស្មូស យល់ថាសម្រាប់ការអប់រំជាជំនួយដល់គំនិតនៅក្នុងការព្យាយាមឈ្វេងយល់ពីការពិតហើយនៅពីក្រោយពាក្យនោះគឺគេត្រូវតែប្រើប្រាស់ឥន្ទ្រីយ៍៕

# មេរៀនទី៣ ទស្សនវិជ្ជា និងទ្រឹស្ដីអប់រំរបស់លោក ចន អេមូស ខូមេនៀស

លោក ចន អេមូស ខូមេនៀស គឺជាអ្នកអប់រំសម័យទំនើបសមនឹងទទួលបានឋានៈខ្ពស់ក្នុងចំណោមអ្នកធ្វើកំណែទម្រង់ការអប់រំគ្រប់ជំនាន់ដោយសារគាត់ជាទស្សនវិទូ អ្នកអប់រំ និងជាអ្នកនិពន្ធសៀវភៅសិក្សា។ គំនិតរបស់លោកមានឥទ្ធិពលទៅលើជីវិតរស់នៅជាក់ស្ដែង និងលក្ខខណ្ឌសង្គមនយោបាយនៅសម័យរបស់គាត់ ដូច្នេះលោកទទួលបានកិត្តិនាម និងកេរ្តិ៍ឈ្មោះមិនត្រឹមតែនៅក្នុងទឹកដីកំណើតរបស់លោកប៉ុណ្ណោះនោះទេ ប៉ុន្តែនៅក្នុងរដ្ឋដទៃទៀតផងដែរ។

លោកកើតនៅឆ្នាំ១៥៩២ ក្នុងភូមិមួយឈ្មោះម៉ូរ៉ាវៀន(Moravian) ក្បែរ យូហ័រស្គីប្រូដ (Uhersky Brod)។ ឪពុកលោកកាន់និកាយសាសនាឈ្មោះថា "The Unity of Brethren" ប៉ុន្តែ ជាទូទៅគេស្គាល់ថា "The Moravian Brethren"។ ឪពុកម្ដាយរបស់ខូមេនៀសបានស្លាប់នៅពេលគាត់អាយុ១២ឆ្នាំ។ នៅពេលគាត់មានអាយុ១៦ឆ្នាំ លោកបានក្លាយជាបេក្ខជនសម្រាប់តំណែងរដ្ឋមន្ត្រី ហើយព្រះវិហារបញ្ជូនលោកទៅសាលាវេយ្យាករណ៍នៅព្រេរ៉ូវ (Prerov)ជាទីកន្លែងដែលបង្ហាញថាលោកជាមនុស្សមិនត្រឹមតែអ្នកសិក្សាឧស្សាហ៍ព្យាយាម និងទទួលបានជោគជ័យប៉ុណ្ណោះទេ ប៉ុន្តែគួរឱ្យទាក់ទាញណាស់ក្នុងចរិតរបស់គាត់ដែលធ្វើឱ្យលោក ប៊ីស្សប ឡាណេស្គី(Bishop Lanecky)ជានាយកសាលាបានដាក់ឈ្មោះបន្ថែមឱ្យគាត់ថា អេមូស(ការស្រឡាញ់)។ នៅពេលអាយុ១៦ឆ្នាំ លោកបានមើលឃើញពីកំហុសដ៏ធ្ងន់ធ្ងរក្នុងការបង្រៀនភាសាឡាតាំងដល់កុមារតូចៗ។ លោកទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងដោយចលនាអប់រំថ្មីនៅសម័យនោះ។ គាត់ជឿថាការអប់រំគឺជាមធ្យោបាយដ៏ប្រសើរបំផុតនៃការរីកចម្រើនរបស់មនុស្ស ហើយធ្វើការអស់មួយជីវិតដើម្បីបញ្ជូនគំនិតទៅឱ្យមនុស្សទាំងអស់។ បន្ទាប់ពីទទួលការអប់រំជាន់ខ្ពស់នៅបណ្ឌិត្យសភាកាល់វីន(Calvinist Academy)នៃរដ្ឋហឺបិន(Herborn)និងមួយឆ្នាំនៅហៃដេលប៊ែហ្គ (Heidelberg)ព្រមទាំងជាគ្រូនៅទីក្រុងព្រេរ៉ូវ(Prerov) លោកចំណាយពេលពីរឆ្នាំទៀតជាជំនួយការរបស់លោក ប៊ីស្សប ឡាណេស្គី(Bishop Lanecky) បន្ទាប់មករៀបការ ហើយបានទៅទទួលបន្ទុកនៅភាគខាងជើងម៉ូរ៉ាវៀន (Northern Moravia)។ ជាអ្នកធ្វើដំណើរដែលមិនចេះនឿយហត់ លោកបានធ្វើដំណើរទៅប្រទេសអង់គ្លេស និងស៊ុយអែត។ ជាច្រើនឆ្នាំក្រោយមក លោកចំណាយពេលនៅប្រទេសប៉ូឡូញជាទីកន្លែងដែលគាត់ក្លាយជានាយកសាលាកាយសម្ពន្ធ(Gymnasium)។ នៅឆ្នាំចុងក្រោយនៃជីវិតរបស់គាត់, ខូមេនៀស ចំណាយពេលនៅអាំស្ទ័រដាម (Amsterdam)ជាទីកន្លែងដែលគាត់សកម្មនៅក្នុងការងារនិកាយសាសនារបស់គាត់។

លោក ខូមេនៀស មានការអាណិតអាសូរយ៉ាងជ្រាលជ្រៅចំពោះមនុស្សសាមញ្ញ។ គាត់ជាជើងឯកដ៏អស្ចារ្យនៃការអប់រំរបស់វណ្ណៈទាប។ លោកនិយាយថា "ការអប់រំដែលខ្ញុំស្នើរួមបញ្ចូលទាំងអស់សមស្របសម្រាប់មនុស្ស ហើយក្នុងនោះមនុស្សទាំងអស់ដែលកើតមកលើលោកនេះគួរតែចេះចែករំលែកគ្នា។ តាមដែលអាចធ្វើទៅបាន មនុស្សគួរទទួលបានការអប់រំជាមួយគ្នាដែលពួកគេអាចជំរុញ និងចំណង់លើអ្វីមួយផ្សេងទៀត"។ គាត់ជឿថាកុមារទាំងអស់កើតមកក្លាយជាមនុស្ស ដូច្នេះពួកគេត្រូវតែទទួលបានការអប់រំ។ គាត់បានប្រឆាំងនឹងអត្ថិភាពនៃសាលាឡាតាំងដែលដាក់ដាច់ដោយឡែកសម្រាប់ការបណ្ដុះបណ្ដាលវណ្ណៈតែអភិជន ហើយគាត់ទាមទារឱ្យសាលាឡាតាំងនោះគួរតែបើកចំហសម្រាប់មនុស្សគ្រប់គ្នា។ លោកបានប្រកាន់ខ្ជាប់នូវគំរិយាបថប្រជាធិបតេយ្យ និងគាំទ្រការអប់រំជាសកលរបស់ពលរដ្ឋលើមូលដ្ឋានសាសនា។

លោក ខូមេនៀស ជាអ្នកសុទិដ្ឋិនិយម ខណៈពេលដែលទេវវិទូភាគច្រើននៅសម័យរបស់គាត់សង្កត់ធ្ងន់លើភាពអាក្រក់ និងភាពវង្វេងស្មារតីរបស់មនុស្ស, លោកសង្កត់ធ្ងន់ទៅលើភាពអស្ចារ្យរបស់មនុស្ស។ ពិតប្រាកដណាស់ ជីវិតគឺជាសមរភូមិរវាងភាពល្អ និងអាក្រក់ ប៉ុន្តែគាត់បានដឹងច្បាស់ថាភាពល្អនឹងទទួលបានជ័យជម្នះ។

ក្នុងនាមជាអ្នកសេរីនិយម គាត់មិនបានទទួលស្គាល់ពួកអភិជនាធិបតេយ្យទេ។ ឯកសិទ្ធិក្នុងថ្នាក់រៀនមិនមានកន្លែងក្នុងគម្រោងគំនិតនៃការអប់រំត្រឹមត្រូវទេ។ គាត់ស្រមៃពីសាធារណរដ្ឋគ្រិស្តសាសនាដែលរឿងទាំងអស់ត្រូវបានរួបរួមគ្នាតាមរយៈចំណេះដឹង និងជំនឿ។ អ្នករិះគន់ខ្លះមើលឃើញថាការបង្រៀនរបស់គាត់ដូចជាប្លាតុងដែរ ដោយជឿលើរដ្ឋគំរូ។ ទោះជាយ៉ាងណាក៏មិនដូចលោកប្លាតុងឡើយ ខូមេនៀស ជឿលើសមភាព, មនុស្សធម៌ អាចរីកចម្រើនបានលុះត្រាតែមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។ សីលធម៌ និងគតិបណ្ឌិតមិនមែនជារបស់ផ្តាច់មុខរបស់ក្រុមណាមួយឡើយ ផ្ទុយទៅវិញពួកវាជាកម្មសិទ្ធិរបស់មនុស្សទាំងអស់។

### ៣.១ គោលបំណងនៃការអប់រំ

យោងតាម ខូមេនៀស គោលដៅនិងគោលបំណងនៃការអប់រំគឺធ្វើឱ្យមនុស្សមានលក្ខណៈដូចព្រះគ្រិស្ត។ នេះបង្ហាញពីការទាក់ទងគ្នារវាងសកម្មភាពនិងឧត្តមគតិ; គុណធម៌គឺជាបេះដូងនៃដំណើរការអប់រំ។ គេអាចហៅគាត់ថាជាអ្នកគិតពិចារណាដ៏ងប់ងល់អំពីព្រះ សម្រាប់លោក ព្រះគឺជាការចាប់ផ្តើម និងចុងបញ្ចប់នៃការអប់រំ។ លោកបានគិតថាការអប់រំគឺជាក្តីសង្ឃឹមរបស់មនុស្សល្អ។ ប្រសិនបើអាចបកស្រាយយ៉ាងត្រឹមត្រូវ វាអាចបង្កើតជាឋានសួគ៌នៅលើផែនដី។

តើគោលដៅនេះអាចសម្រេចបានយ៉ាងដូចម្តេច? លោក ខូមេនៀស និយាយថាការអប់រំគួរតែផ្លាស់ប្តូរពីនៅផ្ទះទៅសាលា។ សិស្សគួរទទួលបានការអប់រំជាក្រុម។ ការធ្វើតាមរបៀបនេះគ្រូបង្រៀននឹងកាន់តែមានឥទ្ធិពល។ ការរៀបចំ និងកាលវិភាគពិតប្រាកដគឺដើម្បីដឹកនាំជីវិតសាលារៀន។ គ្រូបង្រៀនត្រូវជ្រើសរើសចំពោះអ្នកណាដែលស្រឡាញ់ការរៀន និងជាមនុស្សដែលមានការគោរពចំពោះកុមារ។

លោក ខូមេនៀស បានស្នើស្ថាប័នអប់រំចំនួន៤ប្រភេទ។ ទីមួយគឺសាលារៀនជង្គង់ម្តាយ( Mothers knee ) ដែលតំណាងឱ្យការបណ្តុះបណ្តាលកុមារនៅផ្ទះ។ កិច្ចការសម្រាប់ឪពុកម្តាយគឺធ្វើជាគំរូស្ថាបនាសម្រាប់កូនៗ ហើយគំនិតខាងសាសនា និងសីលធម៌ក៏ត្រូវបង្រៀននៅផ្ទះដែរ។ សម្រាប់ស្ថាប័នទីពីរ ដែលលោកស្នើគឺសាលារៀនភាសា( Vernacular School )ដែលសង្កត់ធ្ងន់ទៅលើការសិក្សាភាសាកំណើតជាជាងការសិក្សាពីបុរាណ។ ទន្ទឹមនឹងនេះ សិល្បៈ និងវិទ្យាសាស្ត្រក៏មិនត្រូវធ្វេសប្រហែសទេ។ ប្រភេទទីបី គឺសាលាឡាតាំងសម្រាប់សិស្សពូកែ។ វាសង្កត់ធ្ងន់ទៅលើភាសាក្រិកឡាតាំង និងភាសាហេព្រូ ( Hebrew ) ក៏ដូចជាមូលដ្ឋានគ្រឹះវិទ្យាសាស្ត្រ អក្សរសាស្ត្រ និងសិល្បៈ។ សាលាទីបួនគឺជាសាកលវិទ្យាល័យ និងការធ្វើដំណើរដែលបង្កើតអ្នកដឹកនាំសង្គម។ សាលារៀននេះគឺលើកទឹកចិត្តដល់សិស្សឆ្នើម( ពូកែ )ឱ្យធ្វើការអង្កេត និងឈ្វេងយល់ពីឧត្តមគតិ និងសីលធម៌របស់ប្រជាជាតិនានា។

លោកសង្កត់ធ្ងន់ថាពុទ្ធិមិនមែនបានមកពីធម្មជាតិទេ ប៉ុន្តែបានមកពីបទពិសោធឥន្ទ្រីយ៍របស់យើង។ អ្វីដែលសំខាន់បំផុតនៅក្នុងដំណើរការអប់រំនោះគឺការជំរុញមនោគតិរបស់យុវជន។ លោក ខូមេនៀស យល់ថាការអនុវត្តនឹងជួយពង្រឹងអង្គចងចាំរបស់កុមារ ហើយប្រសិនបើយើងបង្កើតទម្លាប់បញ្ញាត្រឹមត្រូវក្នុងវ័យកុមារភាព នោះពួកគេនឹងទទួលបានអត្ថប្រយោជន៍ច្រើននៅពេលពេញវ័យ។ ដូចជាអ្នកអប់រំប្រតិបត្តិនិយមសម័យទំនើបផងដែរ គាត់បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃសកម្មភាព។ ការរៀនដោយការធ្វើគឺជាគន្លឹះសម្រាប់ប្រព័ន្ធអប់រំរបស់គាត់។ យើងរៀនសរសេរដោយការសរសេរ, រៀនពិចារណាដោយវិចារណញ្ញាណ។ ប៉ុន្តែ សកម្មភាពតែម្នាក់ឯងមិនទាន់គ្រប់គ្រាន់នោះទេ។ សមត្ថភាពចាំបាច់ និងការប៉ាន់ស្មានរបស់សិស្សត្រូវតែមានការអប់រំ។ នេះជាមុខងារនៃការពិចារណាដែលផ្តល់ជាមូលដ្ឋានសម្រាប់ការវិនិច្ឆ័យ។ ម៉្យាងទៀត ការអនុវត្តរបស់មនុស្សនឹងបរាជ័យ ប្រសិនបើគេមើលរំលងពីសារៈសំខាន់នៃវិចារណញ្ញាណ។ លោកយល់ថាការរៀនសូត្រគឺជាដំណើរការមិនចេះរីងស្ងួតដែលទាមទារឱ្យមានការចាប់អារម្មណ៍ និងការចង់ដឹងចង់ឃើញពីសំណាក់សិស្ស។

គេអាចសង្ខេបវិធីសាស្ត្រអប់រំរបស់គាត់ជាគោលការណ៍ចំនួនប្រាំបួនដែលបានធ្វើទៅតាមលំដាប់លំដោយរបស់ធម្មជាតិដូចខាងក្រោម៖

គោលការណ៍ទី១៖ ការសង្កេតធម្មជាតិជាវេលាដ៏សមស្រប។ ឧទាហរណ៍ បក្សីដែលចង់បន្តពូជ វាច្រើនធ្វើនៅរដូវផ្ការីកជាពេលដែលព្រះអាទិត្យផ្តល់ជីវិត និងកម្លាំង។ ខណៈពេលដែលអាកាសធាតុនៅត្រជាក់នៅឡើយ បក្សីចាប់ផ្តើមបង្កកំណើតជាពង និងផ្តល់កំដៅដល់ពងនៅក្នុងខ្លួនរបស់វាដើម្បីការពារពីភាពត្រជាក់។ នៅពេលមានខ្យល់ក្តៅល្មម វានឹងដាក់ពងក្នុងសំបុក ប៉ុន្តែវាមិនទាន់ញាស់ទេ រហូតដល់រដូវក្តៅមកដល់ទើបកូនអាចនឹងមានពន្លឺ និងមានភាពកក់ក្តៅ។ ដូច្នេះ តាមរយៈរឿងនេះគាត់និយាយថា៖

- ការអប់រំរបស់មនុស្សគួរតែចាប់ផ្តើមនៅនិទាឃរដូវនៃជីវិត ពោលគឺក្នុងវ័យកុមារភាព (សម្រាប់វ័យកុមារភាពសមនឹងនិទាឃរដូវ, ជិតពេញវ័យសមនឹងរដូវក្តៅ, ពេញវ័យសមនឹងរដូវស្លឹកឈើជ្រុះ និងមនុស្សចាស់សមនឹងរដូវរងារ)។

- វេលាពេលព្រឹកសមស្របបំផុតសម្រាប់ការសិក្សា (វេលាពេលព្រឹកសមនឹងនិទាឃរដូវ, ថ្ងៃត្រង់សមនឹងរដូវក្តៅ, ពេលល្ងាចសមនឹងរដូវស្លឹកឈើជ្រុះ និងពេលយប់សមនឹងរដូវរងារ)។

- មុខវិជ្ជាទាំងអស់ដែលត្រូវរៀនគួររៀបចំឱ្យបានសមស្របទៅនឹងអាយុសិស្ស អ្វីដែលត្រូវផ្តល់ឱ្យពួកគេរៀនគឺគ្មានអ្វីដែលលើសពីការយល់ដឹងរបស់ពួកគេឡើយ។

គោលការណ៍ទី២៖ ធម្មជាតិរៀបចំវត្ថុធាតុមុនពេលចាប់ផ្តើមផ្តល់ឱ្យ។ ឧទាហរណ៍ បក្សីដែលមានបំណងបង្កើតសត្វស្រដៀងនឹងខ្លួនវា ដំបូងបង្កកំណើតអំប្រ៊ីយ៉ុងពីតំណក់ឈាមរបស់វា ហើយបន្ទាប់មករៀបចំសំបុកដែលត្រូវដាក់ពង។ ដូច្នេះ លោកសង្កត់ធ្ងន់ថា៖

- សៀវភៅនិងសម្ភារឧបទេសចាំបាច់សម្រាប់ការបង្រៀនគឺត្រូវរៀបបម្រុងទុកជាមុន។

- ការយល់ដឹងដំបូងក្នុងការបង្រៀនគឺមាននៅក្នុងវត្ថុ បន្ទាប់មកមាននៅក្នុងជាភាសា។

- ភាសាមិនកិតពីវេយ្យាករណ៍ទេ ប៉ុន្តែវេយ្យាករណ៍បានមកពីអ្នកនិពន្ធ។

- ចំណេះដឹងពីវត្ថុកើតមុន ចំណេះដឹងពីវេយ្យាករណ៍កើតក្រោយ។

- គំរូនេះកើតមានមុនច្បាប់។

គោលការណ៍ទី៣៖ ធម្មជាតិជ្រើសរើសប្រធានបទដែលសមនឹងធ្វើ ឬការផ្តល់ឱ្យដំបូងមួយនូវអាកប្បកិរិយាឆ្ពោះទៅក្នុងគោលបំណងធ្វើឱ្យវាសមរម្យ។ វាជាគុណសម្បត្តិ៖

- អ្នកទាំងអស់ដែលចូលសាលារៀនគឺត្រូវតស៊ូនៅក្នុងការសិក្សារបស់ខ្លួន។

- មុនពេលបង្រៀនសិស្សលើការសិក្សាពិសេសណាមួយ គ្រូត្រូវរៀបចំគំនិតរបស់សិស្ស និងត្រៀមទទួលយកគំនិតសិស្ស។

- របាំងឧបសគ្គទាំងអស់ត្រូវដកចេញពីវិធីរបស់សាលារៀន។

គោលការណ៍ទី៤៖ ធម្មជាតិមិនច្របូកច្របល់ក្នុងការប្រតិបត្តិការរបស់ខ្លួនទេ ប៉ុន្តែនៅក្នុងដំណើរឆ្ពោះទៅមុខជានិច្ច ហើយរីកចម្រើនពីចំណុចមួយទៅចំណុចមួយទៀត។ ដូច្នេះ យើងគួរតែបញ្ឈប់ការសិក្សាភាសាក្រិកចោលរហូតដល់ភាសាឡាតាំងបានស្ទាត់ជំនាញសិន ពីព្រោះវាមិនអាចទៅរួចទេក្នុងការផ្តោតអារម្មណ៍លើរឿងមួយផ្សេងទៀត នៅពេលវារវល់ជាមួយរឿងជាច្រើនក្នុងពេលតែមួយ។

គោលការណ៍ទី៥៖ នៅក្នុងប្រតិបត្តិការទាំងអស់នៃការអភិវឌ្ឍធម្មជាតិគឺមកពីខាងក្នុង។ ឧទាហរណ៍ ករណីបក្សី ការបង្កើតជាដំបូងគេនោះមិនមែនជាក្រញាំ ឬរោម ឬស្បែកនោះទេ ប៉ុន្តែ ជាផ្នែកខាងក្នុង ផ្នែកខាងក្រៅបង្កើតឡើងនៅពេលក្រោយតាមរដូវសមស្រប។ នេះមានន័យថាអ្នកអប់រំគួរតែឈ្វេងយល់ពីរឿងនានាជាមុនសិន និងបន្ទាប់មកចងចាំវា ហើយគ្រូបង្រៀនគួរដឹងអំពីវិធីសាស្ត្រទាំងអស់នេះដើម្បីផ្តល់ចំណេះដឹងឱ្យសិស្ស។

គោលការណ៍ទី៦៖ នៅក្នុងដំណើរការបង្កើតរបស់ធម្មជាតិ វាតែងចាប់ផ្តើមពីសកលភាព ហើយបញ្ចប់ដោយលក្ខណៈដោយឡែក។ ឧទាហរណ៍ បក្សីបង្កើតដំបូងចេញជាស៊ុត។ វាមិនមែនបង្កើតឡើងដំបូងចេញជាក្បាល ភ្នែក

រោម ឬក្រញាំឡើយ ប៉ុន្តែវាដំណើរការដូចតទៅនេះ៖ ស៊ុតទាំងមូលត្រូវកម្តៅល្មម កម្តៅបង្កើតបានទៅជាចលនា ហើយចលនានាំមកនូវអត្ថិភាពនៃប្រព័ន្ធសរសៃឈាមវ៉ែនដែលសម្គាល់នៅក្នុងរូបរាងបក្សីទាំងមូល។ សិល្បករម្នាក់ដំណើរការតាមរបៀបដូចគ្នា។ គាត់មិនចាប់ផ្តើមដោយគូរត្រចៀក ភ្នែក ច្រមុះ ឬមាត់ទេ ប៉ុន្តែដំបូងបង្អស់គូរគំនូរព្រាងនៃផ្ទៃមុខ ឬរាងកាយទាំងមូល។ ប្រសិនបើគាត់ពេញចិត្តថាគំនូរព្រាងនេះប្រហាក់ប្រហែលនឹងវត្ថុដើម នោះគាត់នឹងគូរដោយប្រើប្រាស់ពន្លឺតិចៗរហូតលុបជានចាស់លម្អិតទាំងអស់នោះ។ នៅទីបំផុតគាត់ដាក់ពន្លឺ និងស្រមោលដោយប្រើពណ៌ជាច្រើនដើម្បីបញ្ចប់ផ្នែកជាច្រើនទៀត។

- ភាសា វិទ្យាសាស្ត្រ ឬសិល្បៈនីមួយៗ ជាដំបូងត្រូវបង្រៀនក្នុងលក្ខណៈសាមញ្ញៗបំផុតដល់សិស្សដើម្បីឱ្យពួកគេអាចទទួលយកគំនិតទូទៅ។

- ចំណេះដឹងរបស់សិស្សអាចអភិវឌ្ឍបន្ថែមដោយការដាក់វិធាន និងគំរូចំពោះមុខគាត់។

- អនុញ្ញាតឱ្យរៀនមុខវិជ្ជាជាប្រព័ន្ធដោយមានករណីលើកលែង និងភាពមិនប្រក្រតី។

គោលការណ៍ទី៧៖ ធម្មជាតិមិនលោតផ្លោះនោះទេ ប៉ុន្តែ ដំណើរការជាជំហានៗ។

- ការសិក្សាទាំងអស់គួរតែដាក់ពិន្ទុដោយការប្រុងប្រយ័ត្ននៅទូទាំងថ្នាក់រៀនផ្សេងៗគ្នាតាមរបៀបដែលពួកអ្នកមកមុនរៀបចំផ្លូវសម្រាប់បំភ្លឺអ្នកដែលមកក្រោយ។

- គួរបែងចែកពេលវេលាដោយប្រុងប្រយ័ត្ន ដូច្នេះ គេអាចដាក់កិច្ចការធ្វើជារៀងរាល់ឆ្នាំ, រាល់ខែ, រាល់ថ្ងៃ និងរាល់ម៉ោង។

- ការបែងចែកពេលវេលា និងមុខវិជ្ជាសិក្សាគួរប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ដើម្បីកុំឱ្យមានកំហុសឆ្គង ឬខុសពីលក្ខណៈធម្មជាតិ។

គោលការណ៍ទី៨៖ ប្រសិនបើធម្មជាតិចាប់ផ្តើមបង្កើតអ្វីមួយ វាត្រូវប្រតិបត្តិការទៅតាមដំណាក់កាលរបស់វារហូតដល់ទីបញ្ចប់។ ដូច្នេះ គាត់ទាញទឡ្ហីករណ៍៖

- អ្នកដែលគេបញ្ជូនទៅសាលារៀនគឺត្រូវទុកឱ្យនៅទីនោះរហូតដល់គាត់ក្លាយជាមនុស្សល្អមានគុណធម៌ និងគួរឱ្យគោរព។

- សាលារៀនត្រូវតែស្ថិតនៅកន្លែងស្ងាត់ ឆ្ងាយពីសំឡេងរំខាន និងការបង្វែរអារម្មណ៍។

- អ្វីដែលធ្វើត្រូវអនុលោមតាមប្រធានបទនៃការសិក្សា ត្រូវធ្វើដោយគ្មានការគេចចេញ។

គោលការណ៍ទី៩៖ ធម្មជាតិប្រុងប្រយ័ត្នណាស់ជៀសវាងនូវឧបសគ្គ និងរឿងដែលអាចបណ្តាលឱ្យឈឺចាប់។ ឧទាហរណ៍ នៅពេលបក្សីញាស់ពង វាមិនបណ្តោយឱ្យមានខ្យល់ត្រជាក់ ភ្លៀងធ្លាក់ប៉ះត្រូវពួកវាទេ។ តាមវិធីដូចគ្នារបស់អ្នកសាងសង់ តាមដែលអាចធ្វើទៅបានគឺធ្វើឱ្យស្ងួតឈើ ឥដ្ឋ និងកំបោររបស់គាត់ដោយមិនអនុញ្ញាតឱ្យអ្វីដែលគាត់បានខំសាងសង់ឡើងត្រូវបំផ្លាញ ឬដួលរលំទេ។ ដូចគ្នានេះដែរ វិចិត្រករការពាររូបគំនូរដែលទើបនឹងគូរថ្មីៗពីខ្យល់ កំដៅ ធូលី និងមិនអនុញ្ញាតឱ្យដៃអ្នកដទៃប៉ះវា ប៉ុន្តែគាត់អាចប៉ះវាបាន។

ដូច្នេះ ជាភាពល្ងីល្ងើដែលបង្រៀនសិស្សពីចំណុចដែលមានភាពចម្រូងចម្រាសនៅពេលសិស្សទើបចាប់ផ្តើមរៀនមុខវិជ្ជានោះ។ ត្រូវអនុញ្ញាតឱ្យគំនិតសិស្សធ្វើជាម្ចាស់លើអ្វីដែលថ្មីដើម្បីទទួលយកឥរិយាបថនៃការសង្ស័យ។ តើអ្វីដែលបំផ្លាញរុក្ខជាតិទើបចាប់ផ្តើមចាក់ឫស? (លោក ហ៊ូហ្គោ(Hugo)និយាយថា៖ អ្នកណាដែលចាប់ផ្តើមដោយការអង្កេតនូវចំណុចសង្ស័យនឹងមិនចូលទៅក្នុងជម្រកនៃគតិបណ្ឌិតទេ)។ ដូច្នេះ សាលាគួរយកចិត្តទុកដាក់៖

- អ្នកអប់រំទទួលយកមិនមែនសៀវភៅទេ ប៉ុន្តែវាសមស្របសម្រាប់ថ្នាក់រៀនពួកគេ។

- វាជាប្រភេទដែលពួកគេហៅថាជាប្រភពនៃគតិបណ្ឌិត គុណធម៌ និងការគោរព។

- មិនថានៅក្នុងសាលារៀន ឬក៏នៅក្នុងបរិវេណជុំវិញនោះទេ ត្រូវអនុញ្ញាតឱ្យអ្នកអប់រំស្ថិតនៅលាយឡំជាមួយដៃគូមិនល្អ។

សរុបមកវិញ គោលបំណងអប់រំរបស់ ចន អេមូស ខូមេនៀស អំពីចំណេះដឹង គុណធម៌ និងការគោរពគឺសិស្សរៀនមិនមែនសម្រាប់សាលារៀនទេ ប៉ុន្តែសម្រាប់ជីវិត, ដូច្នេះ យុវជនឆ្ពោះទៅរកភាពស្វាហាប់, ភាពរឹងមាំ, ត្រៀមខ្លួនសម្រាប់អ្វីៗគ្រប់យ៉ាង, មានភាពឧស្សាហ៍ព្យាយាមសក្តិសមនឹងទទួលបានភារកិច្ចណាមួយនៃជីវិត ហើយអ្វីៗទាំងអស់កាន់តែប្រសើរឡើងថែមទៀត ប្រសិនបើពួកគេបានបន្ថែមគុណធម៌ទៅក្នុងការសន្ទនាដ៏ផ្អែមល្ហែម ព្រមទាំងបានបំពាក់នូវការគោរពកោតខ្លាច និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ សិស្សនឹងមានសមត្ថភាពក្នុងការបញ្ចេញមតិ និងមានភាពឧឡារិក។

ខូមេនៀស ជឿថាមនុស្សមានសមត្ថភាពដឹងរឿងទាំងអស់និងធ្វើអ្វីគ្រប់យ៉ាង មានទំនាក់ទំនងជាមួយព្រះ។ គោលបំណងអប់រំរបស់គាត់ផ្អែកលើជំនឿនេះ។ គោលបំណងអប់រំគឺបង្រៀនអ្វីៗគ្រប់យ៉ាងដល់មនុស្សទាំងអស់។ គាត់ជឿថាការអប់រំមានថាមពលក្នុងការបង្កើតជីវិតមនុស្សឡើងវិញ។ ការអប់រំគឺជាដំណើរការដែលមិនអាចខ្វះបាននៅពេលកុមារត្រូវបានបង្កើតជាមនុស្ស។ គាត់ចង់ឱ្យការអប់រំគួរតែចាប់ផ្តើមនៅពេលកុមារមានកំណើតក្នុងផ្ទៃម្តាយមិនមែនរង់ចាំដល់ពេលដែលកុមារចាប់ផ្តើមចូលសាលារៀននោះទេ។

## ៣.២ ចិត្តវិទ្យានៃការអប់រំ

ខូមេនៀស ជាអ្នកសង្កេតការលូតលាស់របស់រុក្ខជាតិនិងសត្វ, សកម្មភាពធម្មជាតិនិងចំណាប់អារម្មណ៍របស់កុមារ និងប្រតិបត្តិការសិប្បកម្មដោយដៃនិងសិល្បៈ។ គាត់បង្កើតទ្រឹស្តី ចិត្តវិទ្យា, ការលូតលាស់នៃធម្មជាតិរបស់កុមារដោយគាត់ផ្អែកលើគោលការណ៍ និងវិធីសាស្ត្របង្រៀនដូចគ្នា។ លោកជឿថាដំណើរការលូតលាស់ធម្មជាតិរបស់កុមារត្រូវតែជាមូលដ្ឋានពិតនៃការអប់រំ។ គាត់និយាយថា "សូមឱ្យយើងធ្វើតាមច្បាប់ធម្មជាតិគ្រប់បែបយ៉ាងដើម្បីសង្កេតមើលពីរបៀបដែលសមត្ថភាពមួយអាចអភិវឌ្ឍពីមួយទៅមួយទៀត និងផ្អែកទៅលើវិធីសាស្ត្រដែលជាគោលការណ៍នៃភាពជោគជ័យ។ គាត់បង្ហាញថា "ការរៀបចំការបង្រៀនពិតប្រាកដគឺត្រូវខ្ចីពីធម្មជាតិ"។ លោកបានទទួលស្គាល់ភាពខុសគ្នាខ្លះៗរបស់កុមារម្នាក់ៗហើយពិភាក្សាពីវិធីដោះស្រាយជាមួយពួកគេតាមរបៀបដ៏ឈ្លាសវៃ។

ខូមេនៀស ចង់ផ្តល់ការអប់រំដល់កុមារឱ្យស្របទៅតាមដំណាក់កាលនៃការអភិវឌ្ឍរបស់ពួកគេ។ នេះគឺជាការចូលរួមចំណែកមួយដ៏សំខាន់របស់លោកចំពោះវិទ្យាសាស្ត្រអប់រំ។ គាត់យល់ពីតម្រូវការ ចំណាប់អារម្មណ៍ និងអំណាចនៃការយល់ដឹងរបស់កុមារនៅក្នុងដំណាក់កាលនីមួយៗនៃការអភិវឌ្ឍនេះ។ គាត់រៀបចំសៀវភៅសិក្សាគោលនៃថ្នាំនីមួយៗសម្រាប់សាលារៀន ឱ្យស្របតាមតម្រូវការ និងចំណាប់អារម្មណ៍របស់កុមារ។

ឥន្ទ្រីយ៍(Senses)៖ លោកចាត់ទុកឥន្ទ្រីយ៍ទាំង៥ជាច្រកទ្វារនៃព្រលឹងមនុស្ស។ គាត់ជឿលើលទ្ធិចាស់ថា "មិនមានអ្វីនៅក្នុងបញ្ញាទេ បើមិនមានអ្វីមុននៅក្នុងឥន្ទ្រីយ៍"។ គាត់បានផ្អែកលើគោលការណ៍វិធីសាស្ត្ររបស់គាត់សម្រាប់សាលារៀនទារក និងសាលាភាសាលើគោលលទ្ធិនេះ។

មនោគតិ(Imagination)៖ លោក ខូមេនៀស ចាត់ទុកមនោគតិគឺជាអារម្មណ៍ខាងក្នុង។ លោកចាត់ទុកថាវាមានសារៈសំខាន់ខ្លាំងសម្រាប់ការអភិវឌ្ឍចំណេះដឹង និងស្មារតីរបស់កុមារ។

អង្គចងចាំ(Memory)៖ ខូមេនៀស ជឿថាអង្គចងចាំអាចអភិវឌ្ឍតាមរយៈការអនុវត្ត ប៉ុន្តែ គាត់បញ្ជាក់ផងដែរថាមុនពេលមានអ្វីត្រូវចងចាំ វាត្រូវមានចំណាប់អារម្មណ៍ច្បាស់លាស់ និងមានឥន្ទ្រីយ៍រឹងមាំ។ យោងតាមលោក ខូមេនៀស គ្មានអ្វីគួរតែប្រព្រឹត្តិទៅក្នុងអង្គចងចាំដោយមិនបានពិភាក្សា និងយល់ពីវាឱ្យបានច្បាស់ទេ។ លោកមិនចង់ឱ្យអ្វីៗទាំងអស់ត្រូវតែចងចាំទេ មានតែអ្វីដែលសំខាន់បំផុតប៉ុណ្ណោះដែលគួរចងចាំ។

វិចារណញ្ញាណ(Reason)៖ លោកគិតថាវិចារណញ្ញាណជួយដល់ការវង្វាស់ និងកំណត់ដូចជា អ្វីទៅ ទីណា និងរបៀបណានៃអ្វីមួយដែលគួរស្វែងរក ឬគួរជៀសវាង។

អារម្មណ៍ និងឆន្ទៈ(Emotions and Will)៖ លោក ខូមេនៀស ទទួលស្គាល់សារៈសំខាន់នៃអារម្មណ៍របស់កុមារក្នុងការអប់រំ។ លោកពិចារណាអំពីអារម្មណ៍អាណិតអាសូរ។

ចំណាប់អារម្មណ៍ពីកំណើតផ្តល់ការប្រឹងប្រែងពីខាងក្នុងបន្ទាប់ពីចំណេះដឹង។ គ្រូល្អម្នាក់ពឹងផ្អែកលើការរំញោចនៃចំណាប់អារម្មណ៍ពីកំណើត និងមិនមែនលើវិធីសាស្ត្រសិប្បនិម្មិតទេ។ គាត់ជឿជាក់ថាចំណង់មានឥទ្ធិពលលើឆន្ទៈ និងកំណត់លក្ខណៈនៃចរិត។ គាត់ផ្តល់កន្លែងសំខាន់បំផុតសម្រាប់ឆន្ទៈ និងលក្ខណៈខាងសីលធម៌នៅក្នុងបទពិសោធរបស់មនុស្ស។

**៣.៣ អង្គភាពនៃការអប់រំ**

**៣.៣.១ រចនាសម្ពន្ធសាលារៀន**

ខូមេនៀស បែងចែករចនាសម្ពន្ធសាលារៀនជាបួនដំណាក់កាលក្នុងរយៈពេល៦ឆ្នាំម្តង។ ដំណាក់កាលនីមួយៗមានមុខងារពិសេសរៀងៗខ្លួនស្របតាមតម្រូវការ និងចំណាប់អារម្មណ៍នៃដំណាក់កាលអភិវឌ្ឍន៍ពិសេសៗទាំងនោះ។ រចនាសម្ពន្ធសាលារៀនទាំងបួនដំណាក់កាលដែលចង្អុលបង្ហាញដោយខូមេនៀស មានដូចខាងក្រោមៈ

ជង្គង់ម្តាយ (Mothers knee) ឬសាលារៀនម្តាយសម្រាប់ទារកទើបនឹងកើតដែលមាននៅគ្រប់គេហដ្ឋាន។

សាលារៀនភាសាសម្រាប់កុមារភាពមាននៅគ្រប់ភូមិ និងភូមិតូចៗ។

សាលារៀនកាយសម្ពន្ធ (Gymnasium) ឬសាលារៀនឡាតាំងសម្រាប់កុមារភាពដែលបង្កើតឱ្យមាននៅគ្រប់ទីក្រុង។

សាកលវិទ្យាល័យ និងការធ្វើដំណើរសម្រាប់យុវជន។ សាកលវិទ្យាល័យគួរមានគ្រប់នគរ ឬនៅគ្រប់ខេត្ត។

សម័យលោក ខូមេនៀស គ្មានសាលារៀននៅតាមភូមិទេ ហើយមានតែការបង្រៀនសម្រាប់កុមារភាគច្រើនដែលកាន់សាសនា។ លោកមានភាពក្លាហាន មើលទៅឆ្ងាយ និងមុនអាយុរបស់លោកទាក់ទងនឹងប្រព័ន្ធសាលារៀនដែលគាត់ស្នើ។ យើងនឹងព្យាយាមឈ្វេងយល់អំពីលក្ខណៈនៃរចនាសម្ពន្ធសាលារៀនដូចការគិតរបស់ខូមេនៀសចំពោះដំណាក់កាលនៃការអភិវឌ្ឍទាំងបួនគឺទារកភាព, កុមារភាព, វ័យជំទង់ និងយុវវ័យ។

**៣.៣.១.១ សាលារៀនសម្រាប់ទារកភាពៈ** ផ្ទះជាសាលាដំបូងគេ ពីព្រោះការអប់រំរបស់កុមារចាប់ផ្តើមតាំងពីកំណើត។ លោកផ្តល់ស្រមោលព្រាងនៃការបណ្តុះបណ្តាលមុនពេលចូលសាលារៀនដែលអ្នកគិតពីការអប់រំក្រោយៗទៀតមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ សៀវភៅតូចមួយដែលមានចំណងជើងថា"សាលាកុមារភាព" បង្ហាញពីការយល់ដឹងដ៏អស្ចារ្យរបស់គាត់ចំពោះតម្រូវការ និងចំណាប់អារម្មណ៍របស់កុមារតូចៗ។ គាត់មិនបានផ្តល់ទូទៅនីយកម្មច្រើននោះទេ។ ជំនួសមកវិញ គាត់បានផ្តល់ព័ត៌មានលម្អិតជាក់លាក់អំពីសកម្មភាព និងសមត្ថភាពរបស់កុមារនៅឆ្នាំបន្តបន្ទាប់នៃជីវិត។ សៀវភៅរៀបរាប់លម្អិតគ្រប់ផ្នែកនៃការអប់រំដូចជា រាងកាយ, ផ្លូវចិត្ត, ហត្ថកម្ម, ការបញ្ចេញមតិ, សង្គម, សាសនា និងសីលធម៌។ ខូមេនៀស ចង់បង្រៀនកុមារតូចៗពីមូលដ្ឋានគ្រឹះតថភាពរបស់វិទ្យាសាស្ត្រទាំងអស់។ មុខងារពិសេសរបស់សាលារៀនទារកគឺការងារនិងលំហាត់ឥន្ទ្រីយ៍, ការបង្រៀននៅក្នុងសាសនា និងការបណ្តុះបណ្តាលសង្គមដំបូង។ ប៉ុន្តែ នៅក្នុងគម្រោងគំនិតនេះលោក ខូមេនៀស បានដឹងយ៉ាងច្បាស់ពីសមត្ថភាពធម្មជាតិ និងដែនកំណត់របស់កុមារ។ លោកមិនស្នើសុំអ្វីក្រៅពីវិសាលភាពនៃចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់កុមារទេ។ លោកបានស្នើឱ្យប្រើប្រាស់រឿងព្រេងនិទាន, រឿងរ៉ាវ, លេង, តន្ត្រី, ហត្ថកម្ម និងកំប្លែង។

**៣.៣.១.២ សាលារៀនភាសាៈ** ចង់បង្កើតសាលាដ៏ល្អសម្រាប់កុមារក្រីក្រ ឬអ្នកមាន។ កុមារទាំងអស់ត្រូវទទួលបានការអប់រំក្នុងសាលាតែមួយ។ នេះជាការចាកចេញដាច់ណាត់ពីប្រពៃណីដែលបានទទួលយកពីបុរាណ។ រហូតមកដល់សម័យគាត់គ្មានសាលារៀនណាត្រូវបានបង្កើតឡើងសម្រាប់ភូមិតូចៗទេ។ សាលាភាសា គឺផ្តល់ការបណ្តុះបណ្តាលត្រៀមដល់អ្នកដែលមានបំណងចូលសាលាឡាតាំង និងការបណ្តុះបណ្តាលចាំបាច់ជាបឋមដល់កុមារទាំងនោះដែលត្រូវចូលរៀនវិជ្ជាជីវៈខ្លះបន្ទាប់ពីចាកចេញពីសាលារៀន។ កាលពីដើម ការបង្រៀនពីប្រភេទនេះផ្តល់ឱ្យសិស្សនៅក្នុងសាលាដាច់ដោយឡែក ប៉ុន្តែ លោកព្យាយាមផ្សារភ្ជាប់គម្លាតរវាងកូនអ្នកមាននិងអ្នកក្រីក្រ, ក្មេងឋានៈទាបនិងក្មេងឋានៈខ្ពស់ ដោយបើកសាលារៀនធម្មតាសម្រាប់ពួកគេ។

នៅសាលាភាសា កុមារត្រូវសិក្សារយៈពេល៦ឆ្នាំមុនពេលពួកគេចាប់ផ្តើមសិក្សាឡាតាំង។ បើតាមលោក ខូមេនៀស នៅក្នុងសាលារៀនភាសា, ឥន្ទ្រីយ៍ខាងក្នុង, មនោគតិ និងអង្គចងចាំគួរតែបណ្តុះបណ្តាលរួមគ្នាជាមួយនឹងការយល់ដឹងពីសរីរាង្គកាយរបស់ពួកគេ។ មុខវិជ្ជាគួរបង្រៀននៅក្នុងសាលាភាសា៖ ការអាន, ការសរសេរ, ការនព្វន្តជាក់ស្តែង, សាសនា, សីលធម៌, ការច្រៀង, សេដ្ឋកិច្ច, ប្រវត្តិសាស្ត្រទូទៅ, នយោបាយ, សិល្បៈ, មេកានិច និងលោហធាតុវិជ្ជា។ លោកចង់ធ្វើឱ្យសាលាភាសាមានលក្ខណៈជាស្ថាប័នដែលកុមារគួរទទួលបានការបណ្តុះបណ្តាលនៅគ្រប់ "សិល្បៈនៃមនុស្សសាមញ្ញ"។

**៣.៣.១.៣ សាលាកាយសម្ពន្ធ ឬសាលាឡាតាំង៖** លោកចង់បើកសាលារៀនកាយសម្ពន្ធ ឬសាលាឡាតាំងដល់កុមារដែលកើតមកខ្ពស់ ឬទាប អ្នកមាន ឬអ្នកក្រ មិនថាពួកគេជ្រើសរើសនៅក្នុងរោងជាង ឬសេចក្តីប្រាថ្នាខ្ពស់ជាងនេះទេ។ កម្មវិធីសិក្សាសាលាឡាតាំងគឺមានដូចជាតក្កវិជ្ជា, វេយ្យាករណ៍, វោហារសាស្ត្រ, វិទ្យាសាស្ត្រសិល្បៈ និងភាសាទាំងបួនគឺភាសាកំណើត, ភាសាឡាតាំង, ភាសាក្រិក និងភាសាហេព្រូ។ ក្នុងការរៀនភាសានោះគឺសង្កត់ធ្ងន់ចម្បងដោយផ្តោតលើភាសាកំណើត និងភាសាឡាតាំង។ នៅក្នុងសាលាឡាតាំងនេះគឺជាការប៉ុនប៉ងធ្វើឱ្យមានឧត្តមភាពនៃចិត្ត។ លោកចង់និយាយថាសៀវភៅសិក្សាឡាតាំងផ្ទាល់ខ្លួនគាត់គួរត្រូវបង្រៀន។ ថ្នាក់រៀនទាំង៦ ឬឆ្នាំនៃសាលារៀនឡាតាំងរួមមាន ថ្នាក់វេយ្យាករណ៍, ថ្នាក់ទស្សនវិជ្ជាធម្មជាតិ, ថ្នាក់គណិតវិទ្យា, ថ្នាក់សីលវិជ្ជា, ថ្នាក់វិចារវិទ្យា និងថ្នាក់វោហារសាស្ត្រ។ លោកចង់និយាយថារាល់ទីក្រុង ឬទីប្រជុំជនទាំងអស់គួរតែមានយ៉ាងហោចណាស់សាលាឡាតាំងមួយ។

**៣.៣.១.៤ សាកលវិទ្យាល័យ និងការធ្វើដំណើរ៖** លោក ខូមេនៀស ចង់ឱ្យខេត្ត ឬនគរទាំងអស់គួរមានសាកលវិទ្យាល័យផ្ទាល់ខ្លួន។ និស្សិតដែលមានចរិតសីលធម៌កម្រិតខ្ពស់គួរបានចូលរៀនសាកលវិទ្យាល័យ។ នៅពេលបញ្ចប់វគ្គសិក្សាពីសាលាឡាតាំង សិស្សត្រូវធ្វើតេស្តដោយការប្រឡងជាសាធារណៈដើម្បីអាចចូលរៀននៅសាកលវិទ្យាល័យ។ លោកនិយាយថា"ចំពោះសាកលវិទ្យាល័យជាកម្មសិទ្ធិរបស់មុខវិជ្ជាដែលមានទំនាក់ទំនងជាពិសេសនឹងឆន្ទៈ, កេរ្តិ៍ឈ្មោះ, សមត្ថភាព លើអ្វីដែលទេវវិជ្ជាបង្រៀនយើងឆ្ពោះទៅរកភាពសុខដុមសម្រាប់ព្រលឹង, ទស្សនវិជ្ជាគំនិត, វេជ្ជសាស្ត្រសម្រាប់មុខងារសំខាន់នៃរាងកាយ និងនីតិសាស្ត្រសម្រាប់កិច្ចការខាងក្រៅរបស់យើង។ ដូច្នេះ ទេវវិជ្ជា, ទស្សនវិជ្ជា, វេជ្ជសាស្ត្រ និងច្បាប់នឹងបង្កើតជាកម្មវិធីសិក្សាចម្បងរបស់សាកលវិទ្យាល័យ។

ក្រៅពីបង្រៀនមុខវិជ្ជាទាំងនោះ សាកលវិទ្យាល័យក៏គួរបណ្តុះបណ្តាលគ្រូ និងអ្នកដឹកនាំសម្រាប់រដ្ឋផងដែរ។ លោកយល់ថាការស្រាវជ្រាវ ឬភាពរីកចម្រើននៃការរៀនគួរជាមុខងាររបស់សាកលវិទ្យាល័យផងដែរ។ គាត់ពេញចិត្តការធ្វើឱ្យសាកលវិទ្យាល័យក្លាយទៅជាមជ្ឈមណ្ឌលសម្រាប់ការសិក្សាគ្រប់មែកជាងនៃចំណេះដឹងរបស់មនុស្ស។ ខូមេនៀស ជឿជាក់ថាការធ្វើដំណើរគឺជាប្រភពដ៏ល្អមួយនៃការប្រមូលព័ត៌មានដោយផ្ទាល់ទាក់ទងនឹងធម្មជាតិរបស់មនុស្ស និងស្ថាប័ននានា។ លោកចង់ឱ្យការធ្វើដំណើរគួររៀបចំឡើងបន្ទាប់ពីអាជីពនៅសាកលវិទ្យាល័យ និងបន្ទាប់ពីការបង្កើតទម្លាប់សីលធម៌ពេញលេញ។

### ៣.៣.២ គ្រូពិសេស និងថ្នាក់រៀនដាច់ដោយឡែក

លោកចង់បានមុខវិជ្ជាសម្រាប់ការបង្រៀនមួយគឺត្រូវធ្វើការសម្រេចចិត្តជ្រើសរើសជារៀងរាល់ឆ្នាំ, រៀងរាល់ខែ, រាល់សប្តាហ៍, រាល់ថ្ងៃ និងសូម្បីរាល់ម៉ោងនីមួយៗនឹងត្រូវមានភារកិច្ចច្បាស់លាស់ត្រូវចង្អុលបង្ហាញសម្រាប់មុខវិជ្ជានោះ។ គ្រូពិសេសគួរចង្អុលបង្ហាញសម្រាប់ថ្នាក់នីមួយៗ ហើយថ្នាក់រៀននីមួយៗគួរនៅក្នុងបន្ទប់ដាច់ដោយឡែក។ អត្ថបទគួររៀបចំដោយបញ្ចូលរាល់ការងារដែលត្រូវធ្វើនៅក្នុងថ្នាក់រៀន។

### ៣.៣.៣ ម៉ោងធ្វើការងារ

លោកមិនចូលចិត្តការកំណត់ថាកុមារតូចៗគួរតម្រូវឱ្យធ្វើការរយៈពេល៦ម៉ោង ឬ៨ ម៉ោងជាប់ៗគ្នានោះទេ។ គាត់ចង់ឱ្យកុមារគួរតែធ្វើការបួនម៉ោងក្នុងមួយថ្ងៃ និងចាស់ៗធ្វើការប្រាំមួយម៉ោងក្នុងមួយថ្ងៃ។ គ្មានកិច្ចការសាលា

(Homework) ធ្វើនៅផ្ទះទេ។ តារាងពេលវេលាសិក្សាប្រចាំថ្ងៃគួរតែមានការសម្រាកលំហែកន្លះម៉ោង។ ថ្ងៃឈប់សម្រាកគួរមានញឹកញាប់ ប៉ុន្តែមិនគួរផ្ដល់ឱ្យការអូសបន្លាយយូរទេ។ ការងារដែលទាមទារឱ្យមានបញ្ញា និងចងចាំកាន់តែច្រើនគួរតែត្រូវបានធ្វើឡើងនៅវេលាព្រឹក ហើយការងារធ្វើដោយដៃ, តន្ត្រី, ការអនុវត្តរបៀបរបប និងការប្រព្រឹត្តទៅនៃអាកប្បកិរិយាសំខាន់ៗគឺនៅពេលរសៀល។

**៣.៣.៤ ការបង្រៀននៅថ្នាក់រៀន**

មុនសម័យលោក ខូមេនៀស ប្រព័ន្ធនៃការបង្រៀននៅថ្នាក់គឺមិនមានទេ។ គ្រូមិនដឹងថាតើត្រូវបង្រៀនកុមារចំនួនប៉ុន្មាននាក់ក្នុងថ្នាក់រៀនក្នុងពេលតែមួយទេ។ សិស្សម្នាក់ៗត្រូវបង្រៀនដោយឡែកៗពីគ្នា។ វិធីសាស្ត្រនេះធ្វើឱ្យវឌ្ឍនភាពនៃការបង្រៀនយឺត។ ជាភារកិច្ចរបស់ ខូមេនៀស ក្នុងការបង្ហាញពីរបៀបដែលគ្រូតែម្នាក់អាចបង្រៀនកុមារច្រើននាក់ក្នុងថ្នាក់រៀនតែមួយក្នុងពេលតែមួយ។ គាត់នឹងពន្យល់លម្អិតពីវិធីសាស្ត្របង្រៀននេះជាបន្តបន្ទាប់។

**៣.៣.៥ សៀវភៅសិក្សាគោល**

នៅសម័យលោក ខូមេនៀស គ្មានភាពជាប់លាប់នៅក្នុងសៀវភៅសិក្សាគោលនោះទេ។ មានសៀវភៅតិចតួចណាស់ ហើយសៀវភៅសិក្សានោះមិនមានសម្រាប់កុមារទេ។ អត្ថបទដែលបានរកឃើញគឺបានប្រើប្រាស់ដោយក្មេងប្រុសដែលរៀនឡាតាំង។ លោកមិនចូលចិត្តការអនុវត្តបែបនេះទេ។ គាត់ចង់ឱ្យសិស្សម្នាក់ៗគួរមានច្បាប់ចម្លងអត្ថបទផ្ទាល់ខ្លួន ហើយរាល់អ្វីដែលត្រូវបង្រៀនក្នុងថ្នាក់រៀនគួរតែរកឃើញតាមរបៀបដែលបានរៀបចំនៅក្នុងសៀវភៅ។

**៣.៤ កម្មវិធីសិក្សា**

គ្មានអ្វីនៅស្ថានសួគ៌ ឬផែនដី ឬនៅក្នុងទឹក, គ្មានអ្វីនៅក្នុងជម្រៅក្រោមដី, គ្មានអ្វីនៅក្នុងរាងកាយមនុស្ស, គ្មានអ្វីនៅក្នុងព្រលឹង, គ្មានអ្វីនៅក្នុងគម្ពីរបរិសុទ្ធ, គ្មានអ្វីនៅក្នុងសិល្បៈ, គ្មានអ្វីនៅក្នុងសេដ្ឋកិច្ច, គ្មានអ្វីនៅក្នុងទម្រង់រដ្ឋ, គ្មានអ្វីនៅក្នុងសាសនា។ ដូច្នេះ លោកចង់បង្កើតកម្មវិធីសិក្សា និងក្នុងវិសាលភាពនៃសព្វវចនាធិប្បាយ។

ទោះយ៉ាងណា លោកមិនចង់ឱ្យខ្លឹមសារលម្អិតទាំងអស់នៃមុខវិជ្ជានីមួយៗយកធ្វើជាគ្រូ(master)នោះទេ។ គាត់ផ្ដល់អនុសាសន៍ថាមានតែចំណុចសំខាន់ៗ ឬគំនិតសំខាន់ប៉ុណ្ណោះ ដែលគួរយកធ្វើជាគ្រូនៅពេលដំបូង។ លោកជឿជាក់ថាតាមរយៈការដាក់ពិន្ទុយ៉ាងប្រុងប្រយ័ត្ន និងវិធីសាស្ត្រសមស្របគឺជួយជំរុញសិស្សឱ្យរៀនច្រើនជាងអ្វីដែលសាលាបង្រៀនពិតប្រាកដ។ ទាក់ទងទៅនឹងភាសា លោកចង់ផ្ដល់ការយកចិត្តទុកដាក់តិចតួចចំពោះភាសាឡាតាំង ភាសាក្រិក និងភាសាហេព្រូ ហើយយកចិត្តទុកដាក់ខ្លាំងចំពោះភាសាដើម។ លោកបានតស៊ូមតិដើម្បីឱ្យមានការសិក្សាភាសាបរទេសទំនើបសម្រាប់ជាប្រយោជន៍នៃការធ្វើទំនាក់ទំនងជាមួយអ្នកជិតខាង។

គាត់មិនពេញចិត្តចំពោះការបង្រៀនអ្នកនិពន្ធបុរាណនៅក្នុងសាលាទេ ពីព្រោះគាត់គិតថាសុខុមាលភាពខាងសីលធម៌ និងខាងស្មារតីរបស់សិស្សអាចប្រសើរឡើងដោយបង្វែរការយកចិត្តទុកដាក់របស់ពួកគេទៅសិក្សាមុខវិជ្ជាដែលមានតម្លៃជាងនេះ។ គាត់និយាយថា"ការខ្វះខ្វែងរបស់យើងក្នុងរឿងនេះបណ្ដាលមកពីសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះ និងមនុស្ស"។ គាត់គាំទ្រដោយសេចក្ដីគោរពចំពោះអ្នកនិពន្ធដូចជា ថឺរ៉េន(Terence), ប្លូទុស(Plautus), ស៊ីសេរ៉ូ(Cicero), អូវីដ(Ovid), កាទុលលុស(Catullus) និងទីប៊ូលលុស(Tibullus)។ លទ្ធផលនៃការគោរពនេះគឺធ្វើឱ្យយើងស្គាល់ពិភពលោកច្បាស់ជាងយើងស្គាល់ព្រះគ្រិស្ត។ ខូមេនៀស ចង់ឱ្យភាសាឡាតាំង និងភាសាដើមគួរតែត្រូវប្រើក្នុងការរៀនវេយ្យាករណ៍, វោហារសាស្ត្រ, វិចារវិទ្យា, នព្វន្ត,ធរណីមាត្រ, តារាសាស្ត្រ, តន្ត្រី, រូបវិទ្យា, ភូមិវិទ្យា, ប្រវត្តិសាស្ត្រ, សាសនា និងសីលធម៌។

ខូមេនៀស ទទួចថាសិល្បៈហត្ថកម្ម និងឧស្សាហកម្ម គួរដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សារបស់សាលាភាសា។ លោកពេញចិត្តសកម្មភាពរាងកាយ និងការលេងច្រើនដើម្បីជាប្រយោជន៍ដល់សុភមង្គល និងសុខភាព។ នេះជាយោបល់បដិវត្តបំផុតសម្រាប់អាយុរបស់គាត់។ ផ្ទុយពីជំនឿរបស់ពួកទេវនិយម, លោកគិតត្រឹមត្រូវពីការលេងរបស់កុមារថាជា"វិធីសាស្ត្រធម្មជាតិធ្វើឱ្យរាងកាយមានសុខភាពល្អ រឹងមាំ និងចិត្តមានការអភិវឌ្ឍខ្ពស់"។

ខូមេនៀស ចង់បង្កើតឱ្យមានការលេងសើច ឬកំប្លែងជាមធ្យោបាយអប់រំ។ គាត់ប្រកាសថាកុមារ "គួរតែត្រូវបង្រៀនយ៉ាងហ្មត់ចត់ ដើម្បីយល់ពីអ្វីដែលត្រូវនិយាយនៅក្នុងរឿងកំប្លែង"។ គាត់ចង់និយាយថា ការកំប្លែង ឬការលេងសើចគួរត្រូវប្រើដើម្បីពង្រឹងបញ្ញារបស់កុមារ។ អ្នកសម័យមុនលោកគ្មានអ្នកអប់រំណាបង្ហាញការយល់ដឹងបែបនេះទេ។ គាត់ចូលចិត្តបង្រៀនអ្វីគ្រប់យ៉ាងសម្រាប់ភាពមានប្រយោជន៍នៅក្នុងជីវិត។ គ្មានអ្វីដែលគួររៀនក្រៅតែពីតម្លៃរបស់វានៅសាលារៀននោះទេ ប៉ុន្តែសម្រាប់ការប្រើប្រាស់នៅក្នុងជីវិត។ ទោះយ៉ាងណា នេះមិនបានន័យថាគាត់ជាមនុស្សប្រយោជន៍និយមនោះទេ។

## ៣.៥ វិធីសាស្ត្របង្រៀន

គេចាត់ទុកលោកជាស្ថាបនិកពិតប្រាកដនៃវិធីសាស្ត្របង្រៀនទំនើប។ គាត់ជាអ្នកប្រឆាំងនឹងវិធីសាស្ត្រដែលបានប្រើក្នុងសាលារៀននៅជំនាន់គាត់ដោយគេមើលឃើញថាសាលារៀនជាកន្លែងគួរឱ្យភ័យខ្លាចចំពោះកុមារ និងជាអ្នកសម្លាប់គំនិតដែលនៅក្នុងនោះមានសិស្សដ៏ច្រើនមិនចូលចិត្តរៀន។ អស់រយៈពេលពី៥ឆ្នាំទៅ១០ឆ្នាំ ឬច្រើនជាងនេះ ពួកគេបានឃុំឃាំងគំនិតរបស់សិស្សដែលអាចស្ទាត់ជំនាញលើបញ្ហាអ្វីមួយ។

លោក ខូមេនៀស ចែកចាយការបង្រៀនដោយ "ជឿជាក់និងហ្មត់ចត់, ប្រាកដនិងច្បាស់, ងាយស្រួលនិងរីករាយ"។ ដូច្នេះ គាត់វិភាគដោយយកចិត្តទុកដាក់ចំពោះគោលការណ៍ដែលជួយធ្វើឱ្យសម្រេចបានលទ្ធផលនេះ។ លោកបានកំណត់វិន័យជាក់លាក់នៃការបង្រៀនដោយបញ្ជាក់ដូចខាងក្រោមនេះ៖

- ជាបឋមពិចារណាលើចំណាប់អារម្មណ៍ពីធម្មជាតិរបស់កុមារ។ គ្មានអ្វីត្រូវបង្រៀនដល់ពួកគេទេ បើមិនទាក់ទងនឹងចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់ពួកគេ។
- ត្រូវតែបង្ហាញដោយផ្ទាល់នៅចំពោះមុខកុមារអំពីអ្វីដែលត្រូវបង្រៀន។ មិនចាំបាច់ប្រើការពន្យល់ទាំងស្រុង (Round explanation)នោះទេ។
- បន្ទាប់ពីពន្យល់គោលការណ៍ទូទៅ ព័ត៌មានលម្អិតគួរយកមកពិចារណា។
- គ្រូបង្រៀនមិនគួរបន្តទៅមុខទៀតនោះទេ លើកលែងតែប្រធានបទនោះសិស្សយល់បានយ៉ាងល្អរួចហើយ។
- ភាពទាក់ទងគ្នា និងការវែកញែក គួរតែចង្អុលបង្ហាញដើម្បីទទួលបានពុទ្ធិច្បាស់លាស់។
- ការអប់រំដំបូងដែលគួរផ្ដល់ឱ្យគឺជាអ្វីដែលអនុវត្តជាក់ស្ដែងនៅក្នុងជីវិតរស់នៅ។
- អ្វីៗដែលត្រូវបង្រៀនគឺត្រូវធ្វើតាមលំដាប់លំដោយ មានតែរឿងមួយទេដែលត្រូវបង្រៀនក្នុងពេលតែមួយ។
- គ្រូគួរចាប់ផ្ដើមពីអ្នកដែលដឹង(ចេះ) បន្ទាប់មកទើបទៅអ្នកមិនដឹង(មិនចេះ)។
- ឥន្ទ្រីយ៍, មនោគតិ, ការយល់ដឹង និងអង្គចងចាំ គួរតែប្រតិបត្តិជារៀងរាល់ថ្ងៃដោយការតភ្ជាប់ជាមួយគ្នា។
- លើកទឹកចិត្តកុមារឱ្យរៀនដោយការធ្វើ។
- ការបង្រៀនដែលត្រូវផ្ដល់ឱ្យកុមារគួរតែស្ថិតនៅក្នុងដែនសមត្ថភាពនៃការយល់ដឹងរបស់កុមារ និងអំណាចរបស់កុមារ។
- ពាក្យមិនត្រូវនិយាយឡើងវិញទេ។
- សម្ភារៈឧបទេស, វត្ថុ និងសកម្មភាពគួរផ្សារភ្ជាប់ជាមួយនឹងពាក្យសម្ដី។
- អ្វីដែលត្រូវរៀនគួរប្រាប់សិស្សម្នាក់ទៅសិស្សម្នាក់ទៀត ដូច្នេះ គ្មានចំណេះដឹងណាមួយដែលមិនបានប្រើប្រាស់ទេ។ លោកចង់លើកទឹកចិត្តសិស្សឱ្យប្រាប់អ្នកដទៃអំពីអ្វីដែលពួកគេបានរៀន ពីព្រោះលោកជឿជាក់ថាការបង្រៀនអ្នកដទៃគឺជាឧបករណ៍ដ៏ល្អបំផុតសម្រាប់ការបញ្ជាក់ និងដោះស្រាយនូវអ្វីដែលពួកគេកំពុងរៀន។
- សម្ភារៈឧបទេសដែលបានរៀនរួចហើយគួរដាក់បញ្ចូលគ្នា និងបញ្ជ្រាបឱ្យបានត្រឹមត្រូវ។ គោលការណ៍នៃការបញ្ជ្រាបនេះ លោកជឿជាក់ថាការបណ្ដុះបណ្ដាលទាំងអស់ផ្ដល់នូវទម្រង់មិនត្រឹមតែសម្ភារៈប៉ុណ្ណោះទេ ប៉ុន្តែដើម្បីភាពជាខ្លួនឯងរបស់សិស្សផងដែរ។

សម្រង់ទាំងអស់នេះ គឺជាគោលការណ៍ និងវិធាននៃវិធីសាស្ត្រដែលលោកបានពិពណ៌នាជាចម្បងនៅក្នុងស្នាដៃការបង្រៀនដ៏អស្ចារ្យ (The Great Didactic)។ គាត់មិនត្រឹមតែជាអ្នកទ្រឹស្តីប៉ុណ្ណោះទេ ប៉ុន្តែក៏ជាអ្នកអនុវត្តផងដែរ។ លោកបានសាកល្បងសុពលភាពនៃគោលការណ៍ និងច្បាប់របស់គាត់ក្នុងថ្នាក់ជាក់ស្តែង។ គាត់ជឿថាការអនុវត្តវិធីសាស្ត្រនេះនឹងធ្វើឱ្យសាលាក្លាយជាកន្លែងមានសុភមង្គល និងរីករាយដែលជំនួសឱ្យទីកន្លែងដ៏ធុញទ្រាន់។

**៣.៦ មុខងារសង្គម**

ចំពោះ ខូមេនៀស យល់ថាការអប់រំមានមុខងារសង្គម។ សេចក្តីស្រឡាញ់ជាចំណែកផ្ទាល់នៃចំណេះដឹង។ ដូចដែលលោកនិយាយនៅក្នុងការបង្រៀនដ៏អស្ចារ្យ (The Great Didactic) "គ្រាប់ពូជចំណេះដឹង គុណធម៌ និងការគោរពសាសនាបានបង្កប់ដោយធម្មជាតិក្នុងខ្លួនយើង"។ គាត់កំណត់ថាមនុស្សជាសត្វដែលអាចបង្រៀនបាន។ លោក ខូមេនៀស យល់ថាការអប់រំមិនមែនជាការទទួលយកអតីតកាលទេ ប៉ុន្តែជាការប្រមើលមើលទៅអនាគត។ ក្នុងនាមជាអ្នកគិតអំពីភពក្សេមក្សាន្ត (Utopian thinker) គាត់ជំរុញឱ្យមានកំណែទម្រង់នៅក្នុងរដ្ឋាភិបាល និងផ្នែកសេដ្ឋកិច្ច។ ដរាបណាប្រជាជាតិនានាធ្វើសង្គ្រាមនឹងគ្នា នោះវាអាចមានការរីកចម្រើនតិចតួច។ គាត់រង់ចាំសៀវភៅសកល, ការអប់រំសកល, ភាសាសកល និងសាលារៀនសកល។ សព្វថ្ងៃយើងមានអង្គការសហប្រជាជាតិជាវេទិកាសម្រាប់សន្តិភាព ប៉ុន្តែ យើងនៅតែឃ្លាតឆ្ងាយពីក្តីសុបិនរបស់លោក ខូមេនៀស ដែលជំរុញឱ្យមានឯកភាពពិភពលោកពិតប្រាកដ។

លោក ខូមេនៀស ដឹងថាការអប់រំបានទទួលការគំរាមកំហែងដោយសារជាតិនិយម និងភាពរើសអើង, អំពើហិង្សានិងភាពល្ងង់ខ្លៅ វាមាននៅគ្រប់ទីកន្លែង ហើយវាគំរាមកំហែងដល់ការរីកចម្រើនរបស់មនុស្សជាតិ។ យើងអាចទទួលបានការអប់រំដោយអំពើហិង្សា ឬដោយសន្តិភាព។ ជាធម្មតាអំពើហិង្សាបង្កើតឱ្យមានទំនាស់កាន់តែច្រើន ដូចដែលលោកជួបប្រទះក្នុងជីវិតផ្ទាល់ខ្លួន។ សម្រាប់ការអប់រំពិតប្រាកដ សន្តិភាពមិនមែនជាប្រណីតភាពទេ ប៉ុន្តែជាតម្រូវការចាំបាច់។ ចំណេះដឹងអាចទទួលបាន មានតែនៅក្នុងបរិយាកាសសន្តិភាពតែប៉ុណ្ណោះ មានតែនៅក្នុងគ្រាសន្តិភាពប៉ុណ្ណោះដែលវិចារណញ្ញាណដុះដាលបាន។ លោកជំរុញមនុស្សដែលមានឆន្ទៈល្អឱ្យរួបរួមគ្នា; គ្រូបង្រៀន, រដ្ឋមន្ត្រី, រដ្ឋបុរស និងអ្នកជំនួញត្រូវបង្កើតសង្គមដោយផ្អែកលើសេចក្តីស្រឡាញ់ និងសប្បុរស។ ការប្រកួតប្រជែងរបស់មនុស្សគឺត្រូវបានពង្រឹង, គំនិតច្នៃប្រឌិតដ៏ពិតប្រាកដនៃជីវិតត្រូវបានបង្កើតឡើង។ លោកចង់ឱ្យមានថវិកាបន្ថែមទៀតសម្រាប់សាលារៀនព្រោះជាការវិនិយោគដ៏ល្អបំផុតក្នុងសង្គមជាពិសេសចំពោះគ្រូបង្រៀន និងជាជំនួយសម្រាប់ការបង្រៀន ជាពិសេសសៀវភៅសិក្សាគោលត្រូវផ្តល់ឱ្យដោយសេរី។

លោក ខូមេនៀស គឺជាអ្នកអប់រំដំបូងគេដែលបង្កើតវិធីសាស្ត្រអប់រំជាផ្លូវការ។ គាត់បានណែនាំ និងធ្វើកំណែទម្រង់សំខាន់ៗក្នុងការបង្រៀនភាសា។ លោកចាប់ផ្តើមនៅក្នុងសាលារៀនដែលរៀនពីធម្មជាតិ។ គាត់តស៊ូមតិដោយភាពវៃឆ្លាត និងមិនផ្អែកលើមនោសញ្ចេតនាសុទ្ធសាធនោះទេគឺជាវិន័យស្រាលៗ។ លោកគាំទ្រដល់កម្មវិធីអប់រំបែបប្រជាធិបតេយ្យហើយលុបចោលការបែងចែកវណ្ណៈ។ ប៉ុន្តែ កម្មវិធីរបស់គាត់គឺស្ថិតនៅក្នុងយុគសម័យដែលជឿលើសិទ្ធិអំណាចរបស់ស្តេច។ នោះជាមូលហេតុដែលកម្មវិធីរបស់គាត់មិនអាចទទួលយកបានក្នុងសម័យនោះ។ ទោះយ៉ាងណា គេទទួលស្គាល់គាត់ថាបានដាក់គ្រាប់ពូជបង្កើតជាកំណែទម្រង់ការអប់រំដ៏អស្ចារ្យនៅក្នុងសតវត្សបន្តបន្ទាប់។ នេះជាភាពអស្ចារ្យពិតប្រាកដរបស់លោក ខូមេនៀស៕

# មេរៀនទី៤ ទស្សនវិជ្ជា និងទ្រឹស្តីអប់រំរបស់លោក ស្ពីណូហ្សា

លោក ស្ពីណូហ្សា គឺជាទស្សនវិទូជនជាតិហូឡង់ដែលត្រូវបានគេចាត់ទុកថាជាមនុស្សម្នាក់នៅក្នុងចំណោមនៃអ្នកវិចារណនិយមដ៏អស្ចារ្យនៅសតវត្សរ៍ទី១៧។

លោក ស្ពីណូហ្សា កើតនៅទីក្រុងអាំស្ទ័រដាម (Amsterdam) នៅក្នុងឆ្នាំ១៦៣២ ក្នុងគ្រួសារមួយដែលជាជនចំណាកស្រុកជ្វីបដែលភៀសខ្លួនពីការធ្វើទុក្ខបុកម្នេញនៅប្រទេសព័រទុយហ្គាល់។ គាត់ជាជនជាតិអេស្ប៉ាញ-ជ្វីប (Spanish Jew) រស់នៅប្រទេសហូឡង់។ លោកទទួលយកគំនិតរបស់លោក រីណេ ដេកាត(René Descartes) ដែលថាសាកលលោកត្រូវបានបែងចែកទៅជាចិត្តឬគំនិត និងរូបធាតុ។ ប៉ុន្តែ លោកមើលឃើញថាប្រសិនបើចិត្តឬគំនិត និងរូបធាតុជាសារធាតុដាច់ដោយឡែកពីគ្នា ពួកវាមិនអាចទាក់ទងគ្នាបានទេ។ លោកពោលថា សុភមង្គលខ្ពស់បំផុតរបស់មនុស្សគឺការឈ្វេងយល់អំពីភាពរួមរបស់សច្ចភាព ពីព្រោះពួកវាគឺជាផ្នែកតូចមួយរបស់ព្រះតែមួយគត់។ ទ្រឹស្តីប៉ង់តេអ៊ីសនិយម (Pantheism) មានជំនឿថាអ្វីៗទាំងអស់គឺជាព្រះ ហើយព្រះគឺអ្វីៗទាំងអស់ (all is God and God is all)។

## ៤.១ គំនិត និងន័យពង្រីក

នៅក្នុងទម្រង់ធរណីមាត្រ អនុមានញែក និងនៅក្នុងសៀវភៅភាគទី២ស្តីអំពីសីលវិជ្ជា លោក ស្ពីណូហ្សា ស្នើឱ្យពង្រីកការទំនួលខុសត្រូវរបស់មនុស្ស, អត្ថិភាពរបស់មនុស្ស, ធម្មជាតិ និងសកម្មភាពរបស់មនុស្ស។ សូមចាំថាមនុស្សអាចយល់ដឹងពីលក្ខណៈសម្បត្តិរបស់ព្រះបានតែពីរយ៉ាងក្នុងចំណោមលក្ខណៈសម្បត្តិជាច្រើនរបស់ព្រះអង្គនោះគឺន័យពង្រីក និងគំនិត។ ចំណុចទាំងពីរនេះបង្ហាញពីឯករាជ្យភាពនៃសារជាតិគ្មានព្រំដែនកំណត់របស់រូបធាតុ។

ក្នុងពិភពធម្មជាតិ រាងកាយព្រះ គុណសម្បត្តិពង្រីកវិសាលភាពរបស់ទ្រង់មានកម្រិតដោយឡែកពីគ្នាដែលបញ្ជាក់ដោយកម្រិតចលនា និងការឈប់ស្ងៀម។ វាបង្កើតសកលលោក ហើយភាវៈទាំងអស់មានចលនាយ៉ាងពិសេស (ស្រដៀងនឹងទស្សនៈស្តីពីពិភពរូបធាតុរបស់ដេកាត)។

នៅក្នុងផ្នែកផ្លូវចិត្ត គំនិតរបស់ព្រះជាម្ចាស់ គុណសម្បត្តិនៃការគិតរបស់ព្រះអង្គ បានបញ្ជាក់ដោយបញ្ញា គ្មានព្រំដែនកំណត់ បង្កើតសច្ចភាព ព្រមទាំងព្រឹត្តិការណ៍ផ្លូវចិត្តនានាដែលជាចលនានៃការគិតពិចារណាផងដែរ។ អ្វីៗដែលបានកើតចេញពីគុណសម្បត្តិនៃការគិតពិចារណានៅក្នុងវិស័យនីមួយៗគឺមានលក្ខណៈឯករាជ្យពីវិស័យផ្សេងទៀត និងមានលក្ខណៈខ្លួនឯងទាំងស្រុងដែលលោកបានហៅវាថាអត្តៈ (Self-Contained)៖ ពិភពធម្មជាតិ និងផ្នែកផ្លូវចិត្តគឺជាប្រព័ន្ធបិទជិតដោយឡែកពីគ្នា។

ទោះជាលក្ខណៈទាំងពីរនេះមិនអាចធ្វើអន្តរកម្មរវាងគ្នាក៏ដោយ ក៏លោក ស្ពីណូហ្សា សន្មតថាគុណសម្បត្តិឯករាជ្យរបស់វាទាំងពីរនេះត្រូវស្របគ្នាយ៉ាងល្អឥតខ្ចោះជាមួយគុណសម្បត្តិមួយផ្សេងទៀត។ "សណ្តាប់ធ្នាប់ និងការតភ្ជាប់គំនិតគឺដូចគ្នានឹងសណ្តាប់ធ្នាប់ និងការតភ្ជាប់គ្នានៃវត្ថុដែរ"។ ដូច្នេះ ប្រាកដណាស់ថា ជាសណ្តាប់ធ្នាប់និងការតភ្ជាប់គ្នានៃគុណសម្បត្តិរបស់ព្រះអង្គ។ ចាប់តាំងពីការវិវឌ្ឍនៃទិដ្ឋភាពធម្មជាតិរបស់ព្រះដោយអនុលោមទៅតាមទម្រង់នៃតក្កវិជ្ជាដែលបានដកចេញពីគុណសម្បត្តិជាមូលដ្ឋានរបស់ព្រះអង្គ។ ផ្ទុយមកវិញ គុណសម្បត្តិទាំងអស់នេះគឺកើតចេញមកពីចំណុចស្នូលនៃភាវៈ និងរូបធាតុទាំងឡាយដែលគ្មានដែនកំណត់។ រូបធាតុនីមួយៗមានលក្ខណៈសម្បត្តិ និងរបៀបរបបនៃការរៀបចំរបស់វាដូចគ្នា ទោះបីជាវាមិនមានឥទ្ធិពលលើគ្នាក៏ដោយ។

ហេតុដូច្នេះហើយ កម្មវត្ថុទាំងអស់របស់ពិភពធម្មជាតិដែលមានអត្ថិភាព ដូចជាមានរបៀបពង្រីកវិសាលភាពនិងគុណសម្បត្តិរបស់ខ្លួនដូចនឹងគុណសម្បត្តិរបស់ព្រះដែរ ប៉ុន្តែ មានគំនិតឆ្លើយតបទៅនឹងគំនិតរបស់ព្រះថាវាជាគំរូនៃការគិតពិចារណា។ គ្រប់រូបរាងកាយដែលកើតមានឡើងនៅក្នុងពិភពរូបធាតុ ជាលទ្ធផលនៃបុព្វហេតុទាំងអស់ ហើយការឆ្លើយតបរបស់វាទៅនឹងព្រឹត្តិការណ៍ផ្លូវចិត្តត្រូវបង្កើតឡើងដោយបញ្ញាដែលគ្មានព្រំដែននេះគឺជាលទ្ធផល

នៃបុព្វហេតុផ្លូវចិត្តសុទ្ធសាធ។ ដោយសារអ្វីគ្រប់យ៉ាងកើតចេញពីលំហូរនៃភាវៈគ្មានព្រំដែនដូចៗគ្នាបែបនេះ យើងអាចសន្និដ្ឋានថា រចនាសម្ពន្ធនៃការគិតត្រិះរិះពិចារណាដែលមាននៅក្នុងបញ្ញាក៏តំណាងឱ្យភាពត្រឹមត្រូវនៃរចនាសម្ពន្ធគំនិតផ្សេងទៀតផងដែរ។

## ៤.២ ស្មារតី និងរាងកាយ

សូមធ្វើការពិចារណាថា តើអ្វីៗទាំងអស់បង្កប់អត្ថន័យសម្រាប់យើងរស់នៅក្នុងនាមជាភាវៈមនុស្សអ្វីខ្លះ? បើយោងទៅតាមលោក ស្ពីណូហ្សា យើងមិនមែនជាអង្គធាតុទេ ប៉ុន្តែយើងជាភាវៈមួយសម្រាប់តែអាទិទេពប៉ុណ្ណោះ ឬធម្មជាតិដែលជាអង្គធាតុពិតប្រាកដមួយ។ យើងមានអត្ថិភាពគ្រាន់តែក៏ជាគំរូមួយដោយផ្អែកលើអត្ថិភាពរបស់យើង អាស្រ័យទៅលើសច្ចភាពនៃភាវៈដែលមានរូបរាងពិតប្រាកដមួយ។ ដោយសាររូបធាតុគ្មានដែនកំណត់ ហើយរូបធាតុគឺជាបុព្វហេតុនៃអ្វីៗទាំងអស់ ហេតុនេះហើយគេបានចាត់ទុកថាយើងម្នាក់ៗគឺជាផ្នែកតូចមួយនៃផ្នែកទាំងមូលនៃរូបធាតុទាំងនោះ។

ជាការពិតខ្លាំងណាស់ ឈើឆ្កាងមានធាតុច្រើនដែលបានដកចេញពីគុណសម្បត្តិរូបធាតុ។ ជាពិសេសយើងបានដឹងថាករណីនីមួយៗវាពាក់ព័ន្ធជាមួយរូបរាងកាយមនុស្សហើយផ្នែកផ្សេងៗទៀតនៃចលនាសរីរាង្គរបស់មនុស្សគឺជាព្រឹត្តិការណ៍រូបរាងកាយដែលបង្ហូរចេញពីព្រះជាម្ចាស់តាមរយៈការពង្រីកគុណសម្បត្តិរបស់ព្រះអង្គ ហើយស្មារតីរបស់មនុស្ស ព័ត៌មាននៃស្មារតីមនុស្សទាំងអស់គឺជាព្រឹត្តិការណ៍ផ្លូវចិត្តដែលបានហូរចេញមកពីព្រះអង្គតាមរយៈគុណសម្បត្តិនៃការគិតពិចារណារបស់ព្រះជាម្ចាស់។ ទោះបីជាមិនអាចមានបុព្វហេតុអន្តរកម្មរវាងចិត្ត និងរូបរាងកាយក៏ដោយក៏សណ្តាប់ធ្នាប់ និងការតភ្ជាប់សមាសធាតុខាងក្នុងរបស់ស្មារតី និងរូបរាងកាយតែងតែមានទំនាក់ទំនងគ្នាយ៉ាងល្អឥតខ្ចោះផងដែរ។

ដូច្នេះ ជាគោលការណ៍ស្មារតីមនុស្សផ្ទុកនូវគំនិតជាច្រើនដែលតំណាងឱ្យផ្នែកផ្សេងៗទៀតនៃរូបរាងកាយរបស់មនុស្សយ៉ាងល្អឥតខ្ចោះ។ ប៉ុន្តែដោយសារស្មារតីទាំងនេះមិនទាន់មានគ្រប់គ្រាន់នៅក្នុងវិញ្ញាណមនុស្សពីព្រោះតែមនុស្សមិនអាចនាំយកមកជាមួយខ្លួននូវសញ្ញាខាងក្នុងឱ្យបានត្រឹមត្រូវ ដូចនេះយើងមិនចាំបាច់ស្គាល់រូបរាងកាយរបស់យើងទេ។

ឧទាហរណ៍ ប្រសិនបើវាស្ថិតក្នុងស្មារតីរបស់ខ្ញុំ ហើយឆ្លើយតបនឹងស្ថានភាពសរីរាង្គកាយពិសេសនៃខួរឆ្អឹងខ្នងរបស់ខ្ញុំ ប៉ុន្តែ នៅពេលខ្ញុំមិនយល់ពីទំនាក់ទំនងរបស់សារពាង្គកាយជាមួយស្មារតីរបស់ខ្ញុំ ក៏ជាហេតុដែលធ្វើឱ្យខ្ញុំយល់មិនច្បាស់ពីកម្មវត្ថុដែលតំណាងឱ្យវានោះដែរ។

## ៤.៣ ពុទ្ធិរបស់មនុស្ស

ស្ពីណូហ្សា (Spinoza) អះអាងថាមនុស្សបានធ្វើការបង្កើតសមត្ថភាព ហើយមុខងាររបស់សមត្ថភាពនោះគឺសម្រាប់ការផ្តល់ពុទ្ធិដល់មនុស្សលោក។ លោក ស្ពីណូហ្សា បានគិតថាទំនាក់ទំនងរវាងគំនិត និងន័យពង្រីកជាប់ទាក់ទងជាមួយសកម្មភាពនៃប្រត្យក្សារម្មណ៍ ភ្នែក ត្រចៀក និងការប៉ះពាល់ដោយផ្ទាល់។ លោកពោលថានៅក្នុងអង្គចងចាំរបស់លោកលេចចេញនូវភស្តុតាងមួយចំនួននៃបទបញ្ញា និងការតភ្ជាប់គ្នារវាងវត្ថុនិងគំនិត។ ការយល់ដឹងអំពីខ្លួនឯង (Self-conscious awareness) លោកហាក់ដូចជាទទួលបាននូវចំណេះដឹងពិតប្រាកដអំពីខ្លួនឯងតំណាងឱ្យគំនិតខ្លួនឯង ហើយលោកប្រើគំនិតនោះដើម្បីបង្ហាញនូវគំនិតផ្សេងទៀតរបស់លោកទៀតផងដែរ។

នៅពេលជិតបញ្ចប់សៀវភៅភាគទី២ លោក ស្ពីណូហ្សា បានបែងចែកពុទ្ធិជាបីប្រភេទគឺៈ

- ពុទ្ធិជាមតិ ឬជាយោបល់ (Opinion)ៈ ពុទ្ធិនេះអាចទទួលបានតាមរយៈបទពិសោធមិនច្បាស់លាស់ ឬទទួលបានពីសញ្ញាណនៃពាក្យនៅក្នុងអង្គចងចាំ ឬការស្រមើស្រមៃ ឬបទពិសោធផ្តល់គំនិតមិនទាន់បានគ្រប់គ្រាន់ និងមិនអាចពឹងផ្អែកលើប្រភពសច្ចភាពបាន។

- ពុទ្ធិវិចារណញ្ញាណ (Reason)៖ ចាប់ផ្តើមដោយគំនិតសាមញ្ញ និងការវិភាគហេតុផល ឬដំណើរទៅរកភាពសមហេតុផលបែបតក្កវិជ្ជាដើម្បីយល់ដឹងពីបុព្វហេតុទូទៅនៃបញ្ហាថាតើវាផ្តល់ឱ្យយើងពីការពិតដែរឬទេ។

- ពុទ្ធិអព្ភន្តរញាណ(Intuition )៖ វាដកចេញពីចិត្ត ឬស្មារតី និងញែកចេញពីរចនាសម្ពន្ធសំខាន់ៗរបស់តថភាព(Structure of Reality) ឬជាគោលគំនិតសំខាន់ៗរបស់ព្រះជាម្ចាស់។ អព្ភន្តរញាណ គឺជាប្រភពដ៏អស្ចារ្យនៃគំនិត ជាទម្រង់ខ្ពស់បំផុតនៃចំណេះដឹង និងជាអ្នកជានាសច្ចភាពចុងក្រោយផងដែរ។

ស្ពីណូហ្សា ចាត់ទុកចំណេះដឹងដែលទទួលបានពីវិចារណញ្ញាណ ឬវិទ្យាសាស្ត្រ គឺជាពុទ្ធិដែលមានឥទ្ធិពល និងគួរឱ្យចង់បានបំផុត ដូច្នេះហើយ ទើបវាប្រសើរជាងហេតុផល។ ហេតុនេះ លោក ស្ពីណូហ្សា បញ្ជាក់ថាគុណធម៌ដ៏ធំបំផុតនៃចិត្ត និងភាពឥតខ្ចោះរបស់មនុស្សគឺការយល់ដឹងអំពីវត្ថុតាមរយៈចំណេះដឹងវិចារណញ្ញាណនេះ ទោះយ៉ាងណា ហេតុផលចាំបាច់ដើម្បីដឹកនាំជីវិតឱ្យមានសុភមង្គលសម្រាប់ ស្ពីណូហ្សា វាមិនអាចឈានដល់សុភមង្គល និងពរជ័យចុងក្រោយបាននោះទេ។

ស្ពីណូហ្សា ផ្តល់អនុសាសន៍ និងដំណើការបើជំហានសម្រាប់ធ្វើឱ្យសម្រេចបាននូវចំណេះដឹងរបស់មនុស្សគឺ៖

ទីមួយ៖ គេមិនត្រូវយកចិត្តទុកដាក់តែលើសក្ខីកម្មដែលមិនត្រឹមត្រូវនៃផ្លូវអារម្មណ៍ និងការរៀនធម្មតាទេ។

ទីពីរ៖ ផ្តើមចេញពីគំនិតចំពោះវត្ថុដែលមានអត្ថិភាពស្រាប់ដោយត្រឡប់ទៅមើលពីអ្វីដែលព្រះជាម្ចាស់បានបង្កើតមកឱ្យនោះ។

ទីបី៖ ប្រើប្រាស់ចំណេះដឹងខ្លឹមដែលអាទិទេពផ្តល់ឱ្យដើម្បីធ្វើវិចារពីអ្វីផ្សេងៗទៀតដែលមានអត្ថិភាព ឬនឹងមានអត្ថិភាព។ តាមពិតទៅ ស្ពីណូហ្សា គិតថាសីលធម៌គឺជាលំហាត់មួយសម្រាប់ស្វែងរកចំណេះដឹងចុងក្រោយ។

## ៤.៤ សកម្មភាព អំពើល្អ និងសេរីភាព

ក្នុងសៀវភៅបីចុងក្រោយរបស់ ស្ពីណូហ្សា ស្តីអំពីសីលវិជ្ជាគឺបានពិពណ៌នាអំពីរបៀបរស់នៅមួយប្រកបទៅដោយភាពខ្ជាប់ខ្ជួនដោយយោលទៅតាមគោលការណ៍របស់លោក។ លទ្ធផលនៃអាកប្បកិរិយារបស់មនុស្សម្នាក់ៗគឺបានកើតចេញពីបំណងប្រាថ្នា ឬប្រត្យក្សារម្មណ៍នៃការឈឺចាប់ដូចជាប្រភេទនៃព្រឹត្តិការណ៍ណាមួយ។ ដូច្នេះចាំបាច់ត្រូវតែកើតចេញពីការគិតពិចារណា អំពីបញ្ហា ឬអំពីរូបធាតុដែលស្ថិតនៅខាងក្រៅ និងវិសាលភាពរបស់វា។ ប៉ុន្តែ ស្ពីណូហ្សា(Spinoza) ក៏បានធ្វើការចង្អុលបង្ហាញពីភាពខុសគ្នានៃបុព្វហេតុសំខាន់ៗពីរប្រភេទផងដែរគឺ៖

បំណងប្រាថ្នា(ចំណង់)៖ នៅពេលខ្លះលោក ស្ពីណូហ្សា មិនយល់ដឹងពីបុព្វហេតុទាំងអស់ឡើយពាក់ព័ន្ធជាមួយនឹងអ្វីដែលលោកធ្វើនោះ។ បុព្វហេតុនៃបំណងប្រាថ្នាបានគ្របដណ្តប់ទៅលើលោកផ្ទាល់ដោយកម្លាំងតណ្ហា។ ប៉ុន្តែ នៅមានពេលខ្លះទៀត លោកមានចលករចំណេះដឹងគ្រប់គ្រាន់ជាមួយនឹងអ្វីដែលលោកធ្វើដឹងខុសដឹងត្រូវ និងអាចចូលរួមធ្វើសកម្មភាពទាំងនោះដោយអស់ពីកម្លាំងកាយ កម្លាំងចិត្ត ពីព្រោះលោកបានស្គាល់ច្បាស់ពីទីតាំងរបស់ខ្លួនលោកនៅក្នុងស្ថានភាពជាក់ស្តែងមួយពិតប្រាកដ។

ប្រត្យក្សារម្មណ៍នៃការឈឺចាប់៖ វាជាគំរូនៃតម្លៃសីលធម៌ដែលមាននៅក្នុងប្រព័ន្ធរបស់លោក ស្ពីណូហ្សា។ អ្វីដែលល្អ ឬអ្វីដែលអាក្រក់ នោះវាគ្រាន់តែជាអ្វីមួយដែលបម្រើ ឬជាការរារាំងផលប្រយោជន៍ឱ្យជីវិតក្នុងរយៈពេលវែងតែប៉ុណ្ណោះ។

ចាប់តាំងពីសកម្មភាពរបស់លោកកើតចេញពីអារម្មណ៍ ឬបំណងប្រាថ្នា លោកតែងធ្វើអ្វីដែលលោកជឿថាជាអំពើល្អ ហើយវានឹងក្លាយទៅជាការពិត ប្រសិនបើលោកមានគំនិតគ្រប់គ្រាន់ពីអ្វីៗគ្រប់យ៉ាងដែលពាក់ព័ន្ធ។ បន្ទាប់មកអ្វីដែលល្អបំផុតសម្រាប់ជីវិតមនុស្សនោះគឺមនុស្សត្រូវយល់ដឹងពីទីតាំងរបស់ខ្លួនដែលមាននៅក្នុងរចនាសម្ពន្ធនៃចក្រវាលនេះក៏ដូចជាអ្វីៗដែលមាននៅក្នុងខ្លឹមសារ និងធម្មជាតិរបស់ព្រះផងដែរ។

ប៉ុន្តែ តើយើងអាចនិយាយបានយ៉ាងដូចម្តេចខ្លះពីទំនួលខុសត្រូវខាងផ្នែកសីលធម៌នៅពេលដែលសកម្មភាពរបស់មនុស្សត្រូវបានកំណត់ដោយភាពតឹងរឹងជាទីបំផុត? សូមចងចាំថា ចំពោះលោក ស្ពីណូហ្សា សេរីភាព គឺជា

ការប្តេជ្ញាចិត្តដោយខ្លួនឯង។ ដូច្នេះ នៅពេលលោកទទួលបានចំណេះដឹងគ្រប់គ្រាន់ពីអារម្មណ៍ និងបំណងប្រាថ្នារបស់ខ្លួនដែលជាបុព្វហេតុនៃសកម្មភាពខាងក្នុងរបស់លោក។ នៅពេលដែលលោកយល់ដឹងពីមូលហេតុដែលលោកត្រូវធ្វើ នៅពេលនោះលោកពិតជាមានសេរីភាព។

ជាមួយគ្នានេះផងដែរ លោក ស្ពីណូហ្សា (Spinoza) ក៏បានពោលបញ្ជាក់បន្ថែមទៀតថា ទោះបីលោកមិនអាចធ្វើការផ្លាស់ប្តូរមធ្យោបាយនៅក្នុងការគិតក៏ដោយ ក៏លោកមិនមានសង្ឃឹមថានឹងទទួលបានរង្វាន់នោះដែរ។ លោកត្រូវតែបន្តរស់នៅ និងធ្វើសកម្មភាពដោយភាពជឿជាក់ថាលោកជាសមាសធាតុដ៏ចាំបាច់ដែលមិនចេះរីងស្ងួត និងសំខាន់បំផុតជាងនេះទៀត។ នៅលើវិថីនៃជីវិតនេះប្រហែលមិនមែនជាការងាយស្រួលនោះឡើយ "ក៏ប៉ុន្តែ អ្វីដែលថ្លៃថ្នូរ គឺពិតជាពិបាក និងកម្ររកឃើញណាស់"៕

# មេរៀនទី៥ ទស្សនវិជ្ជា និងទ្រឹស្តីអប់រំរបស់លោក ហេហ្គែល

ហេហ្គែល (១៧៧០-១៨៣១) បានចំណាយពេលភាគច្រើនក្នុងជីវិតធ្វើជាអ្នកអប់រំ។ នៅចន្លោះឆ្នាំ១៧៩៤ និងឆ្នាំ១៨០០ គាត់ជាគ្រូឯកជន, បង្រៀនដំបូងនៅប៊ឺន(Bern)ប្រទេសស្វីស បន្ទាប់មកនៅហ្វ្រង់ហ្វឺត អាមម៉ែន (Frankfurt-am-Main)។ លុះក្រោយមកចាប់ផ្តើមអាជីពនៅសាកលវិទ្យាល័យយេណា (University of Jena) ក្នុងឆ្នាំ១៨០៦។ គាត់បានបង្រៀនទស្សនវិជ្ជានៅសកលវិទ្យាល័យហៃដេលប៊ែហ្គ (Heidelberg)នៅឆ្នាំ១៨១៦, បន្ទាប់មកជាប្រធានដេប៉ាតឺម៉ង់ទស្សនវិជ្ជានៅសាកលវិទ្យាល័យប៊ែរឡាំងនៅក្នុងឆ្នាំ១៨១៨ ជាកន្លែងដែលលោក បានស្នាក់នៅរហូតដល់ស្លាប់ដោយសារជំងឺអាសន្នរោគក្នុងឆ្នាំ១៨៣១។

ក្នុងនាមជាសាស្ត្រាចារ្យទស្សនវិជ្ជានៅឯសាកលវិទ្យាល័យ, លោក ហេហ្គែល បានបន្តធ្វើសកម្មភាពសំខាន់ៗ របស់លោកដូចជា ការបង្រៀនក្នុងថ្នាក់រៀន និងអត្ថបទទស្សនវិជ្ជាសំខាន់ៗទាំងអស់របស់គាត់ចាប់ពីឆ្នាំ១៨១៦ ដោយយកសៀវភៅទាំងនោះទៅបង្រៀន និងឱ្យសិស្សអាន។ នៅបន្ទាប់ពីមរណភាពរបស់លោក ហេហ្គែល គេបាន យកស្នាដៃដ៏លេចធ្លោរបស់គាត់ទៅបោះពុម្ពផ្សាយជាលើកដំបូងដែលរួមមានបទនិពន្ធស្តីអំពីៈ តក្កវិជ្ជា; ទស្សនវិជ្ជា ធម្មជាតិ; ទស្សនវិជ្ជាគំនិត និងទស្សនវិជ្ជាស្តីពីសិទ្ធិមនុស្សដែលបានដកស្រង់ចេញពីការបង្រៀនរបស់គាត់ក៏ដូចជា ការចម្លងអត្ថបទមេរៀនរបស់លោកទាំងស្រុងដែលបរិយាយអំពីទស្សនវិជ្ជាប្រវត្តិសាស្ត្រ, សោភ័ណវិជ្ជា, ទស្សនវិជ្ជា សាសនា និងប្រវត្តិទស្សនវិជ្ជា។

លោក ហេហ្គែល ជាមិត្តភក្តិជិតស្និទ្ធិរបស់លោក នីតហាំម័រ (Immanuel Niethammer, ១៧៦៦-១៨៤៨) ដែលជាអ្នកគ្រប់គ្រង និងជាអ្នកកែទម្រង់ដ៏សំខាន់នៅក្នុងប្រព័ន្ធអប់រំបាវ៉ារៀន(Bavarian)។ លោក នីតហាំម័រ នៅ ពេលខ្លះបានប្រើប្រាស់ឥទ្ធិពលរបស់គាត់ដើម្បីជួយដល់អាជីពរបស់ ហេហ្គែល ហើយនៅពេលខ្លះបុរសទាំងពីរនាក់ នេះបានពិភាក្សាគ្នាទាក់ទងនឹងការបង្រៀន បញ្ហាគរុកោសល្យទាំងនៅអនុវិទ្យាល័យ ឬកម្រិតសាកលវិទ្យាល័យ។

ការអប់រំមិនត្រឹមជាប្រធានបទលេចធ្លោប៉ុណ្ណោះទេ ប៉ុន្តែវាជាមូលដ្ឋានគ្រឹះនៃទស្សនវិជ្ជារបស់ហេហ្គែល។ ប៉ុន្តែ ប្រហែលជាគួរឱ្យភ្ញាក់ផ្អើលនៅក្នុងទិដ្ឋភាពនៃអាជីពរបស់គាត់, ជាធម្មតាលោក ហេហ្គែល មិនប្រឈមមុខនឹង បញ្ហានេះជាចម្បងក្នុងលក្ខខណ្ឌទ្រឹស្តីនៃការអនុវត្ត ឬវិធីសាស្ត្រគរុកោសល្យនោះទេ។

នៅពេលខ្លះគាត់ពិភាក្សាពីការអប់រំរបស់កុមារ ហើយរិះគន់ទ្រឹស្តីនៃការអប់រំរបស់រូស្សូ។ នៅអំឡុងពេល លោកជានាយកសាលាកាយសម្ពន្ធ(Gymnasium)នៅនូរ៉ឹមប៊ែហ្គ(Nuremberg), ហេហ្គែល ថ្លែងសុន្ទរកថាប្រចាំ ឆ្នាំដែលទាក់ទងនឹងទ្រឹស្តីគរុកោសល្យ និងការពារផ្នែកផ្សេងៗទៀតនៃកម្មវិធីសិក្សារួមមានដូចជា ការបង្រៀន សាសនា វិទ្យាសាស្ត្រធម្មជាតិ ឬយោធា ហើយការពារទស្សនៈរបស់លោក នីតហាំម័រ(Niethammer)ថាកម្មវិធី សិក្សាអនុវិទ្យាល័យគួរផ្តែកទៅលើការអប់រំបែបបុរាណនៅក្រិក និងឡាតាំង ព្រមទាំងអក្សរសាស្ត្រ។ ក្នុងអំឡុងពេល ដូចគ្នា លោក ហេហ្គែល ក៏បានសរសេរអត្ថបទខ្លីៗផ្ញើទៅកាន់លោក នីតហាំម័រ និងលោក ហ្វ្រីឌ្រិស្គ័ រ៉ូម័រ(Friedrich Raumer) លើការបង្រៀនទស្សនវិជ្ជានៅអនុវិទ្យាល័យ។ លោក ហេហ្គែល យល់ស្របជាមួយនឹងលោក អារីស្តូត, គាត់បាននិយាយថាបញ្ហាជាក់ស្តែងនៃការអប់រំគឺ"ដើម្បីរៀបចំមនុស្សឱ្យក្លាយជាពលរដ្ឋល្អរបស់រដ្ឋល្អ"។

## ៥.១ បញ្ញត្តិប៊ៀលឌុង

អ្វីជាមូលដ្ឋានគ្រឹះនៅក្នុងទស្សនវិជ្ជារបស់ ហេហ្គែល គឺប៊ៀលឌុង(Bildung)។ ពាក្យនេះប្រែថា "ការអប់រំ" ប៉ុន្តែអាចប្រែសម្រួលឱ្យកាន់តែសមរម្យក្នុងបរិបទជាច្រើនមានន័យថា ការបង្កើត, ការអភិវឌ្ឍ។ សម្រាប់ ហេហ្គែល វាសំដៅលើការអភិវឌ្ឍខ្លួនឯងលើលក្ខណៈគំនិត ឬស្មារតីដែលចាត់ទុកថាជាដំណើរការសង្គម និងប្រវត្តិសាស្ត្រ។ ពេលខ្លះប៊ៀលឌុងប្រែថា "វប្បធម៌" សំដៅលើការវិវឌ្ឍដែលងាកចេញពីធម្មជាតិហើយឆ្ពោះទៅរកវិចារណញ្ញាណ។

បៀលឌុង (Bildung) ជាផ្នែកនៃដំណើរប្រតិបត្តិការរបស់ស្មារតីៈ មនុស្សជាតិ, សង្គម, ប្រពៃណីប្រវត្តិសាស្ត្រ។ បៀលឌុង មិនអាចកើតឡើងតាមរយៈការចែកចាយព័ត៌មានដោយគ្រូបង្រៀននោះឡើយ ប៉ុន្តែតាមរយៈអ្វីដែលលោក ហេហ្គេល ហៅថា "បទពិសោធ"។

លោកបដិសេធគំនិតថាបៀលឌុងជាប្រភេទអំពើពុករលួយរបស់រដ្ឋធម្មជាតិ។ ផ្ទុយទៅវិញ បៀលឌុង អភិវឌ្ឍគំនិតបុគ្គលដែលមានតម្រូវការ ប៉ុន្តែស្មើភាពគ្នាគឺអាចទទួលស្គាល់ខ្លួនឯងនៅក្នុងតម្រូវការនោះ។ ហេហ្គេល បញ្ជាក់ថាការអប់រំគឺជាការតស៊ូដ៏លំបាកដែលពាក់ព័ន្ធនឹងភាពអវិជ្ជមាននៃចំណង់ និងកម្លាំងពលកម្មនៃគំនិត។ បៀលឌុងពិពណ៌នាពីដំណើរការដែលជីវិតប្រកបដោយសីលធម៌ជំនួសឱ្យតម្រូវការធម្មជាតិ; បៀលឌុង ជាកាលកំណត់នៃបុគ្គលដោយឡែកៗទៅលក្ខណៈសាកល ហើយពីគ្រួសារទៅសង្គមស៊ីវិលនិងរដ្ឋ។

បៀលឌុង គឺការសម្គាល់ទៅលើការចិញ្ចឹមបីបាច់កុមារដោយឪពុកម្តាយ ឬគរុកោសល្យ។ ចំពោះសមិទ្ធិផលចម្បងពីការចិញ្ចឹមបីបាច់គឺធ្វើឱ្យកាន់តែប្រសើរឡើងនូវភាពធម្មតា ឬបុព្វកាលធម្មជាតិដើម្បីឱ្យស្មារតីកុមារកាន់តែស៊ីជម្រៅតាមរយៈការគិតជាសកល។ ហេហ្គេល សង្កត់ធ្ងន់ថានៅក្នុងដំណាក់កាលដំបូងលើដំណើរការនេះទាមទារនូវប្រភេទខ្លះនៃការដាក់កម្រិតពីខាងក្រៅ ឬវិន័យ; ការខកចិត្តចំពោះចំណង់ភ្លាមៗ និងការលូតលាស់សមត្ថភាព; វិបាកលើបទពិសោធនៃទំនាស់និងការខកចិត្តដើម្បីដឹកនាំការយកចិត្តទុកដាក់របស់ខ្លួនតាមរយៈទស្សនៈផ្ទាល់ខ្លួននិងគោលការណ៍វិចារណញ្ញាណ។ គោលបំណងនៃការអប់រំគឺដូចជាការចិញ្ចឹមបីបាច់ដើម្បីឱ្យកុមារមានមនសិការ ឬសម្រាប់ខ្លួនគេផ្ទាល់; អ្វីដែលមានរួចហើយក្នុងខ្លួនគេ ឬសម្រាប់មនុស្សពេញវ័យ ពោលគឺវិចារណញ្ញាណ ឬស្មារតី។ ចាប់តាំងពីកុមារមានភាពចាំបាច់រួចហើយ ឬនៅក្នុងខ្លួនវាមានវិចារណញ្ញាណ, ដំណើរការទាំងមូលរបស់បៀលឌុងគឺជាមូលដ្ឋានគ្រឹះនៅផ្នែកខាងក្នុង, ឬជាសកម្មភាពដឹកនាំដោយខ្លួនឯង, មិនមែនគ្រាន់តែជាដំណើរការនៃការដាក់លក្ខខណ្ឌតាមរយៈរំញោចបរិស្ថាន ឬជាការប្រមូលផ្តុំព័ត៌មានដែលបានបង្ហាញប្រាប់ដោយបទពិសោធប៉ុណ្ណោះទេ។

អ្វីដែលបានរៀនគឺបង្កើតបានជាកម្មសិទ្ធិរបស់មនុស្សគ្រប់គ្នាតាមរយៈការស្គាល់ពួកវាជាអ្វីដែលធ្លាប់ស្គាល់រួចហើយ។ សម្រាប់ហេតុផលនេះ ហេហ្គេល និយាយថាអ្វីដែលធ្លាប់ស្គាល់នោះមិនបានយល់ដឹងថាវាជាវិចារណញ្ញាណទេ។ សម្រាប់ដំណើការយល់ដឹងវិចារណញ្ញាណ ដំបូងតម្រូវឱវត្ថុនោះបាត់បង់ការស្គាល់សិន, ដាក់វាទៅជាលក្ខណៈដោយឡែកៗ ឬបំបែកចេញពីអ្វីដែលនៅសល់ដែលបានផ្តល់ឱ្យនោះដោយកើតឡើងតាមរយៈប្រតិបត្តិការវិភាគនៃការយល់ដឹង។ ទោះយ៉ាងណា នេះគ្រាន់តែជាលក្ខណៈពិសេសរបស់ បៀលឌុង(Bildung)ប៉ុណ្ណោះ; ជំហានដែលមានការសម្រេចចិត្តកើតឡើងកាន់តែច្រើននៅពេលគំនិតកំពុងគិតជួបប្រសព្វជាមួយវត្ថុនោះក្នុងទម្រង់ថ្មី ឬវិចារណញ្ញាណដែលសមស្របនឹងបញ្ញត្តិ។ នៅក្នុងដំណើរការយល់ដឹងពិត ភាពផ្សេងៗរបស់វត្ថុកាន់តែប្រសើរឡើងតាមរយៈការតស៊ូជាមួយវា ហើយគំនិតផ្សារភ្ជាប់ជាមួយអ្នកដែលផ្តល់ឱ្យតាមរយៈការទទួលបាននូវការយល់ដឹងពីវិចារណញ្ញាណរបស់វា។ អ្វីដែលផ្តល់ឱ្យភ្លាមៗដូចបានស្គាល់នៅពេលចាប់ផ្តើមនៃដំណើរការ ពេលនេះវាធ្វើឱ្យប្រសើរឡើងនូវភាពផ្សេងទៀត; វត្ថុមិនមានវត្តមានយូរទៀតទេនៅក្នុងទម្រង់ភ្លាមៗរបស់វា ប៉ុន្តែឥឡូវនេះបានយល់ដោយវិធីនៃបញ្ញត្តិសកលដែលបង្កើតឡើងដោយគំនិត ដូច្នេះ វាស្គាល់ខ្លួនឯងនៅក្នុងវត្ថុ។

ទំនាក់ទំនងថ្មីជាមួយវត្ថុគឺជាអ្វីដែលលោកហៅថា "ភាវៈនៅជាមួយខ្លួនឯងក្នុងអ្នកដទៃ"វាជានិយមន័យរបស់គាត់អំពីសេរីភាពពិតប្រាកដរបស់ស្មារតីៈ មានតែនៅក្នុងសេរីភាពទេ ដែលធន្ទះបំពេញដោយខ្លួនវា គ្មានអ្វីក្រៅតែជាខ្លួនវាទេ, រាល់ទំនាក់ទំនងនៃការពឹងផ្អែកលើអ្វីមួយក្រៅពីខ្លួនវាត្រូវលុបចោល"។ បៀលឌុង ក៏ជាដំណើរការនៃការរំដោះដោយក្នុងនោះសេរីភាពស្មារតីបង្ហាញពីភាពត្រឹមត្រូវលើភាពវិជ្ជមាននៃអ្វីដែលបានផ្តល់ឱ្យក្នុងធម្មជាតិ។

លើសពីនេះ ដោយសារនៅក្នុងការយល់ដឹងពីអ្វីដែលគេទទួលយកដូចដែលបានផ្តល់ឱ្យនៅពេលនេះ ត្រូវគេមើលឃើញថាជាលទ្ធផលរបស់ដំណើរការនៃការគិត, ទំនាក់ទំនងគំនិតរបស់វាគឺដោយសេរី ពីព្រោះវាគាំទ្រខ្លួនឯង ឬបង្ហាញអំពីភាពត្រឹមត្រូវតាមរយៈការគិតដោយខ្លួនឯង។ ដូច្នេះ ការអប់រំ ជា "ការកើតចេញពីកម្លាំងពលកម្មភ្លាមៗ

នៃជីវិតពិត", ការទទួលបាន "គោលការណ៍សកល" ឬ "គិតអំពីវត្ថុ"។ នៅពេលដែលរឿងនេះកើតឡើងមនុស្សអាច "គាំទ្រនិងបដិសេធគំនិតសកលដោយវិចារណញ្ញាណ"។ ប្រៀលឌុង គឺក្នុងពេលតែមួយនឹងដំណើរការនៃការផ្លាស់ប្តូរខ្លួនឯង, ការទទួលបានអំណាចដើម្បីចាប់យក និងបង្ហាញពីហេតុផលសម្រាប់អ្វីដែលមនុស្សម្នាក់ជឿ ឬដឹង។ ការទទួលបានភាពពិតប្រាកដនូវការយល់ដឹងដោយវិចារណញ្ញាណនៃអ្វីដែលដើរទន្ទឹមគ្នាជាមួយនឹងដំណើរការកំណត់ដោយសេរីតាមរយៈការតស៊ូដែលពាក់ព័ន្ធនឹងភាពជាខ្លួនឯង និងការធ្វើឱ្យប្រសើរឡើងនៃទំនាស់ខ្លួនឯង។

## ៥.២ គ្រួសារ សង្គមស៊ីវិល និងរដ្ឋ

ពេលគាត់សរសេរអំពីបាតុភូតវិជ្ជា គាត់មិនទាន់មានទម្រង់បញ្ញត្តិពិភពសង្គមដែលត្រូវនឹងសីលធម៌ខ្លួនឯងក្នុងនាមជាអ្នកបង្កើតវប្បធម៌ទំនើបទេ។ គាត់ចំណាយពេល១០ឆ្នាំនៅក្នុងអាជីពគ្រូបង្រៀននៅសាកលវិទ្យាល័យ; ដំបូងគេនៅក្នុងសព្វវចនាធិប្បាយទស្សនវិជ្ជាវិទ្យាសាស្ត្រប្រមូលផ្តុំឡើងដើម្បីការបង្រៀននៅសាកលវិទ្យាល័យហៃដែលប៊ែហ្គ(Heidelberg)ក្នុងឆ្នាំ១៨១៧ បន្ទាប់មកនៅក្នុងការងារសំខាន់ចុងក្រោយរបស់គាត់គឺទស្សនវិជ្ជាស្តីពីសិទ្ធិមនុស្ស។

សង្គមមុនសម័យទំនើប "សីលធម៌" ក្នុងន័យបច្ចេកទេសរបស់គាត់បានរៀបចំឡើងនៅតាមស្ថាប័នធំៗពីរគឺៈ ទី១ ស្ថាប័នឯកជន ជាលក្ខណៈបុគ្គល និងសង្គមធម្មជាតិ, ភ្ជាប់នឹងសាសនា(គ្រួសារ); និងទី២ ស្ថាប័នសាធារណៈ ជាលក្ខណៈសកល ឬជាសង្គមនយោបាយ, ពិភពលោកិយដែលយកគំរូតាមបញ្ញារបស់មនុស្ស(រដ្ឋ)។ ស្ថាប័នទាំងពីរបង្ហាញពីចរិតលក្ខណៈដោយភ្ជាប់ជាមួយនឹងជីវិតប្រកបដោយសីលធម៌ ពោលគឺមានអត្តសញ្ញាណផ្ទាល់ខ្លួនបន្ទាប់មកក្លាយជាប្រយោជន៍របស់សង្គម និងបុគ្គល។ ស្ថាប័ន "សីលធម៌" ជាស្ថាប័នដែលមានសុខដុមនីយកម្មដោយផ្ទាល់រវាងផលប្រយោជន៍បុគ្គល និងសង្គម; ធម្មជាតិនៃសីលធម៌ គឺជាអ្នកឆ្លុះបញ្ចាំងអំពីស្ថានភាពនៃការងារចិត្តសាស្ត្រ៖ ស្ថាប័នទាំងពីរបង្ហាញពីអត្តសញ្ញាណផ្ទាល់រវាងប្រយោជន៍ខ្លួនឯង និងប្រយោជន៍សង្គមទាំងមូល។

នៅក្នុងគ្រួសារមានតម្រូវការទម្រង់នៃអារម្មណ៍ ឬឥន្ទ្រីយ៍៖ សេចក្តីស្រឡាញ់នៅក្នុងគ្រួសារគឺជាអារម្មណ៍នៃស្មារតីឯកភាពគ្នា; នៅក្នុងរដ្ឋវាគឺជាស្មារតីជាតិនិយម ឬការរៀបចំនយោបាយ។ នៅក្នុងសង្គមទំនើបជីវិតប្រកបទៅដោយសីលធម៌ត្រូវការចូលរួមដោយស្ថាប័នទី៣, ការឯកភាពនៃស្ថាប័នទាំងពីរនេះមិនមែនដោយផ្ទាល់នោះទេ វាជាដំណាក់កាលនៃភាពខុសគ្នា ឬពិភពរូបរាងនៃសីលធម៌ដែលនៅទីបំផុតជីវិតប្រកបដោយសីលធម៌ត្រូវបានបាត់បង់នៅក្នុងស្ថាប័នទី៣នេះ។ លោក ហេហ្គេល បានឱ្យឈ្មោះស្ថាប័នទី៣នេះថាគឺជា"សង្គមស៊ីវិល"។

យោងតាមប្រវត្តិសាស្ត្រ លោក ហេហ្គេល កត់សម្គាល់ថា"ជីវិតប្រកបដោយសីលធម៌"កើតជាមួយនឹងភាពស្រស់ស្អាត និងអរិយធម៌ប្រកបដោយសុខដុមរមនានៃក្រិកបុរាណសម័យ ហើយគាត់មើលឃើញសហសម័យថាលេចចេញជាយូរយារមកហើយនៃដំណើរប្រវត្តិសាស្ត្រដ៏យូរអង្វែងបន្ទាប់ពីការបញ្ចប់របស់វា។ ក្នុងបាតុភូតវិទ្យា, លោកយល់ថាការដួលរលំរដ្ឋប៉ូលីសរបស់ក្រិកជាប់ទាក់ទងនឹងជម្លោះរវាងស្ថាប័នពីរគឺគ្រួសារ និងរដ្ឋ។ សេរីភាពបុគ្គលមិនលេចចេញមកដោយផ្ទាល់ទេ ប៉ុន្តែលេចចេញជាលទ្ធផលមិនផ្ទាល់នៃទំនាស់រវាងទម្រង់សីលធម៌ទាំងពីរ។ ការរំខាននៃជីវិតប្រកបដោយសីលធម៌នៅក្រិកបុរាណនាំមានការផ្តាច់ខ្លួនរបស់ចក្រភពរ៉ូម និងការបាត់បង់សីលធម៌របស់សង្គមក្រិកខ្លួនឯងដែលជំនួសមកវិញនូវឥទ្ធិពលសាសនាគ្រិស្ត និងដឹកនាំទៅរកវប្បធម៌អប់រំ(Bildung)នៅអំឡុងដើមសម័យទំនើប។

ទស្សនវិជ្ជាស្តីអំពីសិទ្ធិបានបង្កើតទស្សនៈវិស័យខាងស្មារតី ឬសណ្តាប់ធ្នាប់សង្គមថាជា "ជីវិតប្រកបដោយសីលធម៌"។ ពេលនោះ គេទទួលស្គាល់ជាសង្គមពិត និងជាសង្គមដែលមានអត្ថិភាពជាក់លាក់។ លោកមើលឃើញពីជីវិតប្រកបដោយសីលធម៌របស់សង្គមសម័យទំនើបថាជាប់ទាក់ទងនឹងស្ថាប័នចំនួនបីគឺ គ្រួសារ, សង្គមស៊ីវិល និងរដ្ឋ។ ស្ថាប័នគ្រួសារគឺជាតថភាពផ្ទាល់នៃស្មារតី, សហគមន៍គ្រួសារគឺជាអារម្មណ៍នៃសេចក្តីស្រឡាញ់។ គេបានចាត់ទុកគ្រួសារគឺជាទីកន្លែងរៀនដំបូងគេអំពីតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងនាមជាភាវៈមនុស្ស ហើយគ្រួសារក៏ជា

កន្លែងដែលរៀនអនុវត្តនៃការបំពេញតួនាទី និងភារកិច្ចទាំងនោះដែរ។ ដូច្នេះ គ្រួសារគឺជាចំណុចចាប់ផ្ដើមនៃខ្លឹមសារសីលធម៌បុគ្គល។

គ្រួសារ គឺជាអង្គភាពដែលបង្កើតឡើងដោយឪពុកម្ដាយតាមរយៈការលះបង់ឯករាជ្យភាពរបស់ខ្លួន ចំណែកកុមារកើតមកក្នុងទម្រង់អត្តសញ្ញាណសីលធម៌របស់គ្រួសារ។ ដោយសារ"សេចក្ដីស្រឡាញ់" មានលក្ខណៈផ្ទាល់ខ្លួន, ជាអារម្មណ៍ចៃដន្យ និងខ្វះការគាំទ្រពីវិចារណញ្ញាណ ដូចនេះ គ្រួសារគ្រាន់តែជាសីលធម៌សាមញ្ញ (មិនស្ថិតស្ថេរ) កុមារមិនអាចទទួលបានសេរីភាពពេញលេញ និងមានភាពចាស់ទុំក្នុងគ្រួសារទេ។ ពេលកុមារធំឡើង ហើយរស់នៅដោយឯករាជ្យពីគ្រួសារ ពេលនោះកុមារនឹងរស់នៅដោយផ្សារភ្ជាប់ជាមួយបណ្ដាញសង្គមទី២គឺ"សង្គមស៊ីវិល"។

សារៈសំខាន់នៃសង្គមស៊ីវិលសម្រាប់បុគ្គលគឺស្ថិតនៅក្នុងតថភាពឯករាជ្យរបស់បុគ្គលដែលត្រូវបានសម្គាល់ដោយសិទ្ធិបុគ្គល។ សង្គមស៊ីវិល គឺជា"ប្រព័ន្ធនៃតម្រូវការ" និងជាទីលានដែលបុគ្គលប្រយុទ្ធដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។ ក្នុងសង្គមស៊ីវិល"បុគ្គលផ្ទាល់ជាកម្មវត្ថុនៃគោលបំណងជាក់លាក់របស់ខ្លួន, ជាការបូកសរុប, ការបញ្ចូលគ្នារវាងអារម្មណ៍ និងភាពចាំបាច់នៃរាងកាយជាមួយគោលការណ៍របស់សង្គមស៊ីវិល"។ លក្ខណៈដោយឡែករបស់មនុស្សគឺមានទំនាក់ទំនងនឹងលក្ខណៈដោយឡែករបស់មនុស្សដទៃទៀត និងទទួលបានការពេញចិត្តដោយវិធីរបស់អ្នកដទៃ។ នៅក្នុងដំណើរការនៃកម្លាំងពលកម្មចំពោះចំណង់ផ្ទាល់ខ្លួន បុគ្គលនៅតែមានសក្ដានុពលសកល ពោលគឺជាការសហការ និងជាការចូលរួមនៅក្នុងកម្លាំងពលកម្មនោះ។

រដ្ឋជាតំណភ្ជាប់ទីបីនៃសីលធម៌។ ខ្លឹមសាររបស់រដ្ឋទំនើបគឺជាសកលភាពដែលផ្សារភ្ជាប់ជាមួយនឹងសេរីភាពពេញលេញរបស់សមាជិកសង្គមម្នាក់ៗ និងសុខុមាលភាពឯកជនដែលជាផលប្រយោជន៍របស់គ្រួសារ ហើយសង្គមស៊ីវិលត្រូវតែផ្ដោតអារម្មណ៍លើរដ្ឋខ្លួនឯង។ បុគ្គលអាចទទួលបានសេរីភាពពិតប្រាកដគឺមានតែនៅក្នុងរដ្ឋទេ។ សម្រាប់បុគ្គល, មិនថាជាក្រុមគ្រួសារដែលមានអត្តសញ្ញាណសាមញ្ញ ឬជាពលរដ្ឋដែលកំពុងប្រយុទ្ធដើម្បីចំណង់ផ្ទាល់ខ្លួនទេគឺមិនមានសេរីភាពគ្រប់គ្រាន់នៅក្នុងសកលភាពនេះឡើយ។

ដូច្នេះ មធ្យោបាយសមហេតុផលសម្រាប់បុគ្គលគឺដើម្បីឱ្យក្លាយជាពលរដ្ឋរបស់រដ្ឋមួយ។ សេរីភាពស្ថិតនៅក្នុងការពិតជាក់ស្ដែងដែលថាបុគ្គលតែម្នាក់ និងផលប្រយោជន៍របស់ពួកគេមិនត្រឹមតែបានអភិវឌ្ឍបានពេញលេញប៉ុណ្ណោះទេ ប៉ុន្តែសិទ្ធិរបស់ពួកគេត្រូវតែទទួលស្គាល់យ៉ាងជាក់លាក់។ ការក្លាយជាសមាជិករបស់រដ្ឋគឺជាកាតព្វកិច្ចខ្ពស់បំផុតរបស់បុគ្គលពីព្រោះអត្ថិភាពនៃវិចារណញ្ញាណរបស់មនុស្សដឹងតែនៅក្នុងសីលធម៌របស់រដ្ឋប៉ុណ្ណោះ។

## ៥.៣ ការអប់រំគឺជាសិទ្ធិរបស់កុមារ និងការទទួលខុសត្រូវរបស់រដ្ឋ

នៅក្នុងនាមខ្លួនជាគ្រួសារសកល សង្គមស៊ីវិលមានសិទ្ធិ, មានកាតព្វកិច្ចក្នុងការគ្រប់គ្រង និងជះឥទ្ធិពលទៅលើការអប់រំកុមារដើម្បីឱ្យពួកគេក្លាយទៅជាសមាជិកសង្គម។ សិទ្ធិរបស់សង្គមគឺសំដៅលើចំណង់ចំណូលចិត្តដោយសេរី និងភាពជាប់លាប់របស់ឪពុកម្ដាយ ជាពិសេសនៅក្នុងករណីឪពុកម្ដាយមិនបានបំពេញការអប់រំដល់កុមារ ប៉ុន្តែផ្នែកផ្សេងទៀតត្រូវផ្ដល់ការអប់រំដល់កុមារជាចាំបាច់។ ទីបំផុត សង្គមត្រូវផ្ដល់កន្លែងអប់រំសាធារណៈសម្រាប់កុមារ។ សង្គមមានសិទ្ធិធ្វើសកម្មភាពតាមគោលការណ៍ដែលសាកល្បងតាមរយៈបទពិសោធរបស់ខ្លួន និងបង្ខំឪពុកម្ដាយបញ្ជូនកូនៗទៅសាលារៀន។

ក្នុងគ្រួសារកុមារអាចទទួលយកភ្លាមៗជាលក្ខណៈបុគ្គលនូវសេចក្ដីស្រឡាញ់ពីឪពុកម្ដាយថាតើអាកប្បកិរិយារបស់គាត់ល្អ ឬអាក្រក់។ ផ្ទុយទៅវិញ នៅក្នុងសាលារៀនកុមារទទួលបានការគោរពដោយយោងទៅតាមតម្លៃ និងសមិទ្ធិផលរបស់ពួកគេ។ កុមារមិនត្រឹមតែទទួលបានការស្រឡាញ់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានការរិះគន់ និងណែនាំទៅតាមគោលការណ៍សកលដែលបានរៀបចំឡើងដោយការបង្រៀនស្របតាមវិធានវិជ្ជមាន ជាទូទៅការដាក់ចេញបទបញ្ញាសកលដែលហាមឃាត់កុមារមិនឱ្យធ្វើអ្វីៗតាមអំពើចិត្ត និងដើម្បីកុំឱ្យពួកគេមានកំហុសដែរ។ សាលារៀនបង្កើតការផ្លាស់ប្ដូរពីគ្រួសារទៅជាសង្គមស៊ីវិល។

## ៥.៤ ការអប់រំ និងសីលធម៌

ការអប់រំធ្វើឱ្យសារជាតិរបស់មនុស្សកាន់តែប្រសើរឡើង និងជាមធ្យោបាយដើម្បីឈានទៅសម្រេចបានខាងសីលធម៌។ លោក ហេហ្គេល ចង្អុលបង្ហាញថាគោលបំណងនៃការអប់រំ, ដំបូងគេគឺបណ្ដុះការយល់ដឹងសីលធម៌ទៅក្នុងអារម្មណ៍ និងវេទយិតភាព។ ការអប់រំគឺជាសិល្បៈដែលធ្វើឱ្យមនុស្សមានសីលធម៌។ ការអប់រំសីលធម៌របស់លោក ហេហ្គេល បានសង្កត់ធ្ងន់ទៅលើទិដ្ឋភាព៣យ៉ាងគឺទិដ្ឋភាពទីមួយៈ ការអប់រំត្រូវតែបណ្ដុះការគ្រប់គ្រងខ្លួនឯងប្រកបដោយវិចារណញ្ញាណនៃចំណង់របស់ប្រធានវិស័យភាព។ ទិដ្ឋភាពទីពីរៈ ការអប់រំត្រូវបណ្ដុះមនសិការរបស់កុមារដោយអនុលោមទៅតាមបទដ្ឋាន, គោលបំណង, ក្លាយជាសមាជិកនៃក្រុមសង្គម និងលុបបំបាត់នូវបុគ្គលភាពរបស់កុមារ។ ទិដ្ឋភាពទីបីៈ ការអភិវឌ្ឍនៃការអប់រំមិនចាកចេញពីជីវិតពិត និងបទពិសោធបែបប្រពៃណីទេ ប៉ុន្តែត្រូវជំទាស់នឹងគំនិតអប់រំដែលប្រាសចាកពីការពិត និងមូលដ្ឋានគ្រឹះប្រវត្តិសាស្ត្រ។

ហេហ្គេល ជឿថាការធ្វើឱ្យឆន្ទៈកាន់តែប្រសើរឡើងកើតមាននៅក្នុងដំណាក់កាលនៃការអប់រំក្នុងគ្រួសារ។ ការអប់រំនេះត្រូវរៀបចំកុមារឱ្យចូលទៅក្នុងជីវិតសង្គមនាពេលអនាគតដើម្បីឱ្យធម្មជាតិកុមារកាន់តែរឹងមាំ, ទទួលបានឯករាជ្យភាព, បុគ្គលិកលក្ខណៈសេរី និងទទួលបានសមត្ថភាព និងចាកចេញពីសហគមន៍ធម្មជាតិនៃគ្រួសារ។ គោលបំណងនៃការអប់រំក្នុងគ្រួសារគឺដើម្បីបណ្ដុះគោលការណ៍សីលធម៌, ដើម្បីទប់ទល់នឹងសេរីភាពដែលតែងមានការភាន់ច្រឡំជាមួយធម្មជាតិ និងធ្វើឱ្យសកលភាពចូលទៅក្នុងមនសិការ និងឆន្ទៈរបស់ពួកគេ។ ធ្វើបែបនេះដើម្បីឱ្យកុមាររៀនពីគោលការណ៍នៃការរស់នៅជាមួយគ្នា និងរៀនប្រើវិចារណញ្ញាណសកលដើម្បីគ្រប់គ្រងសភាវគតិ និងចំណង់របស់ខ្លួន។

ការបង្កើតបញ្ញត្តិសីលធម៌គឺមាននៅក្នុងវិន័យ និងទម្លាប់។ តំណភ្ជាប់ដ៏ចម្បងនៃការអប់រំគឺវិន័យ មានន័យថាជាការបំបែកឆន្ទៈផ្ទាល់ខ្លួនរបស់កុមារ, ដកចេញពីវេទយិតភាព និងធម្មជាតិ។ ដូច្នេះ តម្រូវការនៃការអប់រំវិន័យគឺដើម្បីលុបបំបាត់ចំណង់ចំណូលចិត្តបុគ្គលផ្ទាល់ខ្លួនរបស់កុមារ និងដើម្បីបណ្ដុះវិចារណញ្ញាណ។ ទន្ទឹមនឹងនេះ លោក ហេហ្គេល សង្កត់ធ្ងន់លើសារៈសំខាន់នៃការបង្កើតទម្លាប់ក្នុងការអប់រំ។ ការអប់រំគឺជាសិល្បៈដែលធ្វើឱ្យមនុស្សមានសីលធម៌។ តាមរយៈ វិន័យ និងការបណ្ដុះទម្លាប់ ការអប់រំសីលធម៌ចង្អុលបង្ហាញផ្លូវនៃ"ការបង្កើតឡើងវិញ"ដល់កុមារដែលនោះគឺជាផ្លូវនៃការបង្កើតមនុស្សជាតិប្រកបដោយសីលធម៌។ ការអប់រំធ្វើឱ្យមនុស្សក្លាយជាម្ចាស់នៃចំណង់ធម្មជាតិផ្នែកខាងក្នុងរបស់ពួកគេ។ ហេហ្គេល ចង្អុលបង្ហាញថាការអប់រំគឺជាប្រភេទនៃ"ការខិតខំធ្វើការ"។

ការអប់រំសីលធម៌គួរបណ្ដុះគំនិតសមូហភាពដល់កុមារ និងធ្វើឱ្យពួកគេក្លាយជាសមាជិកនៃអង្គសង្គម។ ការធ្វើបែបនេះ ដើម្បីឱ្យការគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនដែលជាលក្ខណៈបុគ្គលរបស់កុមារកាន់តែប្រសើរ។ មនុស្សជាសត្វសង្គម, មានតែរៀនរស់នៅជាមួយគ្នាក្នុងក្រុមសង្គមទើបទទួលបានសេរីភាពដែលជាសេរីភាពដ៏មានតម្លៃជាងគេ។

ហេហ្គេល បានបង្ហាញថាការអប់រំគឺត្រូវតែពិចារណាពីលក្ខណៈពិសេសនៃគ្រួសារ។ ឥរិយាបថរបស់គ្រួសារគឺស្របទៅនឹងធម្មជាតិនៃវត្ថុវិស័យភាព។ តាមរយៈការអប់រំ កុមាររៀនសហការជាមួយអ្នកដទៃ, ទទួលយកគំនិតរបស់អ្នកដទៃ, រៀនទទួលស្គាល់ ហើយគោរពជំនឿនិងតម្លៃរួម។ ជាមួយគ្នានេះ លោក ហេហ្គេល បានសង្កត់ធ្ងន់ថាការអប់រំគួរតែផ្អែកលើលក្ខណៈធម្មជាតិ, ជីវិតពិតរបស់មនុស្ស និងស្វែងរកនៅក្នុងបទពិសោធរួមនៃប្រវត្តិសាស្ត្រ។

យើងអាចសង្ខេបទស្សនៈរបស់ លោក ហេហ្គេល ស្ដីពីការអប់រំដូចខាងក្រោមៈ

ចំណុចទីមួយ ហេហ្គេល ចង់ផ្ដល់ឱ្យនូវកម្លាំងខាងក្រៅ; បណ្ដុះទម្លាប់ដែលជួយឱ្យកុមារពន្យាពេលរីករាយ។ ក្នុងពាក្យរបស់ហេហ្គេល វាជា"សេរីភាពចេញមកពីកម្លាំងរុញច្រាននៃចំណង់ដែលមាននៅក្នុងសម្ភារៈ, ការទទួលបានគំនិតឧត្ដម និងគោលការណ៍សកលភាព"។ ទម្លាប់ ឬគោលការណ៍សកលភាពជាអវិចារណភាព(irrational)។ ទីពីរ ការអប់រំសម្រាប់កុមារក៏ដូចសម្រាប់មនុស្សពេញវ័យ គឺដើម្បីទទួលបានសមត្ថភាពក្នុងការគិតអរូបី និងការ

យល់ដឹងថ្មីរបស់ពួកគេអំពីអ្វីមួយ។ ក្នុងពាក្យរបស់ហេហ្គេល វាគឺជា"ដំណើរការនៃការកែលម្អខ្លួនឯង, ការផ្លាស់ប្ដូរខ្លួនឯង និងការវិវឌ្ឍខ្លួនឯងលើកម្រិតសមហេតុផលដោយប្រើការគិតអរូបី និងការគិតបែបតក្កវិជ្ជា ដើម្បីឱ្យគេអាចសន្និដ្ឋានអំពីអ្វីៗដែលគេដឹង និងមិនដឹង"។ ដំណើរការនេះគឺជាវិចារណញ្ញាណ។

គំនិតអប់រំនៅក្នុងទស្សនវិជ្ជារបស់លោក ហេហ្គេល បានបង្ហាញពីខ្លឹមសារនៃទស្សនវិជ្ជារបស់គាត់ដែលគ្របដណ្ដប់ទៅលើឯកភាពខាងក្នុងនៃការអភិវឌ្ឍបុគ្គល និងក្រុម។ ដូចដែលលោក ចន ឌូវី បានចង្អុលបង្ហាញនៅក្នុងលទ្ធិប្រជាធិបតេយ្យ និងការអប់រំរបស់គាត់។ ចំណែកឯគំនិតរបស់លោក ហេហ្គេល ស្ដីពីការអប់រំគឺដាក់បញ្ចូលគ្នានូវការយល់ដឹងពេញលេញរបស់បុគ្គលជាមួយនឹងភាពពេញលេញ និងការគោរពតាមជាប្រចាំចំពោះគោលការណ៍សីលធម៌។ ក្នុងនាមជាសារជាតិរបស់មនុស្ស គោលការណ៍សីលធម៌ផ្ដោតលើសុភមង្គល និងភាពឥតខ្ចោះរបស់មនុស្សដែលត្រូវបានបង្រួមចូលគ្នា។

ជាទូទៅចំណុចខ្លាំង និងចំណុចខ្សោយនៃទស្សនវិជ្ជាអប់រំរបស់លោក ហេហ្គេល គឺទ្រឹស្ដីសីលធម៌ និងទ្រឹស្ដីសង្គម។ ក្នុងន័យចង្អៀត, គាត់បានចាត់ទុកការអប់រំថាជាការចិញ្ចឹមបីបាច់ និងជាគុណកោសល្យព្រោះវាដើរតួជាកត្តាកំណត់ក្នុងសង្គមទំនើបដែលជាលទ្ធផលនៃដំណើរការប្រវត្តិសាស្ត្រនៃការអប់រំ ឬវប្បធម៌ (Bildung)។ ចក្ខុវិស័យនេះមានជាប់ពាក់ព័ន្ធនឹងជំនឿទុកចិត្តប្រកបដោយវិចារណញ្ញាណនៅក្នុងទិសដៅវឌ្ឍនភាពនៃប្រវត្តិសាស្ត្រ និងនៅក្នុងវិចារណភាពរបស់ស្ថាប័នសង្គមទំនើប៕

# មេរៀនទី៦ ទស្សនវិជ្ជា និងទ្រឹស្តីអប់រំរបស់លោក ម៉តទីម័រ អាដល័រ

ម៉តទីម័រ អាដល័រ (Mortimer J. Adler) ជាសាស្ត្រាចារ្យ ទស្សនវិទូ និងជាអ្នកទ្រឹស្តីអប់រំជនជាតិអាម៉េរិក។ លោកកើតនៅឆ្នាំ១៩០២ នៅក្រុងញូវយ៉ក ជាកូនប្រុសជនអន្តោប្រវេសន៍ដែលជាអ្នកលក់គ្រឿងអលង្ការ។ ម៉តទីម័រ អាដល័រ ចាប់អារម្មណ៍លើទស្សនវិជ្ជាបន្ទាប់ពីអានស្នាដៃរបស់ទស្សនវិទូជនជាតិអង់គ្លេសលោក ចន ស្ទូអារថ៍ មៀល (John Stuart Mill)។ ម៉តទីម័រ អាដល័រ ក្លាយជាសាស្ត្រាចារ្យចិត្តវិទ្យានៅសាកលវិទ្យាល័យកូលំបៀ (Columbia) ជាកន្លែងដែលគាត់ធ្វើការពេញមួយទសវត្សរ៍ឆ្នាំ១៩២០។

ក្នុងនាមជាសាស្ត្រាចារ្យសាកលវិទ្យាល័យកូលំបៀ(Columbia)បានសរសេរសៀវភៅជាច្រើនពីទស្សនវិជ្ជា និងសាសនាបស្ចិមប្រទេស ក៏ដូចជាស្នាដៃទស្សនវិជ្ជាផ្ទាល់ខ្លួនជាច្រើនរបស់គាត់។ ក្នុងកិច្ចការទស្សនវិជ្ជា គាត់បានចៀសវាងភាសាបែបការអប់រំ(academic)ដើម្បីឱ្យអ្នកអានទាំងអស់ចូលមើលបានពីគំនិតរបស់គាត់។ ការអនុវត្តនេះស្របនឹងជំនឿរបស់គាត់ថាទស្សនវិជ្ជាជាអាជីវកម្មរបស់មនុស្សគ្រប់គ្នា។ លោក អាដល័រ បានសរសេរចងក្រងសៀវភៅជាង៥០ក្បាលក្នុងមួយជីវិតរបស់គាត់។

នៅទសវត្សរ៍ឆ្នាំ១៩៣០ លោកបានក្លាយជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យឈីកាហ្គោ ជាកន្លែងដែលគាត់បានតស៊ូមតិឱ្យមានការអនុម័តមុខវិជ្ជាបែបបុរាណ(Classics)ជាផ្នែកសំខាន់មួយនៃកម្មវិធីសិក្សា។ សាលាមានការស្ទាក់ស្ទើរក្នុងការធ្វើតាមគំនិតគាត់ និងបានចាត់តាំងលោកឱ្យទៅសាលាច្បាប់វិញ។ នៅឆ្នាំក្រោយមក អាដល័រ ជួយបង្កើតវិទ្យាស្ថានស្រាវជ្រាវទស្សនវិជ្ជានៅសាកលវិទ្យាល័យន័រការ៉ូណា(North Carolina), វិទ្យាស្ថានអាស្ពេន (Aspen) និងមជ្ឈមណ្ឌលសម្រាប់ការសិក្សាអំពីគំនិតល្អ ៗ។

អាដល័រ ជាអ្នកគាំទ្រដ៏អស្ចារ្យនៃលទ្ធិនិរន្តរភាពនិយម និងជាសាស្ត្រាចារ្យទស្សនវិជ្ជានៅសាកលវិទ្យាល័យកូលំបៀ(Columbia)។ លោកជាបុគ្គលម្នាក់ដែលរៀនសូត្រល្អបំផុតដោយសិក្សាសៀវភៅបុរាណ។ លោកសរសេរនិក្ខេបបទស្តីពីសំណើនៃការអប់រំ(Paideia Proposal)ដើម្បីរៀបចំវគ្គសិក្សាមួយជាមួយអ្នកដែលគ្មានជំនាញ ឬគ្មានឯកទេសជាក់លាក់។ សេរីនិយមមិនមែនជាវិជ្ជាជីវៈ មនុស្សមិនមែនជាអ្នកបច្ចេកទេស។ "ការអប់រំគួរតែលៃតម្រូវមនុស្សទៅនឹងសេចក្តីពិត ឬសច្ចភាពដែលស្ថិតនៅអស់កល្បជានិច្ច"។ ការអប់រំមានន័យថាជាការបង្រៀន។ ការបង្រៀនបង្កប់ន័យអំពីចំណេះដឹង។ ចំណេះដឹងជាសេចក្តីពិត។ ការពិតនៅគ្រប់ទីកន្លែងគឺមានលក្ខណៈដូចគ្នា។ ហេតុដូច្នេះ ការអប់រំគួរតែមាននៅគ្រប់ទីកន្លែងដែរដើម្បីឱ្យមនុស្សទទួលបានការអប់រំ និងរកឃើញសេចក្តីពិត។ "ការអប់រំមិនមែនជាការក្លែងនៃជីវិតទេ ប៉ុន្តែជាការរៀបចំសម្រាប់ជីវិត"។

នៅក្នុងបទនិពន្ធស្តីពីសំណើនៃការអប់រំ(Paideia Proposal)គឺជាប្រព័ន្ធអប់រំបែបសេរីមួយប្រភេទដែលមានគោលបំណងបណ្តុះការអប់រំដល់កុមារទាំងអស់គ្នា។ បទនិពន្ធនេះជាការឆ្លើយតបទៅនឹងអ្វីដែល ម៉តទីម័រ អាដល័រ (Adler) កំណត់លក្ខណៈវិនិច្ឆ័យនៃប្រព័ន្ធអប់រំមួយដែលប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ ឬអធិបតេយ្យភាពរបស់សហរដ្ឋអាម៉េរិកក្នុងអំឡុងសតវត្សរ៍ទី១៩ ជាពិសេសនៅពេលដែលការយល់ដឹងអំពីសិទ្ធិមនុស្ស ដែលគេគ្រប់គ្នារំពឹងថានឹងមានការធ្លាក់ចុះនៅសតវត្សរ៍ទី២០នោះ។ បទនិពន្ធនេះផ្តោតលើការប៉ាន់ស្មាន៥យ៉ាងដូចខាងក្រោម៖

- កុមារទាំងអស់អាចទទួលបានការអប់រំ។
- ការអប់រំមិនដែលបញ្ចប់នៅក្នុងសាលារៀន ឬស្ថាប័នឧត្តមសិក្សាទេ ប៉ុន្តែវាជាដំណើរការនៃការសិក្សាពេញមួយជីវិតរបស់មនុស្សគ្រប់រូប ។
- បុព្វហេតុចម្បងបំផុតនៃការរៀនសូត្រគឺជាសកម្មភាពនៃចិត្តរបស់កុមារ។ សកម្មភាពនេះមិនត្រឹមតែបង្កើតឡើងដោយគ្រូបង្រៀននោះទេ ប៉ុន្តែការរៀនសូត្រក៏ត្រូវបានវាយតម្លៃដោយគ្រូបង្រៀនទៀតផងដែរ។

- ពហុធាតុនៃការរៀននិងការបង្រៀនត្រូវតែយកមកប្រើប្រាស់នៅក្នុងការអប់រំ ដោយមិនគ្រាន់តែឧទ្ទេស ឬនិយាយប្រាប់ដោយគ្រូបង្រៀនប៉ុណ្ណោះទេ។

- ការរៀននិងបង្រៀនគឺជាការរៀបចំសិស្សដើម្បីឱ្យគេអាចរកប្រាក់ចំណូលបានសម្រាប់ការរស់នៅពេលគឺការរៀននិងបង្រៀនមិនមែនជាវត្ថុបំណងចម្បងនៃការសិក្សាតែនៅក្នុងសាលាប៉ុណ្ណោះទេ តែវាក៏មាននៅក្នុងមជ្ឈដ្ឋានខាងក្រៅផងដែរ។

**៦.១ ទស្សនវិជ្ជាអប់រំ**

ទ្រឹស្តីអប់រំរបស់ អាដល័រ ជាទ្រឹស្តីដែលរស់នៅក្នុងសតវត្សរ៍ទី២០។ គេកត់សម្គាល់ឃើញថាលោក អាដល័រ គឺជាអ្នកឈ្នះពានរង្វាន់អក្សរសាស្ត្រល្វីស (Louis) ពីព្រោះគាត់បានធ្វើការលើសព្វវចនាធិប្បាយ (Encyclopedia Britannica) សម្រាប់ជាការចង្អុលបង្ហាញ និងត្រួសត្រាយគំនិតស្តីពី "សៀវភៅល្អ" អំពីការអប់រំ។ លោក អាដល័របានលក់សៀវភៅនេះដាច់ជាទីបំផុត ជាពិសេសសៀវភៅដែលមានចំណងជើង "តើត្រូវអានសៀវភៅរបៀបណា"។ សៀវភៅនេះជាមគ្គុទេសក៍ និងជាវិធីសម្រាប់អានសៀវភៅដ៏អស្ចារ្យ។

ជាមួយគ្នានេះដែរ ម៉តទីម័រ អាដល័រ តែងប្រកាន់ខ្ជាប់នូវទស្សនវិជ្ជាបែបនិរន្តរភាពនិយម និងមានជំនឿជាក់យ៉ាងច្បាស់លាស់ថា ការអប់រំគួរតែត្រូវធ្វើឡើងសម្រាប់មនុស្សគ្រប់គ្នាដូចៗគ្នា ហើយមុខវិជ្ជាទស្សនវិជ្ជាគួរតែត្រូវដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាលារៀនរដ្ឋផងដែរ។ ក្នុងសំណើរស្រាវជ្រាវរបស់លោក ម៉តទីម័រ អាដល័រ អំពីការអប់រំ (Paideia) គាត់អះអាងយ៉ាងច្បាស់ថាកុមារគ្រប់រូបគួរទទួលបានចំណេះដឹងបីប្រភេទគឺ ចំណេះដឹងអំពីរបៀបរៀបចំ, បំណិនបញ្ញា និងការយល់ដឹងពីគំនិតនិងតម្លៃ។

លោក អាដល័រ មានជំនឿថា ការអប់រំបែបបុរាណមានសារៈសំខាន់បំផុត ពីព្រោះវាបានដឹកនាំសាលារៀនជាច្រើនឱ្យទទួលយក "កម្មវិធីសៀវភៅល្អ" ដែលជាសៀវភៅស្នូលដោយផ្តោតលើទស្សនវិជ្ជា និងអក្សរសាស្ត្រ ហើយមុខវិជ្ជាទាំងអស់នេះមានតាំងពីសម័យបុរាណរហូតមកដល់សម័យទំនើបនេះ។ នៅខណៈពេលដែលលោកបង្រៀននៅសាកលវិទ្យាល័យឈីកាហ្គោ (The University of Chicago) និងសាកលវិទ្យាល័យកូលំបៀ, លោក ម៉តទីម័រ អាដល័រ អះអាងថា និស្សិតថ្នាក់បរិញ្ញាបត្រទាំងអស់ត្រូវតែចំណាយពេលវេលាយ៉ាងតិចមួយឆមាសសម្រាប់រៀន "សៀវភៅល្អអស្ចារ្យ" (The Great Books)។

គ្រប់មហាវិទ្យាល័យដែលមានវគ្គសិក្សាដែលផ្អែកលើមូលដ្ឋានអក្សរសាស្ត្រសម័យទំនើប មានមូលដ្ឋានរបស់លោក ម៉តទីម័រ អាដល័រ។ គំនិតរបស់លោកអំពី "សៀវភៅល្អអស្ចារ្យ" បានបន្សល់ទុក និងជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់សាកលវិទ្យាល័យនានានៅជុំវិញសហរដ្ឋអាម៉េរិក។ សព្វថ្ងៃនេះមានមហាវិទ្យាល័យ និងសាកលវិទ្យាល័យជាង ១៦០បានសិក្សា "សៀវភៅល្អអស្ចារ្យ" យ៉ាងហោចណាស់មួយវគ្គក្នុងមួយឆមាសដែរ។

ទោះជាយ៉ាងណា អាដល័រ គឺជាមនុស្សដែលមានភាពចម្រូងចម្រាសច្រើននៅជុំវិញរឿងសៀវភៅរបស់លោកពោលគឺជាមួយពួកអឺរ៉ុប និងជនជាតិស្បែកស។ ការនិពន្ធរបស់លោក អាដល័រ ក៏មានអ្នករិះគន់ និងមានអ្នកជំទាស់ជាច្រើននៅក្នុងអំឡុងពេលដែលគាត់រស់នៅ ប៉ុន្តែលោកនៅតែបញ្ចុះបញ្ចូលពួកគេទាំងនោះឱ្យមានជំនឿជាក់ និងផ្តល់ទំនុកចិត្តមកលើរូបគាត់វិញ ហើយជាពិសេសសព្វវចនាធិប្បាយប្រ៊ីតាន់នីកា (Britannica) ដែលបានបោះពុម្ពផ្សាយនៅក្នុង ឆ្នាំ១៩៥៤ មានចំនួន៥៤ភាគ។ ចំណែកក្រុមអ្នករិះគន់ក៏វាយប្រហារលោក អាដល័រ និងមិនផ្តោតទិសដៅលើរបៀបនៃការអានស្នាដៃរបស់លោកទាំងអស់នោះទេ។ បញ្ហាប្រឈមមួយទៀតដែលលោក អាដល័រ បានជួបប្រទះគឺរបៀបនៃការអានសៀវភៅដ៏ល្អអស្ចារ្យនេះនៅឆ្នាំ១៩៤០។

ការសន្និដ្ឋានដ៏សំខាន់របស់ អាដល័រ អំពីរបៀបដែលសិស្សគួរតែមានភាពស៊ាំជាមួយ "សៀវភៅក្លាស៊ិក" គឺជាគំនិតមួយដ៏ល្អ ប៉ុន្តែការរចនាឡើងវគ្គសិក្សាទាំងមូល ឬកម្មវិធីសិក្សាដែលមានរយៈពេលបួនឆ្នាំជាមួយសៀវភៅដ៏ល្អអស្ចារ្យគឺឃ្លាតឆ្ងាយបន្តិចម្តងៗបាត់ទៅហើយ។ ពិតមែនហើយ សិស្ស-និស្សិតគួរតែរៀនតាមបែបបុរាណ (ក្លាស៊ិក)

ក្នុងវគ្គសិក្សារបស់ខ្លួនជាប្រចាំទាំងនៅវិទ្យាល័យ និងមហាវិទ្យាល័យ។ ដូច្នេះ ពួកគេអាចទទួលបានទស្សនវិស័យក្នុងប្រវត្តិសាស្ត្រ ប៉ុន្តែសៀវភៅដ៏ល្បីល្បាញនេះមិនជួយឱ្យសិស្សទទួលបានការងារ ឬភាពជោគជ័យក្នុងជីវិតទាំងស្រុងនោះទេ។ តែការសិក្សាបែបបុរាណលើកទឹកចិត្តដល់សិស្សឱ្យមានការគិតកម្រិតខ្ពស់ជាងមុន ប៉ុន្តែវាក៏ខ្វះផងដែរនូវទស្សនៈជាក់ស្តែងនៃជីវិតផងដែរ។

## ៦.២ សេរីភាព និងឆន្ទៈសេរី

អត្ថន័យនៃពាក្យ "សេរីភាព" និង "ឆន្ទៈសេរី"កំពុងស្ថិតនៅក្រោមការជជែកវែកញែក ហើយការជជែកដេញដោលនេះក៏មានការភាន់ច្រឡំដែរ ពីព្រោះជាទូទៅមិនមាននិយមន័យដែលអាចទទួលយកបានទាំងស្រុងនោះទេ ជាពិសេសចំពោះបញ្ញត្តិ "សេរីភាព" ឬ "ឆន្ទៈសេរី"។ "វិទ្យាស្ថានស្រាវជ្រាវទស្សនវិជ្ជា"របស់លោក ម៉តទីម័រ អាដល័រ បានចំណាយពេល១០ឆ្នាំ ដើម្បីសិក្សាពី"គំនិតសេរីភាព" ហើយពាក្យនេះត្រូវបានអ្នកនិពន្ធរាប់រយនាក់ប្រើប្រាស់ធ្វើការពិភាក្សា និងបានជំទាស់អំពីបញ្ញត្តិ"សេរីភាព"នេះផងដែរ។

ការសិក្សានេះបោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៥៨(ភាគមួយ)ស្តីអំពីគំនិតនៃសេរីភាព ដែលមានចំណងជើងថា "ការពិនិត្យមើលកិច្ចសន្ទនាតាមបែបគ្រាមភាសាអំពីគំនិតនៃសេរីភាព" ដោយក្នុងនោះក៏មានការផ្តល់យោបល់ជាបន្តបន្ទាប់ដូចដែលមានសរសេរនៅក្នុងវចនានុក្រមទស្សនវិជ្ជា។ ការស្រាវជ្រាវរបស់ ម៉តទីម័រ អាដល័រ បានធ្វើការសន្និដ្ឋានថា ការកំណត់ប្រភេទទាំងបីនៃសេរីភាពគឺកើតមានតាមរយៈកាលៈទេសៈ, តាមធម្មជាតិ, ការទទួលបាន។ កត្តាទាំងបីនេះគឺមានភាពចាំបាច់ណាស់សម្រាប់ការបញ្ជាក់អំពីប្រធានបទនេះ។

១) សេរីភាពទៅតាមកាលៈទេសៈ៖ មានន័យថា សេរីភាពដែលទទួលបានពីការបង្ខិតបង្ខំ ឬការអត់ធ្មត់។

២) សេរីភាពតាមបែបធម្មជាតិ៖ មានន័យថា សេរីភាពនៃឆន្ទៈសេរី ឬជម្រើសដោយសេរី។ វាគឺជាសេរីភាពដែលកំណត់ពីការសម្រេចចិត្ត ឬផែនការផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ។ សេរីភាពនេះមានចំពោះគ្រប់មនុស្ស ជាប្រចាំ ដោយមិនគិតពីកាលៈទេសៈ ឬស្ថានភាពនៃចិត្តមនុស្សទេ។

៣) សេរីភាពដែលទទួលបាន៖ ជាសេរីភាពដូចនឹងឆន្ទៈដែលយើងគួរតែទទួលបាន ដូច្នេះ វាជាសេរីភាពដើម្បីរស់នៅដូចដែលមនុស្សម្នាក់ៗគួរតែទទួលបានសម្រាប់ការរស់នៅរបស់មនុស្សម្នាក់ៗនោះ។ សេរីភាពនេះមិនមានជាប់ជាមួយខ្លួនមនុស្សម្នាក់ៗទេ៖ ប៉ុន្តែ សេរីភាពនេះត្រូវតែទទួលបានតាមកាលៈទេសៈសម្រាប់មនុស្សម្នាក់ៗប្រកបដោយគុណសម្បត្តិ ដូចជា កុសល, ប្រាជ្ញា ឬគុណធម៌។

អាដល័រ ជឿជាក់ថាទស្សនវិជ្ជាគួរតែក្លាយជាផ្នែកមួយនៃកម្មវិធីសិក្សាសាលារៀនសាធារណៈ។ គាត់ជឿជាក់ថាការអប់រំគួរតែមានលក្ខណៈដូចគ្នានឹងមនុស្សគ្រប់រូប ពីព្រោះថាកុមារមានភាពដូចគ្នានឹងមនុស្សធំដែរ។ គាត់និយាយថាកុមារត្រូវទទួលបានចំណេះដឹងបីប្រភេទផ្សេងគ្នាគឺចំណេះដឹងតាមបែបការរៀបចំ(Organized Knowledge), បំណិនបញ្ញា(Intellectual Skills)និងការយល់ដឹងអំពីគំនិតនិងតម្លៃ។ ចំពោះចំណេះដឹងប្រភេទនីមួយៗនេះមានរបៀបបង្រៀនខុសគ្នាៗ។ ចំណេះដឹងបែបការរៀបចំត្រូវបង្រៀនតាមរយៈការឧទ្ទេស, បំណិនបញ្ញាត្រូវបង្រៀនតាមរយៈការបង្វឹក និងការត្រួតពិនិត្យការអនុវត្ត ហើយចំណេះដឹងលើការយល់ដឹងអំពីគំនិតនិងតម្លៃត្រូវបង្រៀនតាមរយៈវិធីសាស្ត្រពិភាក្សា និងការសួរសំណួរបែបសូក្រាត។

ចំពោះ អាដល័រ យល់ថាការអប់រំគួរតែមានគោលបំណងបីយ៉ាងគឺបង្រៀនប្រជាជនអំពីរបៀបប្រើប្រាស់ពេលទំនេររបស់ពួកគេឱ្យបានល្អ បង្រៀនឱ្យចេះរកស៊ីចិញ្ចឹមជីវិតប្រកបដោយសីលធម៌ គុណធម៌ និងបង្រៀនឱ្យក្លាយជាពលរដ្ឋដែលមានទំនួលខុសត្រូវនៅក្នុងប្រជាធិបតេយ្យ។ លោកជឿជាក់ថាមនុស្សម្នាក់ៗមានសមត្ថភាពពីធម្មជាតិក្នុងការធ្វើរឿងទាំងបីនេះ ហើយការអប់រំគួរតែជាកត្តាសំខាន់បំផុតដើម្បីរៀបចំឱ្យមនុស្សក្លាយជាអ្នកសិក្សាពេញមួយជីវិត។ តាមទស្សនៈរបស់គាត់ការអប់រំមិនដែលបញ្ចប់ឡើយ ពោលគឺដល់អាយុ៦០ឆ្នាំដែលមនុស្សគ្រប់គ្នាអាចអះអាងថាខ្លួនទទួលបានការអប់រំពិតប្រាកដ ហើយមានតែពេលនោះទេដែលពួកគេបានលះបង់ជីវិតដើម្បីរៀន៕

# បណ្ណានុក្រម

**ក. ឯកសារជាភាសាខ្មែរ**

ក្រសួងអប់រំ យុវជន និងកីឡា. (២០១០). សីលធម៌ពលរដ្ឋវិជ្ជា, ថ្នាក់ទី១០ ទី១១ ទី១២, ភ្នំពេញ
វិទ្យាស្ថានជាតិខេមរយានកម្ម. (១៩៧៤). ទស្សនវិជ្ជាថ្នាក់បញ្ចប់, ភ្នំពេញ
ឡុច ចាន់ថន, ឃិន វណ្ណី. (២០២១). ទស្សនវិជ្ជាអប់រំ, ភ្នំពេញ
ហួតគង់យូរ, ឃិន វណ្ណី. (២០២៣). ប្រវត្តិគំនិតនយោបាយ, សៀមរាប
រ៉ែម សំណាង, ឃិន វណ្ណី. (២០១៩). ការគិតត្រិះរិះពិចារណានិងការអភិវឌ្ឍសមត្ថភាពបុគ្គល, ភ្នំពេញ
វ៉ាន់ឌី កាអុន. (២០១៣). ទិដ្ឋភាពខ្លះៗនៃទស្សនវិជ្ជា, ភ្នំពេញ
កា ម៉ាធុល. (២០១១). ប្រវត្តិគំនិតនយោបាយ, ភ្នំពេញ

**ខ. ឯកសារបរទេស**

William Harrison Woodward. (1904). Desiderius Erasmus concerning the Aim and Method of Education, Cambridge.